# អដ្ឋកថាជាតក

## ឯកនិបាត

## ភាគ ២



បិដក លេខ ៥៨

ព.ស. ២៥៥៨



**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ២២៤ សជណ១៧

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ពិតថេរដីកា**
**ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត**

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ។

**យោង** : លិខិតលេខ*០១/១០ស.ធ.អ.យ.ស.* ចុះថ្ងៃទី*២៣* ខែ*តុលា* ឆ្នាំ*២០០៩* ស្ដីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្ដាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

**ចម្លងជូន :**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាខេត្តបាត់ដំបង
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# ពាក្យប្រារព្ធ

សៀវភៅអដ្ឋកថាជាតកនេះ និយាយអំពីប្រវត្តិរបស់ព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ព្យាយាមបំពេញព្រះបារមី កាលនៅជាព្រះបរមពោធិសត្វ ទ្រង់បានជួយសង្គ្រោះសត្វលោកឲ្យផុតអំពីសេចក្ដីទុក្ខទាំងឡាយ ទ្រង់ដឹកនាំឲ្យប្រព្រឹត្តល្អ មានការរក្សាសីលជាដើម សត្វទាំងឡាយក៏បានរួចផុតអំពីអបាយភូមិ និងបានទៅកើតក្នុងសុគតិភពផង ។

ខ្ញុំសង្ឃឹមថាសៀវភៅនេះ នឹងបានជាប្រយោជន៍ដល់ពុទ្ធបរិស័ទទាំងឡាយដែលប្រាថ្នាសិក្សាព្រះពុទ្ធវចនៈ សិក្សាប្រវត្តិព្រះបរមពោធិសត្វ ។

ប្រសិនបើជាមានសេចក្ដី ឬអក្សរណាខុសឆ្គង សូមមេត្តា ខន្តីអភ័យទោស និងសូមមេត្តាជួយកែតម្រូវដើម្បីឲ្យសៀវភៅនេះ បានល្អប្រសើរឡើង ។

សូមថ្លែងអំណរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅចំពោះលោកម្ចាស់ គង់ សុមិត្ត លោកម្ចាស់សួន ចាន់ផល្លី លោកម្ចាស់ កែន សុធន លោកគ្រូធម្មាចារ្យ អ៊ឹម រ៉ៃយ៉ា និង ឧបាសក ឡានសុខុម ព្រមទាំងពុទ្ធបរិស័ទដែលបានជួយពិនិត្យ កែសម្រួលនូវអក្ខរាវិរុទ្ធឲ្យបានត្រឹមត្រូវ និងបានជួយខ្នះខ្នែងក្នុងការផ្សារធម្មទាន ការចូលរួមវិភាគទាន ដើម្បីឲ្យបានសម្រេចជាព្រះធម្មចេតិយ តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។

# ឧទ្ទិសកថា

បុណ្យកុសលដែលខ្ញុំបានបំពេញមក មានការប្រែគម្ពីរអដ្ឋកថានេះជាដើម សូមឧទ្ទិសជូនចំពោះបុព្វការីជនទាំងឡាយ មានមាតា បិតា ជីដូន ជីតា និងញាតិកាក្នុងសង្សារវដ្តដែលបានចែកឋានទៅហើយ សូមបុព្វការីជនទាំងឡាយមានមាតាបិតាជាដើមនោះ បាននូវសេចក្តីសុខចម្រើនគ្រប់ប្រការ ។

សូមប្រគេនបុណ្យកុសលនេះ ដល់លោកម្ចាស់គ្រប់ៗ ព្រះអង្គ និងសូមចែកចំណែកបុណ្យនេះ ដល់ពុទ្ធបរិស័ទទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងសព្វសត្វទាំងអស់ ដែលមានចិត្តចេតនាអាចអនុមោទនាបាន សូមលោកម្ចាស់គ្រប់ៗ ព្រះអង្គ និងពុទ្ធបរិស័ទទាំងអស់ អនុមោទនាត្រេកអររីករាយទទួលយកនូវបុណ្យកុសល ដែលបានសម្រេចអំពីការកសាងព្រះធម្មចេតិយ និងការបំពេញបុណ្យផ្សេងៗទៀតទាំងអស់ អំពីខ្ញុំដោយរីករាយ ។

សូមអនុមោទនា !!!

សូមឲ្យសព្វសត្វទាំងអស់បានសុខចម្រើន បាននូវសម្មាទិដ្ឋិ ឃើញនូវសច្ចធម៌ និងបានរួចផុតចាកទុក្ខគ្រប់ៗ គ្នា ។

ថ្ងៃ ចន្ទ ១៥ កើត ខែភទ្របទ ព.ស. ២៥៥៨

ឧបាសក លឹម ធន់

# សន្លឹកប្រាប់មាតិកា

**មាតិកា** **ទំព័រ**

## អដ្ឋកថា អត្ថកាមវគ្គ ទី ៥


អដ្ឋកថា លោសកជាតក ទី ១ ........................................ ១

អដ្ឋកថា កបោតកជាតក ទី ២ ........................................ ១៨

អដ្ឋកថា វេឡុកជាតក ទី ៣ ........................................ ២៤

អដ្ឋកថា មកសជាតក ទី ៤ ........................................ ២៨

អដ្ឋកថា រោហិណីជាតក ទី ៥ ........................................ ៣២

អដ្ឋកថា អារាមទូសកជាតក ទី ៦ ........................................ ៣៦

អដ្ឋកថា វារុណិទូសកជាតក ទី ៧ ........................................ ៤១

អដ្ឋកថា វេទព្វជាតក ទី ៨ ........................................ ៤៤

អដ្ឋកថា នក្ខត្តជាតក ទី ៩ ........................................ ៥២

អដ្ឋកថា ទុម្មេធជាតក ទី ១០ ........................................ ៥៧


## អដ្ឋកថា អាសីសវគ្គ ទី ៦


អដ្ឋកថា មហាសីលវជាតក ទី ១ ........................................ ៦៤

អដ្ឋកថា ចូឡជនកជាតក ទី ២ ........................................ ៧៨

អដ្ឋកថា បុណ្ណបាតិជាតក ទី ៣ ........................................ ៧៩

អដ្ឋកថា ផលជាតក ទី ៤ ........................................ ៨៣

អដ្ឋកថា បញ្ញាវុធជាតក ទី ៥ ........................................ ៨៨
អដ្ឋកថា កញ្ចនក្ខន្ធជាតក ទី ៦ ........................................ ៩៦
អដ្ឋកថា វានរិន្ទជាតក ទី ៧ ........................................ ១០១
អដ្ឋកថា តយោធម្មជាតក ទី ៨ ........................................ ១០៧
អដ្ឋកថា ភេរិវាទជាតក ទី ៩ ........................................ ១១២
អដ្ឋកថា សង្ខធមនជាតក ទី ១០ ........................................ ១១៥

## អដ្ឋកថា ឥត្ថីវគ្គ ទី ៧

អដ្ឋកថា អសាតមន្តជាតក ទី ១ ........................................ ១១៧
អដ្ឋកថា អណ្ឌភូតជាតក ទី ២ ........................................ ១២៧
អដ្ឋកថា តក្កជាតក ទី ៣ ........................................ ១៤១
អដ្ឋកថា ទុរាជានជាតក ទី ៤ ........................................ ១៤៨
អដ្ឋកថា អនភិរតិជាតក ទី ៥ ........................................ ១៥៣
អដ្ឋកថា មុទុលក្ខណជាតក ទី ៦ ........................................ ១៥៧
អដ្ឋកថា ឧច្ចង្គជាតក ទី ៧ ........................................ ១៦៧
អដ្ឋកថា សាកេតជាតក ទី ៨ ........................................ ១៧២
អដ្ឋកថា វិសវន្តជាតក ទី ៩ ........................................ ១៧៦
អដ្ឋកថា កុទ្ទាលជាតក ទី១០ ........................................ ១៨០

# អដ្ឋកថា វរុណវគ្គ ទី ៨

អដ្ឋកថា វរុណជាតក ទី ១ ........................................ ១៩០
អដ្ឋកថា សីលវនាគជាតក ទី ២ ........................................ ១៩៧
អដ្ឋកថា សច្ចង្កិរជាតក ទី ៣ ........................................ ២០៥
អដ្ឋកថា រុក្ខធម្មជាតក ទី ៤ ........................................ ២១៥
អដ្ឋកថា មច្ឆជាតក ទី ៥ ........................................ ២២០
អដ្ឋកថា អសង្កិយជាតក ទី ៦ ........................................ ២២៧
អដ្ឋកថា មហាសុបិនជាតក ទី ៧ ........................................ ២៣២
អដ្ឋកថា ឥល្លិសជាតក ទី ៨ ........................................ ២៦៣
អដ្ឋកថា ខរស្សរជាតក ទី ៩ ........................................ ២៨៤
អដ្ឋកថា ភីមសេនជាតក ទី ១០ ........................................ ២៨៨

# អដ្ឋកថា អបាយិម្ហវគ្គ ទី ៩

អដ្ឋកថា សុរាបានជាតក ទី ១ ........................................ ២៩៨
អដ្ឋកថា មិត្តវិន្ទជាតក ទី ២ ........................................ ៣០៦
អដ្ឋកថា កាឡកណ្ណិជាតក ទី ៣ ........................................ ៣០៨
អដ្ឋកថា អត្ថស្ស ទ្វារជាតក ទី ៤ ........................................ ៣១៣
អដ្ឋកថា កិម្បក្កជាតក ទី ៥ ........................................ ៣១៨
អដ្ឋកថា សីលវីមំសនជាតក ទី ៦ ........................................ ៣២២

អដ្ឋកថា មង្គលជាតក ទី ៧ ..................................... ៣២៩
អដ្ឋកថា សារម្ភជាតក ទី ៨ ..................................... ៣៣៧
អដ្ឋកថា កុហកជាតក ទី ៩ ..................................... ៣៣៩
អដ្ឋកថា អកតញ្ញូជាតក ទី ១០ ..................................... ៣៤៣

## អដ្ឋកថា លិត្តវគ្គ ទី ១០

អដ្ឋកថា លិត្តជាតក ទី ១ ..................................... ៣៤៩
អដ្ឋកថា មហាសារជាតក ទី ២ ..................................... ៣៥៣
អដ្ឋកថា វិស្សាសភោជនជាតក ទី ៣ ..................................... ៣៧០
អដ្ឋកថា លោមហំសជាតក ទី ៤ ..................................... ៣៧៤
អដ្ឋកថា មហាសុទស្សនជាតក ទី ៥ ..................................... ៣៧៩
អដ្ឋកថា តេលបត្តជាតក ទី ៦ ..................................... ៣៨៤
អដ្ឋកថា នាមសិទ្ធិជាតក ទី ៧ ..................................... ៤០៤
អដ្ឋកថា កូដវាណិជជាតក ទី ៨ ..................................... ៤០៩
អដ្ឋកថា បរោសហស្សជាតក ទី ៩ ..................................... ៤១៤
អដ្ឋកថា អសាតរូបជាតក ទី ១០ ..................................... ៤១៨

## អដ្ឋកថា បរោសតវគ្គ ទី ១១

អដ្ឋកថា បរោសតជាតក ទី១ ..................................... ៤២៦
អដ្ឋកថា បណ្ណិកជាតក ទី២ ..................................... ៤២៧

អដ្ឋកថា វេរិជាតក ទី៣ .................................... ៤៣១
អដ្ឋកថា មិត្តវិន្ទជាតក ទី៤ .................................... ៤៣៣
អដ្ឋកថា ទុព្វលកដ្ឋជាតក ទី៥ .................................... ៤៣៥
អដ្ឋកថា ឧទញ្ចនីជាតក ទី៦ .................................... ៤៣៨
អដ្ឋកថា សាលិត្តកជាតក ទី៧ .................................... ៤៤២
អដ្ឋកថា ពាហិយជាតក ទី៨ .................................... ៤៤៨
អដ្ឋកថា កុណ្ឌកបូវជាតក ទី៩ .................................... ៤៥១
អដ្ឋកថា សព្វសំហារកបញ្ហា ទី១០ .................................... ៤៥៧

## អដ្ឋកថា ហំសិវគ្គ ទី ១២

អដ្ឋកថា គទ្រភបញ្ហា ទី ១ .................................... ៤៥៨
អដ្ឋកថា អមរាទេវិបញ្ហា ទី ២ .................................... ៤៥៨
អដ្ឋកថា សិគាលជាតក ទី ៣ .................................... ៤៥៩
អដ្ឋកថា មិត្តចិន្តិជាតក ទី ៤ .................................... ៤៦៣
អដ្ឋកថា អនុសាសិកជាតក ទី ៥ .................................... ៤៦៧
អដ្ឋកថា ទុព្វចជាតក ទី ៦ .................................... ៤៧១
អដ្ឋកថា តិត្តិរជាតក ទី ៧ .................................... ៤៧៤
អដ្ឋកថា វដ្តកជាតក ទី ៨ .................................... ៤៧៧
អដ្ឋកថា អកាលរាវិជាតក ទី ៩ .................................... ៤៨៣

អដ្ឋកថា ពន្ធនមោក្ខជាតក ទី ១០ .................................... ៤៨៧

## អដ្ឋកថា កុសនាឡិវគ្គ ទី ១៣

អដ្ឋកថា កុសនាឡិជាតក ទី ១ ...................................... ៤៩៧
អដ្ឋកថា ទុម្មេធជាតក ទី ២ ...................................... ៥០៤
អដ្ឋកថា នង្គលីសជាតក ទី ៣ ...................................... ៥១០
អដ្ឋកថា អម្ពជាតក ទី ៤ ...................................... ៥១៦
អដ្ឋកថា កដាហកជាតក ទី ៥ ...................................... ៥២០
អដ្ឋកថា អសិលក្ខណជាតក ទី ៦ ...................................... ៥២៨
អដ្ឋកថា កលណ្ឌុកជាតក ទី ៧ ...................................... ៥៣៥
អដ្ឋកថា មូសិកជាតក ទី ៨ ...................................... ៥៣៨
អដ្ឋកថា អគ្គិកជាតក ទី ៩ ...................................... ៥៤២
អដ្ឋកថា កោសិយជាតក ទី ១០ ...................................... ៥៤៥

## អដ្ឋកថា អសម្បទានវគ្គ ទី ១៤

អដ្ឋកថា អសម្បទានជាតក ទី ១ ...................................... ៥៥១
អដ្ឋកថា បញ្ចភិរុកជាតក ទី ២ ...................................... ៥៥៩
អដ្ឋកថា ឃតាសនជាតក ទី ៣ ...................................... ៥៦៤
អដ្ឋកថា ឈានសោធនជាតក ទី ៤ ...................................... ៥៦៨
អដ្ឋកថា ចន្ទាភជាតក ទី ៥ ...................................... ៥៧០

អដ្ឋកថា សុវណ្ណហំសជាតក ទី ៦ ..................................... ៥៧៣
អដ្ឋកថា ពព្ពុជាតក ទី ៧ .................................... ៥៧៨
អដ្ឋកថា គោធជាតក ទី ៨ ...................................... ៥៨៥
អដ្ឋកថា ឧភតោភដ្ឋជាតក ទី ៩ .................................... ៥៨៩
អដ្ឋកថា កាកជាតក ទី ១០ ................................. ៥៩៣

# អដ្ឋកថា ភកណ្ណកវគ្គ ទី ១៥

អដ្ឋកថា គោធជាតក ទី ១ .................................... ៦០០
អដ្ឋកថា សិង្គាលជាតក ទី ២ .................................... ៦០៤
អដ្ឋកថា វិរោចនជាតក ទី ៣ .................................. ៦០៨
អដ្ឋកថា នង្គុដ្ឋជាតក ទី ៤ .................................... ៦១៤
អដ្ឋកថា រាធជាតក ទី ៥ .................................... ៦១៨
អដ្ឋកថា កាកជាតក ទី ៦ ..................................... ៦២២
អដ្ឋកថា បុប្ផរត្តជាតក ទី ៧ .................................... ៦២៧
អដ្ឋកថា សិង្គាលជាតក ទី ៨ .................................... ៦៣២
អដ្ឋកថា ឯកបណ្ណជាតក ទី ៩ .................................... ៦៣៩
អដ្ឋកថា សញ្ជីវជាតក ទី ១០ ................................... ៦៤៩

# ខុទ្ទកនិកាយ
# អដ្ឋកថាជាតក

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ឯកនិបាត
## អត្ថកាមវគ្គ ទី ៥
### អដ្ឋកថា លោសកជាតក ទី ១

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះលោសកតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **យោ អត្ថកាមស្ស** *ដូច្នេះជាដើម ។*

*ព្រះថេរៈដែលមានឈ្មោះថា លោសកៈ នេះ តើជានរណា ( មានប្រវត្តិយ៉ាងណា ) ?*

*លោកជាកូនអ្នកនេសាទម្នាក់ ដែលរស់នៅក្នុងដែនកោសល ជាអ្នកទម្លាយវង្សត្រកូលរបស់ខ្លួន មានលាភតិច មកបួសក្នុងសម្នាក់ពួកភិក្ខុ ។*

*បានឮថា លោកចុតិអំពីទីដែលលោកកើតហើយ បដិសន្ធិក្នុងផ្ទៃ*

នៃស្ត្រីដែលជាភរិយាអ្នកនេសាទម្នាក់ នៅក្នុងស្រុកអ្នកនេសាទមួយកន្លែងដែលនៅរួមគ្នាដល់ទៅ ១ ពាន់គ្រួសារ ក្នុងដែនកោសល ។ ក្នុងថ្ងៃដែលលោកបដិសន្ធិ អ្នកនេសាទទាំង ១ ពាន់គ្រួសារនោះ នាំគ្នាកាន់សំណាញ់ទៅរកត្រីក្នុងស្ទឹងនិងបឹង មិនបានសូម្បីត្រឹមតែត្រីតូចៗ ហើយចាប់តាំងពីថ្ងៃនោះមក ពួកអ្នកនេសាទទាំងនោះ ក៏ដល់នូវការចិញ្ចឹមជីវិតដោយលំបាក ។ កាលនៅក្នុងផ្ទៃមាតានោះ ផ្ទះអ្នកនេសាទទាំងនោះក៏ត្រូវភ្លើងឆេះអស់ ៧ ដង ត្រូវព្រះរាជាពិន័យអស់ ៧ ដង ដោយហេតុនេះ អ្នកនេសាទទាំងនោះ ក៏ដល់នូវការលំបាកដោយលំដាប់ ។ ពួកជនទាំងនោះពិភាក្សាគ្នាថា កាលពីមុនរឿងបែបនេះ មិនធ្លាប់កើតមានដល់ពួកយើងឡើយ ប៉ុន្តែឥឡូវនេះ ពួកយើងត្រូវចុះអន់ថយក្រលំបាក ក្នុងចំណោមពួកយើងប្រាកដជាមានមនុស្សកាឡកណ្ណីណាម្នាក់មិនខាន ពួកយើងចូរបែងចែកគ្នាជាពីរក្រុមចុះ ដូច្នេះហើយ ក៏បែងចែកគ្នាជាពីរក្រុម ក្នុងមួយក្រុម ៥០០ គ្រួសារ ។ បណ្តាក្រុមទាំងពីរនោះ មាតាបិតារបស់លោសកៈនៅក្នុងក្រុមណា ក្រុមនោះក៏ចុះអន់ថយក្រលំបាកទៅៗ ក្រុមក្រៅអំពីនេះចម្រើនលូតលាស់ឡើងៗ ក្រុមដែលចុះអន់ថយនោះ ក៏បែកគ្នាជាពីរក្រុមទៀត ។ ពួកគេបែកគ្នាជាពីរក្រុមដោយទំនងនេះ រហូតដល់សល់ត្រឹមតែត្រកូលមួយ ទើបអ្នកនេសាទទាំងនោះដឹងថា មនុស្សទាំងនេះ ជាកាឡកណ្ណី ក៏ព្រួតដៃគ្នាវាយបណ្តេញចេញអំពីភូមិ ។ គ្រា

នោះ មាតាបិតារបស់លោសកៈចិញ្ចឹមជីវិតដោយលំបាក លុះគ្រប់ខែក៏ប្រសូតទារកនៅក្នុងកន្ទែងមួយ ។ ធម្មតាអ្នកដែលកើតមកក្នុងភពចុងក្រោយ បុគ្គលណាមួយក៏មិនអាចទម្លាយបាន ព្រោះមានឧបនិស្ស័យនៃអរហត្តផលដ៏រុងរឿងនៅក្នុងហឫទ័យរបស់លោក ដូចប្រទីបក្នុងឆ្នាំងដូច្នោះ ។ មាតាបិតាចិញ្ចឹមទារកនោះមករហូតដល់ពេលដែលទារកនោះរត់ទៅមកបាន ក៏យកអម្បែងឆ្នាំងដីដាក់លើដៃហើយបញ្ជូនទៅដោយពាក្យថា នែកូន កូនឯងចូរទៅកាន់ផ្ទះនោះចុះ ដូច្នេះហើយក៏គេចចេញទៅ ។ ចាប់ពីពេលនោះមក ទារកនោះក៏រស់នៅតែម្នាក់ឯងតាមយថាកម្មដេកនៅក្នុងកន្ទែងមួយ មិនបានងូតទឹក មិនបានជម្រះរាងកាយ មើលទៅដូចបិសាចប្រឡាក់ធូលី ចិញ្ចឹមជីវិតដោយលំបាក ។ ទារកនោះមានអាយុ ៧ ឆ្នាំដោយលំដាប់ ដើររើសគ្រាប់បាយស៊ីម្តងមួយគ្រាប់ៗ ក្នុងទីដែលគេចាក់ទឹកលាងឆ្នាំងជិតផ្ទះមួយ ដូចជាសត្វក្អែក ។

គ្រានោះ ព្រះធម្មសេនាបតីសារីបុត្រនិមន្តបិណ្ឌបាតក្នុងក្រុងសាវត្ថី ឃើញហើយពិចារណាថា ទារកនេះគួរឲ្យអាណិតហ្ន៎ ជាអ្នកស្រុកណាហ្ន៎ ដោយមានមេត្តាចិត្តចំពោះទារកនោះក្រៃលែងឡើងៗ ទើបហៅទារកនោះថា នែកុមារតូច ចូរអ្នកមកនេះ ។ ទារកនោះមកថ្វាយបង្គំហើយឈរក្នុងទីដ៏សមគួរមួយ ។ គ្រានោះ ព្រះថេរៈសួរទារកនោះថា

នែកុមារតូច ឯងជាអ្នកស្រុកណា? ម៉ែឪរបស់ឯងនៅឯណា?

ទារកនោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំឥតទីពឹង មាតាបិតារបស់ខ្ញុំនិយាយថា ខ្ញុំធ្វើឲ្យគាត់លំបាក ទើបគាត់ចោលខ្ញុំហើយគេចទៅ ។

ព្រះថេរៈសួរថា បើដូច្នោះ អ្នកបួសឬ?

ទារកនោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំចង់បួសណាស់ ប៉ុន្តែក្មេងកំព្រាដូចជាខ្ញុំនេះ តើអ្នកណានឹងបំបួស?

ព្រះថេរៈពោលថា អាត្មានឹងបំបួស ។

ទារកពោលថា សាធុលោកម្ចាស់ សូមលោកម្ចាស់អនុគ្រោះឲ្យខ្ញុំបួសផងចុះ ។

ព្រះថេរៈក៏ឲ្យអាហារបរិភោគដល់ទារកនោះ ហើយនាំទៅកាន់វិហារផ្ងូតទឹកឲ្យដោយខ្លួនឯង ហើយឲ្យបព្វជ្ជា រហូតអាយុគ្រប់ ២០ ឆ្នាំក៏ឲ្យឧបសម្បទា ក្នុងពេលឧបសម្បទាហើយ លោកមានឈ្មោះថា លោសកតិស្សត្ថេរ ជាភិក្ខុមិនមានបុណ្យ មានលាភតិច ។ បានឮថា លោកមិនធ្លាប់បានឆាន់ពេញពោះ សូម្បីតែក្នុងកាលអសទិសទាន បានឆាន់ត្រឹមតែល្មមបន្តជីវិតឲ្យប្រព្រឹត្តទៅបានតែប៉ុណ្ណោះ ព្រោះកាលពុទ្ធបរិស័ទដាក់បាត្រលោកត្រឹមតែបាយមួយវែកប៉ុណ្ណោះ បាត្រក៏ប្រាកដដូចជាពេញដោយបាយ កាលបើដូច្នោះ ពុទ្ធបរិស័ទទាំងឡាយក៏សម្គាល់ថា បាត្ររបស់ភិក្ខុនេះពេញ ហើយក៏ហួសទៅដាក់បាត្រភិក្ខុអង្គក្រោយៗ ។ អាចារ្យពួកខ្លះពោលថា ក្នុងពេលប្រគេនយាគូចំពោះលោក យាគូក្នុង

ភាជនៈរបស់គេក៏បាត់អស់ទៅ ដូច្នេះក៏មាន ។ សូម្បីបច្ច័យដទៃ មានរបស់គួរទំពាស៊ីជាដើមក៏ន័យនេះដែរ ។ សម័យក្រោយមកលោកចម្រើនវិបស្សនា សូម្បីបានសម្រេចព្រះអរហត្តផលដែលជាផលដ៏កំពូល ក៏នៅតែមានលាភតិចដដែល ។ កាលអាយុសង្ខាររបស់លោកទ្រុឌទ្រោមដោយលំដាប់ក៏ដល់ថ្ងៃបរិនិព្វាន ។

ព្រះធម្មសេនាបតីត្រិះរិះ ក៏ដឹងដល់ថ្ងៃបរិនិព្វានរបស់លោក ទើបត្រិះរិះថា ថ្ងៃនេះ លោសកតិស្សត្ថេរនឹងបរិនិព្វាន អាត្មាអញគួរឲ្យអាហារដល់លោកឆាន់ឲ្យឆ្អែតម្តង ដូច្នេះហើយ ក៏នាំលោកចូលទៅកាន់នគរសាវត្ថីដើម្បីបិណ្ឌបាត ព្រោះតែនាំព្រះលោសកៈទៅជាមួយ ព្រះថេរៈក៏មិនបានសូម្បីត្រឹមតែការលើកដៃសំពះ ក្នុងនគរសាវត្ថីដែលមានមនុស្សច្រើនសន្ធឹកសន្ធាប់ ទើបព្រះថេរៈពោលថា អាវុសោ លោកចូរទៅគង់រង់ចាំនៅឯរោងឆាន់ចុះ ដូច្នេះហើយក៏បញ្ជូនលោកឲ្យត្រឡប់ទៅវិញ ។ គ្រាន់តែលោកចេញអំពីទីនោះប៉ុណ្ណោះ ពុទ្ធបរិស័ទក៏បង្អកប្រកាសប្រាប់គ្នាថា នែគ្នាយើង លោកម្ចាស់និមន្តមកហើយ និមន្តព្រះថេរៈគង់លើអាសនៈ ឲ្យឆាន់កត្តាហារ ។ ព្រះថេរៈក៏បញ្ជូនអាហារដែលបានហើយនោះទៅ ដោយពោលនឹងមនុស្សទាំងនោះថា ពួកអ្នកចូរប្រគេនភត្តនេះចំពោះលោសកតិស្សត្ថេរ ។ មនុស្សដែលទទួលយកភត្តនោះទៅក៏ភ្លេចព្រះលោសកតិស្សត្ថេរ នាំគ្នាបរិភោគអស់ ។ លុះព្រះថេរៈនិមន្តទៅដល់

ព្រះវិហារ ព្រះលោសកតិស្សត្ថេរក៏ទៅថ្វាយបង្គំព្រះថេរៈ ។ ព្រះថេរៈសួរថា អាវុសោ លោកបានអាហារហើយឬ ? លោកឆ្លើយថា មិនទាន់បានទេ លោកម្ចាស់ ។ ព្រះថេរៈក៏សង្កេត មើលពេលវេលាដឹងថា មិនទាន់កន្លង ទើបពោលថា ណ្ហើយចុះ អ្នកមានអាយុ លោកចូលទៅគង់កន្លែងដើមវិញចុះ ។ លុះឲ្យព្រះលោសកតិស្សត្ថេរទៅគង់រង់ចាំនៅក្នុងរោងឆាន់ហើយ លោកក៏ទៅកាន់ព្រះរាជវាំងរបស់ព្រះបាទកោសល ។ ព្រះរាជាត្រាស់ឲ្យទទួលបាត្ររបស់ព្រះថេរៈ ទ្រង់ដឹងថាមិនមែនជាកាលនៃភត្ត ទើបត្រាស់ឲ្យប្រគេនបង្អែមបួនមុខពេញបាត្រ ។ ព្រះថេរៈទទួលបាត្រត្រឡប់ទៅដល់រោងឆាន់ ក៏ហៅព្រះលោសកតិស្សត្ថេរថា អាវុសោតិស្ស ចូរលោកឆាន់បង្អែមបួនមុខនេះចុះ ហើយឈរកាន់បាត្រ ។ ព្រះលោសកតិស្សត្ថេរខ្មាចក្រែងព្រះថេរៈ ក៏មិនហ៊ានឆាន់ ។ គ្រានោះ ព្រះថេរៈពោលថា អាវុសោតិស្ស ខ្ញុំឈរកាន់បាត្រឲ្យ ចូរលោកឆាន់ចុះ ប្រសិនបើខ្ញុំលែងបាត្រពីដៃ បាត្រប្រាកដជាទទេ ។ គ្រានោះ ព្រះលោសកតិស្សត្ថេរ កាលព្រះធម្មសេនាបតីដែលជាអគ្គសាវកឈរកាន់បាត្រឲ្យ ក៏គង់ឆាន់បង្អែមបួនមុខនោះ បង្អែមបួនមុខនោះ មិនដល់នូវការអស់ទៅដោយកម្លាំងឫទ្ធិរបស់ព្រះថេរៈ ព្រះលោសកតិស្សត្ថេរឆាន់រហូតទាល់តែឆ្អែតលែងត្រូវការ ក្នុងពេលនោះ ក្នុងថ្ងៃនោះឯង លោកក៏បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ព្រះសម្មាសម្ពុទ្ធទ្រង់គង់ក្នុងសម្មាក់របស់

លោក ទ្រង់ត្រាស់ឲ្យបូជាព្រះសរីរៈ រើសយកធាតុទាំងឡាយហើយ កសាងចេតិយតម្កល់ទុក ។

គ្រានោះ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងធម្មសភា សន្ទនាគ្នាថា អ្នកមានអាយុទាំងឡាយ គួរអស្ចារ្យហ្ន៎ ព្រះលោសកតិស្សត្ថេរមានបុណ្យតិច មានលាភតិច ហើយអ្នកដែលមានបុណ្យតិច មានលាភតិចបែបនេះ សម្រេចអរិយធម៌បានដូចម្តេចហ្ន៎ ។ ព្រះបរមសាស្តា ស្តេចយាងមកកាន់ធម្មសភា ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោសកតិស្សនេះបានធ្វើកម្ម គឺភាពជាអ្នកមានលាភតិចនិងភាពជាអ្នកបានអរិយធម៌របស់ខ្លួន ដោយខ្លួនឯង ព្រោះកាលពីមុនលោសកតិស្សនេះបានធ្វើឲ្យអន្តរាយលាភរបស់អ្នកដទៃ ទើបជាអ្នកមានលាភតិច ប៉ុន្តែបានសម្រេចអរិយធម៌ដោយអំណាចវិបស្សនា គឺ អនិច្ចំ ទុក្ខំ អនត្តា ដែលបានបំពេញហើយ ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា **កស្សប** ភិក្ខុមួយរូបអាស្រ័យកុដុម្ពិកៈម្នាក់ នៅក្នុងអាវាសមួយ ជាអ្នកមានឥរិយាបថរមទម មានសីល ព្យាយាមបំពេញវិបស្សនា ។ គ្រានោះ មានព្រះ-

ខីណាស្រពមួយព្រះអង្គដែលមានប្រក្រតីនៅក្នុងព្រៃហេមពាន្ត បានមក ដល់លំនៅរបស់កុដុម្ពិកៈដែលជាឧបដ្ឋាករបស់ភិក្ខុនោះ ដោយលំដាប់។ កុដុម្ពិកៈជ្រះថ្លានឹងឥរិយាបថរបស់ព្រះថេរៈ ទើបទទួលបាត្រនិមន្តលោក ចូលទៅកាន់ផ្ទះ ឲ្យឆាន់ភត្តាហារដោយគោរព ស្តាប់ធម្មកថាបន្តិចបន្តួច ថ្វាយបង្គំហើយពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ និមន្តទៅកាន់វិហារដែលនៅជិតផ្ទះខ្ញុំព្រះករុណាមុនចុះ ចាំពេលល្ងាចខ្ញុំ ព្រះករុណានឹងទៅសួរសុខទុក្ខ ។ ព្រះថេរៈក៏និមន្តទៅកាន់វិហារ ថ្វាយ-បង្គំព្រះថេរៈជាអាវាសិក សួរសុខទុក្ខគ្នានិងគ្នាហើយគង់ក្នុងទីដ៏សមគួរ ។ ព្រះថេរៈជាអាវាសិកក៏ធ្វើបដិសណ្ឋារៈចំពោះលោកហើយសួរថា អ្នកមាន អាយុ បានទទួលភត្តាហារហើយឬ ?

ព្រះថេរៈអាគន្តុកៈឆ្លើយថា បានទទួលហើយ ។

ព្រះថេរៈជាអាវាសិកសួរថា អ្នកមានអាយុ បានទទួលភត្តក្នុងទី ណា ?

ព្រះថេរៈអាគន្តុកៈឆ្លើយថា បានទទួលក្នុងផ្ទះកុដុម្ពិកៈជិតនេះ ឯង ។ លុះប្រាប់យ៉ាងនេះហើយ ក៏សួរដល់សេនាសនៈរបស់ខ្លួន ចាត់-ចែងបោសច្រាសទុកដាក់បាត្រចីវររៀបរយហើយ គង់សម្រាកដោយសុខ ក្នុងឈាន ដោយសុខក្នុងសមាបត្តិ ។ វេលាល្ងាច កុដុម្ពិកៈក៏ឲ្យមនុស្ស កាន់កម្រងផ្កានិងប្រទីបទៅវិហារ ថ្វាយបង្គំព្រះថេរៈជាអាវាសិកហើយ

សួរថា លោកម្ចាស់ដ៏ចម្រើន មានព្រះថេរៈអាគន្តុកៈមកស្នាក់នៅមួយរូប មែនទេ ?

ព្រះថេរៈជាអាវាសិកឆ្លើយថា ចម្រើនពរកុដុម្ពិកៈ ។

កុដុម្ពិកៈសួរថា ឥឡូវនេះលោកសម្រាកនៅឯណា ?

ព្រះថេរៈជាអាវាសិកឆ្លើយថា នៅសេនាសនៈឯណោះ ។

កុដុម្ពិកៈទៅកាន់សម្នាក់ព្រះថេរៈនោះហើយ អង្គុយក្នុងទីដ៏សមគួរ ស្តាប់ធម្មកថារហូតដល់យប់ ទើបបូជាព្រះចេតិយនិងពោធិព្រឹក្ស អុជប្រទីបបំភ្លឺហើយនិមន្តព្រះថេរៈទាំងពីរអង្គឲ្យទទួលភត្តក្នុងថ្ងៃស្អែក ហើយត្រឡប់ទៅផ្ទះវិញ ។ ព្រះថេរៈជាអាវាសិកគិតថា កុដុម្ពិកៈនេះ ត្រូវអាគន្តុកភិក្ខុញុះញង់ឲ្យបែកចិត្តចេញពីអញហើយ បើលោកនៅក្នុងវិហារនេះសោត កុដុម្ពិកៈប្រាកដជាឈប់រាប់អានអញ កើតការមិនពេញចិត្តចំពោះព្រះថេរៈ គិតថា អញគួរតែសម្តែងអាការមិនឲ្យលោកនៅក្នុងវិហារនេះ ដូច្នេះហើយ ពេលដែលព្រះថេរៈមកធ្វើវត្តបដិបត្តិក៏មិននិយាយជាមួយ ។ ព្រះថេរៈដែលជាព្រះខីណាស្រពជ្រាបអធ្យាស្រ័យព្រះថេរៈជាអាវាសិកហើយ ត្រិះរិះថា ព្រះថេរៈនេះ មិនបានដឹងភាពដែលអាត្មាអញមិនមានការជាប់ជំពាក់ក្នុងត្រកូល ក្នុងលាភ ឬក្នុងពួកគណៈឡើយ ហើយក៏ត្រឡប់ទៅកាន់លំនៅរបស់ខ្លួន គង់សម្រាកដោយសុខក្នុងឈាននិងសុខក្នុងសមាបត្តិ ។ ស្អែកឡើង ព្រះថេរៈជាអាវាសិកក៏វាយជួង

ដោយខ្នងក្រចក គោះទ្វារដោយខ្នងក្រចកហើយទៅកាន់ផ្ទះកុដុម្ពិកៈ ។ កុដុម្ពិកៈទទួលបាត្រ និមន្តឲ្យគង់លើអាសនៈដែលក្រាលទុក ហើយសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះថេរៈអាគន្តុកៈនិមន្តទៅណា?

ព្រះថេរៈជាអាវាសិកឆ្លើយថា អាត្មាមិនដឹងការប្រព្រឹត្តិទៅរបស់ព្រះថេរៈដែលជិតស្និទ្ធនឹងអ្នកទេ អាត្មាវាយជួង គោះទ្វារ ក៏មិនអាចដាស់ឲ្យភ្ញាក់បាន កាលពីម្សិលឆាន់ភោជនដ៏ប្រណីតក្នុងផ្ទះរបស់អ្នកហើយប្រហែលជានៅឆ្អែតដល់ថ្ងៃនេះ ទើបដេកលក់រហូតដល់ពេលនេះ អ្នកកាលជ្រះថ្លា ក៏ជ្រះថ្លានឹងភិក្ខុអ្នកមានសភាពបែបនេះឯង ។ ចំណែកព្រះថេរៈជាព្រះខីណាស្រពកំណត់ពេលភិក្ខាចាររបស់ខ្លួនហើយ ក៏ជម្រះសរីរៈ កាន់បាត្រនិងចីវរហោះតាមអាកាសទៅកាន់ទីដទៃ ។

កុដុម្ពិកៈនិមន្តព្រះថេរៈជាអាវាសិកឆាន់មធុបាយាសដែលផ្សំដោយទឹកដោះថ្លា ទឹកឃ្មុំ ដុំស្ករហើយ លាងបាត្រជូតជម្រះអប់ដោយគ្រឿងក្រអូប ដាក់មធុបាយាសពេញហើយពោលថា បពិត្រលោកម្ចាស់ ព្រះថេរៈនោះប្រហែលជាហត់នឿយខ្លាំងហើយមើលទៅ សូមលោកម្ចាស់មេត្តានាំយកមធុបាយាសនេះទៅប្រគេនលោកផងចុះ ហើយប្រគេនបាត្រទៅព្រះថេរៈជាអាវាសិក ។ ព្រះថេរៈជាអាវាសិកមិនប្រកែកទេ ទទួលយកបាត្រមក និមន្តទៅបណ្ដើរគិតបណ្ដើរថា ប្រសិនបើភិក្ខុនោះបានឆាន់មធុបាយាសនេះសោត សូម្បីអញចាប់កទាញចេញទៅ ក៏មិនទៅ

ប្រសិនបើអញឲ្យមធុបាយាសនេះដល់មនុស្សសោត កម្មរបស់អញក៏នឹងប្រាកដ ប្រសិនបើអញចាក់ទៅក្នុងទឹក ទឹកដោះថ្លាក៏នឹងអណ្តែតលើទឹក បើចាក់ចោលលើផែនដី ហ្វូងក្អែកនឹងចោមរោមស៊ី កម្មរបស់អញក៏នឹងប្រាកដ អញគួរចាក់មធុបាបាយាសនេះនៅទីណាល្អហ្ន៎ ឃើញស្រែកំពុងឆេះមួយកន្លែង ក៏កាយផេះឡើងចាក់មធុបាយាសទៅក្នុងស្រែនោះកាយផេះលុបហើយក៏ទៅកាន់វិហារ ។ លុះទៅដល់វិហារមិនឃើញព្រះថេរៈអង្គនោះក៏គិតឃើញថា ប្រហែលភិក្ខុនោះជាព្រះខីណាស្រពដឹងអធ្យាស្រ័យរបស់អាត្មាអញ ហើយទៅកាន់ទីដទៃជាប្រាកដ ឱ ព្រោះតែផ្ទៃជាហេតុ អញបានធ្វើកម្មដ៏មិនសមគួរ ។ ក្នុងនោះឯង សេចក្តីក្តៅក្រហាយចិត្តយ៉ាងខ្លាំង បានកើតឡើងដល់ព្រះថេរៈជាអាវាសិកនោះ ។ ចាប់អំពីថ្ងៃនោះមក លោកក៏ក្លាយទៅជាមនុស្សប្រេត មិនយូរប៉ុន្មានក៏ធ្វើមរណកាលទៅកើតក្នុងនរក ។

ភិក្ខុនោះ ឆេះក្នុងនរកអស់ច្រើនសែនឆ្នាំ សល់ផលកម្មនាំឲ្យកើតជាយក្ស ៥០០ ជាតិ មិនដែលបានអាហារពេញពោះ សូម្បីតែមួយថ្ងៃ ( រហូតដល់ថ្ងៃស្លាប់ទើបបានអាហារស៊ីឆ្អែត ) គឺបានស៊ីទងសុកមនុស្សឆ្អែតម្តង ( បន្ទាប់អំពីកើតជាយក្ស ) ក៏កើតជាឆ្កែ ៥០០ ជាតិ សូម្បីនៅក្នុងកំណើតឆ្កែនោះ ក៏បានស៊ីកម្អួតឆ្អែតតែម្តងប៉ុណ្ណោះ ។ ចំណែកក្នុងកាលដ៏សេស មិនដែលបានអ្វីស៊ីឆ្អែតម្តងឡើយ ចុតិអំពីកំណើតឆ្កែ ក៏មក

កើតក្នុងត្រកូលទុគ៌តមួយក្នុងដែនកាសី ។ ចាប់តាំងពីថ្ងៃដែលគេកើត ត្រកូលនោះក៏យ៉ាប់យ៉ឺនយ៉ាងក្រៃលែង សូម្បីតែទឹកនិងបាយកន្ទះពោះក៏មិនដែលបាន គេមាននាមថា មិត្តវិន្ទុកៈ ។ មាតាបិតារបស់មិត្តវិន្ទុកៈមិនអាចនឹងទ្រាំទ្រចំពោះសេចក្ដីទុក្ខដែលកើតអំពីការអត់ឃ្លានបាន ក៏និយាយថា ទៅចុះ អាកូនកាឡកណ្ណី វាយបណ្ដេញឲ្យចេញទៅ ។ មិត្តវិន្ទុកៈមិនមានទីពឹង ដើរទៅរហូតដល់នគរពារាណសី ។ គ្រានោះព្រះបរមពោធិសត្វសោយព្រះជាតិជាអាចារ្យទិសាបាមោក្ខ បង្រៀនសិល្បៈដល់មាណព ៥០០ នាក់ ។ ពេលនោះ អ្នកនគរពារាណសីឲ្យទុនដល់អ្នកក្រ ឲ្យសិក្សាសិល្បៈ សូម្បីមិត្តវិន្ទុកៈនេះ ក៏បានសិក្សាក្នុងសម្នាក់ព្រះបរមពោធិសត្វ ។ មិត្តវិន្ទុកៈជាក្មេងមិនសុភាព របុិលរប៉ូចមិនជឿ មិនស្ដាប់ឱវាទ ដើរទាត់ធាក់ ជាក្មេងខិលខូច សូម្បីព្រះបរម-ពោធិសត្វទូន្មានប្រៀនប្រដៅក៏មិនស្ដាប់តាមឱវាទ អាស្រ័យហេតុនោះការចម្រើនវ័យ របស់មិត្តវិន្ទុកៈនោះទើបជាការល្ងង់ខ្លៅ ។ គ្រានោះ មិត្ត-វិន្ទុកៈនោះឈ្លោះទាស់ទែងនឹងពួកក្មេងៗ ទាំងមិនស្ដាប់ពាក្យទូន្មាន រត់គេចទៅស្រុកជាយដែនមួយ ស៊ីឈ្នួលគេចិញ្ចឹមជីវិត ។ មិត្តវិន្ទុកៈនោះបានប្រព្រឹត្តខុសនឹងស្ត្រីក្រខ្សត់ម្នាក់ក្នុងភូមិនោះ ស្ត្រីនោះមានកូនជាមួយនឹងមិត្តវិន្ទុកៈពីរនាក់ ពួកអ្នកស្រុកបានប្រគល់ការងារបញ្ជូនដំណឹងឲ្យធ្វើថា អ្នកគប្បីប្រាប់ដំណឹងល្អ ដំណឹងអាក្រក់ដល់ពួកយើង ឲ្យថ្ងៃឈ្នួល

និងសង់ខ្ទមឲ្យនៅត្រង់ទ្វារស្រុកនោះ ។ ព្រោះអាស្រ័យមិត្តវិន្ទុកៈនោះជាដើមហេតុ ធ្វើឲ្យអ្នកស្រុកជាយដែននោះ ត្រូវរាជទណ្ឌ ៧ ដង ភ្លើងឆេះស្រុក ៧ ដង អណ្តូងទឹកបែកធ្លាយ ៧ ដង ។ ទើបពួកគេប្រឹក្សាគ្នាថា កាលពីមុនមិត្តវិន្ទុកៈនេះមិនទាន់មក ពួកយើងមិនដែលមានរឿងអ្វីឡើយ ឥឡូវនេះ ចាប់តាំងពីមិត្តវិន្ទុកៈមកនៅទីនេះ ពួកយើងចុះដុនដាបយ៉ាប់យ៉ឺនទៅៗ លុះប្រឹក្សាគ្នាដូច្នេះហើយ ក៏នាំគ្នាវាយបណ្តេញមិត្តវិន្ទុកៈឲ្យចេញអំពីភូមិ ។ មិត្តវិន្ទុកៈក៏នាំកូនពីរនាក់និងប្រពន្ធទៅកាន់ទីដទៃ ដើរចូលទៅកាន់ព្រៃដែលពួកអមនុស្សរស់នៅ ពួកអមនុស្សចាប់កូននិងប្រពន្ធរបស់មិត្តវិន្ទុកៈសម្លាប់ស៊ីសាច់អស់ ក្នុងព្រៃនោះឯង ។

មិត្តវិន្ទុកៈរត់រួចដើរទៅ ក៏ដល់កំពង់ទូកមួយឈ្មោះគម្ភីរៈ ជួនជាថ្ងៃដែលគេចេញទូកទៅរកស៊ីក៏ស្ម័គ្រចិត្តធ្វើកម្មករលើទូកនោះ ។ ទូកនោះទៅកាន់សមុទ្របាន ៧ ថ្ងៃ ដល់ថ្ងៃទី ៧ ត្រូវកៀងកណ្តាលសមុទ្រដូចគេចាប់ទាញ ។ អ្នកដែលនៅលើទូកទាំងនោះក៏ចាប់ស្លាកកាឡកណ្ណី ស្លាកកាឡកណ្ណីធ្លាក់មកដល់មិត្តវិន្ទុកៈតែម្នាក់ប៉ុណ្ណោះ ដល់ទៅ ៧ ដង ។ ពួកមនុស្សនៅលើទូកនោះបោះក្បូនឬស្សីមួយឲ្យមិត្តវិន្ទុកៈ ហើយនាំគ្នាចាប់ដៃមិត្តវិន្ទុកៈបោះទៅក្នុងសមុទ្រ គ្រាន់តែចាប់មិត្តវិន្ទុកៈបោះទៅក្នុងសមុទ្រភ្លាមទូកក៏រសាត់ទៅបាន មិត្តវិន្ទុកៈដេកលើក្បូនឬស្សីអណ្តែតទៅក្នុងសមុទ្រដោយផលដែលបានរក្សាសីលហើយក្នុងសាសនា **ព្រះកស្សប**-

**សម្មាសម្ពុទ្ធ** ទើបបានជួបទេពធីតា ៤ នាក់ ដែលនៅក្នុងវិមានកែវផលិកមួយក្នុងសមុទ្រ សោយសុខនៅក្នុងសម្នាក់ទេពធីតាទាំងនោះអស់ ៧ ថ្ងៃ ។ ស្រីទាំងនោះជាប្រេតមានវិមានសោយសុខ ៧ ថ្ងៃ សោយទុក្ខ ៧ ថ្ងៃ វិលទៅវិលមក កាលវិមានិកប្រេតទាំងនោះទៅសោយទុក្ខទាំង ៧ ថ្ងៃ ក៏ផ្តាំមិត្តវិន្ទុកៈនោះថា ចូរអ្នកនៅទីនេះ កុំទៅណា ចាំពួកខ្ញុំមកវិញ ហើយក៏នាំគ្នាទៅ ។ លុះវិមានិកប្រេតទាំងនោះទៅបាត់ មិត្តវិន្ទុកៈក៏ចុះដេកលើក្បូនឫស្សីអណ្តែតទៅខាងមុខ បានជួបទេពធីតា ៨ នាក់ក្នុងវិមានប្រាក់ ទេពធីតាទាំងនោះក៏ជាប្រេតមានវិមានដូចគ្នា មិត្តវិន្ទុកៈអណ្តែតទៅបានជួបទេពធីតា ១៦ នាក់ក្នុងវិមានកែវមណី ហើយក៏អណ្តែតទៅទៀត បានជួបទេពធីតា ៣២ នាក់ក្នុងវិមានមាស មិត្តវិន្ទុកៈមិនបានស្តាប់ទេពធីតាដូចគ្នា ទើបអណ្តែតទៅខាងមុខបានជួបយក្ខិនីនៅក្នុងកោះមួយ នៅក្នុងទីនោះមានយក្ខិនីមួយក្លែងខ្លួនជាមេពពែដើររកអាហារ មិត្តវិន្ទុកៈមិនដឹងថាមេពពែនោះជាយក្ខិនី គិតថា អញនឹងស៊ីសាច់ពពែ ដេញចាប់ជើងពពែ យក្ខិនីក៏លើកមិត្តវិន្ទុកៈឡើងជាក់ទៅ ដោយអានុភាពរបស់យក្ខិនី មិត្តវិន្ទុកៈត្រូវយក្ខិនីជាក់ដោយជើងឆ្លងសមុទ្រធ្លាក់ទៅលើគុម្ពឈើបន្លាមួយ ខាងលើខ្នងប្រឡាយនគរពារាណសី ហើយក៏រមៀលធ្លាក់ទៅលើដី ។ គ្រានោះ មេពពែរបស់ព្រះរាជាច្រើនក្បាលដើររកស៊ីលើខ្នងប្រឡាយនោះ ត្រូវពួកចោរលួច ពួកអ្នកឃ្វាលពពែប្រឹក្សាគ្នាថា ពួកយើង

ត្រូវតែចាប់ចោរឲ្យបាន នាំគ្នាពួននៅក្នុងគុម្ពោតព្រៃមួយកន្លែង មិត្តវិន្ទុកៈ រមៀលធ្លាក់មកឈរនៅលើផែនដីបានហើយ ឃើញមេពពែទាំងនោះ ក៏គិតថា អញចាប់មេពពែក្នុងកោះមួយកណ្ដាលសមុទ្រ ត្រូវវាជាក់មកធ្លាក់ទីនេះ ប្រសិនបើអញចាប់មេពពែមួយត្រង់ជើង វាគង់នឹងជាក់អញឲ្យត្រឡប់ទៅសម្នាក់ទេពធីតាដែលមានវិមាននៅក្នុងសមុទ្រវិញមិនខាន ។ មិត្តវិន្ទុកៈយល់ដោយខ្លួនឯងយ៉ាងនេះ មិនបានពិចារណាឲ្យត្រឹមត្រូវដូច្នេះហើយ ក៏លូកដៃទៅចាប់មេពពែមួយត្រង់ជើង មេពពែនោះត្រូវមិត្តវិន្ទុកៈចាប់ជើងភ្លាមក៏ស្រែកទ្រហឹង ពួកអ្នកឃ្វាលពពែក៏នាំគ្នារត់ចូលមកជុំវិញមិត្តវិន្ទុកៈ ស្រែកឡើងថា ពួកយើងរង់ចាំយូរហើយ អាចោរចង្រៃស៊ីមេពពែក្នុងរាជត្រកូលនេះ អាចង្រៃឯងនេះ ដូច្នេះហើយ ក៏ចោមរោមចាប់ចងនាំទៅកាន់ព្រះរាជវាំង ។ គ្រានោះ ព្រះបរមពោធិសត្វហែហមទៅដោយមាណព ៥០០ នាក់ចេញអំពីនគរទៅងូតទឹក ឃើញមិត្តវិន្ទុកៈក៏ចាំបាន ទើបនិយាយនឹងមនុស្សទាំងនោះថា នែអ្នកទាំងឡាយ បុរសនេះជាកូនសិស្សរបស់យើង ព្រោះហេតុអ្វីទើបអ្នកទាំងឡាយចាប់គេ?

អ្នកឃ្វាលពពែទាំងនោះឆ្លើយថា បពិត្រលោកដ៏ចម្រើន បុរសនេះជាមនុស្សអាក្រក់ លួចមេពពែរបស់ស្ដេច ព្រោះហេតុនោះ ទើបពួកខ្ញុំចាប់ ។

ព្រះបរមពោធិសត្វអង្វរថា បើដូច្នោះចូរឲ្យបុរសនេះជាទាសៈនៃ

ពួកយើងចុះ គេនឹងបានអាស្រ័យពួកយើងចិញ្ចឹមជីវិត ។ អ្នកឃ្វាលពពែទាំងនោះយល់ព្រមដោយពាក្យថា សាធុលោកម្ចាស់ ប្រគល់មិត្តវិន្ទុកៈឲ្យព្រះបរមពោធិសត្វហើយក៏នាំគ្នាត្រឡប់ទៅវិញ ។ គ្រានោះ ព្រះបរមពោធិសត្វក៏សួរមិត្តវិន្ទុកៈថា រយៈពេលដែលឯងបាត់មុខទៅនោះ តើឯងទៅទីណា ? មិត្តវិន្ទុកៈក៏តំណាលរឿងដែលខ្លួនធ្វើទាំងអស់ឲ្យព្រះបរមពោធិសត្វស្តាប់ ។ ព្រះបរមពោធិសត្វក៏ពោលថា បុគ្គលដែលមិនធ្វើតាមពាក្យប្រៀនប្រដៅរបស់អ្នកប្រាថ្នាសេចក្តីចម្រើន រមែងបានទុក្ខយ៉ាងនេះ ហើយពោលគាថាដូច្នេះថា

**យោ អត្ថកាមស្ស ហិតានុកម្បិនោ**
**ឱវជ្ជមានោ ន ករោតិ សាសនំ**
**អជិយា ចាតមោលុត្ត មិត្តកោ វិយ សោចតីតិ ។**

បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចម្រើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែងសោកសៅ ដូចជាមិត្តវិន្ទុកៈប្រតោងជើងនៃមេពពែសោកសៅ ។

បណ្តាបទទាំងនោះ បទថា **អត្ថកាមស្ស** សេចក្តីថា អ្នកប្រាថ្នាសេចក្តីចម្រើន ។

បទថា **ហិតានុកម្បិនោ** សេចក្តីថា អ្នកអនុគ្រោះដោយប្រយោជន៍ ។

បទថា **ឱវជ្ជមានោ** សេចក្តីថា ប្រៀនប្រដៅដោយមេត្តាចិត្ត ។

បទថា **ន ករោតិ សាសនំ** សេចក្តីថា មិនធ្វើតាមពាក្យប្រៀនប្រដៅ គឺជាមនុស្សប្រដៅក្រ ស្តីថាមិនបាន ។

បទថា **មិត្តកោ វិយ សោចតិ** សេចក្តីថា បុគ្គលនោះរមែងសោកសៅអស់កាលជានិច្ច ដូចមិត្តវិន្ទុកៈចាប់ជើងពពែហើយ រមែងសោកសៅដូច្នោះ ។

ព្រះបរមពោធិសត្វសម្តែងធម៌ដោយគាថានេះ ដែលមានអត្ថាធិប្បាយដូចពណ៌នាមកនេះ ។

ព្រះថេរៈនោះបានអាហារពេញផ្ទៃក្នុងអត្តភាពទាំងបីនេះ គឺកាលកើតជាយក្សបានស៊ីទងសុកឆ្អែតម្តង កាលកើតជាឆ្កែបានស៊ីកម្អួតឆ្អែតម្តង ជាតិចុងក្រោយក្នុងថ្ងៃបរិនិព្វានបានឆាន់បង្អែមបួនមុខឆ្អែតដោយអានុភាពនៃព្រះធម្មសេនាតីម្តង ដែលឈ្មោះថាការធ្វើឲ្យអន្តរាយលាភរបស់អ្នកដទៃ គប្បីជ្រាបថា មានទោសច្រើនយ៉ាងនេះ ។

ព្រះបរមពោធិសត្វដែលជាអាចារ្យនិងមិត្តវិន្ទុកៈក្នុងគ្រានោះ បានទៅតាមយថាកម្ម ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោសកតិស្សនោះបានធ្វើភាពជាអ្នកមានលាភតិច និងភាពជាអ្នកឲ្យអរិយធម៌ដល់ខ្លួនឯងយ៉ាងនេះ ។ លុះទ្រង់នាំធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំ

ជាតកថា មិត្តវិន្ទុកៈក្នុងកាលនោះ បានមកជាលោសកភិក្ខុក្នុងកាលឥឡូវនេះ អាចារ្យទិសាបាមោក្ខក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា លោសកជាតក ទី ១ ។

# អដ្ឋកថា កបោតកជាតក ទី ២

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកមាននិស្ស័យល្មោះល្មោះមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យោ អត្ថកាមស្ស** ដូច្នេះជាដើម ។

រឿងនៃការល្មោះល្មោះរបស់ភិក្ខុនោះ នឹងសម្ដែងយ៉ាងពិស្ដារក្នុង **កាកជាតក នវកនិបាត** ។ ក្នុងកាលនោះ ភិក្ខុទាំងឡាយនាំភិក្ខុនោះ មកក្រាបទូលព្រះបរមសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះមាននិស្ស័យល្មោះល្មោះ ។ គ្រានោះ ព្រះបរមសាស្ដាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ពិតមែនឬ ? ភិក្ខុនោះក្រាបទូលថា ព្រះករុណាព្រះអង្គ ទើបព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុ សូម្បីក្នុងកាលមុន អ្នកក៏ជាបក្សីល្មោះល្មោះ អស់ជីវិតព្រោះការល្មោះល្មោះរបស់ខ្លួន សូម្បីបណ្ឌិតអាស្រ័យអ្នក ក៏ត្រូវឃ្លាតចាកលំនៅទៅដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុង

នគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាព្រាប ។ គ្រានោះ អ្នកនគរពារាណសីនាំគ្នាព្យួរកំប្រោងដែលដាក់ដោយស្មៅទុកក្នុងទីនោះៗ ដើម្បីឲ្យពួកបក្សីអាស្រ័យនៅយ៉ាងសប្បាយ ព្រោះភាពជាអ្នកប្រាថ្នាបុណ្យប្រាថ្នាកុសល ។ គ្រានោះ ចុងភៅម្នាក់របស់សេដ្ឋីនគរពារាណសីក៏ព្យួរកំប្រោងដែលដាក់ដោយស្មៅក្នុងរោងបាយមួយដែរ ។ ព្រាបពោធិសត្វបានចូលទៅនៅក្នុងកំប្រោងស្មៅនោះ ។ ព្រឹកឡើងក៏ហើរចេញទៅរកអាហារ ល្ងាចទើបហើរត្រឡប់មកដេកនៅក្នុងរោងចុងភៅនោះអស់កាលជានិច្ច ។ ថ្ងៃមួយ ក្អែកមួយហើរឆ្លងកាត់រោងចុងភៅនោះ បានធុំក្លិនម្ហូបដែលចុងភៅកំពុងចម្អិនក៏កើតចិត្តលោភឡើងគិតថា អញអាស្រ័យអ្នកណាហ្ន៎ ទើបបានត្រីនិងសាច់នេះ គិតហើយ ក៏ទំនៅក្នុងទីមិនឆ្ងាយពីច្រកផ្លូវមួយ ។ លុះពេលរសៀល ក៏ឃើញព្រាបពោធិសត្វហើរមក ហើយចូលទៅកាន់រោងចុងភៅ ក៏គិតថា អញទាល់តែអាស្រ័យព្រាបនេះ ទើបបានស៊ីសាច់ ។ លុះព្រឹកឡើងក៏ហើរមកអំពីព្រលឹម ពេលដែលព្រះបរមពោធិសត្វហើរចេញទៅរកអាហារ ក៏ហើរតាមពីក្រោយ ។ គ្រានោះ ព្រះបរមពោធិសត្វក៏សួរក្អែកនោះថា នែសម្លាញ់ ហេតុអ្វីទើបអ្នកហើរតាមយើង ?

ក្អែកឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំពេញចិត្តនឹងកិរិយារបស់លោក ចាប់តាំងពីថ្ងៃនេះទៅ ខ្ញុំសូមបម្រើលោក ។

ព្រាបពោធិសត្វពោលថា ពួកអ្នកមានអាហារផ្សេង ពួកយើងមានអាហារផ្សេង មិនដូចគ្នា ការបម្រើរបស់ពួកអ្នក ពួកអ្នកធ្វើបានដោយលំបាក ។

ក្អែកពោលថា បពិត្រលោកម្ចាស់ ពេលលោកហើរទៅរកអាហារ ខ្ញុំក៏ហើរទៅរកអាហារដែរ គឺហើរទៅជាមួយនឹងលោក ។

ព្រាបពោធិសត្វពោលថា ល្អហើយ អ្នកចូររស់នៅដោយមិនប្រមាទចុះ ។ ព្រាបពោធិសត្វទូន្មានក្អែកយ៉ាងនេះហើយ ក៏ហើរទៅរកអាហារ បរិភោគអាហារមានគ្រាប់តិណជាតិជាដើម ក្នុងវេលាដែលព្រាបពោធិ-សត្វកំពុងរកអាហារ ក្អែកក៏ហើរទៅរកគំនរអាចម៍គោ កកាយហើយចឹកស៊ីដង្កូវ លុះពេញពោះហើយក៏មកកាន់សម្នាក់ព្រាបពោធិសត្វ រួចពោលថា បពិត្រលោកម្ចាស់ លោកត្រាច់ទៅហួសវេលាកាល ធ្វើខ្លួនឲ្យមានឈ្មោះថាអ្នកល្មោភ មិនគួរទេ ដូច្នេះហើយ ចូលទៅកាន់រោងចុងភៅជាមួយព្រាបពោធិសត្វ ដែលស្វែងរកអាហារហើយក៏ហើរមកក្នុងវេលាល្ងាច ។ ចុងភៅពោលថា ព្រាបរបស់អញនាំបក្សីដទៃមក ដូច្នេះហើយក៏ព្យួរកំប្រោងដែលដាក់ដោយស្មៅឲ្យក្អែក ចាប់តាំងពីពេលនោះមក ក្អែកក៏នៅជាមួយគ្នានឹងព្រាបពោធិសត្វ ។

ថ្ងៃមួយ មនុស្សទាំងឡាយនាំត្រីនិងសាច់មកឲ្យសេដ្ឋីយ៉ាងច្រើន ចុងភៅក៏ទទួលមកព្យួរទុកក្នុងរោងចុងភៅ ក្អែកឃើញហើយក៏កើតចំណង់

គិតក្នុងចិត្តថា ស្អែកនេះ អញមិនចេញទៅរកអាហារទេ អញនឹងស៊ីត្រីសាច់នេះឯង ហើយក៏ដេកដំអក់រហូតទល់ភ្លឺ ។ ព្រឹកឡើង ព្រាបពោធិសត្វចេញទៅរកអាហារក៏ហៅក្អែកថា មកសម្លាញ់ យើងនឹងចេញទៅរកអាហារ ។

ក្អែកឆ្លើយថា បពិត្រលោកម្ចាស់ លោកទៅចុះ ខ្ញុំកំពុងឈឺពោះ ។

ព្រាបពោធិសត្វពោលថា នែសម្លាញ់ ធម្មតារោគឈឺពោះធ្លាប់កើតមានដល់ហ្វូងក្អែកអំពីកាលណា យាមទាំងបីនៃរាត្រី ហ្វូងក្អែករមែងឃ្លានគ្រប់ៗយាម សូម្បីលេបប្រឆេះចង្កៀងចូលទៅ ក្អែកក៏ឆ្អែតតែមួយភ្លែតប៉ុណ្ណោះ អ្នកប្រហែលជាចង់ស៊ីត្រីនិងសាច់នេះ មកសម្លាញ់កុំចង់ស៊ីអីដែលឈ្មោះថាគ្រឿងបរិភោគរបស់មនុស្ស ជាវត្ថុដែលហ្វូងក្អែកមិនគួរស៊ី អ្នកកុំធ្វើដូច្នេះឡើយ ទៅរកអាហារជាមួយនឹងយើងចុះ ។

ក្អែកឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំមិនអាចទៅបានទេ ។

ព្រាបពោធិសត្វក៏ពោលដាស់តឿនថា បើដូច្នេះ អ្នកចូរដឹងកម្មរបស់ខ្លួន អ្នកកុំលុះក្នុងអំណាចចំណង់ ចូរជាអ្នកមិនប្រមាទចុះ ពោលដូច្នេះហើយ ក៏ហើរទៅរកអាហារ ។ ចុងភៅក៏ចម្អិនអាហារច្រើនប្រភេទដោយត្រីនិងសាច់មានប្រការផ្សេងៗ ស្រេចហើយក៏បើកភាជនៈបន្តិចដើម្បីឲ្យត្រជាក់ ដាក់កន្ត្រងលើភាជនៈមួយទៀត ហើយក៏ចេញទៅខាងក្រៅឈរជូតញើស ។ គ្រានោះ ក្អែកក៏អើតក្បាលចេញអំពីកំប្រោងស្មៅ

សម្លឹងមើលសព្វគ្រប់ក្នុងរោងចុងភៅ ដឹងថាចុងភៅចេញទៅខាងក្រៅ ក៏គិតថា ឥឡូវនេះសេចក្ដីប្រាថ្នារបស់អញសម្រេចហើយ អញស៊ីសាច់ដុំធំឬក៏ដុំតូចហ្ន៎ លុះគិតដូច្នេះហើយក៏នឹកឃើញថា ធម្មតាដុំសាច់តូចៗ អញមិនអាចស៊ីឲ្យពេញពោះបានឆាប់រហ័សទេ អញត្រូវឆាប់យកដុំធំៗ មកទុកក្នុងកំប្រោងស្មៅដេកលេបទើបល្អ ហើយក៏លោតចេញអំពីកំប្រោងស្មៅទៅឈរជិតកន្ត្រង សំឡេងកន្ត្រងឮសូរគ្រិកៗ ។ ចុងភៅឮសូរសំឡេងនោះហើយ ក៏គិតថា សំឡេងអ្វីហ្ន៎ ត្រឡប់ចូលទៅមើលឃើញក្អែកហើយគិតថា ក្អែកកំហូចនេះចង់ស៊ីសាច់ចៀនរបស់មហា-សេដ្ឋី ខ្លួនអញចិញ្ចឹមជីវិតអាស្រ័យសេដ្ឋី មិនមែនអាស្រ័យក្អែកពាលនេះទេ នឹងទុកវាធ្វើអ្វី? ហើយបិទទ្វារស្ទាក់ចាប់ក្អែកបាន ដករោមអស់ យកខ្ញីស្រស់បុកលាយនឹងអំបិល លាយនឹងទឹកដោះជូរ លាបរហូតពេញខ្លួនក្អែកនោះ ហើយបោះទៅក្នុងកំប្រោងស្មៅវិញ ។ ក្អែកឈឺចាប់យ៉ាងខ្លាំងដេកដកដង្ហើមផឹតផតៗ ។ លុះពេលរសៀល ព្រាបពោធិសត្វហើរត្រលប់មកពីរកអាហារវិញ ឃើញក្អែកដល់នូវសេចក្ដីវិនាសក៏និយាយថា នៃក្អែកឡេះឡោះ អ្នកមិនជឿ មិនស្ដាប់ពាក្យរបស់យើង អាស្រ័យចំណង់របស់អ្នកជាហេតុ ទើបដល់នូវសេចក្ដីទុក្ខធំយ៉ាងនេះ ដូច្នេះហើយ ពោលគាថានេះថា

**យោ អត្ថកាមស្ស ហិតានុកម្បិនោ**

**ឱវជ្ជមានោ ន ករោតិ សាសនំ**
**កាចោតកស្ស វចនំ អកត្វា**
**អមិត្តហត្ថត្ថកតោវ សេតីតិ ។**

*បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចម្រើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះតែងដេកសោកសៅ ដូចក្អែកតាំងនៅក្នុងកណ្តាប់ដៃ នៃបុគ្គលជាសត្រូវ ព្រោះមិនធ្វើតាមពាក្យនៃសត្វព្រាប ។*

*បណ្តាបទទាំងនោះ បទថា* **កាចោតកស្ស វចនំ អកត្វា** *សេចក្តីថា មិនជឿពាក្យទូន្មានដែលប្រាថ្នាប្រយោជន៍របស់ព្រាប ។*

*បទថា* **អមិត្តហត្ថត្ថកតោវ សេតិ** *សេចក្តីថា បុគ្គលនោះតែងដល់នូវសេចក្តីវិនាសធំ ដេកក្រំចិត្ត ដូចក្អែកនេះធ្លាក់នៅក្នុងកណ្តាប់ដៃរបស់សត្រូវ គឺបុគ្គលអ្នកធ្វើសេចក្តីវិនាសឲ្យ នឹងបង្កឲ្យកើតទុក្ខ ។*

*ព្រះបរមពោធិសត្វពោលគាថានេះហើយ គិតថា ឥឡូវនេះ អញក៏មិនអាចនៅទីនេះបាន ទើបហើរទៅកាន់ទីដទៃ ។ ចំណែកក្អែកក៏អស់ជីវិតនៅក្នុងកំប្រោងស្មៅនោះឯង ចុងភៅក៏យកក្អែកទាំងកំប្រោងស្មៅទៅបោះចោលលើគំនរសំរាម ។*

*ព្រះបរមសាស្តា ទ្រង់ត្រាស់បញ្ជាក់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះជាមនុស្សឡេះឡោះ*

នោះ សូម្បីក្នុងកាលមុនក៏ជាអ្នកឡេះឡោះដែរ ហើយបណ្ឌិតទាំងឡាយ អាស្រ័យការឡេះឡោះរបស់ភិក្ខុនេះ ក៏ត្រូវឃ្លាតចាកលំនៅរបស់ខ្លួនទៅដែរ ។ លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសអរិយសច្ច លុះចប់អរិយសច្ច ភិក្ខុនោះក៏បានសម្រេចអនាគាមិផល ។ ព្រះបរមសាស្តា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ក្អែកក្នុងកាលនោះ បានជាភិក្ខុឡេះឡោះក្នុងកាលឥឡូវនេះ ព្រាបក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា កបោតកជាតក ទី ២ ។

# អដ្ឋកថា វេឡុកជាតក ទី ៣

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យោ អត្ថកាមស្ស** ដូច្នេះជាដើម ។

មានរឿងសង្ខេបថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ពិតមែនឬ ដែលថាអ្នកជាមនុស្សប្រដៅក្រនោះ ? កាលភិក្ខុនោះក្រាបទូលថា ព្រះករុណាព្រះអង្គ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនអ្នកក៏ជាមនុស្សប្រដៅក្រដែរ ព្រោះភាពជាមនុស្សប្រដៅក្រនោះឯង ទើបមិនធ្វើ

តាមពាក្យទូន្មានរបស់បណ្ឌិតទាំងឡាយ ហើយត្រូវពស់ចឹកស្លាប់ ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលដែលមានសម្បត្តិច្រើនក្នុងដែនកាសី លុះដល់ចម្រើនវ័យហើយ ក៏ឃើញទោសក្នុងកាមគុណ ឃើញអានិសង្សក្នុងការចេញបួស ទើបលះបង់កាមទាំងឡាយហើយចូលព្រៃហេមពាន្តបួសជាឥសី បំពេញកសិណបរិកម្ម ញុំាងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតហើយ នៅដោយសុខដែលកើតអំពីឈាន ក្រោយមកមានបរិវារច្រើន មានតាបស ៥០០ អង្គចោមរោម ជាគ្រូនៃគណៈ ។ គ្រានោះ មានកូនអាសិរពិសមួយលូនទៅតាមធម្មតារបស់វា ក៏ដល់អាស្រមបទរបស់តាបសមួយរូប ។ តាបសឃើញហើយកើតសេចក្ដីស្រលាញ់អាសិរពិសនោះដូចជាកូន ក៏ចាប់វាយកមកចិញ្ចឹមឲ្យដេកក្នុងបំពង់ឬស្សីមួយ ព្រោះហេតុតែអាសិរពិសនោះដេកក្នុងបំពង់ឬស្សី ទើបតាបសទាំងឡាយឲ្យឈ្មោះថា វេឡុកៈ ហើយព្រោះហេតុតែតាបសនោះចិញ្ចឹមអាសិរពិសនោះដោយសេចក្ដីស្រលាញ់ដូចជាកូន ទើបតាបសទាំងឡាយដាក់ឈ្មោះឲ្យតាបសនោះថា វេឡុកបិតា ។ គ្រានោះ ព្រះបរមពោធិសត្វបានដឹងថា តាបសនោះចិញ្ចឹមអាសិរពិស ទើបហៅមកសួរថា នៃអ្នកដ៏ចម្រើន អ្នកចិញ្ចឹមអាសិរពិសមែនឬ ? កាលតាបសនោះឆ្លើយថា

ពិតមែនហើយ ក៏ដាស់តឿនថា ដែលឈ្មោះថាអាសិរ្ពិសទុកចិត្តមិនបាន ឡើយ ដូច្នេះអ្នកកុំចិញ្ចឹមវាអី ។

តាបសឆ្លើយតបថា បពិត្រលោកអាចារ្យ វាដូចជាកូនរបស់ខ្ញុំ ខ្ញុំ មិនអាចព្រាត់ប្រាសវាបានទេ ។

ព្រះបរមពោធិសត្វដាស់តឿនទៀតថា បើដូច្នេះ អ្នកត្រូវដល់នូវ សេចក្តីស្លាប់ព្រោះតែនៅជិតវាជាប្រាកដ ។ តាបសនោះ មិនជឿពាក្យ ទូន្មានរបស់ព្រះបរមពោធិសត្វ ហើយមិនអាចដោះលែងអាសិរ្ពិសបាន ។ ក្រោយអំពីនោះ ពីរ-បីថ្ងៃប៉ុណ្ណោះ តាបសទាំងអស់នាំគ្នាទៅរកផលាផល លុះទៅដល់ហើយក៏ឃើញថាផលាផលរកបានដោយងាយ ទើបសម្រាក នៅទីនោះពីរ-បីថ្ងៃ ។ ចំណែកតាបសវេឡុកបិតា កាលទៅជាមួយនឹង ក្រុមតាបសទាំងនោះ ក៏ឲ្យអាសិរ្ពិសដេកក្នុងបំពង់ឫស្សីបិទទុកហើយទើប ទៅ ។ កន្លងទៅពីរ-បីថ្ងៃ ទើបត្រឡប់មកវិញជាមួយនឹងតាបសទាំងនោះ គិតថា អញនឹងឲ្យអាហារវេឡុកៈស៊ី បើកបំពង់ឫស្សីហើយនិយាយថា មកចុះកូន កូនឯងឃ្លានហើយឬ ? និយាយបណ្តើរលូកដៃចូលទៅ បណ្តើរ អាសិរ្ពិសខឹងព្រោះអត់អាហារមកពីរ-បីថ្ងៃហើយ ទើបចឹកដៃ តាបសដែលលូកចូលទៅ ធ្វើឲ្យតាបសអស់ជីវិតនៅត្រង់នោះឯង ហើយ លូនចូលព្រៃបាត់ ។ តាបសទាំងឡាយឃើញដូច្នេះ ក៏ប្រាប់ព្រះបរម- ពោធិសត្វ ។ ព្រះបរមពោធិសត្វប្រាប់ឲ្យធ្វើសរីរកិច្ចរបស់តាបសដែល

*អស់ជីវិតនោះ ហើយអង្គុយនៅកណ្តាលតាបសពោលគាថានេះ ទូន្មានតាបសទាំងនោះ ដោយមានសេចក្តីថា*

**យោ អត្ថកាមស្ស ហិតានុកម្បិនោ**
**ឱវជ្ជមានោ ន ករោតិ សាសនំ**
**ឯវំ សោ និហតោ សេតិ វេឡុកស្ស យថា បិតាតិ ។**

*បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចម្រើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែងដេកស្លាប់ ដូចឥសីជាបិតានៃពស់ឈ្មោះវេឡុកៈ ។*

*បណ្តាបទទាំងនោះ បទថា* **ឯវំ សោ និហតោ សេតិ** *សេចក្តីថា បុគ្គលណាមិនជឿពាក្យទូន្មានរបស់ឥសីទាំងឡាយ បុគ្គលនោះរមែងដល់នូវសេចក្តីវិនាសធំ ត្រូវវិបត្តិកម្ចាត់ដេកស្លាប់ ដូចតាបសនេះត្រូវកម្ចាត់ឲ្យដល់នូវការស្អុយរលួយ ដេកស្លាប់នៅក្នុងមាត់អាសិរពិស ដូច្នេះ ។*

*ព្រះបរមពោធិសត្វទូន្មានប្រៀនប្រដៅពួកឥសីយ៉ាងនេះហើយ ញ៉ាំងព្រហ្មវិហារ ៤ ឲ្យចម្រើនហើយ ក្រោយអំពីអស់ជីវិតក៏បដិសន្ធិក្នុងព្រហ្មលោក ។*

*ចំណែកព្រះបរមសាស្តាក៏ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអ្នកជាមនុស្សប្រដៅក្រនោះ សូម្បីក្នុង*

*កាលមុន អ្នកក៏ជាមនុស្សប្រដៅក្រដែរ ព្រោះភាពជាអ្នកប្រដៅក្រ ទើបដល់នូវការអស់អាយុក្នុងមាត់អាសិរ្ពិស ។*

*ព្រះបរមសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា តាបសវេឡុកបិតាក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាលឥឡូវនេះ បរិស័ទដ៏សេស បានមកជាពុទ្ធបរិស័ទ សាស្ដាជាមេគណៈនៃឥសី គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា វេឡុកជាតក ទី ៣ ។

# អដ្ឋកថា មកសជាតក ទី ៤

*ព្រះបរមសាស្ដា កាលស្ដេចទ្រង់ចារិកទៅកាន់ដែនមគធៈ ទ្រង់ប្រារព្ធពួកមនុស្សដែលជាបុគ្គលពាលមួយក្រុម ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **សេយ្យោ អមិត្តោ** *ដូច្នេះជាដើម ។*

*បានឮថា សម័យមួយ ព្រះតថាគតទ្រង់យាងចេញអំពីនគរសាវត្ថីទៅកាន់ដែនមគធៈ ខណៈពេលដែលទ្រង់កំពុងចារិកទៅកាន់ដែនមគធៈនោះ ទ្រង់យាងទៅដល់ស្រុកមួយ ចំណែកអ្នកស្រុកនោះ ភាគច្រើនជាបុគ្គលពាល ។ ថ្ងៃមួយ បុគ្គលពាលទាំងនោះប្រជុំប្រឹក្សាគ្នាថា នៃអ្នកទាំងឡាយ មូសទាំងឡាយចោមរោមខាំយើង ខណៈដែលយើងទៅធ្វើការងារក្នុងព្រៃ ព្រោះហេតុនោះ ទើបការងាររបស់យើងទាំងឡាយ*

ដាច់ទៅ ពួកយើងនឹងកាន់ធ្នូនិងអាវុធ ព្រួតដៃគ្នា នាំគ្នាទៅធ្វើសង្គ្រាមនឹងមូស សម្លាប់វា ចាក់វាឲ្យស្លាប់អស់ ដូច្នេះហើយ នាំគ្នាទៅកាន់ព្រៃ ម្នាក់ៗបំណាំងថា យើងនឹងចាក់មូសទាំងឡាយ ត្រឡប់ទៅជាចាក់គ្នាឯងប្រហារគ្នាឯងទៅវិញ ម្នាក់ៗឈឺចាប់យ៉ាងខ្លាំង ដេកនៅក្នុងស្រុកក៏មានកណ្ដាលស្រុកក៏មាន ក្បែរទ្វារស្រុកក៏មាន ។ ព្រះបរមសាស្ដាចោមរោមដោយពួកភិក្ខុ ទ្រង់យាងចូលទៅកាន់ស្រុកនោះដើម្បីបិណ្ឌបាត ។ ពួកមនុស្សដែលជាអ្នកមានបញ្ញាដ៏សេសឃើញព្រះដ៏មានព្រះភាគហើយ ក៏ធ្វើមណ្ឌបក្បែរទ្វារស្រុក ថ្វាយមហាទានចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ថ្វាយបង្គំព្រះបរមសាស្ដាហើយអង្គុយក្នុងទីដ៏សមគួរ ។ គ្រានោះព្រះបរមសាស្ដាទ្រង់ទតឃើញមនុស្សទាំងឡាយដួលដេកដល់នូវសេចក្ដីទុក្ខក្នុងទីនោះៗ ក៏ត្រាស់សួរឧបាសកទាំងនោះថា មនុស្សទាំងនេះទៅធ្វើអ្វី ទើបដល់នូវសេចក្ដីទុក្ខយ៉ាងនេះ ។ ឧបាសកទាំងនោះក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងនេះប្រជុំប្រឹក្សាគ្នាថា ពួកយើងនឹងធ្វើសង្គ្រាមជាមួយមូស ហើយនាំគ្នាទៅ ត្រឡប់ទៅជាកាប់ចាក់គ្នាឯងដល់នូវសេចក្ដីទុក្ខទៅវិញ ។ ព្រះបរមសាស្ដាទ្រង់ត្រាស់ថា មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលមនុស្សអន្ធពាលគិតគ្នាថា ពួកយើងនឹងសម្លាប់មូស ត្រឡប់ប្រហារខ្លួនឯង សូម្បីក្នុងកាលមុន ពួកមនុស្សអន្ធពាលក៏ប្រជុំប្រឹក្សាគ្នាថា ពួកយើងនឹងប្រហារហ្វូងមូស ត្រឡប់ទៅជា

ប្រហារអ្នកដទៃមកហើយដូចគ្នា ហើយទ្រង់តុណ្ហីភាព កាលមនុស្ស ទាំងនោះក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធក ដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅ ក្នុងនគរពារាណសី ព្រះបរមពោធិសត្វចិញ្ចឹមជីវិតដោយការលក់ដូរ ។ គ្រានោះ ស្រុកជាយដែនមួយក្នុងដែនកាសី មានពួកជាងឈើនៅជាច្រើន ជាងឈើក្បាលទំពែកម្នាក់នៅក្នុងក្រុមជាងឈើទាំងនោះ កំពុងឈូសឈើ ខណៈនោះមានមូសមួយហើរមកទំលើក្បាលបុរសនោះ ដែលមានសភាព ដូចត្រឡោកផ្កាប់ ហើយខាំក្បាលគាត់ដូចប្រហារដោយលំពែង ជាងឈើ នោះ ក៏ប្រាប់កូនរបស់ខ្លួនដែលអង្គុយនៅជិតនោះថា កូនឯងមើលអាមូស មួយនោះ វាខាំក្បាលឪឈឺដូចត្រូវចាក់ដោយលំពែង ចូរសម្លាប់វាចុះ ។ កូន និយាយថា សូមពុកនៅឲ្យស្ងៀម ខ្ញុំនឹងសម្លាប់វាដោយការទះតែម្តង ប៉ុណ្ណោះ ។ គ្រានោះ ព្រះបរមពោធិសត្វកំពុងដើរស្វែងរកទំនិញរបស់ ខ្លួនដល់ស្រុកនោះ អង្គុយសម្រាកក្នុងរោងជាងឈើនោះ ដំណាលគ្នានឹង ជាងឈើនោះប្រាប់កូនថា នៃកូន កូនឯងដេញមូសឲ្យឪបន្តិច កូនឆ្លើយ ថា បាទឪខ្ញុំនឹងដេញវា និយាយបណ្តើរ ផាពូថៅធំដែលមានមុខសស្វាច ឈរពីខាងក្រោយឪកាប់ពេញ ទំហឹងដោយគិតថា កាប់មូស ហួសទៅពុះ លលាដ៍ក្បាលរបស់បិតាជាពីរចំណែក ជាងឈើនោះក៏ស្លាប់ក្នុងទីនោះ

*ឯង ។ ព្រះបរមពោធិសត្វឃើញអំពើរបស់កូនជាងឈើនោះហើយក៏បាន គិតថា បច្ចាមិត្រជាបណ្ឌិតក៏នៅប្រសើរជាង ព្រោះគេនៅខ្លាចក្រែងរាជ-អាជ្ញា មិនហ៊ានសម្លាប់មនុស្សហើយពោលគាថានេះថា*

**សេយ្យោ អមិត្តោ មតិយា ឧបេតោ**

**ន ត្វេវ មិត្តោ មតិវិប្បហីនោ**

**មកសំ វធិស្សន្តិ ហិ ឯលមូគោ**

**បុត្តោ បិតុ អព្ភិទា ឧត្តមង្គន្តិ ។**

*បុគ្គលជាសត្រូវ តែប្រកបដោយប្រាជ្ញា ប្រសើរជាង*

*ឯបុគ្គលជាមិត្ត ដែលប្រាសចាកប្រាជ្ញា មិនប្រសើរ*

*ឡើយ ដូចយ៉ាងកូនបង្កើតដែលល្ងង់ខ្លៅ គិតថា អញ*

*នឹងសម្លាប់មូស ត្រឡប់ជាបំបែកក្បាលបិតាវិញ ។*

*បណ្ដាបទទាំងនោះ បទថា* **សេយ្យោ** *សេចក្ដីថា ប្រសើរ គឺខ្ពស់បំផុត ។ បទថា* **មតិយា ឧបេតោ** *សេចក្ដីថា ប្រកបដោយបញ្ញា ។*

*បទថា* **ឯលមូគោ** *សេចក្ដីថា ល្ងីល្ងើ គឺល្ងង់ខ្លៅ ។*

*បទថា* **បុត្តោ បិតុ អព្ភិទា ឧត្តមង្គំ** *សេចក្ដីថា ព្រោះការដែលខ្លួនជាមនុស្សល្ងង់ខ្លៅ ដូចកូនបង្កើតដែលល្ងង់ខ្លៅ គិតថា អញនឹងសម្លាប់មូស បែរជាកាប់ក្បាលបិតាបែកជាពីរ ព្រោះហេតុនោះ មានបណ្ឌិតជាសត្រូវ ក៏នៅប្រសើរជាងមិត្តដែលល្ងង់ខ្លៅ ។*

ព្រះបរមពោធិសត្វពោលគាថានេះហើយ ក៏ក្រោកឡើងទៅធ្វើការងាររបស់ខ្លួន ។ ចំណែកពួកញាតិក៏បានចាត់ចែងធ្វើសរីរកិច្ចរបស់ជាងឈើនោះ ។

ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា ម្នាលឧបាសកទាំងឡាយ សូម្បីក្នុងកាលមុនក៏ធ្លាប់មានមនុស្សគិតថា អញនឹងសម្លាប់មូស ត្រឡប់ជាសម្លាប់អ្នកដទៃមកហើយដែរ ។ លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ឈ្មួញបណ្ឌិតដែលពោលគាថាហើយចៀសចេញទៅនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា មកសជាតក ទី ៤ ។

# អដ្ឋកថា រោហិណីជាតក ទី ៥

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទាសីរបស់អនាថបិណ្ឌិកសេដ្ឋីម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សេយ្យោ អមិត្តោ** ដូច្នេះជាដើម ។

បានឮថា អនាថបិណ្ឌិកសេដ្ឋីមានទាសីម្នាក់ឈ្មោះរោហិណី ។ ថ្ងៃមួយ មាតារបស់នាងទាសីដែលជាមនុស្សចាស់មកដេកនៅក្នុងរោងជាន់អង្ករ រុយជាច្រើនមករោមមាតារបស់នាងរោហណីនោះ ខាំឈឺដូចចាក់ដោយម្ជុល នាងក៏ប្រាប់កូនស្រីថា នែកូនស្រី រុយរោមខាំម៉ែ កូនឯងចូរ

ដេញវាទៅ ។

នាងរោហិណីឆ្លើយតបថា ចាំម៉ែខ្ញុំនឹងដេញ ងារអង្រែដោយគិតក្នុងចិត្តថា អញនឹងសម្លាប់រុយដែលរោមម៉ែអញឲ្យស្លាប់ ឲ្យដល់នូវសេចក្ដីវិនាស ហើយក៏គ្រវែងអង្រែទៅត្រូវមាតាស្លាប់នៅទីនោះឯង ។ លុះឃើញមាតាស្លាប់ក៏យំសោករៀបរាប់ថា ម៉ែរបស់ខ្ញុំស្លាប់ហើយ ម៉ែរបស់ខ្ញុំស្លាប់ហើយ ។ មនុស្សទាំងឡាយក៏ប្រាប់រឿងនោះដល់លោកសេដ្ឋី ។ លោកសេដ្ឋីបានចាត់ចែងធ្វើសរីរកិច្ចតាមសមគួរហើយ ក៏ទៅកាន់វិហារក្រាបទូលរឿង-រ៉ាវទាំងអស់ចំពោះព្រះបរមសាស្ដា ។ ព្រះបរមសាស្ដាទ្រង់ត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទាសីនេះសម្លាប់មាតាដោយអង្រែ ព្រោះគិតថា សម្លាប់រុយ សូម្បីក្នុងកាលមុន ទាសីនេះក៏សម្លាប់មាតារបស់ខ្លួនដោយអង្រែដែរ ព្រោះគិតថា នឹងសម្លាប់រុយ ។ កាលសេដ្ឋីក្រាបទូលអារាធនាហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលសេដ្ឋី ក្រោយអំពីបិតាអស់អាយុក៏គ្រប់គ្រងតំណែងសេដ្ឋីជំនួស ។ សេដ្ឋីពោធិសត្វនោះមានទាសីម្នាក់ឈ្មោះរោហិណីដែរ សូម្បីទាសីនោះក៏បានសម្លាប់មាតារបស់ខ្លួនដែលបានមកកាន់រោងបុកអង្ករ ដែលប្រាប់ឲ្យដេញរុយដោយ

*អង្រ្ញែបុកអង្ករយ៉ាងនេះឯង លុះមាតាអស់ជីវិតក៏យំសោក ។ ព្រះបរម-ពោធិសត្វស្តាប់រឿងនោះហើយត្រិះរិះថា សូម្បីមានសត្រូវក៏សូមឲ្យជាបណ្ឌិតចុះ ព្រោះវាប្រសើរជាង ហើយពោលគាថានេះថា*

**សេយ្យោ អមិត្តោ មេធាវី យញ្ចេ ពាលានុកម្បកោ**
**បស្ស រោហិណិកំ ជម្មឹ មាតរំ ហន្ត្វាន សោចតីតិ។**

*បុគ្គលជាសត្រូវ តែជាអ្នកប្រាជ្ញ ប្រសើរជាង ឯបុគ្គលពាលជាអ្នកទំនុកបម្រុង មិនប្រសើរឡើយ អ្នកចូរមើលទាសីឈ្មោះរោហិណី ជាស្រីអាក្រក់ សម្លាប់ម្តាយហើយសោកសៅ ។*

*បណ្តាបទទាំងនោះ បទថា* **មេធាវី** *បានដល់ បណ្ឌិត គឺអ្នកដឹងច្បាស់ ។ បទថា* **យំ** *ក្នុងបាទគាថាថា* **យញ្ចេ ពាលានុកម្បកោ** *នេះ លោកធ្វើជាលិង្គវិបល្លាស ។ សព្ទថា* **ចេ** *ជានិបាតប្រើក្នុងអត្ថនៃនាម ។ សេចក្តីថា បណ្ឌិត សូម្បីជាសត្រូវក៏នៅតែប្រសើរជាងមនុស្សល្ងង់ខ្លៅ ដែលមានចិត្តករុណាទាំងរយទាំងពាន់ ។ម្យ៉ាងទៀត បទថា* **យំ** *ជានិបាតចុះក្នុងអត្ថថា បដិសេធ សេចក្តីថា បុគ្គលល្ងង់ខ្លៅដែលមានចិត្តអាណិតអាសូរ នឹងប្រសើរម្តេចបាន ?*

*បទថា* **ជម្មឹ** *គឺ មនុស្សថោកទាប ល្ងង់ខ្លៅ ។*

*បទថា* **មាតរំ ហន្ត្វាន សោចតិ** *សេចក្តីថា នាងរោហិណីជាស្រីល្ងង់ខ្លៅ សម្គាល់ថាអញនឹងសម្លាប់រុយ ត្រលប់ជាសម្លាប់ម្តាយ*

*បង្កើតហើយសោកសៅ ។ ដោយហេតុនេះ ក្នុងលោកនេះ សូម្បីមានសត្រូវក៏សូមឲ្យជាបណ្ឌិតចុះ វាប្រសើរជាង ។ ព្រះបរមពោធិសត្វកាលសរសើរបណ្ឌិត សម្ដែងធម៌ដោយគាថានេះ ។*

*ព្រះបរមសាស្ដាទ្រង់ត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលនាងរោហិណីគិតថា អញនឹងសម្លាប់រុយត្រឡប់ជាសម្លាប់មាតាទៅវិញ សូម្បីក្នុងកាលមុនក៏ធ្លាប់សម្លាប់មាតារបស់ខ្លួនដូច្នេះដែរ ។ លុះទ្រង់នាំព្រះធម្មទេសនានេះមកត្រាស់សម្ដែងហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា មាតារបស់នាងរោហិណីក្នុងកាលនោះ បានមកជាមាតាក្នុងកាលឥឡូវនេះ ធីតាក្នុងកាលនោះ បានមកជាធីតាក្នុងកាលនេះ ចំណែកមហាសេដ្ឋីក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា រោហិណីជាតក ទី ៥ ។

# អដ្ឋកថា អារាមទូសកជាតក ទី ៦

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធក្មេងអ្នកប្រទូសរ៉ាយឧទ្យានដែលនៅក្នុងដែនកោសល ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ន វេ អនត្ថកុសលេន** ដូច្នេះជាដើម ។

បានឮថា កាលព្រះបរមសាស្តាស្តេចចារិកទៅកាន់ដែនកោសល ទ្រង់យាងទៅដល់ស្រុកមួយ កុដុម្ពិកៈម្នាក់ដែលនៅក្នុងស្រុកនោះ និមន្តព្រះតថាគតឲ្យគង់ក្នុងឧទ្យានរបស់ខ្លួន ថ្វាយទានចំពោះព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់គង់នៅក្នុងសួននេះ តាមការពេញព្រះទ័យចុះ ។ ភិក្ខុទាំងឡាយក៏នាំគ្នាក្រោកឡើងបបួលអ្នករក្សាសួនទៅកាន់សួន ឃើញទីវាលស្រឡះរាបស្មើមួយកន្លែង ក៏សួរអ្នករក្សាសួននោះថា នែឧបាសក ឧទ្យាននេះ ត្រង់កន្លែងដទៃមានដើមឈើស្រស់ខៀវខ្ចីគួរឲ្យគយគន់ ប៉ុន្តែត្រង់កន្លែងនេះ មិនមានដើមឈើឬគុម្ពឬស្សីអ្វីសោះ តើព្រោះហេតុអ្វីហ្ន៎ ?

អ្នករក្សាឧទ្យាននោះឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ពេលធ្វើឧទ្យាននេះ មានក្មេងអ្នកស្រុកម្នាក់ កាលនឹងស្រោចទឹកដើមឈើ វាបានដកដើមឈើដែលទើបតែដាំត្រង់កន្លែងនេះឡើង មើលឫសជាមុន ហើយទើបស្រោចទឹកតាមប្រវែងវែងខ្លីនៃឫសជាប្រមាណ ដើមឈើទើបតែដាំថ្មីទាំងនោះក៏ស្វិតស្រពោនងាប់អស់ ដោយហេតុនេះ ទើបត្រង់កន្លែង

នេះវាលស្រឡះមិនមានដើមឈើ ។ ភិក្ខុទាំងឡាយចូលទៅគាល់ព្រះ-បរមសាស្តាហើយក្រាបទូលរឿងនោះ ។

ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្មេងអ្នកស្រុកនោះ មិនមែនទើបតែជាមនុស្សទម្លាយសួនក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ធ្លាប់ទម្លាយសួនដូចគ្នាដែរ ហើយទ្រង់នាំយករឿងក្នុងអតីតកាលមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ពួកអ្នកក្រុងដើរប្រកាសការលេងនក្ខត្តឫក្សក្នុងនគរ ។ ចាប់តាំងពីកាលដែលបានឮសំឡេងស្គរប្រគំក្នុងនក្ខត្តឫក្ស អ្នកនគរនាំគ្នាទៅលេងនក្ខត្តឫក្សយ៉ាងសប្បាយរីករាយ ។ គ្រានោះ ឧទ្យានរបស់ព្រះរាជាមានហ្វូងស្វានៅជាច្រើន ។ អ្នករក្សាសួនគិតថា ក្នុងក្រុងមានបុណ្យនក្ខត្តឫក្សអឹកធឹក អញប្រាប់ឲ្យស្វាទាំងនេះស្រោចទឹកដើមឈើហើយអញក៏អាចទៅលេងបុណ្យនក្ខត្តឫក្សបាន ហើយក៏ទៅរកស្វាមេ-ហ្វូងសួរថា នែស្វាមេហ្វូងសម្លាញ់ ឧទ្យាននេះមានឧបការៈច្រើនដល់ពួកអ្នកទាំងឡាយ ពួកឯងបាននាំគ្នាស៊ីផ្កាឈើ ផ្លែឈើ និងស្លឹកឈើខ្ចីៗក្នុងឧទ្យាននេះ ឥឡូវនេះ ក្នុងនគរកំពុងមានបុណ្យនក្ខត្តឫក្ស ខ្ញុំនឹងទៅលេងបុណ្យនក្ខត្តឫក្សនឹងគេខ្លះ ចូរពួកឯងជួយស្រោចទឹកដើមឈើដែលកំពុងដាំថ្មីៗ ក្នុងសួននេះ រយៈពេលដែលខ្ញុំមិនទាន់មកបានឬទេ ? ស្វា

មេហ្វូងយល់ព្រមថា បាន ពួកខ្ញុំនឹងស្រោចទឹកឲ្យ ។ ឧទ្យានបាលក៏បញ្ជាក់ថា បើដូច្នោះ ចូរពួកឯងប្រយ័ត្ន កុំប្រមាទណា៎ ចាត់ចែងរកថាំងស្បែក ថាំងឈើសម្រាប់ដួសទឹកឲ្យពួកស្វាហើយក៏ទៅ ។ ពួកស្វានាំគ្នាកាន់ថាំងស្បែកនិងថាំងឈើទៅស្រោចទឹកដើមឈើ ។ ពេលនោះស្វាមេហ្វូងក៏និយាយនឹងពួកស្វាយ៉ាងនេះថា នៃស្វាដ៏ចម្រើនទាំងឡាយ ធម្មតាទឹកជាវត្ថុគប្បីសន្សំ ពួកឯងកាលនឹងស្រោចទឹកដើមឈើ ត្រូវដកដើមឈើឡើងមើលឫស ដើមណាចាក់ឫសចូលជ្រៅ ត្រូវស្រោចទឹកច្រើន ដើមណាចាក់ឫសចូលទៅរាក់ ស្រោចតែបន្តិចបានហើយ ខាងក្រោយទឹករបស់យើងនឹងរកបានដោយលំបាក ។ ពួកស្វាក៏នាំគ្នាទទួលថា សាធុ ហើយនាំគ្នាធ្វើតាមនោះ ។ សម័យនោះ មានបុរសឈ្លាសវៃម្នាក់ឃើញពួកស្វាក្នុងរាជឧទ្យានទាំងនោះ នាំគ្នាធ្វើដូច្នេះ ក៏សួរថា នៃពានរទាំងឡាយ ហេតុអ្វីទើបពួកឯងដកដើមឈើដែលទើបតែដាំឡើង ហើយស្រោចទឹកតាមប្រមាណឫសយ៉ាងនេះទៅវិញ ? ពួកពានរតបថា ស្វាមេហ្វូងណែនាំឲ្យធ្វើយ៉ាងនេះ ។ បណ្ឌិតស្តាប់ពាក្យនោះហើយត្រិះរិះថា គួរឲ្យអាណិតណាស់ហ្ន៎ ស្វាល្ងង់ទាំងនេះ គិតថា នឹងធ្វើប្រយោជន៍ត្រឡប់ជាធ្វើហេតុដែលនាំឲ្យវិនាសទៅវិញ ហើយពោលគាថានេះថា

ន វេ អនត្ថកុសលេន អត្ថចរិយា សុខាវហា
ហាបេតិ អត្ថំ ទុម្មេធោ កបិ អារាមិកោ យថាតិ ។

ការប្រព្រឹត្តិនូវសេចក្ដីចម្រើន របស់អ្នកមិនឈ្លាសក្នុងហេតុចម្រើន រមែងមិននាំមកនូវសេចក្ដីសុខទេ បុគ្គលឥតប្រាជ្ញាតែងធ្វើប្រយោជន៍ឲ្យសាបសូន្យ ដូចស្វារក្សាសួន (បានធ្វើប្រយោជន៍ឲ្យវិនាស) ។

បណ្ដាបទទាំងនោះ បទថា វេ ត្រឹមតែជានិបាត ។

បទថា **អនត្ថកុសលេន** សេចក្ដីថា អ្នកឈ្លាសក្នុងហេតុដែលមិនមែនប្រយោជន៍ គឺក្នុងហេតុដែលមិនមែនជាប្រកពឲ្យកើតប្រយោជន៍ ឬបានដល់បុគ្គលដែលមិនឈ្លាសក្នុងប្រយោជន៍ គឺក្នុងហេតុដែលជាប្រកពឲ្យកើតប្រយោជន៍ ។

បទថា **អត្ថចរិយា** បានដល់ ការធ្វើសេចក្ដីចម្រើន ។

បទថា **សុខាវហា** សេចក្ដីថា បុគ្គលដែលមិនឈ្លាសក្នុងប្រយោជន៍បែបនេះ មិនអាចបំពេញប្រយោជន៍ ពោលគឺសេចក្ដីសុខផ្លូវកាយនិងសេចក្ដីសុខផ្លូវចិត្ត បានដល់ មិនអាចនឹងនាំសេចក្ដីសុខមកឲ្យបាន ។ ព្រោះហេតុអ្វី ? ព្រោះថា បុគ្គលឥតប្រាជ្ញារមែងធ្វើប្រយោជន៍ឲ្យសាប-សូន្យ បានដល់ បុគ្គលឥតបញ្ញា គិតថា អញនឹងបំពេញប្រយោជន៍ ក៏បានតែធ្វើប្រយោជន៍ឲ្យវិនាស តែងតែធ្វើអំពើដែលមិនមែនជាប្រយោជន៍ដោយចំណែកមួយប៉ុណ្ណោះ ។

បទថា **កបិ អារាមិកោ យថា** សេចក្ដីថា ស្វាដែលបាន

ទទួលតួនាទីមើលថែសួន ប្រកបកិច្ចការក្នុងសួន គិតថា អញនឹងធ្វើប្រយោជន៍ ក៏ធ្វើបានតែអំពើដែលមិនមែនជាប្រយោជន៍ប៉ុណ្ណោះ យ៉ាង-ណាមិញ បុគ្គលមិនឈ្លាសក្នុងប្រយោជន៍ក៏ដូច្នោះដែរ មិនអាចបំពេញនូវប្រយោជន៍នាំសេចក្ដីសុខមកឲ្យអ្នកណាបានឡើយ បានតែញ៉ាំងប្រយោជន៍ឲ្យវិនាសសាបសូន្យប៉ុណ្ណោះ ។ បណ្ឌិតនោះដាស់តឿនស្វាមេហ្វូងដោយគាថានេះហើយ ក៏នាំបរិស័ទរបស់ខ្លួនចេញចាកសួនទៅដោយប្រការដូច្នេះឯង ។

ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្មេងអ្នកស្រុកនេះ មិនមែនទើបតែប្រទូសរ៉ាយសួនក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ធ្លាប់ប្រទូសរ៉ាយសួនដែរ ។ លុះទ្រង់នាំព្រះ-ធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ស្វាមេហ្វូងក្នុងកាលនោះ បានមកជាក្មេងអ្នកស្រុកដែលប្រទូសរ៉ាយសួនក្នុងកាលឥឡូវនេះ ចំណែកបណ្ឌិត គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា អារាមទូសកជាតក ទី ៦ ។

# អដ្ឋកថា វារុណិទូសកជាតក ទី ៧

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអ្នកធ្វើសុរាឲ្យវិនាសម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា ន វេ អនត្ថកុសលេន ដូច្នេះជាដើម ។

បានឮថា ឈ្មួញសុរាដែលជាសម្លាញ់របស់អនាថបិណ្ឌិកសេដ្ឋីម្នាក់ ផ្សំសុរាមានរសឆ្ងាញ់លក់បានប្រាក់ជាច្រើន ។ កាលមហាជនប្រជុំគ្នាក្នុងរោងសុរាក៏ប្រាប់អ្នកបម្រើថា នែអ្នកទាំងឡាយ ពួកឯងចូរលក់តាមតម្លៃដែលគេទិញ ហើយក៏ចេញទៅងូតទឹក ។ អ្នកបម្រើនោះកាលលក់សុរាឲ្យមហាជន ឃើញមនុស្សទាំងនោះយកអំបិលមកខាំក្រែមជាចន្លោះៗ គិតថា ប្រហែលជាសុរានេះសាបហើយមើលទៅ លុះគិតដូច្នេះហើយ ក៏យកអំបិលដាក់ចូលទៅក្នុងសុរាប្រមាណមួយនាឡិ ហើយដួសសុរាលក់ឲ្យមនុស្សទាំងនោះ ។ មនុស្សទាំងនោះផឹកពេញមាត់ហើយព្រួសចោល នាំគ្នាចូលទៅសួរថា តើអ្នកដាក់អ្វីក្នុងស្រានេះ ? អ្នកបម្រើនោះឆ្លើយថា ខ្ញុំឃើញពួកលោកផឹកសុរាហើយ ហៅខ្ញុំយកអំបិលមកឲ្យហើយខាំស៊ីដូច្នេះ ខ្ញុំក៏ដាក់អំបិលចូលទៅក្នុងសុរា ។ មនុស្សទាំងនោះនាំគ្នាតិះដៀលអ្នកបម្រើថា នែបុរសល្ងង់ អ្នកធ្វើស្រាល្អយ៉ាងនេះឲ្យខូចអស់ហើយនាំគ្នាចៀសចេញទៅ ។ ម្ចាស់ហាងត្រឡប់មកពីងូតទឹកវិញ មិនឃើញអ្នកស៊ីផឹកសូម្បីតែម្នាក់ក៏សួរថា ពួកអ្នកផឹកសុរាទៅណាបាត់អស់ ?

អ្នកបម្រើនោះ ក៏ប្រាប់រឿងនោះឲ្យជ្រាប ។ គ្រានោះ អ្នកលក់សុរានោះ ក៏តិះដៀលថា នែបុរសល្ងង់ អ្នកធ្វើស្រាល្អឲ្យខូចអស់ តិះដៀលអ្នកបម្រើនោះបណ្ដើរនិយាយរឿងនោះប្រាប់អនាថបិណ្ឌិកសេដ្ឋីបណ្ដើរ ។ អនាថ-បិណ្ឌិកសេដ្ឋីត្រិះរិះថា ឥឡូវនេះ អញមានរឿងដែលជាមូលនៃកថាមគ្គ លុះគិតដូច្នេះហើយក៏ទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះបរមសាស្ដា ក្រាប-ទូលរឿងនោះឲ្យទ្រង់ជ្រាប ។ ព្រះបរមសាស្ដាត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអ្នកបម្រើនោះធ្វើសុរាឲ្យខូច សូម្បីកាលមុនក៏ធ្លាប់ធ្វើសុរាឲ្យខូចដែរ ។ កាលអនាថបិណ្ឌិកសេដ្ឋីក្រាប-ទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាសេដ្ឋីនគរពារាណសី ។ អ្នកលក់សុរាម្នាក់ចិញ្ចឹមជីវិតអាស្រ័យដោយការលក់សុរា ។ ថ្ងៃមួយ អ្នកលក់សុរានោះ លាយសុរាឲ្យមានរសជាតិខ្លាំងហើយក៏ប្រាប់អ្នកបម្រើឲ្យលក់សុរាជំនួសហើយក៏ចេញទៅងូតទឹក គ្រាន់តែម្ចាស់ដើរចេញទៅផុតភ្នាម អ្នកបម្រើនោះក៏យកអំបិលទៅដាក់ក្នុងសុរា ធ្វើឲ្យសុរាខូចអស់ដោយន័យដូចរឿងក្នុងបច្ចុប្បន្ន ។ លុះអ្នកលក់សុរាត្រឡប់មកវិញបានដឹងរឿង នោះហើយក៏ទៅប្រាប់សេដ្ឋីឲ្យជ្រាប ។ សេដ្ឋីពោលថា ធម្មតាបុគ្គលល្ងង់ខ្លៅមិនស្គាល់ប្រយោជន៍ គិតថានឹងធ្វើប្រយោជន៍ ត្រឡប់ធ្វើ

ឲ្យខូចប្រយោជន៍ដូច្នេះ លុះពោលដូច្នេះហើយ ក៏ពោលគាថានេះថា

ន វេ អនត្ថកុសលេន អត្ថចរិយា សុខាវហា
ហាបេតិ អត្ថំ ទុម្មេធោ កោណ្ឌញ្ញោ វារុណឹ យថាតិ ។

ការប្រព្រឹត្តិនូវសេចក្តីចម្រើនរបស់អ្នកមិនឈ្លាសក្នុងហេតុចម្រើន រមែងមិននាំមកនូវសេចក្តីសុខទេ បុគ្គលឥតប្រាជ្ញា តែងធ្វើប្រ-យោជន៍ឲ្យសាបសូន្យ ដូចកោណ្ឌញ្ញៈ បានញុំាងសុរាឲ្យវិនាស ។

បណ្តាបទទាំងនោះ បទថា **កោណ្ឌញ្ញោ វារុណឹ យថា** សេចក្តីថា កូនឈ្នួលរបស់អ្នកលក់សុរាម្នាក់នេះ ឈ្មោះកោណ្ឌញ្ញៈ គិតថា អញនឹងធ្វើប្រយោជន៍ ក៏ដាក់អំបិលចូលទៅក្នុងសុរា ធ្វើសុរាឲ្យខូចរស អស់តម្លៃ ត្រូវចាក់ចោល យ៉ាងណាមិញ បុគ្គលដែលមិនឈ្លាសក្នុងប្រយោជន៍ដទៃ ក៏ធ្វើប្រយោជន៍ឲ្យខូចដូច្នោះដែរ ។ ព្រះបរមពោធិសត្វសម្តែងធម៌ដោយគាថានេះ ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអ្នកបម្រើនេះធ្វើសុរាឲ្យវិនាសនោះ សូម្បីក្នុងកាលមុនក៏ធ្លាប់បានធ្វើសុរាឲ្យវិនាសដែរ ដូច្នេះហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា អ្នកដែលធ្វើសុរាឲ្យវិនាសក្នុងកាលនោះ បានមកជាអ្នកធ្វើសុរាឲ្យវិនាសក្នុងកាលនេះ ចំណែកសេដ្ឋីនគរពារាណសី គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា វារុណិទូសកជាតក ទី ៧ ។

# អដ្ឋកថា វេទព្ភជាតក ទី ៨

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អនុ-បាយេន យោ អត្ថំ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ព្រះបរមសាស្តាត្រាស់ទៅកាន់ភិក្ខុនោះថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអ្នកជាមនុស្សប្រដៅក្រនោះ សូម្បីក្នុងកាលមុនអ្នកក៏ជាមនុស្សប្រដៅក្រដែរ ព្រោះហេតុនោះទើបមិនធ្វើតាមពាក្យទូន្មានរបស់បណ្ឌិត ត្រូវកាប់ដោយដាវដាច់ជាពីរកំណាត់ដួលដេកនៅតាមផ្លូវ ហើយព្រោះតែអ្នកឯងម្នាក់ប៉ុណ្ណោះ អ្នកដទៃមួយពាន់នាក់ទៀតក៏ត្រូវអស់ជីវិតដែរ ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតកាលមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី មានព្រាហ្មណ៍ម្នាក់នៅក្នុងស្រុកមួយ ចេះមន្តឈ្មោះវេទព្ភៈ បានឮថាមន្តនោះមានតម្លៃកាត់ថ្លៃពុំបាន គួរបូជាក្រៃលែងណាស់ កាលបានឫក្សពេលាល្អហើយ អ្នកចេះមន្តនោះ រាយមន្តនោះ សម្លឹងមើលអាកាសហើយ ភ្លៀងរតនៈ៧ប្រការក៏ធ្លាក់ចុះមកអំពីអាកាស ។ គ្រានោះព្រះបរមពោធិសត្វរៀនសិល្បៈក្នុងសម្នាក់ព្រាហ្មណ៍នោះ ។ ថ្ងៃមួយព្រាហ្មណ៍បបួលព្រះបរមពោធិសត្វចេញចាកស្រុករបស់ខ្លួន ធ្វើដំណើរទៅ

កាន់ដែនចេតៈដោយធុរៈឯណានីមួយ ។ តាមផ្លូវដែលធ្វើដំណើរទៅនោះមានព្រៃមួយ មានចោរនៅក្នុងព្រៃនោះ ដែលហៅថាបេសនកចោរប្រមាណ ៥០០ នាក់ ជួបជុំគ្នាចាំស្ទាក់ផ្លូវប្លន់ ។ ចោរទាំងនោះចាប់ព្រះ-បរមពោធិសត្វនិងវេទព្វព្រាហ្មណ៍ទុក ។

តើព្រោះហេតុអ្វីទើបចោរទាំងនោះមានឈ្មោះថា បេសនកចោរ ? ព្រោះមានរឿងតំណាលមកថា ពួកចោរនោះចាប់បានមនុស្សពីរនាក់ហើយ ប្រើម្នាក់ឲ្យទៅយកប្រាក់មកឲ្យពួកវា ព្រោះហេតុនោះ ទើបមនុស្សទាំងឡាយហៅពួកចោរនោះថា បេសនកចោរ ។ ពួកចោរទាំងនោះពួនស្ទាក់ត្រង់បរិវេណព្រៃមួយកន្លែង ប្រសិនបើចាប់ឪពុកនិងកូនបាន ក៏និយាយនឹងឪពុកថា ចូរទៅយកទ្រព្យមកឲ្យយើង ហើយយកកូនទៅវិញចុះ ដោយរបៀបនេះជានិច្ច ។ ចាប់ម្ដាយនិងកូនស្រីបានហើយ ក៏ប្រើម្ដាយឲ្យទៅយកប្រាក់មកលោះកូនស្រី ចាប់បងនិងប្អូនបានហើយ ប្រើបងឲ្យយកប្រាក់មកលោះប្អូន ចាប់អាចារ្យនិងសិស្សបានហើយ ក៏ប្រើសិស្សឲ្យយកប្រាក់មកលោះអាចារ្យ គ្រានោះ ពួកចោរនោះចាប់វេទព្វ-ព្រាហ្មណ៍ទុក ហើយដោះលែងព្រះបរមពោធិសត្វឲ្យទៅ ។

ព្រះបរមពោធិសត្វលាអាចារ្យហើយពោលដាស់តឿនថា ខ្ញុំទៅតែពីរ-បីថ្ងៃប៉ុណ្ណោះ លោកអាចារ្យកុំភ័យខ្លាចឡើយ ម្យ៉ាងទៀត សូមធ្វើតាមពាក្យរបស់ខ្ញុំផងចុះ ថ្ងៃនេះ នឹងមានឫក្សល្អដែលនឹងអាចញ៉ាំងភ្លៀងគឺ

ទ្រព្យឲ្យធ្លាក់ចុះមក លោកត្រូវអត់ទ្រាំនឹងសេចក្ដីទុក្ខ កុំរាយមន្តឲ្យមាសប្រាក់ធ្លាក់មកឲ្យសោះ ប្រសិនបើលោកធ្វើឲ្យភ្លៀងមាសភ្លៀងប្រាក់ធ្លាក់ចុះមកនោះ លោកនឹងដល់នូវសេចក្ដីវិនាស ចោរ ៥០០ នាក់នេះនឹងសម្លាប់លោកមិនខាន លុះដាស់តឿនយ៉ាងនេះហើយក៏ធ្វើដំណើរទៅយកទ្រព្យមក ។ ចំណែកពួកចោរលុះព្រះអាទិត្យអស្តង្គតក៏ចងព្រាហ្មណ៍នោះឲ្យដេកផើបមិនរួច ។ គ្រានោះឯង ចន្ទមណ្ឌលដ៏បរិបូណ៌ក៏រះឡើងអំពីទិសខាងកើត ព្រាហ្មណ៍សម្លឹងឃើញនក្ខត្តឫក្សក៏គិតឃើញថា បានឫក្សដែលនឹងធ្វើឲ្យភ្លៀងមាសភ្លៀងប្រាក់ធ្លាក់ចុះមកហើយ អញចាំបាច់សោយទុក្ខយ៉ាងនេះធ្វើអ្វី រាយមន្តឲ្យភ្លៀងរតនៈធ្លាក់ចុះមក យកទ្រព្យឲ្យពួកចោរហើយ ក៏នឹងបានជាឥស្សរៈធ្វើដំណើរទៅតាមសប្បាយ លុះគិតដូច្នេះហើយក៏ហៅពួកចោរមកសួរថា នែចោរដ៏ចម្រើនទាំងឡាយ ពួកអ្នកចាប់ខ្ញុំទុកដើម្បីអ្វី ?

ពួកចោរឆ្លើយថា ដើម្បីទ្រព្យសម្បត្តិ ។

ព្រាហ្មណ៍ក៏ពោលថា នែចោរដ៏ចម្រើនទាំងឡាយ ប្រសិនបើពួកអ្នកត្រូវការទ្រព្យ ចូរប្រញាប់ស្រាយចំណងខ្ញុំ ឲ្យខ្ញុំងូតទឹក កក់ក្បាលស្លៀកសំពត់ស ប្រស់ព្រំខ្លួនដោយគ្រឿងក្រអូប ប្រដាប់ដោយកម្រងផ្កាហើយឃុំខ្លួនខ្ញុំទុកចុះ ។ ពួកចោរស្ដាប់ពាក្យរបស់ព្រាហ្មណ៍នោះហើយក៏ធ្វើតាមគ្រប់យ៉ាង ។ ព្រាហ្មណ៍ដឹងឫក្សហើយក៏រាយមន្ត សម្លឹងមើល

អាកាស ភ្លាមនោះឯង រតនៈទាំងឡាយក៏ធ្លាក់មកអំពីអាកាស ។ ពួកចោរក៏នាំគ្នាកើបយកទ្រព្យដាក់ក្នុងសំពត់ ហើយនាំគ្នាចៀសចេញទៅ ។ សូម្បីព្រាហ្មណ៍ក៏ទៅតាមពួកចោរដែរ ។ គ្រានោះ មានចោរមួយក្រុមដទៃទៀត មានគ្នាចំនួន ៥០០ នាក់ដែរ នាំគ្នាចាប់ចោរទាំងនោះ ។ កាលពួកចោរដែលត្រូវចាប់សួរថា អ្នកទាំងឡាយចាប់ពួកយើងដើម្បីអ្វី?

ពួកចោរនោះក៏ឆ្លើយថា ព្រោះត្រូវការទ្រព្យ ។

ពួកចោរដែលត្រូវចាប់ក៏ប្រាប់ថា ប្រសិនបើពួកអ្នកត្រូវការទ្រព្យ ចូរចាប់ព្រាហ្មណ៍នេះទុកចុះ គាត់សម្លឹងមើលអាកាសហើយធ្វើទ្រព្យឲ្យធ្លាក់ចុះមកបាន ទ្រព្យរបស់ពួកយើងនេះ គាត់ជាអ្នកឲ្យទាំងអស់ ពួកចោរក៏លែងចោរដែលចាប់ទុកនោះ ហើយឃុំខ្លួនព្រាហ្មណ៍ទុកដោយពោលពាក្យថា ចូរលោកឲ្យទ្រព្យដល់ពួកយើងខ្លះ ។

ព្រាហ្មណ៍ពោលថា ខ្ញុំអាចឲ្យទ្រព្យដល់ពួកអ្នកបាន តែឫក្សដែលនឹងហៅទ្រព្យឲ្យធ្លាក់ចុះមកបាននោះ ត្រូវចាំមួយឆ្នាំទៀត ប្រសិនបើពួកអ្នកត្រូវការទ្រព្យ ត្រូវរង់ចាំដល់ពេលនោះ ខ្ញុំនឹងហៅភ្លៀងទ្រព្យឲ្យធ្លាក់ចុះមកបាន ។ ពួកចោរក្រោធខឹងហើយនិយាយថា នែមនុស្សអាក្រក់ត្រង់អ្នកដទៃឯងហៅភ្លៀងប្រាក់ភ្លៀងមាសឲ្យធ្លាក់ចុះមក ឯពួកយើងប្រាប់ឲ្យរង់ចាំមួយឆ្នាំ ដូច្នេះហើយ កាប់ព្រាហ្មណ៍នោះជាពីរកំណាត់ដោយដាវដ៏មុតបោះចោលតាមផ្លូវ នាំគ្នាដេញតាមពួកចោរទាំងនោះ

យ៉ាងលឿន សម្លាប់ចោរទាំងនោះអស់ហើយដណ្ដើមយកទ្រព្យទៅ បែកគ្នាជាពីរពួក សម្លាប់គ្នាឯងស្លាប់អស់ ២៥០ នាក់ ហើយក៏បែកគ្នាទៀត សម្លាប់គ្នាទៀតដោយរបៀបនេះ ទីបំផុតសល់តែពីរនាក់ ហើយសម្លាប់គ្នាឯងស្លាប់អស់ទៀត ពួកចោរមួយពាន់នាក់ដល់នូវសេចក្ដីវិនាសដោយប្រការដូច្នេះ ។

ចោរទាំងពីរដែលនៅសល់ ដណ្ដើមយកទ្រព្យនោះមកបានដោយឧបាយនោះ នាំគ្នាយកទៅលាក់ទុកក្នុងគុម្ពោតព្រៃមួយកន្លែង ចោរម្នាក់កាន់កាំបិតអង្គុយចាំ ម្នាក់យកអង្ករចូលទៅកាន់ស្រុកដើម្បីដាំបាយ ដែលឈ្មោះថាការលោភជាឫសគល់នៃសេចក្ដីវិនាស ព្រោះហេតុនោះ ចោរម្នាក់ដែលអង្គុយចាំទ្រព្យនោះគិតថា កាលចោរនោះមក ទ្រព្យនេះក៏ត្រូវចែកជាពីរចំណែក កុំដូច្នោះឡើយ កាលណាវាមកអញនឹងកាប់ឲ្យស្លាប់ដោយកាំបិតនេះក៏ចប់រឿង លុះគិតដូច្នេះហើយក៏សៀតកាំបិតអង្គុយរង់ចាំចោរម្នាក់នោះមក ។ ចំណែកចោរម្នាក់ទៀតក៏គិតថា ទ្រព្យនេះនឹងត្រូវចែកជាពីរចំណែក បើដូច្នេះអញយកថ្នាំពុលដាក់ក្នុងអាហារឲ្យចោរនោះស៊ីឲ្យអស់ជីវិត ហើយអញគ្រប់គ្រងទ្រព្យតែម្នាក់ឯង លុះគិតដូច្នេះហើយ កាលបាយឆ្អិនក៏ប្រញាប់ស៊ីមុន ចំណែកដែលសល់ដាក់ថ្នាំពុលកាន់ដើរមកកន្លែងដែលចោរម្នាក់ទៀតអង្គុយរង់ចាំ គ្រាន់តែដាក់អាហារចុះភ្លាម ចោរម្នាក់ដែលអង្គុយរង់ចាំនោះ កាប់ដោយកាំបិតដាច់ជា

ពីរកំណាត់ យកទៅបោះចោលក្នុងគុម្ពោតព្រៃហើយត្រឡប់មកបរិភោគអាហារនោះ ក៏អស់ជីវិតក្នុងទីនោះឯង ។ ចោរទាំងអស់ដល់នូវសេចក្ដីវិនាសព្រោះអាស្រ័យទ្រព្យដោយប្រការដូច្នេះ ។

លុះកន្លងទៅបានពីរ-បីថ្ងៃ ព្រះបរមពោធិសត្វក៏កាន់ទ្រព្យមក មិនឃើញអាចារ្យនៅទីនោះ ឃើញតែទ្រព្យខ្ចាត់ខ្ចាយ ក៏គិតថា អាចារ្យមិនជឿពាក្យរបស់អញ ប្រហែលជាហៅទ្រព្យឲ្យធ្លាក់ចុះមកមិនខាន គ្រប់គ្នាត្រូវដល់នូវសេចក្ដីវិនាសទាំងអស់ ដូច្នេះហើយ ក៏ដើរទៅកាន់ផ្លូវធំ ។ កាលដើរទៅដល់ក៏ឃើញអាចារ្យត្រូវកាប់ដាច់ជាពីរកំណាត់ ព្រះបរម-ពោធិសត្វគិតថា អាចារ្យត្រូវមកស្លាប់យ៉ាងនេះព្រោះមិនជឿពាក្យរបស់អញ ហើយក៏រកឧសមកគរជាជើងថ្ករដុតសាកសពអាចារ្យ ។ បូជាដោយផ្កាឈើព្រៃ ហើយដើរតទៅទៀត ឃើញចោរ ៥០០ នាក់ស្លាប់ ដើរតទៅទៀត ឃើញចោរ ២៥០ នាក់ស្លាប់ដោយលំដាប់ ទីបំផុតមិនឃើញចោរទាំងពីរស្លាប់ ក៏គិតថា មនុស្សដែលដល់នូវសេចក្ដីវិនាសនោះ មួយពាន់នាក់ខ្វះពីរនាក់ប្រាកដជានៅមានចោរពីរនាក់ទៀត ហើយចោរពីរនាក់ទៀតមិនរួចខ្លួនឡើយ ចោរពីរនាក់នោះទៅទីណាហ្ន៎ លុះគិតដូច្នេះហើយក៏ដើរទៅមុខទៀត ឃើញផ្លូវចូលទៅកន្លែងលាក់ទ្រព្យរបស់ចោរទាំងពីរនាក់នោះ ដើរទៅទៀតក៏ឃើញបង្វេចទ្រព្យ បានឃើញចោរម្នាក់ស្លាប់នៅជិតថាសបាយ ។ គ្រានោះ ព្រះបរមពោធិសត្វក៏ស្មានដឹងហេតុទាំងអស់

ថា ពួកចោរនោះបានធ្វើយ៉ាងណា ហើយក៏គិតថា ចោរនោះនៅទីណាហ្ន៎ រកមើលក៏ឃើញចោរម្នាក់នោះត្រូវកប់ក្នុងទីនោះ ក៏គិតថា អាចារ្យរបស់អញមិនធ្វើតាមពាក្យទូន្មាន ព្រោះតែខ្លួនជាមនុស្សប្រដៅក្រ សូម្បីខ្លួនឯងក៏ដល់នូវសេចក្ដីវិនាស មិនតែប៉ុណ្ណោះធ្វើឲ្យអ្នកដទៃមួយពាន់នាក់ទៀត ដល់នូវសេចក្ដីវិនាសយ៉ាងអនាថា បុគ្គលដែលប្រាថ្នានូវសេចក្ដីចម្រើនដល់ខ្លួនដោយហេតុដែលមិនមែនជាឧបាយ នឹងដល់នូវសេចក្ដីវិនាសដ៏ធំដូចអាចារ្យរបស់អញដល់នូវសេចក្ដីវិនាសដូច្នោះ ហើយពោលគាថានេះថា

**អនុបាយេន យោ អត្ថំ ឥច្ឆតិ សោ វិហញ្ញតិ**
**ចេតា ហនឹសុ វេទព្ភំ សព្វេ តេ ព្យសនមជ្ឈគុន្តិ ។**

បុគ្គលណា ប្រាថ្នាសេចក្ដីចម្រើនដោយខុសឧបាយ បុគ្គលនោះរមែងលំបាក ដូចពួកចោរនៅក្នុងដែនចេតៈ បានសម្លាប់នូវវេទព្វព្រាហ្មណ៍ ចោរទាំងអស់នោះ ក៏ដល់នូវសេចក្ដីវិនាស ។

បណ្ដាបទទាំងនោះ បទថា **សោ វិហញ្ញតិ** សេចក្ដីថា បុគ្គលណាគិតថា យើងប្រាថ្នាប្រយោជន៍ គឺសេចក្ដីចម្រើន សេចក្ដីសុខដល់ខ្លួន ធ្វើសេចក្ដីព្យាយាមដោយហេតុដែលមិនមែនជាឧបាយ ក្នុងសម័យដែលមិនមែនកាល រមែងក្ដៅក្រហាយគឺលំបាក បានដល់នូវសេចក្ដីវិនាសយ៉ាងធំ ។

*បទថា* **ចេតា** *បានដល់ ពួកចោរដែលនៅក្នុងដែនចេតរដ្ឋ ។*

*បទថា* **ហនឹសុ វេទព្វំ** *សេចក្ដីថា ពួកចោរនៅក្នុងចេតរដ្ឋព្រួតដៃគ្នាសម្លាប់ព្រាហ្មណ៍ដែលមានឈ្មោះថា វេទព្វៈ ព្រោះចេះមន្តវេទព្វៈ ។*

*បទថា* **សព្វេ តេ ព្យសនមជ្ឈគុំ** *សេចក្ដីថា សូម្បីចោរទាំងអស់នោះ ក៏សម្លាប់គ្នាឯងឲ្យស្លាប់អស់ដោយមិនសល់ម្នាក់ ។*

*កាលមានហេតុដូច្នេះ ព្រះបរមពោធិសត្វក៏ប្រកាសកង់រំពងទូទាំងព្រៃថា អាចារ្យរបស់យើងធ្វើសេចក្ដីព្យាយាមក្នុងរឿងដែលមិនមែនជាឋានៈ ដោយហេតុមិនត្រូវទំនង ដោយឧបាយមិនប្រពៃ ហៅទ្រព្យឲ្យធ្លាក់ចុះមក សូម្បីខ្លួនឯងក៏អស់ជីវិត ទាំងជាបច្ច័យនៃសេចក្ដីវិនាសដល់អ្នកដទៃ មួយពាន់នាក់ទៀត យ៉ាងណាមិញ សូម្បីអ្នកដទៃៗ ដែលប្រាថ្នានូវប្រយោជន៍ដើម្បីខ្លួន ធ្វើសេចក្ដីព្យាយាមដោយឧបាយមិនប្រពៃ បុគ្គលទាំងនោះនឹងវិនាសខ្លួនឯងផង ជាបច្ច័យនៃសេចក្ដីវិនាសដល់អ្នកដទៃផងដូច្នេះ ។ កាលពួកទេវតាឲ្យពរសព្ទសាធុការហើយ ក៏សម្ដែងធម៌ដោយគាថានេះ នាំទ្រព្យនោះមកផ្ទះរបស់ខ្លួនដោយឧបាយដ៏ប្រពៃ ធ្វើបុណ្យមានទានជាដើម លុះអស់ជីវិតក៏បានធ្វើសួគ៌ទេវលោកឲ្យបរិបូណ៌ឡើង ។*

*ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអ្នកជាមនុស្សប្រដៅក្រនោះ សូម្បីក្នុងកាលមុនក៏ជាមនុស្សប្រដៅក្រដែរ ព្រោះភាពជាបុគ្គលប្រដៅក្រ ទើបដល់*

*នូវសេចក្ដីវិនាសយ៉ាងធំ ដូច្នេះ ។ លុះទ្រង់នាំព្រះធម្មទេសនានេះមក ហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា វេទព្វព្រាហ្មណ៍ក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាលឥឡូវនេះ ចំណែកសិស្ស គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា វេទព្វជាតក ទី ៨ ។

# អដ្ឋកថា នក្ខត្តជាតក ទី ៩

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ អាជីវកម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **នក្ខត្តំ បដិមានេន្តំ** *ដូច្នេះជាដើម ។*

*បានឮថា កុលបុត្តអ្នកស្រុកក្រៅម្នាក់ទៅដណ្ដឹងកុលធីតាដែល នៅក្នុងក្រុងសាវត្ថីម្នាក់ឲ្យកូនប្រុសរបស់ខ្លួន ដាក់ថ្ងៃថាក្នុងថ្ងៃឯណោះនឹង មកទទួលយកកូនក្រមុំទៅ លុះដល់ថ្ងៃកំណត់ក៏សួរអាជីវក អ្នកចូលទៅ កាន់ត្រកូលរបស់ខ្លួនថា បពិត្រលោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះពួកខ្ញុំនឹងធ្វើ មង្គលម្យ៉ាង តើថ្ងៃនេះជាថ្ងៃល្អដែរទេ ? អាជីវកនោះក្រោធហើយគិតថា ពួកនេះកាលពីដំបូងមិនសួរអញទេ លុះដល់ថ្ងៃទៅយកកូនក្រមុំមកទើប សួរ ណ្ហើយចុះ អញនឹងប្រដៅពួកគេម្ដង ទើបនិយាយថា ថ្ងៃនេះជាថ្ងៃ មិនល្អទេ ពួកអ្នកកុំធ្វើមង្គលក្នុងថ្ងៃនេះឡើយ ប្រសិនបើនៅតែធ្វើនឹង*

វិនាសធំ ។ ពួកមនុស្សក្នុងត្រកូលនាំគ្នាជឿអាជីវកមិនទៅទទួលកូនក្រមុំក្នុងថ្ងៃនោះ ។ ចំណែកពួកអ្នកក្រុងសាវត្ថីបានចាត់ចែងមង្គលទុកហើយ មិនឃើញជនទាំងនោះមក ក៏ពោលថា ជនទាំងនោះកំណត់ថ្ងៃហើយក៏មិនមក ចំណែកមង្គលការរបស់ពួកយើងក៏ជិតសម្រេចហើយ រឿងអ្វីនឹងត្រូវរង់ចាំជនទាំងនោះ យើងនឹងលើកធីតារបស់យើងឲ្យអ្នកដទៃ ហើយក៏លើកធីតារបស់ខ្លួនឲ្យទៅត្រកូលដទៃ ដោយមង្គលដែលត្រៀមទុកនោះឯង ។ លុះថ្ងៃស្អែកឡើង ពួកមនុស្សខាងកូនកំលោះក៏មកដល់ហើយពោលថា ពួកអ្នកចូរឲ្យកូនក្រមុំមកពួកយើងចុះ ភ្លាមនោះឯង ពួកអ្នកក្រុងសាវត្ថីក៏នាំគ្នាជេរពួកនោះថា ពួកអ្នកសមនឹងឈ្មោះថាជាមនុស្សស្រុកក្រៅ មិនមានភាពជាមនុស្សល្អទេ ជាមនុស្សលាមក កំណត់ថ្ងៃទុកហើយមើលងាយ មិនមកតាមថ្ងៃកំណត់ អញ្ជើញមកតាមផ្លូវណាត្រឡប់ទៅវិញតាមផ្លូវនោះចុះ ពួកយើងលើកកូនស្រីឲ្យអ្នកដទៃហើយ ។ ពួកអ្នកស្រុកក្រៅក៏ឈ្លោះប្រកែកនឹងពួកអ្នកក្រុង លុះមិនបានកូនក្រមុំក៏នាំគ្នាទៅតាមផ្លូវដែលមកនោះឯង ។ រឿងដែលអាជីវកធ្វើឲ្យអន្តរាយដល់មង្គលរបស់មនុស្សទាំងនោះ បានដឹងដល់ភិក្ខុទាំងឡាយ ហើយភិក្ខុទាំងនោះប្រជុំគ្នាក្នុងធម្មសភាសន្ទនាគ្នាថា អ្នកមានអាយុទាំងឡាយ អាជីវកធ្វើឲ្យអន្តរាយដល់មង្គលនៃត្រកូល ។ ព្រះបរមសាស្តា ស្តេចយាងមកទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយ

សន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ លុះភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអាជីវកធ្វើឲ្យអន្តរាយដល់មង្គលនៃត្រកូលនោះ សូម្បីក្នុងកាលមុនក៏ក្រោធខឹងនឹងមនុស្សទាំងនោះ ធ្វើអន្តរាយដល់មង្គលហើយដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី អ្នកនគរនាំគ្នាទៅដណ្ដឹងធីតានៃអ្នកជនបទ កំណត់ថ្ងៃហើយសួរអាជីវកដែលស្និទ្ធស្នាលនឹងខ្លួនថា បពិត្រលោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះពួកខ្ញុំនឹងធ្វើមង្គលមួយ តើថ្ងៃនេះជាថ្ងៃល្អទេ? អាជីវកនោះក្រោធហើយគិតថា ពួកនេះកំណត់ថ្ងៃយកតាមការពេញចិត្តរបស់ខ្លួន លុះដល់ថ្ងៃទៅយកកូនក្រមុំមកទើបសួរអញ គិតតទៅទៀតថា ថ្ងៃនេះអញនឹងជំទាស់ពិធីមង្គលនៃពួកនេះ លុះគិតដូច្នេះហើយក៏ពោលថា ថ្ងៃនេះជាថ្ងៃមិនល្អទេ ប្រសិនបើពួកអ្នកនៅតែរឹងទទឹងធ្វើពិធីមង្គលនោះ ពួកអ្នកនឹងជួបប្រសព្វនូវវិនាសធំ ។ មនុស្សទាំងនោះជឿអាជីវកនោះ ទើបមិនទៅទទួលកូនក្រមុំ ។ អ្នកជនបទដឹងថាជនទាំងនោះមិនមក ក៏និយាយគ្នាថា ជនទាំងនោះកំណត់ថ្ងៃទុកហើយ មិនមកតាមថ្ងៃកំណត់ រឿងអ្វីត្រូវនៅរង់ចាំជនទាំងនោះទៀត ហើយក៏លើកធីតារបស់ខ្លួនឲ្យអ្នកដទៃ ។ ស្អែកឡើង អ្នកក្រុងមកសុំកូនក្រមុំ អ្នកជនបទក៏នាំគ្នាពោលថា ពួកអ្នក

ជាអ្នកក្រុង ប៉ុន្តែខ្វះភាពជាមនុស្សល្អ កំណត់ថ្ងៃទុកហើយបែរជាមិនមកទទួលកូនក្រមុំតាមថ្ងៃកំណត់ ព្រោះតែពួកអ្នកមិនមក ទើបពួកយើងលើកកូនស្រីរបស់ពួកយើងឲ្យដល់អ្នកដទៃ ។ អ្នកក្រុងពោលថា ពួកយើងសូមឲ្យអាជីវកមើលឫក្សពារល្អ ឬក៏មិនល្អ អាជីវកបានប្រាប់ពួកយើងថា ថ្ងៃនេះជាថ្ងៃមិនល្អទេ ទើបពួកយើងមិនមកតាមការកំណត់ទុក ដូច្នេះសូមពួកអ្នកឲ្យកូនក្រមុំដល់ពួកយើងចុះ ។ ពួកអ្នកជនបទជំទាស់ថាព្រោះតែពួកអ្នកមិនមក ទើបពួកយើងលើកកូនស្រីឲ្យអ្នកដទៃ ឥឡូវនេះនឹងនាំកូនស្រីដែលឲ្យគេទៅហើយនោះ មកវិញម្ដេចបាន ។ កាលមនុស្សទាំងនោះប្រកែកគ្នាយ៉ាងនេះ មានបុរសដែលជាបណ្ឌិតអ្នកក្រុងម្នាក់ទៅកាន់ជនបទដោយកិច្ចការឯណានីមួយ បានឮពួកអ្នកក្រុងពោលថា ពួកយើងសួរអាជីវកហើយទើបមិនមក ព្រោះថ្ងៃមិនល្អ ក៏និយាយថា ថ្ងៃមានប្រយោជន៍អ្វី ព្រោះការបានកូនក្រមុំក៏ជាឫក្សហើយ មិនមែនឬ? ដូច្នេះ ហើយ ពោលគាថានេះថា

**នក្ខត្តំ បដិមានេន្តំ អត្ថោ ពាលំ ឧបច្ចគា**
**អត្ថោ អត្ថស្ស នក្ខត្តំ កឹ ករិស្សន្តិ តារកាតិ ។**

ប្រយោជន៍រមែងកន្លងបង់នូវមនុស្សល្ងង់ ដែលរាប់អាននក្ខត្តឫក្ស (ព្រោះ) សេចក្ដីចម្រើននៃប្រយោជន៍ ឈ្មោះថានក្ខត្តឫក្ស ឯផ្កាយទាំងឡាយនឹងធ្វើអ្វីបាន ។

*បណ្ដាបទទាំងនោះ បទថា* **បដិមានេន្តំ** *សេចក្ដីថា អ្នករង់ចាំមើល អធិប្បាយថា រវល់តែរង់ចាំមើលថា នក្ខត្តឫក្សនឹងមានក្នុងពេលឥឡូវនេះៗ ។*

*បទថា* **អត្ថោ ពាលំ ឧបច្ចគា** *សេចក្ដីថា ប្រយោជន៍ ពោលគឺការបានកូនក្រមុំ កន្លងបង់នូវបុគ្គលល្ងង់ដូចអ្នកក្រុងនេះ ។*

*បទថា* **អត្ថោ អត្ថស្ស នក្ខត្តំ** *សេចក្ដីថា បុគ្គលស្វែងរកប្រយោជន៍ណា ប្រយោជន៍ដែលគេបានហើយនោះឯង ឈ្មោះថានក្ខត្តឫក្សនៃប្រយោជន៍ ។*

*បទថា* **កឹ ករិស្សន្តិ តារកា** *សេចក្ដីថា ផ្កាយទាំងឡាយក្នុងអាកាសក្រៅពីនេះ នឹងញុំាងប្រយោជន៍អ្វីខ្លះឲ្យសម្រេចបាន ។*

*ពួកអ្នកក្រុងឈ្មោះនឹងពួកអ្នកជនបទហើយ មិនបានកូនក្រមុំ ក៏នាំគ្នាត្រឡប់ទៅវិញ ។*

*ព្រះបរមសាស្ដាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះតែប៉ុណ្ណោះទេ ដែលអាជីវកនោះជំទាស់នឹងពិធីមង្គលនៃត្រកូលនោះ សូម្បីក្នុងកាលមុនក៏បានធ្វើហើយដែរ ។ លុះទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា អាជីវកក្នុងកាលនោះ បានមកជាអាជីវកក្នុងកាលឥឡូវនេះ សូម្បីត្រកូលទាំងនោះក្នុងកាលនោះ ក៏បានមកជាត្រកូលក្នុងកាលឥឡូវនេះ*

ចំណែកបុរសដែលជាបណ្ឌិតឈរពោលគាថាក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា នក្ខត្តជាតក ទី ៩ ។

# អដ្ឋកថា ទុម្មេធជាតក ទី ១០

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ **លោកត្ថចរិយា** គឺការបំពេញប្រយោជន៍ដល់សត្វលោក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ទុម្មេធានំ** ដូច្នេះជាដើម ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងព្រះគភ៌នៃព្រះអគ្គមហេសីរបស់ព្រះរាជាអង្គនោះ លុះប្រសូតចាកព្រះគភ៌ព្រះមាតាហើយ ព្រះញាតិបានថ្វាយព្រះនាមថា ព្រហ្មទត្តកុមារ លុះមានព្រះជន្ម ១៦ ព្រះវស្សា ទ្រង់សិក្សាសិល្បៈក្នុងក្រុងតក្កសិលា ចប់ត្រៃវេទនិងសម្រេចសិល្បសាស្ត្រ ១៨ ប្រការ ។ ក្រោយមកព្រះរាជបិតាទ្រង់ព្រះរាជទានតំណែងឧបរាជឲ្យព្រះអង្គ ។ ក្នុងគ្រានោះ មហាជននៅក្នុងនគរពារាណសីរាប់អានទេវតា នាំគ្នាគោរពទេវតា សម្លាប់ពពែ ចៀម មាន់ និងជ្រូកជាដើមយ៉ាងច្រើន បួងសួងដោយផ្កានិងគ្រឿងក្រអូបផ្សេងៗ និងដោយសាច់និងឈាម ។ ព្រះបរមពោធិសត្វទ្រង់ត្រិះរិះថា ឥឡូវនេះ ប្រជា-

រាស្ត្ររាប់អានទេវតា គោរពទេវតាថាជាវត្ថុដ៏ប្រសើរ នាំគ្នាសម្លាប់សត្វ មហាជនជឿស៊ប់ក្នុងអធម៌តែម្យ៉ាងដោយច្រើន បើអញបានទទួលរាជ-សម្បត្តិក្រោយអំពីព្រះរាជបិតាសោយទិវង្គតទៅ អញនឹងមិនឲ្យសត្វសូម្បីតែមួយដល់នូវសេចក្ដីលំបាក ដូច្នេះអញត្រូវរកឧបាយមិនឲ្យបុគ្គលណាមួយសម្លាប់សត្វ ឲ្យខាងតែបាន ។ ថ្ងៃមួយព្រះអង្គទ្រង់ឡើងរថ ស្ដេចចេញចាកនគរ ទតឃើញមហាជនប្រជុំគ្នានៅក្រោមដើមជ្រៃធំមួយដើម ប្រាថ្នាចង់បានវត្ថុណាៗ ក្នុងបណ្ដាវត្ថុទាំងឡាយដូចជា កូនប្រុស កូនស្រី យសនិងទ្រព្យជាដើម ក៏នាំគ្នាបួងសួងក្នុងសម្នាក់ទេវតាដែលបិតនៅនឹងដើមជ្រៃនោះ ទើបព្រះអង្គស្ដេចចុះចាករថទ្រង់យាងចូលទៅជិតដើមជ្រៃនោះ ទ្រង់បូជាដោយផ្កាកម្រងនិងគ្រឿងក្រអូប ប្រទក្សិណដើមជ្រៃនោះ ដូចពួកដែលរាប់អានទេវតាជាព្រះ ថ្វាយបង្គំទេវតាហើយ ស្ដេចក្រោកឡើងទ្រង់រថត្រឡប់ចូលនគរវិញ ។ តាំងពីនោះមក ស្ដេចយាងទៅកាន់ដើមជ្រៃនោះ គ្រប់ៗពេលដែលទំនេរ ទ្រង់បូជាដូចជាអ្នករាប់អានទេវតា ដូចពណ៌នាមកហើយនោះ ។

សម័យថ្ងៃក្រោយមក ព្រះរាជបិតាសោយទិវង្គតព្រះបរមពោធិសត្វក៏បានសោយរាជ្យដោយទ្រង់វៀរអគតិ ៤ ប្រការ ទ្រង់ប្រព្រឹត្តទសពិធ-រាជធម៌ដ៏តឹងរ៉ឹងបំផុត ទ្រង់គ្រប់គ្រងរាជ្យដោយធម៌ ទ្រង់ព្រះតម្រិះថា មនោរថរបស់អញដល់ទីបំផុតហើយ អញតាំងនៅក្នុងរាជសម្បត្តិហើយ

គំនិតដែលអញគិតទុកក្នុងកាលមុននោះ ក៏នឹងត្រូវធ្វើឲ្យដល់ទីបំផុតក្នុងកាលឥឡូវនេះ ទើបទ្រង់ឲ្យហៅពួកអាមាត្យនិងមហាជន មានព្រាហ្មណ៍និងគហបតីជាដើមមកប្រជុំគ្នាហើយទ្រង់ប្រកាសថា នែអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយដឹងទេថា ហេតុអ្វីទើបយើងបានរាជសម្បត្តិ ?

មហាជននាំគ្នាក្រាបទូលថា បពិត្រមហារាជ ពួកទូលបង្គំទាំងឡាយមិនជ្រាបទេ ។

ព្រះរាជាក៏ត្រាស់សួរថា កាលយើងបូជាដើមជ្រៃមួយដើមឯណោះដោយគ្រឿងក្រអូបជាដើម ផ្គងអញ្ជលីសំពះ តើពួកអ្នកបានឃើញឬទេ ?

មហាជនក្រាបទូលថា បពិត្រមហារាជ ពួកទូលបង្គំបានឃើញដែរ ។

ព្រះរាជាមានព្រះរាជតម្រាស់តទៅទៀតថា ក្នុងគ្រានោះ យើងបានប្រាថ្នាថា ប្រសិនបើបានរាជសម្បត្តិនឹងធ្វើពលិកម្ម យើងបានរាជសម្បត្តិនេះ ដោយអនុភាពនៃទេវតានោះ ឥឡូវនេះ យើងនឹងធ្វើពលិកម្មចំពោះទេវតា ពួកអ្នកកុំយឺតយូរឡើយ នាំគ្នាត្រៀមពលិកម្មចំពោះទេវតាឲ្យឆាប់ៗ ចុះ ។

ពួកអាមាត្យជាដើមទូលសួរថា បពិត្រមហារាជ ពួកទូលបង្គំត្រូវចាត់ចែងវត្ថុអ្វីខ្លះ ?

ព្រះរាជាត្រាស់ថា នែអ្នកទាំងឡាយ កាលយើងបួងសួងទេវតា

*យើងបានអង្វរករថា ខ្ញុំនឹងសម្លាប់ពួកមនុស្សដែលនាំគ្នាប្រព្រឹត្តនូវអំពើនៃមនុស្សទ្រុស្តសីល ៥ ប្រការ មានសម្លាប់សត្វជាដើម និងពួកមនុស្សដែលប្រព្រឹត្តអកុសលកម្មបថ ១០ ក្នុងរជ្ជកាលនៃខ្ញុំ ហើយនឹងធ្វើពលិកម្មដោយពោះវៀន ឈាម សាច់នៃមនុស្សទាំងនោះ ព្រោះហេតុដូច្នោះ ពួកអ្នកចូរវាយគងប្រកាសក្នុងនគរថា ព្រះរាជារបស់ពួកយើងកាលនៅជាឧបរាជ ទ្រង់បួងសួងទេវតាទុកយ៉ាងនេះថា ប្រសិនបើបានគ្រប់គ្រងរាជ-សម្បត្តិ នឹងបញ្ជាឲ្យសម្លាប់មនុស្សទ្រុស្តសីលក្នុងរជ្ជកាលរបស់ព្រះអង្គឲ្យអស់ ហើយធ្វើពលិកម្ម ឥឡូវនេះ ព្រះអង្គមានព្រះរាជបំណងនឹងបញ្ជាឲ្យសម្លាប់មនុស្សដែលទ្រុស្តសីលចំនួនមួយពាន់នាក់ ហើយឲ្យយកគ្រឿងក្នុងមានបេះដូងជាដើមរបស់មនុស្សទាំងនោះទៅធ្វើពលិកម្មចំពោះទេវតា អ្នកនគរទាំងឡាយចូរដឹងយ៉ាងនេះចុះ ។ លុះត្រាស់យ៉ាងនេះហើយ ទ្រង់ប្រកាសព្រះរាជបំណងថា ចាប់តាំងពីពេលនេះតទៅ យើងនឹងត្រូវសម្លាប់មនុស្សទ្រុស្តសីលឲ្យបានមួយពាន់នាក់បូជាយញ្ញ ទើបនឹងផុតចាកការបួងសួង ហើយបានត្រាស់ព្រះគាថានេះថា*

**ទុម្មេធានំ សហស្សេន យញ្ញោ មេ ឧបយាចិតោ**
**ឥទានិ ខោហំ យជិស្សាមិ ពហុ អធម្មិកោ ជនោតិ ។**

*ការបូជា អញបានបួងសួងហើយ ដោយសារមនុស្សអាប់ឥតប្រាជ្ញារាប់ពាន់នាក់ ឥឡូវនេះ អញនឹងបូជា (ព្រោះ) ជន*

មិនប្រកបដោយធម៌ច្រើននាក់ ។

បណ្តាបទទាំងឡាយនោះ ពីរបទថា **ទុម្មេធានំ សហស្សេន** សេចក្តីថា ដែលឈ្មោះថា អ្នកឥតប្រាជ្ញា ព្រោះប្រាជ្ញានៃជនទាំងឡាយនោះ គឺទោសប្រទូស្តហើយ ព្រោះភាពនៃការមិនដឹងថា កម្មនេះគួរធ្វើ កម្មនេះមិនគួរធ្វើ ឬថា ព្រោះភាពនៃការប្រព្រឹត្តិកាន់យកតែអកុសលកម្មបថ ១០ , គឺចំនួនមួយពាន់ ដែលលោករាប់យកជនពាលល្ងង់អប្បឥតប្រាជ្ញាទាំងនោះ ។

បទថា **យញ្ញោ មេ ឧបយាចិតោ** សេចក្តីថា យើងបានចូលទៅរកទេវតា អង្វរករដល់ការបូជាយញ្ញថា នឹងបូជាយញ្ញយ៉ាងនេះ ។

បទថា **ឥទានិ ខោហំ យជិស្សាមិ** សេចក្តីថា យើងនោះនឹងបូជាយញ្ញក្នុងកាលឥឡូវនេះ ព្រោះបានគ្រប់គ្រងរាជសម្បត្តិដោយការបួងសួង ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះឥឡូវនេះ មនុស្សដែលប្រព្រឹត្តអកុសលធម៌មានច្រើនណាស់ ព្រោះហេតុដូច្នោះ ត្រូវចាប់ពួកគេយកទៅធ្វើពលិកម្មក្នុងកាលឥឡូវនេះឯង ។

ពួកអាមាត្យស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ក៏ទទួលព្រះបរមរាជឱង្ការថា ព្រះករុណាថ្លៃវិសេស ហើយវាយស្គរប្រកាសទូទៅពេញ

នគរពារាណសី ដែលមានបរិមណ្ឌល ១២យោជន៍ ។ អ្នកនគរទូទៅស្តាប់អាជ្ញាអំពីការវាយស្គរប្រកាសហើយ ក៏មិនហ៊ានធ្វើខ្លួនឲ្យទៅជាមនុស្សទ្រុស្តសីលទៀត ។ ដោយកុសលោបាយដ៏ប្រពៃ រហូតអស់កាលដែលព្រះបរមពោធិសត្វគ្រប់គ្រងរាជសម្បត្តិ បុគ្គលដែលធ្វើកម្មទាំងឡាយមានទុស្សីលកម្ម ៥ ប្រការ ឬ ១០ ប្រការ សូម្បីត្រឹមតែមួយប្រការក៏មិនប្រាកដឡើយ ។ ព្រះបរមពោធិសត្វទ្រង់មិនបានឲ្យបុគ្គលសូម្បីតែម្នាក់លំបាកឡើយ បញ្ជាឲ្យអ្នកដែនទូទៅរក្សាសីល សូម្បីព្រះអង្គឯងក៏ទ្រង់បំពេញបុណ្យមានការឲ្យទានជាដើម លុះអស់ព្រះជន្មទ្រង់នាំបរិស័ទរបស់ព្រះអង្គទៅណែនតាន់តាប់ក្នុងទេវនគរ ដោយប្រការដូច្នេះ ។

ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតប្រព្រឹត្តជាប្រយោជន៍ចំពោះសត្វលោក សូម្បីក្នុងកាលមុនក៏ធ្លាប់ប្រព្រឹត្តមកហើយដែរ ។ លុះទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកព្រះរាជានគរពារាណសី គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ទុម្មេធជាតក ទី ១០ ។

ចប់ អដ្ឋកថា អត្ថកាមវគ្គ ទី ៥ ។

ចប់ បឋមបណ្ណាសក ។

# រួមជាតកដែលមានក្នុងវគ្គនេះគឺ

*លោសកជាតក ១ កបោតកជាតក ១ វេឡុកជាតក ១ មកសជាតក ១ រោហិណីជាតក ១ អារាមទូសកជាតក ១ វារុណិទូសកជាតក ១ វេទព្វជាតក ១ នក្ខត្តជាតក ១ ទុម្មេធជាតក ១ ។*

# អាសីសវគ្គ ទី ៦

## អដ្ឋកថា មហាសីលវជាតក ទី ១

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកមានសេចក្តីព្យាយាមធូរថយម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **អាសីសេថេវ បុរិសោ** *ដូច្នេះជាដើម ។*

*មានរឿងសង្ខេបថា ព្រះបរមសាស្តា ទ្រង់ត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ពិតឬដែលថាអ្នកជាបុគ្គលមានសេចក្តីព្យាយាមធូរថយនោះ ? កាលភិក្ខុនោះទទួលសារភាពថា ព្រះករុណាព្រះអង្គ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនាដែលនាំសត្វចេញចាកទុក្ខបានបែបនេះហើយ ហេតុដូចម្តេចទើបធូរថយក្នុងសេចក្តីព្យាយាម ? ក្នុងកាលមុនបណ្ឌិតទាំងឡាយ សូម្បីសាបសូន្យចាករាជសម្បត្តិក៏នៅតែតាំងនៅក្នុងសេចក្តីព្យាយាមរបស់ខ្លួន ត្រឡប់ធ្វើយសដែលសាបសូន្យទៅនោះឲ្យកើតឡើងវិញ ហើយទ្រង់លើករឿងក្នុងអតីតមកសាធកដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងព្រះគភ៌នៃព្រះអគ្គមហេសីរបស់ព្រះរាជា ។ ក្នុងថ្ងៃថ្វាយព្រះនាម ព្រះញាតិទាំងឡាយបានថ្វាយព្រះនាមថា សីលវកុមារ ។ លុះមានព្រះជន្ម ១៦ វស្សា ទ្រង់សិក្សាសិល្បៈចេះសព្វគ្រប់ ។ ក្រោយមកព្រះវររាជបិតាសោយទិវង្គតក៏គ្រប់-*

គ្រងរាជ្យជំនួស បានទទួលព្រះនាមថា មហាសីលវរាជ ទ្រង់ប្រព្រឹត្តធម៌ ទ្រង់ជាព្រះធម្មរាជា ។ ព្រះអង្គបញ្ជាឲ្យសាងរោងទាន ៦ កន្លែង គឺ ៤ កន្លែងត្រង់ខ្លោងទ្វារនគរទាំង ៤ ទិស មួយកន្លែងកណ្ដាលនគរ មួយកន្លែងក្បែរខ្លោងទ្វារព្រះរាជវាំង ទ្រង់ឲ្យទានដល់ជនអនាថានិងអ្នកដំណើរជាដើម ទ្រង់រក្សាសីល ៥ សមាទានឧបោសថសីល ទ្រង់សម្បូរដោយខន្តី មេត្តា និងករុណា ទ្រង់ញុំាងសព្វសត្វឲ្យរីករាយ ដូចញុំាងព្រះឱរសដែលគង់លើព្រះឱរូ ( ភ្លៅ ) ឲ្យរីករាយដូច្នោះ ទ្រង់គ្រប់គ្រងរាជ្យដោយធម៌ ។ មានអាមាត្យរបស់ព្រះរាជាម្នាក់ប្រព្រឹត្តល្មើសក្នុងអគ្គមហេសី ចូលទៅក្នុងខេត្តព្រះរាជដ្ឋាន ខាងក្រោយមកកម្មនោះក៏ប្រាកដ អាមាត្យទាំងឡាយក៏នាំគ្នាក្រាបទូលឲ្យទ្រង់ជ្រាប ។ ព្រះបរមពោធិសត្វទ្រង់ឃ្លាំចាំមើល ក៏ទ្រង់ជ្រាបយ៉ាងប្រចក្សដោយព្រះអង្គឯង ទើបបញ្ជាឲ្យអាមាត្យនោះចូលគាល់ ហើយត្រាស់បណ្ដេញថា នែមនុស្សអន្ធពាល អ្នកធ្វើកម្មមិនសមគួរឡើយ អ្នកមិនគួរនៅក្នុងដែនរបស់យើងទេ ចូរនាំយកមាសប្រាក់កូននិងប្រពន្ធទៅកាន់ទីដទៃចុះ ។

អាមាត្យនោះទៅផុតដែនកាសី ដល់ដែនកោសល ចូលទៅបម្រើព្រះរាជាដែនកោសល បានជាទីទុកព្រះរាជហឫទ័យនៃព្រះរាជាដោយលំដាប់ ។ ថ្ងៃមួយ អាមាត្យនោះក្រាបទូលព្រះបាទកោសលថា បពិត្រមហារាជ រាជសម្បត្តិនៅក្នុងនគរពារាណសីប្រៀបដូចសម្បុកឃ្មុំដែល

ប្រាសចាកមេ ព្រះរាជាក៏ទន់ខ្សោយ អាចដណ្តើមយកបានដោយពលពាហនៈមានប្រមាណតិចតួចប៉ុណ្ណោះ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យរបស់អាមាត្យនោះហើយ ទ្រង់ព្រះតម្រិះថា រាជសម្បត្តិនៅក្នុងនគរពារាណសីធំណាស់ ប៉ុន្តែអាមាត្យនេះពោលថា អាចដណ្តើមយកបានដោយពលពាហនៈមានប្រមាណតិចតួចប៉ុណ្ណោះ អាមាត្យនេះប្រហែលជាអ្នកឈ្មបយកការណ៍ទេដឹង គួរឲ្យសង្ស័យណាស់ ទើបមានព្រះតម្រាស់សួរថា អ្នកឯងប្រហែលជាអ្នកយកការណ៍ទេដឹង ?

អាមាត្យនោះក្រាបទូលថា បពិត្រមហារាជ ទូលបង្គំមិនមែនជាអ្នកយកការណ៍ទេ រឿងដែលទូលបង្គំក្រាបទូលនោះពិតទាំងអស់ ប្រសិនបើទ្រង់មិនជឿទូលបង្គំ សូមទ្រង់បញ្ជាមនុស្សឲ្យទៅប្លន់ភូមិស្រុកដែលនៅជាយដែនចុះ ព្រះរាជានគរពារាណសីចាប់មនុស្សទាំងនោះបានហើយ ក៏នឹងព្រះរាជទានទ្រព្យចំណែកព្រះអង្គដល់មនុស្សទាំងនោះ ហើយទ្រង់ដោះលែងឲ្យមកវិញ ។ ព្រះបាទកោសលទ្រង់ព្រះតម្រិះថា អាមាត្យនេះពោលវាចាអង់អាចក្រៃលែងណាស់ អញនឹងសាកល្បងឲ្យដឹងរឿងពិត ហើយទ្រង់ក៏បញ្ជូនមនុស្សរបស់ព្រះអង្គឲ្យទៅប្លន់ស្រុកដែលនៅជាយដែនរបស់ព្រះបាទពារាណសី ។ រាជបុរសចាប់ចោរទាំងនោះបានយកទៅថ្វាយព្រះរាជានគរពារាណសី ។ ព្រះរាជាទតមនុស្សទាំងនោះហើយ ត្រាស់សួរថា នៃអ្នកដ៏ចម្រើន ហេតុអ្វីទើបនាំគ្នាប្លន់អ្នកស្រុក ?

មនុស្សទាំងនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកទូលបង្គំមិនមានអ្វីបរិភោគ ទើបប្លន់ ។

ព្រះរាជាត្រាស់សួរថា កាលបើដូច្នេះ ហេតុអ្វីមិននាំគ្នាមករកយើង ? ចាប់ពីពេលនេះទៅពួកអ្នកកុំធ្វើដូច្នេះទៀត ព្រះរាជទានទ្រព្យចំណែកព្រះអង្គដល់មនុស្សទាំងនោះហើយ ក៏ដោះលែងឲ្យទៅវិញ ។ មនុស្សទាំងនោះទៅក្រាបទូលរឿងនោះថ្វាយព្រះបាទកោសល សូម្បីទ្រង់ជ្រាបរឿងដូច្នេះហើយក៏ដោយ ក៏ព្រះបាទកោសលនៅតែមិនទាន់លើកកងទ័ពទៅ ទ្រង់បញ្ជូនមនុស្សឲ្យទៅប្លន់តាមផ្លូវទៀត ។ ចំណែកព្រះបាទពារាណសី ក៏ទ្រង់នៅតែព្រះរាជទានព្រះរាជទ្រព្យដល់មនុស្សទាំងនោះ ហើយទ្រង់ដោះលែងមនុស្សទាំងនោះឲ្យត្រឡប់ទៅវិញទៀត ។ ពេលនោះ ទើបព្រះបាទកោសលទ្រង់ជ្រាបថា ព្រះរាជានគរពារាណសីជាអ្នកតាំងនៅក្នុងធម៌ ទ្រង់ក៏លើកពលពាហនៈចេញទៅដោយបំណងថា នឹងដណ្តើមយករាជសម្បត្តិនគរពារាណសី ។

ក្នុងគ្រានោះ ព្រះរាជានគរពារាណសីមានអ្នកចម្បាំងដ៏ខ្លាំងពូកែប្រមាណមួយពាន់នាក់ សុទ្ធតែក្លាហានដ៏អស្ចារ្យ បុគ្គលណាមួយក៏មិនអាចធ្វើឲ្យចាញ់បាន សូម្បីដំរីចុះប្រេងរត់សំដៅមករកខ្លួនក៏ទប់ទល់បានមិនរាថយ សូម្បីអសនីបាតគឺរន្ទះធ្លាក់លើក្បាលក៏មិនតក់ស្លុត សុទ្ធតែអាចដណ្តើមរាជសម្បត្តិក្នុងជម្ពូទ្វីបមកថ្វាយបាន ក្នុងកាលដែលព្រះ-

បាទសីលវមហារាជទ្រង់ពេញព្រះរាជហឫទ័យ ។ អ្នកចម្បាំងទាំងនោះដឹងដំណឹងថា ព្រះបាទកោសលលើកទ័ពមក ក៏នាំគ្នាចូលគាល់ព្រះរាជាក្រាបទូលថា បពិត្រមហារាជ បានឮថា ព្រះបាទកោសលលើកកងទ័ពមក មានបំណងនឹងដណ្តើមរាជសម្បត្តិក្នុងនគរពារាណសី សូមព្រះអង្គព្រះរាជទានព្រះបរមរាជានុញ្ញាត ឲ្យពួកទូលបង្គំទាំងឡាយលើកកងទ័ពទៅចាប់ព្រះបាទកោសលរាជ កុំឲ្យរុករានចូលមកក្នុងរាជសីមារបស់ព្រះ-អង្គបាន ។ ព្រះបាទពារាណសីទ្រង់ឃាត់ថា នែអ្នកទាំងឡាយ យើងមិនត្រូវការឲ្យអ្នកដទៃលំបាកព្រោះយើងឡើយ កាលបើព្រះបាទកោសលចង់បានរាជសម្បត្តិ ក៏សូមឲ្យទ្រង់យាងមកគ្រប់គ្រងចុះ អ្នកទាំងឡាយកុំត-ទល់ឡើយ ។ ព្រះបាទកោសលលើកពលមកកន្លងផុតរាជសីមា ចូលមកកាន់ជនបទកណ្តាល ពួកមហាមាត្យដ៏ក្លៀវក្លាក៏នាំគ្នាចូលគាល់ព្រះរាជាក្រាបទូលដូច្នេះម្តងទៀត ព្រះរាជាក៏ទ្រង់ហាមឃាត់ទៀត ។ ព្រះបាទ-កោសលលើកពលមកបោះជំរំខាងក្រៅនគរ ហើយទ្រង់បញ្ជូនព្រះរាជ-សាសន៍ទៅថ្វាយព្រះបាទសីលវមហារាជថា ព្រមលើករាជសម្បត្តិឲ្យ ឬក៏ធ្វើចម្បាំង ? ព្រះបាទសីលវមហារាជទ្រង់បញ្ជូនព្រះរាជសាសន៍តបទៅថា យើងមិនច្បាំងនឹងអ្នកទេ មកគ្រប់គ្រងរាជសម្បត្តិចុះ ។ ពួកអាមាត្យព្រមព្រៀងគ្នាចូលគាល់ព្រះរាជាម្តងទៀត ក្រាបទូលថា បពិត្រព្រះ-សម្មតិទេព ពួកទូលបង្គំនឹងមិនព្រមឲ្យព្រះបាទកោសលចូលក្រុងបាន

ឡើយ នឹងព្រមព្រៀងគ្នាចាប់ខាងក្រៅនគរនោះឯង ។ ព្រះរាជាក៏ទ្រង់ត្រាស់ហាមឃាត់ម្តងទៀត បញ្ជាឲ្យបើកទ្វារក្រុងគ្រប់ទិសហើយ ទ្រង់គង់លើព្រះរាជបល្ល័ង្កក្នុងព្រះរាជវាំង មួយអន្លើដោយអាមាត្យមួយពាន់នាក់ ។ ព្រះបាទកោសល ស្តេចចូលកាន់នគរពារាណសីមួយអន្លើដោយពលនិងពាហនៈដ៏ច្រើន មិនបានទតឃើញសត្រូវតបតសូម្បីតែម្នាក់ ស្តេចចូលកាន់ទ្វារព្រះរាជវាំងហែហមដោយពួកអាមាត្យ ស្តេចឡើងកាន់សាលាវិនិច្ឆ័យដែលតាក់តែងហើយ ក្នុងព្រះរាជវាំងដែលមានទ្វារបើកទុក ហើយទ្រង់បញ្ជាឲ្យចាប់ព្រះបាទសីលវមហារាជអ្នកប្រាសចាកកំហុស ដែលគង់នៅទីនោះមួយអន្លើដោយអាមាត្យមួយពាន់នាក់នោះថា ពួកអ្នកចូរទៅចាប់ព្រះរាជានេះ និងអាមាត្យចងស្លាបសេក ( ចងក្រពាត់ដៃទៅក្រោយ ) ឲ្យមាំហើយនាំទៅកាន់ព្រៃខ្មោច ជីករណ្តៅឲ្យជ្រៅត្រឹមក យកមនុស្សទាំងនេះកប់ក្នុងរណ្តៅនោះត្រឹមក លុបដីកុំឲ្យលើកដៃឡើងបាន ពេលយប់ហ្វូងចចកនាំគ្នាមក ហើយនឹងនាំគ្នាធ្វើកិច្ចដែលគួរធ្វើចំពោះមនុស្សទាំងនេះ ។ ពួកមនុស្សទាំងឡាយស្តាប់ចោររាជអាជ្ញាហើយ ក៏នាំគ្នាចាប់ព្រះរាជានិងពួកអាមាត្យ ចងក្រពាត់ដៃមកក្រោយយ៉ាងណែន នាំចេញទៅកាន់ព្រៃស្មសាន ។

ក្នុងកាលនោះ ព្រះបាទសីលវមហារាជក៏ទ្រង់មិនចងអាឃាតចំពោះចោររាជសូម្បីតែបន្តិច ឯអាមាត្យទាំងនោះដែលត្រូវចាប់ចង ក៏

មិនមានសូម្បីតែម្នាក់ ដែលអាចទម្លាយព្រះតម្រាស់នៃព្រះរាជារបស់ខ្លួន ។ បានឮថា បរិស័ទរបស់ព្រះបាទសីលវមហារាជនោះ មានវិន័យល្អយ៉ាងនេះ ។ គ្រានោះ រាជបុរសរបស់ចោររាជនោះ នាំព្រះបាទសីលវមហារាជមួយអន្លើដោយអាមាត្យទៅដល់ព្រៃខ្មោចហើយ ក៏នាំគ្នាជីករណ្ដៅត្រឹមកចាប់ព្រះបាទសីលវមហារាជកប់ត្រង់កណ្ដាល ចាប់ពួកអាមាត្យដ៏សេសកប់ក្នុងរណ្ដៅសងខាង លុបដីសង្កត់យ៉ាងណែនហើយ ទើបនាំគ្នាត្រឡប់មកវិញ ។ ព្រះបាទសីលវមហារាជទ្រង់ប្រទានឱវាទដល់ពួកអាមាត្យថា នៃអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយគ្រប់គ្នា ចូរចម្រើនមេត្តាចិត្តតែម្យ៉ាងចុះ កុំញ៉ាំងសេចក្ដីក្រោធឲ្យកើតឡើងចំពោះចោររាជឡើយ ។

លុះដល់វេលាអធ្រាត្រហ្វូងចចកគិតថា នឹងខាំស៊ីសាច់មនុស្ស នាំគ្នារត់មក ព្រះរាជានិងពួកអាមាត្យឃើញហ្វូងចចកនោះហើយ ក៏បន្លឺសំឡេងដោយសំឡេងតែមួយ ហ្វូងចចកនីមួយៗ ខ្លាចនាំគ្នារត់គេចអស់ទៅ ។ កាលវាបែរក្រោយមើល មិនឃើញមាននរណាតាមពីក្រោយមកក៏នាំគ្នាត្រឡប់ទៅវិញ ។ ព្រះរាជានិងពួកអាមាត្យបណ្ដេញចចកដោយវិធីនេះ ពួកវានាំគ្នារត់គេចអស់វារៈបីដង បែរមកមើលទៀត ដឹងអាការដែលមនុស្សទាំងនោះ សូម្បីតែម្នាក់ក៏តាមមកមិនបាន ទើបសន្និដ្ឋានថាមនុស្សទាំងនេះត្រូវបានសម្លាប់ហើយ ទើបត្រឡប់ទៅកាន់ទីនោះទៀត សូម្បីព្រះរាជានិងអាមាត្យទាំងនោះធ្វើសំឡេងដ៏លាន់ឮទៀតក៏ដោយ ក៏មិន

រត់ទៅណា ។ ចចកមេហ្វូងដើរសំដៅទៅរកព្រះរាជា ចចកដ៏សេសក៏នាំគ្នាចូលទៅរកពួកអាមាត្យ ។ ព្រះរាជាទ្រង់ឈ្លាសក្នុងឧបាយ ទ្រង់ជ្រាបថា ចចកមេហ្វូងនោះចូលមកជិតព្រះអង្គ ទ្រង់ងើយព្រះសូរង់ឡើងដូចឲ្យឱកាសដល់វានឹងខាំបាន លុះចចកនោះខាំព្រះសូរង់ទ្រង់ក៏សង្កត់ដោយព្រះហនុ ( គឺចង្កា ) យ៉ាងណែនដូចសង្កត់ដោយហិបយន្ត ចចកត្រូវព្រះ-រាជាដែលទ្រទ្រង់កម្លាំងដូចដំរីសារ សង្កត់កដោយព្រះហនុយ៉ាងណែនមិនអាចរើបម្រះបាន ខ្លាចស្លាប់ក៏ស្រែកដោយសំឡេងខ្លាំង ។ ហ្វូងចចកជាបរិវារបានឮសំឡេងរបស់ចចកមេហ្វូងហើយគិតថា ប្រហែលជាចចកមេហ្វូងត្រូវបុរសនោះចាប់បានហើយ ទើបមិនហ៊ានចូលជិតពួកអាមាត្យទាំងនោះ ដោយខ្លាចស្លាប់ក៏នាំគ្នារត់គេចអស់ ។ កាលចចកមេហ្វូងត្រូវព្រះរាជាសង្កត់កយ៉ាងណែនដោយព្រះហនុ ដូចសង្កត់ដោយហិបយន្ត ក៏រើបម្រះទៅមកធ្វើឲ្យដីស្រួយដែលសង្កត់យ៉ាងណែននោះ រលុងខ្លួនបានទាំងវាខ្លួនឯងក៏ខ្លាចស្លាប់ ទើបយកជើងទាំងបួនកាយដីដែលលុបព្រះរាជានោះ ។ ព្រះរាជាទ្រង់ជ្រាបថាដីរលុងហើយ ទ្រង់ក៏បណ្តេញចចកទៅ ទ្រង់តោងមាត់រណ្តៅដកព្រះកាយឡើងបាន ដូចវលាហក ( ពពកខ្មៅ ) ត្រូវខ្ទាត់ខ្ទាយដោយកម្លាំងខ្យល់ដូច្នោះ ទ្រង់ទប់ព្រះអង្គបានហើយ ទ្រង់ក៏លួងលោមពួកអាមាត្យ ទ្រង់កាយដីជួយឲ្យឡើងអំពីរណ្តៅបានគ្រប់គ្នា ព្រះអង្គមានពួកអាមាត្យហែហមគង់នៅក្នុងព្រៃខ្មោចនោះឯង ។

សម័យនោះ ពួកមនុស្សយកសាកសពទៅចោលក្នុងព្រៃខ្មោចនោះ ប៉ុន្តែចោលត្រង់ព្រំដែនយក្សពីរនាក់ ។ យក្សទាំងពីរនោះមិនអាចបែងចែកសាកសពនោះបាន កើតវិវាទហើយនិយាយថា យើងទាំងពីរមិនអាចចែកគ្នាបាន ព្រះបាទសីលវមហារាជអង្គនេះជាព្រះរាជាទ្រទ្រង់ធម៌ ទ្រង់នឹងបែងចែកដល់ពួកយើង ពួកយើងចូលទៅកាន់សម្នាក់ព្រះរាជាអង្គនោះចុះ ហើយក៏ចាប់មនុស្សដែលស្លាប់ហើយនោះត្រង់ជើងម្នាក់ម្ខាង អូសទៅកាន់សម្នាក់ព្រះរាជាហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ចែកសាកសពនេះ ដល់ពួកទូលបង្គំទាំងពីរចុះ ។ ព្រះបាទសីលវមហារាជត្រាស់ថា នែយក្សដ៏ចម្រើន យើងជួយចែកសាកសពនេះឲ្យអ្នកទាំងពីរបាន ប៉ុន្តែយើងនៅមានរាងកាយមិនស្អាតត្រូវងូតទឹកសិន ។ យក្សទាំងពីរក៏ទៅយកទឹកដែលអប់ទុកសម្រាប់ចោររាជមក ដោយអានុភាពរបស់ខ្លួន ថ្វាយព្រះបាទសីលវមហារាជស្រង់ ហើយទៅយកសំពត់របស់ចោររាជដែលទុកដាក់ជាសំពត់ទ្រទ្រង់របស់ព្រះរាជាមកថ្វាយឲ្យទ្រទ្រង់ ហើយទៅនាំយកប្រអប់ព្រះសុគន្ធដែលផ្សំដោយគន្ធជាតិបួនប្រភេទមកថ្វាយឲ្យទ្រង់ប្រស់ព្រំព្រះកាយ ហើយទៅយកផ្កាឈើផ្សេងៗ ដែលរក្សាទុកក្នុងប្រអប់មាសនិងប្រអប់កែវមកថ្វាយឲ្យទ្រង់ប្រដាប់ ។ លុះព្រះបាទមហាសីលវរាជទ្រង់ប្រដាប់កម្រងផ្កាហើយទ្រង់ឈរ យក្សទាំងពីរក៏ក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព តើពួកទូលបង្គំត្រូវធ្វើអ្វីទៀត ?

ព្រះបរមពោធិសត្វទ្រង់សម្ដែងអាការឃ្លាន ។ យក្សទាំងពីរក៏ទៅនាំយកភោជនាហារផ្សេងៗ ដែលមានរសដ៏ប្រណីតៗ ដែលគេចាត់ចែងហើយត្រៀមទុកសម្រាប់ចោររាជមកថ្វាយ ។ ព្រះរាជាទ្រង់ស្រង់ព្រះកាយ តែងព្រះអង្គ ទ្រទ្រង់គ្រឿងរួចស្រេចហើយ ក៏សោយព្រះក្រយាហារ យក្សទាំងពីរក៏ទៅយកទឹកផឹកដែលអប់ហើយនិងកុណ្ឌីមាសព្រមទាំងផ្ដិលមាសដែលគេរៀបចំទុកសម្រាប់ចោររាជមកថ្វាយឲ្យទ្រង់សោយ ។ លុះទ្រង់សោយរួចហើយ ខ្ពុរព្រះឱស្ឋនិងជម្រះព្រះហស្ដហើយ ទើបនាំគ្នាទៅយកព្រះស្រីសន្ទឹក ( ស្លឹកម្លូ ) ដែលផ្សំដោយគន្ធជាតិ ៥ ប្រការ ដែលគេចាត់-ចែងទុកសម្រាប់ចោររាជមកថ្វាយ ។ កាលទ្រង់សោយស្រេចហើយក៏ក្រាបទូលសួរថា តើឲ្យពួកទូលបង្គំទាំងពីរត្រូវធ្វើអ្វីទៀត ? ព្រះរាជាត្រាស់បញ្ជាថា ចូរទៅនាំព្រះខ័នដែលជាមង្គល ដែលរក្សាទុកលើក្បាលដំណេកនៃចោររាជមក ។ យក្សទាំងពីរក៏ទៅនាំយកមកថ្វាយ ព្រះបាទ-សីលវមហារាជទ្រង់ទទួលព្រះខ័ន ទ្រង់ដាក់សាកសពឲ្យត្រង់ ទ្រង់កាប់កណ្ដាលក្បាល ពុះជាពីរចំណែក ព្រះរាជទានឲ្យយក្សទាំងពីរនោះ ម្នាក់មួយចំណែកៗ ស្រេចហើយ ទ្រង់ជម្រះព្រះខ័នសៀតទុកនឹងព្រះអង្គ ។ ចំណែកយក្សទាំងពីរនោះ ស៊ីសាកសពឆ្អែតស្កប់ស្កល់ហើយ មានចិត្តត្រេកអរនាំគ្នាទូលសួរថា បពិត្រព្រះសម្មតិទេព តើពួកទូលបង្គំទាំងពីរត្រូវធ្វើអ្វីថ្វាយទៀត ? ព្រះបរមពោធិសត្វទ្រង់ត្រាស់ថា បើដូច្នោះ ចូរអ្នក

ទាំងពីរសម្ដែងអានុភាព នាំយើងទៅកាន់បន្ទប់ផ្ទំដ៏មានសិរីរបស់ចោររាជ ហើយនាំពួកអាមាត្យទាំងនេះទៅកាន់ផ្ទះរបស់ពួកគេចុះ ។ យក្សទាំងពីរនោះក៏ទទួលព្រះតម្រាស់ ហើយប្រតិបត្តិតាមព្រះរាជបញ្ជា ។

គ្រានោះ ចោររាជផ្ទំលក់លើក្រឡាព្រះបន្ទំក្នុងបន្ទប់ដ៏មានសិរី ព្រះបាទសីលវមហារាជក៏ទ្រង់យកព្រះខ័នប្រហារព្រះឧទរចោររាជដែលកំពុងផ្ទំលក់ភ្ញេចខ្លួន ។ ចោររាជភ្ញាក់ពីព្រះបន្ទំ ទ្រង់ចាំព្រះបាទសីលវមហារាជបានដោយពន្លឺប្រទីប ស្ដេចក្រោកអំពីព្រះយីភូ (ពូក) តម្រង់ព្រះសតិមាំត្រាស់នឹងព្រះបាទសីលវមហារាជថា បពិត្រមហារាជ យាមនៃរាត្រីដូច្នេះ ក្នុងវាំងបិទទ្វារមានអ្នករក្សាយ៉ាងតឹងរ៉ឹងគ្រប់កន្លែង មិនមានចន្លោះ សុទ្ធតែមានអ្នកយាមទាំងអស់ តើព្រះអង្គស្ដេចមកដល់ទីនេះបានដូចម្ដេច ? ព្រះបាទសីលវមហារាជត្រាស់តំណាលដល់ការយាងមករបស់ព្រះអង្គឲ្យចោររាជស្ដាប់ទាំងអស់ដោយពិស្ដារ ។ ចោររាជទ្រង់ព្រះសណ្ដាប់រឿងនោះហើយស្លុតព្រះទ័យយ៉ាងខ្លាំង ត្រាស់ថា បពិត្រមហារាជ ពួកទូលបង្គំជាមនុស្ស ប៉ុន្តែមិនបានដឹងនូវព្រះគុណរបស់ព្រះអង្គ ចំណែកពួកយក្សដែលស៊ីសាច់ស៊ីឈាមមនុស្ស ជាយក្សដ៏កាចឃោរឃៅ ប៉ុន្តែបានដឹងគុណរបស់ព្រះអង្គ បពិត្រមហារាជ ពេលនេះ ទូលបង្គំមិនបានគិតប្រទូសរ៉ាយចំពោះព្រះអង្គ ដែលជាអ្នកបរិបូណ៌ដោយសីលដូច្នេះទៀតឡើយ ទ្រង់ចាប់ព្រះខ័នធ្វើនូវការស្បថ ក្រាបទូលសូមទោស

ព្រះបាទសីលវមហារាជ ទ្រង់យាងព្រះអង្គឲ្យផ្ទំលើព្រះយីភូដ៏ធំ ( ពូកធំ ) ព្រះអង្គខ្លួនឯងផ្ទំលើក្រឡាបន្ទំតូច ។ លុះភ្លឺហើយក៏បញ្ជាឲ្យទូងស្គរប្រកាសឲ្យបណ្ដាសេនាគ្រប់ជាន់ថ្នាក់និងអាមាត្យ ព្រាហ្មណ៍ គហបតីប្រជុំគ្នា ត្រាស់សរសើរព្រះគុណនៃព្រះបាទសីលវមហារាជ ប្រៀបដូចទ្រង់លើកដួងច័ន្ទដ៏ពេញវង់ក្នុងអាកាសឡើងចំពោះមុខមនុស្សទាំងនោះ ទ្រង់សូមខមាទោសព្រះបាទសីលវមហារាជកណ្ដាលបរិស័ទទាំងនោះម្ដងទៀត ទ្រង់ប្រគល់រាជសម្បត្តិថ្វាយព្រះបាទសីលវមហារាជវិញ ហើយត្រាស់ថា ចាប់តាំងពីថ្ងៃនេះតទៅ ឧបទ្ទវន្តរាយដែលកើតអំពីចោរដ៏កាចសាហាវដែលនឹងកើតមានចំពោះព្រះអង្គ ទូលបង្គំសូមទទួលភារៈកម្ចាត់ សូមព្រះអង្គទ្រង់សោយរាជ្យដោយមានទូលបង្គំជាអ្នករក្សាចុះ ហើយទ្រង់ដាក់អាជ្ញាចំពោះអាមាត្យដែលញុះញង់ រួបរួមពលពាហនៈ ហើយស្ដេចយាងទៅកាន់ដែនរបស់ព្រះអង្គវិញ ។

ចំណែកព្រះបាទសីលវមហារាជ ទ្រង់ប្រដាប់ដោយរាជអលង្ការ ទ្រង់គង់លើកញ្ចនបល្ល័ង្កដែលមានកម្រាលជើងធ្វើដោយស្បែកឈ្លូស ខាងក្រោមស្វេតច្ឆត្រ ទតរាជសម្បត្តិរបស់ព្រះអង្គហើយទ្រង់ព្រះតម្រិះថា សម្បត្តិដ៏ឧឡារបែបនេះ និងការត្រឡប់បានជីវិតនៃអាមាត្យមួយពាន់នាក់យ៉ាងនេះ ប្រសិនបើអញមិនមានសេចក្ដីព្យាយាម នឹងមិនបានសូម្បីតែម្យ៉ាង ប៉ុន្តែដោយកម្លាំងនៃសេចក្ដីព្យាយាម ទើបអញបានយសដែល

សាបសូន្យទៅហើយ និងបានឲ្យជីវិតទានដល់អាមាត្យមួយពាន់នាក់ បុគ្គលមិនគួរអស់សង្ឃឹមឡើយ គួរធ្វើសេចក្តីព្យាយាមតែម្យ៉ាង ព្រោះអ្នកដែលធ្វើសេចក្តីព្យាយាមហើយ រមែងសម្រេចផលយ៉ាងនេះ ហើយត្រាស់គាថានេះ ដោយអំណាចនៃឧទានថា

**អាសីសេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ**
**បស្សាមិ វោហំ អត្តានំ យថា ឥច្ឆឹ តថា អហុតិ ។**

*បុរសជាបណ្ឌិត គប្បីប៉ុនប៉ងឲ្យមុតមាំ មិនគប្បីនឿយណាយឡើយ យើងឃើញខ្លួនយើងស្រាប់ហើយ យើងប្រាថ្នាយ៉ាងណា បានយ៉ាងនោះ ។*

បណ្តាបទទាំងនោះ បទថា **អាសីសេថេវ បុរិសោ** សេចក្តីថា បុរសជាបណ្ឌិត គប្បីធ្វើសេចក្តីសង្ឃឹមទុកដោយកម្លាំងនៃសេចក្តីព្យាយាមរបស់ខ្លួនថា កាលយើងប្រារព្ធសេចក្តីព្យាយាមយ៉ាងនេះ នឹងផុតចាកទុក្ខនេះ ដូច្នេះ ។

បទថា **ន និព្វិន្ទេយ្យ បណ្ឌិតោ** សេចក្តីថា បុរសដែលមានឈ្មោះថាបណ្ឌិត គឺជាអ្នកឈ្លាសក្នុងឧបាយ កាលធ្វើសេចក្តីព្យាយាមក្នុងទីណាមួយ គប្បីខ្នះខ្នែង មិនគប្បីនឿយណាយ គឺមិនគួរអស់សង្ឃឹមថា យើងនឹងមិនបានផលនៃសេចក្តីព្យាយាមនេះឡើយ ដូច្នេះ។

បទថា **វោ** ក្នុងបទថា **បស្សាមិ វោហំ អត្តានំ** នេះត្រឹមតែជា

និបាត បានសេចក្តីថា ថ្ងៃនេះយើងឃើញខ្លួនយើងស្រាប់ហើយ ។

បទថា **យថា ឥច្ឆឹ តថា អហុ** សេចក្តីថា ( យើងឃើញខ្លួនយើងជាតួយ៉ាង ) ថា យើងត្រូវកប់ក្នុងរណ្តៅពិតៗ ប៉ុន្តែរួចផុតចាកទុក្ខបាន បានទទួលសម្បត្តិរបស់ខ្លួនវិញ យើងនោះ ក៏ឃើញខ្លួនឯងបានទទួលសម្បត្តិនេះ កាលមុនយើងប្រាថ្នាយ៉ាងណា ខ្លួនយើងក៏បានសម្រេចយ៉ាងនោះ ។

លុះព្រះបរមពោធិសត្វត្រាស់ថា នៃអ្នកដ៏ចម្រើនទាំងឡាយ ធម្មតាផលនៃសេចក្តីព្យាយាម របស់បុគ្គលដែលសម្បូរដោយសីលទាំងឡាយរមែងសម្រេចបានគួរឲ្យអស្ចារ្យពិតៗ ដូច្នេះហើយ ទ្រង់បន្លឺឧទានដោយគាថានេះ ទ្រង់បំពេញបុណ្យទាំងឡាយរហូតអស់ព្រះជន្ម ហើយស្តេចក៏ទៅតាមយថាកម្មដោយប្រការដូច្នេះ ។

ព្រះបរមសាស្តា លុះទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសចតុរារិយសច្ច កាលចប់ចតុរារិយសច្ច ភិក្ខុអ្នកមានសេចក្តីព្យាយាមធូរថយនោះ បានសម្រេចព្រះអរហត្តផល ។ ព្រះបរមសាស្តាទ្រង់បន្តអនុសន្ធិប្រជុំជាតកថា អាមាត្យអាក្រក់ក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ អាមាត្យមួយពាន់បានមកជាពុទ្ធបរិស័ទចំណែកព្រះបាទសីលវមហារាជ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា មហាសីលវជាតក ទី ១ ។

# អដ្ឋកថា ចូឡជនកជាតក ទី ២

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកមានសេចក្ដីព្យាយាមធូរថយដូចគ្នា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **វាយមេថេវ បុរិសោ** *ដូច្នេះជាដើម ។*

*រឿងដែលនឹងពោលក្នុងជាតកនេះទាំងអស់ នឹងមានជាក់ច្បាស់ក្នុង* **មហាជនកជាតក** *។*

*កាលព្រះរាជាទ្រង់គង់ក្រោមស្វេតច្ឆត្រហើយ ត្រាស់ព្រះគាថានេះថា*

**វាយមេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ**
**បស្សាមិ វោហំ អត្តានំ ឧទកា ថលមុព្ភតន្តិ ។**

*បុរសជាបណ្ឌិត ត្រូវតែប្រឹងប្រែង មិនត្រូវនឿយណាយឡើយ*
*យើងឃើញខ្លួនយើងដែលឡើងអំពីទឹក កាន់គោកស្រាប់ហើយ ។*

*បណ្ដាបទទាំងនោះ បទថា* **វាយមេថេវ បុរិសោ** *សេចក្ដីថា បុរសជាបណ្ឌិត គប្បីធ្វើសេចក្ដីព្យាយាមឲ្យរឿយៗ ។*

*បទថា* **ឧទកា ថលមុព្ភតំ** *សេចក្ដីថា យើងឃើញប្រចក្សខ្លួនឯងថាផុតអំពីទឹក ឡើងមកលើគោកបាន គឺឋិតនៅលើគោកបាន ។ ពេលនោះ ភិក្ខុអ្នកមានសេចក្ដីព្យាយាមធូរថយបានសម្រេចអរហត្តផលហើយ ។ ព្រះបាទជនកបានជា* **ព្រះសម្មាសម្ពុទ្ធ** *៕*

ចប់ អដ្ឋកថា ចូឡជនកជាតក ទី ២ ។

# អដ្ឋកថា បុណ្ណបាតិជាតក ទី ៣

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសុរាលាយថ្នាំពិស ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **តថេវ បុណ្ណបាតិយោ** ដូច្នេះជាដើម ។

សម័យមួយ ពួកអ្នកលេងសុរាក្នុងក្រុងសាវត្ថី ជួបជុំប្រឹក្សាគ្នាថា លុយសម្រាប់ទិញសុរារបស់ពួកយើងអស់ហើយ តើពួកយើងនឹងរកទីណាបាន ? គ្រានោះ អ្នកលេងម្នាក់ពោលថា កុំព្រួយឡើយ ឧបាយនៅមានម្យ៉ាង ។ ពួកអ្នកលេងសួរថា ឧបាយយ៉ាងណា ? អ្នកលេងនោះប្រាប់ថា អនាថបិណ្ឌិកសេដ្ឋីពាក់ចិញ្ចៀនច្រើនវង់ ស្លៀកសំពត់សាច់រលោងទៅគាល់ព្រះរាជា ពួកយើងយកថ្នាំដាក់ក្នុងសុរាអន្ទុយត្រៀមដើម្បីនឹងផឹក ពេលអនាថបិណ្ឌិកសេដ្ឋីមក អញ្ជើញគាត់ថា អញ្ជើញមកនេះមហាសេដ្ឋី ហើយឲ្យគាត់ផឹក កាលគាត់សន្លប់ហើយ ដោះចិញ្ចៀននិងសម្លៀកបំពាក់យកធ្វើជាដើមទុនទិញសុរាផឹក ។ អ្នកលេងទាំងនោះយល់ព្រមថា ល្អណាស់ៗ ហើយនាំគ្នាធ្វើយ៉ាងនោះ ។ ពេលលោកសេដ្ឋីដើរមកក៏ដើរទៅរកលោកសេដ្ឋីពោលថា បពិត្រសេដ្ឋីដ៏ចម្រើន សូមលោកអញ្ជើញមកខាងនេះបន្តិចសិន សុរាក្នុងវង់របស់ពួកខ្ញុំគួរឲ្យរីករាយក្រៃលែងណាស់ សូមលោកផឹកបន្តិចសិន សឹមទៅចុះ ។ អនាថបិណ្ឌិកសេដ្ឋីជាព្រះសោតាបន្ន ជាអរិយសាវក នឹងផឹកសុរាម្តេចបាន សូម្បីគាត់

មិនត្រូវការក៏គិតនឹងចាប់ ( ភស្តុតាង ) ពួកអ្នកលេងទាំងនោះ ទើបដើរទៅដល់ទីដែលចាក់ស្រាត្រៀមទុកផឹក សម្ងឹងមើលពួកអ្នកលេងទាំងនោះហើយ ដើរទៅកាន់កន្លែងដែលពួកគេត្រៀមផឹកសុរា ឃើញកិរិយារបស់ពួកជនទាំងនោះក៏ដឹងថា ពួកនេះផ្សំសុរានេះទុកដោយហេតុនេះ ហើយត្រិះរិះតទៅថា ចាប់តាំងពីថ្ងៃនេះទៅ អញត្រូវដេញពួកនេះឲ្យចេញអំពីទីនេះ ដូច្នេះហើយនិយាយថា នែពួកអ្នកលេង ពួកឯងលេងសុរាអាក្រក់ក្រៃលែងណាស់ ពួកឯងយកថ្នាំដាក់ក្នុងសុរាហើយឃុបឃិតគ្នា ធ្វើមនុស្សដែលមកផឹកឲ្យសន្លប់ហើយប្លន់ទ្រព្យសម្បត្តិគេ ចាត់ចែងវង់ផឹក អង្គុយរង់ចាំអួតសុរាតែម្យ៉ាង បុគ្គលណា សូម្បីតែម្នាក់ក៏មិនហ៊ានលើកសុរាទាំងនេះផឹក ប្រសិនបើសុរានេះមិនលាយដោយថ្នាំពិសទេនោះ ប្រាកដជាពួកឯងផឹកអស់ហើយ ។ អនាថបិណ្ឌិកសេដ្ឋីគំរាមដេញអ្នកលេងទាំងនោះឲ្យចេញអំពីទីនោះហើយក៏ទៅផ្ទះរបស់ខ្លួន លុះទៅដល់ផ្ទះបានគិតថាត្រូវក្រាបទូលរឿងដែលពួកអ្នកលេងធ្វើឲ្យព្រះតថាគតទ្រង់ជ្រាប ទើបទៅកាន់វត្តជេតពនក្រាបទូលព្រះបរមសាស្តាឲ្យទ្រង់ជ្រាប ។ ព្រះបរមសាស្តាត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលពួកអ្នកលេងទាំងនោះប្រាថ្នានឹងបោកបញ្ឆោតអ្នក សូម្បីកាលមុនក៏មានបំណងនឹងបោកបញ្ឆោតបណ្ឌិតទាំងឡាយដែរ ។ កាលសេដ្ឋីក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាពារាណសីសេដ្ឋី សូម្បីក្នុងកាលនោះ ពួកអ្នកលេងទាំងនោះក៏ប្រឹក្សាគ្នាយ៉ាងនេះ ផ្សំសុរាទុក ពេលពារាណសីសេដ្ឋីដើរមក ក៏ដើរទៅរកលោកសេដ្ឋីនាំគ្នានិយាយដោយមានទំនងតែមួយ ។ សេដ្ឋីមិនមានបំណងនឹងផឹក ប៉ុន្តែចង់ចាប់ទោសពួកអ្នកលេងទាំងនោះ ទើបទៅកាន់ទីនោះ លុះឃើញកិរិយារបស់ពួកអ្នកលេងទាំងនោះហើយក៏គិតថា ពួកអ្នកលេងទាំងនេះប្រាថ្នានឹងធ្វើអំពើនេះ អញត្រូវដេញពួកវាឲ្យចេញអំពីទីនេះ ហើយពោលយ៉ាងនេះថា នែអ្នកលេងដ៏ចម្រើនទាំងឡាយ ធម្មតាការផឹកសុរាហើយចូលគាល់ព្រះរាជាមិនសមគួរឡើយ យើងទៅគាល់ព្រះរាជាហើយត្រឡប់មកវិញ អ្នកទាំងឡាយអង្គុយរង់ចាំនៅទីនេះចុះ ។ លុះទៅគាល់ព្រះរាជាហើយត្រឡប់មកវិញ ពួកអ្នកលេងទាំងឡាយនាំគ្នាពោលថា បពិត្រសេដ្ឋីសូមលោកអញ្ជើញមកទីនេះ ។ សេដ្ឋីទៅកាន់ទីនោះហើយសម្លឹងមើលសុរាដែលលាយដោយថ្នាំពិសហើយពោលថា នែអ្នកលេងដ៏ចម្រើនទាំងឡាយ ការធ្វើរបស់ពួកអ្នកមិនត្រូវចិត្តយើងឡើយ សុរារបស់ពួកអ្នកនៅពេញដូចដើម ពួកអ្នកអង្គុយសរសើរសុរាតែម្យ៉ាង មិននាំគ្នាផឹកសោះ ប្រសិនបើសុរានេះជាទីរីករាយពិតៗ ប្រាកដជាពួកអ្នកផឹកខ្លះហើយ ប៉ុន្តែសុរានេះប្រាកដជាពួកអ្នកផ្សំដោយថ្នាំពិសមិនខាន កាល

*នឹងទម្លាយមនោរថនៃពួកអ្នកលេងទាំងនោះ ទើបពោលគាថានេះថា*

**តថេវ បុណ្ណាចាតិយោ អញ្ញាយំ វត្តតេ កថា**
**អាការកេន ជានាមិ នេវាយំ ភទ្ទកា សុរាតិ ។**

*ភាជន៍សុរានៅពេញដដែល តែសម្តីចេញទៅដោយឡែក យើង*
*ដឹងបាន ដោយហេតុ (នេះ) សុរានេះមិនមែនស្រួលទេ ។*

*បណ្តាបទទាំងនោះ បទថា* **តថេវ** *សេចក្តីថា ពេលយើងទៅឃើញសុរានេះយ៉ាងណា សូម្បីពេលនេះ សុរានេះក៏នៅពេញដូចដើម ។*

*បទថា* **អញ្ញាយំ វត្តតេ កថា** *សេចក្តីថា ពាក្យសរសើរសុរារបស់ពួកអ្នក ជាពាក្យកុហក គឺជាពាក្យមិនពិត ព្រោះបើសុរានេះល្អពិតៗ ពួកអ្នកក៏ត្រូវនាំគ្នាផឹកនឹងនៅសល់តែឱទឹន តែពួកអ្នកឯងមិនបានផឹក សូម្បីតែម្នាក់ ។*

*បទថា* **អាការកេន ជានាមិ** *ព្រោះហេតុដូច្នេះ ទើបយើងដឹងដោយហេតុនេះ ។*

*បទថា* **នេវាយំ ភទ្ទកា សុរា** *សេចក្តីថា សុរានេះមិនល្អទេ ពិតជាសុរាលាយដោយថ្នាំពិស ។*

*សេដ្ឋីគំរាមពួកអ្នកលេងមិនឲ្យពួកវាធ្វើយ៉ាងនេះទៀត ហើយក៏ដោះលែងទៅ ។ ធ្វើបុណ្យមានឲ្យទានជាដើម រហូតអស់ជីវិតហើយក៏ទៅតាមយថាកម្ម ។*

ព្រះបរមសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ពួកអ្នកលេងក្នុងកាលនោះ បានមកជាពួកអ្នកលេងក្នុងកាលឥឡូវនេះ ចំណែកពារាណសីសេដ្ឋី គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា បុណ្ណបាតិជាតក ទី ៣ ។

# អដ្ឋកថា ផលជាតក ទី ៤

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកដែលឈ្លាសវៃមើលផ្លែឈើម្នាក់ ត្រាស់ធម្មទេសនានេះ មានពាក្យផ្ដើមថា ** នាយំ រុក្ខោ ទុរារុហោ** ដូច្នេះជាដើម ។

បានឮថា កុដុម្ពិកៈអ្នកក្រុងសាវត្ថីម្នាក់ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យគង់ក្នុងចម្ការរបស់ខ្លួន ថ្វាយយាគូនិងគ្រឿងឧបភោគហើយប្រើអ្នកយាមសួនថា នៃអ្នកដ៏ចម្រើន អ្នកចូរត្រាច់ទៅក្នុងសួនជាមួយនឹងលោកម្ចាស់ទាំងឡាយ ប្រគេនផ្លែឈើផ្សេងៗ មានផ្លែស្វាយជាដើមចំពោះលោកម្ចាស់ទាំងឡាយផងចុះ ។ អ្នករក្សាសួនទទួលពាក្យហើយនាំភិក្ខុសង្ឃត្រាច់ទៅក្នុងសួនមើលផ្លែឈើ ដឹងផ្លែឈើដោយការជំនាញថា ផ្លែឈើនោះខ្ចី ផ្លែឈើនោះស្រគាល ផ្លែនោះទុំល្អហើយ អ្នករក្សាសួននោះនិយាយយ៉ាងណាពិតជាយ៉ាងនោះមែន ។ ភិក្ខុទាំងឡាយក្រាបទូលព្រះតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកថែសួននេះឈ្លាសក្នុង

ការមើលផ្លែឈើ សូម្បីឈរនៅលើដីសម្លឹងមើលផ្លែឈើហើយ ក៏ដឹងបាន ថា ផ្លែឈើនោះខ្ចី ផ្លែនោះស្រគាល ផ្លែនោះទុំល្អហើយ អ្នកថែសួននោះ និយាយយ៉ាងណាពិតយ៉ាងនោះមែន ។ ព្រះបរមសាស្ដាទ្រង់ត្រាស់ ថា ម្នាលភិក្ខុទាំងឡាយ អ្នកថែសួននេះ មិនមែនជាអ្នកឈ្លាសក្នុងការមើល ផ្លែឈើតែម្នាក់ឯងប៉ុណ្ណោះទេ ក្នុងកាលមុនបណ្ឌិតទាំងឡាយដែលជា អ្នកឈ្លាសក្នុងការមើលផ្លែឈើក៏ធ្លាប់មានមកហើយ ហើយទ្រង់ក៏នាំយក រឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុង នគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឈ្មួញរទេះ កាល ចម្រើនវ័យហើយ ធ្វើជាអ្នកជំនួញដោយមានរទេះ ៥០០ ។ សម័យមួយ ទៅដល់ព្រៃជ្រៅ ក៏ដោះរទេះសម្រាកនៅក្នុងព្រៃ ហៅមនុស្សទាំងអស់ មកប្រជុំគ្នា រួចហើយពោលថា ក្នុងព្រៃនេះ រមែងមានដើមឈើដែល មានជាតពុល ស្លឹកមានជាតពុលក៏មាន ផ្កាមានជាតពុលក៏មាន ផ្លែមាន ជាតពុលក៏មាន រសផ្អែមមានជាតពុលក៏មាន ពួកអ្នកមិនត្រូវបរិភោគមុន ពេលដែលប្រាប់យើងជាដាច់ខាត ។ ពួកឈ្មួញទាំងនោះ ទទួលពាក្យ ហើយនាំគ្នាចូលទៅកាន់ព្រៃ ។ ត្រង់មាត់ព្រៃមានដើមឈើមានជាតពុល មួយដើម នៅក្បែរទ្វារស្រុកមួយកន្លែង ដើម មែក ស្លឹកខ្ចី ផ្កា ផ្លែ គ្រប់ យ៉ាងនៃដើមឈើនោះ ដូចដើមស្វាយមិនខុសគ្នាឡើយ ជាងនោះទៅ-

ទៀត ផ្លែខ្ចីនិងផ្លែទុំដូចផ្លែស្វាយ ទាំងពណ៌និងសណ្ឋាន ទាំងត្របកផ្កា និងរស ក៏មិនប្លែកគ្នា ប៉ុន្តែបរិភោគចូលទៅហើយធ្វើឲ្យអ្នកបរិភោគនោះ អស់ជីវិតភ្លាម ដូចថ្នាំពុលមួយប្រភេទដែលកាចសាហាវដូច្នោះ ។ ពួកឈ្មួញដែលដើរទៅខាងមុខ ពួកខ្លះជាមនុស្សឡេះឡោះ សម្គាល់ថា នេះដើមស្វាយ ក៏បេះបរិភោគ ពួកខ្លះគិតថា សួរប្រធានក្រុមសិន សឹមបរិភោគ ក៏ឈរកាន់ផ្លែឈើនោះរង់ចាំ ។ លុះប្រធានក្រុមមកដល់ក៏នាំគ្នាសួរថា បពិត្រលោកម្ចាស់ តើពួកខ្ញុំអាចបរិភោគផ្លែស្វាយទាំងនេះបានឬទេ ? ព្រះបរមពោធិសត្វដឹងថា នេះមិនមែនដើមស្វាយ ក៏ហាមឃាត់ថា ដើមនេះឈ្មោះថា កឹផលព្រឹក្ស មិនមែនដើមស្វាយទេ ពួកអ្នកកុំបរិភោគឡើយ ពួកដែលបរិភោគចូលទៅហើយ ក៏ចាត់ចែងធ្វើឲ្យក្អួតចេញមក ហើយឲ្យផឹករបស់ផ្អែមបួនមុខ ធ្វើឲ្យប្រាសចាករោគ ។ ក្នុងកាលមុន ពួកមនុស្សនាំគ្នាសម្រាកនៅក្បែរដើមឈើនេះ បរិភោគផ្លែដែលមានជាតពុល ដោយសម្គាល់ថាជាផ្លែស្វាយក៏ដល់នូវការអស់ជីវិត ។ ស្អែកឡើងពួកអ្នកស្រុកក៏នាំគ្នាចេញមក ឃើញមនុស្សស្លាប់ក៏នាំគ្នាអូសជើងយកទៅចោលក្នុងទីផ្សេងៗ ហើយក៏កាន់យករបស់របរព្រមទាំងរទេះ ។ ក្នុងថ្ងៃនោះគ្រាន់តែអរុណរះភ្លាម ពួកអ្នកស្រុកក៏និយាយគ្នាថា គោជារបស់យើង រទេះជារបស់យើង ភណ្ឌជារបស់យើង នាំគ្នារត់ទៅកាន់ដើមឈើនោះ លុះឃើញមនុស្សទាំងឡាយរួចផុតអំពីភ័យ ម្នាក់ៗក៏សួរថា ពួកលោក

ដឹងបានយ៉ាងណាថា ដើមឈើនេះ មិនមែនជាដើមស្វាយ ? មនុស្ស ទាំងនោះក៏ឆ្លើយតបថា ពួកយើងមិនដឹងទេ តែប្រធានរបស់ពួកយើង ដឹង ។

ពួកអ្នកស្រុកក៏សួរព្រះបរមពោធិសត្វថា បពិត្របណ្ឌិត លោក ធ្វើយ៉ាងណា ទើបដឹងថា ដើមឈើនេះ មិនមែនជាដើមស្វាយ ?

ព្រះបរមពោធិសត្វប្រាប់ថា ខ្ញុំដឹងដោយហេតុពីរប្រការ ហើយ ពោលគាថានេះថា

**នាយំ រុក្ខោ ទុរារុហោ នបិ គាមតោ អារកា**
**អាការកេន ជានាមិ នាយំ សាទុផលោ ទុមោតិ ។**

ឈើនេះ មិនមែនលំបាកឡើង ទាំងមិនឋិតនៅឆ្ងាយអំពីស្រុក
ខ្ញុំដឹងបានដោយហេតុ (នេះ) ឈើនេះ មិនមែនមានផ្លែស្រួល
ទេ ។

បណ្ដាបទទាំងនោះ បទថា **នាយំ រុក្ខោ ទុរារុហោ** សេចក្ដីថា ព្រះបរមពោធិសត្វពោលថា ដើមឈើមានជាតពុលនេះ មិនលំបាក ឡើងទេ បុគ្គលណាមួយក៏អាចឡើងបានដោយងាយ ដូចមានមនុស្ស យកបង្គោងមកដាក់ដូច្នោះ ។

បទថា **នបិ គាមតោ អារកា** សេចក្ដីថា ព្រះបរមពោធិសត្វ សម្ដែងថា ទាំងឋិតនៅមិនឆ្ងាយអំពីស្រុក គឺនៅជិតទ្វារស្រុក ។

*បទថា* **អាការេន ជានាមិ** *សេចក្តីថា ដោយហេតុពីរប្រការនេះ ទើបខ្ញុំដឹងដើមឈើនេះ ។*

*សួរថា ដឹងបានដូចម្តេច ?*

*ឆ្លើយថា ដឹងថា ដើមឈើនេះ មិនមែនដើមឈើមានផ្លែល្អទេ អធិប្បាយថា ប្រសិនបើដើមឈើនេះ មានផ្លែឆ្ងាញ់ដូចផ្លែស្វាយនោះ កាលដើមនេះឡើងបានស្រួលផង បិតនៅមិនឆ្ងាយអំពីស្រុកយ៉ាងនេះផង ផ្លែរបស់វានឹងមិនសល់សូម្បីតែមួយផ្លែ ប្រាកដជាត្រូវពួកអ្នកស្រុកបរិភោគអស់ ដណ្តើមគ្នាបេះជានិច្ច ខ្ញុំកំណត់ដោយប្រាជ្ញារបស់ខ្លួនយ៉ាងនេះ ទើបដឹងបានថា ដើមឈើនេះ ជាដើមឈើមានជាតពុល ។*

*ព្រះបរមពោធិសត្វសម្តែងធម៌ដល់មហាជនហើយ ក៏ធ្វើដំណើរទៅដោយសុវត្ថិភាព ។*

*ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន បណ្ឌិតទាំងឡាយក៏ធ្លាប់ជាអ្នកឈ្លាសវៃក្នុងការមើលផ្លែឈើមកហើយយ៉ាងនេះ ។*

*លុះទ្រង់នាំព្រះធម្មទេសនាមកយ៉ាងនេះហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកឈ្មួញរទេះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា ផលជាតក ទី ៤ ។

# អដ្ឋកថា បញ្ញាវុធជាតក ទី ៥

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកមានសេចក្តីព្យាយាមធូរថយមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **យោ អលីនេន ចិត្តេន** *ដូច្នេះជាដើម ។*

*ព្រះបរមសាស្តាត្រាស់ហៅភិក្ខុនោះមក ហើយត្រាស់សួរថា ម្នាលភិក្ខុ ពិតមែនឬ ដែលគេថាអ្នកជាបុគ្គលមានសេចក្តីព្យាយាមធូរថយនោះ? កាលភិក្ខុនោះក្រាបទូលថា ព្រះករុណាព្រះអង្គ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុនបណ្ឌិតទាំងឡាយធ្វើសេចក្តីព្យាយាមក្នុងទីដែលគួរប្រកបសេចក្តីព្យាយាម ក៏បានរាជសម្បត្តិ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងព្រះគភ៌នៃព្រះអគ្គមហេសីរបស់ព្រះរាជាអង្គនោះ ។ ក្នុងថ្ងៃដែលថ្វាយព្រះនាមព្រះបរមពោធិសត្វ រាជត្រកូលបានអង្គាសព្រាហ្មណ៍ ១០៨ នាក់ ឲ្យឆ្អែតស្កប់ស្កល់ដោយរបស់គួរបរិភោគ គួរប្រាថ្នា គ្រប់ៗប្រការ ហើយសាកសួរលក្ខណៈរបស់ព្រះរាជកុមារ ។ ពួកព្រាហ្មណ៍ដែលឈ្លាសវៃក្នុងការទាយលក្ខណៈ ឃើញភាពសម្បូរដោយលក្ខណៈហើយក៏នាំគ្នាទាយថា បពិត្រមហារាជ ព្រះរាជកុមារសម្បូរដោយបុញ្ញាធិការដូច្នេះ កាល*

ព្រះអង្គសោយទិវង្គតហើយនឹងត្រូវបានគ្រងរាជសម្បត្តិ នឹងមានឈ្មោះ បោះសំឡេងប្រាកដដោយការប្រើប្រាស់អាវុធ ៥ ប្រការ ជាអគ្គបុរសក្នុង ជម្ពូទ្វីប ព្រោះហេតុតែបានស្ដាប់ការទស្សន៍ទាយរបស់ព្រាហ្មណ៍ទាំងនោះ ទើបថ្វាយព្រះនាមព្រះរាជកុមារនោះថា បញ្ចាវុធកុមារ ។ លុះព្រះរាជ-កុមារនោះធំដឹងក្ដីហើយ មានព្រះជន្ម ១៦ ព្រះវស្សា ព្រះរាជាត្រាស់ ហៅមក ហើយត្រាស់ប្រាប់ថា បុត្តជាទីស្រលាញ់ ចូរបុត្តរៀនសិល្ប-សាស្ត្រចុះ ។

ព្រះរាជកុមារសួរថា បពិត្រព្រះបិតា ទូលបង្គំនឹងទៅរៀនក្នុង សម្នាក់អ្នកណា ?

ព្រះរាជាត្រាស់ថា ចូរបុត្រទៅរៀនក្នុងសម្នាក់អាចារ្យទិសាបា-មោក្ខនៅឯតក្កសិលានគរ ដែនគន្ធារៈ ហើយកូនឯងឲ្យទ្រព្យនេះជាតម្លៃ សម្រាប់បូជាគុណអាចារ្យ ទ្រង់ព្រះរាជទានទ្រព្យមួយពាន់កហាបណៈ ហើយទើបបញ្ជូនទៅ ។ ព្រះរាជកុមារយាងទៅកាន់សម្នាក់អាចារ្យទិសា-បាមោក្ខនោះ ទ្រង់សិក្សាសិល្បៈ ទ្រង់ទទួលអាវុធ ៥ ប្រការដែលអាចារ្យ ថ្វាយ ( លុះរៀនចប់សព្វគ្រប់ហើយ ) លាអាចារ្យចេញពីនគរតក្កសិលា សៀតអាវុធទាំង ៥ នឹងព្រះកាយ ទ្រង់យាងទៅកាន់នគរពារាណសី ។ ព្រះបរមពោធិសត្វយាងមកដល់ព្រៃមួយ ជាព្រៃដែលសិលេសលោម យក្សរស់នៅ ។ គ្រានោះ ពួកមនុស្សឃើញព្រះរាជកុមារត្រង់មាត់ព្រៃក៏

ឃាត់ថា នែមាណពដ៏ចម្រើន អ្នកកុំចូលទៅកាន់ព្រៃនេះ ក្នុងព្រៃនេះ មានយក្សឈ្មោះថា សិលេសលោមយក្សរស់នៅ យក្សនោះធ្វើឲ្យមនុស្ស ដែលវាឃើញហើយស្លាប់យ៉ាងច្រើន ។ ព្រះបរមពោធិសត្វតាំងស្មារតី មិនឲ្យញាប់ញ័រ ឆ្ពោះមុខចូលទៅកាន់ព្រៃដូចរាជសីហ៍ដែលមិនខ្លាច ដូច្នោះ ។ លុះទៅដល់កណ្តាលព្រៃ យក្សនោះក៏ប្រែកាយខ្ពស់មួយដួរ ដើមត្នោត ក្បាលប៉ុនផ្ទះកំពូល ភ្នែកម្ខាងៗប៉ុនកង់រទេះ ចង្កូមទាំងពីរប៉ុន ត្រយូងចេក មុខស ពោះចម្រុះពណ៌ ដៃជើងខៀវ សម្តែងខ្លួនឲ្យព្រះ-បរមពោធិសត្វឃើញ ហើយស្រែកថា អ្នកឯងទៅណា ឈប់សិន អ្នកឯង ត្រូវជាអាហាររបស់យើង ។ ពេលនោះ ព្រះបរមពោធិសត្វគំរាមយក្ស នោះថា នែយក្ស យើងត្រៀមខ្លួនហើយទើបចូលមកកាន់ព្រៃនេះ អ្នក កុំប្រហែសចូលមកជិតយើង ព្រោះយើងនឹងបាញ់អ្នកឯងដោយកូនសរ លាបដោយថ្នាំពិស ឲ្យដួលដេកនៅត្រង់នេះ ហើយបាញ់កូនសរលាប ដោយថ្នាំពិសទៅ ។ កូនសរទៅជាប់នឹងរោមរបស់យក្សទាំងអស់ ។ ព្រះបរមពោធិសត្វបាញ់កូនសរទៅជាប់ៗ គ្នាដោយអាការយ៉ាងនេះ អស់ កូនសរ ៥០ គ្រប់កូនសរសុទ្ធតែជាប់ត្រង់រោមរបស់យក្សទាំងអស់ ។ យក្សនោះរលាស់ព្រួញទាំងអស់ឲ្យធ្លាក់នៅជិតជើង ហើយស្ទុះចូលទៅ រកព្រះបរមពោធិសត្វ ។ ព្រះបរមពោធិសត្វគំរាមយក្សម្តងទៀត ហើយ ទាញព្រះខ័នចេញមកកាប់ ព្រះខ័នប្រវែង ៣៣ ធ្នាប់ ក៏ជាប់ត្រង់រោម

របស់យក្សនោះទៀត ពេលនោះទើបចាក់យក្សនោះដោយលំពែង សូម្បីលំពែងនោះក៏ជាប់នឹងរោមរបស់យក្សនោះដែរ លុះព្រះបរមពោធិសត្វដឹងថាយក្សនោះមានរោមស្អិតហើយ ក៏វាយដោយដំបង សូម្បីដំបងនោះក៏ជាប់នឹងរោមរបស់យក្សទៀត ព្រះបរមពោធិសត្វដឹងថាយក្សមានខ្លួនស្អិត ក៏បន្លឺសីហនាទដោយមិនញាប់ញ័រប្រកាសកង់រំពងថា នែយក្សឯងមិនធ្លាប់បានឮឈ្មោះយើង ដែលមានឈ្មោះថាបញ្ចាវុធកុមារទេឬ ? កាលយើងនឹងចូលព្រៃដែលឯងនៅនេះ យើងត្រៀមអាវុធមានធ្នូជាដើមហើយ ទើបមក ថ្ងៃនេះយើងនឹងវាយឯងឲ្យខ្ទេចដូចជាធូលី ហើយលោតចូលដាល់ដោយដៃខាងស្តាំ ដៃខាងស្តាំក៏ជាប់រោម ដាល់ដោយដៃឆ្វេង ដៃឆ្វេងក៏ជាប់ទៀត ទាត់ដោយជើងស្តាំ ជើងស្តាំក៏ជាប់ ទាត់ដោយជើងឆ្វេង ជើងឆ្វេងក៏ជាប់ គិតថាទង្គិចឲ្យយក្សបែកក្បាល ហើយក៏ទង្គិចដោយសីសៈ សូម្បីសីសៈក៏ជាប់រោមរបស់យក្សទៀត ព្រះបរមពោធិសត្វជាប់ទ្រឹងក្នុងទីទាំង៥ សូម្បីព្យួរតែងតោង ក៏មិនខ្លាចមិនភ័យរន្ធត់ឡើយ ។

យក្សនោះក៏គិតថា បុរសនេះជាបុរសឯក ជាសីហបុរស ជាបុរសអាជានេយ្យ មិនមែនបុរសធម្មតាទេ សូម្បីត្រូវយក្សដូចអញចាប់ ក៏មិនញាប់ញ័រតក់ស្លុត ក្នុងផ្លូវនេះអញសម្លាប់មនុស្សច្រើនណាស់ អញមិនដែលឃើញបុរសបែបនេះ សូម្បីតែម្នាក់ឡើយ ព្រោះហេតុអ្វីហ្ន៎ ទើប

បុរសនេះមិនខ្លាច យក្សមិនអាចស៊ីព្រះបរមពោធិសត្វបាន ទើបសួរថា

នែមាណព ព្រោះហេតុអ្វីទើបអ្នកមិនខ្លាចស្លាប់?

ព្រះបរមពោធិសត្វឆ្លើយថា នែយក្សដ៏ចម្រើន ហេតុដូចម្ដេច ទើបយើងត្រូវខ្លាច ? ព្រោះក្នុងអត្តភាពមួយ សេចក្ដីស្លាប់នោះជារបស់ទៀងទាត់ ម្យ៉ាងទៀតក្នុងពោះរបស់យើងមានវជិរាវុធ ប្រសិនបើអ្នកស៊ីយើង ក៏នឹងមិនអាចធ្វើឲ្យអាវុធរលាយបាន អាវុធនោះនឹងកាត់ផ្ដាច់ពោះវៀនរបស់អ្នក ឲ្យដាច់ជាកំណាត់ៗ តូចខ្លះ ធំខ្លះ ធ្វើឲ្យអ្នកឯងអស់ជីវិតបាន ដោយហេតុដូចពោលមកនេះ ពួកយើងក៏ត្រូវស្លាប់ទាំង-ពីរនាក់ ដោយហេតុនេះ ទើបយើងមិនខ្លាចស្លាប់ ។

ពាក្យថា **វជិរាវុធ** នេះ ព្រះបរមពោធិសត្វត្រាស់សំដៅដល់អាវុធគឺញាណខាងក្នុងខ្លួនព្រះអង្គ ។ យក្សស្ដាប់ពាក្យនោះហើយគិតថា មាណពនេះពោលនូវពាក្យណា ពាក្យនោះពិតទាំងអស់ ដុំសាច់ សូម្បីប្រមាណប៉ុនគ្រាប់សណ្ដែកបាយអំពីរាងកាយនៃបុរសសីហៈនេះ ប្រសិន-បើអញបរិភោគចូលទៅក្នុងពោះហើយនឹងមិនអាចឲ្យរលាយបាន អញនឹងដោះលែងបុរសនេះ ។ លុះគិតដូច្នេះហើយ ក៏កើតការខ្លាចស្លាប់ ទើបដោះលែងព្រះបរមពោធិសត្វទៅដោយពោលថា នែមាណព អ្នកជាបុរសសីហៈ យើងមិនបរិភោគសាច់របស់អ្នកឯងទេ អ្នកឯងផុតអំពីកណ្ដាប់ដៃរបស់យើង ដូចព្រះចន្ទផុតអំពីមាត់រាហូដូច្នោះ អញ្ជើញអ្នក

ទៅចុះ ពួកញាតិមិត្តរបស់អ្នកនឹងបានសប្បាយចិត្ត ។ គ្រានោះ ព្រះ-បរមពោធិសត្វត្រាស់ទៅកាន់យក្សនោះថា នែយក្ស យើងត្រូវទៅមុន ចំណែកអ្នកបានធ្វើអកុសលទុកហើយក្នុងកាលមុន ទើបបានមកកើតជាយក្សដ៏កាចសាហាវ មានដៃប្រឡាក់ដោយឈាម មានសាច់ឈាមអ្នកដទៃជាអាហារ ប្រសិនបើអ្នកតាំងនៅក្នុងអត្តភាពនេះហើយ នៅតែធ្វើអកុសលកម្មតទៅទៀត អ្នកនឹងទៅកាន់ទីងងឹតទៀត ចាប់តាំងពីអ្នកបានជួបយើងហើយ យើងនឹងមិនបណ្ដោយឲ្យអ្នកធ្វើអកុសលកម្មតទៅទៀតទេ ។ លុះពោលដូច្នេះហើយ ក៏ត្រាស់ទោសនៃទុស្សីលកម្មទាំង ៥ ដោយន័យជាដើមយ៉ាងនេះថា ដែលឈ្មោះថា **កម្ម** គឺការញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះកន្ទង់ រមែងញុំាងសត្វឲ្យកើតក្នុងកំណើតនរក ក្នុងកំណើតតិរច្ឆាន ក្នុងកំណើតបេតវិស័យ និងក្នុងកំណើតអសុរកាយ លុះបានមកកើតជាមនុស្ស ក៏ធ្វើឲ្យជាមនុស្សមានអាយុខ្លី ហើយទ្រង់សម្ដែងអានិសង្សនៃសីលទាំង ៥ គំរាមយក្សដោយហេតុផ្សេងៗ ទ្រង់សម្ដែងធម៌ទូន្មានយក្សរហូតទាល់តែអស់ភាពរឹងរូស ណែនាំឲ្យតាំងនៅក្នុងសីល ៥ ធ្វើយក្សនោះឲ្យជាទេវតាទទួលពលិកម្មក្នុងព្រៃនោះ ហើយដាស់តឿនដោយអប្បមាទធម៌ ទើបទ្រង់យាងចេញអំពីព្រៃ ប្រាប់មនុស្សដែលនៅត្រង់មាត់ព្រៃ ( អំពីហេតុការណ៍ដែលបានប្រយុទ្ធជាមួយយក្ស ) ហើយទ្រង់សៀតអាវុធទាំង ៥ ប្រចាំព្រះអង្គយាងទៅកាន់នគរពារាណសី

ចូលគាល់ព្រះរាជបិតាព្រះរាជមាតា ។ ក្រោយមកបានគ្រងរាជសម្បត្តិ ទ្រង់គ្រប់គ្រងរាជ្យប្រកបដោយធម៌ ទ្រង់បំពេញបុញ្ញកម្មទាំងឡាយ មានឲ្យទានជាដើម លុះអស់ជីវិតហើយស្តេចក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយ លុះទ្រង់បានត្រាស់ដឹងហើយ ទើបត្រាស់ព្រះគាថានេះថា

**យោ អលីនេន ចិត្តេន អលីនមនសោ នរោ**
**ភាវេតិ កុសលំ ធម្មំ យោគក្ខេមស្ស បត្តិយា**
**បាបុណេ អនុបុព្វេន សព្វសំយោជនក្ខយន្តិ ។**

បុរសណា មានចិត្តមិនរួញរា ចម្រើនកុសលធម៌ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ដោយចិត្តមិនរួញរា បុរសនោះ គប្បីដល់នូវធម៌ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងពួង តាមលំដាប់ ។

ក្នុងព្រះគាថានោះប្រមូលសេចក្តីបានដូច្នេះ បុរសណា មានចិត្តមិនរួញរា គឺមិនស្ទាក់ស្ទើរ មិនសើរើ មានចិត្តមិនរួញរាដោយប្រក្រតី ជាអ្នកមានអធ្យាស្រ័យរឹងមាំ ចម្រើនធម៌ដែលមានឈ្មោះថា **កុសល** បានដល់ពោធិបក្ខិយធម៌ ៣៧ ប្រការ ព្រោះជាធម៌ដែលប្រាសចាកទោស ចម្រើនវិបស្សនាដោយចិត្តដ៏ទូលាយ ដើម្បីដល់នូវការក្សេមចាកយោគៈទាំង ៤ គឺ ព្រះនិព្វាន បុរសនោះលើកឡើងនូវត្រៃលក្ខណ៍ គឺ **អនិច្ចំ**

**ឧក្កំ អរហត្តា** *ក្នុងសង្ខារទាំងពួងយ៉ាងនេះហើយ ញ៉ាំងពោធិបក្ខិយធម៌ ដែលកើតឡើងអំពីតរុណវិបស្សនាឲ្យចម្រើន បានសម្រេចអរហត្តផល ដែលដល់ការរាប់ថា ជាការអស់សំយោជនៈទាំងពួង ព្រោះកើតក្នុងទីបំផុតនៃមគ្គទាំង ៤ ដែលជាហេតុអស់ទៅនៃសំយោជនៈទាំងពួង មិនសេសសល់ សូម្បីតែសំយោជនៈមួយ ។*

*ព្រះបរមសាស្ដា ទ្រង់កាន់យកកំពូលនៃព្រះធម្មទេសនាដោយព្រះអរហត្តផល ដោយប្រការដូច្នេះ ក្នុងទីបំផុតទ្រង់ប្រកាសចតុរារិយសច្ច ( អរិយសច្ច ៤ ) ក្នុងវេលាចប់អរិយសច្ចធម៌ ភិក្ខុនោះបានសម្រេចអរហត្តផល ។ ព្រះបរមសាស្ដា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា យក្សក្នុងកាលនោះ បានមកជាអង្គុលិមាល ចំណែកបញ្ចាវុធកុមារ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា បញ្ចាវុធជាតក ទី ៥ ។

# អដ្ឋកថា កញ្ចនក្ខន្ធជាតក ទី ៦

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យោ បហដ្ឋេន ចិត្តេន** ដូច្នេះជាដើម ។

បានឮថា កុលបុត្រអ្នកក្រុងសាវត្ថីម្នាក់ស្តាប់ព្រះធម្មទេសនារបស់ព្រះបរមសាស្តាហើយ បួសឧទ្ទិសជីវិតក្នុងសាសនា គឺព្រះរតនត្រៃ ។ គ្រានោះ អាចារ្យនិងឧបជ្ឈាយ៍របស់លោកប្រៀនប្រដៅអំពីសីលថា អ្នកមានអាយុ ដែលឈ្មោះថាសីល ១ យ៉ាងក៏មាន ២ យ៉ាងក៏មាន ៣ យ៉ាងក៏មាន ៤ យ៉ាងក៏មាន ៥ យ៉ាងក៏មាន ៦ យ៉ាងក៏មាន ៧ យ៉ាងក៏មាន ៨ យ៉ាងក៏មាន ៩ យ៉ាងក៏មាន ដែលឈ្មោះថាសីល គឺមានច្រើនយ៉ាង នេះហៅថា **ចុល្លសីល** នេះហៅថា **មជ្ឈិមសីល** នេះហៅថា **មហាសីល** នេះហៅថា **បាតិមោក្ខសំវរសីល** នេះហៅថា **ឥន្ទ្រិយសំវរសីល** នេះហៅថា **អាជីវបារិសុទ្ធិសីល** នេះហៅថា **បច្ចយសន្និស្សិតសីល** ។ ភិក្ខុនោះគិតថា ដែលឈ្មោះថា **សីល** មានច្រើនក្រៃលែងណាស់ អញមិនអាចសមាទានប្រព្រឹត្តបានទេ បព្វជ្ជារបស់បុគ្គលដែលមិនអាចបំពេញសីលឲ្យបរិបូណ៌បាន នឹងមានប្រយោជន៍អ្វី អញនឹងសឹកទៅជាគ្រហស្ថបំពេញបុញ្ញកម្មទាំងឡាយ មានការឲ្យទានជាដើម ចិញ្ចឹមកូនប្រពន្ធ លុះគិតដូច្នេះហើយ ក៏ប្រាប់អាចារ្យនិងឧបជ្ឈាយ៍

ថា បពិត្រលោកអាចារ្យដ៏ចម្រើន ខ្ញុំមិនអាចរក្សាសីលបាន កាលមិនអាចរក្សាសីលបាន បព្វជ្ជាក៏នឹងមិនមានប្រយោជន៍ ខ្ញុំនឹងសូមលាសិក្ខា សូមទទួលបាត្រនិងចីវររបស់លោកទៅចុះ ។ គ្រានោះ អាចារ្យនិងឧបជ្ឈាយ៍ក៏ប្រាប់ភិក្ខុនោះថា អាវុសោ បើដូច្នោះ អ្នកចូលទៅថ្វាយបង្គំព្រះទសពលចុះ លុះពោលដូច្នេះហើយ ក៏នាំភិក្ខុនោះទៅកាន់ធម្មសភាដែលជាទីគង់នៅនៃព្រះបរមសាស្តា ។

ព្រះបរមសាស្តាទ្រង់ទតឃើញភិក្ខុនោះហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនាំភិក្ខុអ្នកមិនប្រាថ្នា (បព្វជ្ជាភេទ) មកឬ?

ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះបានប្រាប់ថា ខ្ញុំមិនអាចរក្សាសីលបាន ហើយក៏ប្រគល់បាត្រនិងចីវរឲ្យខ្ញុំព្រះ-អង្គទាំងឡាយ ដូច្នេះហើយ ទើបខ្ញុំព្រះអង្គទាំងឡាយនាំភិក្ខុនេះមក ។

ព្រះបរមសាស្តាទ្រង់ត្រាស់សួរថា ហេតុដូចម្តេចទើបពួកអ្នកប្រាប់សីលដល់ភិក្ខុនេះច្រើនម្ល៉េះ? ភិក្ខុនេះអាចរក្សាបានប៉ុនណា ក៏គប្បីរក្សាប៉ុណ្ណោះចុះ ចាប់តាំងពីថ្ងៃនេះទៅពួកអ្នកកុំពោលអ្វីៗ នឹងភិក្ខុនេះឡើយ តថាគតប៉ុណ្ណោះនឹងដឹងនូវអំពើដែលគួរធ្វើ ហើយទ្រង់ត្រាស់ទៅកាន់ភិក្ខុនោះថា ម្នាលភិក្ខុ អ្នកនឹងត្រូវការសីលច្រើនយ៉ាងធ្វើអ្វី អ្នកអាចនឹងរក្សាសីល ៣ ប្រភេទប៉ុណ្ណោះបានឬ ?

ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអាចរក្សា

បាន ។

ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះពុទ្ធតម្រាស់ថា បើដូច្នោះ ចាប់តាំងពីថ្ងៃនេះទៅ អ្នកចូររក្សាទ្វារទាំងបី គឺកាយទ្វារ វចីទ្វារ មនោទ្វារ កុំធ្វើអាក្រក់ដោយកាយ វាចា និងចិត្ត ទៅចុះ កុំសឹកឡើយ ចូររក្សាសីលបីប្រភេទនេះចុះ ។ ដោយព្រះពុទ្ធតម្រាស់ត្រឹមតែប៉ុណ្ណោះ ភិក្ខុនោះក៏មានចិត្តត្រេកអរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រពៃណាស់ ខ្ញុំព្រះអង្គនឹងរក្សាសីលបីប្រភេទនេះទុក លុះពោលដូច្នោះហើយក៏ថ្វាយបង្គំលាព្រះបរមសាស្តា ត្រឡប់ទៅជាមួយនឹងអាចារ្យព្រមទាំងឧបជ្ឈាយ៍វិញ ។ កាលលោករក្សាសីលទាំងបីនោះ ក៏បានគិតថា សីលដែលអាចារ្យនិងឧបជ្ឈាយ៍ប្រាប់អញ ក៏មានតែប៉ុណ្ណោះឯង ប៉ុន្តែលោកទាំងនោះមិនអាចឲ្យអញយល់បាន ព្រោះលោកមិនមែនជាព្រះពុទ្ធ ព្រះសម្មាសម្ពុទ្ធទ្រង់សង្គ្រោះសីលទាំងអស់ ចូលក្នុងទ្វារបីប៉ុណ្ណោះ ឲ្យអញទទួលយកបាន ព្រោះព្រះអង្គជាព្រះពុទ្ធ ទ្រង់ត្រាស់ដឹងដោយប្រពៃ (និង) ព្រោះព្រះអង្គជាព្រះធម្មរាជាដ៏កំពូល ព្រះអង្គទ្រង់ជាទីពឹងនៃអញពិតៗ លុះគិតដូច្នេះហើយក៏ចម្រើនវិបស្សនាបានសម្រេចអរហត្តផលដោយ ( ត្រឹមតែ ) ពីរ-បីថ្ងៃប៉ុណ្ណោះ ។ ភិក្ខុទាំងឡាយជ្រាបសេចក្តីប្រព្រឹត្តិទៅដូច្នោះហើយប្រជុំគ្នាក្នុងធម្មសភា មួយអង្គៗលើកដល់ព្រះពុទ្ធគុណថា អ្នកមានអាយុទាំងឡាយ បានឮថា ភិក្ខុនោះពោលថា មិនអាចរក្សាសីលទាំងឡាយ

បាន ចង់សឹក ព្រះបរមសាស្តា ទ្រង់សង្ខេបសីលទាំងអស់ដោយចំណែក បី ឲ្យលោកទទួលយកបាន ឲ្យបានសម្រេចអរហត្តផល ឱ ដែលឈ្មោះ ថា ព្រះពុទ្ធទាំងឡាយជាអច្ឆរិយមនុស្ស ។ ព្រះបរមសាស្តា ស្តេចយាង មក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំង-ឡាយអង្គុយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះ ក្រាបទូល ឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែ ក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភារៈដ៏ធ្ងន់ក៏តថាគតបែងចែកដោយ ចំណែកតូចៗ ឲ្យជារបស់ស្រាលៗ សូម្បីក្នុងកាលមុនបណ្ឌិតទាំងឡាយ បានដុំមាសមួយដុំធំ កាលមិនអាចនឹងលើកឡើងបាន ក៏ចែកជាចំណែក តូចៗ ហើយលើកឡើងបាន ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតកាល មកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុង នគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាអ្នកស្រែនៅក្នុងស្រុក មួយ ។ ថ្ងៃមួយ កំពុងភ្ជួរស្រែដែលនៅក្នុងខេត្តដែននៃភូមិឋានដែលគេ បោះបង់ចោលមួយ ។ កាលពីមុនក្នុងផ្ទះមួយខ្នងនោះ ធ្លាប់មានសេដ្ឋី ដែលសម្បូរដោយទ្រព្យសម្បត្តិម្នាក់ កប់ដុំមាសមួយដុំធំប៉ុនគល់ភ្លៅ ប្រវែង ប្រមាណ ៤ ហត្ថហើយក៏ស្លាប់ទៅ ។ នង្គ័លរបស់ព្រះបរមពោធិសត្វទៅ ទាក់នឹងដុំមាសនោះហើយឈប់ ។ ព្រះបរមពោធិសត្វគិតថា ប្រាកដ

ជាឫសឈើហើយ ក៏កាយដីមើលឃើញដុំមាសនោះ កាយដីលុបវិញ ហើយក្លួរតទៅទៀត លុះព្រះអាទិត្យអស្តង្គតក៏ទុកដាក់សម្ភារៈមាននឹម និងនង្គ័លជាដើម ក្នុងទីដ៏សមគួរមួយ គិតថា កាលបើអញលើកដុំមាស នេះទៅ មិនអាចលើកយកទៅបានទេ កាលមិនអាចទើបអង្គុយចុះ បំបែកដុំមាសនោះចេញជាបួនចំណែកដោយគិតថា នឹងចិញ្ចឹមខ្លួនឯង ប៉ុណ្ណោះ កប់ទុកចំនួនប៉ុណ្ណោះ ដាក់ទុកធ្វើជាដើមទុនចំនួនប៉ុណ្ណោះ ធ្វើ បុណ្យមានឲ្យទានជាដើមចំនួនប៉ុណ្ណោះ ។ លុះបែងចែកយ៉ាងនេះហើយ បំបែកដុំមាសនោះយកទៅ ដូចកាន់យករបស់ស្រាលៗ ដូច្នេះ ។ ព្រះ-បរមពោធិសត្វយកដុំមាសនោះទៅផ្ទះ ចែកជាបួនចំណែក ធ្វើបុណ្យមាន ឲ្យទានជាដើម លុះអស់ជីវិតហើយក៏ទៅតាមយថាកម្ម ។

ព្រះដ៏មានព្រះភាគ ទ្រង់នាំព្រះធម្មទេសនានេះមកដូច្នេះ លុះ ទ្រង់បានត្រាស់ដឹងហើយ ទើបត្រាស់ព្រះគាថានេះថា

**យោ បហដ្ឋេន ចិត្តេន បហដ្ឋមនសោ នរោ**
**ភាវេតិ កុសលំ ធម្មំ យោគក្ខេមស្ស បត្តិយា**
**បាបុណេ អនុបុព្វេន សព្វសំយោជនក្ខយន្តិ ។**

បុរសណា មានចិត្តរីករាយចម្រើនកុសលធម៌ ដើម្បីដល់
នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ដោយចិត្តដែល
រីករាយ បុរសនោះ គប្បីដល់នូវធម៌ជាគ្រឿងអស់ទៅនៃ

*សំយោជនៈទាំងពួង តាមលំដាប់ ។*

*បណ្ដាបទទាំងនោះ បទថា* **បហាជ្ជេ** *បានដល់ ប្រាសចាក នីវរណធម៌ ។*

*បទថា* **បហាជ្ជមហេសោ** *សេចក្ដីថា ព្រោះហេតុតែមានចិត្តប្រាស-ចាកនីវរណធម៌នោះឯង ទើបឈ្មោះថាមានចិត្តរីករាយដូចមាស គឺជាអ្នកមានចិត្តរុងរឿងភ្លឺស្វាងហើយ ។*

*ព្រះបរមសាស្ដា ទ្រង់ញ៉ាំងព្រះធម្មទេសនាឲ្យដល់កំពូលគឺអរហត្តហើយ ទ្រង់បញ្ចប់ព្រះធម្មទេសនា បន្តអនុសន្ធិប្រជុំជាតកថា បុរសដែលបានដុំមាសក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា កញ្ចនក្ខន្ធជាតក ទី ៦ ។

# អដ្ឋកថា វានរិន្ទជាតក ទី ៧

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសេចក្ដីខ្វល់ខ្វាយព្យាយាមផ្ដាច់ព្រះជន្មទ្រង់របស់ភិក្ខុទេវទត្ត ត្រាស់ព្រះ-ធម្មទេសនានេះ មានពាក្យផ្ដើមថា* យស្សេតេ ចតុរោ ធម្មា *ដូច្នេះជាដើម ។*

*សម័យនោះ ព្រះបរមសាស្ដាទ្រង់ព្រះសណ្ដាប់ដំណឹងថា ទេវទត្តកំពុងព្យាយាមដើម្បីផ្ដាច់ព្រះជន្មព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុទាំង-*

ឡាយមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលទេវទត្តព្យាយាម សម្លាប់តថាគតនោះ សូម្បីក្នុងកាលមុនក៏ធ្លាប់ព្យាយាមសម្លាប់តថាគត ដែរ ប៉ុន្តែមិនអាចធ្វើហេតុត្រឹមតែការតក់ស្លុតឲ្យកើតមានដល់តថាគត ឡើយ ហើយទ្រង់នាំយករឿងក្នុងអតីតកាលមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុង នគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាស្វា លុះចម្រើន វ័យមានរាងកាយធំធាត់ប៉ុនកូនសេះ សម្បូរដោយកម្លាំង ត្រាច់ទៅតាម មាត់ស្ទឹងតែម្នាក់ឯង ។ កណ្តាលស្ទឹងនោះ មានកោះមួយសម្បូរដោយ ដើមឈើមានផ្លែផ្សេងៗ មានស្វាយនិងខ្នុរជាដើម ។ ព្រះបរមពោធិសត្វ មានកម្លាំងដូចដំរីសារ សម្បូរដោយកម្លាំង លោតអំពីមាត់ស្ទឹងខាងអាយ ហើយ ក៏ទៅឈរនៅលើផ្ទាំងថ្មមួយផ្ទាំងដែលនៅត្រង់កណ្តាលស្ទឹង គឺ ចន្លោះមាត់ស្ទឹងនិងកោះ លោតអំពីផ្ទាំងថ្មនោះ ទៅលើកោះស៊ីផ្លែឈើ ផ្សេងៗនៅលើកោះនោះ លុះវេលារសៀលក៏លោតត្រឡប់មកលំនៅរបស់ ខ្លួនវិញដោយឧបាយនោះ លុះស្អែកឡើងក៏ធ្វើដូច្នោះទៀត អាស្រ័យទី នោះដោយនិយាមនេះឯង ។

ក្នុងកាលនោះ មានក្រពើមួយនិងប្រពន្ធនៅក្នុងស្ទឹងនោះ អស់ កាលយូរ ។ ក្រពើញីនោះឃើញព្រះបរមពោធិសត្វលោតទៅលោតមក កើតការចាញ់កូនចង់ស៊ីបេះដូងរបស់ព្រះបរមពោធិសត្វ ក៏និយាយនឹង

ក្រពើជាប្ដីថា បពិត្របង ខ្ញុំចាញ់កូន ចង់ស៊ីបេះដូងរបស់ពានរិន្ទនេះ ។

ក្រពើឈ្មោលពោលថា បាន តើនាងចង់ស៊ីរបស់អ្វី អញនឹងរកមកឲ្យ ហើយនិយាយតទៅទៀតថា ថ្ងៃនេះអញនឹងរង់ចាំចាប់ពានរិន្ទនោះពេលដែលវាត្រឡប់មកអំពីកោះពេលរសៀល ហើយទៅដេករង់ចាំនៅលើផ្ទាំងថ្ម ។ ព្រះបរមពោធិសត្វត្រាច់ទៅរកស៊ីពេញមួយថ្ងៃ លុះពេលរសៀលក៏ឈរសម្រាកនៅមាត់កោះ សម្លឹងមើលផ្ទាំងថ្ម ហើយគិតថា ថ្ងៃនេះផ្ទាំងថ្មខ្ពស់ជាងថ្ងៃមុន ព្រោះហេតុអ្វីហ្ន៎ ។ បានឮថា ប្រមាណទឹកនិងប្រមាណនៃផ្ទាំងថ្ម ព្រះបរមពោធិសត្វកំណត់ទុកយ៉ាងល្អហើយ ព្រោះហេតុនោះទើបមានបរិវិតក្កថា ថ្ងៃនេះទឹកមិនស្រក ហើយក៏មិនឡើងដែរ កាលបើដូច្នេះ ហេតុអ្វីក៏ផ្ទាំងថ្មនេះឡើងខ្ពស់ម៉្លេះ ក្រពើដេករង់ចាំចាប់អញនៅលើផ្ទាំងថ្មនេះទេដឹង ? ព្រះបរមពោធិសត្វគិតថា អញនឹងសាកល្បងមើលសិន ក៏ឈរក្នុងទីនោះធ្វើដូចជានិយាយនឹងផ្ទាំងថ្មនោះថា នៃថ្មដ៏ចម្រើន មិនបានទទួលចម្លើយក៏ពោលថា នៃថ្មដ៏ចម្រើន នៃថ្មដ៏ចម្រើន អស់វារៈដល់បីដង ថ្មនឹងឆ្លើយបានដូចម្ដេច ? ពានរនៅតែនិយាយនឹងថ្មទៀតថា នៃថ្មដ៏ចម្រើន ហេតុដូចម្ដេចថ្ងៃនេះឯងមិនឆ្លើយនឹងការសួររបស់ខ្ញុំ ? ក្រពើស្ដាប់ហើយគិតថា ប្រហែលជាថ្ងៃមុនៗផ្ទាំងថ្មនេះឆ្លើយនឹងការសួររបស់ពានរនេះហើយមើលទៅ ពេលនេះអញនឹងឆ្លើយចំពោះការសួររបស់ពានរ លុះគិតដូច្នោះហើយក៏ឆ្លើយថា

មានការអ្វី ពានរដ៏ចម្រើន ?

ព្រះបរមពោធិសត្វសួរថា អ្នកជានរណា ?

ក្រពើឆ្លើយថា យើងជាក្រពើ ។

ព្រះបរមពោធិសត្វសួរថា អ្នកឯងមកដេកទីនេះ ដើម្បីត្រូវការអ្វី ?

ក្រពើឆ្លើយថា ដើម្បីត្រូវការបេះដូងរបស់អ្នក ។

ព្រះបរមពោធិសត្វត្រិះរិះថា អញមិនមានផ្លូវដទៃទៀតទេ ថ្ងៃនេះត្រូវតែបញ្ឆោតក្រពើនេះ លុះគិតដូច្នេះហើយ ក៏និយាយនឹងក្រពើនោះថា នែក្រពើសម្លាញ់ យើងកាត់ចិត្តលះបង់រាងកាយឲ្យអ្នកហើយ អ្នកឯងចូរហាមាត់រង់ចាំត្របាក់យើង នៅពេលដែលយើងទៅដល់មាត់របស់អ្នកចុះ ។ ព្រោះជាធម្មតា កាលក្រពើហាមាត់ ភ្នែកទាំងពីរខាងរបស់វាត្រូវបិទ ។ ក្រពើមិនទាន់បានកំណត់ដឹងហេតុ (ដែលជាធម្មតា )នោះក៏ហាមាត់រង់ចាំ ភ្លាមនោះភ្នែកទាំងពីររបស់វាក៏បិទ ។ ព្រះបរមពោធិសត្វដឹងសភាពដូច្នេះ ក៏លោតទៅអំពីកោះជាន់ក្បាលក្រពើ ហើយលោតអំពីក្បាលក្រពើទៅកាន់ត្រើយខាងអាយនៃស្ទឹង រហ័សដូចផ្លេកបន្ទោរ ។ ក្រពើឃើញហេតុដ៏អស្ចារ្យដូច្នោះ ក៏គិតថា ពានរិន្ទនេះធ្វើនូវអំពើដ៏-អស្ចារ្យក្រៃលែងណាស់ គិតបណ្តើរ ពោលបណ្តើរថា នែពានរិន្ទដ៏ចម្រើន ក្នុងលោកនេះ បុគ្គលដែលប្រកបដោយធម៌ ៤ ប្រការ រមែងគ្របសង្កត់សត្រូវបាន ធម៌ទាំង ៤ ប្រការនោះ ប្រហែលជាមាននៅខាងក្នុង

ខ្លួនរបស់អ្នកគ្រប់យ៉ាងហើយ ទើបពោលគាថានេះថា

**យស្សេតេ ចតុរោ ធម្មា វានរិន្ទ យថា តវ**

**សច្ចំ ធម្មោ ធិតិ ចាគោ ទិដ្ឋំ សោ អតិវត្តតីតិ ។**

បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៤ ដូចអ្នក គឺសេចក្ដីទៀងទាត់ ១ ធម៌គឺប្រាជ្ញាជាគ្រឿងពិចារណា ១ ព្យាយាមមិនដាច់ ១ ការលះ ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន ។

បណ្ដាបទទាំងនោះ បទថា **យស្ស** បានដល់ បុគ្គលណាមួយ ។

បទថា **ឯតេ** សេចក្ដីថា រមែងប្រាកដប្រចក្សក្នុងធម៌ដែលខ្ញុំនឹងពោលក្នុងកាលឥឡូវនេះ ។

បទថា **ចតុរោ ធម្មា** បានដល់ គុណធម៌ ៤ ប្រការ ។

បទថា **សច្ចំ** បានដល់ វចីសច្ចៈ គឺដែលអ្នកប្រាប់ថានឹងមកកាន់សម្នាក់របស់ខ្ញុំ អ្នកក៏មិនបានធ្វើខុសពាក្យសម្ដីមកពិតនោះឯង នេះជាវចីសច្ចៈ របស់អ្នក ។

បទថា **ធម្មោ** បានដល់ វិចារណបញ្ញា ពោលគឺចេះពិចារណាថា កាលធ្វើយ៉ាងនេះហើយនឹងមានផលដូច្នេះ សេចក្ដីនេះ ជាវិចារណ-បញ្ញារបស់អ្នក ។

សេចក្ដីព្យាយាមដែលមិនរួញរា លោកហៅថា **ធិតិ** សូម្បីគុណ-ធម៌នេះក៏មានក្នុងខ្លួនអ្នក ។

បទថា **ចាគោ** បានដល់ ការលះបង់ខ្លួន គឺការដែលអ្នកលះបង់ជីវិតមកកាន់សម្នាក់របស់ខ្ញុំ ប៉ុន្តែខ្ញុំមិនអាចចាប់អ្នកបាន នេះជាកំហុសរបស់ខ្ញុំតែម្នាក់ឯងគត់ ។

បទថា **ធិជ្ជំ** បានដល់ បច្ចាមិត្រ ។

បទថា **សោ អតិវត្តតិ** សេចក្តីថា ធម៌ ៤ យ៉ាងដូចពោលមកនេះ មានដល់បុគ្គលណា ដូចមានដល់អ្នក បុគ្គលនោះរមែងឈានកន្លង គឺគ្របសង្កត់បាននូវបច្ចាមិត្តរបស់ខ្លួន ដូចជាអ្នកឈានកន្លងផុតអំពីកណ្តាប់ដៃរបស់ខ្ញុំក្នុងថ្ងៃនេះ ដូច្នេះ ។

ក្រពើសរសើរព្រះបរមពោធិសត្វយ៉ាងនេះហើយ ក៏ទៅកាន់លំនៅរបស់ខ្លួនវិញ ។

ព្រះបរមសាស្តា ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តមិនមែនព្យាយាមសម្លាប់តថាគតតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ធ្លាប់ព្យាយាមសម្លាប់តថាគតដែរ ដូច្នេះ ។ លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ក្រពើក្នុងកាលនោះ បានមកជាទេវទត្ត ប្រពន្ធរបស់ក្រពើ បានមកជានាងចិញ្ចមាណវិកា ចំណែកពានរិន្ទ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា វានរិន្ទជាតក ទី ៧ ។

# អដ្ឋកថា តយោធម្មជាតក ទី ៨

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការព្យាយាមផ្តាច់ព្រះជន្មព្រះអង្គរបស់ភិក្ខុទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យស្សេតេ ច តយោ ធម្មា** ដូច្នេះជាដើម ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ទេវទត្តកើតក្នុងកំណើតពានរ (ស្វា) គ្រប់គ្រងហ្វូងនៅក្នុងហិមវន្តប្រទេស កាលកូនពានរដែលអាស្រ័យខ្លួនធំហើយក៏ខាំពូជ នៃកូនពានរទាំងនោះអស់ ព្រោះខ្លាចក្រែងពានរទាំងនោះដណ្តើមគ្រប់គ្រងហ្វូង ។ គ្រានោះ ព្រះបរមពោធិសត្វអាស្រ័យពានរនោះ បដិសន្ធិក្នុងពោះនៃមេស្វាមួយ ។ គ្រានោះ មេស្វានោះដឹងថាខ្លួនមានកូន ដើម្បីនឹងរក្សាការមានកូនរបស់ខ្លួន ក៏បានទៅកាន់ជើងភ្នំមួយដទៃទៀត លុះដល់គ្រប់ខែក៏ប្រសូតព្រះបរមពោធិសត្វ ។ ព្រះបរមពោធិសត្វចម្រើនវ័យដល់នូវភាពជាអ្នកដឹងក្តីហើយ ជាអ្នកសម្បូរដោយកម្លាំង ។ ថ្ងៃមួយសួរមាតាថា បពិត្រម៉ែ អ្នកណាជាឪពុករបស់ខ្ញុំ?

មេស្វាឆ្លើយថា នៃកូនដ៏ចម្រើន បិតារបស់កូនឯងជាអ្នកគ្រប់គ្រងហ្វូងនៅភ្នំឯណោះ ។

ព្រះបរមពោធិសត្វពោលថា ម៉ែនាំខ្ញុំទៅរកបិតាចុះ ។

មេស្វាពោលថា កូនដ៏ចម្រើន កូនឯងមិនអាចចូលទៅជិតបិតារបស់

កូនឯងបានទេ ព្រោះបិតាកូនឯងតែងតែខាំពូជនៃកូនពានរដែលអាស្រ័យខ្លួនកើតមកអស់ ព្រោះខ្លាចកូនពានរទាំងនោះដណ្តើមគ្រប់គ្រងហ្វូង ។

ព្រះបរមពោធិសត្វពោលថា បពិត្រម៉ែ សូមម៉ែនាំខ្ញុំទៅចុះ ខ្ញុំនឹងដឹង (អនាគតរបស់ខ្លួនឯង) ។

មេស្វានោះ ក៏នាំព្រះបរមពោធិសត្វទៅកាន់សម្នាក់ពានរដែលជាបិតា ។

ស្វាមេហ្វូងនោះ គ្រាន់តែឃើញព្រះបរមពោធិសត្វភ្លាម ក៏គិតថា កាលកូននេះធំឡើងនឹងមិនព្រមឲ្យអញគ្រប់គ្រងហ្វូងទេ ត្រូវសម្លាប់វាឥឡូវអញនឹងធ្វើដូចជាចាប់ឱបវាហើយក៏ច្របាច់ឲ្យណែន ឲ្យអស់ជីវិតទាល់តែបាន ទើបពោលថា មកនេះកូន កូនឯងទៅណាបាត់យូរម្ល៉េះ ? ដូច្នេះហើយ ធ្វើដូចជាចាប់ឱបព្រះបរមពោធិសត្វ ឱបរឹតយ៉ាងណែន ។ ព្រះបរមពោធិសត្វមានកម្លាំងដូចដំរីសារ សម្បូរដោយកម្លាំង ក៏ឱបរឹតតបទៅវិញ ។ គ្រានោះ ឆ្អឹងទាំងអស់របស់ពានរនោះ ក៏ដល់នូវអាការស្ទើរតែបាក់ ។ គ្រានោះ ពានរជាបិតាគិតថា អាកូននេះធំឡើងប្រាកដជាសម្លាប់អញមិនខាន អញត្រូវរកឧបាយអ្វីមួយប្រញាប់សម្លាប់វាឲ្យបានមុន ភ្លាមនោះក៏គិតថា មិនឆ្ងាយអំពីទីនេះ មានស្រះដែលមានអារក្ស-ទឹកនៅ អញនឹងឲ្យអារក្សទឹកនោះ ស៊ីវានៅក្នុងស្រះនោះ ។ គិតដូច្នោះហើយ ក៏និយាយទៅកាន់ព្រះបរមពោធិសត្វថា នៃកូន ឪពុកចាស់ហើយ

ឪពុកនឹងប្រគល់ហ្វូងឲ្យកូនឯង ថ្ងៃនេះនឹងតែងតាំងកូនឯងឲ្យជាមេហ្វូង នៅទីឯណោះមានស្រះមួយ ក្នុងស្រះនោះមានផ្កាកុមុទ ២ ទង ឧប្បល ៣ ទង បទុម ៥ ទងកំពុងរីក ចូរកូនឯងទៅយកផ្កាទាំងនោះមក ។

ព្រះបរមពោធិសត្វទទួលថា សាធុបិតា ខ្ញុំនឹងទៅយកមក ហើយក៏ធ្វើដំណើរទៅ ប៉ុន្តែមិនប្រញាប់ចុះទៅភ្លាមទេ ពិនិត្យមើលជុំវិញស្រះ ឃើញតែស្នាមដើងចុះប៉ុណ្ណោះ មិនឃើញស្នាមដើងឡើង ក៏ដឹងថា ស្រះនេះប្រាកដជាមានអារក្សទឹកគ្រប់គ្រងមិនខាន បិតារបស់អញមិនអាចសម្លាប់អញដោយខ្លួនឯងបាន ទើបសង្ឃឹមថានឹងឲ្យអារក្សទឹកស៊ីអញជំនួសគាត់ អញនឹងមិនចុះក្នុងស្រះនេះ ហើយត្រូវបេះផ្កាឲ្យបានផង ហើយដើរទៅរកទីដែលមិនមានទឹក បេះបានផ្កាពីរទង លោតទៅត្រើយខាងនាយ លោតអំពីត្រើយខាងនាយមកត្រើយខាងអាយក៏ស្រវាចាប់បានផ្កាពីរទងទៀតដោយឧបាយនេះឯង ដោយវិធីនេះ ព្រះបរមពោធិសត្វបេះផ្កាបានមួយគំនរ ដោយមិនចាំបាច់ចុះកាន់ទីដែលនៅក្នុងអាជ្ញារបស់អារក្សទឹកឡើយ ។ លុះព្រះបរមពោធិសត្វឃើញថាមិនអាចបេះឲ្យបានច្រើនជាងនេះ ក៏ប្រមូលផ្កាទុកមួយគំនរ ។ ចំណែកអារក្សទឹកក៏ត្រិះរិះថា អស់កាលមានប្រមាណប៉ុណ្ណោះ អញមិនដែលឃើញអច្ឆរិយបុរសមានបញ្ញាយ៉ាងនេះឡើយ បេះផ្កាបានតាមសេចក្តីប្រាថ្នាដោយមិនចាំបាច់ចុះក្នុងទីដែលនៅក្នុងអាជ្ញារបស់អញ ទើបងើបឡើងអំពីទឹកចូល

*ទៅរកព្រះបរមពោធិសត្វពោលថា នៃពានរិន្ទដ៏ចម្រើន ក្នុងលោកនេះ បុគ្គលណាមានធម៌ ៣ ប្រការ បុគ្គលនោះរមែងកន្លងបង់នូវសត្រូវបាន ប្រហែលជាក្នុងខ្លួនរបស់អ្នកមានធម៌ទាំងអស់នោះគ្រប់ប្រការហើយមើលទៅ កាលនឹងសរសើរព្រះបរមពោធិសត្វ ទើបពោលគាថានេះថា*

**យស្សេតេ ច តយោ ធម្មា វានរិន្ទ យថា តវ**
**ទក្ខិយំ សូរិយំ បញ្ញា ទិដ្ឋំ សោ អតិវត្តតីតិ ។**

*បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៣ ដូចអ្នក គឺសេចក្តីសង្វាត ១ សេចក្តីក្លៀវក្លា ១ បញ្ញា ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន ។*

*បណ្តាបទទាំងនោះ បទថា* **ទក្ខិយំ** *បានដល់ ភាពជាអ្នកមានសេចក្តីព្យាយាម ។ បទនេះ ជាឈ្មោះរបស់សេចក្តីព្យាយាមយ៉ាងខ្ពស់ ដែលប្រកបដោយបញ្ញា ដែលដឹងឧបាយកម្ចាត់សត្រូវដែលបានជួបប្រសព្វ ។*

*បទថា* **សូរិយំ** *បានដល់ ភាពជាអ្នកក្លៀវក្លា ។ បទនេះ ជាឈ្មោះនៃអ្នកមិនមានការភ្ញាក់ផ្អើល ។*

*បទថា* **បញ្ញា** *នេះ ជាឈ្មោះនៃការដឹងឧបាយដែលជាចំណុចផ្តើមនៃការប្រាកដផល ។*

*អារក្សទឹកនោះសរសើរព្រះបរមពោធិសត្វដោយគាថានេះ យ៉ាង*

នេះហើយក៏សួរថា អ្នកបេះផ្កាទាំងនេះទៅធ្វើអ្វី?

ព្រះបរមពោធិសត្វឆ្លើយថា ឪពុករបស់យើង ចង់តែងតាំងយើងឲ្យធ្វើជាមេហ្វូង យើងបេះផ្កាទៅព្រោះហេតុនោះ ។

អារក្សទឹកពោលថា ឧត្តមបុរសដូចអ្នក មិនគួរនាំផ្កាទាំងនេះទៅទេ ខ្ញុំនឹងនាំយកទៅឲ្យ ហើយក្រសោបផ្កាទាំងនោះដើរតាមក្រោយព្រះបរម-ពោធិសត្វទៅ ។ គ្រានោះ បិតារបស់ព្រះបរមពោធិសត្វឃើញព្រះបរម-ពោធិសត្វអំពីចម្ងាយក៏គិតថា អញបញ្ជូនវាទៅដោយបំណងថា នឹងឲ្យជាចំណីអារក្សទឹក ឥឡូវនេះវាត្រឡប់ជាប្រើអារក្សទឹកឲ្យកាន់ផ្កាមកវិញ ពេលនេះអញវិនាសហើយ បេះដូងបែកជា ៧ បំណែក អស់ជីវិតក្នុងទីនោះឯង ។ ហ្វូងស្វាដ៏សេសប្រជុំគ្នាលើកព្រះបរមពោធិសត្វធ្វើជាស្តេចពានរ ។

ព្រះបរមសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ស្វាមេហ្វូងក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ចំណែកកូនរបស់ស្វាមេហ្វូងក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា តយោធម្មជាតក ទី ៨ ។

# អដ្ឋកថា ភេរិវាទជាតក ទី ៩

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ ពាក្យផ្ដើមថា **ធមេ ធមេ** ដូច្នេះជាដើម ។

សេចក្ដីសង្ខេបថា ព្រះបរមសាស្ដាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ពិតឬ ត្រង់ដែលគេថាអ្នកជាមនុស្សប្រដៅក្រ ? កាលភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ជាការពិតហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកជាមនុស្សប្រដៅក្រតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ សូម្បីកាលមុនអ្នកក៏ធ្លាប់ជាមនុស្សប្រដៅក្រដែរ ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលអ្នកវាយស្គរនៅក្នុងស្រុកមួយ ។ ព្រះបរមពោធិសត្វឮដំណឹងថា នៅក្នុងនគរពារាណសីមានបុណ្យដ៏ឱឡារិកមួយ ក៏គិតថា អញនឹងនាំស្គរទៅវាយជិតបរិវេណដែលមានមហោស្រពដើម្បីរកទ្រព្យ ហើយក៏នាំកូនប្រុសទៅកាន់នគរពារាណសីវាយស្គរបានទ្រព្យជាច្រើន នាំទ្រព្យទៅផ្ទះរបស់ខ្លួនធ្ងងកាត់ព្រៃចោរ ក៏ហាមឃាត់កូនប្រុសដែលវាយស្គរមិនឈប់ឈរថា នែកូន កូនឯងកុំវាយស្គរមិនឈប់ជាចន្លោះៗឡើយ ចូរវាយជាចន្លោះ ធ្វើដូចជាគេវាយស្គរ

ពេលអ្នកធំធ្វើដំណើរ ។ កូនប្រុសនោះ សូម្បីត្រូវបិតាហាមឃាត់ត្រឡប់ជានិយាយថា ខ្ញុំនឹងបណ្តេញពួកចោរឲ្យរត់គេចចេញទៅដោយសំឡេងស្គរឲ្យទាល់តែបាន ហើយក៏វាយថែមហើយថែមទៀត ដោយមិនឈប់ជាចន្លោះៗឡើយ ។ ពួកចោរស្តាប់សំឡេងស្គរលើកដំបូងហើយ ក៏គិតថា ចង្វាក់ដូចស្គរអ្នកធំដើរផ្លូវ នាំគ្នារត់គេច លុះស្តាប់សំឡេងជាប់ៗគ្នាច្រើនពេកទៅក៏និយាយគ្នាថា មិនមែនស្គរអ្នកធំដើរផ្លូវទេ ត្រឡប់មកពួនចាំមើលឃើញមនុស្សពីរនាក់ប៉ុណ្ណោះ ក៏ចោមរោមវាយដណ្តើមយកទ្រព្យ ។ ព្រះបរមពោធិសត្វពោលថា កូនឯងវាយស្គរថែមហើយថែមទៀត ដោយមានសំឡេងតែមួយ ជាហេតុធ្វើឲ្យទ្រព្យដែលយើងរកបានមកដោយលំបាក វិនាសអស់ ហើយពោលគាថានេះថា

**ធមេ ធមេ នាតិធមេ អតិធន្តំ ហិ បាបកំ**
**ធមន្តេន សតំ លទ្ធំ អតិធន្តេន នាសិតន្តិ ។**

បុគ្គលគប្បីវាយ (ស្គរ) ចុះ ប៉ុន្តែកុំវាយឲ្យជ្រុល ព្រោះ
ការវាយស្គរជ្រុល ជាការអាក្រក់ កហាបណៈមួយរយ
ដែលបានហើយដោយការវាយស្គរ (កូនវាឲ្យ) វិនាស
ហើយ ដោយការវាយស្គរជ្រុល ។

បណ្តាបទទាំងនោះ បទថា **ធមេ ធមេ** សេចក្តីថា ស្គរគួរវាយ មិនមែនមិនគួរវាយទេ អធិប្បាយថា ស្គរវាយបាន មិនមែនហាមមិនឲ្យ

*វាយទេ ។*

*បទថា* **ជាតិជមេ** *សេចក្ដីថា ប៉ុន្តែមិនគួរវាយឲ្យជ្រុលរហូតមិនឈប់នោះទេ ។*

*សួរថា ព្រោះហេតុអ្វី?*

*ឆ្លើយថា ព្រោះថា ការវាយស្គរជ្រុល ជាការអាក្រក់របស់យើង សេចក្ដីថា ការវាយស្គរមិនឈប់ជាការអាក្រក់ គឺបង្កឲ្យកើតរឿងអាក្រក់ដល់យើងទាំងពីរនាក់ ក្នុងកាលឥឡូវនេះ ។*

*បទថា* **ធមេន្តេន សតំ លទ្ធំ** *សេចក្ដីថា ព្រោះការវាយស្គរក្នុងនគរ បានទ្រព្យមកមួយរយកហាបណៈ ។*

*បទថា* **អតិធមេន្តេន ជាសិតំ** *សេចក្ដីថា ប៉ុន្តែពេលនេះ ព្រោះកូនប្រុសរបស់អញមិនធ្វើតាមពាក្យទូន្មាន វាយស្គរជ្រុលក្នុងព្រៃចោរនេះ ព្រោះការវាយស្គរជ្រុលនោះ ទ្រព្យទាំងអស់ត្រូវវិនាស ។*

*ព្រះបរមសាស្ដា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា កូនប្រុសក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាលឥឡូវនេះ ចំណែកបិតា គឺ* **តថាគត** *នេះឯង ៗ*

ចប់ អដ្ឋកថា ភេរិវាទជាតក ទី ៩ ។

# អដ្ឋកថា សទ្ទធមនជាតក ទី ១០

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រដូចគ្នា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **ជមេ ជមេ** *ដូច្នេះជាដើម ។*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលអ្នកផ្លុំស័ង្ខ ។ កាលមានបុណ្យក្នុងនគរពារាណសីយ៉ាងឱឡារិក ក៏នាំបិតាទៅផ្លុំស័ង្ខបានទ្រព្យ ពេលត្រឡប់មកវិញ ក៏ពោលហាមឃាត់បិតាអ្នកផ្លុំស័ង្ខមិនចេះឈប់ជិតៗព្រៃចោរ ។ បិតាត្រឡប់ជានិយាយថា នឹងបណ្តេញពួកចោរដោយសំឡេងស័ង្ខ ហើយផ្លុំស័ង្ខជ្រុលមិនដាច់ជាចន្លោះ ។ ពួកចោរក៏នាំគ្នាចោមរោមវាយដណ្តើមយកទ្រព្យអស់ ដោយមានទំនងដូចរឿងមុននោះឯង ។ ព្រះបរមពោធិសត្វពោលគាថា ដោយមានន័យដូចរឿងមុននោះថា*

**ធមេ ធមេ នាតិធមេ អតិធន្តំ ហិ បាបកំ**
**ធន្តេនាធិគតា ភោគា តេ តាតោ វិធមី ធមន្តិ ។**

*បុគ្គលគប្បីផ្លុំ (ស័ង្ខ) ចុះ ប៉ុន្តែកុំគប្បីផ្លុំឲ្យជ្រុល ព្រោះ*
*ការផ្លុំជ្រុល ជាការអាក្រក់ ភោគៈទាំងឡាយដែលបាន*
*ហើយដោយការផ្លុំ បិតាផ្លុំបំផ្លាញភោគៈទាំងនោះ ។*

បណ្ដាបទទាំងនោះ បទថា **តេ តាតោ វិឃមី ធមំ** សេចក្ដីថា បិតារបស់អញផ្ដុំស័ង្ខរឿយៗ ផ្ដុំរហូតទាល់តែធ្វើទ្រព្យដែលបានមក ដោយការផ្ដុំស័ង្ខនោះ វិនាសអស់មិនមានសេសសល់ ។

ព្រះបរមសាស្ដា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា បិតាក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រ ក្នុងកាលឥឡូវនេះ ចំណែកបុត្តក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា សង្ខធមនជាតក ទី ១០ ។

ចប់ អដ្ឋកថា អាសីសវគ្គ ទី ៦ ។

## រួមជាតកដែលមានក្នុងវគ្គនេះគឺ

មហាសីលវជាតក ១ ចូឡជនកជាតក ១ បុណ្ណបាតិជាតក ១ ផលជាតក ១ បញ្ចាវុធជាតក ១ កញ្ចនក្ខន្ធជាតក ១ វានរិន្ទជាតក ១ តយោធម្មជាតក ១ ភេរិវាទជាតក ១ សង្ខធមនជាតក ១ ។

# ឥត្ថីវគ្គ ទី ៧

# អដ្ឋកថា អសាតមន្តជាតក ទី ១

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកអផ្សុកចង់សឹក ត្រាស់ធម្មទេសនានេះ មានពាក្យផ្តើមថា* **អាសា លោកិត្ថិយោ** **នាម** *ដូច្នេះជាដើម ។*

*រឿងរបស់ភិក្ខុនោះ នឹងជាក់ច្បាស់ក្នុង* **ឧម្មាទន្តីជាតក** *។ រឿងសង្ខេបថា ព្រះបរមសាស្តា ទ្រង់ត្រាស់ទៅកាន់ភិក្ខុនោះថា ម្នាលភិក្ខុ ធម្មតាស្ត្រីដោយចំណែកច្រើន មិនគួរត្រេកអរ ឥតសតិ លាមក ជាអ្នកមានការបិទបាំង អ្នកអផ្សុកព្រោះស្ត្រីអាក្រក់ៗ ដូច្នេះធ្វើអ្វី? ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍នៅក្នុងនគរតក្កសិលា ដែនគន្ធាររដ្ឋ លុះដឹងក្តីហើយរៀនចប់ត្រៃវេទនិងសិល្បៈទាំងពួង បានជាអាចារ្យទិសាបាមោក្ខ ។ គ្រានោះ នៅក្នុងនគរពារាណសី មានត្រកូលព្រាហ្មណ៍មួយ ចាប់តាំងពីថ្ងៃដែលបុត្តប្រសូត ក៏ដុតភ្លើងទុកមិនឲ្យរលត់ឡើយ លុះពេលដែលព្រាហ្មណកុមារមានអាយុ ១៦ ឆ្នាំ មាតាបិតាក៏ពោលថា នែកូន យើងដុតភ្លើងតម្កល់ទុកក្នុងថ្ងៃដែលឯងកើតមក ប្រសិនបើកូនប្រាថ្នានឹងទៅកាន់ព្រហ្មលោក ចូរកាន់ភ្លើងនោះចូលព្រៃ*

បូជាព្រះអគ្គី ក៏នឹងដល់ព្រហ្មលោកបាន ប្រសិនបើប្រាថ្នានឹងគ្រប់គ្រងផ្ទះ ក៏ចូរទៅកាន់នគរតក្កសិលា រៀនសិល្បៈក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ហើយស្វែងរកទ្រព្យសម្បត្តិចុះ ។ មាណពនោះពោលថា ខ្ញុំមិនអាចនឹងចូលព្រៃបូជាភ្លើងបានទេ ខ្ញុំប្រាថ្នានឹងស្វែងរកទ្រព្យសម្បត្តិប៉ុណ្ណោះ ហើយលាមាតាបិតា ទទួលយកប្រាក់ ១ ពាន់កហាបណៈទុកជាតម្លៃសិក្សារៀន-សូត្រ ធ្វើដំណើរទៅកាន់នគរតក្កសិលា រៀនសិល្បៈហើយក៏ត្រឡប់មកវិញ ។ ប៉ុន្តែមាតាបិតារបស់មាណពនោះ មិនត្រូវការឲ្យបុត្តនៅគ្រប់គ្រងផ្ទះ ត្រូវការឲ្យបុត្តបម្រើភ្លើងក្នុងព្រៃ ។ គ្រានោះ មាតាប្រាថ្នានឹងសម្តែងទោសរបស់ស្ត្រីដោយចំណែកច្រើន ហើយបញ្ជូនមាណពចូលព្រៃ ក៏ត្រិះរិះថា អាចារ្យនោះគង់ជាបណ្ឌិតឈ្លាសវៃ អាចប្រាប់ទោសរបស់ស្ត្រីដោយចំណែកច្រើនដល់កូនរបស់អញបាន ទើបពោលថា នែកូនជាទីស្រលាញ់ កូនឯងរៀនសិល្បៈចប់ហើយឬ ?

មាណពឆ្លើយថា បាទម៉ែ ខ្ញុំរៀនចប់ហើយ ។

មាតាសួរថា សូម្បីអសាតមន្ត ក៏កូនឯងរៀនចប់ហើយឬ?

មាណពឆ្លើយថា មិនទាន់បានរៀនទេម៉ែ ។

មាតាពោលថា នែកូនជាទីស្រលាញ់ ប្រសិនបើកូនឯងមិនទាន់បានរៀនអសាតមន្តទេនោះ គេមិនហៅថារៀនសិល្បៈចប់ហើយដែរ ទៅចុះ កូនឯងទៅរៀនហើយសឹមមក ។ មាណពទទួលពាក្យហើយ ក៏ធ្វើ

ដំណើរទៅកាន់នគរតក្កសិលាម្ដងទៀត ។ ចំណែកមាតារបស់អាចារ្យ-ទិសាបាមោក្ខនោះ ជាស្ត្រីចាស់ជរា អាយុ ១២០ ឆ្នាំ អាចារ្យងូតទឹកឲ្យមាតាដោយដៃរបស់ខ្លួន រកអាហារឲ្យបរិភោគដោយខ្លួនឯង រកទឹកឲ្យផឹកដោយខ្លួនឯង បម្រើមាតាជានិច្ច អ្នកដទៃនាំគ្នារង្កៀសអាចារ្យដែលធ្វើយ៉ាងនោះ ។ អាចារ្យត្រិះរិះថា ល្អើយចុះ អញចូលព្រៃបម្រើមាតាក្នុងព្រៃនោះចុះ លុះគិតដូច្នោះហើយ ក៏ចាត់ចែងកសាងបណ្ណសាលាក្នុងទីមានទឹកស្រួល ក្នុងព្រៃដ៏ស្ងប់ស្ងាត់មួយ ធ្វើកិច្ចការងារស្រេចហើយជញ្ជូនរបស់របរមានប្រេងនិងអង្ករជាដើមមកបម្រុងទុក នាំមាតាទៅកាន់ទីនោះហើយបម្រើមាតាតទៅទៀត ។

ចំណែកមាណពទៅដល់នគរតក្កសិលាហើយ មិនឃើញអាចារ្យ ក៏សួរថា លោកអាចារ្យទៅណា ? លុះដឹងដំណឹងនោះហើយ ក៏ទៅកាន់ព្រៃនោះ ថ្វាយបង្គំអាចារ្យហើយឈរក្នុងទីដ៏សមគួរមួយ ។ គ្រានោះ អាចារ្យសួរមាណពនោះថា នែមាណពដ៏ចម្រើន តើមានរឿងអ្វី ទើបអ្នកឯងត្រឡប់មកវិញរហ័សម្ល៉េះ ?

មាណពសួរថា បពិត្រលោកអាចារ្យ លោកមិនទាន់បានឲ្យខ្ញុំរៀនអសាតមន្ត មិនមែនឬ ?

អាចារ្យសួរតបទៅវិញថា អ្នកណាបង្ខំឲ្យអ្នករៀនអសាតមន្ត ?

មាណពឆ្លើយថា បពិត្រលោកអាចារ្យ មាតារបស់ខ្ញុំជាអ្នកបង្ខំ ។

ព្រះបរមពោធិសត្វត្រិះរិះថា មន្តណាៗដែលមានឈ្មោះថា អសាតមន្ត មិនមានឡើយ ប៉ុន្តែមាតារបស់មាណពនេះ ពិតជាប្រាថ្នាឲ្យគេស្គាល់ទោសស្ត្រីជាប្រាកដ ទើបពោលថា ប្រពៃណាស់មាណព យើងនឹងឲ្យអសាតមន្តដល់ឯង ចាប់តាំងពីថ្ងៃនេះទៅ ឯងចូរធ្វើកិច្ចការជំនួសយើង ឲ្យមាតារបស់យើងផ្ងូតទឹកដោយដៃរបស់ឯង ឲ្យបរិភោគ ឲ្យផឹក បម្រើមាតារបស់យើងជានិច្ច ម្យ៉ាងទៀត កាលឯងប្របាច់ដៃ ជើង ក្បាល និងខ្នងរបស់មាតាយើង ត្រូវនិយាយសរសើរដៃជើងជាដើម ក្នុងពេលដែលកំពុងប្របាច់ថា បពិត្រម៉ែដ៏ចម្រើន ពិតមែនតែម៉ែចាស់ក៏ដោយ ប៉ុន្តែរាងកាយរបស់ម៉ែ នៅតែចង់ឲ្យគយគន់ជានិច្ច កាលម៉ែនៅក្រមុំរាងកាយរបស់ម៉ែស្រស់ស្អាតយ៉ាងណាហ្ន៎ កាលមាតារបស់យើងពោលពាក្យណា ឯងមិនត្រូវអៀនខ្មាស មិនត្រូវធ្វើឲ្យមាតារបស់យើងសង្ស័យឡើយ ប្រាប់ពាក្យនោះដល់យើងចុះ អ្នកធ្វើយ៉ាងនេះទើបនឹងបានអសាតមន្ត មិនធ្វើក៏មិនបាន ។ មាណពយល់ព្រមដោយពាក្យថា សាធុ លោកអាចារ្យ ចាប់តាំងពីថ្ងៃនោះមក មាណពក៏ធ្វើតាមប្រការដែលអាចារ្យប្រាប់គ្រប់យ៉ាង ។ កាលមាណពពោលសរសើររឿយៗ នាងក៏សម្គាល់ថា មាណពនេះត្រូវការអភិរម្យនឹងអញជាប្រាកដ ទាំងដែលខ្លួនជាមនុស្សចាស់ជរា ក្អែកងងឹតកិលេសក៏នៅកើតឡើងក្នុងសន្តានបាន ។ ថ្ងៃមួយ នាងក៏ពោលទៅកាន់មាណពដែលកំពុងពោលសរសើររាងកាយរបស់ខ្លួនថា អ្នកប្រាថ្នារួម

អភិរម្យជាមួយនឹងយើងឬ ?

មាណពឆ្លើយថា បពិត្រម៉ែ ខ្ញុំប្រាថ្នាខ្លាំងណាស់ ប៉ុន្តែ (វាមកទើសត្រង់ ) អាចារ្យជាទីគោរពកោតក្រែង ។

នាងពោលថា ប្រសិនបើអ្នកស្រលាញ់ខ្ញុំ ក៏ចូរសម្លាប់កូនខ្ញុំចុះ ។

មាណពពោលតបថា ខ្ញុំរៀនសិល្បៈច្រើនយ៉ាងនេះ ក្នុងសម្នាក់លោកអាចារ្យ នឹងមកសម្លាប់លោកអាចារ្យ ព្រោះអាស្រ័យហេតុត្រឹមតែកិលេសពុំសមគួរឡើយ ។

នាងពោលថា បើដូច្នោះ ប្រសិនបើអ្នកមិនបោះបង់ខ្ញុំទេនោះ ខ្ញុំនេះឯង នឹងសម្លាប់គេដោយផ្ទាល់ ។

ធម្មតាស្ត្រីដោយចំណែកច្រើនមិនគួរត្រេកអរ លាមក មានអាចម៌កំបាំងខាងក្នុងអាក្រក់យ៉ាងនេះ សូម្បីចាស់បែបនោះ ក៏នៅតែស្រឡាញ់ពេញចិត្តនឹងកាមគុណ រហូតប្រាថ្នាសម្លាប់កូនអ្នកមានឧបការៈបែបនេះក៏មាន ។

មាណពប្រាប់ពាក្យទាំងអស់នោះចំពោះព្រះបរមពោធិសត្វ ។ ព្រះបរមពោធិសត្វពោលថា ការដែលអ្នកប្រាប់រឿងរ៉ាវគ្រប់យ៉ាងនោះ ឈ្មោះថាអ្នកបានធ្វើនូវអំពើដ៏ត្រឹមត្រូវហើយ ។ កាលពិនិត្យមើលនូវអាយុសង្ខាររបស់មាតាក៏ដឹងថាត្រូវស្លាប់ក្នុងថ្ងៃនេះ ទើបពោលថា មកចុះមាណពយើងត្រូវសាកល្បងមើល ទើបកាត់ដើមល្វាមួយដើម ធ្វើរូបទីងមោងប៉ុន

ខ្លួន គ្របដណ្ដប់ជិតខ្លួន ដាក់ឲ្យដេកផ្ងារលើគ្រែដេករបស់ខ្លួន ចងខ្សែបង្កាន់ដៃទុកហើយ ពោលនឹងសិស្សថា នៃមាណព អ្នកចូរកាន់ពូថៅទៅឲ្យសញ្ញាដល់មាតារបស់យើង ។

មាណពក៏ទៅប្រាប់ថា បពិត្រម៉ែ អាចារ្យសម្រាន្តនៅលើគ្រែរបស់លោក លើបណ្ណសាលា ខ្ញុំចងខ្សែទុកធ្វើជាគ្រឿងសម្គាល់ហើយ ម៉ែកាន់ពូថៅនេះ ប្រសិនបើអាចសម្លាប់បាន ក៏ចូរសម្លាប់ចុះ ។

នាងពោលថា អ្នកមិនត្រូវបោះបង់ខ្ញុំចោលទេ ។

មាណពពោលថា រឿងអ្វីដែលខ្ញុំត្រូវបោះបង់ម៉ែចោលនោះ ។

នាងក៏ចាប់ពូថៅញ័រៗ ដើរទៅតាមខ្សែស្ទួរ យកដៃស្ទាបអង្អែលមើលសម្គាល់ក្នុងចិត្តថា នេះជាកូនប្រុសរបស់អញ ហើយបើកសំពត់គ្របចំណែកខាងមុខនៃរូបសិប្បនិមិត្ត ងាពូថៅដោយគិតថា នឹងកាប់តែម្ដងឲ្យស្លាប់នៅនឹងកន្លែង ហើយកាប់ត្រង់ក កាលមានសំឡេងលាន់ឮសូរខ្លាំងទើបបានដឹងថា មនុស្សដែលខ្លួនកាប់នោះជាឈើ ។ កាលព្រះបរមពោធិសត្វសួរថា បពិត្រមាតា តើមាតាធ្វើអ្វី ? ក៏គិតថា អញត្រូវគេបោកបញ្ឆោតហើយ លុះគិតដូច្នោះហើយ ក៏ដួលស្លាប់នៅត្រង់នោះឯង ។ បានឮថា ប្រសិនបើនាងមិនដេកស្លាប់នៅក្នុងបណ្ណសាលារបស់ព្រះបរមពោធិសត្វ ក៏គង់ស្លាប់ក្នុងខណៈនោះឯង ។ ព្រះបរមពោធិសត្វដឹងថាមាតាស្លាប់ហើយក៏ធ្វើសរីរកិច្ច លុះភ្លើងដែលឆេះសាកសពនោះរលត់

ហើយក៏បូជាដោយផ្កា ហើយនាំមាណពមកអង្គុយត្រង់ទ្វារបណ្ណសាលា ពោលទូន្មានថា នែមាណព ដែលឈ្មោះថាអសាតមន្ត ចាត់ជាវិជ្ជាមួយផ្នែកដោយចំពោះមិនមានទេ ក៏ប៉ុន្តែស្ត្រីដោយចំណែកច្រើន មិនស្គាល់រាក់ជ្រៅ ស្រឡាញ់ងាយ មាតារបស់អ្នកប្រាប់ឲ្យអ្នករៀនអសាតមន្ត ហើយបញ្ជូនអ្នកមកកាន់សម្នាក់យើង ការដែលមាតារបស់អ្នកបញ្ជូនអ្នកមកសម្នាក់យើង ក៏ដើម្បីឲ្យដឹងទោសរបស់ស្ត្រី ឥឡូវនេះ អ្នកក៏ឃើញទោសរបស់មាតាយើងដោយច្បាស់ហើយ ដោយហេតុនេះ គប្បីជ្រាបថា ធម្មតាស្ត្រីដោយច្រើន មិនចេះឆ្អែត លាមក ដូច្នេះហើយ បញ្ជូនមាណពឲ្យត្រឡប់ទៅវិញ ។ មាណពនោះលាអាចារ្យទៅកាន់សម្នាក់មាតាបិតាវិញ ពេលនោះមាតាសួរថា កូនឯងរៀនអសាតមន្តចប់ហើយឬ ?

មាណពឆ្លើយថា បាទម៉ែ រៀនចប់ហើយ ។

មាតាសួរថា ពេលនេះកូនឯងចង់ធ្វើអ្វី ចង់បួសបម្រើភ្លើង ឬក៏នៅគ្រប់គ្រងផ្ទះ ?

មាណពឆ្លើយថា បពិត្រមាតា ខ្ញុំឃើញទោសរបស់ស្ត្រីដោយជាក់-ច្បាស់ហើយ ខ្ញុំមិនត្រូវការនៅគ្រប់គ្រងផ្ទះទេ ខ្ញុំនឹងបួស កាលនឹងប្រកាសសេចក្តីប្រាថ្នារបស់ខ្លួន ទើបពោលគាថានេះថា

**អាសា លោកិត្ថិយោ ណាម វេលា តាសំ ន វិជ្ជតិ**
**សារត្តា ច បគព្ភា ច សិខី សព្វឃសោ យថា**

**តា ហិត្វា បព្វជិស្សាមិ វិវេកមនុព្រូហយន្តិ ។**

*ធម្មតាពួកស្ត្រីក្នុងលោក តែងមានសេចក្តីប្រាថ្នា (ចំពោះបុរសដែលមានចិត្តជាប់ចំពាក់នឹងខ្លួន) វេលា (ឬកម្រិត) របស់ស្ត្រីទាំងនោះ មិនមានឡើយ (ស្ត្រីទាំងនោះ) ត្រេកត្រអាលផង រលោភលោភផង ដូចភ្លើងដែលឆេះវត្ថុគ្រប់យ៉ាង (មិនរើសមុខ) ខ្ញុំនឹងលះបង់ស្ត្រីទាំងនោះ ហើយបួស ចម្រើននូវវិវេកធម៌ ។*

*បណ្ដាបទទាំងនោះ បទថា* **អាសា** *សេចក្តីថា មិនចេះឈប់ឈរ គឺមានការប្រព្រឹត្តិអាក្រក់ ។ម្យ៉ាងទៀត សេចក្តីសុខលោកហៅថា* **សាតៈ** *សេចក្តីសុខនោះ មិនមានដល់ស្ត្រីទាំងនោះ ទាំងញុំាងការមិនសុខចិត្តឲ្យកើតដល់អ្នកដែលមានចិត្តប្រតិព័ទ្ធខ្លួន ទើបឈ្មោះថា មិនចេះឈប់ឈរ អធិប្បាយថា នៅមិនសុខគឺជាទីតាំងនៃសេចក្តីទុក្ខ ។ ដើម្បីនឹងសម្តែងសេចក្តីនេះឲ្យជាក់ច្បាស់ គប្បីនាំព្រះសូត្រនេះមកសាធកដូច្នេះថា*

*ស្ត្រីទាំងនោះ មានកលល្បិច ១០០ ជំពូក បោកបញ្ឆោត ជាអណ្ដូងកើតនៃសេចក្តីសោក ឬមានរោគ ជាតួចង្រៃ គ្រោតគ្រាត បង្កឲ្យកើតចំណង់ ជាដើមហេតុនៃសេចក្តីស្លាប់ បុរសណាជាប់ចិត្តនឹងស្រី បុរសនោះ ចាត់ជាមនុស្សអាក្រក់ ក្នុងពួកមនុស្ស ។*

*បណ្ដាបទទាំងនោះ បទថា* **លោកិត្ថិយោ** *ប្រែថា ស្ត្រីក្នុងលោក ។*

បទថា **វេលា តាសំ ន វិជ្ជតិ** សេចក្តីថា បពិត្រម៉ែ ស្ត្រីទាំងនោះ កិលេសកើតឡើងហើយ វេលាគឺការសង្រួម ព្រំដែនឈ្មោះថាប្រមាណ មិនមានឡើយ ជាស្ត្រីត្រេកអរខ្លាំង គឺជាប់ចិត្តក្នុងកាមគុណទាំង ៥ ទាំង ជាអ្នកគ្មានក្រែងរអែង ព្រោះប្រកបដោយការគ្នង ៣ ប្រការគឺ គ្នងដោយ កាយ គ្នងដោយវាចា គ្នងដោយចិត្ត ។ ព្រោះថាការសង្រួម នៅពេលជួប ប្រសព្វនឹងអារម្មណ៍មានកាយទ្វារជាដើម មិនមានក្នុងស្ត្រីទាំងនោះឡើយ គឺជាស្ត្រីអន្ទះអន្ទែង ប្រៀបបាននឹងពួកក្អែក ព្រាហ្មណមាណពសម្តែង លក្ខណៈស្ត្រីដូចពណ៌នាមកនេះ ។

បទថា **សិខី សព្វភ្ខសោ យថា** សេចក្តីថា ធម្មតាភ្លើងដែល ដល់ការរាប់ថា **សិខី** ព្រោះមានអណ្តាតស្រួច បានគ្រឿងឆេះណាមួយ ទោះបីវត្ថុនោះមិនស្អាត មានលាមកជាដើម ឬរបស់ស្អាត មានទឹកដោះថ្លា ទឹកឃ្មុំ ទឹកអំពៅជាដើម គួរប្រាថ្នាខ្លះ មិនគួរប្រាថ្នាខ្លះ ក៏ឆេះទាំងអស់ ព្រោះហេតុនោះ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា ឆេះគ្រប់យ៉ាង យ៉ាងណាមិញ សូម្បីស្ត្រីទាំងឡាយក៏ដូច្នោះដែរ ទោះជាមនុស្សមាន កំណើតថោកទាប មានការងារថោកទាប ដូចជាហ្មដំរី អ្នកចិញ្ចឹមគោជា ដើមក៏ដោយ ទោះជាមនុស្សមានកំណើតខ្ពង់ខ្ពស់ ការងារខ្ពង់ខ្ពស់ដូចជា ក្សត្រជាដើមក៏ដោយ មិនបានគិតដល់ភាពថោកទាបឬខ្ពង់ខ្ពស់ឡើយ កាល សេចក្តីត្រេកអរដោយអំណាចកិលេសកើតឡើងហើយ ដោយអំណាចនៃ

សេចក្តីត្រេកអរក្នុងលោក បានមនុស្សប្រភេទណា ក៏សេពបានទាំងអស់ ព្រោះហេតុដូច្នោះ ទើបប្រៀបដូចភ្លើងដែលឆេះវត្ថុគ្រប់យ៉ាង ភ្លើងស៊ីវត្ថុគ្រប់យ៉ាង យ៉ាងណាមិញ ស្ត្រីទាំងនោះក៏គប្បីជ្រាបថា មានសភាពដូច្នោះដែរ ។

បទថា **តា ហិត្វា បព្វជិស្សាមិ** ខ្ញុំនឹងលះបង់ស្ត្រីលាមក ទាំងដែលជាទីតាំងនៃសេចក្តីទុក្ខនោះ ចូលព្រៃបួសជាឥសី ។

បទថា **វិវេកមនុព្រូហយំ** សេចក្តីថា វិវេកមាន ៣ គឺកាយ-វិវេក ចិត្តវិវេក ឧបធិវិវេក បណ្តាវិវេកទាំង៣ នោះ គួរចម្រើនកាយវិវេកផង ចិត្តវិវេកផង ។ លោកអធិប្បាយទុកថា ( មាណពពោលថា ) បពិត្រមាតា ខ្ញុំត្រូវការបួសធ្វើកសិណបរិកម្ម ញុំាងសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតឡើង ហើយនឹងចៀសចេញចាកពួកគណៈ ព្រមទាំងដកចិត្តចាកកិលេស ចម្រើនវិវេកនឹងជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ រឿងគ្រប់គ្រងផ្ទះសម្រាប់ខ្ញុំមិនមានឡើយ ។

មាណពតិះដៀលស្ត្រីទាំងឡាយយ៉ាងនេះហើយ លាមាតាបិតាទៅបួស ចម្រើនវិវេកមានប្រការដូចពោលហើយ បានជាអ្នកមានព្រហ្ម-លោកជាទីទៅខាងមុខ ។

ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុ ធម្មតាស្ត្រីទាំងឡាយក្នុងលោក មិនចេះស្កប់ស្កល់នឹងកាមគុណ លាមក មានខាងដើមនិងទីបំផុត

ជាហេតុឲ្យកើតទុក្ខយ៉ាងនេះ ទ្រង់សម្តែងទោសនៃស្ត្រីទាំងឡាយហើយ ទើបទ្រង់ប្រកាសសច្ចធម៌ លុះចប់សច្ចធម៌ ភិក្ខុនោះបានសម្រេចសោតាបត្តិផល ។ ព្រះបរមសាស្តា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា មាតារបស់មាណពក្នុងកាលនោះ បានមកជាភិក្ខុនីឈ្មោះ ភទ្ទាកាបិលានី ក្នុងកាលឥឡូវនេះ បិតារបស់មាណព បានមកជាមហាកស្សប មាណពជាកូនសិស្ស បានមកជាអានន្ទ ចំណែកអាចារ្យ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា អសាតមន្តជាតក ទី ១ ។

# អដ្ឋកថា អណ្ឌភូតជាតក ទី ២

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកអផ្សុក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យំ ព្រាហ្មណោ អវាទេសិ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ព្រះដ៏មានព្រះភាគត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ពិតមែនឬ ត្រង់ដែលគេថាអ្នកអផ្សុកចង់សឹកនោះ ? លុះភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតមែនហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ធម្មតាស្ត្រីទាំងឡាយ បុគ្គលណាក៏រក្សាមិនបាន កាលមុនបណ្ឌិតទាំងឡាយ សូម្បីចង់រក្សាស្ត្រីទុកតាំងតែពីប្រសូតចាកផ្ទៃ ក៏មិនអាចរក្សាបាន ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងផ្ទៃនៃអគ្គមហេសីរបស់ព្រះបាទព្រហ្មទត្តនោះ លុះទ្រង់ចម្រើនវ័យហើយក៏សិក្សាសិល្បៈចប់សព្វគ្រប់ លុះព្រះវររាជបិតាសោយទិវង្គតទៅក៏បានសោយរាជ្យប្រកបដោយធម៌ ។ ព្រះរាជាទ្រង់ពេញព្រះទ័យលេងល្បែងបាស្កាជាមួយនឹងបុរោហិត កាលនឹងទ្រង់កំសាន្ត ទ្រង់ច្រៀងចម្រៀងសម្រាប់ការភ្នាល់នេះថា

ស្ទឹងទាំងអស់មានដំណើរវៀច ព្រៃទាំងអស់សម្រេចអំពីឈើ
( យ៉ាងណាមិញ ) ពួកស្រីទាំងអស់ ( វៀរលែងតែស្រីមាន
កិលេសស្តើង ) កាលបើមានបុគ្គលអ្នកខ្សឹបខ្សៀវ ក៏តែងធ្វើ
នូវអំពើលាមកបាន ( យ៉ាងនោះដែរ ) ។

លុះទ្រង់ច្រៀងរួចហើយ ទើបទ្រង់ដើរកូនបាស្កាមាសលើបន្ទះក្តារប្រាក់ ។ កាលព្រះរាជាទ្រង់លេងដោយវិធីនេះ ទ្រង់ឈ្នះជានិច្ច ។ ចំណែកបុរោហិតចាញ់ជានិច្ច ។ បុរោហិតកាលទ្រព្យសម្បត្តិក្នុងផ្ទះអស់ទៅៗដោយលំដាប់ដូច្នេះ ក៏បានគិតថា ប្រសិនបើយ៉ាងនេះ ទ្រព្យសម្បត្តិក្នុងផ្ទះគ្រប់យ៉ាងត្រូវអស់ជាប្រាកដ អញត្រូវរកមាតុគ្រាមម្នាក់ដែលមិនធ្លាប់រួមដំណេកនឹងបុរសដទៃ មកនៅក្នុងផ្ទះឲ្យខាងតែបាន ។ លុះគិតដូច្នោះហើយ ក៏ត្រឡប់កើតបរិវិតក្កថា អញមិនអាចនឹងរក្សាស្ត្រីដែលធ្លាប់ឃើញបុរសដទៃបានទេ អញចាំបាច់រក្សាស្ត្រីម្នាក់ដែលទើបតែកើត លុះ

ចម្រើនវ័យហើយទើបឲ្យនៅក្នុងអំណាច ធ្វើឲ្យជាស្ត្រីមានបុរសតែម្នាក់ ចាត់ចែងការរក្សាយ៉ាងមាំ ទើបនឹងនាំយកទ្រព្យមកអំពីរាជត្រកូលបាន ។ បុរោហិតនោះជាមនុស្សឈ្លាសវៃក្នុងវិជ្ជាមើលអវយវៈ ដូច្នោះហើយ គ្រាន់តែឃើញស្ត្រីទុគ៌តម្នាក់មានគភ៌ក្លាម ក៏ដឹងថា នាងនឹងសម្រាលកូនស្រី ទើបហៅនាងមកឲ្យស្នៀង ឲ្យនៅតែក្នុងផ្ទះប៉ុណ្ណោះ លុះសម្រាលកូនហើយក៏ឲ្យប្រាក់បញ្ជូនស្រីនោះទៅ ។ បុរោហិតមិនឲ្យក្មេងស្រីនោះឃើញបុរសដទៃឡើយ អនុញ្ញាតឲ្យតែពួកស្ត្រីប៉ុណ្ណោះ ប៉ះបាន ចិញ្ចឹមមើលថែរហូតពេញវ័យទើបធ្វើឲ្យនាងនៅក្នុងអំណាចរបស់ខ្លួន នៅចន្លោះពេលដែលកុមារីនោះមិនទាន់ធំពេញវ័យ បុរោហិតនោះមិនព្រមលេងល្បែងបាស្កាភ្នាល់ជា មួយព្រះរាជាឡើយ លុះធ្វើឲ្យកុមារីនោះនៅក្នុងអំណាចហើយ ក៏ក្រាបទូលព្រះរាជាថា បពិត្រមហារាជ យើងលេងល្បែងបាស្កាភ្នាល់ចុះ ។ ព្រះរាជាទ្រង់យល់ព្រមដោយព្រះតម្រាស់ថា នៃបុរោហិត ប្រពៃហើយ ។ ព្រះរាជាទ្រង់លេងដោយទំនងដូចមុននោះឯង នៅពេលដែលព្រះរាជាទ្រង់ច្រៀងហើយទតមើលកូនបាស្កា បុរោហិតក៏ពោលថា វៀរមាណវិកា ។ ចាប់តាំងពីពេលនោះមក បុរោហិតក៏ឈ្នះព្រះរាជាវិញ ។

ព្រះបរមពោធិសត្វទ្រង់ប៉ាន់ស្មានថា នៅក្នុងផ្ទះរបស់បុរោហិតនេះប្រាកដជាមានស្ត្រីម្នាក់ដែលមានប្រុសតែម្នាក់ ទ្រង់ឲ្យអាមាត្យទៅស៊ើប

មើល ក៏ទ្រង់ជ្រាបថា មានពិត ទ្រង់ព្រះតម្រិះតទៅថា ត្រូវឲ្យមនុស្ស ទម្លាយសីលរបស់នាង ទើបបញ្ជាឲ្យហៅអ្នកលេងម្នាក់ចូលគាល់ មាន ព្រះតម្រាស់ថា នែអ្នកដ៏ចម្រើន តើអ្នកអាចទម្លាយសីលនៃស្ត្រីដែលជា ប្រពន្ធរបស់បុរោហិតបានឬទេ ?

អ្នកលេងនោះទទួលព្រះរាជឱង្ការថា បពិត្រព្រះសម្មតិទេព ទូល-បង្គំអាច ។ ពេលនោះ ព្រះរាជាទ្រង់ព្រះរាជទានទ្រព្យដល់អ្នកលេងនោះ ហើយមានព្រះតម្រាស់ថា បើដូច្នោះ ចូរធ្វើឲ្យសម្រេចដោយឆាប់ចុះ ក៏ បញ្ជូនអ្នកលេងនោះទៅ ។ អ្នកលេងនោះទទួលទ្រព្យហើយ ចំណាយ ទិញគ្រឿងក្រអូបមានខ្លឹមចន្ទន៍និងក្រស្នាជាដើម ទៅបើករានលក់គ្រឿង ក្រអូបគ្រប់យ៉ាងមិនឆ្ងាយអំពីផ្ទះរបស់បុរោហិតនោះ ។ ចំណែកផ្ទះរបស់ បុរោហិតក៏ជាផ្ទះ ៧ ជាន់ មានខ្លោងទ្វារ ៧ ត្រង់ខ្លោងទ្វារនីមួយៗ មានស្ត្រី រក្សាទាំងអស់ បុរសដទៃវៀរព្រាហ្មណ៍ចេញ មិនមានអ្នកណាបានចូលទៅ កាន់ផ្ទះនោះឡើយ សូម្បីធុងសំរាមក៏សុទ្ធតែជាស្ត្រីទៅជម្រះទាំងអស់ មាន តែបុរោហិតនិងស្រីបម្រើរបស់មាណវិកានោះប៉ុណ្ណោះ ដែលបានឃើញ មាណវិកានោះ ។ គ្រានោះ ស្ត្រីអ្នកបម្រើរបស់មាណវិកា កាន់ទ្រព្យដែល ជាតម្លៃសម្រាប់ទិញគ្រឿងក្រអូបនិងផ្កាដើរទៅ ពេលដើរទៅនោះ បានដើរ ឆ្លងកាត់តូបលក់គ្រឿងក្រអូបរបស់អ្នកលេងនោះ អ្នកលេងនោះដឹងយ៉ាង ច្បាស់ថា ស្ត្រីនេះ ជាស្ត្រីបម្រើមាណវិកា ។ ថ្ងៃមួយ គ្រាន់តែឃើញនាង

ដើរមកភ្ជាម ក៏ក្រោកឡើងអំពីតូបលក់ ស្ទុះចូលទៅផ្តួលខ្លួនជិតជើងនាង ឱបជើងទាំងពីរយ៉ាងណែនដោយដៃទាំងពីរ រួចយំរៀបរាប់ថា បពិត្រមាតា មាតាទៅណាបាត់យូរម្ល៉េះ ? ពួកអ្នកលេងដ៏សេសដែលឈរនៅម្ខាងនោះ ក៏នាំគ្នានិយាយថា ម៉ែនិងកូនមើលទៅដូចគ្នាដោយសណ្ឋាននៃដៃ ជើង និងមុខ ហើយអាកប្បកិរិយាមើលទៅដូចមនុស្សតែម្នាក់ ។ ស្ត្រីនោះ កាលពួកអ្នកលេងនាំគ្នានិយាយដូច្នោះ ក៏ជឿយ៉ាងមាំ ហើយយល់ថា បុរសនេះជាកូនរបស់ខ្លួនពិតមែន សូម្បីខ្លួនឯងក៏យំរៀបរាប់ដែរ ។ ជន ទាំងពីរនាក់នោះ ក៏ឈរឱបគ្នាយំ ។

គ្រានោះ អ្នកលេងក៏ពោលថា បពិត្រមាតា មាតានៅទីណា ?

នាងឆ្លើយថា មាតានៅបម្រើស្រីក្រមុំរបស់បុរោហិត ដែលមាន ដំណើរល្វត់ល្វន់ ស្រស់ឆើត រូបស្អាតដូចកិន្នរី ។

អ្នកលេងនោះសួរតទៅទៀតថា ឥឡូវនេះ មាតានឹងទៅទីណា ?

នាងប្រាប់ថា មាតានឹងទៅរកទិញគ្រឿងក្រអូបនិងកម្រងផ្កាជូន ស្រីក្រមុំនោះ ។

អ្នកលេងពោលថា បពិត្រមាតា មាតាចាំបាច់ទៅទិញទីដទៃធ្វើអ្វី ចាប់ពីថ្ងៃនេះទៅ សូមមាតាយករបស់ខ្ញុំចុះ ហើយមិនទទួលប្រាក់តម្លៃ គ្រឿងក្រអូប ឲ្យវត្ថុមានស្លា ម្លូ ក្រវាញជាដើម ព្រមទាំងផ្កាជាច្រើន ។ មាណវិកាឃើញគ្រឿងក្រអូបនិងផ្កាច្រើនសន្ធឹកសន្ធាប់ ក៏សួរថា

បពិត្រម៉ែ ថ្ងៃនេះ ព្រាហ្មណ៍របស់យើងសប្បាយចិត្តឬយ៉ាងណា ?

នាងសួរថា ហេតុដូចម្ដេចទើបចៅហ្វាយសួរយ៉ាងនេះ ?

មាណវិកាឆ្លើយថា ព្រោះខ្ញុំឃើញរបស់ទាំងនេះច្រើនពេក ។

នាងពោលថា ព្រាហ្មណ៍មិនបានឲ្យប្រាក់ដែលជាតម្លៃវត្ថុដ៏ច្រើនទាំងនេះទេ ប៉ុន្តែវត្ថុទាំងនេះខ្ញុំយកមកអំពីសម្នាក់កូនរបស់ខ្ញុំ ។ ចាប់តាំងពីពេលនោះមក នាងក៏យកប្រាក់ថ្លៃវត្ថុដែលព្រាហ្មណ៍ឲ្យដោយខ្លួនឯងហើយទៅយកគ្រឿងក្រអូបនិងផ្កាជាដើម មកអំពីសម្នាក់អ្នកលេងនោះជានិច្ច ។ កន្លងមកបានពីរ-បីថ្ងៃ អ្នកលេងក៏សាកល្បងធ្វើដូចជាឈឺដេកនៅលើគ្រែ នាងទៅដល់ទ្វារតូបរបស់អ្នកលេងនោះ មិនឃើញក៏សួរថា កូនរបស់ខ្ញុំទៅណា ? មនុស្សនៅក្នុងតូបនោះប្រាប់ថា កូនប្រុសរបស់នាងឈឺ ។ នាងទៅដល់ទីដេករបស់អ្នកលេងហើយអង្គុយស្ទាបខ្នង រួចសួរថា នែកូន កូនឯងមិនស្រួលខ្លួនឬ ? អ្នកលេងនៅស្ងៀម ។ នាងក៏សួរទៀតថា ហេតុដូចម្ដេចកូនឯងមិនឆ្លើយ ?

អ្នកលេងពោលថា បពិត្រមាតា សូម្បីខ្ញុំស្លាប់ក៏មិនអាចប្រាប់មាតាបាន ។

នាងក៏ពោលថា ប្រសិនបើម៉ែជាមនុស្សដែលកូនឯងមិនគួរប្រាប់ តើកូនឯងគួរប្រាប់អ្នកណា ? ប្រាប់ម៉ែមកចុះ ។

អ្នកលេងក៏ប្រាប់ថា បពិត្រមាតាខ្ញុំមិនឈឺអ្វីទេ ប៉ុន្តែខ្ញុំបានឮមាតា

សរសើរមាណវិកាហើយ ក៏មានចិត្តប្រតិព័ទ្ធយ៉ាងខ្លាំង កាលបើខ្ញុំបាននាង ទើបមានជីវិតតទៅ កាលមិនបាននឹងស្លាប់ក្នុងទីនេះឯង ។

នាងពោលថា នែកូន រឿងនេះទុកឲ្យជាភារៈរបស់ម៉ែចុះ កូនកុំខ្វល់ចិត្តព្រោះរឿងនេះឡើយ លួងលោមចិត្តអ្នកលេងនោះហើយ ក៏យកគ្រឿងក្រអូបនិងផ្កាទៅយ៉ាងសន្ធឹកសន្ធាប់ មកដល់សម្នាក់មាណវិកា ហើយក៏ពោលថា បពិត្រនាងម្ចាស់ កូនរបស់ខ្ញុំបានឮពាក្យសរសើរនាងម្ចាស់អំពីសម្នាក់របស់ខ្ញុំហើយ មានចិត្តប្រតិព័ទ្ធយ៉ាងខ្លាំង តើធ្វើយ៉ាងណាទៅទើបល្អ?

មាណវិកាឆ្លើយថា ប្រសិនបើម៉ែនាំកូនប្រុសរបស់ម៉ែមកបាន ខ្ញុំនឹងឲ្យឱកាស ។ ស្ត្រីបម្រើនោះស្តាប់ពាក្យរបស់មាណវិកាហើយ ចាប់ពីពេលនោះមក ក៏កើបសំរាមជាច្រើនមកអំពីជ្រុងនៃផ្ទះគ្រប់ជ្រុង មកចាក់លើក្បាលស្ត្រីដែលយាមខ្លោងទ្វារ ។ ស្ត្រីអ្នកយាមចង្អៀតចង្អល់ចិត្តដោយរឿងនោះក៏ចេញទៅ ឈប់យាមខ្លោងទ្វារ ។ ដោយទំនងនេះឯង ស្ត្រីអ្នកយាមណានិយាយអ្វីៗ នាងក៏កើបសំរាមចាក់លើក្បាលស្ត្រីអ្នកយាមនោះៗ ចាប់តាំងពីពេលនោះមក ទោះបីនាងនាំវត្ថុណាចូលមក ឬនាំចេញទៅ ក៏មិនមានអ្នកណាហ៊ានត្រួតពិនិត្យមើលវត្ថុនោះ ។

បានឱកាស នាងឲ្យអ្នកលេងនោះដេកក្នុងកំប្រោងផ្កា រែកទៅកាន់សម្នាក់មាណវិកា ។ អ្នកលេងនោះទម្លាយសីលរបស់មាណវិកាហើយ ក៏

នៅក្នុងប្រាសាទនោះឯងពីរ-បីថ្ងៃ ។ កាលបុរោហិតចេញទៅខាងក្រៅ ទាំងពីរនាក់ក៏រួមអភិរម្យ កាលបុរោហិតមក អ្នកលេងក៏ពួន ។ លុះកន្លង មកបានមួយឬពីរថ្ងៃ មាណវិកាក៏និយាយនឹងអ្នកលេងថា បងសម្លាញ់ ពេលនេះបងឯងគួរទៅទីណា ?

អ្នកលេងក៏ពោលថា ខ្ញុំនឹងវាយ ( ក្បាល ) ព្រាហ្មណ៍ឲ្យបានមុន នឹងទៅ ។

មាណវិកាពោលថា យ៉ាងនោះក៏បាន ហើយឲ្យអ្នកលេងពួន ។ កាលព្រាហ្មណ៍មកក៏និយាយយ៉ាងនេះថា បពិត្រព្រាហ្មណ៍ ខ្ញុំចង់រាំនៅ ពេលដែលលោកលេងពិណ ។

ព្រាហ្មណ៍យល់ព្រមថា នែនាងដ៏ចម្រើន នាងចូររាំចុះ ។

នាងពោលថា បពិត្រព្រាហ្មណ៍ ខ្ញុំខ្មាសអៀននៅពេលដែល លោកសម្លឹងមើលខ្ញុំ ខ្ញុំសូមបិទមុខលោកសិន សឹមរាំ ។

បុរោហិតពោលថា ប្រសិនបើនាងអៀនខ្មាស ក៏ចូរធ្វើយ៉ាងនោះ ចុះ ។ មាណវិកាចាប់យកសំពត់សាច់ក្រាស់បិទភ្នែកបុរោហិតហើយចង រហូតទាល់តែងងឹតមើលអ្វីមិនឃើញ ព្រាហ្មណ៍ព្រមឲ្យបិទភ្នែក ដេញ ពិណរឿយៗទៅ ។ មាណវិការាំបានបន្តិចក៏ពោលថា បពិត្រព្រាហ្មណ៍ខ្ញុំ ចង់ខោកក្បាលលោកម្តង ។ ព្រាហ្មណ៍វង្វេងចំពោះស្ត្រី មិនដឹងហេតុ-ការណ៍ ក៏ពោលថា ខោកចុះអូន ។ មាណវិកាឲ្យសញ្ញាដល់អ្នកលេង ។

អ្នកលេងជំទើតដើងចូលមកជិត ឈរក្រោយខ្នងព្រាហ្មណ៍ហើយខោកក្បាលដោយកែងដៃ ។ ភ្នែករបស់ព្រាហ្មណ៍លៀន ក្បាលពកឡើង ព្រាហ្មណ៍ឈឺចាប់ប្រញាប់ពោលថា នាងចូរបញ្ជូនដៃមកនេះ ។ នាងក៏ហុចដៃរបស់ខ្លួនដាក់លើដៃព្រាហ្មណ៍ ។ ព្រាហ្មណ៍ពោលថា ដៃទន់ភ្លន់ប៉ុន្តែខោកឈឺណាស់ អ្នកលេងលុះខោកក្បាលព្រាហ្មណ៍ហើយ ក៏លាក់ខ្លួនពួនអាត្មា ។ មាណវិកា កាលអ្នកលេងលាក់ខ្លួនបាត់ ក៏យកសំពត់ចេញអំពីមុខព្រាហ្មណ៍ ហើយយកប្រេងមកលាបច្របាច់ក្បាលឲ្យព្រាហ្មណ៍ ។ កាលព្រាហ្មណ៍ចេញទៅខាងក្រៅ ស្ត្រីបម្រើឲ្យអ្នកលេងដេកក្នុងកំប្រោងផ្កាដូចមុន នាំចេញទៅ ។ អ្នកលេងក៏ទៅគាល់ព្រះរាជាក្រាបទូលរឿងរ៉ាវទាំងអស់ឲ្យទ្រង់ជ្រាប ។

ព្រះរាជាក៏ត្រាស់ទៅកាន់ព្រាហ្មណ៍ដែលចូលមកគាល់ទ្រង់ថា នែព្រាហ្មណ៍ យើងលេងបាស្កាភ្នាល់គ្នាទៀតចុះ ។

បុរោហិតឆ្លើយតបនឹងព្រះតម្រាស់ថា ព្រះករុណាថ្លៃវិសេស ។ ព្រះរាជាបញ្ជាឲ្យចាត់ចែងកន្លែងដើម្បីលេងបាស្កា ទ្រង់ច្រៀងបទចម្រៀងស្ដីអំពីការលេងភ្នាល់ហើយ ទ្រង់ទតមើលកូនបាស្កា ព្រាហ្មណ៍មិនដឹង ថា មាណវិកាត្រូវទម្លាយតបៈហើយនៅតែពោលថា វៀរមាណវិកា សូម្បីពោលយ៉ាងនេះក៏ដោយ ក៏នៅតែលេងចាញ់ព្រះរាជាដដែល ។ ព្រះរាជាទ្រង់ឈ្នះ ហើយត្រាស់ថា នែព្រាហ្មណ៍ អ្នកពោលអ្វីទៀត ? តបៈនៃ

នាងមាណវិការបស់អ្នកត្រូវទម្លាយហើយ អ្នកព្យាយាមរក្សាមាតុគ្រាម តាំងតែពីនៅក្នុងគភ៌ ធ្វើការការពារក្នុងទីទាំងឡាយដល់ទៅ ៧ កន្លែង សម្គាល់ថា អញនឹងរក្សាបាន ដែលឈ្មោះថាមាតុគ្រាម សូម្បីបុរសនឹងយកដាក់ក្នុងពោះហើយត្រាច់ទៅ ក៏មិនអាចរក្សាបាន ធម្មតាស្ត្រីដែលមានបុរសតែម្នាក់មិនមានឡើយ នាងមាណវិការបស់អ្នកពោលថា ខ្ញុំចង់រាំ យកសំពត់បិទមុខអ្នកដែលកំពុងដេញពិណ ឲ្យប្រុសស្មន់របស់ខ្លួនខោកក្បាលអ្នកហើយ ក៏បញ្ជូនបុរសនោះទៅវិញ ពេលនេះអ្នកនឹងវៀរ ( មាណវិកា ) បានដូចម្តេចទៅ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**យំ ព្រាហ្មណោ អវាទេសិ វីណំ សម្មុខវេឋិតោ**
**អណ្ឌាភូតា ភតា ភរិយា តាសុ កោ ជាតុវិស្សសេ ។**

ព្រាហ្មណ៍ បានរុំមុខរបស់ខ្លួនហើយដេញពិណដោយហេតុ
ណា ( មិនដឹងហេតុនោះទេ ) ប្រពន្ធដែលខ្លួនចិញ្ចឹមតាំងពី
នៅជាអណ្ឌៈ ( កូននៅក្នុងគភ៌ ) អ្នកណាគប្បីទុកចិត្តចំពោះ
ប្រពន្ធទាំងនោះ ដោយដាច់ខាតបាន ។

បណ្តាបទទាំងនោះ បទថា **យំ ព្រាហ្មណោ អវាទេសិ វីណំ សម្មុខវេឋិតោ** សេចក្តីថា ព្រាហ្មណ៍ត្រូវនាងមាណវិកាយកសំពត់សាច់ក្រាស់រុំមុខជិតឈឹង ហើយឲ្យដេញពិណ ដោយហេតុណា មិនដឹងហេតុនោះទេ ព្រោះនាងត្រូវការកុហកព្រាហ្មណ៍ ទើបបានធ្វើយ៉ាងនេះ ។

ប៉ុន្តែព្រាហ្មណ៍មិនដឹងថា ស្ត្រីទាំងឡាយមានមាយាច្រើនយ៉ាងនោះ លុះជឿមាតុគ្រាម ទើបបានសម្គាល់យ៉ាងនេះថា នាងអៀនខ្មាសនឹងអញ ។ ព្រះរាជាកាលប្រកាសការមិនដឹងរបស់ព្រាហ្មណ៍នោះ ទើបត្រាស់យ៉ាងនេះ ។ នេះជាការអធិប្បាយក្នុងចំណុចនេះ ។

បទថា **អណ្ឌភូតា ភតា ភរិយា** សេចក្តីថា អណ្ឌៈលោកហៅថាពូជ គឺស្ត្រីដែលត្រូវនាំមកចិញ្ចឹមតាំងតែនៅជាពូជ គឺត្រូវនាំមកចិញ្ចឹមតាំងតែក្នុងពេលដែលមិនទាន់ប្រសូតចាកផ្ទៃនៃមាតា ។ម្យ៉ាងទៀតសព្ទថា **ភតា** សំដៅដល់ពាក្យសួរ គឺសួរថា នោះជានរណា? ឆ្លើយថា ជាភរិយា គឺជាម្ចាស់នៃបុត្រ ជាស្ត្រីបម្រើ ។ ដ្បិតថា ស្ត្រីនោះលោកហៅថាភរិយាព្រោះត្រូវចិញ្ចឹមដោយភត្តនិងសំពត់ជាដើម ១ ព្រោះមានសំវរៈរវាំងកុំឲ្យត្រូវទម្លាយ ១ ព្រោះត្រូវចិញ្ចឹមដោយលោកធម៌ ១ ។

បទថា **ជាតុ** ក្នុងបាទគាថាថា **តាសុ កោ ជាតុវិស្សសេ** នេះជាពាក្យពោលដោយចំណែកមួយ ។ អធិប្បាយថា កាលភរិយាទាំងនោះសូម្បីត្រូវការពារតាំងតែនៅក្នុងផ្ទៃនៃមាតា ក៏គង់ដល់នូវវិការៈ ( ក្បត់ចិត្ត ) យ៉ាងនេះ អ្នកណាទៅ គឺមនុស្សមានបញ្ញាណា នឹងគប្បីដាក់ចិត្តចំពោះភរិយាបានយ៉ាងស៊ប់សួន បានដល់ អ្នកណាទៅគួរនឹងជឿបានថា ស្ត្រីទាំងនេះមិនមានវិការៈ ( ក្បត់ចិត្ត ) ចំពោះអញ ដ្បិតថា ធម្មតាមាតុគ្រាមកាលមានអ្នកហៅរក កាលមានអ្នកបបួលដោយអំណាចអសទ្ធម្ម បុគ្គល

ណាមួយក៏មិនអាចរក្សាបានឡើយ ។

ព្រះរាជាទ្រង់សម្តែងធម៌ដល់ព្រាហ្មណ៍យ៉ាងនេះ ព្រាហ្មណ៍ស្តាប់ព្រះធម្មទេសនារបស់ព្រះពោធិសត្វហើយ ក៏ទៅកាន់និវេសន៍ពោលនឹងមាណវិកានោះថា បានឮថា នាងហ៊ានប្រព្រឹត្តអាក្រក់ដល់កម្រិតនេះឬ?

មាណវិកាសួរថា បពិត្រព្រាហ្មណ៍ អ្នកណានិយាយយ៉ាងនេះ ខ្ញុំនេះឯងខោកក្បាលលោក អ្នកដទៃមិនមានអ្នកណាទេ បើលោកមិនជឿថា ខ្ញុំមិនស្គាល់សម្ផស្សប្រុសដទៃ ខ្ញុំនឹងធ្វើសច្ចកិរិយា ដើរកាត់ភ្លើងឲ្យលោកជឿ ។

ព្រាហ្មណ៍ពោលថា យ៉ាងនោះក៏ល្អ ទើបឲ្យគរឧសមួយគំនរធំបង្កាត់ភ្លើងហើយហៅនាងមក រួចពោលថា ប្រសិនបើនាងជឿជាក់ខ្លួនឯងចូរដើរកាត់ភ្លើងចុះ ។ ចំណែកមាណវិកាប្រាប់ស្រីបម្រើរបស់ខ្លួនទុកថា បពិត្រម៉ែ ចូរទៅប្រាប់កូនរបស់ម៉ែឲ្យទៅទីនោះ ពេលខ្ញុំដើរកាត់ភ្លើងឲ្យចាប់ដៃខ្ញុំទាញចេញ ស្ត្រីនោះក៏ទៅប្រាប់យ៉ាងនោះ ។ អ្នកលេងមកឈរកណ្តាលមហាជន មាណវិកាសង្ឃឹមថា នឹងកុហកព្រាហ្មណ៍បាន ទើបឈរកណ្តាលមហាជនធ្វើសច្ចកិរិយាថា បពិត្រព្រាហ្មណ៍ដែលឈ្មោះថាការប៉ះពាល់ដោយដៃរបស់បុរសដទៃ វៀរលោកចេញហើយ ខ្ញុំមិនធ្លាប់ស្គាល់ឡើយ ដោយសច្ចៈនេះ សូមភ្លើងនេះកុំឆេះខ្ញុំឡើយ រួចហើយធ្វើអាកប្បកិរិយានឹងដើរកាត់ភ្លើង ។ ពេលនោះអ្នកលេងក៏ប្រកាសថា នែ

អ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយចូរមើលការធ្វើរបស់ព្រាហ្មណ៍បុរោហិតចុះ លោកឲ្យមាតុគ្រាមដែលមានរូបស្អាតយ៉ាងនេះដើរកាត់ភ្លើងហើយស្ទុះទៅចាប់ដៃនាង ។ នាងរលាស់ដៃហើយនិយាយនឹងបុរោហិតថា បពិត្រព្រាហ្មណ៍ សច្ចកិរិយារបស់ខ្ញុំត្រូវទម្លាយហើយ ខ្ញុំមិនអាចដើរកាត់ភ្លើងបានទេ ។

ព្រាហ្មណ៍សួរថា ព្រោះហេតុអ្វី?

មាណវិកាឆ្លើយថា ថ្ងៃនេះ ខ្ញុំបានធ្វើសច្ចកិរិយាយ៉ាងនេះថា វៀរស្វាមីរបស់ខ្ញុំចេញហើយ ខ្ញុំមិនស្គាល់សម្ផស្សដៃនៃបុរសដទៃឡើយ ពេលនេះ ខ្ញុំត្រូវបុរសនេះចាប់ដៃហើយ ។ ព្រាហ្មណ៍ដឹងភ្លាមថា អញត្រូវមាណវិកាកុហកហើយ ក៏វាយបណ្ដេញនាងឲ្យចេញអំពីទីនោះ ។ បានឮថា ស្ត្រីទាំងនេះប្រកបដោយអសទ្ធម្មយ៉ាងនេះ ធ្វើកម្មអាក្រក់ជាច្រើន ដើម្បីនឹងកុហកស្វាមីរបស់ខ្លួន បានធ្វើការស្បថទាំងថ្ងៃថា ខ្ញុំមិនបានធ្វើយ៉ាងនេះ រមែងជាស្ត្រីមានចិត្តប្រែប្រួលទៅដោយប្រការផ្សេងៗ ។

## សមដូចគាថាព័ន្ធដែលលោកពោលទុកថា

ចោរីនំ ពហុពុទ្ធីនំ យាសុ សច្ចំ សុទុល្លភំ
ថីនំ ភាវោ ទុរាជានោ មច្ឆស្សេវោទកេ គតំ។

ពួកស្រីដែលដូចជាចោរ មានពុតត្បុតច្រើន មានពាក្យ
សច្ចៈ គេរកបានដោយកម្រណាស់ ភាពនៃស្រីទាំង-

*ឡាយ គេដឹងបានដោយក្រ ដូចដំណើរនៃត្រីក្នុងទឹក ។*

**មុសា តាសំ យថា សច្ចំ សច្ចំ តាសំ យថា មុសា**

**គាវោ ពហិ តិណស្សេវ ឱមសន្តិ វរំ វរំ ។**

*ពាក្យកុហករបស់ ពួកស្រីទាំងនោះ ក៏ដូចជាពាក្យពិត ឯពាក្យពិត របស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យកុហក (ពួកស្រី) ដូចគោ ស៊ីច្បិចតែស្មៅល្អៗ ខាងក្រៅ ។*

**ចោរិយោ កឋិនា ហេតា វាឡា ច លបសក្ខរា**

**ន តា កិញ្ចិ ន ជានន្តិ យំ មនុស្សេសុ វញ្ចនំ។**

*ពិតណាស់ ស្រីទាំងនេះដូចចោរ មានចិត្តរឹងត្អឹង ខូចកាច តែមានសម្ដីផ្អែមដូចស្ករ ការបញ្ឆោតណាក្នុងពួកមនុស្ស ពួកស្រីទាំងនោះ មិនមែនជាមិនដឹងការបញ្ឆោតណាមួយ(នោះ) ទេ ។*

*ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា មាតុគ្រាមណាៗ ក៏ដោយ ក៏រក្សាមិនបានយ៉ាងនេះ ដូច្នេះ លុះទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រកាសសច្ចៈ ក្នុងវេលាចប់សច្ចៈ ភិក្ខុដែលអផ្សុកនោះ បានសម្រេចសោតាបត្តិផល ។ ព្រះបរមសាស្ដា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ព្រះបាទពារាណសីក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា អណ្ឌភូតជាតក ទី ២ ។

# អដ្ឋកថា តក្កជាតក ទី ៣

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលអផ្សុកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កោធនា អកតញ្ញូ ច** ដូច្នេះជាដើម ។

ព្រះបរមសាស្តា ទ្រង់ត្រាស់សួរថា ពិតឬភិក្ខុ ដែលគេថាអ្នកអផ្សុកចង់សឹក ? កាលភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនពិតមែនហើយ ទើបទ្រង់ត្រាស់ថា ធម្មតាស្ត្រីទាំងឡាយជាមនុស្សអកតញ្ញូ ទ្រុស្ត-មិត្រ ហេតុអ្វីទើបអ្នកអផ្សុកព្រោះអាស្រ័យស្ត្រីទាំងនោះ ហើយទ្រង់នាំយករឿងក្នុងអតីតកាលមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបួសជាឥសី សាងអាស្រមនៅក្បែរមាត់ស្ទឹងគង្គា ញុំាងសមាបត្តិនិងអភិញ្ញាឲ្យកើតហើយ នៅជាសុខដែលកើតអំពីសេចក្តីត្រេកអរក្នុងឈាន ។ សម័យនោះ ធីតារបស់សេដ្ឋីក្នុងនគរពារាណសីឈ្មោះ ទុដ្ឋកុមារី ជាស្រីកាច គ្រោតគ្រាត ច្រើនជេរ ច្រើនវាយទាសៈនិងកម្មករ ។ ថ្ងៃមួយ បរិវាររបស់នាងបបួលនាងថា បពិត្រនាងម្ចាស់ យើងទៅលេងទឹកស្ទឹងគង្គា ។ កាលមនុស្សទាំងនោះលេងទឹកនៅក្នុងស្ទឹងនោះឯង ព្រះអាទិត្យក៏ជិតអស្តង្គត មេឃភ្លៀងក៏តាំងខ្មៅឡើង មនុស្សទាំងឡាយឃើញមេឃជិតភ្លៀង ក៏ប្រញាប់រត់ជាន់ជើងគ្នា

ពួកទាសកម្មកររបស់សេដ្ឋីធីតានិយាយគ្នាថា ថ្ងៃនេះ ពួកយើងគួរតែកាច់បំបាក់ភាពកាចសាហាវរបស់សេដ្ឋីធីតានេះ ហើយបោះបង់នាងទុកក្នុងទឹកនោះឯង នាំគ្នាឡើងអំពីស្ទឹងអស់ ។ ភ្លៀងក៏បង្អុរចុះមក សូម្បីព្រះអាទិត្យក៏អស្តង្គត ភាពងងឹតក៏បានកើតឡើង ។ ពួកទាសៈនិងកម្មករទាំងនោះវៀរតែសេដ្ឋីធីតានោះម្នាក់ បានទៅដល់ផ្ទះ ។ កាលមនុស្សទាំងឡាយសួរថា សេដ្ឋីធីតាទៅណា? ក៏ពោលថា នាងឡើងអំពីស្ទឹងគង្គាមុនហើយ កាលបើដូច្នេះទើបពួកខ្ញុំមិនដឹងថានាងទៅណា សូម្បីពួកញាតិនាំគ្នាស្វែងរក ក៏រកមិនឃើញ ។

សេដ្ឋីធីតាយំខ្សឹកខ្សួលអណ្តែតទៅតាមទឹក ទៅដល់ទីជិតបណ្ណសាលារបស់ព្រះបរមពោធិសត្វ នៅវេលាអធ្រាត្រព្រះបរមពោធិសត្វបានឮសំឡេងរបស់នាងហើយក៏គិតថា នុ៎ះជាសំឡេងស្ត្រី ត្រូវជួយយកអាសានាង លុះគិតដូច្នោះហើយក៏កាន់គប់ស្មៅដើរទៅកាន់មាត់ស្ទឹង ឃើញនាងហើយក៏លួងលោមថា កុំខ្លាច កុំខ្លាច ។ ព្រះបរមពោធិសត្វមានកម្លាំងដូចដំរីសារ សម្បូរដោយកម្លាំង ហែលទៅជួយនាងឡើងមកបាន នាំទៅអាស្រមបង្កាត់ភ្លើងឲ្យនាងអាំង លុះនាងអស់រងាហើយក៏ទៅរកផ្លែឈើតូចធំដែលមានរសជាតិឆ្ងាញ់ៗមកឲ្យនាង រួចហើយក៏សួរនៅពេលដែលនាងកំពុងបរិភោគផ្លែឈើនោះថា នាងនៅទីណា ហេតុដូចម្តេចទើបធ្លាក់ទឹកអណ្តែតមកទីនេះ? នាងក៏តំណាលរឿងរ៉ាវទាំងអស់ឲ្យស្តាប់ ។ គ្រា-

នោះ ព្រះបរមពោធិសត្វប្រាប់នាងថា នាងសម្រាកនៅទីនេះចុះ ហើយចាត់ចែងឲ្យនាងសម្រាកនៅក្នុងបណ្ណសាលា ខ្លួនឯងសម្រាកកណ្ដាលវាលពីរ-បីថ្ងៃ ហើយពោលថា ពេលនេះចូរនាងទៅចុះ ។ សេដ្ឋីធីតាគិតថា អញនឹងធ្វើតាបសនេះឲ្យដល់សីលភេទ ហើយបបួលឲ្យទៅជាមួយ ឲ្យទាល់តែបាន ដូច្នេះហើយ មិនព្រមទៅ ។ លុះវេលាកន្លងទៅក៏សម្ដែងមាយាស្រ្តី ធ្វើឲ្យតាបសដាច់សីលវិនាសចាកឈាន ។ តាបសក៏បបួលនាងនៅក្នុងព្រៃនោះឯង ។ គ្រានោះ នាងពោលទៅកាន់តាបសថា បពិត្រអ្នកជាម្ចាស់ យើងទាំងពីរនឹងនៅក្នុងព្រៃនេះធ្វើអ្វី យើងទាំងពីរនាក់នាំគ្នាទៅកាន់ភូមិមនុស្សចុះ ។ តាបសក៏នាំនាងទៅកាន់ស្រុកជាយដែនមួយ ប្រកបមុខរបរដោយការលក់តក្កៈគឺទឹកដោះជូរចិញ្ចឹមនាង ។ ព្រោះតាបសលក់តក្កៈចិញ្ចឹមជីវិត ទើបជនទាំងឡាយដាក់ឈ្មោះឲ្យថា តក្កបណ្ឌិត ។ គ្រា-នោះ ពួកអ្នកស្រុកនាំគ្នាឲ្យស្បៀងអាហារដល់តក្កបណ្ឌិត ហើយពោលថា សូមលោកជួយប្រាប់ហេតុការណ៍ដែលបុគ្គលប្រកប (គឺធ្វើ) ថា ល្អឬអាក្រក់ដល់ពួកខ្ញុំចុះ ហើយនាំគ្នាកសាងខ្ទមឲ្យនៅជិតខ្លោងទ្វារស្រុក ។

សម័យនោះ ពួកចោរនាំគ្នាចុះមកអំពីភ្នំប្លន់ជនបទជាយដែន ថ្ងៃមួយ នាំគ្នាមកប្លន់ស្រុកនោះ ហើយប្រើអ្នកជនបទនោះឲ្យជញ្ជូនរបស់របរទៅឲ្យ ដណ្ដើមយកសេដ្ឋីធីតានោះទៅកាន់សម្នាក់របស់ខ្លួនហើយ ទើបដោះលែងមនុស្សដ៏សេស ។ ចំណែកមេចោរពេញចិត្តនឹងរូបសម្បត្តិរបស់

នាង ទើបធ្វើនាងឲ្យជាភរិយារបស់ខ្លួន ។ តក្កបណ្ឌិតសួរថា ស្ត្រីឈ្មោះនេះទៅណា ? សូម្បីបានដឹងថា ត្រូវមេចោរចាប់យកធ្វើភរិយាហើយ ក៏នៅតែគិតថា នាងមិនទាន់បោះបង់អញ នាងនឹងគេចអំពីចោរត្រលប់មករកអញមិនខាន រង់ចាំនាងនៅក្នុងស្រុកនោះឯង ។ ចំណែកសេដ្ឋីធីតាក៏គិតថា អញនៅទីនេះសុខជាង តក្កបណ្ឌិតអាស្រ័យហេតុណាមួយហើយនឹងមកនាំអញចេញអំពីទីនេះ ដូច្នោះអញនឹងសាបសូន្យចាកសេចក្តី-សុខនេះ បើដូច្នោះ មានតែអញធ្វើដូចជានៅស្រឡាញ់ ឲ្យមនុស្សទៅតាមតក្កបណ្ឌិតមក ហើយឲ្យគេសម្លាប់ចោល ។ គិតហើយហៅមនុស្សម្នាក់មកបញ្ជូនដំណឹងទៅថា ខ្ញុំនៅយ៉ាងលំបាកក្នុងទីនេះ សូមតក្កបណ្ឌិតមកទទួលខ្ញុំទៅផងចុះ ។ តក្កបណ្ឌិតស្តាប់ដំណឹងនោះហើយក៏ជឿ ទើបទៅកាន់ផ្ទះមេចោរ ឈប់រង់ចាំត្រង់មាត់ទ្វារផ្ទះបញ្ជូនដំណឹងទៅ នាងចេញមកជួបហើយនិយាយថា បពិត្រអ្នកជាម្ចាស់ ប្រសិនបើយើងនាំគ្នាទៅពេលនេះ មេចោរនឹងដេញតាមសម្លាប់យើងទាំងពីរនាក់មិនខាន យើងនឹងទៅក្នុងវេលាអធ្រាត្រចុះ នាំតក្កបណ្ឌិតមកឲ្យបរិភោគ ឲ្យលាក់ខ្លួននៅក្នុងជង្រុកស្រូវ ។ ពេលរសៀល មេចោរត្រលប់មកវិញ ផឹកស្រាស្រវឹង នាងក៏សួរថា បពិត្រលោកម្ចាស់ ប្រសិនបើលោកឃើញសត្រូវរបស់លោកក្នុងពេលនេះ លោកនឹងធ្វើអ្វីចំពោះគេ ?

មេចោរពោលថា យើងនឹងធ្វើយ៉ាងនេះៗ ។

នាងក៏ប្រាប់ថា សត្រូវនោះនៅឆ្ងាយអំពីកាលណា អង្គុយនៅក្នុងជង្រុកស្រូវនេះឯង ។ មេចោរកាន់កាំបិតដើរទៅកាន់ជង្រុកស្រូវ ឃើញតក្កបណ្ឌិតក៏ចាប់គ្រវីឲ្យដួលកណ្ដាលផ្ទះ វាយដោយកំណាត់ឈើ អុកដោយជង្គង់ជាដើមរហូតអស់ចិត្ត តក្កបណ្ឌិតសូម្បីត្រូវវាយ ក៏មិនបានពោលពាក្យអ្វីដទៃឡើយ ពោលតែពាក្យថា ក្រោធ អកតញ្ញូ ចូលចិត្តញុះញង់ ទ្រុស្តមិត្រ តែម្យ៉ាងប៉ុណ្ណោះ ។ ចំណែកចោរវាយតក្កបណ្ឌិតហើយក៏ចងឲ្យដេក មកបរិភោគអាហារល្ងាចហើយក៏ដេកលក់ទៅ លុះភ្ញាក់ឡើងបច្ចូសសម័យ ក៏ផ្ដើមវាយតក្កបណ្ឌិតទៀត ។ ចំណែកតក្កបណ្ឌិតក៏ពោលតែពាក្យ ៤ ម៉ាត់នោះដដែល ចោរគិតថា បុរសនេះត្រូវអញវាយយ៉ាងនេះ ក៏មិនព្រមពោលពាក្យអ្វីយ៉ាងដទៃឡើយ ពោលតែពាក្យ ៤ ម៉ាត់ប៉ុណ្ណោះ អញនឹងសួរបុរសនេះមើល ហើយក៏សួរតក្កបណ្ឌិតថា នែអ្នកដ៏ចម្រើន អ្នកសូម្បីត្រូវយើងវាយយ៉ាងនេះ ហេតុដូចម្ដេចទើបពោលតែពាក្យ ៤ ម៉ាត់ប៉ុណ្ណោះ ?

តក្កបណ្ឌិតពោលថា បើដូច្នោះ អ្នកចូរស្ដាប់ចុះ ហើយពោលលំដាប់ហេតុការណ៍តាំងពីដើមថា ដើមឡើយខ្ញុំជាតាបសមួយរូបនៅក្នុងព្រៃ បានឈាន ខ្ញុំជួយស្ត្រីនេះដែលអណ្ដែតមកតាមដងស្ទឹងគង្គា ឲ្យឡើងលើគោកបាន ហើយចិញ្ចឹមបីបាច់ ក្រោយមកស្ត្រីនេះក៏លួងលោមខ្ញុំ ធ្វើឲ្យខ្ញុំសាបសូន្យចាកឈាន ខ្ញុំត្រូវបោះបង់ព្រៃ នាំនាងមកចិញ្ចឹមនៅឯស្រុកជាយដែន

លុះនាងបញ្ជូនដំណឹងទៅប្រាប់ខ្ញុំថា ត្រូវពួកចោរចាប់យកមកទីនេះ រស់នៅដោយលំបាក ឲ្យជួយនាំនាងត្រឡប់ទៅវិញ ធ្វើឲ្យខ្ញុំត្រូវធ្លាក់ក្នុង-កណ្ដាប់ដៃអ្នកក្នុងពេលនេះ ដោយហេតុនេះ ទើបខ្ញុំពោលយ៉ាងនេះ ។

ចោរគិតថា ស្ត្រីនេះប្រព្រឹត្តខុសយ៉ាងនេះ ចំពោះអ្នកដែលបរិបូណ៌ដោយគុណមានឧបការៈច្រើនយ៉ាងនេះ ស្រីនេះគង់នឹងធ្វើឧបទ្ទវន្តរាយណាមួយឲ្យដល់អញមិនខាន ត្រូវសម្លាប់វាចោល ។ មេចោរលួងលោមតក្កបណ្ឌិតឲ្យស្រាលចិត្តហើយ ដាស់នាងទាញកាំបិតចេញមកនិយាយថា យើងនឹងសម្លាប់បុរសនេះនៅក្បែរខ្លោងទ្វារស្រុក ដើរទៅក្រៅស្រុកជាមួយនឹងនាង ប្រាប់ឲ្យនាងចាប់ដៃតក្កបណ្ឌិតដោយពាក្យថា ចូរចាប់ដៃបុរសនេះ ហើយហូតកាំបិតធ្វើដូចជាកាប់តក្កបណ្ឌិត ត្រឡប់ជាកាប់នាងដាច់ពីរកំណាត់ ងូតទឹកកក់ក្បាលហើយ មើលថែទាំតក្កបណ្ឌិតដោយភោជនដ៏ប្រណីតអស់ពីរ-បីថ្ងៃ ទើបសួរថា ពេលនេះលោកនឹងទៅទីណាទៀត ?

តក្កបណ្ឌិតឆ្លើយថា ដែលឈ្មោះថាកិច្ចដោយការនៅគ្រប់គ្រងផ្ទះមិនមានដល់ខ្ញុំឡើយ ខ្ញុំនឹងបួសជាឥសីនៅក្នុងព្រៃ ។

មេចោរពោលថា បើដូច្នោះ ខ្ញុំក៏បួសដែរ ។ ទាំងពីរនាក់នាំគ្នាបួសទៅកាន់ព្រៃនោះ ញ៉ាំងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើង ក្រោយអំពីអស់ជីវិតក៏ទៅកាន់ព្រហ្មលោក ។

ព្រះបរមសាស្ដាទ្រង់ត្រាស់រឿងទាំងពីរនេះហើយ កាលទ្រង់បាន

ត្រាស់ដឹងហើយ ទើបទ្រង់សម្តែងគាថានេះថា

**កោធនា អកតញ្ញូ ច បិសុណា ច វិភេទិកា**
**ព្រហ្មចរិយំ ចរ ភិក្ខុ សោ សុខំ ន វិហាហិសីតិ ។**

(ធម្មតាស្ត្រី) ច្រើនខឹង មិនដឹងឧបការៈដែលគេធ្វើដល់ខ្លួន ជាអ្នកញុះញង់ បំបែកបំបាក់មិត្ត ម្នាលភិក្ខុ អ្នកចូរប្រព្រឹត្ត ព្រហ្មចរិយៈចុះ អ្នកនោះនឹងមិនវិនាសសេចក្តីសុខ ។

ក្នុងព្រះគាថានោះ ប្រមូលសេចក្តីអធិប្បាយបានដូច្នេះ ម្នាលភិក្ខុ ធម្មតាស្ត្រីទាំងឡាយក្នុងលោកនេះ ជាអ្នកច្រើនទៅដោយសេចក្តីក្រោធ មិនអាចហាមឃាត់សេចក្តីក្រោធដែលកើតឡើងបានឡើយ ជាបុគ្គល អកតញ្ញូ មិនដឹងឧបការគុណសូម្បីដ៏ច្រើន ជាមនុស្សច្រើនទៅដោយការ ញុះញង់ ចូលចិត្តពោលតែពាក្យដែលសម្តែងដល់ការញុះញង់ជានិច្ច ជា អ្នកមាននិស្ស័យខាងទ្រុស្តមិត្ត មានប្រក្រតីពោលពាក្យធ្វើឲ្យមិត្តបែកបាក់ គ្នាជាប្រចាំ ស្ត្រីទាំងនេះប្រកបដោយធម៌ដ៏លាមកបែបនេះ ។ អ្នកនៅត្រូវ ការស្ត្រីទាំងនេះធ្វើអ្វី ? ម្នាលភិក្ខុ អ្នកចូរប្រព្រឹត្ត ព្រហ្មចរិយធម៌ចុះ ព្រោះថាការវៀរចាកមេថុនធម្ម ឈ្មោះថា ព្រហ្មចរិយៈ ដោយអត្ថថាជា គុណដ៏បរិសុទ្ធ អ្នកប្រព្រឹត្តព្រហ្មចរិយធម៌នោះនឹងមិនវិនាសចាកសេចក្តី សុខ គឺថាកាលអ្នកប្រព្រឹត្តព្រហ្មចរិយៈនោះ នឹងមិនវិនាសចាកសេចក្តីសុខ ក្នុងឈាន បានដល់សេចក្តីសុខដែលកើតអំពីមគ្គ និងសេចក្តីសុខដែល

*កើតអំពីផល អធិប្បាយថា នឹងមិនលះបង់សេចក្តីសុខនេះ គឺនឹងមិនសាបសូន្យចាកសេចក្តីសុខនេះ ។ បាលីថា* **ន បរិហាយសិ** *អ្នកនឹងមិនសាបសូន្យ ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នានោះឯង ។*

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុអ្នកអផ្សុកនោះ បានសម្រេចសោតាបត្តិផល ។ ព្រះបរមសាស្តា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា មេចោរក្នុងកាលនោះ បានមកជាអានន្ទ ចំណែកតក្កបណ្ឌិត គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា តក្កជាតក ទី ៣ ។

# អដ្ឋកថា ទុរាជានជាតក ទី ៤

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **មា សុនន្ទិ ឥច្ឆតិ មំ** *ដូច្នេះជាដើម ។*

*បានឮថា ឧបាសកអ្នកក្រុងសាវត្ថីម្នាក់ តាំងមាំនៅក្នុងសរណៈទាំង ៣ ក្នុងសីលទាំង៥ ជាពុទ្ធមាមកៈ( អ្នករាប់អានព្រះពុទ្ធថាជារបស់យើង ) ជាធម្មមាមកៈ (អ្នករាប់អានព្រះធម៌ថាជារបស់យើង) ជាសង្ឃមាមកៈ ( អ្នករាប់អានព្រះសង្ឃថាជារបស់យើង ) ។ ចំណែកភរិយារបស់គាត់ជា*

ស្ត្រីទ្រុស្តសីល មានបាបធម៌ ថ្ងៃណាបានប្រព្រឹត្តក្បត់ចិត្តស្វាមី ថ្ងៃនោះស្រស់ស្រាយសប្បាយរីករាយ ដូចទាសីដែលលោះមកដោយទ្រព្យ ១០០ កហាបណៈ ប៉ុន្តែថ្ងៃណាមិនបានគប់នឹងសហាយស្មន់ទេ ថ្ងៃនោះ មានអាការដូចជាចៅហ្វាយនាយដ៏កាចឃោរឃៅ ។ ឧបាសកនោះមិនយល់ចិត្តនាងដូច្នោះ ក៏កើតការធុញថប់ចំពោះនាងជាភរិយា មិនបានចូលគាល់ព្រះសម្ពុទ្ធ ។ ក្រោយមកគាត់ក៏កាន់គ្រឿងសក្ការៈ មានគ្រឿងក្រអូបនិងកម្រងផ្កាជាដើម ទៅថ្វាយបង្គំព្រះសម្មាសម្ពុទ្ធហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះបរមសាស្តាត្រាស់សួរថា មានបញ្ហាអ្វីឬឧបាសក ទើបមិនបានមកកាន់សម្នាក់តថាគតដល់ទៅ ៧-៨ ថ្ងៃ ?

ឧបាសកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភរិយារបស់ខ្ញុំព្រះអង្គ ថ្ងៃខ្លះដូចជាទាសីដែលគេលោះមកដោយទ្រព្យរាប់រយកហាបណៈ ថ្ងៃខ្លះកាចឃោរឃៅណាស់ ខ្ញុំព្រះអង្គមិនយល់ចិត្តនាង កើតការធុញថប់ចំពោះនាងខ្លាំងណាស់ ទើបមិនបានចូលមកគាល់ព្រះអង្គ ។ លុះព្រះបរមសាស្តាទ្រង់ព្រះសណ្តាប់ពាក្យរបស់ឧបាសកនោះហើយ ទើបត្រាស់ថា ម្នាលឧបាសក ភាវៈរបស់មាតុគ្រាមដឹងបានដោយលំបាកពិតមែន សូម្បីកាលពីមុនបណ្ឌិតទាំងឡាយក៏បានប្រាប់អ្នកហើយ ប៉ុន្តែអ្នកភ្លេចព្រោះការកើតស្លាប់ៗ ក្នុងភពទាំងឡាយដ៏ច្រើន ។ កាលឧបាសកក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វជាអាចារ្យទិសាបាមោក្ខ ឲ្យមាណព ៥០០ នាក់សិក្សាសិល្បៈ ។ គ្រានោះ មានមាណពម្នាក់នៅក្រៅស្រុកមករៀនសិល្បៈក្នុងសម្នាក់អាចារ្យទិសាបាមោក្ខនោះ មានចិត្តស្រឡាញ់ស្ត្រីម្នាក់ ក្រោយមកបាននាងជាភរិយារស់នៅក្នុងនគរពារាណសីនុ៎ះឯង មិនបានទៅឧបដ្ឋាកអាចារ្យអស់ពីរ-បីថ្ងៃ ចំណែកស្ត្រីជាភរិយារបស់មាណពនោះ ជាស្ត្រីមាននិស្ស័យអាក្រក់ ប្រព្រឹត្តថោកទាប ថ្ងៃណាដែលបានប្រព្រឹត្តក្បត់ចិត្តស្វាមី ថ្ងៃនោះមានចិត្តទន់ភ្លន់ដូចទាសី (ដែលគេលោះមកដោយទ្រព្យ ១០០ កហាបណៈ) ថ្ងៃណាមិនបានប្រព្រឹត្តក្បត់ចិត្តស្វាមីថ្ងៃនោះមួម៉ៅក្តៅក្រហាយ ជេរគេជេរឯង មានអាការដូចចៅហ្វាយដ៏កាចឃោរឃៅ ។ មាណពនោះមិនយល់ចិត្តប្រពន្ធ តាមដានការប្រព្រឹត្តិរបស់នាងមិនទាន់ក៏កើតការធុញថប់ មិនសប្បាយចិត្តចំពោះការប្រព្រឹត្តិរបស់នាង ដូច្នោះហើយ មិនបានទៅកាន់សម្នាក់អាចារ្យ ។ លុះកន្លងមកបាន ៧-៨ ថ្ងៃ ទើបបានទៅកាន់សម្នាក់អាចារ្យ ។ អាចារ្យក៏សួរថា នែមាណព ព្រោះហេតុអ្វីទើបអ្នកបាត់មុខយូរម្ល៉េះ ?

មាណពឆ្លើយថា បពិត្រលោកអាចារ្យ ភរិយារបស់ខ្ញុំថ្ងៃខ្លះមើលទៅដូចជាស្រឡាញ់ខ្ញុំ ប្រាថ្នាខ្ញុំ ត្រូវការខ្ញុំ ដូចជាទាសីដែលអស់មានះ ថ្ងៃខ្លះដូចចៅហ្វាយដ៏កាចឃោរឃៅ ខ្ញុំមិនយល់ចិត្តនាង ទើបមានចិត្ត

ធុញថប់ក្តៅក្រហាយមិនសប្បាយចិត្ត មិនបានមកបម្រើលោកអាចារ្យ ។

អាចារ្យពោលថា នែមាណព រឿងនេះវាយ៉ាងហ្នឹងឯង ធម្មតាស្ត្រីមាននិស្ស័យខាងប្រព្រឹត្តអាក្រក់ ក្បត់ចិត្តស្វាមី ថ្ងៃណាបានប្រព្រឹត្តអាក្រក់ ថ្ងៃនោះក៏មានចិត្តទន់ភ្លន់លួងលោមស្វាមី ដូចទាសីដែលអស់មានះ ប៉ុន្តែថ្ងៃណាមិនបានប្រព្រឹត្តអាក្រក់ក្បត់ចិត្តស្វាមីទេ ថ្ងៃនោះ ក្លាយទៅជាស្ត្រីកាចឆ្នាស ប្រងើងប្រងាង រឹងត្អឹងដោយមានះ មិនព្រមប្រព្រឹត្តឱនលំទោនទន់ភ្លន់ចំពោះស្វាមី ធម្មតាស្ត្រីមានការប្រព្រឹត្តិថោកទាប មាននិស្ស័យអាក្រក់យ៉ាងនេះឯង ដែលឈ្មោះថាសភាពរបស់ស្ត្រីដឹងបានដោយលំបាក កាលពួកនាងត្រូវការអ្នកក៏ដោយ មិនត្រូវការអ្នកក៏ដោយ អ្នកគប្បីតាំងខ្លួនជាកណ្តាលចុះ ហើយពោលគាថានេះ ដោយបំណងឲ្យឱវាទមាណពថា

**មា សុនន្ទិ ឥច្ឆតិ មំ មាសុ សោចិ ន ឥច្ឆតិ**
**ថីនំ ភាវោ ទុរាជានោ មច្ឆស្សេវោទកេ គតន្តិ។**

*អ្នកកុំត្រេកអរ (ថាស្ត្រីនេះ) ប្រាថ្នាអញ កុំសោកសៅ*
*(ថាស្ត្រីនេះ) មិនប្រាថ្នាអញ ភាពរបស់ស្ត្រីទាំងឡាយ*
*ដឹងបានដោយក្រ ដូចជាដំណើរទៅនៃត្រីក្នុងទឹក ។*

បណ្តាបទទាំងនោះ សុ អក្សរក្នុងបាទគាថាថា **មា សុនន្ទិ ឥច្ឆតិ មំ** ត្រឹមតែជានិបាត សេចក្តីថា កុំត្រេកអរថា ស្ត្រីនេះត្រូវការអញ

*គឺមានសេចក្ដីប្រាថ្នា មានសេចក្ដីស្នេហាចំពោះអញ ។*

*បទថា* **មាសុ សោចិ ន ឥច្ឆតិ** *សេចក្ដីថា ទាំងមិនចាំបាច់ខ្វូចចិត្តថា ស្ត្រីមិនត្រូវការអញ ពន្យល់សេចក្ដីថា កាលនាងត្រូវការ ក៏កុំបានចិត្តកុំត្រេកអរ កាលនាងមិនត្រូវការ ក៏កុំសោកសៅ ធ្វើចិត្តឲ្យជាកណ្ដាល ។*

*បទថា* **ថីនំ ភាវោ ទុរាជានោ** *សេចក្ដី ធម្មតាភាវៈរបស់ស្ត្រីដឹងបានដោយក្រ ព្រោះមានមាយាស្ត្រីបិទបាំង ។*

*សួរថា សេចក្ដីនេះដូចអ្វី?*

*ឆ្លើយថា ដូចដំណើរទៅនៃត្រីក្នុងទឹក ដឹងបានដោយក្រ ព្រោះទឹកបិទបាំង ដោយហេតុនេះឯង កាលអ្នកប្រមងមក ត្រីក៏កំបាំងកាយហែលទៅក្រោមទឹក រត់គេចមិនឲ្យចាប់ខ្លួនបានយ៉ាងណា ស្ត្រីទាំងឡាយក៏ដូច្នោះដែរ ធ្វើអំពើអាក្រក់សូម្បីដ៏ច្រើន ក៏បិទបាំងអំពើដែលខ្លួនធ្វើដោយមាយាស្ត្រី គឺកុហកស្វាមីថា ខ្ញុំមិនបានធ្វើយ៉ាងនេះ ធម្មតាស្ត្រីទាំងនេះមានបាបធម៌ មានការប្រព្រឹត្តិអាក្រក់យ៉ាងនេះ ត្រូវតាំងចិត្តឲ្យជាកណ្ដាលចំពោះស្ត្រីទាំងនោះ ទើបមានសេចក្ដីសុខ ។*

*ព្រះបរមពោធិសត្វឲ្យឱវាទសិស្សយ៉ាងនេះ តាំងពីនោះមកមាណពក៏ផ្ដើមដាក់ចិត្តជាកណ្ដាលចំពោះស្ត្រីទាំងនោះ ។ ចំណែកភរិយារបស់មាណពនោះ កាលដឹងថា លោកអាចារ្យដឹងការប្រព្រឹត្តិអាក្រក់របស់ខ្លួនហើយ តាំងពីនោះមកក៏ឈប់ប្រព្រឹត្តអាក្រក់ ។*

ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ កាលចប់សច្ចៈហើយ ឧបាសកនោះបានសម្រេចសោតាបត្តិផល ។ ព្រះបរមសាស្តា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ប្តីប្រពន្ធទាំងពីរនាក់ក្នុងកាលនោះ បានមកជាប្តីប្រពន្ធក្នុងកាលឥឡូវនេះ ចំណែកអាចារ្យ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ទុរាជានជាតក ទី ៤ ។

# អដ្ឋកថា អនភិរតិជាតក ទី ៥

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកអ្នកមានសេចក្តីទុក្ខ ព្រោះអាស្រ័យប្រពន្ធមានសហាយក្បត់ចិត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យថា នទី ច បន្ថោ ច** ដូច្នេះជាដើម ។

កាលឧបាសកនោះតាមដានប្រពន្ធ ក៏ដឹងថាប្រពន្ធមានសហាយក្បត់ចិត្តខ្លួន ក៏ក្តៅក្រហាយកើតទុក្ខ និងព្រោះហេតុតែខ្លួនជាអ្នកមានចិត្តមួម៉ៅក្តៅក្រហាយមិនសប្បាយ ទើបមិនចូលទៅគាល់ព្រះបរមសាស្តាអស់ ៧-៨ ថ្ងៃ ។ ថ្ងៃមួយគាត់ទៅកាន់វិហារ ថ្វាយបង្គំព្រះតថាគតហើយអង្គុយក្នុងទីដ៏សមគួរមួយ កាលព្រះបរមសាស្តាត្រាស់សួរថា ម្នាលឧបាសក ព្រោះហេតុអ្វី ទើបមិនមកកាន់សម្នាក់តថាគតអស់៧-៨ ថ្ងៃ ?

ក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភរិយារបស់ខ្ញុំព្រះអង្គមានសហាយក្បត់ចិត្តខ្ញុំព្រះអង្គ ព្រោះហេតុតែខ្ញុំព្រះអង្គមានចិត្តសៅហ្មងកករល្អក់ មិនសប្បាយក្នុងការប្រព្រឹត្តិអាក្រក់របស់នាង ទើបមិនបានមកគាល់ព្រះអង្គ ។ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលឧបាសក បុរសមិនត្រូវក្តៅក្រហាយខឹងក្រោធចំពោះស្ត្រីទាំងឡាយថា ស្ត្រីទាំងនេះ ប្រព្រឹត្តអនាចារក្បត់ចិត្តអញឡើយ គប្បីដាក់ចិត្តជាកណ្តាលតែម្យ៉ាងប៉ុណ្ណោះ សូម្បីក្នុងអតីតកាលបណ្ឌិតទាំងឡាយក៏បានប្រាប់អ្នកហើយ ប៉ុន្តែអ្នកចាំមិនបាន ព្រោះភពដទៃបិទបាំង ។ កាលឧបាសកក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបានជាអាចារ្យទិសាបាមោក្ខដូចរឿងមុននោះដែរ ។ គ្រានោះ សិស្សរបស់លោកបានឃើញទោសរបស់ភរិយាហើយ មិនមកកាន់សម្នាក់របស់លោកអស់ពីរ-បីថ្ងៃ ព្រោះមិនសប្បាយចិត្ត ថ្ងៃមួយ ត្រូវអាចារ្យសួរ ក៏ប្រាប់រឿងនោះឲ្យអាចារ្យជ្រាប ។ អាចារ្យក៏ពោលថា នៃអ្នកដ៏ចម្រើន ធម្មតាស្ត្រីជារបស់សាធារណៈដល់ជនទូទៅ បណ្ឌិតទាំងឡាយមិនគួរថ្នាំងថ្នាក់អាក់អន់ចិត្តចំពោះស្ត្រីទាំងនោះថា ស្ត្រីទាំងនេះជាមនុស្សទ្រុស្តសីល មានតែបាបធម៌ ហើយពោលគាថានេះដោយបំណងឲ្យបានជាពាក្យទូន្មានប្រៀនប្រដៅ ដោយមានសេចក្តីថា

**យថា នទី ច បន្ថោ ច ចានាគារំ សភា បចា**
**ឯវំ លោកិត្ថិយោ នាម នាសំ កុជ្ឈន្តិ បណ្ឌិតាតិ។**

*ទន្លេក្តី ផ្លូវក្តី តៀមស្រាក្តី សាលាសម្នាក់ក្តី អណ្តូងទឹកក្តី ( ជារបស់សាធារណៈ ) យ៉ាងណា ធម្មតាស្ត្រីទាំងឡាយក្នុងលោក ក៏យ៉ាងនោះដែរ បណ្ឌិតទាំងឡាយ មិនខឹងនឹងស្ត្រីទាំងនោះទេ ។*

*បណ្តាបទទាំងនោះ បទថា* **យថា នទី** *សេចក្តីថា ស្ទឹងមានកំពង់ច្រើន ជាកន្លែងសាធារណៈ ដល់មនុស្សកើតក្នុងត្រកូលថោកទាបមានត្រកូលចណ្ឌាលជាដើម សូម្បីអ្នកកើតក្នុងត្រកូលខ្ពង់ខ្ពស់ មានត្រកូលក្សត្រជាដើម ដែលប្រាថ្នានឹងមកងូត បណ្តាមនុស្សទាំងនោះ អ្នកដែលងូតមិនបាន មិនមានឡើយ ។*

*សូម្បីក្នុងបទមានជាដើមថា* **បន្ថោ** *ក៏មានសេចក្តីអធិប្បាយថា សូម្បីផ្លូវធំ ក៏ជាផ្លូវសាធារណៈដល់ជនទាំងពួង អ្នកដែលដើរផ្លូវនោះមិនបាន មិនមានឡើយ ។*

*បទថា* **ចានាគារំ** *សេចក្តីថា តៀមស្រាចាត់ជាទីសាធារណៈ ដល់ជនទូទៅ អ្នកដែលប្រាថ្នានឹងផឹកក៏មានសិទ្ធិចូលទៅកាន់តៀមស្រានោះបានទាំងអស់ ។ សូម្បីកន្លែងអ្នកដែលប្រាថ្នាបុណ្យកសាងទុក សម្រាប់ជាទីស្នាក់អាស្រ័យនៃមនុស្សទាំងឡាយក្នុងទីនោះៗ ក៏ជាទីសាធារណៈដែរ*

អ្នកដែលចូលទៅកាន់ទីនោះមិនបាន មិនមានឡើយ សូម្បីពាងទឹកដែលគេតម្កល់ទឹកផឹកនៅជិតផ្លូវធំ ក៏ជារបស់សាធារណៈដល់ជនទូទៅដែរ អ្នកដែលផឹកមិនបាន មិនមានឡើយ យ៉ាងណា ។

បទថា **ឯវំ លោកិត្ថិយោ នាម** សេចក្តីថា នែមាណព ធម្មតាស្ត្រីទាំងឡាយក្នុងលោកនេះ ក៏យ៉ាងនោះដែរ ជារបស់សាធារណៈដល់ជនទូទៅ គឺដូចស្ទឹង ផ្លូវ តៀមស្រា សាលាសម្នាក់ និងអណ្តូងទឹក ដោយអត្ថថា ជារបស់សាធារណៈនោះឯង ព្រោះហេតុនោះ បណ្ឌិតទាំងឡាយរមែងមិនខឹងនឹងស្ត្រីទាំងនោះឡើយ អធិប្បាយថា បណ្ឌិត គឺអ្នកឈ្លាសសម្បូរដោយការចេះដឹង គិតឃើញថា ស្ត្រីទាំងនេះលាមក អនាចារ ទ្រុស្ត-សីល ជាស្ត្រីសាធារណៈដល់ជនទូទៅ ដូច្នោះហើយ ទើបមិនខឹងនឹងស្ត្រីទាំងនោះ ។

ព្រះបរមពោធិសត្វឲ្យឱវាទដល់សិស្សយ៉ាងនេះ មាណពនោះស្តាប់ឱវាទនេះហើយ ក៏ដាក់ចិត្តជាកណ្តាលបាន សូម្បីភរិយារបស់មាណពនោះក៏គិតថា បានឮថា លោកអាចារ្យដឹងរឿងរបស់អញហើយ ចាប់តាំងពីពេលនោះមក ក៏ឈប់ប្រព្រឹត្តអំពើដ៏លាមកទៀត ។

សូម្បីភរិយារបស់ឧបាសកនោះក៏គិតថា ព្រះបរមសាស្តាដឹងរឿងរបស់អញហើយ ចាប់តាំងពីពេលនោះមក នាងក៏ឈប់ប្រព្រឹត្តអាក្រក់ទៀត ។

*ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ កាលចប់សច្ចៈហើយ ឧបាសកនោះក៏បានសម្រេចសោតាបត្តិផល ។ ព្រះបរមសាស្ដា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា គូស្វាមីភរិយាក្នុងកាលនោះ បានមកជាគូស្វាមីភរិយាក្នុងកាលឥឡូវនេះ ចំណែកព្រាហ្មណ៍ជាអាចារ្យ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា អនភិរតិជាតក ទី ៥ ។

# អដ្ឋកថា មុទុលក្ខណជាតក ទី ៦

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសភាវធម៌ដែលធ្វើឲ្យមនុស្សសៅហ្មង ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **ឯកា ឥច្ឆា បុរេ អាសិ** *ដូច្នេះជាដើម ។*

*បានឮថា បុរសអ្នកក្រុងសាវត្ថីម្នាក់ស្ដាប់ព្រះធម្មទេសនារបស់ព្រះបរមសាស្ដាហើយ បួសឧទ្ទិសជីវិតចំពោះព្រះសាសនា ពោលគឺព្រះ-រតនត្រ័យ ជាព្រះយោគាវចរបដិបត្តិដ៏តឹងរ៉ឹង មិនព្រងើយកន្តើយចំពោះព្រះកម្មដ្ឋាន ។ ថ្ងៃមួយ ត្រាច់ទៅបិណ្ឌបាតក្នុងនគរសាវត្ថី ឃើញស្ត្រីម្នាក់តាក់តែងខ្លួនយ៉ាងស្អាត មិនសង្រួមចក្ខុ សម្លឹងមើលស្រីនោះដោយអំណាចសុភនិមិត្ត កិលេសខាងក្នុងខ្លួនលោកធ្វើឲ្យញាប់ញ័រ ដូចដើមឈើមានជ័រត្រូវចូតដោយកាំបិតដូច្នោះ ។ ចាប់តាំងពីពេលនោះមក លោកក៏*

ធ្លាក់នៅក្នុងអំណាចនៃកិលេស មិនស្រួលកាយ ហើយក៏មិនសប្បាយចិត្ត ជ្រួលច្របល់ដូចគ្នានឹងសត្វសំពោច មិនត្រេកអរក្នុងព្រះសាសនា សក់វែង រោមទ្រុបទ្រុល ក្រចកដៃវែង ចីវរក៏សៅហ្មង ។ គ្រានោះ ភិក្ខុទាំងឡាយដែលជាសម្លាញ់ឃើញការប្រែប្រួលនៃឥន្ទ្រីយ៍ ក៏នាំគ្នាសួរថា អ្នកមានអាយុ ហេតុដូចម្ដេចក៏ឥន្ទ្រីយ៍របស់អ្នកមិនដូចមុន ?

លោកឆ្លើយថា អ្នកមានអាយុ ខ្ញុំអផ្សុក ( អស់សេចក្ដីត្រេកអរក្នុងព្រះសាសនា) ភិក្ខុទាំងនោះក៏នាំលោកទៅកាន់សម្នាក់ព្រះបរមសាស្ដា ។

ព្រះបរមសាស្ដាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនាំភិក្ខុអ្នកមិនប្រាថ្នាមកឬ ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុរូបនេះអផ្សុកហើយ ។

ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ពិតមែនឬ ?

ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែនហើយ ។

ទ្រង់ត្រាស់សួរបន្តទៀតថា អ្នកណាធ្វើឲ្យអ្នកអផ្សុក ?

ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គកំពុងត្រាច់បិណ្ឌបាត បានឃើញស្ត្រីម្នាក់ មិនសង្រួមចក្ខុសម្លឹងមើលនាង គ្រានោះ កិលេសរបស់ខ្ញុំព្រះអង្គក៏កម្រើកឡើង ហេតុនោះទើបខ្ញុំព្រះអង្គអផ្សុក ។

ព្រះបរមសាស្ដាត្រាស់ទៅកាន់ភិក្ខុនោះថា ម្នាលភិក្ខុ កាលដែលអ្នកទម្លាយឥន្ទ្រិយ៍សម្លឹងមើលវិសភាគារម្មណ៍ ដោយអំណាចនៃការឃើញថា ល្អ កិលេសក៏កម្រើកឡើងដោយហេតុណា ហេតុនេះមិនអស្ចារ្យទេ កាលពីមុនសូម្បីព្រះពោធិសត្វទាំងឡាយបានអភិញ្ញា ៥ សមាបត្តិ ៨ គ្របសង្កត់កិលេសបានហើយដោយអំណាចឈាន មានចិត្តបរិសុទ្ធត្រាច់ទៅក្នុងអាកាសបាន កាលទម្លាយឥន្ទ្រិយ៍សម្លឹងមើលវិសភាគារម្មណ៍ ក៏សាបសូន្យចាកឈាន កិលេសកម្រើកឡើងសោយទុក្ខយ៉ាងច្រើន ខ្យល់មានកម្លាំងដកភ្នំសិនេរុបាន ហេតុដូចម្ដេចនឹងមិនបក់ផាត់ភ្នំត្រងោលប៉ុនដើងដំរីឲ្យប៉ើងទៅ ខ្យល់ដែលផ្ដួលដើមព្រីងធំឲ្យដួលបាន ហេតុដូចម្ដេចនឹងមិនបក់គុម្ពឈើដែលដុះនៅក្បែរមាត់ស្នឹងឲ្យអណ្ដែតទៅ ម្យ៉ាងទៀត ខ្យល់ដែលបក់មហាសមុទ្រឲ្យរីងបាន ហេតុដូចម្ដេចនឹងមិនបក់ទឹកក្នុងអណ្ដូងតូចឲ្យស្ងួតហួតហែងទៅ កិលេសដែលធ្វើឲ្យព្រះពោធិសត្វអ្នកមានបញ្ញាដ៏ខ្ពង់ខ្ពស់ មានចិត្តផូរផង់ឲ្យវង្វេងបាន នឹងខ្លាចអ្វីចំពោះអ្នក សត្វសូម្បីបរិសុទ្ធក៏ត្រូវសៅហ្មង សូម្បីបរិបូរដោយយសដ៏ខ្ពង់ខ្ពស់ក៏គង់ដល់នូវការអស់យសទៅបាន ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិនៅក្នុងត្រកូលព្រាហ្មណ៍

ដែលមានសម្បត្តិស្តុកស្តម្ភមួយ នៅក្នុងដែនកាសី ។ លុះដឹងក្តីហើយរៀនចប់សិល្បៈគ្រប់ប្រភេទ លះបង់កាមហើយទៅបួសជាឥសី ធ្វើកសិណបរិកម្ម ញ៉ាំងអភិញ្ញានិងសមាបត្តិឲ្យកើតឡើងហើយ នៅដោយសុខក្នុងឈាន ក្នុងព្រៃហេមពាន្ត ។ សម័យមួយ លោកចេញអំពីព្រៃហេមពាន្តដើម្បីបរិភោគភោជនដែលមានរសប្រៃខ្លះ រសជូរខ្លះ ក៏ធ្វើដំណើរមកដល់នគរពារាណសី សម្រាកនៅក្នុងព្រះរាជឧទ្យាន ។ ព្រឹកឡើងធ្វើសរីរកិច្ចស្រេចហើយ គ្រងសំពត់សម្បកឈើ ដណ្តប់ស្បែកខ្លាធៀងស្មាម្ខាង បួងសក់ស្រួលបួលហើយ កាន់បរិក្ខារត្រាច់ភិក្ខាចារនៅក្នុងនគរពារាណសីដល់ទ្វារព្រះរាជនិវេសន៍ ព្រះរាជាទ្រង់ជ្រះថ្លានឹងឥរិយាបថរបស់លោកបញ្ជាឲ្យនិមន្តមក ឲ្យគង់លើអាសនៈដ៏មានតម្លៃ ទ្រង់អង្គាសដោយខាទនីយភោជនីហារដ៏ប្រណីត តាបសនោះធ្វើអនុមោទនាគាថាហើយទ្រង់អារាធនាឲ្យគង់នៅក្នុងព្រះរាជឧទ្យាន ។ តាបសក៏ទទួលព្រះរាជ-អាយាចនៈ ( ទទួលអារាធនា ) ឆាន់ក្នុងព្រះរាជវាំង ថ្វាយឱវាទដល់រាជ-ត្រកូល ស្នាក់នៅក្នុងព្រះរាជឧទ្យានអស់ ១៦ ឆ្នាំ ។ ថ្ងៃមួយ ព្រះរាជាស្តេចយាងទៅបង្ក្រាបបច្ចន្តជនបទដែលបះបោរ ទ្រង់ត្រាស់ផ្តាំអគ្គមហេសីព្រះនាមមុទុលក្ខណាថា ចូរនាងកុំប្រមាទ ចូរបម្រើលោកម្ចាស់របស់យើងដូច្នេះហើយ ស្តេចយាងទៅ ។

ព្រះបរមពោធិសត្វ តាំងតែពីពេលដែលព្រះរាជាយាងចេញទៅក៏

ទៅកាន់ព្រះរាជវាំងតាមពេលដែលខ្លួនពេញចិត្ត ។ ថ្ងៃមួយ ព្រះនាង-មុទុលក្ខណាត្រៀមអាហារសម្រាប់តាបសស្រេចហើយ ព្រះនាងត្រិះរិះថា ថ្ងៃនេះលោកម្ចាស់របស់អញប្រហែលជាក្រមក ទើបព្រះនាងស្រង់ព្រះ-កាយដោយព្រះសុគន្ធទក តាក់តែងព្រះកាយដោយគ្រឿងអលង្ការទាំងពួង ព្រះនាងបញ្ជាឲ្យគេរៀបចំចូឡសយនា គឺព្រះបន្ទំតូច លើផ្ទៃព្រះរោង ព្រះនាងសម្រាកព្រះកាយរង់ចាំតាបសមក ។ ចំណែកព្រះបរមពោធិសត្វ កំណត់វេលារបស់ខ្លួនហើយ ចេញចាកឈានហោះទៅកាន់ព្រះរាជ-និវេសន៍ភ្លាម ។ ព្រះនាងមុទុលក្ខណាទ្រង់ស្តាប់សំឡេងសំពត់សម្បកឈើ ក៏ដឹងថា លោកម្ចាស់មកហើយ ក៏ប្រញាប់ក្រោកឡើង កាលព្រះនាងប្រញាប់ក្រោកឡើងដូច្នោះ សំពត់ដែលព្រះនាងដណ្តប់នោះជាសំពត់សាច់ស្តើងរលោង ក៏របូតធ្លាក់អំពីព្រះកាយ ។ ភ្លាមនោះ តាបសចូលតាមបង្អួច ឃើញរូបារម្មណ៍ដែលជាវិសភាគរបស់ព្រះទេវី ក៏ទម្លាយឥន្ទ្រីយ៍សម្លឹងមើលដោយអំណាចចិត្តដែលសម្គាល់ថាស្អាត ភ្លាមនោះ កិលេសដែលនៅខាងក្នុងក៏កម្រើកឡើង ដូចដើមឈើមានជ័រត្រូវឆ្ងូតដោយកាំបិតដូច្នោះ ។ ភ្លាមនោះឯង ឈានរបស់លោកក៏សាបសូន្យដូចក្អែកបាក់ស្លាប ។ តាបសពោធិសត្វឈរទទួលអាហារហើយមិនបរិភោគទេ ញាប់ញ័រព្រោះកិលេសទាំងឡាយ ចុះអំពីប្រាសាទដើរទៅកាន់ព្រះរាជឧទ្យាន ចូលក្នុងបណ្ណសាលាដាក់អាហារលើទីដេក ត្រូវវិសភាគារម្មណ៍ជាប់ណែនក្នុងចិត្ត

ភ្លើងកិលេសដុតពេលស្គាំងស្គម ព្រោះអត់អាហារ ដេកសុបសៅនៅលើទី ដេកអស់ ៧ ថ្ងៃ ។

ថ្ងៃទី ៧ ព្រះរាជាទ្រង់បង្ក្រាបបច្ចន្តជនបទរៀបរយហើយ ស្ដេចត្រឡប់មក ទ្រង់ប្រទក្សិណនគរហើយ ស្ដេចមិនទាន់យាងទៅកាន់ព្រះ-រាជនិវេសន៍នៅឡើយទេ ទ្រង់ព្រះតម្រិះថា អញនឹងទៅជួបលោកម្ចាស់របស់អញសិន ដូច្នេះហើយ ទ្រង់ហួសទៅកាន់ព្រះរាជឧទ្យាន ទតឃើញតាបសសិង ទ្រង់ព្រះតម្រិះថា ប្រហែលជាលោកម្ចាស់របស់យើងមិនស្រួលខ្លួនហើយមើលទៅ បញ្ជាឲ្យសម្អាតបណ្ណសាលាបណ្ដើរ ទ្រង់ច្របាច់ជើងទាំងពីររបស់តាបសបណ្ដើរ ហើយទ្រង់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់មិនស្រួលខ្លួនឬ?

តាបសពោធិសត្វថ្វាយព្រះពរថា មហាបពិត្រ ការមិនស្រួលខ្លួនយ៉ាងដទៃ មិនមានដល់អាត្មាភាពទេ ប៉ុន្តែព្រោះអំណាចកិលេស អាត្មាភាពមានចិត្តប្រែប្រួលហើយ ។

ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ស្រឡាញ់អ្នកណា?

តាបសពោធិសត្វថ្វាយព្រះពរថា ចិត្តរបស់អាត្មាប្រតិព័ទ្ធព្រះនាង-មុទុលក្ខណា ។

ព្រះរាជាមានព្រះរាជឱង្ការថា ប្រពៃហើយលោកម្ចាស់ ខ្ញុំត្រេកអរ

ថ្វាយព្រះនាងមុទុលក្ខណាចំពោះលោកម្ចាស់ ហើយទ្រង់នាំតាបសទៅកាន់ព្រះរាជនិវេសន៍ ឲ្យព្រះទេវីប្រដាប់ព្រះកាយដោយគ្រឿងអលង្ការទាំងពួង ហើយព្រះរាជទានដល់តាបស ប៉ុន្តែមុននឹងព្រះរាជទាននោះ ទ្រង់បានឲ្យសញ្ញាសម្ងាត់ចំពោះព្រះទេវីថា នាងត្រូវព្យាយាមការពារលោកម្ចាស់របស់យើងដោយកម្លាំងរបស់នាង ។

ព្រះនាងទទួលព្រះរាជឱង្ការថា ព្រះមេខ្ញុំម្ចាស់ ខ្ញុំម្ចាស់នឹងរក្សាខ្លួនឲ្យផុតពីកណ្តាប់ដៃរបស់លោកម្ចាស់ពួកយើង ។ តាបសក៏នាំព្រះទេវីចុះចាកព្រះរាជនិវេសន៍ ពេលចេញផុតខ្លោងទ្វារធំ ព្រះនាងត្រាស់ទៅកាន់តាបសថា បពិត្រអ្នកជាម្ចាស់ យើងគួរមានផ្ទះមួយ ចូរលោកទៅក្រាបទូលសូមផ្ទះអំពីព្រះរាជាមួយខ្នងចុះ ។ តាបសក៏ទៅក្រាបទូលសុំឲ្យព្រះ-រាជាព្រះរាជទានផ្ទះមួយខ្នង ។ ព្រះរាជាក៏ព្រះរាជទានផ្ទះដែលបោះបង់ចោល ដែលមនុស្សទាំងឡាយប្រើប្រាស់ធ្វើជាវច្ចកុដិឲ្យមួយខ្នង តាបសក៏នាំព្រះទេវីទៅកាន់ផ្ទះនោះ ព្រះទេវីមិនព្រមចូលទៅ តាបសទូលសួរថា

ហេតុអ្វីទើបមិនយាងចូលផ្ទះនេះ ?

ព្រះទេវីត្រាស់ថា ព្រោះផ្ទះនេះកខ្វក់ណាស់ ។

តាបសទូលសួរថា ពេលនេះ យើងគួរធ្វើដូចម្តេច ?

ព្រះទេវីត្រាស់ថា ត្រូវសម្អាតផ្ទះនោះ ហើយបញ្ជូនតាបសឲ្យទៅកាន់ព្រះរាជដំណាក់ មានព្រះសវនីយ៍ថា សូមលោកទៅយកចប យក

*បង្គីមក លុះតាបសយកចបនិងបង្គីមកហើយ ក៏ឲ្យកើបលាមកនិងសំរាមយកទៅចោល ស្រេចហើយឲ្យទៅជញ្ជូនយកអាចម៍គោមកលាប លុះតាបសយកអាចម៍គោមកលាបស្រេចហើយក៏ត្រាស់ថា លោកត្រូវទៅជញ្ជូនគ្រែ ជញ្ជូនតាំងមក ហើយប្រើឲ្យតាបសជញ្ជូនមក មួយមុខម្តងៗ មិនតែប៉ុណ្ណោះនៅប្រើឲ្យដងទឹកដាក់ពាងជាដើមទៀត តាបសយកក្អមទៅដងទឹកមកចាក់ក្នុងពាងរហូតទាល់តែពេញ ត្រៀមទឹកទុកសម្រាប់ងូតហើយរៀបចំទីដេក ។ ពេលនោះ ព្រះនាងមុទុលក្ខណាចាប់តាបសដែលកំពុងរៀបចំទីដេកទាញឲ្យដួលមានមុខមករកខ្លួន ហើយត្រាស់ថា លោកម្ចាស់ មិនដឹងខ្លួនថាលោកជាសមណៈឬជាព្រាហ្មណ៍ ទេឬ? តាបសភ្ញាក់ខ្លួនមានសតិក្នុងពេលនោះឯង ។ ប៉ុន្តែពេលកន្លងមក លោកមិនដឹងខ្លួនឡើយ ។ ដែលឈ្មោះថាកិលេសទាំងឡាយ រមែងធ្វើឲ្យវង្វេងយ៉ាងនេះឯង ។ ក្នុងរឿងនេះ គួរពោលអាងព្រះពុទ្ធវចនៈមានជាដើមថា* ***ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទនីវរណៈ រមែងធ្វើឲ្យងងឹត ធ្វើឲ្យវង្វេង ធ្វើឲ្យមិនស្គាល់ខ្លួនតាមសេចក្តីពិតដូច្នេះ*** *។ តាបសត្រឡប់មានសតិគិតឃើញថា តណ្ហានេះ កាលចម្រើនឡើងនឹងមិនឲ្យអញងើបក្បាលឡើងអំពីអបាយទាំងបួនបានឡើយ អញគួរយកព្រះទេវីនេះទៅថ្វាយព្រះរាជាវិញ ហើយចូលកាន់ព្រៃហេមពាន្តថ្ងៃនេះតែម្តង លុះគិតដូច្នេះហើយក៏នាំព្រះទេវីចូលគាល់ព្រះរាជា ថ្វាយព្រះពរថា ថ្វាយព្រះពរមហាបពិត្រ អាត្មាមិន*

ត្រូវការព្រះទេវីរបស់មហាបពិត្រទេ ព្រោះអាស្រ័យព្រះនាងតែម្នាក់គត់ ទើបតណ្ហាចម្រើនឡើងដល់អាត្មាយ៉ាងសន្ធឹកសន្ធាប់ ហើយពោលគាថានេះថា

**ឯកា ឥច្ឆា បុរេ អាសិ អលទ្ធា មុទុលក្ខណំ**
**យតោ លទ្ធា អឡារក្ខិ ឥច្ឆា ឥច្ឆំ វិជាយថាតិ។**

មុនអំពីពេលដែលមិនទាន់បាននូវនាងមុទុលក្ខណា សេចក្ដីប្រាថ្នាមានតែមួយ កាលណាអាត្មាភាពបាននាងមុទុ-លក្ខណា ជាស្ត្រីមានភ្នែកល្អហើយ សេចក្ដីប្រាថ្នារឹតតែញុំាងសេចក្ដីប្រាថ្នា (ផ្សេងៗ) ឲ្យកើតឡើងទៀត ។

ព្រះគាថានេះ ប្រមូលអត្ថាធិប្បាយបានដូច្នេះ ថ្វាយព្រះពរ មហា-បពិត្រមុនពេលដែលអាត្មាភាព មិនទាន់បានទទួលព្រះទេវីមុទុលក្ខណាអំពីមហាបពិត្រ អាត្មាភាពមានសេចក្ដីប្រាថ្នាតែមួយ គឺសេចក្ដីប្រាថ្នាតែម្យ៉ាងប៉ុណ្ណោះថា ឱ ធ្វើដូចម្ដេចហ្ន៎ ទើបអញបានព្រះនាងមុទុលក្ខណា ប៉ុន្តែលុះអាត្មាភាពបានព្រះនាងមុទុលក្ខណា ដែលជាស្ត្រីមានព្រះនេត្រភ្លឺប្រិចៗ មានព្រះនេត្រភ្លឺចិញ្ចាចចិញ្ចែង មានព្រះនេត្រល្អកាលណា កាលនោះសេចក្ដីប្រាថ្នាដំបូងរបស់អាត្មា ជួយឲ្យកើតសេចក្ដីប្រាថ្នាផ្សេងៗទៀត ដូចជាប្រាថ្នាផ្ទះ ប្រាថ្នាគ្រឿងឧបករណ៍ ប្រាថ្នាគ្រឿងឧបភោគជាដើម សេចក្ដីប្រាថ្នារបស់អាត្មានោះ កាលចម្រើនឡើងយ៉ាងនេះ នឹងមិនព្រម

ឲ្យអាត្មាលើកក្បាលឡើងអំពីអបាយបានឡើយ បពិត្រមហារាជ សូមព្រះអង្គទទួលយកមហេសីរបស់ទ្រង់វិញចុះ ចំណែកអាត្មាចម្រើនពរលាទៅកាន់ព្រៃហេមពាន្តវិញហើយ ។

ភ្លាមនោះឯង តាបសក៏ញ៉ាំងឈានដែលសាបសូន្យទៅហើយឲ្យកើតឡើងវិញ គង់ក្នុងអាកាសសម្តែងធម៌ថ្វាយឱវាទព្រះរាជាហើយ ទៅកាន់ព្រៃហេមពាន្តតាមផ្លូវអាកាសមួយរំពេច មិនមកកាន់ប្រទេសដែលជាទីនៅនៃមនុស្សទៀតឡើយ ព្រះបរមពោធិសត្វចម្រើនព្រហ្មវិហារ មិនសាបសូន្យចាកឈាន ក្រោយអំពីចុតិក៏បដិសន្ធិក្នុងព្រហ្មលោក ។

ព្រះបរមសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ ភិក្ខុនោះបានសម្រេចអរហត្តផល ។ ព្រះបរមសាស្តា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះបានមកជាអានន្ទក្នុងកាលឥឡូវនេះ ព្រះនាងមុទុលក្ខណា បានមកជាឧប្បលវណ្ណា ចំណែកឥសី គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា មុទុលក្ខណជាតក ទី ៦ ។

# អដ្ឋកថា ឧច្ឆង្គជាតក ទី ៧

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្ត្រីអ្នកជនបទម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **ឧច្ឆង្គេ ទេវ មេ បុត្តោ** *ដូច្នេះជាដើម ។*

*សេចក្ដីពិស្ដារថា ក្នុងដែនកោសល មានមនុស្សបីនាក់ភ្ជួរស្រែនៅក្បែរមាត់ព្រៃមួយកន្លែង ។ សម័យនោះ ពួកចោរនៅក្នុងព្រៃប្លន់មនុស្សហើយនាំគ្នារត់គេច មនុស្សទាំងឡាយស្វែងរកចាប់ចោរទាំងនោះ កាលរកមិនឃើញក៏តាមមកដល់ទីនោះ ហើយពោលថា ពួកឯងប្លន់គេក្នុងព្រៃហើយ ពេលនេះមកធ្វើដូចជាអ្នកស្រែ ចាប់មនុស្សទាំងបីនាក់នោះ ដោយសម្គាល់ថាជាចោរ នាំមកថ្វាយព្រះបាទកោសល ។ គ្រានោះ មានស្ត្រីម្នាក់មកយំរៀបរាប់ថា សូមទ្រង់ព្រះរាជទានសម្លៀកបំពាក់ឲ្យនាងខ្ញុំផង ដើរជុំវិញព្រះរាជនិវេសន៍ទៅមកៗ ។ ព្រះរាជាទ្រង់ស្ដាប់សំឡេងរបស់នាងហើយបញ្ជាថា ពួកអ្នកចូរឲ្យសម្លៀកបំពាក់ដល់នាង ។ ពួករាជបុរសក៏យកហិបសំពត់សាដកមកឲ្យ នាងឃើញសំពត់នោះហើយពោលថា ខ្ញុំមិនបានសុំឲ្យព្រះអង្គព្រះរាជទានសំពត់នេះទេ ខ្ញុំសូមឲ្យព្រះអង្គព្រះរាជ-ទានសម្លៀកបំពាក់គឺស្វាមី ។ ពួករាជបុរសនាំគ្នាទៅក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ស្ត្រីនោះមិនបានសូមសម្លៀកបំពាក់នេះទេ នាងសូមសម្លៀកបំពាក់គឺស្វាមី ។ ព្រះរាជាក៏ត្រាស់ឲ្យនាងចូលគាល់ មាន*

ព្រះរាជតម្រាស់សួរថា នែនាងដ៏ចម្រើន បានឮថា នាងសូមសំពត់គឺស្វាមីឬ ?

នាងក្រាបទូលថា ព្រះមេខ្ញុំម្ចាស់ ដ្បិតថា ស្វាមីទាំងឡាយជាសម្លៀកបំពាក់របស់ស្ត្រីដោយពិត ប្រសិនបើមិនមានស្វាមីទេ ស្ត្រីសូម្បីស្លៀកដណ្តប់សំពត់ដែលមានតម្លៃទាំងពាន់កហាបណៈក៏ដោយ ក៏នៅតែមានឈ្មោះថាជាស្ត្រីអាក្រាតកាយដដែល ។ ដើម្បីឲ្យសេចក្តីនេះ សម្រេចប្រយោជន៍ បណ្ឌិតគប្បីយករឿងមកសាធកដូច្នេះថា

ទន្លេដែលគ្មានទឹក ហៅថា ទន្លេស្រាត ដែនដែលគ្មានព្រះរាជា
ហៅថា ដែនស្រាត ចំណែកស្ត្រីមេម៉ាយ បើទុកជាមានបងប្អូន
ប្រុសដល់ ១០ នាក់ ក៏ហៅថា ស្ត្រីស្រាត ភាពជាស្ត្រីមេម៉ាយ
រមែងក្តៅក្រហាយក្នុងលោក ។

ព្រះរាជាទ្រង់ជ្រះថ្លានឹងនាង ត្រាស់សួរថា មនុស្សទាំងបីនាក់នេះត្រូវជាអ្វីនឹងនាង ?

នាងក្រាបទូលថា បពិត្រព្រះសម្មតិទេព ម្នាក់ជាស្វាមី ម្នាក់ជាបងប្រុស ម្នាក់ជាបុត្រ ។

ព្រះរាជាត្រាស់សួរថា យើងពេញចិត្តនឹងនាង បណ្តាមនុស្សបីនាក់នេះ យើងឲ្យនាងម្នាក់ តើនាងចង់បានម្នាក់ណា ?

នាងក្រាបទូលថា បពិត្រព្រះសម្មតិទេព កាលបើខ្ញុំម្ចាស់នៅមាន

ជីវិត ស្វាមីម្នាក់ខ្ញុំម្ចាស់អាចរកបាន សូម្បីកូនក៏រកបានដោយងាយដែរ ។ ប៉ុន្តែព្រោះមាតាបិតារបស់ខ្ញុំម្ចាស់អស់ជីវិតទៅហើយ បងប្រុសខ្ញុំម្ចាស់មិនងាយរកបានឡើយ ដូច្នេះ សូមទ្រង់មេត្តាព្រះរាជទានបងប្រុសឲ្យខ្ញុំម្ចាស់ចុះ ។ ព្រះរាជាទ្រង់ត្រេកអរហើយ ទ្រង់បញ្ជាឲ្យដោះលែងជនទាំងបីនាក់ព្រោះអាស្រ័យស្ត្រីនោះតែម្នាក់ មនុស្សទាំងបីនាក់នោះ រួចផុតចាកទុក្ខបានដោយប្រការដូច្នេះ ។

រឿងនោះដឹងដល់ពួកភិក្ខុ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងធម្មសភា សន្ទនាសរសើរគុណនៃស្ត្រីនោះថា អ្នកមានអាយុទាំងឡាយអាស្រ័យស្ត្រីតែម្នាក់ បុរសបីនាក់បានរួចផុតចាកទុក្ខ ។ ព្រះបរមសាស្តាស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះអ្នកទាំងឡាយប្រជុំសន្ទនាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្ត្រីនេះរំដោះបុរសទាំងបីនាក់នេះឲ្យរួចផុតចាកទុក្ខបាន មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ធ្លាប់រំដោះបុរសទាំងបីនាក់នេះ ឲ្យរួចផុតចាកទុក្ខដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី មនុស្សបីនាក់នាំគ្នាទៅភ្ជួរស្រែក្បែរមាត់ព្រៃ ដូច្នេះ តអំពីនោះទៅ រឿងទាំងអស់ដូចរឿងមុននោះឯង ។ (ប៉ុន្តែដែលប្លែកគ្នាមាន

ដូច្នេះ) កាលព្រះរាជាត្រាស់សួរថា បណ្ដាបុរសទាំងបីនាក់ នាងត្រូវការបុរសណា ?

នាងក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់មិនអាចព្រះរាជ-ទានទាំងបីនាក់បានឬ ?

ព្រះរាជាត្រាស់ថា អើ យើងមិនអាចឲ្យទាំងបីនាក់បានទេ ។

នាងក្រាបទូលថា ប្រសិនបើ ព្រះអង្គមិនអាចព្រះរាជទានទាំងបីនាក់បាន សូមទ្រង់ព្រះរាជទានបងប្រុសឲ្យខ្ញុំម្ចាស់ចុះ ។

ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វីទើបនាងត្រូវការបងប្រុស ?

នាងក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ធម្មតាស្វាមីនិងកូនរកបានដោយងាយ ប៉ុន្តែបងប្រុស ខ្ញុំម្ចាស់មិនងាយរកបានឡើយ ហើយក្រាបទូលគាថានេះថា

**ឧច្ឆង្គេ ទេវ មេ បុត្តោ បថេ ធាវន្តិយា បតិ**
**តញ្ច ទេសំ ន បស្សាមិ យតោ សោទរិយមានយេ។**

បពិត្រព្រះសម្មតិទេព កូនរបស់ខ្ញុំព្រះអង្គ (ដូចជាអន្ទក់ដែលដក់) ក្នុងថ្នក់ (បានដោយងាយ) ស្ត្រីដែលដើរទៅតាមផ្លូវរកប្ដី (បានដោយងាយ) ឯខ្ញុំព្រះអង្គមិនឃើញប្រទេស គឺផ្ទៃនៃមាតានោះដែលខ្ញុំព្រះអង្គគួរនាំយកបងប្អូនប្រុសបង្កើតមកបាន ។

បណ្ដាបទទាំងនោះ បទថា **ឧច្ឆង្គេ ទេវ មេ បុត្តោ** សេចក្ដីថា

បពិត្រព្រះសម្មតិទេព បុត្តនៅក្នុងថ្នក់របស់ខ្ញុំម្ចាស់ដោយប្រៀបសេចក្តីថា កាលខ្ញុំម្ចាស់ចូលព្រៃធ្វើសំពត់ជាថ្នក់ បេះបន្លែដាក់ក្នុងថ្នក់នោះ បន្លែនោះឈ្មោះថាជារបស់រកបានដោយងាយ ព្រោះមាននៅក្នុងថ្នក់ យ៉ាងណាមិញ សូម្បីស្ត្រីក៏រកបុត្តបានដោយងាយ ដូចបន្លែក្នុងថ្នក់ដូច្នោះដែរ ដោយហេតុនោះ ទើបខ្ញុំម្ចាស់ពោលថា បពិត្រសម្មតិទេព បុត្តនៅក្នុងថ្នក់របស់ខ្ញុំម្ចាស់ ។

បទថា **បថេ ធាវន្តិយា បតិ** សេចក្តីថា ធម្មតាថា ស្វាមី កាលស្ត្រីឡើងកាន់ផ្លូវដើរទៅតែម្នាក់ឯង ក៏អាចរកបាន បុរសដែលឃើញហើយជាស្វាមីបានទាំងអស់ ដោយហេតុនោះ ទើបខ្ញុំម្ចាស់ពោលថា ស្វាមី កាលខ្ញុំម្ចាស់ដើរទៅតាមផ្លូវ (ក៏រកបានដោយងាយ) ដូច្នេះ ។

បទថា **តញ្ច ទេសំ ន បស្សាមិ យតោ សោទរិយមានយេ** សេចក្តីថា ប៉ុន្តែព្រោះមាតាបិតារបស់ខ្ញុំម្ចាស់មិនមាន ព្រោះហេតុដូច្នោះ ពេលនេះប្រទេសដទៃ ពោលគឺផ្ទៃនៃមាតា ដែលខ្ញុំម្ចាស់នឹងស្វែងរកបងប្អូនដែលមានឈ្មោះថារួមផ្ទៃជាមួយ ព្រោះកើតរួមឧទរនោះ ខ្ញុំម្ចាស់រកមើលមិនឃើញឡើយ ព្រោះហេតុនោះ សូមព្រះអង្គទ្រង់ព្រះរាជទានបងប្រុសឲ្យដល់ខ្ញុំម្ចាស់ចុះ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា នាងនេះនិយាយត្រឹមត្រូវណាស់ ដូច្នេះហើយមានព្រះទ័យត្រេកអរ បញ្ជាឲ្យនាំមនុស្សទាំងបីនាក់ចេញអំពីគុក

*ព្រះរាជទានឲ្យនាង នាងក៏នាំបុរសទាំងបីនាក់នោះទៅផ្ទះវិញ ។*

*ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន នាងក៏ធ្លាប់ជួយបុរសទាំងបីនាក់នេះ ឲ្យរួចផុតចាកទុក្ខដែរ កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា មនុស្សទាំងបួននាក់ក្នុងអតីតបានមកជាមនុស្សទាំងបួននាក់ក្នុងបច្ចុប្បន្ន ចំណែកព្រះរាជាក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា ឧច្ឆង្គជាតក ទី ៧ ។

# អដ្ឋកថា សាកេតជាតក ទី ៨

*ព្រះបរមសាស្តា កាលទ្រង់អាស្រ័យក្រុងសាកេត ទ្រង់គង់នៅក្នុងព្រះវិហារអញ្ជនវន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្ដើមថា* **យស្មឹ មនោ និវីសតិ** *ដូច្នេះជាដើម ។*

*បានឮថា នៅពេលដែលព្រះដ៏មានព្រះភាគហែហមដោយពួកភិក្ខុ ទ្រង់យាងចូលទៅកាន់ក្រុងសាកេតដើម្បីបិណ្ឌបាត ព្រាហ្មណ៍ចាស់អ្នកក្រុងសាកេតម្នាក់កំពុងដើរទៅខាងក្រៅនគរ ឃើញព្រះទសពលនៅចន្លោះខ្លោងទ្វារ ក៏ក្រាបចុះទៀបព្រះយុគលបាទ ចាប់ព្រះបាទទាំងគូយ៉ាងណែនហើយក្រាបទូលថា បាដ៏ចម្រើន ធម្មតាថា បុត្រត្រូវបម្រើមាតា*

បិតានៅពេលដែលគាត់មានវ័យចាស់ជរា មិនមែនឬ ? ហេតុអ្វីទើប បាមិនបង្ហាញខ្លួនអស់កាលមានប្រមាណប៉ុណ្ណេះ ខ្ញុំបានឃើញបាហើយ ប៉ុន្តែបាចូលទៅរកមាតារបស់បាចុះ ហើយនាំព្រះបរមសាស្តាទៅកាន់ផ្ទះ របស់ខ្លួន ។ ព្រះបរមសាស្តា ស្តេចយាងទៅកាន់ផ្ទះរបស់ព្រាហ្មណ៍ ទ្រង់ គង់លើអាសនៈដែលគេក្រាលទុកមួយអន្លើដោយភិក្ខុសង្ឃ ។ ចំណែក ព្រាហ្មណី បានឮថា ពេលនេះបុត្តរបស់យើងមកហើយ ក៏មកក្រាប ទៀបបាទមូលនៃព្រះបរមសាស្តាហើយយំរៀបរាប់ថា បាដ៏ចម្រើន បាទៅ ណា បាត់យូរម្ល៉េះ ធម្មតាបុត្រត្រូវទំនុកបម្រុងមាតាបិតា នៅពេលដែលគាត់ មានវ័យចាស់ជរា មិនមែនឬ ? ហើយប្រាប់ឲ្យបុត្តធីតាមកថ្វាយបង្គំ ដោយពាក្យថា កូនឯងចូរទៅថ្វាយបង្គំបងប្រុសរបស់កូនឯងចុះ ព្រាហ្មណ៍ ទាំងពីរនាក់ប្តីប្រពន្ធ ថ្វាយមហាទានដោយចិត្តសប្បាយរីករាយ ។ ព្រះ-បរមសាស្តា លុះទ្រង់សោយស្រេចហើយ ក៏ត្រាស់ **ជរាសូត្រ** ដល់ ព្រាហ្មណ៍ទាំងពីរនាក់ប្តីប្រពន្ធនោះ លុះចប់ព្រះសូត្រ ព្រាហ្មណ៍ទាំងពីរ-នាក់ប្តីប្រពន្ធនោះ ក៏បានសម្រេចអនាគាមិផល ។ ព្រះបរមសាស្តា ស្តេច ក្រោកចាកអាសនៈ យាងទៅកាន់វិហារអញ្ជនវនវិញ ។ ពួកភិក្ខុអង្គុយ ប្រជុំគ្នាក្នុងធម្មសភាសន្ទនាគ្នាថា អ្នកមានអាយុទាំងឡាយ ព្រាហ្មណ៍ក៏ ដឹងដែរថា ព្រះបិតារបស់ព្រះតថាគត គឺព្រះបាទសុទ្ធោទនៈ ព្រះមាតាគឺ ព្រះនាងមហាមាយា ដឹងដូច្នេះហើយក៏នៅតែប្រាប់ព្រាហ្មណីថា ព្រះ-

តថាគតជាបុត្តរបស់យើង ចំណែកព្រះបរមសាស្តាក៏ទ្រង់យល់ព្រមដែរ តើសេចក្តីនេះ មានហេតុដូចម្តេចហ្ន៎ ។ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះ-សណ្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ទាំងពីរនាក់ប្តីប្រពន្ធ ហៅបុត្តរបស់ខ្លួននោះឯងថាបុត្ត ហើយទ្រង់នាំយកអតីតនិទានមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍នេះ ក្នុងអតីតកាលធ្លាប់ជាបិតារបស់តថាគត ៥០០ ជាតិ ជាឪពុកមារបស់តថាគត ៥០០ ជាតិ ជាជីតារបស់តថាគត ៥០០ ជាតិ តជាប់គ្នាមិនដាច់ខ្សែ ចំណែកនាងព្រាហ្មណីក៏ធ្លាប់ជាមាតារបស់តថាគត ៥០០ ជាតិ ជាម្តាយមីងរបស់តថាគត ៥០០ ជាតិ ជាជីដូនរបស់តថាគត ៥០០ ជាតិដែរ តថាគតចម្រើនឡើងក្នុងដៃរបស់ព្រាហ្មណ៍ ១៥០០ ជាតិ ចម្រើនឡើងក្នុងដៃរបស់ព្រាហ្មណី ១៥០០ ជាតិ យ៉ាងនេះជាការដែលទ្រង់ត្រាស់ដល់ជាតិក្នុងអតីត ៣០០០ ជាតិ ។ លុះទ្រង់បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធហើយ ទើបត្រាស់ព្រះគាថានេះថា

**យស្មិំ មនោ និវិសតិ ចិត្តញ្ចាបិ បសីទតិ**
**អទិដ្ឋបុព្វកេ បោសេ កាមំ តស្មឹបិ វិស្សសេតិ ។**

ចិត្តតាំងនៅស៊ប់ ឬក៏ចិត្តជ្រះថ្លា ក្នុងបុគ្គលណា ដែលខ្លួនមិនធ្លាប់ឃើញហើយ ជនតែងស្និទ្ធស្នាលចំពោះបុគ្គលនោះ ដោយពិត ។

*បណ្ដាបទទាំងនោះ បទថា* **យស្មិំ មនោ និវីសតិ** *សេចក្ដីថា ចិត្តតាំងនៅស៊ប់ក្នុងបុគ្គលណា ដែលខ្លួនទើបតែឃើញម្ដងប៉ុណ្ណោះ ។*

*បទថា* **ចិត្តញ្ចាបិ បសីទតិ** *សេចក្ដីថា មួយទៀត ចិត្តរមែងជ្រះថ្លាក្នុងបុគ្គលណាដែលខ្លួនទើបតែឃើញម្ដងប៉ុណ្ណោះ ។*

*បទថា* **អទិដ្ឋបុព្វកេ ភោសេ** *សេចក្ដីថា ក្នុងបុគ្គលនោះ សូម្បីក្នុងយាមប្រក្រតី ទោះជាបុគ្គលដែលខ្លួនមិនធ្លាប់ឃើញសោះ ក្នុងអត្តភាពនេះ ។*

*បទថា* **កាមំ តស្មិំបិ វិស្សសេ** *មានអធិប្បាយថា រមែងស្និទ្ធស្នាលគ្នាដោយចំណែកមួយ គឺស្និទ្ធស្នាលចំពោះបុគ្គលនោះភ្លាមដោយអំណាចសេចក្ដីស្រឡាញ់ដែលធ្លាប់មានក្នុងកាលមុននោះឯង ។*

*ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកយ៉ាងនេះហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ព្រាហ្មណ៍និងព្រាហ្មណីក្នុងកាលនោះ បានមកជាព្រាហ្មណ៍និងព្រាហ្មណីក្នុងកាលឥឡូវនេះ ចំណែកបុត្តគឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា សាកេតជាតក ទី ៨ ។

# អដ្ឋកថា វិសវន្តជាតក ទី ៩

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះធម្មសេនាបតី ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្តើមថា **ធិរត្ថុ តំ វិសំ វន្តំ** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលដែលព្រះសារីបុត្តត្តេរឆាន់របស់ដែលគួរទំពាស៊ីធ្វើដោយម្សៅ មនុស្សទាំងឡាយនាំគ្នាយករបស់ដែលគួរទំពាស៊ីធ្វើដោយម្សៅជាច្រើនមកកាន់វិហារដើម្បីភិក្ខុសង្ឃ របស់ដ៏សេសអំពីភិក្ខុសង្ឃទទួលនោះនៅមានច្រើន មនុស្សទាំងឡាយនាំគ្នានិយាយថា សូមលោកម្ចាស់ទាំងឡាយទទួលទុក ដើម្បីភិក្ខុដែលចូលទៅកាន់ស្រុកផងចុះ ។ គ្រានោះ ភិក្ខុកំលោះដែលជាសទ្ធិវិហារិករបស់ព្រះថេរៈចូលទៅកាន់ស្រុក ពួកភិក្ខុទទួលចំណែករបស់លោកទុក កាលលោកមិនទាន់មក ឃើញថាថ្ងៃជិតជ្រេហើយ ក៏យកទៅប្រគេនព្រះថេរៈ ( ព្រះសារីបុត្ត ) ។ កាលព្រះថេរៈឆាន់ហើយ ភិក្ខុកំលោះនោះក៏មកដល់ គ្រានោះ ព្រះថេរៈប្រាប់លោកថា អ្នកមានអាយុ ខ្ញុំឆាន់របស់គួរទំពាស៊ីដែលគេទុកឲ្យលោកអស់ហើយ ។ ភិក្ខុនោះពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ធម្មតារបស់ឆ្ងាញ់អ្នកណាមិនពេញចិត្ត ។ សេចក្តីសង្វេគបានកើតមានដល់ព្រះមហាថេរៈ លោកក៏អធិដ្ឋានទុកថា ចាប់តាំងពីពេលនេះទៅ អញនឹងមិនឆាន់របស់ដែលគួរទំពាស៊ី ដែលធ្វើដោយម្សៅទៀតទេ ។ បានឮថា តាំង

ពីពេលនោះមក ព្រះសារីបុត្តត្ថេរមិនដែលឆាន់របស់ដែលមានឈ្មោះថា របស់គួរទំពាស៊ីដែលធ្វើដោយម្សៅឡើយ ។ ការដែលព្រះធម្មសេនាបតីសារីបុត្តមិនឆាន់របស់ដែលគួរទំពាស៊ីដែលធ្វើដោយម្សៅនោះ បានផ្សព្វ-ផ្សាយទៅដល់ពួកភិក្ខុ ។ ភិក្ខុទាំងឡាយគង់ក្នុងធម្មសភានិយាយគ្នាអំពីរឿងនោះ ។ គ្រានោះ ព្រះបរមសាស្ដា ស្ដេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តសូម្បីអស់ជីវិត ក៏មិនព្រមទទួលវត្ថុដែលខ្លួនបោះបង់ចោលទៀតឡើយ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វកើតក្នុងត្រកូលអាយលម្ពាយ ចិញ្ចឹមជីវិតដោយវេជ្ជកម្ម ។ គ្រានោះ ពស់ខាំអ្នកជនបទម្នាក់ ពួកញាតិរបស់គេមិនធ្វេសប្រហែសប្រញាប់នាំមករកគ្រូពស់ ។ គ្រូពស់សួរថា ចង់ឲ្យខ្ញុំបិទថ្នាំដកពិសមុន ឬក៏ឲ្យហៅពស់មួយដែលខាំនោះមក ឲ្យវាបឺតពិសចេញអំពីមុខដំបៅដែលវាខាំ ?

ពួកញាតិពោលថា សូមលោកហៅពស់នោះមក ឲ្យវាបឺតពិសចេញចុះ ។

គ្រូពស់ក៏ហៅពស់មកហើយសួរថា ឯងខាំបុរសនេះឬ?

ពស់ឆ្លើយថា ពិតមែនហើយ ។

គ្រូពស់ពោលថា ឯងចូរយកមាត់បឺតពិសចេញអំពីមុខដំបៅដែលឯងខាំចុះ ។

ពស់ឆ្លើយថា ខ្ញុំមិនដែលបឺតពិសដែលខ្ញុំបានខ្ជាក់ចោលហើយទេ ខ្ញុំនឹងមិនព្រមបឺតពិសដែលខ្ញុំខ្ជាក់ចោលឡើយ ។

គ្រូពស់ឲ្យគេទៅរកឧសមកបង្កាត់ភ្លើងហើយពោលថា ប្រសិនបើឯងមិនបឺតពិសរបស់ឯងទេ ឯងចូលទៅកាន់គំនរភ្លើងនេះចុះ ។

ពស់ឆ្លើយថា ខ្ញុំសុខចិត្តលូនចូលគំនរភ្លើង ប៉ុន្តែមិនព្រមបឺតពិសដែលខ្ញុំខ្ជាក់ចោលជាដាច់ខាត ហើយពោលគាថានេះថា

**ធិរត្ថុ តំ វិសំ វន្តំ យមហំ ជីវិតការណា**
**វន្តំ បច្ចាវមិស្សាមិ មតំ មេ ជីវិតា វរន្តិ ។**

អញនឹងស្រូបយកពិសណាវិញ ដែលអញបានខ្ជាក់ចោល
ហើយ ព្រោះហេតុនៃជីវិត ចូរតិះដៀលនូវពិសដែលអញ
ខ្ជាក់ចោលហើយនោះចុះ អញស្លាប់ប្រសើរជាងរស់នៅ ។

បណ្ដាបទទាំងនោះ បទថា **ធិរត្ថុ** ជានិបាតចុះ ក្នុងអត្ថថា តិះ-ដៀល ។

បទថា **តំ វិសំ** សេចក្ដីថា ពិសដែលអញខ្ជាក់ចោលហើយ នឹង

*មិនបឺតស្រូបមកវិញ ព្រោះហេតុនៃការរួចផុតនោះឡើយ ។*

*បទថា* **មតំ មេ ជីវិតា វរំ** *សេចក្តីថា ការលូនចូលកាន់គំនរភ្លើងហើយស្លាប់នោះ ប្រសើរជាងការរស់នៅរបស់អញ ដែលបឺតយកពិសនោះវិញ ។ លុះពោលយ៉ាងនេះហើយក៏លូនចូលកាន់គំនរភ្លើង ។ គ្រានោះ គ្រូពស់ក៏ហាមពស់មិនឲ្យលូនចូលកាន់គំនរភ្លើង ហើយចាត់ចែងព្យាបាលបុរសនោះឲ្យអស់ពិស ឲ្យអស់រោគ ដោយឱសថនិងមន្ត ហើយសម្តែងធម៌ឲ្យពស់កាន់សីល រួចហើយផ្តែផ្តាំថា ចាប់ពីពេលនេះទៅឯងកុំបៀតបៀនអ្នកដទៃទៀត ដូច្នេះហើយ ក៏ដោះលែងទៅ ។*

*ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្ត សូម្បីត្រូវលះបង់ជីវិត ក៏មិនព្រមទទួលវត្ថុដែលខ្លួនបោះបង់ហើយដែរ ។ លុះទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ពស់ក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកគ្រូពស់ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា វិសវន្តជាតក ទី ៩ ។

# អដ្ឋកថា កុទ្ទាលជាតក ទី ១០

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះ-ចិត្តហត្ថសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្តើមថា* **ន តំ ជិតំ សាធុ ជិតំ** *ដូច្នេះជាដើម ។*

*បានឮថា ព្រះចិត្តហត្ថសារីបុត្តត្ថេរជាកុមារដែលកើតក្នុងត្រកូលមួយក្នុងនគរសាវត្ថី ។ ថ្ងៃមួយ ភ្ជួរស្រែហើយដោះគោដាក់នង្គ័លចូលទៅកាន់វិហារ បានភោជនប្រណីតមានរសឆ្ងាញ់អំពីបាត្រព្រះថេរៈមួយអង្គ គិតថា អញធ្វើការផ្សេងៗ ដោយដៃរបស់ខ្លួនអស់យប់និងថ្ងៃ ក៏មិនទាន់បានអាហារដ៏ឆ្ងាញ់យ៉ាងនេះដែរ ដូច្នេះអញគួរតែបួសជាសមណៈ ។ លោកបួសហើយបានប្រមាណកន្លះខែ កាលធ្វើទុកក្នុងចិត្តដោយឧបាយមិនប្រពៃធ្លាក់ទៅក្នុងអំណាចនៃកិលេសក៏សឹកទៅ ។ កាលលំបាកលំបិនដោយអាហារក៏មកបួសទៀត រៀនព្រះអភិធម្មដោយឧបាយនេះ សឹកហើយបួសៗ អស់ ៦ ដង ក្នុងភាពជាភិក្ខុលើកទី ៧ ជាអ្នកទ្រទ្រង់ព្រះអភិធម្ម ៧ គម្ពីរ បានបង្រៀនធម៌ដល់ភិក្ខុជាច្រើន ចម្រើនវិបស្សនាបានសម្រេចព្រះ-អរហត្ត ។ គ្រានោះ ភិក្ខុជាសម្លាញ់នឹងលោកចំអកចំអន់ឡកឡឺយថា អាវុសោចិត្តហត្ថ ពេលនេះកិលេសទាំងឡាយរបស់លោកមិនចម្រើនដូចកាលពីមុនទេឬ ? លោកឆ្លើយថា អាវុសោ ចាប់តាំងពីពេលនេះទៅ ខ្ញុំមិនសមគួរទៅជាគ្រហស្ថឡើយ ។ កាលលោកបានសម្រេចអរហត្តយ៉ាង*

នេះហើយ មានការចោទសួរគ្នាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ កាលឧបនិស្ស័យនៃអរហត្តបែបនេះមានហើយ ហេតុដូចម្តេចព្រះចិត្ត-ហត្ថសារីបុត្តត្ថេរត្រូវសឹកអស់ ៦ ដង ភាពជាបុថុជ្ជន ជាភារៈ មានទោសច្រើនដូច្នេះហ្ន៎ ។ ព្រះបរមសាស្តា ស្តេចយាងមកហើយ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដែលឈ្មោះថាចិត្តរបស់បុថុជ្ជន តែងតែវង្វេង សង្កត់សង្កិនបានដោយលំបាក តែងជាប់ដោយអំណាចនៃអារម្មណ៍ លុះជាប់ម្តងហើយក៏មិនអាចដោះបានដោយរហ័ស ( ជាធម្មជាតិរហ័ស មានប្រក្រតីធ្លាក់ទៅតាមសេចក្តីប្រាថ្នាក្នុងអារម្មណ៍ណាមួយ ) ការទូន្មានចិត្តបែបនេះ ជាការប្រពៃណាស់ ព្រោះថា ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំប្រយោជន៍និងសេចក្តីសុខមកឲ្យ ហើយទ្រង់ត្រាស់ព្រះគាថានេះថា

**ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ**
**ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ។**

*ការទូន្មានចិត្ត ដែលសង្កត់សង្កិន បានដោយលំបាក ជាធម្មជាតិរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច (ព្រោះថា)*

ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

លុះទ្រង់ត្រាស់ព្រះគាថានេះហើយ ក៏ត្រាស់តទៅទៀតថា ព្រោះហេតុតែចិត្តនោះ ជាធម្មជាតិសង្កត់សង្កិនបានដោយលំបាក បណ្ឌិតទាំងឡាយក្នុងកាលមុន អាស្រ័យចបតែមួយមិនអាចបោះបង់វាចោលបាន ត្រូវសឹកអស់ ៦ ដង ដោយអំណាចលោភៈ ក្នុងភេទនៃបព្វជិតលើកទី ៧ ញ៉ាំងឈានឲ្យកើតឡើងហើយ ទើបសង្កត់សង្កិនលោភៈនោះបាន ដូច្នេះ ហើយទ្រង់នាំយករឿងក្នុងអតីតកាលមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលអ្នកដាំបន្លែ លុះដឹងក្តីហើយមានឈ្មោះថា កុទ្ទាលបណ្ឌិត ។ កុទ្ទាលបណ្ឌិតសម្អាតផ្ទៃដីដោយចប ដាំបន្លែទាំងឡាយមានឃ្លោក ត្រឡាច ល្ពៅជាដើម បេះបន្លែទាំងនោះលក់ចិញ្ចឹមជីវិតដោយលំបាក ។ ពិតណាស់ កុទ្ទាលបណ្ឌិតក្រៅអំពីចបមួយប៉ុណ្ណោះ ទ្រព្យសម្បត្តិដទៃមិនមានឡើយ ។ ថ្ងៃមួយលោកត្រិះរិះថា នឹងមានប្រយោជន៍អ្វីដោយការនៅគ្រប់គ្រងផ្ទះ អញនឹងបួសដូច្នេះ ។ ថ្ងៃមួយ លោកលាក់ចបទុកក្នុងទីស្ងាត់ហើយបួសជាឥសី ។ កាលនឹកដល់ចបពេលណា ក៏មិនអាចកាត់ការជាប់ជំពាក់បាន ត្រូវសឹកព្រោះអាស្រ័យចបកំបុតមួយនោះ ។ លើកទី ២ លើកទី ៣ ក៏យ៉ាងនោះ លាក់ចបនោះទុកក្នុងទីកំបាំង បួសសឹកៗ អស់ ៦ ដង ក្នុងលើកទី ៧ បាន

គិតឃើញថា អញអាស្រ័យចបកំបាក់មួយនេះ ត្រូវសឹកអស់ច្រើនដង លើកនេះអញនឹងគ្រវែងវាចោលក្នុងទន្លេហើយបួស លុះគិតដូច្នេះហើយ ក៏ដើរទៅកាន់មាត់ទន្លេ គិតថា ប្រសិនបើអញនៅឃើញទីធ្លាក់របស់វា ក៏នឹងត្រូវចង់ស្រង់វាឡើងមកវិញទៀត ហើយចាប់ដងចបដោយកម្លាំងដ៏ខ្លាំងដូចដំរីសារ គ្រវីលើក្បាល ៣ ជុំ ធ្មេចភ្នែកគ្រវែងទៅកណ្ដាលទន្លេ ហើយបន្លឺសំឡេងខ្លាំងៗ ៣ ដងថា អញឈ្នះហើយ អញឈ្នះហើយ ។

គ្រានោះ ព្រះបាទពារាណសីទ្រង់បង្ក្រាបបច្ចន្តជនបទរួចរាល់ហើយ ស្ដេចត្រឡប់មកវិញ ទ្រង់កក់ព្រះកេសាក្នុងទន្លេនោះ ប្រដាប់អង្គដោយគ្រឿងអលង្ការទាំងពួង ស្ដេចយាងទៅដោយក្បួនដំរី ទ្រង់ព្រះសណ្ដាប់សំឡេងរបស់ព្រះបរមពោធិសត្វ ទ្រង់សង្ស័យក្នុងព្រះទ័យថា បុរសនេះពោលថា អញឈ្នះហើយ អញឈ្នះហើយ អ្នកណាទៅដែលគេឈ្នះនោះ? មានព្រះតម្រាស់ឲ្យហៅកុទ្ទាលបណ្ឌិតមកគាល់ ហើយត្រាស់សួរថា នែបុរសដ៏ចម្រើន យើងកំពុងឈ្នះសង្គ្រាម មានជ័យជម្នះនៅពេលនេះ ចំណែកអ្នកឈ្នះអ្វី ?

ព្រះបរមពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព សូម្បីព្រះ-អង្គឈ្នះសង្គ្រាមទាំង ១ រយដង ទាំង ១ ពាន់ដង សូម្បី ១ សែនដង ក៏នៅតែឈ្មោះថា ឈ្នះមិនប្រពៃ ព្រោះយកឈ្នះកិលេសទាំងឡាយមិនទាន់បាន ប៉ុន្តែទូលបង្គំសង្កត់សង្កិនកិលេសខាងក្នុងបាន យកឈ្នះកិលេស

ទាំងឡាយបាន លុះពោលដូច្នេះហើយ សម្លឹងមើលទឹកទន្លេ ញ៉ាំងឈាន មានអាបោកសិណជាអារម្មណ៍ឲ្យកើតឡើងហើយ អង្គុយក្នុងអាកាស ដោយអំណាចនៃឈាននិងសមាបត្តិ កាលនឹងសម្តែងធម៌ថ្វាយព្រះរាជា ក៏បានពោលគាថានេះថា

**ន តំ ជិតំ សាធុ ជិតំ យំ ជិតំ អវជីយតិ**
**តំ ខោ ជិតំ សាធុ ជិតំ យំ ជិតំ នាវជិយ្យតីតិ ។**

សេចក្តីឈ្នះណា ត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះ នោះ មិនឈ្មោះថា ឈ្នះប្រពៃទេ សេចក្តីឈ្នះណា មិនត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះនោះ ទើប ឈ្មោះថា ឈ្នះប្រពៃមែនពិត ។

បណ្តាបទទាំងនោះ បទថា **ន តំ ជិតំ សាធុ ជិតំ យំ ជិតំ អវជីយតិ** សេចក្តីថា ការបង្ក្រាបបច្ចាមិត្របាន ហើយឈ្នះដណ្តើមយក ដែនបាន ហើយបច្ចាមិត្តទាំងនោះនឹងរកវិធីវាយដណ្តើមយកវិញ ការ ឈ្នះនោះ មិនឈ្មោះថា ជាការឈ្នះដ៏ប្រពៃទេ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះត្រូវនៅវាយដណ្តើមគ្នារឿយៗ ។

ម្យ៉ាងទៀត ជ័យជម្នះដែលហៅបានថា ការឈ្នះព្រោះច្បាំងនឹង បច្ចាមិត្រ ក្រោយមកកាលបច្ចាមិត្រច្បាំងឈ្នះវិញ ក៏ត្រឡប់ជាបរាជ័យ

ជ័យជម្នះនោះមិនប្រសើរឡើយ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះត្រឡប់ជាបរាជ័យវិញ ។

បទថា **តំ ខោ ជិតំ សាធុ ជិតំ យំ ជិតំ នាវជិយ្យតិ** សេចក្តីថា ចំណែកការសង្កត់សង្កិនពួកបច្ចាមិត្របានហើយឈ្នះ បច្ចា-មិត្រទាំងនោះ នឹងដណ្តើមយកជ័យជម្នះមិនបាន ការបានជ័យជម្នះតែម្តង ហើយមិនត្រឡប់ទៅជាបរាជ័យវិញ ការឈ្នះនោះជាការឈ្នះដ៏ប្រពៃ គឺជ័យជម្នះនោះឈ្មោះថាប្រសើរ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះមិនបរាជ័យវិញ ។ បពិត្រព្រះសម្មតិទេព ព្រោះហេតុនោះ សូម្បីទ្រង់ឈ្នះសង្គ្រាមដ៏ធំទាំងមួយពាន់ដង មួយសែនដង ក៏មិនមានព្រះនាមថាជាមេទ័ពដ៏កំពូលដែរ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះទ្រង់មិនទាន់ឈ្នះកិលេសរបស់ទ្រង់ ចំណែកបុគ្គលណាឈ្នះកិលេសក្នុងខ្លួនបានសូម្បីតែម្តង បុគ្គលនោះចាត់ជាមេទ័ពដ៏កំពូល ។ ព្រះបរមពោធិសត្វអង្គុយក្នុងអាកាសសម្តែងធម៌ថ្វាយព្រះរាជាដោយពុទ្ធលីលា ក្នុងភាពជាមេទ័ពដ៏កំពូលនោះ មានព្រះសូត្រជាគ្រឿងសាធកដូច្នេះថា

យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ។

*អ្នកណា គប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាមអស់មួយពាន់ៗ ដង គឺមួយលាន ចំណែកអ្នកណា ឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះឈ្មោះថាជាមនុស្សខ្ពង់ខ្ពស់ ជាងអ្នកដែលឈ្នះ ក្នុងសង្គ្រាមនោះ ។*

*កាលព្រះរាជាទ្រង់ស្តាប់ព្រះធម៌នោះឯង ទ្រង់លះបង់កិលេសបាន ដោយអំណាចតទង្គប្បហាន មានព្រះទ័យបង្អោនទៅក្នុងបព្វជ្ជា ។ សូម្បីពួកយោធារបស់ព្រះអង្គ ក៏លះបង់កិលេសបានដែរ ។ ព្រះរាជាត្រាស់សួរព្រះបរមពោធិសត្វថា ពេលនេះអ្នកនឹងទៅទីណា ?*

*ព្រះបរមពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំនឹងចូលព្រៃហេមពាន្តបួសជាឥសី ។ ព្រះរាជាត្រាស់ថា បើដូច្នោះយើងក៏បួសដែរ ហើយស្តេចយាងទៅជាមួយនឹងព្រះបរមពោធិសត្វ ។ ពលនិកាយទាំងអស់គឺ ព្រាហ្មណ៍ គហបតីនិងពួកទាហានទាំងអស់ ប្រជុំគ្នាក្នុងគណៈនោះ ជាមហាសមាគមចេញបព្វជ្ជាជាមួយព្រះរាជាដែរ ។ អ្នកនគរពារាណសីឮដំណឹងថា ព្រះរាជាយើងទាំងឡាយទ្រង់ព្រះសណ្តាប់ព្រះធម្មទេសនារបស់កុទ្ទាលបណ្ឌិតហើយ ទ្រង់បែរព្រះភក្ត្រសំដៅទៅរកបព្វជ្ជា ស្តេចយាងចេញទ្រង់ព្រះផ្នួសមួយអន្លើដោយពលនិកាយ ( ក៏គិត*

ថា ) ពួកយើងនៅធ្វើអ្វីក្នុងនគរនេះទៀត ? គិតដូច្នេះហើយ អ្នកនៅក្នុងនគរទាំងអស់ នាំគ្នាចេញអំពីនគរពារាណសីដែលមានបរិមណ្ឌល ១២ យោជន៍ បរិស័ទក៏មានបរិមណ្ឌល ១២ យោជន៍ដែរ ព្រះបរមពោធិសត្វនាំបរិស័ទទាំងអស់នោះចូលកាន់ព្រៃហេមពាន្ត ។ ក្នុងខណៈនោះ អាសនៈរបស់សក្កទេវរាជសម្តែងអាការក្តៅ ។ សក្កទេវរាជទ្រង់ពិចារណាមើលក៏ទតឃើញថា កុទ្ទាលបណ្ឌិតចេញសាងមហាភិនិស្ក្រមណ៍ ហើយទ្រង់ព្រះតម្រិះថា នឹងមានជាមហាសមាគម ដូច្នេះ កុទ្ទាលបណ្ឌិតនោះគួរតែបានទីលំនៅ ហើយត្រាស់ហៅវិស្សុកម្មទេវបុត្រមក ត្រាស់បញ្ជាថា នែវិស្សុកម្មទេវបុត្រ កុទ្ទាលបណ្ឌិតកំពុងចេញសាងអភិនិស្ក្រមណ៍ លោកគួរបានទីលំនៅ អ្នកចូរទៅកាន់ព្រៃហេមពាន្ត និមិត្តអាស្រមបទបណ្តោយ ៣០ យោជន៍ ទទឹង ១៥ យោជន៍ នៅក្នុងភូមិភាគដ៏គួរឲ្យមនោរម្យចុះ ។

វិស្សុកម្មទេវបុត្តទទួលទេវបញ្ជាថា ព្រះករុណាថ្លៃវិសេស ខ្ញុំព្រះអង្គនឹងធ្វើឲ្យសម្រេចដូចទេវបញ្ជា ហើយក៏ទៅធ្វើតាមនោះ នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ។ ចំណែកសេចក្តីពិស្តារនឹងប្រាកដច្បាស់ក្នុង **ហត្ថិបាលជាតក** ពិតណាស់ រឿងនេះនិងរឿងនោះមានបរិច្ឆេទតែមួយ ។

ចំណែកវិស្សុកម្មទេវបុត្រ និមិត្តបណ្ណសាលាក្នុងអាស្រមបទហើយក៏បណ្តេញម្រឹគ បក្សី និងអមនុស្សដែលមានសំឡេងអាក្រក់ ឲ្យទៅឆ្ងាយ

ហើយនិមិត្តផ្លូវដើរតូចៗ តាមទិសាភាគនោះៗស្រេចហើយ ត្រឡប់ទៅកាន់វិមានដែលជាលំនៅរបស់ខ្លួនវិញ ។

ចំណែកកុទ្ទាលបណ្ឌិតនាំបរិស័ទចូលកាន់ព្រៃហេមពាន្ត ធ្វើដំណើររហូតដល់អាស្រមបទដែលសក្កទេវរាជទ្រង់ប្រទាន កាន់យកគ្រឿងបរិក្ខាររបស់បព្វជិតដែលវិស្សុកម្មទេវបុត្រនិមិត្តទុកឲ្យ បួសខ្លួនឯងមុនហើយ ឲ្យបរិស័ទបួសតាមក្រោយ ចាត់ចែងអាស្រមបទឲ្យនៅតាមសមគួរ មានព្រះរាជា ៧ ព្រះអង្គទៀត លះបង់រាជសម្បត្តិ ៧ នគរ (តាមមកទ្រង់ព្រះ-ផ្នួស ) អាស្រមបទ ៣០ យោជន៍ពេញបរិបូរ ។ កុទ្ទាលបណ្ឌិតធ្វើបរិកម្មក្នុងកសិណដ៏សេស ចម្រើនព្រហ្មវិហារធម៌ប្រាប់កម្មដ្ឋានដល់បរិស័ទ ។ បរិស័ទទាំងអស់សុទ្ធតែបានសមាបត្តិ ចម្រើនព្រហ្មវិហារហើយនាំគ្នាទៅកាន់ព្រហ្មលោកទាំងអស់ ។ ចំណែកប្រជាជនដែលឧបត្ថម្ភទំនុកបម្រុងតាបសទាំងអស់នោះ ក៏សុទ្ធតែបានទៅកាន់ទេវលោកទាំងអស់ដែរ ។

ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាចិត្តនេះជាប់ទៅដោយអំណាចនៃកិលេសហើយ ជាធម្មជាតិដោះបានដោយលំបាក លោភធម៌ទាំងឡាយដែលកើតឡើងហើយ ជាសភាវៈដែលលះ-បង់បានដោយកម្រ រមែងធ្វើបុគ្គលជាបណ្ឌិតដូច្នេះ ឲ្យក្លាយទៅជាមនុស្សមិនចេះដឹងដោយប្រការដូច្នេះ ។ លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ កាលចប់សច្ចៈ ភិក្ខុទាំងឡាយពួក

ខ្លះបានជាព្រះសោតាបន្ន ពួកខ្លះបានជាព្រះសកទាគាមី ពួកខ្លះបានជាព្រះអនាគាមី ពួកខ្លះបានជាព្រះអរហន្ត ។ ព្រះបរមសាស្តា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកកុទ្ទាលបណ្ឌិត គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា កុទ្ទាលជាតក ទី ១០ ។

ចប់ អដ្ឋកថា ឥត្ថីវគ្គ ទី ៧ ។

## រួមជាតកដែលមានក្នុងវគ្គនេះគឺ

*អសាតមន្តជាតក ១ អណ្ឌភូតជាតក ១ តក្កជាតក ១ ទុរាជានជាតក ១ អនភិរតិជាតក ១ មុទុលក្ខណជាតក ១ ឧច្ឆង្គជាតក ១ សាកេតជាតក ១ វិសវន្តជាតក ១ កុទ្ទាលជាតក ១ ។*

# វរុណវគ្គ ទី ៨

# អដ្ឋកថា វរុណជាតក ទី ១

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សត្ថេរបុត្តកុដុម្ពិកៈ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **យោ បុព្វេ ករណីយានិ** *ដូច្នេះជាដើម ។*

*បានឮថា ថ្ងៃមួយ កុលបុត្តអ្នកនគរសាវត្ថីជាសម្លាញ់នឹងគ្នាប្រមាណ ៣០ នាក់ កាន់ផ្កាកម្រងគ្រឿងក្រអូបនិងសំពត់ជាដើម គិតថា ពួកយើងនឹងស្តាប់ព្រះធម្មទេសនារបស់ព្រះបរមសាស្តា ដែលមហាជនចោមរោមហើយនាំគ្នាទៅកាន់វត្តជេតពន អង្គុយសម្រាកក្នុងរោងឈ្មោះនាគមាឡកៈនិងវិសាលមាឡកៈជាដើម ។ លុះវេលារសៀល កាលដែលព្រះបរមសាស្តាស្តេចយាងចេញអំពីព្រះគន្ធកុដិ ដែលអប់ហើយដោយគ្រឿងក្រអូបស្តេចយាងទៅកាន់ធម្មសភា ទ្រង់គង់លើបវរពុទ្ធាសនៈដែលតាក់តែងហើយ ទើបនាំគ្នាទៅកាន់ធម្មសភាមួយអន្ទើដោយបរិវារ បូជាព្រះបរមសាស្តាដោយគ្រឿងក្រអូបនិងកម្រងផ្កា ថ្វាយបង្គំបាទមូលដែលប្រដាប់ដោយចក្រ ទ្រទ្រង់ព្រះរស្មីប្រៀបដូចផ្ការីក ហើយអង្គុយស្តាប់ធម៌នៅក្នុងទីដ៏សមគួរមួយ ។ ពួកគេគិតថា យើងទាំងឡាយត្រូវបួស ទើបដឹងទូទៅដល់ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយបានទូលទូលាយ ពេលដែលព្រះតថាគតស្តេចចេញអំពីធម្មសភា កុលបុត្រទាំងនោះក៏នាំគ្នាចូល*

ថ្វាយបង្គំទូលសូមបព្វជ្ជា ។ ព្រះបរមសាស្តាទ្រង់ប្រទានបព្វជ្ជាឲ្យដល់កុលបុត្តទាំងនោះ ។ កុលបុត្តទាំងនោះធ្វើឲ្យអាចារ្យនិងឧបជ្ឈាយ៍ប្រោសប្រាណហើយ បានឧបសម្បទានៅក្នុងសម្នាក់អាចារ្យនិងឧបជ្ឈាយ៍ ៥ ព្រះ-វស្សា រៀនមាតិកាទាំងពីរស្ទាត់ជំនាញហើយ ស្គាល់វត្ថុដែលជាកប្បិយៈនិងអកប្បិយៈ រៀនអនុមោទនា ៣ ដេរជ្រលក់ចីវរ ហើយលាអាចារ្យនិងឧបជ្ឈាយ៍ថា បពិត្រលោកអាចារ្យ ពួកខ្ញុំនឹងបំពេញសមណធម៌ ហើយនាំគ្នាចូលទៅគាល់ព្រះបរមសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរហើយក្រាបទូលអង្វរថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គនឿយ-ណាយក្នុងភពទាំងឡាយ ខ្លាចការកើត ចាស់ ឈឺ ស្លាប់ សូមព្រះអង្គទ្រង់ព្រះមេត្តាត្រាស់ប្រាប់កម្មដ្ឋាន ដើម្បីដោះខ្លួនអំពីសង្សារទុក្ខដល់ពួកខ្ញុំព្រះ-អង្គចុះ ។ ព្រះបរមសាស្តាទ្រង់ជ្រាបសប្បាយៈ ទើបត្រាស់ប្រាប់កម្មដ្ឋាន ១ ក្នុងបណ្តាកម្មដ្ឋានទាំង ៣៨ ប្រការ [១] ដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះបរមសាស្តាហើយថ្វាយបង្គំទ្រង់ ធ្វើប្រទក្សិណទៅកាន់បរិវេណ លាអាចារ្យនិងឧបជ្ឈាយ៍ កាន់យកបាត្រនិងចីវរចេញអំពីវិហារ ធ្វើដំណើរទៅដោយតាំងចិត្តថា ពួកយើងនឹងបំពេញ

---

១- កម្មដ្ឋាន ៣៨ គឺ កម្មដ្ឋាន ៤០ វៀរ អនាបានស្សតិ និង មរណានុស្សតិ ។

សមណធម៌ ។

គ្រានោះ បណ្ដាភិក្ខុទាំងនោះ មានភិក្ខុមួយរូបដែលមានឈ្មោះថា កុដុម្ពិកបុត្តតិស្សត្ថេរ ជាអ្នកខ្ជិលច្រអូសមានសេចក្ដីព្យាយាមធូរថយ ជាប់ជំពាក់នឹងរសអាហារ លោកគិតយ៉ាងនេះថា អញមិនអាចនៅក្នុងព្រៃ មិនអាចនឹងញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយការត្រាច់បិណ្ឌបាតបានទេ ការនៅក្នុងព្រៃមិនមានប្រយោជន៍អ្វីដល់អញឡើយ អញនឹងត្រឡប់ទៅវិញ លោកបោះបង់ចោលសេចក្ដីព្យាយាមហើយ និមន្តតាមភិក្ខុទាំងនោះបានបន្តិចហើយក៏ត្រឡប់វិញ ។ ចំណែកភិក្ខុទាំងនោះ នាំគ្នាត្រាច់ទៅកាន់ចារិកក្នុងដែនកោសល ដល់ស្រុកជាយដែនមួយ ក៏ចូលទៅអាស្រ័យស្រុកនោះ ចាំវស្សានៅក្បែរមាត់ព្រៃមួយកន្លែង ជាអ្នកមិនប្រមាទ ព្យាយាមរហូតអស់កាលខាងក្នុងវស្សា កាន់យកបន្ទប់វិបស្សនា ញុំាំងបឋវីឲ្យញាប់ញ័រ បានសម្រេចព្រះអរហត្ត លុះចេញវស្សាបវារណាហើយ ប្រឹក្សាគ្នាថា នឹងក្រាបទូលគុណដែលខ្លួនបានសម្រេចហើយចំពោះព្រះបរមសាស្ដា ទើបនាំគ្នាចេញអំពីបច្ចន្តគ្រាម និមន្តទៅដល់វត្តជេតពនដោយលំដាប់ ទុកដាក់បាត្រនិងចីវរស្រួលបួលហើយ ក៏ចូលទៅជួបអាចារ្យនិងឧបជ្ឈាយ៍ ប្រាថ្នានឹងចូលទៅគាល់ព្រះតថាគត នាំគ្នាទៅកាន់សម្នាក់ទ្រង់ ថ្វាយបង្គំហើយអង្គុយគាល់ក្នុងទីដ៏សមគួរ ។ ព្រះបរមសាស្ដាទ្រង់ធ្វើបដិសណ្ឋារៈដោយព្រះតម្រាស់ដ៏ពីរោះនឹងភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះ បានទទួល

បដិសណ្ឋារៈហើយ ក៏ក្រាបទូលគុណដែលខ្លួនបានហើយចំពោះព្រះអង្គ ។ ព្រះបរមសាស្ដាទ្រង់សរសើរគុណភិក្ខុទាំងនោះ ព្រះកុដុម្ពិកបុត្តតិស្សត្ថេរ ឃើញព្រះបរមសាស្ដាទ្រង់សរសើរគុណភិក្ខុទាំងនោះ ក៏ប្រាថ្នានឹងបំពេញសមណធម៌ដែរ ។ ចំណែកភិក្ខុទាំងនោះក៏ក្រាបទូលលាព្រះតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គនឹងទៅនៅមាត់ព្រៃនោះ ព្រះបរម-សាស្ដាក៏ទ្រង់អនុញ្ញាត ។ ភិក្ខុទាំងនោះ ថ្វាយបង្គំព្រះបរមសាស្ដាហើយ និមន្តទៅកាន់បរិវេណ ។ គ្រានោះ ព្រះកុដុម្ពិកបុត្តតិស្សត្ថេរបំពេញសេចក្ដីព្យាយាមដ៏តឹងរ៉ឹងក្នុងរវាងរត្តិកាល បំពេញសមណធម៌ដ៏ខ្លាំងក្លាពេក លុះដល់មជ្ឈិមយាមទាំងដែលខ្លួនឈរផ្អែកបង្ខះក្ដារសម្រាប់សម្រាក ក៏ដេកលក់រមៀលធ្លាក់ចុះមក ឆ្អឹងក្បាលជង្គង់របស់លោកក៏បែក កើតទុក្ខវេទនាយ៉ាងខ្លាំងក្លា ។ កាលភិក្ខុទាំងនោះត្រូវជួយបម្រើលោក ការធ្វើដំណើរទៅក៏ត្រូវផ្អាក ។ គ្រានោះ ព្រះបរមសាស្ដាត្រាស់សួរភិក្ខុទាំងនោះដែលមកកាន់ទីបម្រើថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយថ្វាយបង្គំលាតថាគតកាលពីម្សិលថា នឹងនាំគ្នាទៅក្នុងថ្ងៃស្អែក មិនមែនឬ ?

ភិក្ខុទាំងនោះក្រាបទូលថា ពិតដូច្នោះមែនហើយព្រះអង្គ ប៉ុន្តែតិស្សត្ថេរបុត្តកុដុម្ពិកៈជាសម្លាញ់របស់ខ្ញុំព្រះអង្គទាំងឡាយ ធ្វើសមណធម៌យ៉ាងខ្លាំងក្លាក្នុងវេលាមិនមែនកាល ត្រូវការងងុយគ្របសង្កត់ រមៀលធ្លាក់បែកក្បាលជង្គង់ ព្រោះមានលោកជាហេតុ ទើបពួកខ្ញុំព្រះអង្គចាំបាច់ត្រូវ

បញ្ឈប់ការធ្វើដំណើរ ។

ព្រះតថាគតទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះប្រញាប់ធ្វើសេចក្ដីព្យាយាមក្នុងវេលាដែលមិនមែនកាល ព្រោះការដែលខ្លួនជាអ្នកមានសេចក្ដីព្យាយាមធួរថយ ទើបធ្វើឲ្យអន្តរាយដល់ការធ្វើដំណើររបស់ពួកអ្នក សូម្បីក្នុងកាលមុន ភិក្ខុនេះក៏បានធ្វើឲ្យអន្តរាយដល់ការធ្វើដំណើររបស់ពួកអ្នកដែរ ។ កាលភិក្ខុទាំងនោះក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបរមពោធិសត្វសោយព្រះជាតិជាអាចារ្យទិសាបាមោក្ខ ឲ្យមាណព ៥០០ នាក់រៀនសិល្បៈ នៅក្នុងនគរតក្កសិលាដែនគន្ធារៈ ។ ថ្ងៃមួយ មាណពទាំងនោះនាំគ្នាទៅព្រៃដើម្បីរកឧសប្រមូលឧសទុក ក្នុងចំណោមមាណពទាំងនោះ មានមាណពខ្ជិលម្នាក់ឃើញដើមថ្ងាន់សម្គាល់ថាដើមឈើនេះ ជាដើមឈើស្ងួត គិតថា ដេកបន្តិចសិនក៏បាន ក្រោយសឹមឡើងកាច់ឧសទម្លាក់ចុះកងទៅ ទើបក្រាលសំពត់ដណ្ដប់ដេកស្រមុកយ៉ាងស្រួល ។ ចំណែកមាណពក្រៅពីនេះ នាំគ្នាចងឧសជាបាច់ៗ ហើយរែកទៅ យកជើងទាត់ខ្នងមាណពនោះ មាណពនោះភ្ញាក់ហើយទើបនាំគ្នាទៅ ។ មាណពកម្ជិលនោះក្រោកឡើងយកដៃញីភ្នែក រហូតទាល់បាត់ងងុយដេកហើយក៏ឡើងដើមឈើនោះ ចាប់មែក

ស្ងួតឲ្យកោងមករកខ្លួន គ្រាន់តែកាច់ភ្ញាម ចុងមែកឈើដែលកាច់នោះ ភ្ញាត់មកចំភ្នែកខ្វាក់ យកដៃម្ខាងបិទភ្នែក ដៃម្ខាងកាច់ឧសស្រស់ៗ ចុះមក ចងជាបាច់វែកទៅយ៉ាងប្រញាប់ យកទៅបោះលើឧសដែលពួកមាណពគរទុកនោះដែរ ។ ក្នុងថ្ងៃនោះ ត្រកូលមួយដែលមានប្រក្រតីនៅក្នុងជនបទនិមន្តអាចារ្យទុកថា ថ្ងៃស្អែកនេះ ពួកខ្ញុំនិមន្តអាចារ្យសូត្រមន្ត ។ អាចារ្យក៏ពោលទៅកាន់មាណពទាំងនោះថា នែអ្នកទាំងឡាយ ថ្ងៃស្អែកនេះ ត្រូវទៅកាន់ស្រុកមួយ ប៉ុន្តែត្រូវបរិភោគមុនសិន បើមិនបរិភោគទេ មិនអាចទៅបានទេ ត្រូវឲ្យគេដាំបាយអំពីព្រលឹម ហើយកាន់យកចំណែកសម្រាប់ខ្លួននិងចំណែកសម្រាប់យើង ហើយប្រញាប់នាំគ្នាទៅចុះ ។ មាណពទាំង-នោះដាស់ទាសីឲ្យក្រោកឡើងដាំបាយអំពីព្រលឹម ទាសីនោះទៅយកឧសក៏បានឧសស្រស់ សូម្បីយកមាត់ផ្លុំរឿយៗ ក៏មិនអាចធ្វើឲ្យភ្លើងឆេះបានរហូតទាល់តែព្រះអាទិត្យរះឡើង ។ មាណពទាំងនោះឃើញថា ថ្ងៃណាស់ហើយ ពួកយើងមិនអាចទៅបានទេ ក៏នាំគ្នាទៅកាន់សម្នាក់អាចារ្យ ។ អាចារ្យសួរថា នែអ្នកទាំងឡាយ អ្នកទាំងឡាយមិនបានទៅទេឬ?

មាណពទាំងនោះឆ្លើយថា បាទលោកអាចារ្យ ពួកខ្ញុំមិនបានទៅទេ ។

អាចារ្យសួរថា ព្រោះហេតុអ្វី ?

មាណពទាំងនោះឆ្លើយប្រាប់ថា មាណពកម្ជិលឯណោះ ទៅព្រៃរកឧសជាមួយនឹងពួកខ្ញុំ ទៅដេកលក់ក្រោមដើមថ្ងាន់ ក្រោយពីភ្ញាក់ប្រញាប់

ឡើងដើមថ្នាំ កាច់មែកថ្នាំធ្វើជាឧស ត្រូវមែកថ្នាំបាក់ភ្ញាត់មកត្រូវភ្នែក ខ្វាក់ យកឧសស្រស់ៗ មកបោះលើឧសដែលពួកខ្ញុំរកបានមក អ្នកដាំបាយយកឧសស្រស់ៗ នោះទៅដោយសម្គាល់ថាឧសស្ងួត រហូតទាល់តែព្រះ-អាទិត្យរះឡើងខ្ពស់ក៏មិនអាចបង្កាត់ភ្លើងឲ្យឆេះបាន ដោយហេតុនេះទើបជាឧបសគ្គចំពោះការធ្វើដំណើររបស់ពួកខ្ញុំ ។ ព្រះពោធិសត្វស្តាប់រឿងដែលមាណពនោះធ្វើខុសហើយ ក៏ពោលថា ការវិនាសបែបនេះ រមែងមានព្រោះអាស្រ័យអំពើរបស់ពួកអន្ធពាល ហើយពោលគាថានេះថា

**យោ បុព្វេ ករណីយានិ បច្ឆា សោ កាតុមិច្ឆតិ**
**វរុណកដ្ឋំ ភញ្ជោវ ស បច្ឆា អនុតប្បតីតិ ។**

អំពើទាំងឡាយដែលគេត្រូវធ្វើក្នុងកាលមុន នរៈណាប្រាថ្នាធ្វើ ខាងក្រោយវិញ នរៈនោះ រមែងក្តៅក្រហាយរឿយៗ ក្នុងកាល ជាខាងក្រោយ ដូចជាមាណព ដែលកាច់ឧសឈើថ្នាំ ។

បណ្តាបទទាំងនោះ បទថា **ស បច្ឆា អនុតប្បតិ** សេចក្តីថា បុគ្គលណាមួយមិនបានពិចារណាឲ្យបានច្បាស់ថា កិច្ចនេះត្រូវធ្វើមុន កិច្ចនេះត្រូវធ្វើក្រោយ យកកិច្ចដែលត្រូវធ្វើមុន គឺអំពើដែលត្រូវធ្វើមុននោះឯងមកធ្វើក្រោយវិញ បុគ្គលនោះជាបុគ្គលពាល រមែងក្តៅក្រហាយ គឺសោកសៅក្នុងកាលជាខាងក្រោយ ដូចជាមាណពដែលកាច់ឧសឈើថ្នាំ។

ព្រះបរមពោធិសត្វពោលហេតុនេះ ចំពោះពួកអន្តេវាសិកដោយ

ប្រការដូច្នេះហើយ ធ្វើបុណ្យមានឲ្យទានជាដើម ក្រោយពីអស់ជីវិតក៏ទៅតាមយថាកម្មរបស់ខ្លួន ។

ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលភិក្ខុនេះ ធ្វើឲ្យអន្តរាយចំពោះការធ្វើដំណើររបស់ពួកអ្នកនោះ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏បានធ្វើឲ្យអន្តរាយដែរ ។ ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា មាណពខ្ជាក់ក្អែកក្នុងកាលនោះ បានមកជាភិក្ខុបែកឆ្អឹងក្បាលជង្គង់ក្នុងកាលឥឡូវនេះ មាណពដ៏សេស បានមកជាពុទ្ធបរិស័ទ ចំណែកព្រាហ្មណ៍ជាអាចារ្យ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា វរុណជាតក ទី ១ ។

# អដ្ឋកថា សីលវនាគជាតក ទី ២

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្តើមថា **អកតញ្ញុស្ស បោសស្ស** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ភិក្ខុទាំងឡាយគង់សន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុទេវទត្តជាបុគ្គលអកតញ្ញូ មិនដឹងគុណព្រះតថាគត ។ ព្រះបរមសាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ

ទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលភិក្ខុទេវទត្តជាបុគ្គលអកតញ្ញូនេះ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ធ្លាប់ជាបុគ្គលអកតញ្ញូមិនដឹងគុណាតថាគតដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងកំណើតដំរីនៅក្នុងហិមវន្តប្រទេស កាលប្រសូតចាកគភ៌មាតាក៏មានអវយវៈសទាំងអស់ មានពណ៌ចែងចាំងដូចប្រាក់ ភ្នែកទាំងគូរបស់ស្តេចដំរីនោះដូចកែវមណី មានបសាទគ្រប់ ៥ ចំណែក មាត់ដូចសំពត់កម្ពលក្រហម ប្រមោយដូចកម្រងប្រាក់ដែលប្រដាប់ចាំងផ្ទេកៗ ដោយមាស ជើងទាំង ៤ ដូចជ្រលក់ដោយទឹកល័ក្ត អត្តភាពដែលបារមីទាំង ១០ តាក់តែងហើយរបស់ដំរីពោធិសត្វនោះ ដល់នូវភាពដ៏ល្អគួរឲ្យគយគន់យ៉ាងនេះ ។ គ្រានោះ ហ្វូងដំរីក្នុងព្រៃហេមពាន្តទាំងអស់មកប្រជុំគ្នា ហើយនាំគ្នាបម្រើព្រះបរមពោធិសត្វដែលធំដឹងក្តីហើយ ទើបព្រះបរមពោធិសត្វមានដំរី ៨ ម៉ឺនជាបរិវារ រស់នៅក្នុងព្រៃហេមពាន្តដោយប្រការដូច្នេះ ។ ក្រោយមកឃើញទោសក្នុងពួកគណៈ ក៏ចៀសចេញចាកពួកគណៈទៅកាន់ទីស្ងាត់កាយ ស្នាក់អាស្រ័យនៅក្នុងព្រៃ

តែម្នាក់ឯងប៉ុណ្ណោះ ។ ព្រោះហេតុតែដំរីពោធិសត្វនោះជាសត្វមានសីល ទើបមានឈ្មោះថា សីលវនាគរាជ ស្តេចដំរីមានសីល ។ គ្រានោះ ព្រានព្រៃអ្នកនគរពារាណសីម្នាក់ ចូលកាន់ព្រៃស្វែងរកវត្ថុដែលជាគ្រឿងញ៉ាំងជីវិតរបស់ខ្លួនឲ្យប្រព្រឹត្តទៅ មិនអាចកំណត់ទិសបានក៏វង្វេងផ្លូវ ជាអ្នកខ្លាចស្លាប់លើកម្រាមដៃដប់ យំរៀបរាប់សោកសៅនៅក្នុងព្រៃនោះ ។ ស្តេចដំរីពោធិសត្វបានឮសំឡេងយំរបស់ព្រានព្រៃនោះហើយ ត្រូវករុណាចូលមកដាស់តឿនថា អញនឹងជួយបុរសនេះឲ្យផុតទុក្ខ ក៏ដើរចូលទៅរកបុរសនោះ បុរសនោះឃើញស្តេចដំរីហើយក៏រត់គេច ។ ព្រះបរមពោធិសត្វឃើញបុរសនោះរត់ ក៏ឈប់ឈរ ។ បុរសនោះឃើញព្រះបរមពោធិសត្វឈប់ក៏ឈប់ដែរ ។ ព្រះបរមពោធិសត្វក៏ដើរទៅជិតទៀត បុរសនោះក៏រត់គេចទៀត ។ ពេលព្រះបរមពោធិសត្វឈប់ បុរសនោះក៏ឈប់ហើយគិតថា ស្តេចដំរីនេះពេលអញរត់ក៏ឈប់ឈរ ដើរមករកអញពេលដែលអញឈប់ ប្រហែលជាមិនមានបំណងអាក្រក់ចំពោះអញទេ ប្រាកដជាចង់ជួយអញឲ្យផុតទុក្ខ ទើបបុរសនោះដាច់ចិត្តឈរស្ងៀម ។ ព្រះមហាសត្វចូលទៅជិតបុរសនោះហើយសួរថា នែបុរសដ៏ចម្រើន ហេតុដូចម្តេចទើបអ្នកដើរយំនៅក្នុងព្រៃនេះ ?

បុរសនោះឆ្លើយថា នែស្តេចដំរី ខ្ញុំវង្វេងទិស រកផ្លូវទៅផ្ទះមិនឃើញ ទើបដើរយំនៅក្នុងព្រៃ ព្រោះខ្លាចស្លាប់ ។ គ្រានោះ ព្រះមហាសត្វ

ក៏នាំបុរសនោះទៅកាន់លំនៅរបស់ខ្លួន ឲ្យបរិភោគទាល់តែឆ្អែតដោយផលាផលអស់ពីរ-បីថ្ងៃ ហើយពោលថា នែបុរសដ៏ចម្រើន អ្នកកុំខ្លាចឡើយ ខ្ញុំនឹងនាំអ្នកទៅកាន់ទឹកដីមនុស្ស ហើយឲ្យអង្គុយលើខ្នងរបស់ខ្លួន នាំទៅរហូតដល់ទឹកដីមនុស្ស ។ គ្រានោះ ព្រានព្រៃនោះជាមនុស្សមានសន្តានទ្រុស្តមិត្រ ទើបគិតតាមផ្លូវថា ប្រសិនបើមានអ្នកណាសួរ ត្រូវប្រាប់បានដូច្នេះ អង្គុយលើខ្នងដំរីពោធិសត្វដាក់ផែនការសម្គាល់ដោយដើមឈើនិងភ្នំគ្រប់កន្លែង ។ លុះព្រះមហាសត្វនាំបុរសនោះចេញផុតព្រៃ ក៏ឈប់ត្រង់ផ្លូវធំដែលជាផ្លូវធ្វើដំណើរទៅកាន់នគរពារាណសី ហើយផ្ដាំថា នែបុរសដ៏ចម្រើន ចូរអ្នកទៅតាមផ្លូវនេះចុះ ប៉ុន្តែបើមានអ្នកណាសួរអំពីលំនៅរបស់ខ្ញុំ អ្នកកុំប្រាប់ឡើយ ដូច្នេះហើយ បញ្ជូនបុរសនោះទៅ ហើយត្រឡប់ទៅកាន់លំនៅរបស់ខ្លួនវិញ ។

គ្រានោះ បុរសនោះទៅដល់នគរពារាណសីហើយក៏ទៅកាន់កន្លែងជាងឆ្លាក់ភ្លុក ឃើញពួកជាងឆ្លាក់ភ្លុកកំពុងធ្វើគ្រឿងភ្លុកច្រើនប្រភេទ ក៏សួរថា នែអ្នកដ៏ចម្រើនទាំងឡាយ ប្រសិនបើបានភ្លុកដំរីនៅរស់ អ្នកទាំងឡាយទិញឬទេ ?

ពួកជាងឆ្លើយថា នែអ្នកដ៏ចម្រើន អ្នកនិយាយអ្វី ធម្មតាភ្លុកដំរីដែលនៅរស់ ថ្លៃជាងភ្លុកដំរីដែលស្លាប់ហើយច្រើនដង ។

បុរសនោះពោលថា បើដូច្នោះ ខ្ញុំនឹងនាំភ្លុកដំរីដែលនៅរស់មកឲ្យ

អ្នកទាំងឡាយ ហើយចាត់ចែងរៀបចំស្បៀងអាហារសម្រាប់ធ្វើដំណើរទៅកាន់លំនៅរបស់ស្តេចដំរីពោធិសត្វ ។ ព្រះបរមពោធិសត្វឃើញបុរសនោះមក ក៏សួរថា អ្នកមកដើម្បីប្រាថ្នាអ្វី ?

បុរសនោះឆ្លើយថា នៃស្តេចដំរី ខ្ញុំជាស្នូមយាចកកំព្រា មិនមានទីពឹង មិនអាចញុំាងជីវិតឲ្យប្រព្រឹត្តទៅបាន មកសុំកាត់ភ្លុករបស់អ្នក ប្រសិនបើអ្នកឲ្យ ខ្ញុំនឹងយកភ្លុកនោះទៅលក់ចិញ្ចឹមជីវិតដោយទ្រព្យនោះ ។

ព្រះបរមពោធិសត្វពោលថា ណ្ហើយចុះ អ្នកដ៏ចម្រើន ខ្ញុំនឹងឲ្យភ្លុកទៅអ្នក បើមានរណារសម្រាប់អារភ្លុក ។

បុរសនោះពោលថា ស្តេចដំរីដ៏ចម្រើន ខ្ញុំបានយករណារមកដែរ ។

ព្រះបរមពោធិសត្វពោលថា បើដូច្នោះ អ្នកចូរយករណារអារភ្លុកខ្ញុំចុះ ហើយលុតជង្គង់ចុះឲ្យទាប បុរសនោះក៏អារចុងភ្លុកទាំងគូរបស់ដំរីពោធិសត្វ ។ ព្រះបរមពោធិសត្វចាប់ភ្លុកទាំងគូនោះដោយប្រមោយហើយអធិដ្ឋានដើម្បីព្រះសព្វញ្ញុតញ្ញាណថា នៃអ្នកដ៏ចម្រើន ខ្ញុំមិនមែនឲ្យភ្លុកទាំងគូនេះដោយគិតថា ភ្លុកទាំងនេះមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់ខ្ញុំដូច្នេះទេ ប៉ុន្តែ **ព្រះសព្វញ្ញុតញ្ញាណ** ដែលអាចត្រាស់ដឹងធម៌ទាំងពួង ជាទីស្រឡាញ់របស់ខ្ញុំក្រៃលែងជាងភ្លុកទាំងនេះ រាប់រយដង ពាន់ដង សែនដង ការឲ្យភ្លុកជាទានរបស់ខ្ញុំនេះ ចូរប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងធម៌ទាំងពួងចុះ ហើយលះបង់ភ្លុកទាំងគូឲ្យ

ទៅបុរសនោះ ។

ព្រានព្រៃយកភ្លុកទៅលក់ លុះចាយអស់លុយក៏ទៅកាន់សម្នាក់ព្រះបរមពោធិសត្វទៀត រួចហើយពោលថា នៃស្តេចដំរី ទ្រព្យដែលបានព្រោះលក់ភ្លុករបស់អ្នកបានត្រឹមតែសងបំណុលគេប៉ុណ្ណោះ សូមអ្នកឲ្យភ្លុកចំណែកដែលសេសសល់ដល់ខ្ញុំទៀតចុះ ។ ព្រះមហាសត្វក៏យល់ព្រមហើយឲ្យព្រានព្រៃនោះកាត់ លើកភ្លុកចំណែកដ៏សេសឲ្យដោយន័យដូចមុនទៀត ។ ចំណែកព្រានព្រៃលក់ភ្លុកទាំងនោះហើយ ក៏មកកាន់សម្នាក់ព្រះបរមពោធិសត្វសូមភ្លុកទៀតថា នៃស្តេចដំរី ខ្ញុំមិនអាចញុំាងជីវិតឲ្យប្រព្រឹត្តទៅបានទេ សូមឲ្យគល់ភ្លុកដល់ខ្ញុំចុះ ។ ព្រះបរមពោធិសត្វយល់ព្រម ហើយក៏លុតជង្គង់ចុះដោយន័យដូចមុន ។ មនុស្សបិត្តបាបនោះ ក៏ជាន់ប្រមោយដែលប្រៀបដូចកម្រងប្រាក់របស់ព្រះមហាសត្វ ឈានឡើងកាន់សីសៈដែលប្រៀបបាននឹងកំពូលភ្នំកៃលាស យកកែងជើងច្រំភ្លុកទាំង-ពីរ ចាប់ហែកសាច់ដែលគ្របដណ្តប់ភ្លុក យករណារអារគល់ភ្លុកហើយក៏ចៀសចេញទៅ ។ កាលមនុស្សបិត្តបាបនោះ ដើរផុតអំពីគន្លងចក្ខុរបស់ព្រះបរមពោធិសត្វប៉ុណ្ណោះ ផែនដីដែលមានកម្រាស់ ២៤០.០០០ យោជន៍ សូម្បីអាចទ្រទ្រង់នូវរបស់ដ៏ធ្ងន់ មានភ្នំសិនេរុនិងភ្នំយុគន្ធរជាដើម និងអាចទ្រទ្រង់នូវវត្ថុដែលគួរខ្ពើមមានក្លិនស្អុយ គឺមូត្រនិងលាមកជាដើមបាន ក៏មិនអាចទប់ទល់នឹងគំនរនៃទោស ដែលមិនមែនជាគុណរបស់បុរសនោះ

បាន ទើបហែកឲ្យមានប្រយោជន៍ ភ្លាមនោះឯង អណ្តាតភ្លើងលៀនចេញអំពីមហានរកអវិចីរុំព័ទ្ធបុរសអ្នកទ្រុស្តមិត្តនោះ ដូចក្រសោបដោយសំពត់កម្ពលពណ៌ក្រហមដែលជារបស់ដែលត្រកូលឲ្យដូច្នោះ ។ ពេលដែលមនុស្សចិត្តបាបចូលទៅកាន់ចន្លោះផែនដីយ៉ាងនេះហើយ រុក្ខទេវតាដែលនៅក្នុងព្រៃនោះគិតឃើញថា សូម្បីឲ្យសម្បត្តិចក្រពត្តិ ក៏មិនអាចញុំាងបុរសអកតញ្ញូដែលជាអ្នកទ្រុស្តមិត្តនេះ ឲ្យឆ្អែតគ្រប់គ្រាន់បានឡើយ កាលសម្តែងធម៌ឲ្យកងរំពងទូទៅពេញព្រៃ ក៏បានពោលគាថានេះថា

**អកតញ្ញុស្ស បោសស្ស និច្ចំ វិវរទស្សិនោ**
**សព្វញ្ចេ បឋវឹ ទជ្ជា នេវ នំ អភិរាធយេតិ ។**

ប្រសិនបើគេឲ្យផែនដីទាំងមូលដល់បុរសអកតញ្ញូ ជាអ្នកឃើញទោសជានិច្ច ក៏មិនគប្បីញុំាងបុរសអកតញ្ញូនោះឲ្យត្រេកអរបានឡើយ ។

បណ្តាបទទាំងនោះ បទថា **អកតញ្ញុស្ស** សេចក្តីថា ដល់មនុស្សមិនដឹងគុណដែលអ្នកដទៃធ្វើមកលើខ្លួន ។

បទថា **បោសស្ស** ប្រែថា ដល់បុរស ។

បទថា **វិវរទស្សិនោ** សេចក្តីថា ជាអ្នកឃើញទោសជានិច្ច ។

បទថា **សព្វញ្ចេ បឋវឹ ទជ្ជា** សេចក្តីថា ប្រសិនបើឲ្យចក្រពត្រាធិរាជសម្បត្តិទាំងអស់ ឬន័យម្យ៉ាងទៀត ប្រសិនបើត្រឡប់ផែនដីដ៏ធំនេះ

យករសជាតផែនដីមកឲ្យបុរសដូច្នោះ ។

បទថា **នេវ នំ អភិរាធយេ** សេចក្ដីថា បុគ្គលណាមួយ សូម្បីធ្វើយ៉ាងនេះបាន ក៏មិនអាចញ៉ាំងបុរសអកតញ្ញូអ្នកទម្លាយគុណដែលលោកធ្វើហើយ ឲ្យត្រេកអរ ឬជ្រះថ្លាបានឡើយ ។ ទេវតានោះសម្ដែងធម៌លាន់រំពងពេញព្រៃ ដោយប្រការដូច្នេះ ។ ព្រះបរមពោធិសត្វតាំងនៅរហូតអស់អាយុក្ខ័យ ក្រោយអំពីចុតិក៏បានទៅតាមយថាកម្ម ។

ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុទេវទត្តជាបុគ្គលអកតញ្ញូនោះសូម្បីក្នុងកាលមុនក៏ជាបុគ្គលអកតញ្ញូដែរ ។ លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា បុរសអ្នកទ្រុស្ដមិត្តក្នុងកាលនោះ បានមកជាទេវទត្ត រុក្ខទេវតាបានមកជាសារីបុត្ត ចំណែកស្ដេចដំរីមានសីល គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា សីលវនាគជាតក ទី ២ ។

# អដ្ឋកថា សច្ចង្កិរជាតក ទី ៣

ព្រះបរមសាស្ដា កាលទ្រង់គង់នៅនាវត្តវេឡុវ័នមហាវិហារ ទ្រង់ប្រារព្ធការព្យាយាមផ្ដាច់ព្រះជន្មរបស់ទ្រង់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សច្ចំ កិរេវមាហំសុ** ដូច្នេះជាដើម ។

សេចក្ដីសង្ខេបថា កាលភិក្ខុទាំងឡាយប្រជុំសន្ទនាគ្នាក្នុងធម្មសភាអំពីទោសដែលមិនមែនជាគុណរបស់ភិក្ខុទេវទត្តថា អ្នកមានអាយុទាំង-ឡាយ ភិក្ខុទេវទត្តមិនមែនត្រឹមតែមិនដឹងគុណព្រះសម្មាសម្ពុទ្ធទេ ថែមទាំងព្យាយាមសម្លាប់ព្រះអង្គទៀតផង ។ ព្រះបរមសាស្ដា ស្ដេចយាងមកទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយកំពុងសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលទេវទត្តព្យាយាមសម្លាប់តថាគតនោះ មិនមែនទើបតែពេលនេះទេ សូម្បីកាលពីមុនក៏ព្យាយាមសម្លាប់តថាគតដែរ ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតកាលមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះឱរសរបស់ព្រះអង្គមានព្រះនាមថា ទុដ្ឋកុមារ មានសន្ដានកាចឃោរឃៅ ប្រៀបដូចអាសិរពិសដែលត្រូវគេវាយ មិនទាន់បានដេរ មិនទាន់បានវាយអ្នកណា មិនព្រមត្រាស់ជាមួយនឹងអ្នកណាឡើយ

ឱរសអង្គនេះមិនជាទីពេញចិត្ត គួរឲ្យស្អុតរន្ធត់ដល់មនុស្សខាងក្នុងនិងមនុស្សខាងក្រៅ ដូចធូលីខ្ចាតចូលភ្នែក និងដូចបិសាចដ៏កាចឃោរឃៅរង់ចាំទំពាស៊ីដូច្នោះ ។ ថ្ងៃមួយ ទ្រង់មានព្រះរាជបំណងនឹងលេងទឹកស្ទឹង ទ្រង់យាងទៅកាន់ស្ទឹងមួយអន្ទើដោយបរិវារជាច្រើន ពេលនោះមេឃក៏ងងឹតរកភ្លៀង ទិសទាំងឡាយក៏ងងឹតសូន្យ ។ ទុដ្ឋកុមារប្រាប់បម្រើថា នែវ៉ឺយ មកនាំយើងទៅកណ្តាលស្ទឹង ឲ្យយើងស្រង់ទឹកហើយចាំនាំយើងត្រឡប់ទៅវិញ អ្នកបម្រើទាំងឡាយក៏នាំទុដ្ឋកុមារទៅកណ្តាលស្ទឹងហើយប្រឹក្សាគ្នាថា ព្រះរាជានឹងធ្វើអ្វីពួកយើង ពួកយើងចូរលែងមនុស្សចិត្តអាក្រក់នេះ ឲ្យស្លាប់ក្នុងស្ទឹងនេះចុះ ដូច្នេះហើយពោលថា មនុស្សចិត្តអាក្រក់ទៅតាមការពេញចិត្តចុះ នាំគ្នាសង្កត់ឲ្យលិចចុះក្នុងទឹក ហើយនាំគ្នាហែលត្រឡប់ឡើងទៅឈរនៅលើច្រាំងស្ទឹង ។ កាលមានអ្នកសួរថា ព្រះរាជកុមារយាងទៅណា? ក៏នាំគ្នាឆ្លើយថា ពួកយើងមិនឃើញទ្រង់ទេ ប្រហែលទ្រង់ឃើញមេឃងងឹតរកភ្លៀងក៏មុជចុះក្នុងទឹក ហើយងើបឡើងយាងទៅកាន់ព្រះរាជវាំងមុនហើយមើលទៅ ។ ពួកអាមាត្យក៏ទៅកាន់ព្រះរាជដំណាក់ ។ ព្រះរាជាត្រាស់សួរថា ឱរសរបស់យើងទៅណា?

ពួកអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកទូលបង្គំមិនដឹងទេ កាលមេឃងងឹតរកភ្លៀង ពួកទូលបង្គំសម្គាល់ថា ព្រះរាជកុមារទ្រង់យាងមកមុនហើយ ទើបពួកទូលបង្គំមកតាមក្រោយ ។

ព្រះរាជាត្រាស់ឲ្យបើកទ្វារនគរ ស្តេចយាងទៅកាន់ឆ្នេរស្ទឹងហើយត្រាស់ថា អ្នកទាំងឡាយ ចូរនាំគ្នាស្វែងរក ហើយឲ្យស្វែងរកក្នុងទីទាំងឡាយ មិនមានអ្នកណាឃើញព្រះរាជកុមារឡើយ ។ ចំណែកព្រះរាជកុមារនោះ នៅពេលដែលមេឃងងឹតស្លុបហើយធ្លាក់ភ្លៀងទៀត អណ្តែតនៅក្នុងស្ទឹង ឃើញកំណាត់ឈើមួយកំណាត់ ទើបតោងកំណាត់ឈើនោះ ត្រូវមរណភ័យគំរាមក៏ទួញយំនៅក្នុងស្ទឹងនោះ ។

ក្នុងកាលនោះ មានសេដ្ឋីអ្នកនគរពារាណសីម្នាក់ កប់ទ្រព្យ ៤០ កោដិនៅក្បែរឆ្នេរស្ទឹង ព្រោះការជាប់ជំពាក់នឹងទ្រព្យ ស្លាប់ទៅកើតជាពស់ នៅលើកំណប់ទ្រព្យនោះ ។ នៅមានសេដ្ឋីម្នាក់ទៀតកប់ទ្រព្យ ៣០ កោដិ ត្រង់ទីនោះដែរ ព្រោះការជាប់ជំពាក់នឹងទ្រព្យ ស្លាប់ទៅកើតជាកណ្តុរនៅទីនោះដែរ ។ ទឹកជ្រោះហូរចូលទៅដល់ទីនៅនៃពស់និងកណ្តុរទាំងពីរនោះ សត្វទាំងពីរនោះក៏ចេញមកតាមផ្លូវដែលទឹកជ្រោះហូរចូលទៅនោះឯង ហែលកាត់ខ្សែទឹកទៅដល់កំណាត់ឈើដែលព្រះរាជកុមារតោងនោះ សត្វនីមួយៗឡើងកាន់ចុងកំណាត់ឈើម្ខាងមួយ ដេកនៅលើកំណាត់ឈើនោះឯង ។ នៅក្បែរឆ្នេរស្ទឹងនោះ មានដើមរកាមួយដើម មានសត្វសេកមួយនៅនឹងដើមរកានោះ សូម្បីដើមរកានោះក៏ត្រូវទឹកជ្រោះអូសដួលរលំទៅក្នុងស្ទឹងដែរ កាលភ្លៀងកំពុងធ្លាក់សត្វសេកមិនអាចហើរទៅបានក៏អណ្តែតទៅទំលើចុងម្ខាងនៃកំណាត់ឈើនោះ ។ ដោយប្រការដូចពោលមកនេះ

ទើបរួមគ្នាបាន ៤ នាក់ អណ្តែតនៅក្នុងស្ទឹងនោះ ។

ក្នុងកាលនោះ ព្រះមហាសត្វបដិសន្ធិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍នៅក្នុងដែនកាសី ចម្រើនវ័យហើយ បួសជាឥសី សាងសាលានៅលើឆ្នេរស្ទឹងមួយ ។ ឥសីនោះកំពុងចង្ក្រមនៅក្នុងវេលាអធ្រាត្រ បានឮសំឡេងយំដ៏លាន់ឮកងរំពងរបស់ព្រះរាជកុមារ ក៏ត្រិះរិះថា កាលតាបសអ្នកសម្បូរដោយមេត្តា ករុណានៅមាន នឹងបណ្តោយឲ្យបុរសនេះស្លាប់មិនសមគួរឡើយ អញនឹងជួយបុរសនេះឲ្យផុតអំពីទឹក ឲ្យរួចអំពីការអស់ជីវិត ហើយក៏លួងលោមព្រះរាជកុមារថា កុំខ្លាចឡើយ ហែលកាត់ខ្សែទឹកទៅតោងចុងកំណាត់ឈើម្ខាងទាញមក តាបសនោះមានកម្លាំងដូចដំរីសារ សម្បូរដោយកម្លាំង សម្រាកតែម្តងក៏ដល់ត្រើយ បីព្រះរាជកុមារឡើងដាក់លើឆ្នេរស្ទឹង លុះឃើញសត្វទាំងឡាយមានពស់ជាដើម ក៏ជួយនាំឡើងទៅកាន់អាស្រមបទ បង្កាត់ភ្លើងហើយគិតថា សត្វទាំងនេះមានកម្លាំងខ្សោយជាង ក៏ឲ្យពស់ជាដើមអាំងភ្លើងមុន ឲ្យព្រះរាជកុមារអាំងភ្លើងជាខាងក្រោយ ធ្វើឲ្យបាត់រងា សូម្បីពេលឲ្យអាហារក៏ឲ្យពស់ជាដើមមុនដែរ ហើយយកផ្លែឈើទៅថ្វាយព្រះរាជកុមារជាក្រោយ ។ ព្រះរាជកុមារទ្រង់ព្រះតម្រិះថា តាបសកោងនេះ មិនបានរាប់អានអញជាព្រះរាជកុមារ ត្រឡប់ជាលើកតម្កើងពួកសត្វតិរច្ឆានទៅវិញ ទើបចងអាឃាតចំពោះតាបសពោធិសត្វ ។ ក្រោយមកពីរ-បីថ្ងៃ កាលព្រះរាជកុមារនិងសត្វទាំងនោះមានកម្លាំងជា

ប្រក្រតីហើយ ខ្សែទឹកក្នុងស្ទឹងក៏ស្រក ពស់ថ្វាយបង្គំលាតាបសហើយ ពោលថា បពិត្រតាបសដ៏ចម្រើន លោកបានធ្វើឧបការគុណយ៉ាងធំចំពោះ ខ្ញុំ ខ្ញុំមិនមែនជាអ្នកខ្វះខាត កប់ទ្រព្យទុក ៤០ កោដិក្នុងទីឯណោះ កាល លោកត្រូវការប្រើប្រាស់ទ្រព្យ ខ្ញុំអាចជូនទ្រព្យទាំងអស់នោះដល់លោក បាន សូមលោកទៅទីនោះហើយហៅខ្ញុំថា ទីឃៈ ចុះ ហើយក៏លាតាបស ទៅ ។ ចំណែកកណ្ដុរក៏បវារណាតាបសទុកយ៉ាងនោះដែរ ពោលថា កាលលោកត្រូវការប្រើប្រាស់ សូមទៅឈរក្នុងទីឯណោះហៅខ្ញុំថា ឧន្ទុរៈ ចុះ ដូច្នេះហើយក៏លាទៅ ។ ចំណែកសេកថ្វាយបង្គំតាបសហើយពោល ថា បពិត្រតាបសដ៏ចម្រើន ខ្ញុំមិនមានទ្រព្យទេ ប៉ុន្តែកាលលោកត្រូវការអង្ករ ស្រូវសាលីពណ៌ក្រហម សូមលោកទៅកាន់លំនៅរបស់ខ្ញុំក្នុងទីឯណោះ ហៅខ្ញុំថា សុវៈ ខ្ញុំអាចប្រាប់ពួកញាតិឲ្យជួយជញ្ជូនអង្ករស្រូវសាលីពណ៌ ក្រហមមកជូនលោកច្រើនរទេះ ហើយក៏លាតាបសទៅ ។ ចំណែកព្រះ-រាជកុមារព្រោះចងចិត្តទុកក្នុងធម៌របស់អ្នកទ្រុស្តមិត្តគិតបានថា កាលដែល អញមិននិយាយពាក្យអ្វីៗខ្លះហើយនៅស្ងៀម មិនសមគួរឡើយ អញនឹង សម្លាប់តាបសនេះ នៅពេលដែលតាបសនេះទៅរកអញ ទើបពោលថា បពិត្រតាបសដ៏ចម្រើន កាលខ្ញុំតាំងនៅក្នុងរាជសម្បត្តិ សូមលោកនិមន្តទៅ កាន់សម្នាក់របស់ខ្ញុំ ខ្ញុំនឹងបម្រើលោកដោយបច្ច័យ ៤ ហើយក៏លាទៅ ព្រះរាជកុមារនោះយាងទៅមិនយូរប៉ុន្មាន ក៏បានសោយរាជសម្បត្តិ ។

ព្រះបរមពោធិសត្វត្រិះរិះថា អញនឹងសាកល្បងអ្នកទាំងអស់នោះដូច្នេះហើយ ទើបទៅកាន់សម្នាក់ពស់មុន ឈរនៅក្នុងទីមិនឆ្ងាយហៅថា ទីឃៈ ត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ ពស់ក៏លូនចេញមកថ្វាយបង្គំតាបសពោធិសត្វ ហើយពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ត្រង់នេះមានទ្រព្យ ៤០ កោដិ សូមលោកជីកយកទៅឲ្យអស់ចុះ ។

ព្រះបរមពោធិសត្វពោលថា ប្រពៃហើយ កាលមានកិច្ចកើតឡើងសឹមនឹងគាស់យកវា ប្រាប់ឲ្យពស់ត្រឡប់ទៅវិញហើយ ហួសទៅកាន់សម្នាក់កណ្ដុរបន្លឺសំឡេងហៅ សូម្បីកណ្ដុរក៏ធ្វើដូចពស់ដែរ ។ ព្រះបរមពោធិសត្វក៏ប្រាប់ឲ្យកណ្ដុរត្រឡប់ទៅវិញ ។ ហើយហួសទៅកាន់សម្នាក់សេកហៅថា សុវៈ ត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ សេកក៏ហើរចេញអំពីចុងឈើមកថ្វាយបង្គំតាបសពោធិសត្វហើយសួរថា បពិត្រតាបសដ៏ចម្រើន ខ្ញុំនឹងត្រូវទៅរកពួកញាតិរបស់ខ្ញុំ ឲ្យជួយជញ្ជូនស្រូវសាលីដែលកើតឯងអំពីហិមវន្តប្រទេស មកជូនលោកឬ?

ព្រះបរមពោធិសត្វពោលថា ចាំដល់ពេលយើងត្រូវការ យើងនឹងមករកឯង ប្រាប់ឲ្យសេកត្រឡប់ទៅវិញ ហើយគិតថា ពេលនេះអញនឹងសាកល្បងព្រះរាជាទើបទៅសម្រាកនៅក្នុងព្រះរាជឧទ្យាន ព្រឹកឡើងក៏សង្រួមមារយាទរៀបរយល្អហើយ ចូលទៅកាន់នគរដោយភិក្ខាចារវត្ត ។ គ្រានោះ ព្រះរាជាអ្នកទ្រុស្តមិត្តអង្គនោះ គង់លើ-កដំរីដ៏ប្រសើរដែលតាក់-

តែងហើយ ទ្រង់ប្រទក្សិណនគរដោយរាជបរិវារដ៏ច្រើន ទតឃើញតាបសអំពីចម្ងាយ ក៏ទ្រង់ព្រះតម្រិះថា តាបសនេះ គឺតាបសកោងនោះ ប្រហែលជាចង់នៅក្នុងសម្នាក់អញហើយមើលទៅ ទើបបានមកទីនេះ អញត្រូវតែឲ្យរាជបុរសកាត់ក្បាលតាបសនេះ កុំឲ្យតាបសនេះប្រកាសគុណដែលធ្វើមកលើអញកណ្តាលហ្វូងមនុស្សបាន ហើយទ្រង់សម្លឹងមើលរាជបុរស កាលរាជបុរសក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព ទូលបង្គំទាំងឡាយត្រូវធ្វើអ្វី? ទើបបញ្ជាថា តាបសកំហូចនោះ ប្រហែលប្រាថ្នាសុំអ្វីពីយើងហើយមើលទៅ អ្នកទាំងឡាយមិនត្រូវឲ្យតាបសកំហូចនោះឃើញយើងឡើយ ចាប់វាចងស្ទាបសេក វាយបណ្តើរ ទៅគ្រប់ផ្លូវបែកជា ៤ នាំចេញអំពីនគរ កាត់ក្បាលវាត្រង់ទីពិឃាត ហើយយកលំពែងចាក់ខ្លួនវា ។ រាជបុរសទាំងនោះទទួលព្រះរាជឱង្ការហើយ នាំគ្នាចងព្រះបរមពោធិសត្វអ្នកប្រាសចាកកំហុស វាយបណ្តើរទៅគ្រប់ផ្លូវបែកជា ៤ ហើយត្រៀមនឹងនាំទៅកាន់ទីពិឃាត ។ ព្រះបរមពោធិសត្វមិនបានកន្ទក់កន្ទេញថា ពុកម៉ែទាំងឡាយនៅពេលដែលត្រូវគេវាយគ្រប់កន្លែង ប្រាសចាកការភ័យញាប់ញ័រពោលគាថានេះថា

**សច្ចំ កិរេវមាហំសុ នរា ឯកច្ចិយា ឥធ**
**កដ្ឋំ និប្លវិតំ សេយ្យោ នត្វេវេកច្ចិយោ នរោតិ ។**

បានឮថា នរៈពួកខ្លះ ក្នុងលោកនេះ បាននិយាយពិតយ៉ាង

នេះថា ឧសដែលគេស្រង់ឡើងអំពីទឹក ប្រសើរជាង នរៈពួកខ្លះដែលគេស្រង់ឡើង (អំពីទឹក) មិនប្រសើរឡើយ ។

បណ្ដាបទទាំងនោះ បទថា **សច្ចំ កិរេវមាហំសុ** សេចក្ដីថា បានឮថា បណ្ឌិតទាំងឡាយពោលទុកយ៉ាងនេះមិនខុសឡើយ ។

បទថា **នរា ឯកច្ចិយា ឥធ** សេចក្ដីថា បុរសដែលជាបណ្ឌិតពួកខ្លះក្នុងលោកនេះ ។

បទថា **កដ្ឋំ និប្លវិតំ សេយ្យោ** សេចក្ដីថា បានឮថា បុរសដែលជាបណ្ឌិតទាំងនោះពោលថា ឈើស្ងួតដែលជាឈើស្រាលៗ អណ្ដែតក្នុងទឹក លើកឡើងដាក់លើគោកនោះ ប្រសើរជាង សេចក្ដីនោះជាការពិត ។

សួរថា ព្រោះហេតុអ្វី?

ឆ្លើយថា ព្រោះថា ឈើនោះនៅមានប្រយោជន៍ដល់សេចក្ដីត្រូវការអាចដុតដាំបាយដាំទឹកជាដើម នៅមានឧបការៈដល់សេចក្ដីត្រូវការ ក្នុងការអាំងភ្លើងរបស់ពួកជនអ្នកត្រូវភាពរងាគ្របសង្កត់ ជាឧបការៈដល់សេចក្ដីត្រូវការ ក្នុងការកម្ចាត់អន្តរាយដទៃៗ ក៏បាន ។

បទថា **នត្វេវេកច្ចិយោ នរោ** សេចក្ដីថា ចំណែកបុគ្គលខ្លះគឺបុគ្គលទ្រុស្តមិត្ត បុគ្គលអកតញ្ញូ បុគ្គលចិត្តបាប ត្រូវខ្សែទឹកបន្សាត់យកទៅ ជួយទាញដៃឲ្យឡើងពីស្ទឹងបាន មិនប្រសើរឡើយ ជាការពិតណាស់ យើងបានជួយមនុស្សចិត្តបាបនេះ ឲ្យរួចផុតអំពីសេចក្ដីស្លាប់ ត្រឡប់ជា

នាំទុក្ខមកឲ្យយើងវិញ ។

ព្រះបរមពោធិសត្វពោលគាថានេះ ក្នុងទីដែលគេវាយគ្រប់កន្លែង ដោយប្រការដូច្នេះ ពួកជនម្នាក់ៗបានឮពាក្យជាគាថានោះ ពួកជនដែលជាបណ្ឌិតក្នុងពួកមនុស្សទាំងនោះ នាំគ្នាពោលថា បពិត្រអ្នកដ៏ចម្រើន អ្នកបានធ្វើគុណអ្វីដល់ព្រះរាជារបស់ពួកយើងឬ ? ព្រះបរមពោធិសត្វក៏តំណាលរឿងនោះហើយពោលថា ខ្ញុំនេះឯងជាអ្នកជួយព្រះរាជាអង្គនេះឲ្យឡើងអំពីជំនន់ទឹកដ៏ធំ ត្រឡប់ជានាំទុក្ខមកឲ្យខ្ញុំវិញ ខ្ញុំរលឹកបានថា ខ្ញុំមិនបានធ្វើតាមពាក្យរបស់បណ្ឌិតអំពីកាលមុន ទើបពោលយ៉ាងនេះ ។ អ្នកនគរមានក្សត្រនិងព្រាហ្មណ៍ជាដើមស្តាប់ពាក្យនោះហើយ នាំគ្នាពោលថា ព្រោះអាស្រ័យព្រះរាជាអ្នកទ្រុស្តមិត្ត មិនបានដឹងសូម្បីត្រឹមតែគុណរបស់អ្នកដល់ព្រមដោយគុណ អ្នកឲ្យជីវិតដល់ខ្លួនយ៉ាងនេះ ព្រះរាជាអង្គនេះនឹងញុំាំងពួកយើងឲ្យមានសេចក្តីចម្រើនអំពីទីណា ចាប់វាចុះ ដូច្នេះហើយម្នាក់ៗក្រោធខឹង ស្ទុះចូលទៅជុំវិញព្រះរាជា ហើយសម្លាប់ព្រះរាជានោះទាំងដែលព្រះរាជាអង្គនោះគង់នៅលើដំរីទ្រនំឯង ដោយគ្រឿងប្រហារ មានព្រួញ លំពែង ដុំថ្ម និងកំណាត់ឈើជាដើម រួចចាប់ជើងទាញចុះមកអូសយកទៅចោលនៅលើខ្នងប្រឡាយ ហើយអភិសេកព្រះបរមពោធិសត្វឲ្យឡើងគ្រងរាជ្យជំនួសវិញ ។

ចំណែកព្រះបរមពោធិសត្វទ្រង់គ្រងរាជ្យដោយធម៌ ។ ថ្ងៃមួយ ទ្រង់

ប្រាថ្នានឹងសាកល្បងសត្វមានពស់ជាដើម ទើបស្ដេចយាងទៅកាន់លំនៅរបស់សត្វពស់ហើយត្រាស់ហៅថា ទីឃៈ ពស់លូនមកថ្វាយបង្គំហើយពោលថា បពិត្រលោកម្ចាស់ សូមលោកគាស់យកទ្រព្យរបស់លោកទៅចុះ ។ ព្រះរាជាបញ្ជាឲ្យអាមាត្យមកទទួលយកទ្រព្យ ៤០ កោដិ ហើយយាងទៅកាន់សម្នាក់កណ្ដុរ ត្រាស់ហៅថា ឧន្ទុរៈ កណ្ដុរក៏មកថ្វាយបង្គំថ្វាយសម្បត្តិ ៣០ កោដិ ព្រះរាជាបញ្ជាឲ្យអាមាត្យទទួលយកទ្រព្យនោះទុក ហើយយាងទៅកាន់លំនៅរបស់សេក ត្រាស់ហៅថា សុវៈ ។ សេកក៏ហើរចេញមកថ្វាយបង្គំបាទមូលហើយក្រាបទូលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងទៅនាំយកស្រូវសាលីមកជូន ។ ព្រះរាជាត្រាស់ថា ពេលណាយើងត្រូវការស្រូវសាលី យើងនឹងប្រាប់អ្នក តោះទៅ យើងនាំគ្នាទៅ ហើយទ្រង់នាំសត្វទាំង ៣ និងទ្រព្យ ៧០ កោដិទៅកាន់នគរ ទ្រង់បញ្ជាឲ្យធ្វើនាឡិមាស ព្រះរាជទានឲ្យពស់ដើម្បីធ្វើជាលំនៅ បញ្ជាឲ្យធ្វើល្អាងកែវផលិកសម្រាប់ជាទីនៅនៃកណ្ដុរ បញ្ជាឲ្យធ្វើទ្រុងមាសសម្រាប់ជាទីនៅនៃសត្វសេក ព្រះរាជទានលាជលាយដោយទឹកឃ្មុំដាក់ចានមាសឲ្យពស់និងសេកស៊ី ព្រះរាជទានអង្ករស្រូវសាលីឲ្យកណ្ដុរស៊ីរាល់ថ្ងៃ ទ្រង់ធ្វើបុណ្យមានឲ្យទានជាដើម បុគ្គលទាំង ៤ នោះសាមគ្គីគ្នា រីករាយរកគ្នា ដរាបអស់ជីវិត ក្រោយអំពីអស់ជីវិត ក៏ទៅតាមយថាកម្មរៀងៗ ខ្លួន ។

ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែ

ពេលនេះប៉ុណ្ណោះទេ ដែលទេវទត្តព្យាយាមសម្លាប់តថាគតនោះ សូម្បីកាលពីមុនក៏ព្យាយាមសម្លាប់តថាគតដែរ ដូច្នេះ ។ កាលទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ព្រះរាជាអ្នកទ្រុស្តមិត្តក្នុងកាលនោះ បានមកជាទេវទត្ត ពស់បានមកជាសារីបុត្ត កណ្តុរបានមកជាមោគ្គល្លាន សេកបានមកជាអានន្ទ ធម្មរាជា គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា សច្ចង្កិរជាតក ទី ៣ ។

# អដ្ឋកថា រុក្ខធម្មជាតក ទី ៤

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមហាវិនាស ដែលកំពុងកើតមានដល់ព្រះញាតិទាំងឡាយរបស់ព្រះអង្គ ព្រោះឈ្លោះដណ្តើមទឹកធ្វើស្រែ ស្តេចហោះទៅតាមអាកាស ទ្រង់គង់នៅខាងលើស្ទឹងរោហិណី ទ្រង់ផ្សាយព្រះរស្មីពណ៌ខៀវ ឲ្យព្រះញាតិទាំង-ឡាយសង្វេគហើយ ស្តេចចុះចាកអាកាសគង់នៅលើច្នេរស្ទឹង ទ្រង់ប្រារព្ធការឈ្លោះទាស់ទែងគ្នានោះ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សាធុ សម្ពហុលា ញាតី** ដូច្នេះជាដើម ។

ក្នុងព្រះជាតកដែលលើកយកមកនេះជាសេចក្តីសង្ខេប ចំណែកសេចក្តីពិស្តារ នឹងប្រាកដច្បាស់នៅក្នុង **កុណាលជាតក** ។ ក្នុងគ្រា-

នោះ ព្រះបរមសាស្តាទ្រង់ត្រាស់ហៅព្រះញាតិទាំងឡាយមកហើយ ទ្រង់ត្រាស់ថា មហាបពិត្រទាំងឡាយ អ្នកទាំងឡាយមានឈ្មោះថាជាញាតិនឹងគ្នា គួរតែសាមគ្គីគ្នា រួមចិត្តរួមថ្លើមគ្នា ដ្បិតថា កាលព្រះញាតិទាំង-ឡាយសាមគ្គីគ្នា ពួកបច្ចាមិត្តរមែងមិនបានឱកាស កុំថាតែពួកមនុស្សសូម្បីដើមឈើទាំងឡាយដែលមិនមានចិត្តវិញ្ញាណ នៅតែគួរសាមគ្គីគ្នា ដ្បិតក្នុងអតីតកាល នៅក្នុងព្រៃហិមពាន្ត មហាវាតភ័យបានគំរាមកំហែងព្រៃរាំង ព្រោះតែដើមទាំងឡាយនោះប្រទាក់គ្នាយ៉ាងណែនទៅដោយដើមគុម្ពឈើ និងវល្លិ ទើបមិនអាចធ្វើឲ្យដើមរាំងទាំងនោះដួលរលំបាន បក់បោកទៅតាមចុងដើមរាំងប៉ុណ្ណោះ ប៉ុន្តែបក់យកដើមឈើមួយដើមធំដែលដុះនៅលើទីទួល សូម្បីសម្បូរទៅដោយមែកប្រគាប ឲ្យដួលចុះលើផែនដីដកឫសដកគល់ឡើង ព្រោះមិនប្រទាក់គ្នានឹងដើមឈើដទៃៗ ដោយហេតុនេះ ទើបគួរអ្នកទាំងឡាយសាមគ្គីគ្នា រួមចិត្តរួមថ្លើមជាមួយគ្នា ។ កាលដែលព្រះញាតិទាំងនោះអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី វេស្សវ័ណមហារាជដែលទ្រង់ឧប្បត្តិឡើងដំបូងនោះ ក៏ចុតិ សក្កទេវរាជទ្រង់តែងតាំងស្តេចវេស្សវ័ណអង្គថ្មី ។ ក្នុងពេលផ្លាស់ប្តូរស្តេចវេស្សវ័ណនេះ ស្តេចវេស្សវ័ណអង្គក្រោយបញ្ជូនដំណឹងទៅប្រាប់

ទេវតាថា ចូរចាប់ដើមឈើ គុម្ពឫស្សី គុម្ពឈើ និងវល្លិដែលជាវិមានក្នុង លំនៅឋានដ៏ជាទីពេញចិត្តរៀងៗខ្លួនចុះ ។ គ្រានោះ ព្រះបរមពោធិសត្វ សោយព្រះជាតិជារុក្ខទេវតានៅក្នុងព្រៃរាំងមួយ ក្នុងហិមវន្តប្រទេស ទ្រង់ ប្រកាសប្រាប់ទេវតាដែលជាពួកញាតិថា កាលអ្នកទាំងឡាយចាប់វិមានកុំ ចាប់ដើមឈើដែលនៅលើទីទួល ប៉ុន្តែចូរចាប់ដើមឈើដែលជាវិមាន ដែលតាំងនៅជុំវិញវិមាន ដែលយើងចាប់ហើយក្នុងព្រៃរាំងនេះចុះ ។ បណ្តាទេវតាទាំងនោះ ពួកទេវតាណាដែលជាបណ្ឌិត ក៏ធ្វើតាមការប្រាប់ របស់ព្រះបរមពោធិសត្វ ចាប់ដើមឈើដែលជាវិមាន ដែលនៅជុំវិញវិមាន របស់ព្រះបរមពោធិសត្វ ចំណែកពួកទេវតាដែលមិនមែនជាបណ្ឌិតនាំគ្នា និយាយថា ពួកយើងត្រូវការអ្វីដោយវិមានក្នុងព្រៃនោះ ចូរនាំគ្នាចាប់ វិមានដែលនៅក្បែរខ្លោងទ្វារស្រុក និគម និងរាជធានីក្នុងឋានមនុស្សចុះ ដ្បិតថា ពួកទេវតាដែលនៅក្នុងស្រុកជាដើមនោះ តែងតែជួបប្រសព្វនូវ លាភដ៏ប្រសើរនិងយសដ៏ប្រសើរ ហើយនាំគ្នាចាប់យកវិមានដើមឈើធំៗ ដែលដុះនៅលើទីទួលក្នុងឋានមនុស្ស ។ ថ្ងៃមួយ មានខ្យល់និងភ្លៀងដ៏ធំ សូម្បីដើមឈើធំៗ ក្នុងព្រៃដែលមានឫសយ៉ាងមាំមានមែកធំៗ ក៏ត្រូវខ្យល់ កាច់បាក់ដួលរលំទាំងឫសទាំងគល់ ។ ប៉ុន្តែព្រៃរាំងដែលដុះនៅជិតជាប់ គ្នា សូម្បីខ្យល់បក់បោកយ៉ាងណាក៏ដោយ ក៏មិនអាចធ្វើឲ្យដើមដួលរលំ សូម្បីតែមួយដើម ។ ពួកទេវតាដែលមានវិមានដួលរលំ មិនមានទីនៅ នាំ

គ្នាដឹកដៃកូនៗ ទៅកាន់ព្រៃហេមពាន្ត ប្រាប់រឿងរ៉ាវរបស់ខ្លួនដល់ទេវតាដែលនៅក្នុងព្រៃរាំង ទេវតាទាំងនោះក៏នាំគ្នាប្រាប់រឿងដែលពួកទេវតាទាំងនោះមិនមានទីពឹងដល់ព្រះបរមពោធិសត្វ ។ ព្រះបរមពោធិសត្វពោលថា ធម្មតាអ្នកដែលមិនជឿពាក្យរបស់ពួកបណ្ឌិតហើយ នាំគ្នាទៅកាន់កន្លែងដែលមិនមានបច្ច័យអាចឲ្យវិមានតាំងនៅបាន រមែងជាយ៉ាងនេះឯង កាលនឹងសម្តែងធម៌ទើបពោលគាថានេះថា

**សាធុ សម្ពហុលា ញាតី អបិ រុក្ខា អរញ្ញជា**
**វាតោ វហតិ ឯកដ្ឋំ ព្រហន្តម្បិ វនប្បតិន្តិ ។**

មានពួកញាតិច្រើននាក់ ប្រពៃ សូម្បីពួកឈើ ដែលដុះក្នុងព្រៃច្រើនដើម ក៏ប្រពៃដែរ ឯខ្យល់រមែងរំលំ នូវឈើជាធំក្នុងព្រៃ បរិបូណ៌ដោយមែកនិងប្រគាប ដែលតាំងនៅតែឯង ។

បណ្តាបទទាំងនោះ បទថា **សម្ពហុលា** សេចក្តីថា ញាតិ ៤ នាក់ឈ្មោះថា ច្រើន សូម្បីក្រៃលែងជាងនោះ រហូតរាប់រយរាប់ពាន់ ឈ្មោះថា ច្រើនក្រៃលែង កាលពួកញាតិច្រើនសន្និកសន្ធាប់យ៉ាងនេះ អាស្រ័យគ្នាទៅវិញទៅមក ក៏ប្រពៃណាស់ គឺល្អណាស់ ប្រសើរបំផុត សត្រូវនឹងកម្ចាត់មិនបាន ។

បទថា **អបិ រុក្ខា អរញ្ញជា** សេចក្តីថា កុំថាតែពួកជនដែលរួមគ្នាជាពួកមនុស្សឡើយ សូម្បីដើមឈើដែលដុះក្នុងព្រៃច្រើនដើមតាំងនៅ

ដោយការពឹងពាក់គ្នា ទប់ទល់គ្នាទៅវិញទៅមក ក៏ជាការប្រពៃពិត ព្រោះសូម្បីដើមឈើទាំងឡាយ ក៏គួរបានការជួយគ្នាទៅវិញទៅមក ។

បទថា **វាតោ វហតិ ឯកដ្ឋំ** សេចក្តីថា ខ្យល់ មានខ្យល់ដែលបក់មកអំពីទិសខាងកើតជាដើម បក់ដើមឈើដែលខ្ពស់ត្រដែតដែលតាំងនៅលើទីទួលតែឯង ឲ្យដួលរលំទាំងឫសទាំងគល់ ។

បទថា **ព្រហន្តម្បិ វនប្បតឹ** សេចក្តីថា ខ្យល់រមែងបក់ដើមឈើធំដែលតាំងនៅតែឯង សូម្បីបរិបូរដោយមែកនិងប្រគាប ឲ្យបាក់រលំ រំលើង-ឫសរំលើងគល់ទៅបាន ។

ព្រះមហាសត្វពោលហេតុនេះ កាលអស់អាយុក៏ទៅតាមយថាកម្ម ។ ព្រះបរមសាស្តាទ្រង់ត្រាស់ថា មហាបពិត្រទាំងឡាយ ពួកញាតិត្រូវតែសាមគ្គីគ្នា ព្រោះហេតុនោះ ចូរមហាបពិត្រទាំងឡាយសាមគ្គីគ្នា ការពារគ្នា រស់នៅដោយចេះស្រឡាញ់គ្នា ។

ព្រះបរមសាស្តា លុះទ្រង់នាំយកព្រះធម្មទេសនាមកហើយ ទ្រង់ប្រជុំជាតកថា ពួកទេវតាក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកទេវតាដែលជាបណ្ឌិត គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា រុក្ខធម្មជាតក ទី ៤ ។

# អដ្ឋកថា មច្ឆជាតក ទី ៥

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភ្លៀង ដែលទ្រង់បណ្តាលឲ្យធ្លាក់មក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **អភិត្ថនយ បជ្ជុន្ន** *ដូច្នេះជាដើម។*

*បានឮថា សម័យមួយ ក្នុងដែនកោសលមិនមានភ្លៀងសោះ សន្ទូងទាំងឡាយហួតហែង អណ្តូងទឹក ស្រះបោក្ខរណី និងស្រះក្នុងទីនោះៗ ក៏រីងស្ងួត សូម្បីស្រះបោក្ខរណីជេតពនដែលនៅជិតខ្លោងទ្វារវត្តជេតពនក៏ដាច់ទឹកដែរ ។ ហ្វូងក្អែកនិងហ្វូងបក្សីជាដើម នាំគ្នាចោមរោមយកចំពុះចឹកត្រីនិងអណ្តើកដែលកប់ចូលទៅក្នុងភក់ ចេញមកស៊ីទាំងដែលកំពុងរើបម្រះ ។ ព្រះបរមសាស្តា ទ្រង់ទតឃើញសេចក្តីវិនាសរបស់ត្រីនិងអណ្តើក ត្រូវព្រះមហាករុណាដាស់តឿនព្រះទ័យឲ្យទ្រង់មានឧស្សាហៈ ទើបទ្រង់ព្រះតម្រិះថា ថ្ងៃនេះតថាគតគួរបណ្តាលភ្លៀងឲ្យធ្លាក់ចុះមក ។ លុះរាត្រីកន្លងទៅ (ភ្លឺ ) ទ្រង់បដិបត្តិសរីរៈស្រេចហើយ ទ្រង់កំណត់វេលាភិក្ខាចារ មានភិក្ខុសង្ឃមួយពួកធំហែហម ស្តេចចូលទៅបិណ្ឌបាតក្នុងនគរសាវត្ថីដោយព្រះពុទ្ធលីលា ក្រោយកត្តទ្រង់ត្រឡប់មកអំពីបិណ្ឌបាតហើយ កាលទ្រង់ត្រឡប់មកអំពីនគរសាវត្ថីចូលកាន់ព្រះវិហារ ទ្រង់ប្រថាប់ឈរក្បែរជណ្តើរស្រះបោក្ខរណីជេតពន ត្រាស់ហៅព្រះអានន្ទថា ម្នាលអានន្ទ អ្នកចូរយកសំពត់ងូតទឹកមក តថាគតនឹងស្រង់ទឹកក្នុងស្រះ-*

បោក្ខរណីជេតពន ។

ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទឹកក្នុងស្រះ-បោក្ខរណីជេតពនរីងស្ងួតអស់ហើយ នៅសល់ត្រឹមតែសើមដីប៉ុណ្ណោះ មិនមែនឬ ព្រះអង្គ?

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ធម្មតាកម្លាំងរបស់ព្រះពុទ្ធខ្លាំង អ្នកចូរទៅយកសំពត់ងូតទឹកមកចុះ ។ ព្រះអានន្ទក៏ទៅយកមកថ្វាយ ព្រះបរមសាស្តាទ្រង់ស្លៀកសំពត់ឧទកសាដកដោយជាយម្ខាង ជាយម្ខាងទៀតទ្រង់ដណ្តប់ព្រះសរីរៈ ទ្រង់ប្រថាប់ឈរនៅក្បែរជណ្តើរ ទ្រង់តាំងព្រះទ័យថា តថាគតនឹងស្រង់ទឹកក្នុងស្រះបោក្ខរណីជេតពន ។

ភ្លាមនោះឯង បណ្ឌុកម្ពលសិលាសនៈរបស់សក្កទេវរាជ ក៏សម្តែងអាការក្តៅ សក្កទេវរាជទ្រង់ពិចារណាថា តើមានហេតុអ្វីហ្ន៎? ទ្រង់ជ្រាបហេតុនោះ ទើបមានទេវបញ្ជាហៅវលាហកទេវរាជម្ចាស់ភ្លៀងមកគាល់ ហើយត្រាស់ថា នែទេវបុត្រ ព្រះបរមសាស្តាទ្រង់តាំងព្រះទ័យថា តថាគតនឹងស្រង់ទឹកក្នុងស្រះបោក្ខរណីជេតពន ទ្រង់ប្រថាប់ឈរនៅក្បែរជណ្តើរស្រះ អ្នកចូរធ្វើដែនកោសលទាំងមូលឲ្យមានភ្លៀងធ្លាក់ជោកជាំ បណ្តាលឲ្យភ្លៀងធ្លាក់ចុះមកឆាប់ៗចុះ ។ វលាហកទេវរាជទទួលទេវបញ្ជាហើយ ស្លៀកដុំពពកមួយដុំ ដណ្តប់មួយដុំ ច្រៀងបទចម្រៀងដែលមានឈ្មោះថា មេឃសង្គីត បែរមុខទៅរកលោកធាតុខាងកើត ហោះទៅកាន់ទិសខាង

កើត ក៏ប្រាកដដុំពពកមួយដុំប៉ុនលានបញ្ចាន់ស្រូវ ត្រួតលើគ្នាជាជាន់ៗ ទាំងរយជាន់ ពាន់ជាន់ ផ្គរលាន់ទ្រហឹងអឺងកង ផ្លេកបន្ទោរដាលប្រវាត់ ភ្លៀងក៏ធ្លាក់ចុះមកដូចគេផ្កាប់ផ្ទាំង ដែនកោសលទាំងមូលជន់លិចដូចជំនន់ ទឹកហូរមក ភ្លៀងបង្អុរចុះមកមិនដាច់ខ្សែ មួយភ្លែតប៉ុណ្ណោះ ក៏ពេញស្រះ-បោក្ខរណីជេតពន ទឹកលិចរហូតដល់មាត់ជណ្ដើរ ។

ព្រះបរមសាស្ដា ទ្រង់ស្រង់ទឹកក្នុងស្រះបោក្ខរណីជេតពនហើយ ទ្រង់គ្រងសំពត់ពីរជាន់ពណ៌ក្រហម ក្រវាត់វត្ថពន្ធចង្កេះ ទ្រង់គ្រងព្រះ-សុគតចីវរធៀងស្មាម្ខាង ហែហមដោយភិក្ខុសង្ឃ ស្ដេចយាងទៅ ទ្រង់គង់លើបវរពុទ្ធាសនៈ ដែលក្រាលទុកហើយក្នុងបរិវេណព្រះគន្ធកុដិ កាលភិក្ខុសង្ឃសម្ដែងវត្តបដិបត្តិហើយ ស្ដេចឧដ្ឋាការទ្រង់ប្រថាប់ឈរលើផ្ទៃជណ្ដើរកែវមណី ប្រទានឱវាទដល់ភិក្ខុសង្ឃ ហើយទ្រង់បញ្ជូនភិក្ខុសង្ឃឲ្យត្រឡប់ទៅវិញ ស្ដេចយាងចូលកាន់ព្រះគន្ធកុដិដែលមានក្លិនជាប់ចិត្ត ទ្រង់ផ្ទំសីហ-សេយ្យាដោយបែរទៅខាងស្ដាំ ។ លុះដល់ពេលរសៀល ពួកភិក្ខុអង្គុយប្រជុំគ្នាក្នុងធម្មសភាលើករឿងឡើងសន្ទនាគ្នាថា អ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរមើលព្រះគុណសម្បត្តិ គឺ ខន្តី មេត្តា និងព្រះករុណារបស់ព្រះទសពល កាលសត្វទាំងឡាយកំពុងតែស្វិតស្រពោន ជលាល័យគ្រប់កន្លែងក៏រីងស្ងួត ហ្វូងត្រីនិងអណ្ដើកជួបប្រសព្វទុក្ខធំ ទ្រង់អាស្រ័យព្រះករុណា ទ្រង់ស្លៀកសំពត់ឧទកសាដក ដោយព្រះពុទ្ធបំណងនឹងឲ្យ

មហាជនផុតចាកទុក្ខ ទ្រង់ប្រថាប់ឈរនៅក្បែរជណ្តើរនៃស្រះបោក្ខរណី-ជេតវន ទ្រង់បណ្តាលឲ្យភ្លៀងបង្អុរចុះមក ដូចជំនន់ទឹកធំហូរមក ជន់លិចកោសលរដ្ឋគ្រប់កន្លែង ដោយវេលាត្រឹមតែមួយភ្លែត ទ្រង់ដោះមហាជនឲ្យរួចផុតអំពីទុក្ខតាមផ្លូវកាយ ទុក្ខតាមផ្លូវចិត្តហើយ ស្តេចយាងចូលកាន់វិហារ ។ ព្រះបរមសាស្តា ស្តេចយាងចេញអំពីព្រះគន្ធកុដិមកកាន់ធម្មសភា ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតធ្វើឲ្យភ្លៀងបង្អុរចុះមក ក្នុងកាលមហាជនកំពុងតែជួបការលំបាកដោយទឹកភ្លៀងនោះ សូម្បីក្នុងកាលមុនគឺតថាគតកើតក្នុងកំណើតសត្វតិរច្ឆាន ក្នុងកាលជាស្តេចនៃហ្វូងត្រី ក៏បានធ្វើភ្លៀងឲ្យបង្អុរចុះមកដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល មានត្រពាំងមួយព័ទ្ធជុំវិញដោយព្រៃក្រាស់នៃវល្លិត្រង់ស្រះបោក្ខរណីជេតពន នាក្រុងសាវត្ថីដែនកោសលនេះឯង ។ គ្រា-នោះ ព្រះបរមពោធិសត្វបដិសន្ធិក្នុងកំណើតត្រី មានហ្វូងត្រីជាបរិវារនៅក្នុងត្រពាំងនោះ សូម្បីក្នុងកាលនោះ ដែននោះក៏គ្មានភ្លៀងធ្លាក់ចុះមកដូចពេលនេះដែរ សន្ទូងរបស់ពួកអ្នកស្រុកក្រៀមស្វិតខូចខាតអស់ ក្នុងបឹង

*ជាដើមគ្មានទឹក ហ្វូងត្រីនិងអណ្តើកនាំគ្នាត្បុរចូលភក់ ។ សូម្បីអូរនោះ ហ្វូងត្រីក៏នាំគ្នាត្បុរចូលភក់ជ្រកក្នុងទីនោះៗ ហ្វូងក្អែកជាដើមក៏នាំគ្នាចឹក ចេញមកស៊ីដោយចំពុះ ។ ព្រះពោធិសត្វឃើញការវិនាសនៃពួកញាតិក៏ ត្រិះរិះថា អ្នកដទៃវៀរអាត្មាអញចេញហើយ មិនមានអ្នកណាអាចជួយ ដោះទុក្ខពួកត្រីទាំងនេះបានឡើយ អញនឹងធ្វើសច្ចកិរិយាឲ្យភ្លៀងបង្អុរចុះ មក ដោះពួកញាតិអំពីទុក្ខគឺសេចក្តីស្លាប់ឲ្យទាល់តែបាន ហើយញែកភក់ ពណ៌ខ្មៅចេញមក ស្តេចត្រីធំមានពណ៌ដូចត្របកផ្កាអញ្ចាន បើកភ្នែកទាំង គូដែលប្រៀបបាននឹងកែវមណី មានពណ៌ក្រហមសម្លឹងមើលអាកាស បន្លឺ សំឡេងពោលទៅកាន់ទេវរាជឈ្មោះបជ្ជុន្នថា បពិត្រព្រះបជ្ជុន្នដ៏ចម្រើន ខ្ញុំអាស្រ័យពួកញាតិក្តៅក្រហាយណាស់ កាលខ្ញុំជាអ្នកទ្រទ្រង់សីល ដល់ នូវសេចក្តីលំបាកយ៉ាងនេះ ហេតុដូចម្តេចលោកមិនជួយឲ្យភ្លៀងធ្លាក់ចុះ មក ខ្ញុំកើតក្នុងឋានៈដែលអាចខាំសត្វដទៃស៊ី ប៉ុន្តែខ្ញុំមិនធ្លាប់មានឈ្មោះ ថាស៊ីមច្ឆជាតិ តាំងពីត្រីតូចប៉ុនគ្រាប់អង្ករ សូម្បីសត្វដទៃៗ ខ្ញុំក៏មិនធ្លាប់ ផ្តាច់ជីវិតដែរ ដោយសច្ចវាចានេះ សូមលោកញុំាងភ្លៀងឲ្យធ្លាក់ចុះមក ដោះពួកញាតិរបស់ខ្ញុំឲ្យរួចផុតចាកទុក្ខចុះ កាលនឹងហៅទេវរាជឈ្មោះ បជ្ជុន្ន ដូចប្រើបម្រើ ក៏ពោលគាថានេះថា*

អភិត្ថនយ បជ្ជុន្ន  និធឹ កាកស្ស នាសយ
កាកំ សោកាយ រន្ធេហិ  មញ្ច សោកា បមោចយាតិ ។

*បពិត្រមេឃ សូមអ្នកញុំាងផ្គរឲ្យលាន់ឡើង សូមបំផ្លាញ កំណប់របស់ក្អែកឲ្យវិនាស សូមធ្វើទុក្ខក្អែកឲ្យសោកសៅ សូមញុំាងខ្ញុំ (និងពួកញាតិខ្ញុំ) ឲ្យរួចចាកសេចក្តីសោក ។*

*បណ្តាបទទាំងនោះ បទថា* **អភិត្ថនយ បជ្ជុន្ន** *សេចក្តីថា មេឃ ហៅថា ស្តេចបជ្ជុន្ន ក៏ស្តេចត្រីនេះ ហៅវលាហកទេវរាជថាជាម្ចាស់ភ្លៀង អ្នកមានឈ្មោះដោយអំណាចនៃមេឃ ។ បានឮថា ស្តេចត្រីនោះមាន បំណងដូច្នេះថា ធម្មតាភ្លៀងមិនគ្រហឹម មិនឲ្យមានផ្លេកបន្ទោរ សូម្បី បង្អុរចុះមកក៏មិនល្អ ព្រោះដូច្នោះ អ្នកចូរគ្រហឹម ចូរឲ្យមានផ្លេកបន្ទោរ ហើយញុំាងភ្លៀងឲ្យបង្អុរមកចុះ ។*

*បទថា* **និធឹ កាកស្ស ធាសយ** *សេចក្តីថា ហ្វូងក្អែកនាំគ្នា ចឹកហ្វូងត្រីដែលត្បុរចូលភក់ដើម្បីជ្រក ចេញមកដោយចំពុះស៊ីជាអាហារ ព្រោះហេតុនោះ ទើបហ្វូងត្រីដែលត្បុរចូលភក់នោះ ហៅថាកំណប់ទ្រព្យ របស់ក្អែកជាដើមនោះ កាលលោកបណ្តាលឲ្យភ្លៀងបង្អុរចុះមកជាប្រក្រតី ហើយ ក៏ជាការទម្លាយកំណប់ទ្រព្យរបស់ហ្វូងក្អែកនោះ ។*

*បទថា* **កាកំ សោកាយ រន្ធេហិ** *សេចក្តីថា ហ្វូងក្អែក កាល ត្រពាំងមានទឹកពេញហើយ មិនបានហ្វូងត្រីជាអាហារក៏ត្រូវសុបសៅ កាល អ្នកធ្វើឲ្យត្រពាំងនេះពេញប្រៀបដោយទឹក ក៏ជាការទម្លាយហ្វូងក្អែកនោះ ដោយសេចក្តីសោក អ្នកចូរញុំាងភ្លៀងឲ្យបង្អុរចុះមក ដើម្បីរម្ងាប់សេចក្តី*

*សោក គឺដើម្បីការស្រឡះចិត្តរបស់ត្រីទាំងឡាយ ។ អធិប្បាយថា ហ្វូងក្អែកនឹងដល់នូវសេចក្តីសុបសៅ ដែលមានលក្ខណៈខ្វោចផ្សាខាងក្នុងបាន ដោយវិធីណា អ្នកចូរធ្វើវិធីនោះចុះ ។*

ច *អក្សរក្នុងបទគាថាថា* មញ្ច សោកោ បមោចយ *នេះមានការប្រមូលមកជាអត្ថ មានន័យថា អ្នកមេត្តាឲ្យខ្ញុំនិងពួកញាតិទាំងអស់រួចផុតអំពីសោក ដែលកើតអំពីសេចក្តីស្លាប់នេះចុះ ។*

*ព្រះពោធិសត្វហៅស្តេចបជ្ជុន្នដូចប្រើបម្រើយ៉ាងនេះ ឲ្យបណ្តាលភ្លៀងមួយមេធំធ្លាក់ចុះមក ទូទៅពេញដែនកោសល ធ្វើឲ្យមហាជនរួចផុតអំពីមរណទុក្ខ ក្នុងបរិយោសាននៃជីវិតក៏បានទៅតាមយថាកម្ម ។*

*ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលដែលតថាគតបណ្តាលឲ្យភ្លៀងបង្អុរចុះមកនោះ មិនមែនមានតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន កាលដែលតថាគតកើតក្នុងកំណើតត្រីក៏បណ្តាលឲ្យភ្លៀងបង្អុរចុះមកដែរ ។ លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ហ្វូងត្រីក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ បជ្ជុន្នទេវរាជបានមកជាអានន្ទ ចំណែកស្តេចត្រី គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា មច្ឆជាតក ទី ៥ ។

# អដ្ឋកថា អសង្កិយជាតក ទី ៦

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកអ្នកក្រុងសាវត្ថីម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អសង្កិយោម្ហិ គាមម្ហិ** ដូច្នេះជាដើម ។

បានឮថា ឧបាសកនោះជាព្រះអរិយសាវកថ្នាក់សោតាបន្ន ធ្វើដំណើរទៅជាមួយនឹងពួករទេះមួយក្រុម លុះឈ្មួញរទេះទាំងឡាយដោះរទេះសម្រាកនៅក្នុងព្រៃមួយ ក៏ដើរចង្រ្កមក្រោមដើមឈើមួយ ។ ពួកចោរ ៥០០ កំណត់វេលារបស់ខ្លួនហើយ គិតគ្នាថា ពួកយើងនឹងចេញប្លន់ម្នាក់ៗកាន់ដុំថ្មនិងដំបងជាដើម នាំគ្នាទៅឡោមព័ទ្ធទីនោះ ។ ចំណែកឧបាសកនោះ នៅតែដើរចង្រ្កមធ្វើដូចជាមិនដឹង ចោរទាំងឡាយឃើញឧបាសកនោះហើយគិតគ្នាថា បុរសនេះប្រាកដជាអ្នកយាមទីសម្រាក ចាំឲ្យបុរសនេះដេកលក់សិន ពួកយើងនឹងប្លន់ កាលមិនអាចវាយលុកចូល ក៏សម្ងំនៅក្នុងទីនោះៗ ។ ចំណែកឧបាសកនោះនៅតែអធិដ្ឋានដើរចង្រ្កមទាំងក្នុងបឋមយាម មជ្ឈិមយាម សូម្បីក្នុងបច្ឆិមយាម រហូតដល់ភ្លឺ ។ ពួកចោរមិនបានឱកាស ក៏បោះដុំថ្មនិងដំបងជាដើមចោល នាំគ្នាត្រឡប់ទៅវិញ ។ ចំណែកឧបាសកនោះធ្វើកិច្ចរបស់ខ្លួនស្រេចហើយ ត្រឡប់មកកាន់នគរសាវត្ថី ចូលគាល់ព្រះបរមសាស្តាក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកដែលកំពុងរក្សាខ្លួន ក៏ជាអ្នករក្សាអ្នកដទៃផងឬ? ព្រះបរម-

សាស្តាទ្រង់ត្រាស់ថា ពិតមែនហើយឧបាសក អ្នករក្សាខ្លួនឈ្មោះថារក្សាអ្នកដទៃ រក្សាអ្នកដទៃក៏ឈ្មោះថារក្សាខ្លួននោះឯង ។ ឧបាសកនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះព្រះដ៏មានព្រះភាគត្រាស់ទុកប្រពៃហើយ ខ្ញុំព្រះអង្គធ្វើដំណើរជាមួយនឹងពួករទេះមួយក្រុម ដើរបង្រ្គមនៅក្រោមដើមឈើ ដោយគិតថានឹងរក្សាខ្លួន ( ក្លាយជាអ្នក ) រក្សាពួករទេះទាំងអស់ ។ ព្រះបរមសាស្តាត្រាស់ថា ម្នាលឧបាសក សូម្បីកាលពីមុនបណ្ឌិតទាំងឡាយរក្សាខ្លួន ក៏ក្លាយជាអ្នករក្សាអ្នកដទៃហើយដែរ កាលឧបាសកនោះក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ។ គ្រានោះ ព្រះមហាសត្វបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ចម្រើនវ័យហើយ ឃើញទោសរបស់កាមក៏បួសជាឥសីនៅក្នុងព្រៃហិមពាន្តមកកាន់ជនបទដើម្បីសេពរសប្រៃខ្លះ រសជូរខ្លះ កាលត្រាច់ទៅតាមជនបទបានធ្វើដំណើរជាមួយនឹងពួករទេះមួយក្រុម កាលពួករទេះសម្រាកនៅក្នុងព្រៃមួយ ក៏សម្រាកនៅដោយសេចក្តីសុខដែលកើតអំពីឈាន មិនឆ្ងាយអំពីពួករទេះ បង្រ្គមក្រោមដើមឈើមួយហើយឈរស្ងៀម ។ គ្រានោះ ពួកចោរ ៥០០ នាំគ្នាមកដោយគិតថា នឹងប្លន់ពួករទេះក្នុងវេលាដែលបរិភោគអាហារល្ងាចហើយ ពួកចោរទាំងនោះឃើញតាបសហើយគិតថា ប្រសិន-

បើតាបសនេះឃើញពួកយើង គង់នឹងប្រាប់អ្នករទេះមិនខាន ចាំពេលតាបសនេះដេកលក់ ពួកយើងប្លន់ចុះ ហើយនាំគ្នាពួននៅក្នុងទីនោះឯង ។ ចំណែកតាបសដើរចង្ក្រមជានិច្ចរហូតទល់ភ្លឺ ពួកចោរមិនបានឱកាស ក៏នាំគ្នាបោះដំបងនិងដុំថ្មដែលកាន់មកនោះចោល ហើយស្រែកប្រាប់អ្នករទេះថា អ្នករទេះដ៏ចម្រើន ប្រសិនបើតាបសដែលដើរទៅដើរមកក្រោមដើមឈើនេះ មិនមានក្នុងថ្ងៃនេះទេ ពួកអ្នកគ្រប់គ្នាប្រាកដជាត្រូវជួបការប្លន់យ៉ាងពិត ស្អែកនេះ ពួកអ្នកគួរធ្វើសក្ការបូជាធំចំពោះតាបសអង្គនេះ ដូច្នេះហើយ នាំគ្នាចៀសចេញទៅ ។ លុះភ្លឺច្បាស់ហើយ ពួកអ្នករទេះឃើញដំបងនិងដុំថ្មជាដើម ដែលពួកចោរបោះចោល ម្នាក់ៗភ័យខ្លាចនាំគ្នាទៅកាន់សម្នាក់តាបសពោធិសត្វហើយសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ឃើញពួកចោរឬ ? ព្រះមហាសត្វឆ្លើយថា ចម្រើនពរ អ្នកមានអាយុទាំងឡាយ អាត្មាឃើញ ។ ពួកអ្នករទេះសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ឃើញចោរមានប្រមាណប៉ុណ្ណោះ មិនមានការភ័យខ្លាច ការតក់ស្លុតកើតឡើងសោះទេឬ ? ព្រះមហាសត្វឆ្លើយថា អ្នកមានអាយុទាំងឡាយ ការភ័យខ្លាច ការតក់ស្លុតព្រោះឃើញពួកចោរមានចំពោះអ្នកមានទ្រព្យ ប៉ុន្តែអាត្មាជាអ្នកមិនមានទ្រព្យនឹងត្រូវខ្លាចធ្វើអ្វី មានអ្វីគួរឲ្យខ្លាច ? ព្រោះកាលអាត្មានៅក្នុងស្រុកក្តី ក្នុងព្រៃក្តី ការភ័យខ្លាចឬការតក់ស្លុត រមែងមិនមាន កាលនឹងសម្តែងធម៌ដល់មនុស្សទាំងនោះ បាន

*ពោលគាថានេះថា*

**អសង្កិយោម្ហិ គាមម្ហិ អរញ្ញេ នត្ថិ មេ ភយំ**

**ឧជុមគ្គំ សមារុឡ្ហោ មេត្តាយ ករុណាយ ចាតិ ។**

*យើងជាអ្នកមិនមានសេចក្តីរង្កៀស ក្នុងស្រុក យើងជាអ្នកមិនមានភ័យ ក្នុងព្រៃ បានឡើងកាន់ផ្លូវត្រង់ ដោយមេត្តានិងករុណាហើយ ។*

*បណ្តាបទទាំងនោះ បទថា* **អសង្កិយោម្ហិ គាមម្ហិ** *នេះ ព្រះបរមពោធិសត្វសម្តែងថា យើងជាអ្នកមិនមានសេចក្តីរង្កៀស ព្រោះមិនប្រកបដោយធម៌ជាគ្រឿងរង្កៀស មិនតាំងនៅក្នុងធម៌ជាគ្រឿងរង្កៀស សូម្បីនៅក្នុងស្រុកក៏មិនមានសេចក្តីរង្កៀស ជាអ្នកមិនមានភ័យ ព្រោះមិនតាំងនៅក្នុងធម៌ជាគ្រឿងរង្កៀស ។*

*បទថា* **អរញ្ញេ** *បានដល់ ទីដែលផុតអំពីស្រុកនិងឧបចារស្រុក ។*

*បទថា* **ឧជុមគ្គំ សមារុឡ្ហោ មេត្តាយ ករុណាយ ច** *នេះ ព្រះបរមពោធិសត្វពោលទុកថា យើងបានឡើងកាន់ផ្លូវត្រង់ គឺផ្លូវទៅកាន់ព្រហ្មលោកដែលវៀរចាកការវៀចកាយទ្វារជាដើម ដោយមេត្តានិងករុណាដែលជាអារម្មណ៍នៃតតិយជ្ឈាននិងចតុត្ថជ្ឈាន ន័យម្យ៉ាងទៀត ដោយបទនេះ ព្រះបរមពោធិសត្វសម្តែងថា ព្រោះភាពជាអ្នកមានសីលបរិសុទ្ធ ទើបឈ្មោះថា ឡើងកាន់ផ្លូវត្រង់ដែលវៀរចាកការវៀចដោយកាយ វាចា*

ចិត្ត ដែលបានដល់ផ្លូវទៅកាន់ព្រហ្មលោក ដូច្នេះ ហើយសម្តែងសេចក្តីឲ្យក្រៃលែងជាងនោះថា ព្រោះតាំងមាំនៅក្នុងមេត្តានិងករុណា ឈ្មោះថាឡើងកាន់ផ្លូវត្រង់ គឺផ្លូវទៅកាន់ព្រហ្មលោក ។ អធិប្បាយថា ធម៌ទាំងឡាយមានមេត្តានិងករុណាជាដើម ឈ្មោះថាជាផ្លូវត្រង់ ព្រោះអ្នកដែលមានឈានមិនសាបសូន្យ ជាអ្នកមានព្រហ្មលោកជាទិសដៅដោយចំណែកមួយ ។

ព្រះបរមពោធិសត្វ លុះសម្តែងធម៌ដោយគាថានេះ ដោយប្រការដូច្នេះ កាលមនុស្សទាំងនោះមានចិត្តត្រេកអរហើយ ធ្វើសក្ការបូជាហើយ ចម្រើនព្រហ្មវិហារ ៤ រហូតអស់ជីវិត ក្រោយអំពីចុតិទៅបដិសន្ធិក្នុងព្រហ្មលោក ។

ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា អ្នករទេះកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកតាបស គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា អសង្កិយជាតក ទី ៦ ។

# អដ្ឋកថា មហាសុបិនជាតក ទី ៧

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមហាសុបិន ១៦ ប្រការ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **ឧសភា រុក្ខា គាវិយោ** *ដូច្នេះជាដើម ។*

*បានឮថា ថ្ងៃមួយ ព្រះបាទកោសលមហារាជ ស្ដេចចូលផ្ទំក្នុងរាត្រីកាល ក្នុងបច្ឆិមយាម ទ្រង់ទតឃើញសុបិននិមិត្តដ៏ធំ ១៦ប្រការ ទ្រង់ស្ទុតព្រះទ័យភ័យញាប់ញ័រ ភ្ញាក់ពីព្រះបន្ទំទ្រង់ព្រះតម្រិះថា ព្រោះឃើញសុបិននិមិត្តទាំងនេះ នឹងមានរឿងអ្វីកើតឡើងដល់អញហ្ន៎ ជាអ្នកដែលមរណភ័យគំរាមហើយ ទ្រង់គង់លើព្រះក្រឡាបន្ទំនុំះឯង រហូតទល់ភ្លឺ ។*

*លុះភ្លឺឡើង ពួកព្រាហ្មណ៍បុរោហិតចូលគាល់ ក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព ទ្រង់ផ្ទំជាសុខឬ ?*

*ទ្រង់ត្រាស់ថា នែអាចារ្យទាំងឡាយ យើងនឹងមានសេចក្ដីសុខពីណា កាលពីយប់មិញវេលាជិតភ្លឺ យើងឃើញសុបិននិមិត្ត ១៦ ប្រការ តាំងតែពីឃើញសុបិននិមិត្តទាំងនោះហើយ យើងក៏ភ័យខ្លាចជាខ្លាំង ។ កាលពួកបុរោហិតក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់រៀបរាប់ប្រាប់អំពីការឃើញសុបិននិមិត្តទាំងនោះដល់ពួកទូលបង្គំចុះ ពួកទូលបង្គំស្ដាប់ហើយនឹងទាយថ្វាយបាន ។ ព្រះរាជាក៏ទ្រង់តំណាលអំពីព្រះសុបិនដែលទ្រង់ឃើញហើយឲ្យពួកព្រាហ្មណ៍ស្ដាប់ ហើយត្រាស់សួរថា ព្រោះ*

ការឃើញសុបិនទាំងនេះ តើនឹងមានរឿងអ្វីកើតឡើងដល់យើង ? ពួកព្រាហ្មណ៍នាំគ្នាគ្រវីដៃ កាលព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ទើបអ្នកទាំងឡាយនាំគ្នាគ្រវីដៃ ?

ព្រាហ្មណ៍ទាំងនោះក៏នាំគ្នាក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះសុបិនទាំងឡាយអាក្រក់ក្រៃលែងណាស់ ។

ព្រះរាជាត្រាស់សួរថា សុបិនទាំងនោះនឹងមានផលដូចម្ដេចខ្លះ ?

ព្រាហ្មណ៍ទាំងនោះក៏នាំគ្នាក្រាបទូលថា នឹងមានអន្តរាយ ៣ យ៉ាងនេះ គឺអន្តរាយដល់រាជសម្បត្តិ ១ អន្តរាយគឺរោគបៀតបៀន ១ អន្តរាយដល់ព្រះជន្ម ១ បណ្ដាអន្តរាយទាំង ៣ យ៉ាងនោះ នឹងមានអន្តរាយណាមួយកើតមានចំពោះព្រះអង្គ ។

ព្រះរាជាត្រាស់សួរថា អាចកែខៃបាន ឬក៏មិនបាន ?

ព្រាហ្មណ៍ទាំងនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព សុបិនទាំងនេះអស់ផ្លូវកែបានហើយ ព្រោះអាក្រក់ក្រៃលែងណាស់ ប៉ុន្តែពួកទូលបង្គំទាំងឡាយនឹងធ្វើឲ្យកែខៃវិញបាន កាលបើពួកទូលបង្គំមិនអាចកែខៃព្រះសុបិនទាំងនេះបានហើយ ដែលឈ្មោះថាភាពជាអ្នកសម្រេចការសិក្សានឹងមានប្រយោជន៍អ្វី ?

ព្រះរាជាត្រាស់សួរថា នែអាចារ្យទាំងឡាយ អ្នកទាំងឡាយនឹងធ្វើដូចម្ដេចដើម្បីឲ្យកែខៃបាន ?

ព្រាហ្មណ៍ទាំងនោះនាំគ្នាក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកទូលបង្គំត្រូវបូជាយញ្ញដោយវត្ថុមួយមុខៗ ៤ គ្រប់ៗយ៉ាង ។

ព្រះរាជាទ្រង់ស្ដាប់ព្រះទ័យត្រាស់ថា នែអាចារ្យទាំងឡាយ បើដូច្នោះ យើងសូមប្រគល់ជីវិតទុកក្នុងដៃរបស់អ្នកទាំងឡាយហើយ អ្នកទាំងឡាយប្រញាប់ធ្វើសួស្ដីឲ្យដល់យើងឆាប់ៗ ចុះ ។ ព្រាហ្មណ៍ទាំងនោះត្រេកអររីករាយថា ពួកយើងបានទ្រព្យច្រើន បានរបស់បរិភោគច្រើនៗហើយ ហើយនាំគ្នាក្រាបទូលលួងលោមព្រះរាជាថា បពិត្រព្រះសម្មតិទេព សូមទ្រង់កុំព្រួយឡើយ ហើយនាំគ្នាចេញពីរាជនិវេសន៍ ចាត់ចែងធ្វើរណ្ដៅបូជាយញ្ញក្រៅនគរ ចាប់សត្វជើង ៤ យ៉ាងច្រើន ចងនឹងបង្គោលយញ្ញ ដើរប្រមូលបក្សីបានគ្រប់សព្វហើយដើរខ្វាត់ខ្វែងទៅមកពោលថាយើងគួរបានវត្ថុនេះៗ ។

គ្រានោះ ព្រះនាងមល្លិកាទេវីទ្រង់ជ្រាបហេតុនោះហើយ ក៏ចូលគាល់ព្រះរាជាហើយក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព មានហេតុអ្វីទើបពួកព្រាហ្មណ៍ឆ្វេឆ្វាម៉្លេះ ?

ព្រះរាជាត្រាស់ថា នែនាងដ៏ចម្រើន នាងរវល់តែពីសុខសប្បាយទើបមិនដឹងថាអាសិរពិសរាសញ្ចរមកជិតៗ ត្រចៀករបស់ពួកយើង ។

ព្រះនាងមល្លិកាក្រាបទូលសួរថា បពិត្រមហារាជ តើរឿងនោះដូចម្ដេច ?

ព្រះរាជាត្រាស់ថា យើងយល់សប្តិអាក្រក់បែបនេះ ពួកព្រាហ្មណ៍ទាយថា អន្តរាយ ៣ យ៉ាង ណាមួយនឹងកើតឡើង ដើម្បីកម្ចាត់អន្តរាយទាំងនោះត្រូវបូជាយញ្ញ ទើបត្រូវដើរទៅដើរមករឿយៗ ។

ព្រះនាងមល្លិកាក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព បុគ្គលដែលជាកំពូលនៃព្រាហ្មណ៍ក្នុងលោកព្រមទាំងទេវលោក ព្រះអង្គបានទូលសួរអំពីការកែខែព្រះសុបិនហើយឬ?

ព្រះរាជាត្រាស់សួរថា នែនាងដ៏ចម្រើន បុគ្គលដែលជាកំពូលនៃព្រាហ្មណ៍ក្នុងលោកព្រមទាំងទេវលោកនោះ តើជានរណា?

ព្រះនាងមល្លិកាក្រាបទូលថា ព្រះអង្គមិនស្គាល់មហាព្រាហ្មណ៍គោតមដែលជាព្រះតថាគត ព្រះអង្គអស់កិលេសហើយ ជាព្រះសព្វញ្ញូជាអគ្គបុគ្គលក្នុងលោកព្រមទាំងទេវលោកទេឬ ? ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គប្រាកដជាទ្រង់ជ្រាបហេតុផលនៃព្រះសុបិនទាំងនោះ សូមព្រះអង្គយាងទៅក្រាបទូលសួរព្រះដ៏មានព្រះភាគអង្គនោះចុះ ។

ព្រះរាជាទ្រង់យល់ព្រមថា ប្រពៃហើយព្រះទេវី ហើយស្តេចយាងទៅកាន់ព្រះវិហារ ថ្វាយបង្គំព្រះបរមសាស្តាហើយទ្រង់គង់ក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគទ្រង់ថ្លែងព្រះសូរសៀងដ៏ពីរោះត្រាស់សួរថា មហាបពិត្រ តើមានរឿងអ្វី ទើបមហាបពិត្រយាងមកកាន់សម្នាក់តថាគតដូចជាមានរាជកិច្ចប្រញាប់យ៉ាងនេះ?

ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលពីជិតភ្លឺ ខ្ញុំព្រះអង្គបានឃើញមហាសុបិន ១៦ ប្រការ ខ្ញុំព្រះអង្គភ័យខ្លាចក៏ប្រាប់ពួកព្រាហ្មណ៍ ពួកព្រាហ្មណ៍ទាយថា បពិត្រមហារាជ ព្រះសុបិននេះអាក្រក់ក្រៃលែងណាស់ ដើម្បីរម្ងាប់សុបិនទាំងនោះ ត្រូវបូជាយញ្ញ ដោយយញ្ញវត្ថុមួយមុខ ៤ គ្រប់វត្ថុ ហើយនាំគ្នាត្រៀមបូជាយញ្ញ ពួកសត្វជាច្រើនត្រូវមរណភ័យគំរាម បពិត្រព្រះដ៏មានព្រះភាគ ព្រះអង្គជាបុគ្គលដ៏កំពូលក្នុងលោកព្រមទាំងទេវលោក ញេយ្យធម៌ដែលគួរកំណត់ដឹងក្នុងអតីត អនាគត បច្ចុប្បន្ន ដែលមិនទាន់មកដល់ ដែលកន្លងក្នុងញាណរបស់ព្រះអង្គនោះមិនមានឡើយ បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គទ្រង់ព្រះមេត្តាព្យាករសុបិនរបស់ខ្ញុំព្រះអង្គទាំងនោះផងចុះ ។

ព្រះបរមសាស្តាទ្រង់ត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ ដូច្នេះពិតមែនហើយ ក្នុងលោកព្រមទាំងទេវលោកវៀរតថាគតចេញហើយ អ្នកដទៃដែលអាចដឹងហេតុឬផលនៃសុបិនទាំងនេះ មិនមានឡើយ តថាគតនឹងព្យាករឲ្យមហាបពិត្រទ្រង់ជ្រាប ក៏ប៉ុន្តែសូមមហាបពិត្រត្រាស់ប្រាប់សុបិនតាមទំនងដែលមហាបពិត្រទ្រង់ឃើញហើយនោះចុះ ។ ព្រះបាទបសេនទិកោសលទ្រង់ទទួលព្រះពុទ្ធតម្រាស់ថា ប្រពៃហើយព្រះអង្គ ហើយផ្តើមក្រាបទូលព្រះសុបិនតាមទំនងដែលទ្រង់ឃើញហើយគ្រប់សព្វ ដោយទ្រង់ដាក់មាតិកាដូច្នេះថា

ឧសភា រុក្ខា គាវិយោ គវា ច
អស្សោ កំសោ សិគាលី ច កុម្ភោ
ពោក្ខរណី ច អបាកចន្ទនំ
លាពូនិ សីទន្តិ សិលា ប្លវន្តិ
មណ្ឌូកិយោ កណ្ហសប្បេ គិលន្តិ
កាកំ សុវណ្ណា បរិវារយន្តិ
តសា វកា ឯឡកានំ ភយា ហិ
វិប្បរិយាយោ វត្តតិ នយិធមត្ថីតិ ។

គោឡើងកទាំងឡាយ ១ ឈើទាំងឡាយ ១ មេគោទាំងឡាយ ១ គោឈ្មោលទាំងឡាយ ១ សេះ១ ភាជន៍ (មាស) ១ មេចចក ១ ក្អម ១ ស្រះបោក្ខរណី ១ បាយឆៅ ១ ខ្លឹមចន្ទន៍ ១ ផ្លែឃ្លោកទាំងឡាយលិច ១ ថ្មទាំងឡាយអណ្តែត ១ មេកង្កែបទាំងឡាយខាំពស់វែកទាំងឡាយ ១ រាជហង្សមាសទាំងឡាយចោមរោមក្អែក ១ ខ្លាដំបងទាំងឡាយ (រត់ទៅ) ព្រោះភ្ញាក់ផ្អើល ដោយសេចក្តីខ្លាចអំពីពពែទាំងឡាយ ១ បរិយាយចម្លែកប្រព្រឹត្តទៅ ន័យទាំងឡាយមានក្នុងសុបិនទាំងនេះ ។

ហើយត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញសុបិនប្រការទី ១ យ៉ាងនេះថា គោមានពណ៌ដូចផ្កាអញ្ជ័នចំនួន ៤ គោនីមួយៗ

គិតថានឹងជល់គ្នា នាំគ្នាមកកាន់លានព្រះរាជវាំងអំពីទិសទាំង ៤ កាល មហាជនប្រជុំគ្នាគិតថា ពួកយើងនឹងមើលគោជល់គ្នា គោទាំងនោះសម្តែងអាការនឹងជល់គ្នា បន្លឺសំឡេងគំរាមដាក់គ្នា ហើយមិនជល់គ្នា ត្រឡប់ថយចេញទៅវិញ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គឃើញសុបិននេះជាបឋម តើសុបិននេះមានផលដូចម្តេច?

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះនឹងមិនមានក្នុងរជ្ជកាលនៃមហាបពិត្រ ក្នុងកាលសាសនាតថាគតទេ ប៉ុន្តែក្នុងអនាគត កាលលោកវិលទៅដល់ចំណុចវិនាស ក្នុងរជ្ជកាលនៃព្រះ-រាជាកំព្រាដែលមិនបានគ្រងរាជ្យដោយធម៌ និងក្នុងកាលនៃពួកមនុស្សដែលមិនតាំងនៅក្នុងធម៌ កាលកុសលធម៌សាបសូន្យទៅ អកុសលធម៌ចម្រើនឡើង ក្នុងកាលដែលលោកសាបសូន្យនឹងរាំងភ្លៀង ហើយសន្ទូងស្ងួតក្រៀមស្វិតអស់ ទុព្ភិក្ខភ័យនឹងកើតឡើង ពពកទាំងឡាយតាំងឡើងពីទិសទាំង ៤ ដូចនឹងធ្លាក់គ្រាប់ភ្លៀង លុះពួកស្ត្រីប្រញាប់កើបស្រូវជាដើមដែលយកចេញហាលក្តៅចូលទុកក្នុងផ្ទះព្រោះខ្លាចទទឹក កាលពួកបុរសៗកាន់ចបនិងបង្គីនាំគ្នាចេញទៅ ដើម្បីនឹងទប់ភ្លឺស្រែការពារទឹក ក៏គ្រាន់តែសម្តែងអាការនឹងធ្លាក់ភ្លៀង ផ្គរលាន់គ្រហឹមគ្រឹមៗ ផ្លេកបន្ទោរឆ្វេចឆ្វាច ហើយក៏មិនធ្លាក់ចុះមក រសាត់បាត់ទៅអស់ ដូចគោសម្តែងអាការថា នឹងជល់គ្នាហើយ ត្រឡប់មិនជល់គ្នាដូច្នោះ នេះជាផលនៃសុបិននិមិត្តនោះ

ប៉ុន្តែមិនមានអន្តរាយណាមួយ កើតឡើងចំពោះមហាបពិត្រព្រោះរឿងនោះជាបច្ច័យឡើយ មហាបពិត្រឃើញសុបិននេះប្រារព្ធអនាគត ចំណែកពួកព្រាហ្មណ៍អាស្រ័យការចិញ្ចឹមជីវិតរបស់ខ្លួន ទើបទាយដូច្នេះ ។ ព្រះ-បរមសាស្តា កាលត្រាស់ផលនៃសុបិនដោយប្រការដូច្នេះហើយ ទើបទ្រង់ត្រាស់បន្តទៀតថា សូមមហាបពិត្រត្រាស់សួរសុបិនប្រការទី ២ ទៀតចុះ ។

ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញសុបិនប្រការទី ២ យ៉ាងនេះថា ដើមឈើតូចៗ និងគុម្ពឫស្សីជ្រែកផែនដី ដុះឡើងបានមួយចំអាមខ្លះ មួយហត្ថខ្លះ ដុះឡើងបានត្រឹមតែប៉ុណ្ណោះ ក៏ចេញផ្កា ចេញផ្លែ នេះជាសុបិនប្រការទី ២ ដែលខ្ញុំព្រះអង្គបានឃើញ បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាផលនៃសុបិននេះ ?

ព្រះបរមសាស្តាទ្រង់ត្រាស់ថា មហាបពិត្រ សូម្បីផលនៃសុបិននេះ ក៏នឹងមានក្នុងកាលដែលលោកវិនាស វេលាមនុស្សមានអាយុតិច ដ្បិតថា សត្វទាំងឡាយក្នុងអនាគតនឹងមានរាគៈខ្លាំងក្លា កុមារីមានវ័យមិនទាន់គ្រប់គ្រាន់ ក៏នឹងរួមសង្វាសជាមួយបុរសដទៃ ជាស្ត្រីមានរដូវមានគភ៌ នាំគ្នាចម្រើនដោយបុត្តនិងធីតា កាលដែលកុមារីទាំងនោះមានរដូវ ប្រៀបដូចដើមឈើតូចៗ មានផ្កា កាលដែលកុមារីទាំងនោះចម្រើនដោយបុត្តនិងធីតា ក៏ដូចដើមឈើតូចៗ មានផ្លែ ភ័យមាននិមិត្តនេះជាហេតុ មិនមានដល់មហាបពិត្រទេ សូមមហាបពិត្រត្រាស់សួរសុបិនប្រការទី ៣ តទៅ

ទៀតចុះ ។

ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គបានសុបិនឃើញមេគោទាំងឡាយ នាំគ្នាបៅទឹកដោះកូនគោទាំងឡាយ ដែលទើបតែកើតក្នុងថ្ងៃនោះ នេះជាសុបិនទី ៣ ដែលខ្ញុំព្រះ-អង្គបានឃើញ បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាផលនៃសុបិននោះ ?

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មហាបពិត្រ សូម្បីផលនៃសុបិននេះ ក៏នឹងមានក្នុងអនាគតដែរ គឺនឹងមានក្នុងកាលមនុស្សទាំងឡាយនាំគ្នាលះបង់ជេដ្ឋាបចាយិកកម្ម គឺភាពជាអ្នកប្រព្រឹត្តឱនលំទោនចំពោះរៀម-ច្បង ព្រោះក្នុងអនាគតពួកសត្វនឹងមិនបានតម្កល់ទុកនូវការកោតក្រែងចំពោះមាតាបិតាឬចំពោះជីដូនជីតា ម្នាក់ៗស្វែងរកទ្រព្យដោយខ្លួនឯង កាលប្រាថ្នានឹងឲ្យរបស់បរិភោគរបស់ប្រើប្រាស់ដល់មនុស្សចាស់ៗ ក៏ឲ្យ កាលមិនចង់ឲ្យ ក៏មិនឲ្យ មនុស្សចាស់ៗទាំងនោះ មិនមានទីពឹង ចិញ្ចឹមខ្លួនឯងមិនបានត្រូវអង្វរពួកក្មេងៗ ដើម្បីចិញ្ចឹមជីវិត ដូចមេគោធំៗ នាំគ្នាមកសូមបៅដោះកូនគោដែលទើបតែកើតក្នុងថ្ងៃនោះ សូម្បីភ័យមានសុបិននេះជាហេតុ ក៏មិនមានដល់មហាបពិត្រដែរ សូមមហាបពិត្រត្រាស់សួរសុបិនទី ៤ តទៅទៀតចុះ ។

ព្រះរាជាក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គសុបិនឃើញពួកជនមិនទឹមគោធំៗ ដែលធ្លាប់នាំនឹម ដែលសម្បូរដោយរាងកាយ

និងកម្លាំងដើម្បីអូសនឹមទេ ត្រឡប់ជាទឹមគោស្ទាវៗដែលកំពុងហ្វឹក ឲ្យអូសនឹម គោស្ទាវៗទាំងនោះមិនអាចនាំនឹមទៅបាន ក៏នាំគ្នារលាស់នឹមឈរធ្វើព្រងើយ រទេះទាំងឡាយក៏ទៅមិនបាន នេះជាសុបិនទី ៤ របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន តើសុបិននេះមានផលដូចម្តេច ?

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មហាបពិត្រ សូម្បីផលនៃសុបិននេះ ក៏នឹងមានក្នុងរជ្ជសម័យនៃព្រះរាជាអ្នកមិនតាំងនៅក្នុងធម៌ ក្នុងអនាគតដែរ ដ្បិតថា ក្នុងអនាគតព្រះរាជាអ្នកមានបុណ្យតិច មិនបានតាំងនៅក្នុងធម៌ នឹងមិនព្រះរាជទានយសដល់មហាមាត្យដែលជាបណ្ឌិតឈ្លាសវៃក្នុងបវេណី អាចនឹងញ៉ាំងរាជកិច្ចគ្រប់យ៉ាងឲ្យសម្រេចបាន ហើយទ្រង់មិនតែងតាំងអាមាត្យដែលជាធំ ដែលជាបណ្ឌិតអ្នកឈ្លាសវៃក្នុងវោហារទុកក្នុងទីវិនិច្ឆ័យក្តីក្នុងរោងសាល ប៉ុន្តែទ្រង់បែរជាព្រះរាជទានយសឲ្យពួកកំលោះៗ ផ្ទុយនឹងរឿងដែលពោលហើយនោះ តែងតាំងមនុស្សជូច្នោះទុកក្នុងតំណែងអ្នកវិនិច្ឆ័យក្តី មនុស្សក្មេងៗទាំងនោះ មិនដឹងទូទៅដល់រាជកិច្ចនិងការដែលគួរនិងមិនគួរ មិនអាចតម្កល់យសនោះទុកបាន ទាំងមិនអាចចាត់ចែងរាជកិច្ចឲ្យសម្រេចបាន កាលមិនអាចក៏នាំគ្នាបោះបង់ធុរៈការងារចោល ចំណែកអាមាត្យដែលជាបណ្ឌិត កាលមិនបានយសសូម្បីអាចនឹងញ៉ាំងកិច្ចទាំងឡាយឲ្យសម្រេចបាន ក៏នាំគ្នាពោលថា ពួកយើងត្រូវការអ្វីដោយរឿងទាំងនេះ ពួកយើងក្លាយជាមនុស្សខាងក្រៅទៅ

ហើយ ពួកក្មេងកំលោះគេជាមនុស្សនៅក្នុងវង្សត្រកូលគេគង់នឹងដឹង ហើយមិន រក្សាការងារដែលកើតឡើង កាលបើដូច្នោះ សេចក្ដីវិនាសប៉ុណ្ណោះ នឹង មានដល់ព្រះរាជាទាំងនោះដោយប្រការទាំងពួង ដូចពេលដែលពួកជន ចាប់គោស្ទាវៗ ដែលកំពុងហ្វឹកហាត់ មិនទាន់អាចនាំនឹមទៅបាន យកនឹម មកទឹម ហើយជាពេលដែលមិនយកគោធំៗ ដែលធ្លាប់នាំនឹមទៅបាន មកទឹមដូច្នោះ សូម្បីភ័យមានសុបិននេះជាហេតុ ក៏មិនមានដល់មហា-បពិត្រដែរ សូមមហាបពិត្រត្រាស់សួរសុបិនទី ៥ តទៅទៀតចុះ ។

ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គបានសុបិនឃើញសេះមួយមានមាត់ពីរ ពួកជននាំគ្នាឲ្យស្មៅត្រង់ មាត់ទាំងពីរខាងរបស់វា វាស៊ីស្មៅដោយមាត់ទាំងពីរខាង នេះជាសុបិនទី ៥ របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន តើសុបិននេះនឹងមានផលដូច ម្ដេច ?

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះ ក៏ នឹងមានក្នុងរជ្ជកាលនៃព្រះរាជាអ្នកមិនតាំងនៅក្នុងធម៌ ក្នុងអនាគតដែរ ដ្បិតថា ក្នុងអនាគតកាលពួកព្រះរាជាល្ងង់ខ្លៅមិនតាំងនៅក្នុងធម៌ ទ្រង់នឹង តែងតាំងមនុស្សមិននឹងន មិនប្រកបដោយធម៌ទុកក្នុងតំណែងវិនិច្ឆ័យក្ដី មនុស្សទាំងនោះជាបុគ្គលពាល មិនអើពើនឹងបុណ្យបាប អង្គុយក្នុងរោង កាត់ក្ដី កាលកាត់ក្ដីក៏នឹងទទួលសំណូកអំពីដៃរបស់កូនក្ដីទាំងពីរបំណែក

មកស៊ី ដូចសេះស៊ីស្មៅដោយមាត់ទាំងពីរដូច្នោះ ភ័យព្រោះមានសុបិននេះជាហេតុ ក៏រមែងមិនមានដល់មហាបពិត្រឡើយ សូមមហាបពិត្រត្រាស់សួរសុបិនទី ៦ តទៅទៀតចុះ ។

ព្រះរាជាក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គសុបិនឃើញគេដុសខាត់ថាសមាស តម្លៃទាំងសែនកហាបណៈ ហើយនាំគ្នាយកទៅឲ្យចចកចាស់មួយដោយពាក្យថា ចូរអ្នកបន្ទោបង់បស្សាវៈដាក់ថាសមាសនេះចុះ ចចកចាស់នោះ ក៏បន្ទោបង់បស្សាវៈដាក់ថាសមាសនោះ នេះជាសុបិនប្រការទី ៦ របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើនតើផលនៃសុបិននេះដូចម្តេច ?

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មហាបពិត្រ ផលនៃសុបិននេះក៏នឹងមានក្នុងអនាគតដែរ ដ្បិតថា ក្នុងអនាគតពួកព្រះរាជាដែលមិនតាំងនៅក្នុងធម៌ ទ្រង់រង្កៀសកុលបុត្រអ្នកសម្បូរដោយជាតិ ហើយមិនព្រះរាជទានយសឲ្យ ត្រឡប់ជាព្រះរាជទានឲ្យដល់មនុស្សមិនមានត្រកូលប៉ុណ្ណោះ កាលបើដូច្នោះ ត្រកូលធំៗនឹងធ្លាក់ខ្លួនក្រលំបាក ត្រកូលថោកទាបនឹងក្លាយជាត្រកូលខ្ពស់ទៅវិញ កាលពួកអ្នកមានត្រកូលទាំងនោះមិនអាចចិញ្ចឹមជីវិតបាន នឹងគិតថា យើងត្រូវអាស្រ័យពួកទាំងនេះចិញ្ចឹមជីវិត ហើយក៏នាំគ្នាលើកធីតាឲ្យអ្នកមិនមានត្រកូលទាំងនោះ កាលនៅរួមជាមួយនឹងពួកមនុស្សមិនមានត្រកូលរបស់កុលធីតាទាំងនោះ ក៏ដូចជាយក

ថាសមាសត្រង់ទឹកមូត្រចចកដូច្នោះ ភ័យមានសុបិននេះជាហេតុ រមែង មិនមានដល់មហាបពិត្រឡើយ សូមមហាបពិត្រត្រាស់សួរសុបិនទី ៧ ត ទៅទៀតចុះ ។

ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានសុបិន ឃើញយ៉ាងនេះថា បុរសម្នាក់វេញខ្សែហើយសម្រូត (ខ្សែ ) ចុះទៅជិត ជើង មេចចកស្គមស្បែកដណ្តាប់ឆ្អឹងមួយដេកនៅក្រោមតាំងដែលបុរស នោះអង្គុយ ( រង់ចាំ ) ទំពាស៊ីខ្សែនោះ បុរសនោះមិនបានដឹងឡើយ នេះ ជាសុបិនទី ៧ របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន តើផលនៃសុបិន នេះ ដូចម្តេច ?

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មហាបពិត្រ សូម្បីផលនៃសុបិន ប្រការនេះក៏នឹងមានក្នុងអនាគតដែរ ដ្បិតថា ក្នុងកាលខាងមុខ ពួកស្ត្រី នឹងនាំគ្នាឡេះឡោះ មិននឹងនចំពោះបុរស ឈ្ងក់វង្វេងក្នុងសុរា គិតតែពី តែងខ្លួន ចូលចិត្តដើរផ្តេសផ្តាសតាមផ្លូវថ្នល់ ឃើញតែអាមិសៈ ជាស្ត្រី ទ្រុស្តសីល មានការប្រព្រឹត្តិអាក្រក់ក្បត់ចិត្តស្វាមី ស្ត្រីទាំងអស់នោះនឹងរួម គ្នាដណ្តើមយកទ្រព្យដែលស្វាមីធ្វើការងារ មានកសិកម្មនិងគោរក្ខកម្មជា ដើម សន្សំទុកដោយលំបាក យកទៅទិញសុរាផឹកជាមួយនឹងសហាយ ទិញកម្រងផ្កានិងគ្រឿងក្រអូបគ្រឿងលាបមកតែងខ្លួន រង់ចាំមើលសហាយ របស់ខ្លួនខាងលើផ្ទះដែលជិតខ្លះ ក្នុងទីកំបាំងក្នែកខ្លះ សូម្បីស្រូវដែល

ត្រៀមទុកសម្រាប់ព្រោះថ្ងៃស្អែក ក៏យកទៅបុកចាក់ចែងដាំបបរ ដាំបាយ និងរបស់គួរទំពាស៊ីជាដើម យកមកស៊ីជាមួយនឹងសហាយ ដូចមេចចក ស្គមដែលដេកក្រោមតាំង រង់ចាំទំពាស៊ីខ្សែដែលគេវេញហើយ សម្រូត ចុះទៅជិតៗជើងដូច្នោះ ភ័យដែលមានសុបិននេះជាហេតុ មិនមានដល់ មហាបពិត្រទេ សូមមហាបពិត្រត្រាស់សួរសុបិនទី ៨ តទៅទៀតចុះ ។

ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានសុបិន ឃើញពាងទឹកមួយធំ ពេញប្រៀបដោយទឹកនៅចំកណ្តាល ហើយមាន ពាងទទេតូចៗជាច្រើននៅព័ទ្ធជុំវិញ មហាជនមកពីទិសទាំង៨ នាំគ្នាយក ផ្ទាំងដងទឹកចាក់ពាងធំដែលមានទឹកពេញហើយនោះ ទឹកក៏ហៀរហូរចេញ ទៅ សូម្បីដូច្នោះគេក៏នៅតែនាំគ្នាដងទឹកចាក់ពាងធំដែលពេញហើយនោះ ដដែល ដោយមិនរវល់មើល មិនចាក់ទឹកដាក់ទៅក្នុងពាងទទេតូចៗនោះ សោះឡើយ នេះជាសុបិនទី៨ របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន តើសុបិននេះនឹងប្រាកដផលដូចម្តេចដែរ ?

ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់តបថា មហាបពិត្រ ផលនៃសុបិននេះ នឹងមានក្នុងអនាគតដូចគ្នា ដ្បិតថា ក្នុងអនាគតលោកនឹងសាបសូន្យ ដែនទាំងឡាយ មិនមានច្បាប់ទម្លាប់ ព្រះរាជាធ្លាក់ខ្លួនក្រីក្រ ស្តេចណា បានជាធំ ស្តេចនោះមានទ្រព្យយ៉ាងច្រើនត្រឹមតែ ១ សែនកហាបណៈ ក្នុងព្រះរាជឃ្លាំងប៉ុណ្ណោះ ។ ស្តេចទាំងនោះ កាលក្រលំបាកយ៉ាងនេះ ក៏

កេណ្ឌអ្នកជនបទឲ្យធ្វើស្រែធ្វើចម្ការដើម្បីព្រះអង្គ ពួកមនុស្សមិនបានធ្វើការងាររបស់ខ្លួន រវល់តែសាបព្រោះនូវបុព្វន្នជាតិ មានស្រូវសាលីជាដើម និងអបរន្នជាតិ មានសណ្តែកលូជាដើម ហើយច្រូតកាត់បោកបែន ជញ្ជូនមកដាក់ក្នុងជង្រុករបស់ព្រះរាជាប៉ុណ្ណោះ មិនបានសម្លឹងមើលជង្រុកទទេក្នុងផ្ទះទាំងឡាយរបស់ខ្លួនឡើយ ដូចជាការយកទឹកទៅចាក់ក្នុងពាងដែលមានទឹកពេញហើយ មិនចាក់ក្នុងពាងដែលមិនមានទឹកដូច្នោះ ភ័យដែលមានសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រទេ សូមមហាបពិត្រត្រាស់សួរសុបិនទី ៩ តទៅទៀតចុះ ។

ព្រះរាជាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានសុបិនឃើញស្រះបោក្ខរណីមួយដេរដាសទៅដោយផ្កាឈូក ៥ ពណ៌ ស្រះនោះមានទឹកជ្រៅត្រង់កណ្តាល មានកំពង់សម្រាប់ចុះឡើងជុំវិញ ពួកសត្វទ្វេបាទ ចតុបាទតែងនាំគ្នាចុះផឹកទឹកក្នុងស្រះនោះដោយជុំវិញ ប៉ុន្តែចម្ងៃកត្រង់កណ្តាលស្រះដែលមានទឹកជ្រៅនោះ ត្រឡប់ជាល្អក់ទៅវិញ ចំណែកទឹកខាងៗជុំវិញស្រះ បែរជាថ្លាស្អាតមិនកករល្អក់ទៅវិញ ខ្ញុំព្រះអង្គបានសុបិនឃើញយ៉ាងនេះ នេះជាសុបិនទី ៩ របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន តើសុបិននេះនឹងប្រាកដផលដូចម្តេចដែរ ?

ព្រះបរមសាស្តាទ្រង់ត្រាស់តបថា មហាបពិត្រ ផលនៃសុបិននេះនឹងមានក្នុងអនាគតដែរ ដ្បិតថា ក្នុងកាលខាងមុខ ព្រះរាជាទាំងឡាយ

នឹងមិនតាំងនៅក្នុងធម៌ លុះក្នុងអំណាចនៃអគតិ មានឆន្ទាគតិជាដើម នឹងមិនព្រះរាជទានការវិនិច្ឆ័យក្ដីដោយធម៌ មានព្រះទ័យប្រាថ្នាតែសំណូក គិតតែប្រយោជន៍ផ្ទាល់ខ្លួន ឡេះឡោះក្នុងទ្រព្យសម្បត្តិ មិនមានសេចក្ដីអត់ធន់ មេត្តា ករុណា ដល់ប្រជារាស្ត្រឡើយ តែងតែគាបសង្កត់រឹបជាន់យកពន្ធដារអាករច្រើនហួសប្រមាណ ដូចជាគេគាបយកទឹកអំពៅដោយឃ្នាបយន្តដូច្នោះ ពួកប្រជារាស្ត្រទ្រាំមិនបានក៏នាំគ្នារត់គេចចេញពីនគរ ពីទីប្រជុំ ទៅសម្ងំនៅតាមតំបន់ជាយដែនណែនណាន់តាន់តាប់ ដូចទឹកស្រះបោក្ខរណីល្អក់ត្រង់កណ្ដាលថ្លាខាងជុំវិញដូច្នោះដែរ ភ័យមានសុបិននេះជាហេតុ រមែងមិនមានដល់មហាបពិត្រឡើយ សូមមហាបពិត្រត្រាស់សួរសុបិនទី ១០ តទៅទៀតចុះ ។

ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានសុបិនឃើញបាយដែលមនុស្សដាំក្នុងឆ្នាំងតែមួយ តែមិនឆ្អិនទាំងអស់ទេ អ្នកដាំពិនិត្យមើលឃើញថា មិនឆ្អិនដោយចំណែក ៣ យ៉ាង គឺ ខ្ជោចមួយចំណែក ឆៅមួយចំណែក ឆ្អិនល្អមួយចំណែក ( បាយមួយឆ្នាំង ឆ្អិនក៏មាន ឆៅក៏មាន ជ្រាយក៏មាន នៅក្នុងឆ្នាំងតែមួយនោះ ) នេះជាសុបិនទី ១០ របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន តើសុបិននេះនឹងមានផលដូចម្ដេច ?

ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់តបថា មហាបពិត្រ ផលនៃសុបិននេះ

នឹងមានក្នុងអនាគតដែរ ដ្បិតថា ក្នុងកាលខាងមុខព្រះរាជាទាំងឡាយនឹងមិនតាំងនៅក្នុងធម៌ មិនមានទសពិធរាជធម៌ កាលព្រះរាជាទាំងនោះមិនតាំងនៅក្នុងធម៌ហើយ អ្នករាជការក្ដី ព្រាហ្មណ៍និងគហបតីក្ដី អ្នកនិគមនិងអ្នកជនបទក្ដី រហូតដល់ទេវតាក៏មិនតាំងនៅក្នុងធម៌ សូម្បីតែសមណ-ព្រាហ្មណ៍ក៏មិនប្រព្រឹត្តធម៌វិន័យដែរ ក្នុងរដ្ឋកាលនៃអធម្មិករាជទាំង-ឡាយដែលមានសភាពដូច្នេះ ជាហេតុធ្វើឲ្យខ្យល់ទាំងឡាយបក់មិនស្មើ បក់ខ្លាំងពេក ធ្វើឲ្យវិមានក្នុងអាកាសរបស់ទេវតាញាប់ញ័រ កាលវិមានទាំងនោះត្រូវខ្យល់បក់ឲ្យញាប់ញ័រ ពួកទេវតាក៏ខឹងក្រោធ ហើយមិនឲ្យភ្លៀងធ្លាក់ ទោះបីឲ្យភ្លៀងធ្លាក់ ក៏មិនធ្លាក់សព្វដែន និងមិនធ្លាក់ឲ្យជាឧបការៈដល់ការងារ មានការសាបព្រោះក្នុងទីទាំងពួងឡើយ ។ សូម្បីក្នុងជនបទ ក្នុងស្រុក ក្នុងត្រពាំងមួយ ក្នុងស្រះតូចមួយ ក៏ដូចក្នុងដែនដែរ កាលធ្លាក់ក្នុងទីទួលក៏មិនធ្លាក់ក្នុងទីទំនាប កាលធ្លាក់ក្នុងទីទំនាបក៏មិនធ្លាក់ក្នុងទីទួល សន្ទូងមួយផ្នែកនឹងខូចព្រោះលិចទឹក កាលភ្លៀងមិនធ្លាក់ក្នុងផ្នែកមួយ សន្ទូងនឹងស្វិតស្រពោន កាលភ្លៀងធ្លាក់ល្អក្នុងផ្នែកមួយ សន្ទូងក៏លូតលាស់ល្អ ស្រូវដែលសាបព្រោះហើយក្នុងដែនសីមារបស់ព្រះរាជាតែមួយនឹងជា ៣ ស្ថានដោយប្រការដូច្នេះ ដូចបាយក្នុងឆ្នាំងតែមួយមានផល ៣ យ៉ាងដូច្នោះ ។ ភ័យមានសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រទេ សូមមហាបពិត្រ ត្រាស់សួរសុបិនទី ១១ តទៅទៀតចុះ ។

ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានសុបិនឃើញមនុស្សទាំងឡាយយកខ្លឹមចន្ទន៍ ដែលជាវត្ថុមានតម្លៃរាប់សែនកហាបណៈ ទៅដូរយកទឹកដោះផ្អូមស្អុយ នេះជាសុបិនទី ១១ របស់ខ្ញុំព្រះអង្គ បពិត្រព្រះដ៏មានព្រះភាគ តើសុបិននេះមានផលដូចម្តេច ?

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា មហាបពិត្រ សូម្បីផលនៃសុបិននេះ ក៏នឹងមានក្នុងអនាគតដែរ គឺក្នុងកាលសាសនាតថាគតសាបសូន្យនោះឯង ដ្បិតថា ក្នុងកាលខាងមុខ ពួកភិក្ខុអលជ្ជី អ្នកមិនខ្មាសបាប មិនខ្លាចបាប ជាអ្នកឃើញតែអំពីបច្ច័យនឹងមានច្រើន ភិក្ខុអ្នកមិនខ្មាសបាប មិនខ្លាចបាបទាំងនោះ នឹងនាំគ្នាសម្តែងធម៌ទេសនាដែលតថាគតសម្តែងហើយដោយល្អ ដើម្បីព្រះនិព្វាន ដើម្បីរំលត់ទុក្ខ ពោលតិះដៀលអំពីការល្មោភក្នុងបច្ច័យដល់បរិស័ទទាំងឡាយ ព្រោះហេតុតែបច្ច័យបួនមានចីវរៈជាដើម នឹងមិនអាចសម្តែងឲ្យផុតអំពីបច្ច័យទាំងឡាយហើយតាំងនៅក្នុងចំណែកនៃធម៌ដែលនាំសត្វឲ្យរួចផុតចាកទុក្ខ ឆ្ពោះទៅកាន់ព្រះនិព្វានឡើយ ជនទាំងឡាយក៏នឹងស្តាប់ធម៌ដែលសម្បូរដោយបទនិងព្យញ្ជនៈហើយ ពីរោះជាប់ចិត្តតែម្យ៉ាងប៉ុណ្ណោះ ហើយនឹងប្រគេនខ្លួនឯងថែមទាំងញុំាងអ្នកដទៃឲ្យប្រគេននូវបច្ច័យទាំងឡាយ មានចីវរបច្ច័យជាដើម ដែលមានតម្លៃថ្លៃ ។ ភិក្ខុទាំងឡាយមួយពួកទៀត នឹងនាំគ្នាអង្គុយ

ទីផ្សេងៗ មានចិញ្ចើមថ្នល់ ផ្លូវបែកជាបួន និងក្បែរទ្វារវាំងជាដើម ហើយសម្តែងធម៌ដ៏ប្រសើរនោះ ដូរយករូបិយៈ មានកន្ទះកហាបណៈ មួយបាទ ឬមួយមាសកៈជាដើម ដោយប្រការដូច្នេះ ក៏យកធម៌ដែលតថាគតសម្តែងទុកដោយល្អហើយ ដែលមានតម្លៃគួរដល់ព្រះនិព្វាន ទៅសម្តែងកែច្នៃរកបច្ច័យបួននិងរូបិយៈជាដើម ដូចមនុស្សទាំងឡាយយកខ្លឹមចន្ទន៍ដែលជាវត្ថុមានតម្លៃរាប់សែនទៅដូរយកទឹកដោះផ្អូមស្អុយដូច្នោះ ភ័យដែលមានសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រទេ សូមមហាបពិត្រត្រាស់សួរសុបិនទី ១២ តទៅទៀតចុះ ។

ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានសុបិនឃើញផ្លែឃ្លោកដែលគេយកបណ្តូលចេញហើយ វាជាវត្ថុស្រាលណាស់ ត្រូវអណ្តែតទឹក ប៉ុន្តែវាត្រឡប់ជាលិចទឹកទៅវិញ នេះជាសុបិនទី ១២ របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន តើសុបិននេះមានផលដូចម្តេចដែរ ?

ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់តបថា មហាបពិត្រ ផលនៃសុបិននេះក៏នឹងមានក្នុងអនាគត កាលលោកនេះវិលទៅដល់ចំណុចវិនាស ក្នុងរជ្ជកាលនៃព្រះរាជាដែលប្រាសចាកគុណធម៌ មិនតាំងនៅក្នុងធម៌ ដ្បិតថាក្នុងកាលនោះព្រះរាជាទាំងឡាយ នឹងមិនព្រះរាជទានយសដល់កុលបុត្រដែលសម្បូរដោយជាតិ ទ្រង់ព្រះរាជទានយសដល់អ្នកដែលមិនមានពូជ-

ពង្សវង្សត្រកូលខ្ពង់ខ្ពស់ប៉ុណ្ណោះ ពួកនោះនឹងជាធំ មួយផ្នែកទៀតនឹងជាអ្នកក្រលំបាក ពាក្យសម្ដីរបស់អ្នកមានត្រកូលខ្ពង់ខ្ពស់ គេមិនយកទៅប្រើការទេ ត្រូវគេបោះបង់ចោលដូចឃ្លោកលិចទឹក ត្រូវគេមើលងាយក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ក្បែរខ្លោងទ្វាររាំង ទីប្រជុំអាមាត្យ ឬនៅក្នុងរោងកាត់ក្ដីជាដើម សូម្បីក្នុងសង្ឃសន្និបាត (ទីប្រជុំសង្ឃ) ក៏ដូច្នោះដែរ ឬក្នុងកិច្ចកម្មដែលសង្ឃគប្បីធ្វើឬគណៈគប្បីធ្វើក្ដី ទាំងក្នុងការវិនិច្ឆ័យអធិករណ៍ទាក់ទងនឹងបាត្រចីវរ និងបរិវេណជាដើមក្ដី ពាក្យសម្ដីរបស់ភិក្ខុអាក្រក់ទ្រុស្ដសីលប៉ុណ្ណោះ នឹងជាពាក្យនាំសត្វចេញចាកទុក្ខបាន មិនមែនពាក្យរបស់ភិក្ខុលជ្ជី គឺភិក្ខុអ្នកមានសីលបរិសុទ្ធទេ កាលបើដូច្នេះ ក៏ដូចជាការលិចចុះនៃឃ្លោក ដោយប្រការទាំងពួង ភ័យមានសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រទេ សូមមហាបពិត្រត្រាស់សួរសុបិនទី ១៣ តទៅទៀតចុះ ។

ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានសុបិនឃើញដុំថ្មតាន់ប៉ុនផ្ទះកំពូល អណ្ដែតដូចទូក នេះជាសុបិនទី ១៣ របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន តើសុបិននេះនឹងប្រាកដផលដូចម្ដេចដែរ?

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់តបថាមហាបពិត្រ ផលនៃសុបិនមួយនេះក៏នឹងមានក្នុងកាលអនាគតដែរ ដ្បិតថា ក្នុងកាលនោះ ព្រះរាជាដែល

មិនតាំងនៅក្នុងធម៌ទាំងឡាយ នឹងព្រះរាជទានយសឲ្យដល់មនុស្សថោក-ទាប ដែលចូលចិត្តប្រចុបប្រចែង អែបអប មានចរិយាមិនថ្លៃថ្នូរ ឲ្យធ្វើជាមន្ត្រី ពួកនោះនឹងបានឡើងជាធំ ពួកអ្នកមានត្រកូលខ្ពង់ខ្ពស់មិនមានយសស័ក្តិ ធ្លាក់ខ្លួនជាមនុស្សថោកទាប គ្មានអ្នកណាគោរពកោតក្រែងជឿពាក្យសម្ដីឡើយ នឹងគោរពកោតក្រែងតែមន្ត្រីដែលមានត្រកូលថោកទាបប៉ុណ្ណោះ ពាក្យសម្ដីរបស់កុលបុត្រដែលឈ្លាសវៃក្នុងការវិនិច្ឆ័យ ដែលធ្ងន់ក្នុងធម៌ដូចដុំថ្មតាន់ នឹងមិនឈមចុះតាំងមាំក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ឬក្នុងទីប្រជុំអាមាត្យ ឬក្នុងសាលប្រជុំ កាលពួកបណ្ឌិតកំពុងពោល ពួកក្រៅពីនេះនឹងពោលពាក្យចំអកចំអន់ថា ពួកនេះនិយាយអ្វី សូម្បីក្នុងទីប្រជុំសង្ឃ ពួកភិក្ខុក៏នឹងមិនឃើញភិក្ខុអ្នកមានសីលជាទីស្រឡាញ់ អ្នកគួរគោរពថាជាសំខាន់ឡើយ ក្នុងឋានៈផ្សេងៗដូចពោលមកនេះ ទាំងពាក្យសម្ដីរបស់ភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងនោះ ក៏នឹងមិនធ្ងន់ ដូចដុំថ្មតាន់អណ្ដែតដូច្នោះ ភ័យដែលមានសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រឡើយ សូមមហាបពិត្រត្រាស់សួរសុបិនទី ១៤ តទៅទៀតចុះ ។

ព្រះបាទបសេនទិកោសលក្រាបទូលសុបិនទី ១៤ ថា បពិត្រព្រះ-អង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានសុបិនឃើញហ្វូងកូនកង្កែបតូចៗ ប៉ុនផ្កាស្រគំដេញតាមខាំហ្វូងពស់វែកយ៉ាងរហ័ស ខាំស៊ីៗ នេះជាសុបិនទី ១៤ របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន តើសុបិននេះនឹងប្រាកដផលដូចម្ដេច

ដែរ ?

ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់តបថា មហាបពិត្រ ផលនៃសុបិននេះ នឹងមានក្នុងអនាគត គឺក្នុងកាលលោកសាបសូន្យចុះដូចគ្នា ដ្បិតថា ក្នុងគ្រានោះ ពួកមនុស្សនឹងមានរាគចរិតខ្លាំង ជាតិអាក្រក់ បណ្ដោតបណ្ដោយខ្លួន បណ្ដោតបណ្ដោយចិត្តតាមអំណាចរបស់កិលេស នឹងត្រូវប្រព្រឹត្តទៅតាមអំណាចនៃភរិយាក្មេងៗរបស់ខ្លួន អ្នកមានទាសកម្មករជាដើមក្តី សត្វពាហនៈមានគោក្របីជាដើមក្តី មាសប្រាក់ក្តី ដែលមានក្នុងផ្ទះគ្រប់យ៉ាងនឹងនៅក្នុងការគ្រប់គ្រងរបស់ពួកនាងទាំងអស់ កាលពួកស្វាមីសួរដល់មាសប្រាក់ឯណោះៗ ថានៅទីណា ឬសួរដល់ចំនួនថា មានប៉ុន្មានក្តី ពួកនាងនាំគ្នាតបថា វានៅទីណាក៏ដោយ មិនចាំបាច់មកត្រួតត្រា លោកចង់ដឹងរបស់មានឬមិនមានក្នុងផ្ទះរបស់យើងអីចឹងឬ ? ហើយនឹងជេរដោយប្រការផ្សេងៗ ចាក់ដោតដោយលំពែងគឺមាត់ សង្កត់សង្កិនទុកក្នុងអំណាចដូចជាទាសៈនិងអ្នកស៊ីឈ្នួល តាំងភាពជាម្ចាស់ជាធំរបស់ខ្លួនទុកបន្តទៅ ដូចវេលាដែលកូនកង្កែបប៉ុនផ្កាស្រគំ នាំគ្នាដេញខាំស៊ីហ្វូងពស់វែកដែលមានពិសយ៉ាងខ្លាំងក្លាដូច្នោះ ភ័យដែលមានសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រឡើយ សូមមហាបពិត្រត្រាស់សួរសុបិនទី ១៥ តទៅទៀតចុះ ។

ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំ

ព្រះអង្គបានសុបិនឃើញរាជហង្សមាស ដែលមានឈ្មោះថា មាស ព្រោះមានរោមពណ៌ដូចមាស នាំគ្នាហែហមក្អែកដែលប្រកបដោយអសទ្ធម្ម ១០ ប្រការដែលត្រាច់រកស៊ីក្នុងភូមិស្រុក នេះជាសុបិនទី ១៥ របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន តើសុបិននេះនឹងប្រាកដផលដូចម្ដេចដែរ ?

ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់តបថា មហាបពិត្រ ផលនៃសុបិននេះក៏នឹងមានក្នុងអនាគតកាលដែរ គឺក្នុងរជ្ជកាលនៃព្រះរាជាល្ងង់ខ្លៅ ដ្បិតថាក្នុងអនាគតព្រះរាជាទាំងឡាយមិនមានចំណេះវិជ្ជា មិនឈ្លាសក្នុងសិល្បៈមានហត្ថីសិល្បៈជាដើម មិនក្លាហាន មិនមានសមត្ថភាពក្នុងយុទ្ធសិល្ប៍ជាដើម ព្រះរាជាទាំងនោះនឹងមិនតែងតាំងកុលបុត្រដែលមានជាតិស្មើគ្នាឲ្យមានបុណ្យស័ក្តិធំដុំអ្វីទេ ព្រោះរង្កៀសការវិបត្តិនៃរាជសម្បត្តិរបស់ព្រះ-អង្គ នឹងតែងតាំងពួកអ្នកកើតក្នុងត្រកូលថោកទាប (មានពួកអ្នកចាត់ចែងទឹកស្រង់ និងអ្នកកោរពុកមាត់ ពុកចង្កាជាដើម ) ដែលរស់នៅក្រោមបាទ-មូលរបស់ព្រះអង្គ (ឲ្យមានបុណ្យស័ក្តិធំដុំទៅវិញ កាលបើយ៉ាងនេះ អ្នកកើតក្នុងត្រកូលខ្ពស់ទាំងឡាយ ) មិនអាចនឹងចិញ្ចឹមជីវិតបានស្រួល ( ត្រូវតែទៅអែបអបអ្នកមានត្រកូលទាប តែមានបុណ្យសក្តិ មានឫទ្ធិអំណាច ) ពួកកុលបុត្រអ្នកសម្បូរដោយជាតិនិងគោត្ត កាលមិនបានទីពឹងក្នុងរាជ-ត្រកូល ក៏នឹងនាំគ្នាប្រតិបត្តិទំនុកបម្រុងពួកជនដែលមិនមានត្រកូល មានជាតិនិងគោត្តថោកទាបដែលមានឥស្សរិយយស ដូចជារាជហង្សហែហម

ក្អែកដូច្នោះ ភ័យដែលមានសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រឡើយ សូមមហាបពិត្រត្រាស់សួរសុបិនទី ១៦ តទៅទៀតចុះ ។

ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលមុនៗ ខ្លាដំបងនាំគ្នាខាំស៊ីហ្វូងពពែ តែខ្ញុំព្រះអង្គសុបិនឃើញហ្វូងពពែដេញខាំខ្លាដំបងត្របាក់ស៊ីក្នុងទីនោះៗ ខ្លាដទៃៗ គឺខ្លាធំ ខ្លារខិន ឃើញហ្វូងពពែអំពីចម្ងាយ ក៏ភ័យខ្លាចដល់នូវភាពតក់ស្លុត នាំគ្នារត់ពួនតាមគុម្ពឈើ ព្រៃស្បាត ញកភ្នំ ព្រោះខ្លាចហ្វូងពពែ នេះជាសុបិនទី ១៦ របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន តើផលនៃសុបិននេះ នឹងប្រាកដផលដូចម្ដេចដែរ ?

ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់តបថា មហាបពិត្រ សូម្បីផលនៃសុបិននេះ ក៏នឹងមានក្នុងរជ្ជកាលនៃព្រះរាជាដែលមិនតាំងនៅក្នុងធម៌ ក្នុងអនាគតកាលដែរ ដ្បិតថា ក្នុងកាលនោះ ពួកមនុស្សដែលមិនមានត្រកូលនឹងក្លាយជារាជវល្លភៈ ( គឺអ្នកស្និទ្ធស្នាលនឹងព្រះរាជា ) ជាធំ ជាប្រធាន ពួកមនុស្សដែលមានត្រកូលនឹងក្លាយជាអ្នកក្រីក្រលំបាក រាជវល្លភៈទាំងនោះ ញុំាងព្រះរាជាឲ្យជឿសម្ដីរបស់ខ្លួន មានកម្លាំងក្នុងស្ថានទីរាជការ មានសាលាប្រជុំជាដើម ហើយនាំគ្នាដណ្ដើមយកដីចម្ការ ដីស្រែ ទូក សួន ជាដើម ដែលជាមរតករបស់ពួកអ្នកមានត្រកូលទាំងឡាយថា ទីនេះជារបស់យើង កាលពួកអ្នកមានត្រកូលប្រកែកតវ៉ាថា ទីនេះមិនមែនជារបស់

ពួកលោកទេ ជារបស់ពួកយើង ហើយក៏នាំគ្នាស្រែកទាមទារនៅសាលាប្រជុំជាដើម ពួករាជវល្លភៈក៏នាំគ្នាប្រាប់ឲ្យដាក់ខ្នោះវាយដោយផ្តៅជាដើម ចាប់ក្របួចកអូសចេញទៅព្រមនឹងបណ្តេញគំរាមថា ពួកឯងមិនស្គាល់ប្រមាណខ្លួនមករករឿងនឹងពួកយើង ប្រញាប់ទៅទូលព្រះរាជាឲ្យដាក់អាជ្ញាផ្សេងៗ មានកាត់ជើងកាត់ដៃជាដើម ពួកអ្នកមានត្រកូលខ្លាចក្រែង ពួករាជវល្លភៈ ក៏នាំគ្នាយល់ព្រមឲ្យទីដីរបស់ខ្លួនថា ទីដីទាំងនេះ បើជារបស់ពួកលោក ក៏អញ្ជើញពួកលោកគ្រប់គ្រងចុះ ហើយក៏ត្រឡប់មកផ្ទះរបស់ខ្លួនដេកទាំងខ្លាចញញើតរៀងៗខ្លួន ។ ឯភិក្ខុអាក្រក់ទាំងឡាយ ក៏នាំគ្នាបៀតបៀនភិក្ខុអ្នកមានសីលជាទីស្រឡាញ់តាមពេញចិត្ត ពួកភិក្ខុអ្នកមានសីលជាទីស្រឡាញ់ទាំងនោះមិនបានទីពឹង ក៏នាំគ្នាចូលព្រៃ ពួនសម្ងំក្នុងទីស្ងាត់ ។ ការដែលអ្នកមានត្រកូលនិងភិក្ខុអ្នកមានសីលជាទីស្រឡាញ់ ត្រូវមនុស្សជាតិអាក្រក់និងភិក្ខុលាមកទាំងឡាយ ចូលទៅប្រទូស្តយ៉ាងនេះ ក៏ដូចជាការដែលពួកខ្លាដំបងនិងខ្លាធំទាំងឡាយនាំគ្នារត់គេច ព្រោះខ្លាចហ្វូងពពែដូច្នោះ ភ័យមានសុបិននេះជាហេតុ នឹងមិនមានដល់មហាបពិត្រឡើយ ដ្បិតថា សុបិនដែលមហាបពិត្រឃើញហើយប្រារព្ធអនាគតទាំងអស់ ប៉ុន្តែពួកព្រាហ្មណ៍មិនបានទាយសុបិននេះ ដោយភក្តីភាពចំពោះមហាបពិត្រឡើយ ទាយព្រោះអាស្រ័យការចិញ្ចឹមជីវិតជាហេតុ ឃើញតែអាមិសៈប៉ុណ្ណោះថា ពួកយើងនឹងបានទ្រព្យច្រើនៗ លុះទ្រង់ព្យាករផល

នៃមហាសុបិន ១៦ ប្រការយ៉ាងនេះហើយ ទើបទ្រង់ត្រាស់បន្តទៀតថា មហាបពិត្រ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលមហាបពិត្រ បានឃើញសុបិនទាំងនេះ សូម្បីព្រះរាជាទាំងឡាយអំពីកាលមុនក៏ទ្រង់ បានឃើញហើយដែរ សូម្បីពួកព្រាហ្មណ៍ក្នុងកាលនោះ ក៏កាន់យកសុបិន ទាំងនេះរាប់បញ្ចូលក្នុងកំពូលយញ្ញវិធីយ៉ាងនេះដែរ ក្រោយមកអាស្រ័យ ពាក្យណែនាំដែលពួកបណ្ឌិតនាំគ្នាក្រាបទូល ទើបសួរព្រះបរមពោធិសត្វ ឯបុរាណកបណ្ឌិតទាំងឡាយ កាលនឹងព្យាករសុបិនទាំងនេះថ្វាយព្រះ-រាជាទាំងនោះ ក៏នាំគ្នាព្យាករតាមទំនងនេះឯង ។ កាលព្រះបាទបសេនទិ-កោសលក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូច តទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុង នគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ចម្រើនវ័យហើយ បួសជាឥសី ញុំាងអភិញ្ញាសមាបត្តិឲ្យកើតឡើងហើយ ជាអ្នកលេងឈាននៅក្នុងព្រៃហេមពាន្ត ។ គ្រានោះ នៅក្នុងនគរពារាណសី ព្រះបាទព្រហ្មទត្តទ្រង់ឃើញព្រះសុបិនទាំងនេះ ដោយមានទំនងដូច មហាសុបិនដែលព្រះបាទបសេនទិកោសលទ្រង់ឃើញដែរ ទ្រង់ត្រាស់សួរ ពួកព្រាហ្មណ៍ ពួកព្រាហ្មណ៍ប្រារព្ធនឹងបូជាយញ្ញយ៉ាងនោះដែរ ។ បណ្ដា ព្រាហ្មណ៍ទាំងនោះ ព្រាហ្មណ៍បុរោហិតម្នាក់ មានសិស្សជាបណ្ឌិតឈ្មោស-

វៃ កូនសិស្សនោះពោលនឹងអាចារ្យដែលជាព្រាហ្មណ៍ថា បពិត្រលោកអាចារ្យ គម្ពីរវេទទាំង ៣ នោះ ប្រការដែលថាការសម្លាប់សត្វមួយហើយធ្វើឲ្យកើតសិរីសួស្តីដល់សត្វមួយទៀត មិនមានឡើយ មិនមែនឬ?

អាចារ្យឆ្លើយថា នែបា ដោយឧបាយនេះ ទ្រព្យចំនួនច្រើននឹងកើតមានដល់ពួកយើង ឯងប្រហែលជាចង់រក្សាព្រះរាជ្យទ្រព្យទេដឹង?

មាណពពោលថា បពិត្រលោកអាចារ្យ បើដូច្នោះ សូមលោកធ្វើការងាររបស់លោកទៅចុះ ខ្ញុំនឹងធ្វើអ្វីក្នុងសម្នាក់ពួកលោកបាន ហើយធ្វើដំណើរចេញអំពីទីនោះទៅរហូតដល់ព្រះរាជឧទ្យាន ។ ក្នុងថ្ងៃនោះឯងព្រះបរមពោធិសត្វក៏ដឹងហេតុនោះ លោកគិតថា ថ្ងៃនេះកាលអញធ្វើដំណើរទៅកាន់ភូមិមនុស្ស ការផុតអំពីចំណងនឹងមានដល់មហាជនដូច្នេះហើយ ទើបហោះមកតាមអាកាស ចុះក្នុងព្រះរាជឧទ្យាន គង់លើផ្ទាំងសិលាដែលជាមង្គលដូចបដិមាមាសដូច្នោះ ។ មាណពចូលទៅរកព្រះ-បរមពោធិសត្វថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរ ។ ចំណែកតាបស-ពោធិសត្វក៏បានធ្វើបដិសណ្ឋារៈដោយសំឡេងដ៏ពីរោះ ហើយសួរថា នែមាណព យ៉ាងដូចម្តេចដែរ ព្រះរាជានៅសោយរាជសម្បត្តិប្រកបដោយធម៌ទេឬ ?

មាណពឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះរាជានៅមានព្រះនាមថាធម្មិករាជដដែល ក៏ប៉ុន្តែ ពួកព្រាហ្មណ៍កំពុងដឹកនាំព្រះអង្គឲ្យ

ដើរផ្លូវខុស ព្រះរាជាទ្រង់ឃើញព្រះសុបិន ១៦ ប្រការ ត្រាស់ប្រាប់ពួកព្រាហ្មណ៍ ពួកព្រាហ្មណ៍ពោលថា ពួកយើងនឹងត្រូវបូជាយញ្ញហើយត្រៀមការបូជាភ្លាម បពិត្រលោកម្ចាស់ដ៏ចម្រើន ការដែលលោកម្ចាស់ធ្វើឲ្យព្រះរាជាទ្រង់យល់ថា ផលនៃសុបិននេះ យ៉ាងនេះ ហើយជួយមហាជនឲ្យរួចផុតអំពីភ័យ មិនគួរទេឬ?

ព្រះបរមពោធិសត្វពោលថា នែមាណព យើងក៏មិនស្គាល់ព្រះរាជា ព្រះរាជាក៏ទ្រង់មិនស្គាល់យើង ប្រសិនបើព្រះអង្គយាងមកសួរនៅទីនេះ យើងអាចប្រាប់ព្រះរាជាបាន ។

មាណពពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំនឹងនាំព្រះរាជាមកកាន់ទីនេះ សូមលោកម្ចាស់មេត្តាអង្គុយរង់ចាំនៅទីនេះមួយភ្លែត ។ កូនសិស្សនោះសូមឲ្យព្រះបរមពោធិសត្វប្ដេជ្ញាហើយ ក៏ទៅកាន់ព្រះរាជដំណាក់ក្រាបទូលព្រះរាជាថា បពិត្រមហារាជ មានតាបសអ្នកត្រាច់ទៅក្នុងអាកាសបានមួយរូប ហោះចុះមកក្នុងឧទ្យានរបស់ព្រះអង្គ ពោលថានឹងព្យាករផលនៃសុបិនដែលទ្រង់ឃើញហើយ ពេលនេះកំពុងរង់ចាំព្រះអង្គ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវពាក្យរបស់មាណពនោះភ្លាម ក៏ប្រញាប់យាងទៅកាន់ព្រះរាជឧទ្យានដោយបរិវារដ៏ច្រើន ទ្រង់ថ្វាយបង្គំតាបសហើយគង់ក្នុងទីដ៏សមគួរ រួចមានព្រះតម្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន បានឮថា លោកម្ចាស់ដឹងផលនៃសុបិនដែលខ្ញុំឃើញឬ?

ព្រះបរមពោធិសត្វឆ្លើយថា ថ្វាយព្រះពរមហាបពិត្រ អាត្មាភាពដឹង ។

ព្រះរាជាត្រាស់ថា បើដូច្នោះ និមន្តលោកម្ចាស់ព្យាករចុះ ។

ព្រះបរមពោធិសត្វពោលថា ថ្វាយព្រះពរមហាបពិត្រ អាត្មាភាពនឹងព្យាករថ្វាយ សូមមហាបពិត្រត្រាស់ប្រាប់ព្រះសុបិនតាមដែលទ្រង់បានឃើញហើយឲ្យអាត្មាភាពស្តាប់ចុះ ។ ព្រះរាជាត្រាស់ថា សាធុលោកម្ចាស់ហើយត្រាស់ប្រាប់ព្រះសុបិនថា

គោឧសភរាជ ១ ឈើទាំងឡាយ ១ មេគោទាំងឡាយ ១
គោឈ្មោលទាំងឡាយ ១ សេះ ១ ភាជន៍ (មាស) ១
មេចចក ១ ក្អម ១ ស្រះបោក្ខរណី ១ បាយឆៅ ១
ខ្លឹមចន្ទន៍ ១ ផ្លែឃ្លោកទាំងឡាយលិច ១ ថ្មទាំងឡាយ-
អណ្តែត ១ មេកង្កែបទាំងឡាយខាំពស់វែកទាំងឡាយ ១
រាជហង្សមាសទាំងឡាយ ចោមរោមក្អែកទាំងឡាយ ១
សត្វខ្លាទាំងឡាយ ( រត់ទៅ ) ព្រោះភ្ញាក់ផ្អើលដោយ
សេចក្តីខ្លាចអំពីសត្វពពែទាំងឡាយ ១ បរិយាយចម្លែក
ប្រព្រឹត្តទៅ ន័យទាំងឡាយមាននៅក្នុងសុបិនទាំងនេះ ។

ព្រះរាជាត្រាស់ប្រាប់ព្រះសុបិនតាមនិយមដែលព្រះបាទបសេនទិកោសលត្រាស់ប្រាប់នោះឯង ចំណែកព្រះបរមពោធិសត្វក៏ព្យាករផលនៃ

សុបិនទាំងនោះដោយពិស្តារ តាមទំនងដែលព្រះបរមសាស្តាទ្រង់ព្យាករ ក្នុងពេលនេះឯង ក្នុងទីបំផុតថ្វាយព្រះពរដូច្នេះដោយខ្លួនឯងថា នឹងប្រព្រឹត្តទៅក្នុងកាលលោកដល់ចំណុចសាបសូន្យ មិនទាន់មានក្នុងយុគនេះទេ ។

សេចក្តីអធិប្បាយក្នុងពាក្យនោះមានដូច្នេះគឺ ថ្វាយព្រះពរមហាបពិត្រ ផលនៃសុបិនទាំងនោះមានដូច្នេះគឺ ការបូជាយញ្ញដែលកំពុងប្រព្រឹត្តទៅដើម្បីកម្ចាត់អន្តរាយព្រះសុបិនទាំងនោះ រមែងប្រព្រឹត្តទៅខុសគោលដៅ លោកអធិប្បាយថា រមែងប្រព្រឹត្តទៅខុសរបៀប ខុសអំពីការពិត ។

សួរថា ព្រោះហេតុអ្វី?

ឆ្លើយថា ព្រោះថា ផលនៃសុបិនទាំងនេះ នឹងមានក្នុងកាលដែលលោកដល់ចំណុចសាបសូន្យ គឺក្នុងកាលដែលមនុស្សម្នាក់ៗ កាន់យកប្រការដែលមិនមែនហេតុថាជាហេតុ ក្នុងកាលដែលសត្វលោកបោះបង់ហេតុថាមិនមែនហេតុ ក្នុងកាលដែលសត្វលោកកាន់យករឿងមិនពិតថាជារឿងពិត ក្នុងកាលដែលសត្វលោកបោះបង់រឿងពិតចោល ដោយគិតថាមិនមែនជារឿងពិត ក្នុងកាលដែលពួកអលជ្ជីចម្រើនឡើង និងក្នុងកាលដែលពួកលជ្ជីថយចុះ មិនទាន់មានក្នុងយុគនេះទេ សេចក្តីថា ផលនៃសុបិនទាំងនេះ មិនទាន់មានក្នុងកាលឥឡូវនេះ ក្នុងយុគនេះ ក្នុងជំនាន់

នៃបុរសបច្ចុប្បន្ននេះ ពោលគឺក្នុងវដ្តកាលរបស់មហាបពិត្រ ឬក្នុងសាសនារបស់តថាគតនេះឡើយ ព្រោះហេតុនោះ ការបូជាយញ្ញដែលកំពុងប្រព្រឹត្តទៅដើម្បីកម្ចាត់អន្តរាយនៃព្រះសុបិនទាំងនេះ ទើបប្រព្រឹត្តទៅដោយឃៀងឃាត សូមមហាបពិត្របញ្ឈប់ការបូជាយញ្ញនោះចុះ ភ័យឬការតក់ស្លុតដែលមានព្រះសុបិននេះជាហេតុ មិនមានដល់មហាបពិត្រទេ ។ ព្រះមហាបុរសធ្វើឲ្យព្រះរាជាធូរស្បើយព្រះទ័យ ដោះមហាជនអំពីចំណងហើយហោះឡើងកាន់អាកាស ថ្វាយឱវាទព្រះរាជា ដឹកនាំឲ្យតាំងមាំក្នុងសីល ៥ ហើយថ្វាយព្រះពរថា តាំងពីពេលនេះតទៅ សូមមហាបពិត្រកុំរួមគំនិតជាមួយនឹងព្រាហ្មណ៍ បូជាយញ្ញដែលមានឈ្មោះថា បសុឃាតយញ្ញ ( យញ្ញសម្លាប់សត្វ ) តទៅទៀត លុះសម្ដែងធម៌ហើយត្រឡប់ទៅលំនៅរបស់ខ្លួនតាមអាកាស ។ ចំណែកព្រះរាជាតាំងនៅក្នុងឱវាទរបស់ព្រះបរមពោធិសត្វ ទ្រង់បំពេញបុណ្យមានឲ្យទានជាដើម ហើយស្ដេចទៅតាមយថាកម្ម ។

ព្រះបរមសាស្ដា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ឲ្យព្រះបាទបសេនទិកោសលបញ្ឈប់ការបូជាយញ្ញ ដោយព្រះពុទ្ធតម្រាស់ថា ព្រោះសុបិនជាបច្ច័យ ភ័យមិនមានដល់មហាបពិត្រទេ សូមមហាបពិត្របញ្ជាឲ្យឈប់បូជាយញ្ញចុះ ព្រះរាជទានជីវិតឲ្យដល់មហាជនហើយទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជា

អានន្ទ មាណពជាកូនសិស្ស បានមកជាសារីបុត្ត ចំណែកតាបសគឺ **តថាគត** នេះឯង ។

លុះព្រះដ៏មានព្រះភាគស្តេចបរិនិព្វានហើយ ព្រះសង្គីតិកាចារ្យទាំងឡាយ លើកបទទាំង ៣ មាន **ឧសភា** ជាដើម ឡើងកាន់អដ្ឋកថា ពោលបទទាំង ៥ មាន **លាវុធិ** ជាដើម លើកឡើងកាន់បាលីឯកនិបាត ដោយប្រការដូច្នេះ ៕

ចប់ អដ្ឋកថា មហាសុបិនជាតក ទី ៧ ។

# អដ្ឋកថា ឥល្លិសជាតក ទី ៨

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះ មច្ឆរិយកោសិយ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧភោ ខញ្ជា** ដូច្នេះជាដើម ។

បានឮថា នៅមិនឆ្ងាយអំពីនគររាជគ្រឹះ មាននិគមឈ្មោះថាសក្ករៈ ក្នុងនិគមនោះ មានសេដ្ឋីម្នាក់ឈ្មោះថា មច្ឆរិយកោសិយ មានសម្បត្តិ ៨០ កោដិ ។ សេដ្ឋីនោះ សូម្បីតែចុងស្មៅជ្រលក់ប្រេងហើយឲ្យទានដល់អ្នកដទៃតែម្តង ក៏មិនមាន ទាំងខ្លួនឯងក៏មិនហ៊ានបរិភោគ ដោយប្រការដូច្នេះ សម្បត្តិរបស់គាត់មិនបានជាប្រយោជន៍ដល់បុត្រនិងភរិយាជាដើម ទាំងមិនបានជាប្រយោជន៍ដល់សមណព្រាហ្មណ៍ តាំងនៅដោយមិនប្រើប្រាស់

ដូចស្រះបោក្ខរណីដែលមានអារក្សទឹកឃុំគ្រងដូច្នោះ ។

ថ្ងៃមួយ ព្រះបរមសាស្ដា ស្ដេចចេញចាកមហាករុណាសមាបត្តិ វេលាជិតភ្លឺ ទ្រង់ត្រួតមើលសត្វលោកដែលជាផៅពង្សនៃអ្នកដែលទ្រង់អាចណែនាំឲ្យត្រាស់ដឹងបាន ទូទៅក្នុងលោកធាតុទាំងមូល ទ្រង់ទតឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់សេដ្ឋី មួយអន្លើដោយភរិយាដែលនៅចម្ងាយ ៤៥ យោជន៍ ។ ថ្ងៃមុនអំពីថ្ងៃនោះ សេដ្ឋីបានទៅកាន់ព្រះរាជវាំងចូលគាល់ព្រះរាជា ពេលធ្វើដំណើរមកតាមផ្លូវបានឃើញអ្នកជនបទម្នាក់កំពុងបរិភោគនំអំបែងដែលផ្សំដោយសណ្ដែក កើតការឃ្លានចង់បរិភោគនំនោះ ទៅដល់ផ្ទះរបស់ខ្លួនហើយត្រិះរិះថា ប្រសិនបើអញប្រាប់ថា ចង់បរិភោគនំអំបែង មនុស្សជាច្រើនក៏នឹងចង់បរិភោគជាមួយអញដែរ កាលបើដូច្នេះ ទ្រព្យសម្បត្តិទាំងឡាយមានអង្ករ ទឹកដោះថ្លា ស្ករអំពៅជាដើមរបស់អញនឹងត្រូវវិនាសហិនហោចអស់ អញនឹងមិនប្រាប់អ្នកណាៗទាំងអស់ អញសុខចិត្តអត់សង្កត់ការឃ្លានទុក ។ លុះការស្រេកឃ្លាននោះវាខ្លាំងពេក គាត់ក៏កើតរោគស្លេកស្លាំងមានខ្លួនរវើររវាមដោយសរសៃ ពេលនោះគាត់មិនអាចអត់ទ្រាំនឹងចំណង់បាន ទើបចូលដេកទទូរនៅលើគ្រែតូចមួយ សូម្បីមានអាការដូច្នោះក៏ដោយ ក៏នៅតែមិនព្រមហាមាត់ប្រាប់អ្នកណាៗឡើយ ព្រោះខ្លាចអស់ទ្រព្យ ។ ចំណែកភរិយារបស់គាត់ក៏ចូលទៅរកគាត់អង្អុយអង្អែលខ្នង ហើយសួរថា បពិត្រអ្នកជាម្ចាស់ លោកមានជម្ងឺ ឬ?

សេដ្ឋីឆ្លើយថា ខ្ញុំមិនឈឺ មិនគ្រុន មិនកើតអ្វីទេ ។

ភរិយាសួរថា ព្រះរាជាទ្រង់ព្រះពិរោធនឹងលោកឬ?

សេដ្ឋីឆ្លើយថា សូម្បីព្រះរាជាក៏ទ្រង់មិនបានពិរោធនឹងខ្ញុំដែរ ។

ភរិយាសួរថា កាលបើដូច្នោះ កូនប្រុសកូនស្រីជាដើម ឬបរិវារមានទាសៈនិងកម្មករជាដើម បានធ្វើនូវអំពើអ្វីដែលលោកមិនពេញចិត្តឬ?

សេដ្ឋីឆ្លើយថា សូម្បីរឿងយ៉ាងនេះ ក៏មិនមានដល់ខ្ញុំ ។

ភរិយាសួរថា ប្រហែលជាលោកនឹកចង់បរិភោគអ្វីទេដឹង? សេដ្ឋីសូម្បីភរិយាពោលយ៉ាងនេះ ក៏នៅតែមិនព្រមប្រាប់ សុខចិត្តដេកស្ងៀម ព្រោះខ្លាចអស់ទ្រព្យ ។ ពេលនោះ ភរិយារបស់គាត់ក៏ពោលនឹងគាត់ថា

បពិត្រអ្នកជាម្ចាស់ លោកចង់បរិភោគអ្វី សូមប្រាប់មកចុះ ។

សេដ្ឋីធ្វើអាកប្បកិរិយាអត់ធន់ពាក្យសម្ដី ហើយពោលថា បាទ ខ្ញុំចង់បរិភោគនំម្យ៉ាង ។

ភរិយាសួរថា តើលោកចង់បរិភោគនំអ្វី?

សេដ្ឋីឆ្លើយថា ខ្ញុំចង់បរិភោគនំអំបែង ។

ភរិយាពោលថា កាលបើដូច្នោះ ហេតុអ្វីលោកមិនប្រាប់ខ្ញុំ លោកជាមនុស្សក្រឬ? ពេលនេះ លោកកុំព្រួយ ខ្ញុំនឹងចៀននំអំបែងឲ្យល្មមចែកអ្នកសុក្ករនិគមបរិភោគ ។

សេដ្ឋីពោលថា នាងនិយាយដល់ពួកនោះធ្វើអ្វី ពួកគេធ្វើការងារ

របស់ខ្លួនហើយ ក៏នឹងធ្វើបរិភោគខ្លួនឯងទៅ ។

កិរិយាពោលថា បើដូច្នោះ ខ្ញុំនឹងធ្វើឲ្យល្មមចែកពួកអ្នកនៅផ្លូវជាមួយយើង ។

សេដ្ឋីពោលថា ខ្ញុំដឹងថានាងជាអ្នកមានទ្រព្យច្រើនហើយ ។

កិរិយាសួរថា បើដូច្នោះ ធ្វើឲ្យល្មមចែកកូនប្រពន្ធក្នុងផ្ទះប៉ុណ្ណោះបានទេ?

សេដ្ឋីពោលថា នាងទៅរវល់នឹងពួកនោះធ្វើអ្វី?

កិរិយាសួរថា បើដូច្នោះ ធ្វើឲ្យល្មមបរិភោគចំពោះតែលោកនឹងខ្ញុំបានទេ?

សេដ្ឋីសួរថា ទាក់ទងនឹងនាងអ្វីដែរ?

កិរិយាពោលថា បើដូច្នោះ ធ្វើឲ្យល្មមតែលោកបរិភោគបានហើយ។

សេដ្ឋីពោលថា កាលបើនាងធ្វើនៅទីនេះ មនុស្សជាច្រើននឹងនាំគ្នាមកមើល នាងចូរយកចុងអង្កររៀរដើមអង្ករចេញ ទាំងខ្ទះនិងជើងក្រានក៏យកទៅផង កាន់យកទឹកដោះស្រស់ ទឹកដោះថ្លា ទឹកឃ្មុំ ស្ករអំពៅបន្តិចបន្តួច ឡើងទៅកាន់ប្រាសាទជាន់ទី ៧ ហើយធ្វើនៅទីនោះចុះ ខ្ញុំម្នាក់ឯងប៉ុណ្ណោះ នឹងអង្គុយបរិភោគនៅទីនោះ ។

កិរិយាទទួលពាក្យហើយ ឲ្យអ្នកបម្រើជញ្ជូនរបស់ដែលត្រូវប្រើប្រាស់ឡើងទៅកាន់ប្រាសាទ ដេញទាសីឲ្យចុះអំពីប្រាសាទ ហើយឲ្យអញ្ជើញ

សេដ្ឋីឡើងកាន់ប្រាសាទ ។ សេដ្ឋីបិទទ្វារជំបូងដាក់គន្លឹះស្រួលបួលហើយឡើងកាន់ប្រាសាទ ៧ ជាន់ លុះដល់ជាន់ទី ៧ បិទទ្វារហើយ អង្គុយរង់ចាំភរិយាចៀននំ ។ ចំណែកភរិយារបស់សេដ្ឋីចាត់ចែងបង្កាត់ភ្លើង លើកខ្ទះឡើងដាក់លើជើងក្រាន ផ្ដើមនឹងចៀននំ ។

គ្រានោះ ព្រះបរមសាស្ដាទ្រង់ត្រាស់ហៅព្រះមហាមោគ្គល្លានអំពីព្រឹកព្រលឹម រួចទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន សេដ្ឋីកំណាញ់នៅក្នុងសក្ករនិគមមិនឆ្ងាយអំពីនគររាជគ្រឹះម្នាក់បានត្រិះរិះថា អញនឹងបរិភោគនំអំបែង ខ្លាចអ្នកដទៃឃើញឲ្យភរិយាចៀននំនៅលើប្រាសាទជាន់ទី ៧ អ្នកចូរទៅកាន់ទីនោះ ទូន្មានសេដ្ឋីធ្វើឲ្យអស់ព្យសន៍ ហើយឲ្យស្វាមីភរិយាទាំងពីរនាក់នោះយកនំ ទឹកដោះថ្លា ទឹកឃ្មុំ ស្ករអំពៅមកកាន់វត្តជេតពនដោយកម្លាំងរបស់ខ្លួនចុះ ថ្ងៃនេះ តថាគតនិងភិក្ខុ ៥០០រូប នឹងគង់រង់ចាំនៅក្នុងវិហារ នឹងធ្វើភត្តកិច្ចដោយនំនោះឯង ។ ព្រះថេរៈទទួលព្រះតម្រាស់របស់ព្រះបរមសាស្ដាថា ព្រះករុណាព្រះអង្គ ហើយទៅកាន់និគមនោះដោយកម្លាំងឫទ្ធិ ភ្លាមនោះឯង គ្រងចីវរស្លៀកស្បង់រៀបរយហើយ ឈរនៅក្នុងអាកាសក្បែរបង្អួច ដូចរូបដែលធ្វើដោយកែវមណីអណ្ដែតមកដូច្នោះ ។ សេដ្ឋីត្រិះរិះថា ព្រោះខ្លាចមនុស្សប្រភេទនេះ ទើបអញមកកាន់ទីនេះ ប៉ុន្តែបុរសនេះមកកាន់ទីជិតបង្អួចទាល់តែបាន រកមើលមិនឃើញវត្ថុដែលអាចកាន់យកបានក៏បញ្ចេញសំឡេង តដ: តដ: មកដោយការ

ចង្អៀតចង្អល់ចិត្ត ដូចយកដុំអំបិលដាក់ទៅក្នុងភ្លើងផ្ទុះប្រេះៗដូច្នោះ ហើយពោលយ៉ាងនេះថា នែសមណៈ កុំថាតែលោកឈរនៅក្នុងអាកាស សូម្បីនឹងដើរទៅមក សម្ដែងស្នាមជើងក្នុងអាកាសដែលរកស្នាមមិនបាន ក៏នៅតែមិនបានអ្វី ។ ព្រះថេរៈក៏និមន្តចង្ក្រមទៅមកនៅទីនោះឯង ។ សេដ្ឋីពោលថា លោកចង្ក្រមនឹងបានអ្វី សូម្បីអង្គុយពែនភ្នែនក្នុងអាកាស ក៏នៅតែមិនបានអ្វីដដែល ។ ព្រះថេរៈក៏គង់ពែនភ្នែនក្នុងអាកាស ។ គ្រានោះសេដ្ឋីពោលថា កុំថាតែលោកពែនភ្នែនក្នុងអាកាស សូម្បីនឹងមកឈរនៅនឹងធរណីបង្អួចក៏ខ្ញុំនៅតែមិនឲ្យដដែល ។ ព្រះថេរៈក៏បានមកឈរនៅនឹងធរណីបង្អួច ។ ពេលនោះ សេដ្ឋីពោលថា សូម្បីលោកឈរនៅនឹងធរណីបង្អួចហើយក៏ដោយ ខ្ញុំនៅតែមិនឲ្យដដែល សូម្បីតែលោកធ្វើផ្សែងឲ្យកើតមាន ក៏ខ្ញុំនៅតែមិនឲ្យដដែល ។ ព្រះថេរៈក៏ធ្វើឲ្យមានផ្សែងហុយចូលប្រាសាទ កាលដែលព្រះថេរៈធ្វើដូច្នោះ មានអាការដូចយកម្ជុលចាក់ភ្នែកសេដ្ឋី សេដ្ឋីមិនហ៊ានពោលថា កុំថាតែលោកធ្វើផ្សែងឲ្យកើតមាន សូម្បីលោកធ្វើភ្លើងឲ្យឆេះប្រាសាទក៏ខ្ញុំនៅតែមិនឲ្យ ព្រោះខ្លាចភ្លើងឆេះប្រាសាទ គាត់ត្រិះរិះថា សមណៈនេះសូមស្វិតណាស់ មិនបាន ប្រហែលជាមិនព្រមទៅទេ ទើបប្រាប់ភរិយាថា នែនាងដ៏ចម្រើន នាងចូរចៀននំ ១ បន្ទះតូចឲ្យសមណៈ ហើយបញ្ជូនលោកឲ្យទៅចុះ ។ ភរិយាសេដ្ឋីដួសម្សៅបន្តិចប៉ុណ្ណោះ ហើយដាក់ទៅក្នុងខ្ទះសម្រាប់ចៀននំ នំធំពេញខ្ទះ គ្រាស់ពេញ

វង់ប្រាកដដល់សេដ្ឋី ។ សេដ្ឋីឃើញនំនោះហើយនិយាយថា នាងប្រហែលជាដាក់ម្សៅច្រើនពេកទេដឹង ? ហើយយកចុងវែកដួសម្សៅបន្តិចដាក់ទៅក្នុងខ្ទះខ្លួនឯង នំរីតតែធំជាងមុន មិនថាជាដាក់នំដោយវិធីណាៗ នំក៏រីតតែធំឡើងៗ ។ សេដ្ឋីហត់នឿយក៏ប្រាប់ភរិយាថា នែនាងដ៏ចម្រើន នាងចូរឲ្យនំដល់សមណៈនេះមួយចំណិតចុះ ។ កាលភរិយាសេដ្ឋីបេះនំមួយចំណិតចេញពីថាស នំទាំងអស់ជាប់គ្នាតែមួយផ្ទាំង ។ នាងប្រាប់សេដ្ឋីថា បពិត្រអ្នកជាម្ចាស់ នំជាប់គ្នាទាំងអស់ ខ្ញុំមិនអាចហែកបានទេ ។ សេដ្ឋីពោលថា ខ្ញុំនឹងធ្វើខ្លួនឯង ក៏មិនអាចហែកនំចេញបាន កាលសេដ្ឋីព្យាយាមខ្លាំងដើម្បីហែកនំនោះ ញើសក៏ហូរចេញអំពីកាយ សេចក្តីស្រេកឃ្លានក៏បាត់អស់ទៅ ។ គ្រានោះ សេដ្ឋីក៏និយាយទៅកាន់ភរិយាថា នែនាងដ៏ចម្រើន ខ្ញុំមិនត្រូវការនំទៀតទេ នាងចូរប្រគេនភិក្ខុនេះទាំងថាសចុះ ។ ភរិយាសេដ្ឋីក៏លើកថាសចូលទៅរកព្រះថេរៈ ហើយប្រគេននំទាំងអស់ចំពោះព្រះថេរៈ ។

ព្រះថេរៈកាលសម្តែងធម៌ដល់មនុស្សទាំងពីរនាក់នោះ ក៏ពោលអំពីគុណព្រះរតនៈទាំងបី ហើយបង្ហាញផលនៃការឲ្យទានជាដើមថា ទានដែលបុគ្គលឲ្យហើយមានផល ការបូជាមានផល ភ្លឺច្បាស់ដូចសម្តែងឲ្យឃើញព្រះចន្ទពេញវង់នៅលើផ្ទៃនភាល័យដូច្នោះ ។ លុះស្តាប់ធម៌ហើយ មហាសេដ្ឋីមានចិត្តជ្រះថ្លាពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន និមន្តគង់

លើអាសនៈនេះ ហើយឆាន់នំនេះចុះ ។

ព្រះថេរៈពោលថា ចម្រើនពរមហាសេដ្ឋី ព្រះសម្មាសម្ពុទ្ធទ្រង់បាន ត្រាស់ថា តថាគតនឹងឆាន់នំ ឥឡូវនេះទ្រង់គង់នៅក្នុងព្រះវិហារមួយអន្លើ ដោយភិក្ខុ ៥០០ រូប កាលបើលោកពេញចិត្ត ចូរឲ្យភរិយាកាន់នំនិងទឹក-ដោះជាដើម យើងនឹងទៅកាន់សម្នាក់ព្រះបរមសាស្តា ។

សេដ្ឋីសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឥឡូវនេះ ព្រះបរម-សាស្តា ទ្រង់គង់នៅទីណា ?

ព្រះថេរៈឆ្លើយថា ព្រះបរមសាស្តាទ្រង់គង់នៅក្នុងវត្តជេតពន ឆ្ងាយអំពីទីនេះ ៤៥ យោជន៍ ។

សេដ្ឋីពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងនឹងធ្វើដំណើរទៅកាន់ទីឆ្ងាយបែបហ្នឹង ដោយមិនឲ្យហួសកត្តកាលដូចម្តេចបាន ?

ព្រះថេរៈពោលថា មហាសេដ្ឋី ប្រសិនបើលោកពេញចិត្ត អាត្មានឹងនាំលោកទៅដោយកម្លាំងឫទ្ធិរបស់ខ្លួន ក្បាលជណ្តើរនៅនឹងប្រាសាទរបស់លោក នឹងប្រាកដនៅក្នុងទីតាំងរបស់ខ្លួន ប៉ុន្តែទីបំផុត គឺជើងនៃជណ្តើរនឹងប្រាកដនៅនឹងខ្លោងទ្វារវត្តជេតពន អាត្មានឹងនាំលោកទៅកាន់វត្តជេតពន ដោយរយៈពេលស្មើនឹងកាលដែលលោកចុះអំពីប្រាសាទជាន់លើ មកកាន់ប្រាសាទជាន់ក្រោមប៉ុណ្ណោះ ។

សេដ្ឋីពោលថា សាធុលោកម្ចាស់ ។ ព្រះថេរៈក៏អធិដ្ឋានថា ក្បាល

ជណ្ដើរចូរនៅកន្ទែងដើម ដើងជណ្ដើរចូរនៅខ្លោងទ្វារវត្តជេតពនចុះ ។ ជណ្ដើរក៏បានតាំងនៅក្នុងទីទាំងឡាយ ដូចដែលព្រះថេរៈអធិដ្ឋានដោយអាការយ៉ាងនេះ ព្រះថេរៈនាំសេដ្ឋីនិងភរិយាទៅដល់វត្តជេតពន រហ័សជាងពេលចុះអំពីប្រាសាទជាន់លើ មកដល់ប្រាសាទជាន់ក្រោមទៅទៀត ។ សេដ្ឋីនិងភរិយាទាំងពីរនាក់ប្ដីប្រពន្ធចូលគាល់ព្រះបរមសាស្ដា ក្រាបទូលភត្តកាលចំពោះទ្រង់ ព្រះបរមសាស្ដាទ្រង់យាងចូលកាន់រោងភត្ត ទ្រង់គង់លើបវរពុទ្ធាសនៈដែលគេចាត់ចែងទុកមួយអន្លើដោយភិក្ខុសង្ឃ ។ សេដ្ឋីបានប្រគេនទឹកទក្ខិណោទកចំពោះភិក្ខុសង្ឃមានព្រះសម្មាសម្ពុទ្ធជាប្រធាន ភរិយារបស់សេដ្ឋីក៏បានដាក់នំក្នុងបាត្ររបស់ព្រះតថាគត ។ ព្រះបរម-សាស្ដាទ្រង់ទទួលនំល្មមនឹងព្រះបំណាងរបស់ព្រះអង្គ សូម្បីភិក្ខុ ៥០០ រូបនោះក៏ទទួលដូច្នោះដែរ ។ សេដ្ឋីក៏ដើរប្រគេនទឹកដោះស្រស់ ទឹកដោះថ្លា ទឹកឃ្មុំ ទឹកអំពៅ និងស្ករត្នោតជាដើម ។ ព្រះបរមសាស្ដានិងភិក្ខុសង្ឃ ៥០០ រូបធ្វើភត្តកិច្ចស្រេចហើយ មហាសេដ្ឋីនិងភរិយាក៏ទទួលទានល្មមដល់សេចក្ដីត្រូវការ ការអស់ទៅនៃនំទាំងឡាយក៏មិនប្រាកដ សូម្បីប្រគេនចំពោះភិក្ខុសង្ឃទាំងឡាយនិងអ្នកស៊ីដែលក្នុងវត្តទាំងអស់ហើយ ការអស់ទៅនៃនំទាំងឡាយក៏នៅតែមិនប្រាកដដដែល ។ សេដ្ឋីនិងភរិយាក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន នំនៅសល់ច្រើនទៀត ។ ព្រះដ៏មានព្រះភាគត្រាស់ថា បើដូច្នោះ អ្នកចូរចាក់ចោលនៅក្បែរខ្លោងទ្វារ

វត្តជេតពនចុះ ។ ពីរនាក់ស្វាមីភរិយាក៏យកនំទៅចាក់ចោលនៅកន្លែងមួយ មិនឆ្ងាយអំពីខ្លោងទ្វារវត្តជេតពន ទីនោះទើបប្រាកដឈ្មោះថា ជ្រោយនំចាក់អំបែង រហូតមកដល់សព្វថ្ងៃនេះ ។ មហាសេដ្ឋីនិងភរិយានាំគ្នាចូលគាល់ព្រះដ៏មានព្រះភាគ ហើយឈរនៅក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគទ្រង់សម្តែងអនុមោទនាកថា លុះចប់អនុមោទនាកថា សេដ្ឋីនិងភរិយាទាំងពីរនាក់បានសម្រេចសោតាបត្តិផល ថ្វាយបង្គំព្រះបរមសាស្តាហើយឡើងដណ្តើរបិតនៅក្នុងប្រាសាទរបស់ខ្លួននោះឯង ។ ចាប់តាំងពីពេលនោះមក មហាសេដ្ឋីក៏បរិច្ចាគទ្រព្យ ៨០ កោដិក្នុងព្រះពុទ្ធសាសនា ។

ស្អែកឡើង កាលព្រះសម្មាសម្ពុទ្ធស្តេចនិមន្តបិណ្ឌបាតក្នុងនគរសាវត្ថីហើយ ស្តេចយាងមកកាន់វត្តជេតពន ប្រទានសុគតោវាទដល់ពួកភិក្ខុហើយ ទ្រង់យាងចូលកាន់ព្រះគន្ធកុដិ ទ្រង់សម្រាកព្រះកាយ លុះវេលារសៀល ពួកភិក្ខុអង្គុយប្រជុំគ្នាក្នុងធម្មសភា ពោលអំពីគុណកថារបស់ព្រះថេរៈថា អ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរមើលអានុភាពរបស់ព្រះមហាមោគ្គល្លានចុះ លោកមិនបានធ្វើឲ្យគេខូចសទ្ធា មិនបានប៉ះពាល់ទ្រព្យសម្បត្តិ ទូន្មានសេដ្ឋីដែលកំណាញ់ស្វិតតែប៉ុណ្ណោះ ធ្វើឲ្យអស់ព្យសន៍ ឲ្យកាន់នំមកវត្តជេតពនគាល់ព្រះបរមសាស្តា ធ្វើឲ្យបានសម្រេចសោតាបត្តិផល ឱ ព្រះថេរៈមានអានុភាពហ្ន៎ ។ ព្រះបរមសាស្តាស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ

អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ជម្មតាភិក្ខុអ្នកទូន្មានត្រកូល មិនត្រូវបៀតបៀនត្រកូលឲ្យលំបាកទេ គប្បីធ្វើខ្លួនឲ្យដូចជាភមរជាតិក្រេបយកលំអងផ្កា ចូលទៅកាន់ត្រកូលហើយធ្វើឲ្យគេដឹងពុទ្ធគុណ កាលទ្រង់សរសើរព្រះថេរៈ ក៏បានត្រាស់ព្រះគាថាក្នុងធម្មបទនេះថា

**យថាបិ ភមរោ បុប្ផំ វណ្ណគន្ធំ អហេឋយំ**
**បលេតិ រសមាទាយ ឯវំ គាមេ មុនី ចរេ ។**

ភមរជាតិ មិនធ្វើផ្កាឈើដែលមានពណ៌និងក្លិនឲ្យ
វិនាសទេ ក្រេបយកតែរស ហើរទៅ យ៉ាងណាមិញ
អ្នកប្រាជ្ញ គប្បីត្រាច់ទៅក្នុងស្រុក ក៏យ៉ាងនោះឯង ។

ដើម្បីនឹងប្រកាសគុណរបស់ព្រះថេរៈឲ្យក្រៃលែងឡើង ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលមច្ឆរិយសេដ្ឋីត្រូវមោគ្គល្លានទូន្មាននោះ សូម្បីកាលពីមុនមោគ្គល្លានក៏ធ្លាប់ទូន្មានសេដ្ឋីនេះឲ្យដឹងកម្មផលដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី សេដ្ឋីឈ្មោះឥល្លិសៈមានទ្រព្យសម្បត្តិ ៨០ កោដិ ប្រកប

ដោយបុរសទោសច្រើនស្ថាន ជាមនុស្សខ្ចក ក្ញែង ក្អែកស្រលៀង មិនមាន សទ្ធា មិនជ្រះថ្លា កំណាញ់មិនឲ្យអ្វីៗដល់អ្នកដទៃ ទាំងមិនបរិភោគខ្លួនឯង មានប្រក្រតីនៅក្នុងក្រុងសាវត្ថី ផ្ទះរបស់សេដ្ឋីនោះដូចស្រះបោក្ខរណីដែល មានអារក្សទឹកហួងហែង ប៉ុន្តែមាតាបិតារបស់សេដ្ឋីនោះជាអ្នកឲ្យទាន ជា ទានបតីរហូតមក ៧ ជួរត្រកូល ។ លុះឥល្លិសៈនោះបានតំណែងសេដ្ឋី ហើយ ក៏ទម្លាយវង្សត្រកូលចោល ដុតរោងទាន វាយបណ្តេញពួកស្មូម- យាចក រក្សាតែទ្រព្យសម្បត្តិប៉ុណ្ណោះ ។ ថ្ងៃមួយ ឥល្លិសសេដ្ឋីនោះទៅ គាល់ព្រះរាជា ពេលដើរមកផ្ទះវិញឃើញអ្នកស្រុកក្រៅម្នាក់ស្មើយកម្លាំង ព្រោះការធ្វើដំណើរ កាន់ដបស្រាមកមួយដប អង្គុយលើតាំងតូចមួយ ចាក់ សុរាដាក់ពែង ហើយផឹក បរិភោគគ្រឿងក្លែមនិងសម្ងួខត្តរិកង្គបង់ប្រហុក នឹកចង់ផឹកដែរ ប៉ុន្តែគិតឃើញថា ប្រសិនបើអញនឹងផឹកសុរា កាលអញ កំពុងផឹកមនុស្សជាច្រើនក៏នឹងចង់ផឹកដែរ ការអស់ទៅនៃទ្រព្យសម្បត្តិក៏ នឹងមានដល់អញដោយអាការយ៉ាងនេះ ។ ឥល្លិសសេដ្ឋីនោះ គ្របសង្កត់ ចំណង់នោះទុក លុះវេលាកន្លងទៅមិនអាចគ្របសង្កត់បាន ក៏កើតរោគ ស្គមលឿង មានខ្លួនរវើមរវាមដោយសរសៃដូចស្ទឹកកប្បាសដែលទុំដូច្នោះ ។ ថ្ងៃមួយ ទើបចូលបន្ទប់ដេក ចូលទៅដេកទទូរនៅលើគ្រែតូចមួយ ភរិយា របស់គាត់ចូលទៅអង្អែលខ្នងរួចសួរថា បពិត្រអ្នកជាម្ចាស់ លោកមានជម្ងឺ ឬ ? ពាក្យទាំងអស់ គប្បីជ្រាបតាមទំនងដែលពោលហើយនោះចុះ ។

កាលភរិយាពោលថា បើដូច្នោះ ខ្ញុំនឹងផ្សំសុរាសម្រាប់តែលោកម្នាក់ប៉ុណ្ណោះ ។ សេដ្ឋីត្រិះរិះថា កាលបើផ្សំសុរាក្នុងផ្ទះ មនុស្សជាច្រើនក៏ចង់ផឹកដែរ ឲ្យទៅទិញមកអំពីផ្សារ ប៉ុន្តែមិនអាចអង្គុយផឹកនៅក្នុងទីនេះបាន ទើបឲ្យប្រាក់ទៅប្រមាណមួយមាសកៈ ឲ្យទៅទិញសុរាមកអំពីផ្សារមួយដប ឲ្យបាវបម្រើកាន់ចេញអំពីក្រុងទៅដល់ឆ្នេរស្ទឹង លបចូលកាន់គុម្ពោតព្រៃមួយ ឲ្យបាវបម្រើដាក់ដបសុរាទុកហើយពោលថា ឯងទៅចុះ ឲ្យបាវបម្រើទៅអង្គុយក្នុងទីឆ្ងាយ ចាក់សុរាដាក់ពែង ផ្តើមផឹកសុរា ។

ចំណែកបិតារបស់សេដ្ឋីនោះ បដិសន្ធិជាសក្កទេវរាជក្នុងទេវលោក ព្រោះបានធ្វើបុណ្យទាំងឡាយមានឲ្យទានជាដើម ។ គ្រានោះ សក្កទេវរាជត្រិះរិះថា ទានរបស់អញនៅប្រព្រឹត្តទៅទេហ្ន៎ លុះឃើញថាទានមិនប្រព្រឹត្តទៅ ហើយឃើញបុត្រទម្លាយវង្សត្រកូល ដុតរោងទានបណ្តេញពួកស្មូមយាចក តាំងនៅក្នុងភាពជាអ្នកកំណាញ់ កំពុងចូលក្នុងព្រៃផឹកសុរាតែម្នាក់ឯងព្រោះខ្លាចអ្នកដទៃឃើញ ទើបសក្កទេវរាជទ្រង់ត្រិះរិះថា អញត្រូវទៅទូន្មានឥល្លិសៈនោះ ឲ្យដឹងអំពីកម្មនិងផលនៃកម្ម ហើយឲ្យបំពេញទាន ធ្វើឲ្យគេសមគួរនឹងកើតក្នុងទេវលោក ដូច្នេះ គិតហើយស្តេចចុះមកកាន់ឋានមនុស្ស ទ្រង់និមិត្តអត្តភាពជាមនុស្សក្ញែងនិងភ្នែកស្រលៀងដូចសេដ្ឋីឈ្មោះឥល្លិសៈ ចូលទៅកាន់នគរពារាណសី សម្រាកនៅក្បែរខ្លោងទ្វារព្រះរាជនិវេសន៍ ឲ្យក្រាបទូលការមករបស់ខ្លួន កាល

បានទទួលព្រះបរមរាជានុញ្ញាតថា ចូរចូលមកចុះ ទើបចូលទៅថ្វាយបង្គំព្រះរាជាហើយឈរក្នុងទីដ៏សមគួរមួយ ។ ព្រះរាជាមានព្រះតម្រាស់សួរថា នែមហាសេដ្ឋី មានការអ្វី ទើបអ្នកមកកាន់សម្នាក់របស់យើងខុសកាលវេលាដូច្នេះ ?

សក្កទេវរាជក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមកដោយបំណងថា ក្នុងផ្ទះរបស់ទូលបង្គំមានទ្រព្យ ៨០ កោដិ សូមព្រះអង្គបញ្ជារាជបុរសឲ្យទៅជញ្ជូនមកដាក់ឃ្លាំងរបស់ព្រះអង្គចុះ ។

ព្រះរាជាត្រាស់ថា កុំឡើយមហាសេដ្ឋី ទ្រព្យក្នុងឃ្លាំងរបស់យើងមានច្រើនជាងទ្រព្យរបស់អ្នក ។

សក្កទេវរាជក្រាបទូលថា បពិត្រព្រះសម្មតិទេព ប្រសិនបើព្រះ-អង្គមិនត្រូវការទេ ទូលបង្គំនឹងចំណាយទ្រព្យទាំងនោះឲ្យជាទាន តាមការពេញចិត្តរបស់ទូលបង្គំ ។

ព្រះរាជាត្រាស់ថា ឲ្យចុះ មហាសេដ្ឋី ។ ឥន្ទសេដ្ឋីទទួលព្រះបរម-រាជានុញ្ញាតហើយ ថ្វាយបង្គំព្រះរាជា ចេញទៅកាន់ផ្ទះរបស់ឥល្លិស-សេដ្ឋី ។ ពួកអ្នកបម្រើគ្រប់គ្នាក៏ចោមរោម សូម្បីអ្នកបម្រើតែម្នាក់ដែលនឹងអាចដឹងថា អ្នកនេះមិនមែនជាឥល្លិសសេដ្ឋី មិនមានឡើយ ។

លុះសក្កទេវរាជចូលកាន់ផ្ទះហើយក៏ឈរនៅត្រង់ធរណីទ្វារ ហៅអ្នកយាមទ្វារមកប្រាប់ថា បើអ្នកណាមានរូបរាងដូចយើងចូលមកដោយ

ពោលថា នេះផ្ទះរបស់យើង ពួកអ្នកគប្បីវាយខ្នងអ្នកនោះហើយបណ្តេញចេញ ។ លុះផ្តាំដូច្នេះហើយ ក៏ឡើងកាន់ប្រាសាទគង់លើអាសនៈដ៏ប្រសើរ បញ្ជាឲ្យហៅភរិយារបស់សេដ្ឋីមក សម្តែងអាការដូចសេដ្ឋីមិនខុសត្រង់ណាឡើយ រួចពោលថា នែនាងដ៏ចម្រើន យើងនឹងឲ្យទានជាមួយគ្នាចុះ ។ ភរិយា បុត្រធីតា និងទាសកម្មករ បានឮពាក្យរបស់សក្កទេវរាជហើយ នាំគ្នាពោលថា អស់កាលប្រមាណប៉ុណ្ណេះ ការគិតថានឹងឲ្យទានមិនមានឡើយ ប៉ុន្តែថ្ងៃនេះផឹកសុរាហើយកើតចិត្តល្អចង់ឲ្យទានជាប្រាកដ ។ ពេលនោះ ភរិយារបស់សេដ្ឋីក៏ពោលថា បពិត្រអ្នកជាម្ចាស់ សូមលោកឲ្យទានតាមសប្បាយចុះ ។

សក្កទេវរាជពោលថា បើដូច្នោះ នាងចូរហៅអ្នកវាយស្គរមក ឲ្យនាំស្គរទៅវាយប្រកាសទូទៅក្នុងនគរថា អ្នកដែលត្រូវការមាស ប្រាក់ កែវមណី និងកែវមុក្តាជាដើម ចូរនាំគ្នាទៅកាន់ផ្ទះរបស់ឥល្លិសសេដ្ឋីចុះ អ្នកទូងស្គរក៏បានធ្វើដូច្នោះ មហាជនម្នាក់ៗនាំគ្នាកាន់ភាជន៍ជាដើម ទៅជុំគ្នានៅមុខខ្លោងទ្វារផ្ទះ ។ សក្កទេវរាជទ្រង់បញ្ជាឲ្យបើកបន្ទប់ដែលពេញទៅដោយរតនៈ ៧ ប្រការជាច្រើនបន្ទប់ រួចពោលថា យើងឲ្យដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរនាំគ្នាជញ្ជូនយកទៅតាមការពេញចិត្តចុះ ។ មហាជននាំគ្នាជញ្ជូនទ្រព្យចេញទៅគរទុកក្នុងទីទូលាយ រួចដាក់ក្នុងភាជន៍ដែលយកមករហូតពេញ ហើយទើបនាំគ្នាចៀសចេញទៅ ។

ចំណែកអ្នកស្រុកជនបទម្នាក់ ទឹមគោរបស់ឥល្លិសសេដ្ឋី ឲ្យអូសរថរបស់សេដ្ឋីនោះ ផ្ទុកពេញដោយរតនៈ ៧ ប្រការ ចេញអំពីនគរទៅតាមផ្លូវធំ បររថទៅមិនឆ្ងាយអំពីគុម្ពោតព្រៃនោះ បររថបណ្ដើរពោលសរសើរគុណរបស់សេដ្ឋីបណ្ដើរថា បពិត្រលោកឥល្លិសសេដ្ឋីដ៏ចម្រើន សូមលោកមានជីវិតអស់រយឆ្នាំចុះ ពេលនេះ ខ្ញុំមិនចាំបាច់ធ្វើការងារចិញ្ចឹមជីវិតរហូតអស់មួយជីវិត ព្រោះអាស្រ័យលោក រថនេះក៏ជារបស់លោក គោមួយនឹមនេះក៏ជារបស់លោកដែរ កែវ ៧ ប្រការក្នុងផ្ទះរបស់លោក មាតារបស់លោកក៏មិនបានឲ្យ បិតារបស់លោកក៏មិនបានឲ្យ ខ្ញុំបានព្រោះអាស្រ័យលោកពិតៗ ។ ឥល្លិសសេដ្ឋីស្ដាប់សំឡេងនោះហើយ កើតការខ្លាចព្រួយបារម្ភនឹកភ្នកក្នុងចិត្តថា បុរសនេះយកឈ្មោះរបស់អញមកពោលអាងក្នុងរឿងនេះៗ ព្រះរាជាព្រះរាជទានទ្រព្យរបស់អញដល់មហាជនទេដឹង ស្ទុះចេញអំពីគុម្ពោតព្រៃចាប់គោនិងរថបាន ក៏ពោលគំរាមថា នែមនុស្សអាក្រក់ គោក៏របស់អញ រថក៏របស់អញ ពោលបណ្ដើររត់ទៅចាប់ខ្សែគោបណ្ដើរ ។ គហបតីក៏ចុះអំពីរថពោលថា នែមនុស្សអាក្រក់ ឥល្លិសសេដ្ឋីឲ្យទានដល់មនុស្សក្នុងក្រុងទាំងអស់ ឯងជាអ្វី ? រួចស្ទុះទៅវាយកញ្ចឹងក រហ័សដូចផ្លេកបន្ទោរ ហើយទាញរថមកបរទៅទៀត ។ ចំណែកឥល្លិសសេដ្ឋីក្រោកឡើងញ័រខ្លួនខឹងច្រឡោត រត់ទៅទាញរថម្ដងទៀត ។ គហបតីក៏ចុះអំពីរថចាប់ក្របួចសក់ទាញមកអុកនឹងជង្គង់ ចាប់កគ្រវីទៅមកហើយក៏

ចៀសចេញទៅ ។ កាលត្រូវដំណំយ៉ាងនេះ ការស្រវឹងសុរារបស់សេដ្ឋីក៏បាត់អស់ទៅ ដើរខ្សឹកៗទៅកាន់ខ្លោងទ្វារនិវេសន៍យ៉ាងរហ័ស ឃើញមហាជននាំគ្នាជញ្ជូនទ្រព្យយកទៅក៏ស្រែកសួរថា នែអ្នកទាំងឡាយ តើមានរឿងអ្វី ព្រះរាជាបញ្ជាឲ្យមកប្លន់ទ្រព្យរបស់យើងឬ ? ហើយទៅចាប់មនុស្សទាំងនោះ ។ មនុស្សទាំងនោះ អ្នកដែលត្រូវចាប់ក៏នាំគ្នាវាយសេដ្ឋីរហូតទាល់តែដួលនៅលើដី ។ សេដ្ឋីឈឺចាប់ខ្លាំងណាស់ប្រាថ្នានឹងចូលផ្ទះ ពួកអ្នកយាមទ្វារស្រែកសួរថា នែគហបតីអាក្រក់ ឯងចង់ចូលទៅណា ? រួចវាត់ដោយបន្ទះឫស្សីចាប់កអូសចេញទៅ ។ សេដ្ឋីគិតថា ពេលនេះវៀរព្រះរាជាចេញ អ្នកដទៃដែលជាទីពឹងពំនាក់អាស្រ័យរបស់អញមិនមានឡើយ ហើយក៏ទៅកាន់ព្រះរាជដំណាក់ក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព ព្រះអង្គបញ្ជាឲ្យមនុស្សទៅប្លន់ផ្ទះរបស់ទូលបង្គំឬ ?

ព្រះរាជាត្រាស់តបថា នែសេដ្ឋី យើងមិនបានបញ្ជាឲ្យមនុស្សទៅប្លន់ផ្ទះរបស់លោកទេ លោកខ្លួនឯងទេតើដែលមកប្រាប់យើងថា ប្រសិនបើព្រះអង្គមិនត្រូវការទ្រព្យរបស់ទូលបង្គំទេ ទូលបង្គំនឹងឲ្យទ្រព្យរបស់ទូលបង្គំជាទាន ឲ្យមនុស្សដើរទូងស្គរប្រកាសក្នុងនគរហើយបានឲ្យទានមិនមែនឬ ?

សេដ្ឋីក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនបានមកកាន់សម្នាក់របស់ព្រះអង្គទេ ទ្រង់មិនជ្រាបថាទូលបង្គំជាមនុស្សកំណាញ់ទេឬ ?

ទូលបង្គំមិនព្រមឲ្យ សូម្បីតែតំណក់ប្រេងដែលជាប់នឹងចុងសួ្បវដល់អ្នកណាៗឡើយ បពិត្រព្រះសម្មតិទេព សូមទ្រង់ព្រះករុណាបញ្ជាឲ្យហៅមនុស្សដែលឲ្យទាននោះមក ហើយទ្រង់ពិចារណាចុះ ។ ព្រះរាជាត្រាស់ឲ្យហៅសក្កទេវរាជមក ការប្លែកគ្នានៃមនុស្សទាំងពីរនាក់នោះ ព្រះរាជាក៏ទ្រង់ជ្រាបមិនបាន ពួកអាមាត្យក៏មិនដឹងដែរ ។

សេដ្ឋីកំណាញ់ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ចាំទូលបង្គំមិនបានឬ ? ទូលបង្គំជាសេដ្ឋី បុរសនេះមិនមែនជាសេដ្ឋីទេ ។

ព្រះរាជាត្រាស់តបថា យើងចាំមិនបាន នៅមានអ្នកណាដែលអាចចាំអ្នកបានខ្លះទេ ?

សេដ្ឋីក្រាបទូលថា ព្រះករុណាថ្លៃវិសេស ភរិយារបស់ទូលបង្គំ ។

ព្រះរាជាមានព្រះតម្រាស់ឲ្យហៅភរិយាសេដ្ឋីចូលគាល់ ហើយត្រាស់សួរថា នៃនាងដ៏ចម្រើន តើម្នាក់ណាជាស្វាមីរបស់នាង ?

នាងក្រាបទូលថា បពិត្រព្រះសម្មតិទេព ម្នាក់នេះ ហើយទៅឈរជិតសក្កទេវរាជ ។ ព្រះរាជបញ្ជាឲ្យហៅ បុត្ត ធីតា ទាសៈ កម្មករមកសួរគ្រប់គ្នានាំគ្នាឈរនៅក្នុងសម្នាក់សក្កទេវរាជទាំងអស់ ។ សេដ្ឋីត្រឡប់គិតបានថា លើក្បាលរបស់អញមានពក សក់ដុះជិតឈឹង មានតែជាងកាត់-សក់ម្នាក់ប៉ុណ្ណោះ ដែលដឹងពកនោះ ត្រូវក្រាបទូលព្រះរាជាឲ្យហៅជាងកាត់សក់មក ។ លុះគិតដូច្នេះហើយក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព

ជាងកាត់សក់ពិតជាចាំទូលបង្គំបាន សូមព្រះអង្គទ្រង់បញ្ជាឲ្យហៅជាងកាត់សក់នោះមកចុះ ។ ក្នុងគ្រានោះ ព្រះបរមពោធិសត្វបានជាជាងកោរកាត់របស់ឥល្លិសសេដ្ឋី ។ ព្រះរាជាបញ្ជាឲ្យហៅជាងកោរកាត់នោះមកសួរថា នែអ្នកដ៏ចម្រើន អ្នកចាំឥល្លិសសេដ្ឋីបានឬទេ?

ព្រះបរមពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំពិនិត្យមើលក្បាលហើយ ពិតជាចាំបាន ។

ព្រះរាជាត្រាស់ថា បើដូច្នោះ អ្នកចូរពិនិត្យមើលក្បាលនៃមនុស្សទាំងពីរនាក់នេះចុះ ។ ក្នុងនោះឯង សក្កទេវរាជក៏បណ្ដាលឲ្យកើតពកនៅលើក្បាល ព្រះបរមពោធិសត្វពិនិត្យមើលសីសៈនៃមនុស្សទាំងពីរនាក់ ក៏ឃើញពិត ( ដូចគ្នា ) ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព នៅលើក្បាលនៃមនុស្សទាំងពីរនាក់នោះ មានពកដូចគ្នា បណ្ដាមនុស្សទាំងពីរនាក់នេះ ទូលបង្គំមិនអាចចាំបានទេ សូម្បីតែឥល្លិសៈម្នាក់ ហើយពោលគាថានេះថា

**ឧភោ ខញ្ជា ឧភោ កុណី ឧភោ វិសមចក្ខុកា**
**ឧភិន្នំ បិឡកា ជាតា នាហំ បស្សាមិ ឥល្លិសន្តិ។**

ជនទាំងពីរនាក់ខ្ចក ជនទាំងពីរនាក់ក្ងែង ជនទាំងពីរនាក់
មានភ្នែកស្រលៀង ពកកើត (លើក្បាល) របស់ជនទាំង
ពីរនាក់ ខ្ញុំព្រះអង្គមិនស្គាល់ (អ្នកណា) ជាឥល្លិសសេដ្ឋីទេ ។

បណ្ដាបទទាំងនោះ បទថា **ឧភោ** បានដល់ ជនទាំងពីរនាក់ ។

បទថា **ខញ្ជា** បានដល់ មានជើងខ្ចក ។

បទថា **កុណី** បានដល់ មានដៃក្ងែង ។

បទថា **វិសមចក្ខុកា** បានដល់ មានភ្នែកមិនស្មើគ្នា អធិប្បាយថា មានភ្នែកស្រលៀង ។

បទថា **បិឡកា** សេចក្ដីថា នៅលើក្បាលនៃជនទាំងពីរនាក់នោះ មានពកកើតឡើងហើយ មានសណ្ឋានដូចគ្នា នៅត្រង់កន្លែងដូចគ្នា ។

បទថា **ណាហំ បស្សាមិ** សេចក្ដីថា ជាងកោរកាត់ទូលថា ជនទាំងពីរនាក់នេះ ទូលបង្គំមិនដឹងច្បាស់ថាអ្នកណាជាឥល្លិសសេដ្ឋីទេ គឺមិនដឹងច្បាស់នូវភាពជាឥល្លិសសេដ្ឋីរបស់បុរសម្នាក់ៗ ឡើយ ។

ឥល្លិសសេដ្ឋី គ្រាន់តែបានស្ដាប់ពាក្យរបស់ព្រះបរមពោធិសត្វភ្លាម ក៏ញាប់ញ័រមិនអាចទប់ស្មារតីបានព្រោះការល្មោភក្នុងទ្រព្យ ក៏ដួលនៅទីនោះឯង ។ គ្រានោះ សក្កទេវរាជពោលថា នែមហារាជ យើងមិនមែនជាឥល្លិសៈទេ យើងជាសក្កទេវរាជ ហើយបានទៅប្រថាប់ឈរនៅក្នុងអាកាសដោយអាកប្បកិរិយាដ៏អង់អាច ។ ពួកអាមាត្យជួយបបោសអង្អែលមុខឥល្លិសសេដ្ឋីហើយប្រោះដោយទឹក ឥល្លិសសេដ្ឋីប្រញាប់ក្រោកឡើងថ្វាយបង្គំសក្កទេវរាជ ភ្លាមនោះឯង សក្កទេវរាជពោលទៅកាន់សេដ្ឋីថា នែឥល្លិសៈ ទ្រព្យនេះជារបស់យើង មិនមែនជារបស់អ្នកទេ ព្រោះយើងជា

បិតារបស់អ្នក អ្នកជាបុត្ររបស់យើង យើងធ្វើបុណ្យមានឲ្យទានជាដើម ទើបបានដល់ភាពជាសក្កទេវរាជ ប៉ុន្តែអ្នកកាត់វង្សរបស់យើងដាច់អស់ ជាអ្នកមិនព្រមឲ្យទាន តាំងនៅក្នុងភាពជាមនុស្សកំណាញ់ ដុតរោងទានបណ្ដេញពួកស្មូមយាចក គិតតែពីការសន្សំទ្រព្យ បរិភោគខ្លួនឯងក៏មិនព្រម ឲ្យអ្នកដទៃក៏មិនឲ្យ ធ្វើខ្លួនឯងដូចអារក្សទឹកហួងហែងស្រះ ប្រសិនបើអ្នកត្រឡប់សាងរោងទានឲ្យជាប្រក្រតី ហើយឲ្យទាននោះ ជាការប្រពៃ ប្រសិនបើអ្នកមិនឲ្យទាន យើងនឹងធ្វើឲ្យទ្រព្យរបស់អ្នកវិនាសរហូតទាល់តែអស់ ហើយនឹងវាយក្បាលរបស់អ្នកដោយឥន្ទវជិរៈនេះឲ្យអស់ជីវិត ។ ឥល្លិសសេដ្ឋីត្រូវគំរាមដោយមហាភ័យបានប្ដេជ្ញាថា ចាប់តាំងពីថ្ងៃនេះទៅ ខ្ញុំនឹងឲ្យទាន ។ សក្កទេវរាជទទួលការប្ដេជ្ញារបស់សេដ្ឋីហើយ ទ្រង់គង់ក្នុងអាកាសសម្ដែងធម៌ ដឹកនាំសេដ្ឋីឲ្យតាំងនៅក្នុងសីលហើយស្ដេចទៅកាន់ឋានរបស់ព្រះអង្គវិញ ។ ចំណែកឥល្លិសសេដ្ឋីក៏ធ្វើបុណ្យទាំងឡាយមានឲ្យទានជាដើម បានជាអ្នកមានស្ថានសួគ៌ជាទីទៅខាងមុខ ។

ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងពេលនេះប៉ុណ្ណោះទេ ដែលមោគ្គល្លានទូន្មានសេដ្ឋីកំណាញ់នោះ សូម្បីកាលពីមុនក៏ធ្លាប់ទូន្មានហើយដែរ ។ លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ឥល្លិសសេដ្ឋីក្នុងកាលនោះ បានមកជាមច្ឆរិយកោសិយសេដ្ឋីក្នុងកាលឥឡូវនេះ សក្កទេវរាជបានមក

ជាមោគ្គល្លាន ព្រះរាជាបានមកជាអានន្ទ ចំណែកជាឥកោរកាត់ គឺ **តថាគត** នេះឯង ។

ចប់ អដ្ឋកថា ឥល្លិសជាតក ទី ៨ ។

# អដ្ឋកថា ខរស្សរជាតក ទី ៩

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអាមាត្យម្នាក់ ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្ដើមថា **យតោ វិលុត្តា ច ហតា ច គាវោ** ដូច្នេះជាដើម ។

បានឮថា អាមាត្យម្នាក់របស់ព្រះបាទកោសល ញុំាងព្រះរាជាឲ្យប្រោសប្រាណហើយ បានកម្រាំងក្នុងបច្ចន្តគ្រាម បានទៅឃុបឃិតនឹងពួកចោរ គិតថា យើងនឹងនាំពួកមនុស្សចូលកាន់ព្រៃ ឲ្យពួកចោរប្លន់ស្រុកហើយបែងទ្រព្យសម្បត្តិឲ្យយើងពាក់កណ្ដាល លុះគិតដូច្នេះហើយ ក៏ហៅពួកមនុស្សឲ្យមកជុំគ្នាហើយនាំចូលព្រៃ កាលពួកចោរនាំគ្នាចាប់មេគោសម្លាប់ស៊ី ប្លន់ផ្ទះអ្នកស្រុក ហើយនាំគ្នាចៀសចេញទៅ អាមាត្យនោះមានមហាជនហែហមត្រឡប់ចូលស្រុកក្នុងវេលារសៀល មិនយូរប៉ុន្មានការធ្វើរបស់គេក៏ប្រាកដ ពួកប្រជារាស្ត្រនាំគ្នាក្រាបទូលព្រះរាជា ។ ព្រះរាជាបញ្ជាឲ្យហៅអាមាត្យនោះមកហើយឲ្យកំណត់ទោស ទ្រង់ដាក់ព្រះរាជ-អាជ្ញាសមគួរដល់ទោសានុទោស បញ្ជូនចៅហ្វាយស្រុកដទៃឲ្យទៅជំនួស

ហើយស្ដេចយាងទៅកាន់វត្តជេតពនថ្វាយបង្គំព្រះតថាគត ក្រាបទូលរឿងនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអាមាត្យនោះមានប្រក្រតីប្រព្រឹត្តយ៉ាងនេះ សូម្បីក្នុងកាលមុនក៏មានប្រក្រតីប្រព្រឹត្តយ៉ាងនេះដែរ ។ កាលព្រះបាទកោសលក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ទ្រង់បានព្រះរាជទានបច្ចន្តគ្រាមឲ្យដល់អាមាត្យម្នាក់ ។ រឿងតទៅទាំងអស់ក៏ដូចរឿងមុននោះឯង ។ គ្រានោះ ព្រះបរមពោធិសត្វត្រាច់ទៅកាន់បច្ចន្តគ្រាមដើម្បីជួញប្រែ សម្រាកនៅក្នុងស្រុកនោះ កាលចៅហ្វាយស្រុកនោះ ទូងស្គរធ្វើដំណើរមកដោយមានមហាជនហែហមក្នុងពេលរសៀល ព្រះបរមពោធិសត្វក៏ពោលថា ចៅហ្វាយស្រុកអាក្រក់ម្នាក់នេះ ឃុបឃិតជាមួយពួកចោរ ឲ្យពួកចោរប្លន់អ្នកស្រុក លុះពួកចោរនាំគ្នាគេចចូលព្រៃហើយ វាយស្គរឲ្យមានសំឡេងខ្លាំង ដើរមក ធ្វើដូចមនុស្សស្ងប់ស្ងៀម ។ ព្រះបរមពោធិសត្វ លុះពោលដូច្នោះហើយ ទើបពោលគាថានេះថា

**យតោ វិលុត្តា ច ហតា ច គាវោ**
**ទឌ្ឍានិ គេហានិ ជនោ ច នីតោ**

**អជាតមា បុត្តហាតាយ បុត្តោ**
**ខរស្សរំ ទេណ្ឌិមំ វាទយន្តោតិ ។**

*កាលណា (ពួកចោរ) ប្លន់សម្លាប់គោទាំងឡាយដុត ផ្ទះទាំងឡាយ នឹងនាំជនយកទៅហើយ ក្នុងកាល នោះ កូនរបស់ស្ត្រីដែលមានកូនស្លាប់ហើយ (គឺ ចៅហ្វាយស្រុកឥតមានសេចក្ដីអៀនខ្មាស) វាយស្គរ ឲ្យមានសំឡេងខ្លាំង ដើរមក ។*

*បណ្ដាបទទាំងនោះ បទថា* **យតោ** *ប្រែថា កាលណា ។ បទថា* **វិលុត្តា ច ហតា ច** *សេចក្ដីថា ពួកចោរប្លន់សម្លាប់ អារកគោទាំងឡាយ ដើម្បីស៊ីសាច់ ។ បទថា* **គាវោ** *បានដល់ ហ្វូងគោ ។*

*បទថា* **ទឌ្ឍានិ** *បានដល់ ដុតផ្ទះឲ្យឆេះ ។*

*បទថា* **ជនោ ច នីតោ** *បានដល់ ចាប់មនុស្ស នាំយកទៅធ្វើជា ចំណាប់ខ្មាំង ។*

*បទថា* **បុត្តហាតាយ បុត្តោ** *បានដល់ កូនស្ត្រីដែលមាតាបោះបង់ ចោលហើយ អធិប្បាយថា បានដល់មនុស្សមុខក្រាស់ព្រោះថា មនុស្ស ដែលប្រាសចាកហិរិនិងឱត្តប្បៈហើយ ឈ្មោះថា មិនមានមាតា ព្រោះ ហេតុនេះ សូម្បីមាតានៅមានជីវិត បុគ្គលនោះក៏មិនតាំងនៅក្នុងឋានៈជា កូន ព្រោះហេតុដូច្នោះ បុគ្គលនោះរមែងមានឈ្មោះថា ជាកូនរបស់ស្ត្រី*

ដែលមាតាបិតាស្លាប់ ។

បទថា **ខរស្សរំ** បានដល់ សំឡេងទ្រហឹងអឺងកង ។

បទថា **ឌេណ្ឌិមំ** បានដល់ វាយស្គរ ។

ព្រះបរមពោធិសត្វបរិភាសចៅហ្វាយស្រុកដោយគាថានេះ ដោយប្រការដូច្នេះ កម្មរបស់ចៅហ្វាយស្រុកនោះ បានប្រាកដឡើងក្នុងកាលមិនយូរឡើយ ។ គ្រានោះ ព្រះរាជាទ្រង់ដាក់ព្រះរាជទណ្ឌដល់ចៅហ្វាយស្រុកនោះ សមគួរដល់ទោសានុទោស ។

ព្រះបរមសាស្តាទ្រង់ត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលអាមាត្យនោះ មានប្រក្រតីប្រព្រឹត្តយ៉ាងនេះ សូម្បីក្នុងកាលមុនក៏មានប្រក្រតីប្រព្រឹត្តអាក្រក់ដូច្នេះដែរ ។ លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា អាមាត្យក្នុងកាលនោះ បានមកជាអាមាត្យក្នុងកាលឥឡូវនេះ ចំណែកបណ្ឌិតអ្នកលើកគាថាឡើងពោលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ខរស្សរជាតក ទី ៩ ។

# អដ្ឋកថា ភីមសេនជាតក ទី ១០

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកច្រើនទៅដោយការអួតអាងមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **យង្គេ បរិកត្ថិតំ បុរេ** *ដូច្នេះជាដើម ។*

*បានឮថា ភិក្ខុមួយរូបដើរនិយាយអួតអាង ពោលពាក្យឡេះឡោះនិយាយកុហកភិក្ខុទាំងឡាយ ទាំងដែលជាថេរៈ ទាំងដែលជានវក ទាំងដែលជាមជ្ឈិម ដោយអំណាចសម្បត្តិមានជាតិជាដើមថា អ្នកមានអាយុទាំងឡាយ ប្រសិនបើពោលដោយជាតិ អ្នកទាំងឡាយមិនស្មើនឹងខ្ញុំឡើយ បើពោលដោយគោត្ត ក៏គ្មានផ្ទុវណាស្មើនឹងគោត្តរបស់ខ្ញុំដែរ ពួកយើងកើតក្នុងត្រកូលមហាក្សត្របែបនេះ អ្នកដែលស្មើនឹងយើងដោយគោត្តក្ដី ដោយទ្រព្យក្ដី ដោយត្រកូលក្ដី មិនមានឡើយ មាសប្រាក់ជាដើមរបស់ពួកយើងមានរហូតទាល់តែរាប់មិនអស់ គ្រាន់តែពួកទាសកម្មកររបស់ពួកយើងក៏នាំគ្នាស៊ីបាយដែលជាអង្ករស្រូវសាលី ស្លៀកសំពត់ដែលមកអំពីដែនកាសីជាដើម លាបគ្រឿងក្រអូបដែលមកអំពីដែនកាសី ព្រោះតែពួកយើងជាបព្វជិតទេ ទើបពួកយើងបរិភោគភោជនសៅហ្មងព្រមទាំងប្រើ-ប្រាស់ចីវរដ៏សៅហ្មងយ៉ាងនេះ ។ គ្រានោះ ភិក្ខុមួយរូប បានសាកសួរអំពីភូមិកំណើតនៃត្រកូលរបស់លោកដឹងជាក់ច្បាស់ ក៏ពោលប្រាប់ភិក្ខុទាំង-ឡាយថា ភិក្ខុរូបនោះ ពោលអួត ពួកភិក្ខុអង្គុយប្រជុំគ្នាក្នុងធម្មសភា នាំគ្នា*

និយាយដល់ទោសមិនមែនគុណរបស់ភិក្ខុនោះថា អ្នកមានអាយុទាំងឡាយ ភិក្ខុនោះបួសក្នុង សាសនាដែលជាសាសនានាំសត្វចេញចាកទុក្ខបែបនេះ នៅតែនិយាយអួត និយាយឡេះឡោះ និយាយកុហកទៀត ។ ព្រះបរមសាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុនោះនិយាយអួត សូម្បីក្នុងកាលមុនក៏ធ្លាប់និយាយអួត និយាយឡេះឡោះ និយាយកុហកដែរ លុះទ្រង់ត្រាស់ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ក្នុងនិគមមួយ ចម្រើនវ័យហើយ រៀនត្រៃវេទដែលជាទីតាំងនៃវិជ្ជា ១៨ ប្រការ ក្នុងសម្នាក់អាចារ្យទិសាបាមោក្ខនៅក្នុងនគរតក្កសិលា រៀនចប់សិល្បៈគ្រប់ប្រការ មានឈ្មោះថា ចូឡធនុគ្គហបណ្ឌិត ។ ចូឡធនុគ្គហបណ្ឌិតចេញអំពីតក្កសិលានគរ ស្វះស្វែងរកសិល្បៈក្នុងលទ្ធិសម័យគ្រប់យ៉ាង ធ្វើដំណើរទៅដល់មហិសរ្សកដ្ឋ ក្នុងជាតកនេះ ព្រះបរមពោធិសត្វមានរាងតឿបន្តិច ដំណើរដូចមនុស្សគម ។ ចូឡធនុគ្គហបណ្ឌិតត្រិះរិះថា ប្រសិន-

បើអញចូលគាល់ព្រះរាជាអង្គណា ព្រះរាជាអង្គនោះនឹងពោលថា អ្នកមានរាងតឿយ៉ាងនេះ នឹងធ្វើជាអ្នករាជការបានឬ? ណ្ហើយចុះ អញស្វែងរកអ្នកដែលមានរាងកាយខ្ពស់មាំមួនម្នាក់ធ្វើជាខែល ហើយនឹងចិញ្ចឹមជីវិតអាស្រ័យអ្នកនោះ លុះគិតដូច្នេះហើយ ក៏ស្វែងរកបុរសដែលមានរូបរាងយ៉ាងនោះ ។ លុះទៅដល់កន្លែងនៃជាងតម្បាញម្នាក់ឈ្មោះ ភីមសេន ក៏ធ្វើបដិសណ្ឋារៈនឹងភីមសេនបណ្តើរ សួរបណ្តើរថា នែសម្លាញ់ សម្លាញ់ឯងឈ្មោះអ្វី?

ភីមសេនឆ្លើយថា ខ្ញុំឈ្មោះភីមសេន ។

ចូឡធនុគ្គហបណ្ឌិតសួរថា អ្នកជាមនុស្សមានរូបរាងស្អាត ប្រកបដោយអវយវៈគ្រប់យ៉ាងដូច្នេះ នឹងធ្វើការងារថោកទាបនេះធ្វើអ្វី?

ភីមសេនឆ្លើយថា ខ្ញុំមិនអាចនៅស្ងៀមបាន (ដោយមិនធ្វើការងារ) ។

ចូឡធនុគ្គហបណ្ឌិតពោលថា នែសម្លាញ់ សម្លាញ់ឯងកុំធ្វើការងារនេះអី ក្នុងជម្ពូទ្វីបទាំងមូលនឹងស្វែងរកនាយខ្មាន់ធ្នូដែលមានកម្លាំងខ្លាំងពូកែដូចខ្ញុំមិនមានឡើយ ប៉ុន្តែបើខ្ញុំចូលគាល់ព្រះរាជាអង្គណា ព្រះរាជាអង្គនោះនឹងក្រោធចំពោះខ្ញុំថា មនុស្សតឿយ៉ាងនេះនឹងធ្វើជាអ្នករាជការបានដូចម្តេច អ្នកគប្បីចូលគាល់ព្រះរាជាក្រាបទូលថា ខ្ញុំព្រះអង្គជានាយ-ខ្មាន់ធ្នូដូច្នេះ ព្រះរាជានឹងព្រះរាជទានរង្វាន់ឲ្យអ្នក ហើយព្រះរាជទានស្បៀងរឿយៗ ខ្ញុំនឹងរង់ចាំធ្វើការងារដែលកើតឡើងដល់អ្នក ខ្ញុំសូមរស់

ក្រោយខ្នងអ្នកដោយពិធីយ៉ាងនេះ យើងទាំងពីរនាក់ក៏នឹងរស់នៅជាសុខ អ្នកចូរធ្វើតាមពាក្យរបស់ខ្ញុំ ភីមសេនក៏យល់ព្រម ។ ចូឡធនុគ្គហបណ្ឌិតក៏នាំភីមសេនទៅកាន់នគរពារាណសី ធ្វើខ្លួនឯងជាអ្នកបម្រើ លើកភីមសេនដាក់ខាងមុខ ឈរនៅក្បែរខ្លោងទ្វារព្រះរាជដ្ឋាន ឲ្យក្រាបទូលព្រះរាជា លុះបានទទួលព្រះបរមរាជានុញ្ញាតថា នាំគ្នាចូលមកចុះ ទាំងពីរនាក់ក៏ចូលទៅថ្វាយបង្គំព្រះរាជា ហើយឈរនៅក្នុងទីដ៏សមគួរមួយ ។ កាលព្រះរាជាត្រាស់សួរថា អ្នកទាំងពីរនាំគ្នាមកធ្វើអ្វី ?

ភីមសេនក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំជានាយខ្មាន់ធ្នូ ក្នុងជម្ពូទ្វីបទាំងមូលនឹងស្វែងរកនាយខ្មាន់ធ្នូដូចទូលបង្គំ មិនមានឡើយ ។

ព្រះរាជាត្រាស់សួរថា នែនាយខ្មាន់ធ្នូ អ្នកបានអ្វីទើបសុខចិត្តបម្រើយើង ?

ភីមសេនក្រាបទូលថា កាលបានព្រះរាជទ្រព្យ ១ ពាន់កហាបណៈរាល់ៗ កន្លះខែ ទើបទូលបង្គំចូលមកទទួលរាជការ ។

ព្រះរាជាត្រាស់សួរថា បុរសម្នាក់នេះ ត្រូវជាអ្វីនឹងអ្នក ?

ភីមសេនក្រាបទូលថា ព្រះករុណាថ្លៃវិសេស បុរសម្នាក់នេះ ជាអ្នកបម្រើរបស់ទូលបង្គំ ។

ព្រះរាជាត្រាស់ថា ប្រពៃហើយ ចូរបម្រើយើងចុះ ។ ចាប់ពីពេល-

នោះមក ភីមសេនក៏ចូលទទួលបម្រើរាជការ ប៉ុន្តែរាជកិច្ចដែលកើតឡើង ហើយ ព្រះបរមពោធិសត្វចាត់ចែងធ្វើតែម្នាក់ឯង ។

ក្នុងសម័យនោះ មានព្រៃមួយដែលនៅក្នុងដែនកាសី មានខ្លាដ៏កាចសាហាវ ស្ទាក់ផ្លូវទៅមកនៃមនុស្សទាំងឡាយ ចាប់ពួកមនុស្សយកទៅស៊ីជាច្រើន ។ អ្នកក្រុងនាំគ្នាក្រាបទូលរឿងនោះចំពោះព្រះរាជា ព្រះរាជាបញ្ជាឲ្យហៅភីមសេនចូលគាល់រួចសួរថា នែអ្នកដ៏ចម្រើន អ្នកអាចចាប់ខ្លាបានទេ ?

ភីមសេនក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ប្រសិនបើទូលបង្គំមិនអាចចាប់ខ្លាបាន ទូលបង្គំនឹងមានឈ្មោះថានាយខ្មាន់ធ្នូដូចម្ដេចបាន ? ព្រះរាជាព្រះរាជទានរង្វាន់ឲ្យភីមសេនហើយ ទ្រង់បញ្ជូនឲ្យទៅចាប់ខ្លា ភីមសេនទៅដល់ផ្ទះប្រាប់ព្រះបរមពោធិសត្វ ។ ព្រះបរមពោធិសត្វពោលថា ប្រពៃហើយសម្លាញ់ សម្លាញ់ឯងទៅចុះ ។

ភីមសេនសួរថា អ្នកមិនទៅទេឬ ?

ព្រះបរមពោធិសត្វឆ្លើយថា ខ្ញុំមិនទៅទេ ប៉ុន្តែនឹងប្រាប់ឧបាយ ។

ភីមសេនពោលថា ចូរប្រាប់មកចុះ សម្លាញ់ ។

ព្រះបរមពោធិសត្វប្រាប់ថា អ្នកកុំប្រញាប់ទៅកន្លែងខ្លាតែម្នាក់ឯងជាដាច់ខាត ត្រូវប្រជុំអ្នកជនបទ កេណ្ឌឲ្យកាន់ធ្នូទៅឲ្យបានមួយពាន់ ឬពីរពាន់នាក់ហើយទៅកន្លែងខ្លានោះ លុះដឹងថាវាក្រោកឡើងត្រូវប្រញាប់

ចូលគុម្ពោតព្រៃ ដេកក្រាប ចំណែកពួកអ្នកស្រុកនឹងនាំគ្នាវាយខ្លារហូត ទាល់តែចាប់បាន លុះអ្នកស្រុកទាំងនោះចាប់ខ្លាបានហើយ អ្នកត្រូវយក ធ្មេញខាំវល្លិមួយសរសៃ ចាប់ចុងវល្លិដើរទៅកាន់ទីនោះ លុះទៅដល់ទីជិត ខ្លាដែលងាប់ហើយគប្បីពោលថា នែអ្នកដ៏ចម្រើនទាំងឡាយ អ្នកណាធ្វើ ឲ្យខ្លានេះងាប់ ? ខ្ញុំគិតថានឹងចងខ្លាដោយវល្លិនេះ ដូចគេចងគោដឹកទៅ កាន់រាជដំណាក់ឲ្យទាល់តែបាន ខ្ញុំចូលទៅកាន់គុម្ពោតព្រៃដើម្បីរកវល្លិ កាលមិនទាន់បាននាំវល្លិមក អ្នកណាសម្លាប់ខ្លានេះឲ្យងាប់បាត់ទៅហើយ កាលបើដូច្នេះ អ្នកស្រុកទាំងនោះភ័យខ្លាចពោលថា បពិត្រលោកម្ចាស់ សូមលោកមេត្តាកុំក្រាបទូលព្រះរាជាឡើយ ហើយនាំគ្នាឲ្យទ្រព្យជាច្រើន ដល់អ្នក ខ្លាក៏អ្នកចាប់បាន ទាំងទ្រព្យក៏អ្នកបានអំពីសម្នាក់ព្រះរាជាទៀត ផង ។ ភីមសេនយល់ព្រមថា ប្រពៃពិតមែន ហើយទៅចាប់ខ្លាតាមការ ណែនាំរបស់ព្រះបរមពោធិសត្វ ធ្វើព្រៃឲ្យអស់ភ័យហើយមានមហាជន ហែហមមកកាន់នគរពារាណសី ចូលគាល់ព្រះរាជាក្រាបទូលថា បពិត្រ ព្រះសម្មតិទេព ទូលបង្គំចាប់ខ្លាបានហើយ ធ្វើព្រៃឲ្យអស់ភ័យហើយ ។ ព្រះរាជាទ្រង់រីករាយសប្បាយព្រះទ័យ ព្រះរាជទានទ្រព្យយ៉ាងច្រើន ។ ថ្ងៃ ស្អែកឡើង ពួកអ្នកក្រុងមកក្រាបទូលថា មានក្របីកាចស្ទាក់ផ្លូវអ្នកដំណើរ មួយកន្លែង ព្រះរាជាក៏បញ្ជូនភីមសេនទៅដោយទំនងដូចមុន ភីមសេនក៏ ចាប់ក្របីនោះបានមក តាមពាក្យណែនាំរបស់ព្រះបរមពោធិសត្វដូច

ពេលចាប់ខ្លាដូច្នោះ ។ ព្រះរាជាក៏បានព្រះរាជទានទ្រព្យឲ្យជាច្រើនទៀត កើតមានឥស្សរិយយសដ៏ធំក្រៃលែង ភីមសេនផ្ដើមស្រវឹង ដោយការស្រវឹងក្នុងភាពជាធំ មើលងាយព្រះបរមពោធិសត្វ មិនជឿពាក្យណែនាំ ពោលពាក្យគ្រោតគ្រាតអសុរោះជាដើមថា យើងមិនបានចិញ្ចឹមជីវិតអាស្រ័យអ្នកទេ អ្នកតែប៉ុណ្ណោះឬដែលជាកូនប្រុសនោះ ?

ក្រោយមកមិនបានប៉ុន្មានថ្ងៃផង ព្រះរាជានៃប្រទេសជិតខាងមួយព្រះអង្គលើកទ័ពមកឡោមព័ទ្ធនគរពារាណសី រួចបញ្ជូនព្រះរាជសាសន៍ទៅថ្វាយព្រះរាជាថា ព្រះអង្គព្រមឲ្យរាជសម្បត្តិដល់ទូលបង្គំ ឬច្បាំង ។ ព្រះរាជាទ្រង់បញ្ជូនភីមសេនឲ្យចេញទៅថា អ្នកចូរចេញទៅច្បាំង ។ ភីមសេនពាក់គ្រឿងចម្បាំងគ្រប់យ៉ាង តែងខ្លួនជាព្រះរាជាអង្គុយលើខ្នងដំរីដែលតាក់តែងល្អហើយ សូម្បីព្រះបរមពោធិសត្វក៏ពាក់គ្រឿងចម្បាំងគ្រប់យ៉ាង អង្គុយជិតនាំខាងចុងទីអង្គុយរបស់ភីមសេននោះឯង ព្រោះខ្លាចភីមសេនស្លាប់ ។ ស្ដេចដំរីហែហមដោយមហាជន លើកក្បួនចេញទៅតាមខ្លោងទ្វារនគរ លុះដល់សមរភូមិ ភីមសេនគ្រាន់តែបានឮសំឡេងស្គរចម្បាំងភ្លាមក៏ភ័យញាប់ញ័រ ព្រះបរមពោធិសត្វខ្លាចភីមសេនធ្លាក់អំពីខ្នងដំរីស្លាប់ ទើបយកខ្សែចងភីមសេនឲ្យជាប់ដើម្បីមិនឲ្យធ្លាក់អំពីខ្នងដំរី លុះបានឃើញសមរភូមិភ្លាម ភីមសេនរឹតតែខ្លាចស្លាប់ខ្លាំងឡើងៗ រហូតដល់ឧច្ចារៈបស្សាវៈហូរស្រោចខ្នងដំរី ។ ព្រះបរមពោធិសត្វពោលថា នៃ

ភីមសេន ការធ្វើនៅពេលនេះ មិនដូចពាក្យនិយាយនៅពេលមុនៗរបស់អ្នកឡើយ ពេលមុនមើលទៅអ្នកហាក់ដូចជាអ្នកក្លៀវក្លា ជាអ្នកស្ទាត់ជំនាញក្នុងសង្គ្រាម ពេលនេះអ្នកបានប្រទូសរ៉ាយខ្នងដំរីហើយ រួចពោលគាថាដោយមានសេចក្ដីថា

**យន្តេ បវិកត្ថិតំ បុរេ**
**អថ តេ បូតិសរា សជន្តិ បច្ឆា**
**ឧភយំ ន សមេតិ ភីមសេន**
**យុទ្ធកថា ច ឥទញ្ច តេ វិហញ្ញន្តិ ។**

ម្នាលភីមសេន ក្នុងកាលមុន ឯងបានអួតហើយ ក្នុងកាលក្រោយ ស្រាប់តែគ្រឿងសំអុយសម្រាប់ហូរចេញ ( អាចម៍) របស់ឯង ហូរចេញមក ហេតុទាំងពីរមិនសមគ្នា គឺការនិយាយអំពីចម្បាំងនិងការចង្អៀតចង្អល់ចិត្តរបស់ឯងនេះ ។

បណ្ដាបទទាំងនោះ បទថា **យន្តេ បវិកត្ថិតំ បុរេ** សេចក្ដីថា ពាក្យណា គឺពាក្យដែលអ្នកបានអួតហើយថា ឯងតែម្នាក់ប៉ុណ្ណោះឬដែលជាកូនប្រុសនោះ ខ្ញុំមិនមែនជាកូនប្រុសឬ ? សូម្បីខ្ញុំក៏ជាទាហានដែលជំនាញខាងចម្បាំង ដូច្នេះ នេះជាពាក្យមុន ។

បទថា **អថ តេ បូតិសរា សជន្តិ បច្ឆា** សេចក្ដីថា ក្នុងកាលខាងក្រោយមូត្រនិងលាមកដែលមានឈ្មោះថា គ្រឿងសម្អុយ ព្រោះវាជា

*របស់ស្តុយផង ជារបស់ហូរបានផង បានហូរចេញមក ។ ពាក្យថា* **បច្ឆា** *បានដល់ ក្រោយអំពីការអួតនោះ អធិប្បាយថា ពេលនេះ គឺពេលដែលនៅក្នុងសមរភូមិនេះ ។*

*បទថា* **ឧភយំ ន សមេតិ ភីមសេន** *នៃភីមសេន ពាក្យទាំង-ពីរនេះ មើលទៅមិនសមគ្នាឡើយ ។*

*សួរថា ពាក្យណាខ្លះ ?*

*ឆ្លើយថា គឺពាក្យដែលអួតអំពីការច្បាំង និងការចង្អៀតចង្អល់ចិត្តរបស់អ្នកនេះ មានអធិប្បាយថា បានដល់ពាក្យដែលពោលអំពីចម្បាំងក្នុងកាលមុន និងការចង្អៀតចង្អល់ ការលំបាកចិត្តរហូតដល់ហូរមូត្រនិងលាមកស្រោចខ្នងដំរីមិនសមគ្នាឡើយ ។*

*ព្រះបរមពោធិសត្វតិះដៀលភីមសេនយ៉ាងនេះហើយ លួងលោមថា កុំខ្លាចឡើយសម្លាញ់ ដរាបណានៅមានខ្ញុំ អ្នកកុំខ្លាចឡើយ ដូច្នេះហើយ ឲ្យភីមសេនចុះអំពីខ្នងដំរី រួចពោលថា ចូរទៅងូតទឹកចុះ បញ្ជូនភីមសេនឲ្យត្រឡប់ទៅដោយត្រិះរិះថា ថ្ងៃនេះអញគួរបង្ហាញខ្លួន ហើយបំបោលដំរីចូលកាន់សង្គ្រាម បន្លឺសីហនាទ ឡោមព័ទ្ធវាយបំបែកកងទ័ព ប្រើឲ្យចាប់ព្រះរាជាដែលជាសត្រូវបានហើយទៅគាល់ព្រះបាទពារាណសី ។ ព្រះរាជាទ្រង់សប្បាយព្រះទ័យ ព្រះរាជទានយសដ៏ធំដល់ព្រះបរមពោធិសត្វ ។ ចាប់តាំងពីពេលនោះមក ឈ្មោះថា ចូឡធនុគ្គហបណ្ឌិត ក៏ខ្ចរខ្ចាយទៅ*

ពេញជម្ពូទ្វីប ។ ព្រះបរមពោធិសត្វបានឲ្យរង្វាន់ដល់ភីមសេន ហើយបញ្ជូនឲ្យត្រឡប់ទៅភូមិកំណើតវិញ ធ្វើបុណ្យមានឲ្យទានជាដើម ហើយក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះច្រើនទៅដោយការអួតអាងនោះ សូម្បីក្នុងកាលមុនក៏ធ្លាប់ជាអ្នកអួតអាងដែរ ។ លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ភីមសេនក្នុងកាលនោះបានមកជាភិក្ខុអ្នកច្រើនទៅដោយការអួតអាងក្នុងកាលឥឡូវនេះ ចំណែកចូឡធនុគ្គហបណ្ឌិត គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ភីមសេនជាតក ទី ១០ ។

ចប់ អដ្ឋកថា វរុណវគ្គ ទី ៨ ។

# រួមជាតកដែលមានក្នុងវគ្គនេះគឺ

វរុណជាតក ១ សីលវនាគជាតក ១ សច្ចង្កិរជាតក ១ រុក្ខធម្មជាតក ១ មច្ឆជាតក ១ អសង្កិយជាតក ១ មហាសុបិនជាតក ១ ឥល្លិសជាតក ១ ខរស្សរជាតក ១ ភីមសេនជាតក ១ ។

# អបាយិម្ហវគ្គ ទី ៩
# អដ្ឋកថា សុរាបានជាតក ទី ១

ព្រះបរមសាស្តា កាលទ្រង់អាស្រ័យនគរកោសម្ពី ទ្រង់គង់នៅក្នុង ឃោសិតារាម ទ្រង់ប្រារព្ធព្រះសាគតត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មាន ពាក្យផ្តើមថា **អចាយិម្ហ អនច្ចិម្ហ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា កាលព្រះដ៏មានព្រះភាគទ្រង់ចាំព្រះវស្សានៅក្នុង នគរសាវត្ថីហើយ ស្តេចយាងទៅកាន់ចារិករហូតដល់និគមឈ្មោះ ភទ្ទវតិកា ពួកអ្នកចិញ្ចឹមគោ ចិញ្ចឹមសត្វ អ្នកស្រែ និងអ្នកធ្វើដំណើរ ឃើញព្រះបរម-សាស្តាស្តេចយាងមកហើយ នាំគ្នាទៅថ្វាយបង្គំ រួចក្រាបទូលឃាត់ថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់កុំយាងទៅកាន់កំពង់ឈ្មោះអម្ពៈឡើយ នាគឈ្មោះ អម្ពតិត្ថកៈ ដែលនៅនឹងអាស្រមរបស់ជដិលត្រង់កំពង់អម្ពៈ កាចសាហាវណាស់ នឹងបៀតបៀនព្រះអង្គបាន ។ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើដូចជាទ្រង់មិនបានឮពាក្យរបស់មនុស្សទាំងនោះ សូម្បីមនុស្សទាំង នោះឃាត់អស់វារៈ ៣ ដង ក៏ទ្រង់នៅតែយាងទៅដដែល ។ បានឮថា ពេលនោះ ព្រះដ៏មានព្រះភាគស្តេចយាងទៅគង់នៅក្នុងដងព្រៃមួយកន្លែង មិនឆ្ងាយអំពីភទ្ទវតិកានិគមនោះ ។ គ្រានោះ ព្រះសាគតត្ថេរជាពុទ្ធុបដ្ឋាក ប្រកបដោយឫទ្ធិដែលជារបស់បុថុជ្ជនចូលទៅជិតអាស្រមនោះ ក្រាល កម្រាលដែលធ្វើអំពីស្មៅនៅក្នុងលំនៅរបស់ស្តេចនាគនោះ ហើយគង់

ពត់ភ្នែន នាគអត់ធន់នឹងការមើលងាយមិនបានក៏បញ្ចេញផ្សែង ព្រះថេរៈក៏បញ្ចេញផ្សែងតប ។ នាគធ្វើឲ្យភ្លើងឆេះ ព្រះថេរៈក៏ធ្វើឲ្យភ្លើងឆេះដែរ តេជះរបស់នាគគ្របសង្កត់ព្រះថេរៈមិនបាន ប៉ុន្តែតេជះរបស់ព្រះថេរៈគ្របសង្កត់នាគបាន ។ ព្រះថេរៈទូន្មានស្តេចនាគនោះធ្វើឲ្យតាំងនៅក្នុងសរណៈក្នុងសីលបានហើយ ទើបនិមន្តទៅកាន់សម្នាក់ព្រះបរមសាស្តា ។ ចំណែកព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគមឈ្មោះភទ្ទវតិកាតាមព្រះពុទ្ធអធ្យាស្រ័យហើយ ស្តេចយាងទៅកាន់នគរកោសម្ពីវិញ ។ រឿងរ៉ាវដែលព្រះសាគតត្ថេរទូន្មានស្តេចនាគ បានឮសុសសាយផ្សាយទូទៅពេញជនបទ ។

អ្នកនគរកោសម្ពីធ្វើការទទួលព្រះបរមសាស្តា នាំគ្នាថ្វាយបង្គំព្រះអង្គហើយ ក៏ហួសទៅកាន់សម្នាក់ព្រះសាគតត្ថេរ ថ្វាយបង្គំហើយឈរនៅក្នុងទីដ៏សមគួរ រួចនាំគ្នាពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន វត្ថុណាដែលលោកម្ចាស់បានដោយកម្រ សូមលោកម្ចាស់ប្រាប់វត្ថុនោះចុះ ពួកខ្ញុំព្រះករុណានឹងចាត់ចែងវត្ថុនោះប្រគេន ។ ព្រះថេរៈក៏នៅស្ងៀម ប៉ុន្តែពួកឆព្វគ្គិយភិក្ខុនាំគ្នានិយាយថា អ្នកមានអាយុទាំងឡាយ សុរាពណ៌ក្រហមដូចជើងព្រាបជាវត្ថុដែលបព្វជិតរកបានដោយកម្រក្រៃលែង ហើយក៏ជាវត្ថុគួរឲ្យពេញចិត្តផងដែរ ប្រសិនបើអ្នកទាំងឡាយជ្រះថ្លាចំពោះព្រះថេរៈ ចូរចាត់ចែងសុរាពណ៌ក្រហមដូចពណ៌ជើងព្រាបប្រគេនចុះ ។ អ្នក

នគរទាំងនោះក៏យល់ព្រមដោយពាក្យថា ប្រពៃហើយលោកម្ចាស់ នាំគ្នាក្រាបទូលនិមន្តព្រះបរមសាស្តាដើម្បីទ្រង់ឆាន់ក្នុងថ្ងៃស្អែក ហើយនាំគ្នាចូលកាន់នគរ ម្នាក់ៗចាត់ចែងសុរាដែលមានពណ៌ក្រហមដូចជើងព្រាបទុកក្នុងផ្ទះរបស់ខ្លួនដោយបំណងថា នឹងប្រគេនព្រះថេរៈ និមន្តព្រះថេរៈទៅហើយ នាំគ្នាប្រគេនសុរាគ្រប់ៗផ្ទះ ។ ព្រះថេរៈឆាន់សុរាហើយស្រវឹងនិមន្តចេញអំពីនគរ ដួលនៅក្បែរខ្លោងទ្វារនគរដេកថ្ងូរនៅទីនោះឯង ។ ព្រះបរមសាស្តាទ្រង់ធ្វើភត្តកិច្ចហើយ កាលទ្រង់យាងចេញអំពីនគរ ទ្រង់ទតឃើញព្រះថេរៈដេកដោយអាការដូច្នោះ មានព្រះពុទ្ធតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជួយគ្រាហ៍សាគតទៅ ទ្រង់ឲ្យពួកភិក្ខុគ្រាហ៍ព្រះសាគតត្ថេរទៅកាន់អារាម ។ ពួកភិក្ខុដាក់សីសៈរបស់ព្រះថេរៈនៅក្បែរបាទមូលព្រះតថាគត ហើយឲ្យដេកបែរសីសៈទៅរកព្រះតថាគត ព្រះសាគតត្ថេរត្រឡប់ដេកសណ្ដូកជើង ឆ្ពោះទៅរកព្រះភក្ត្រព្រះបរមសាស្តាទៅវិញ ។ ព្រះបរមសាស្តាត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ការគោរពតថាគតដែលសាគតធ្លាប់មានពីមុននោះ ឥឡូវនេះនៅមានឬទេ ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនមានទេ ។

ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាច្បាំងជាមួយស្តេចនាគឈ្មោះអម្ពតិត្ថកៈ ?

ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន គឺសាគតភិក្ខុ ។

ព្រះដ៏មានព្រះភាគត្រាស់សួរថា ឥឡូវនេះ សាគតនៅអាចប្រាំង ជាមួយពស់ទឹកបានឬ ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន រឿងនោះមិន អាចទេ ។

ព្រះដ៏មានព្រះភាគត្រាស់សួរទៀតថា ម្នាលភិក្ខុទាំងឡាយ ផឹកវត្ថុ ណាហើយ ប្រាសចាកការចងចាំ វង្វេងស្មារតីយ៉ាងនេះ វត្ថុនោះ ភិក្ខុគួរ ផឹកឬ ?

ភិក្ខុទាំងឡាយក្រាបទូលថា មិនគួរឡើយ ព្រះអង្គ ។

ព្រះដ៏មានព្រះភាគទ្រង់តិះដៀលព្រះថេរៈហើយ ទ្រង់ត្រាស់ហៅ ភិក្ខុទាំងឡាយមក ទ្រង់បញ្ញត្តសិក្ខាបទ ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ព្រោះ ផឹកសុរានិងមេរ័យ ហើយស្ដេចក្រោកចាកអាសនៈយាងចូលកាន់ព្រះគន្ធ-កុដិ ។ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភានិយាយអំពីទោសនៃការផឹក សុរាថា អ្នកមានអាយុទាំងឡាយ ដែលឈ្មោះថាការផឹកសុរាមានទោស ខ្លាំងណាស់ ធ្វើឲ្យព្រះសាគតត្ថេរដែលមានឈ្មោះថាសម្បូរដោយបញ្ញា មានឫទ្ធិ មិនដឹងសូម្បីតែគុណរបស់ព្រះបរមសាស្ដា ទើបបានធ្វើយ៉ាង នោះ ។ ព្រះបរមសាស្ដាស្ដេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំង-ឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿង អ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់

ថា ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតផឹកសុរាហើយសន្ទប់បាត់ស្មារតីដេកស្តូកស្តឹងនោះ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏មានរឿងដូច្នេះដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ក្នុងដែនកាសី ចម្រើនវ័យហើយ បួសជាឥសី បានសម្រេចអភិញ្ញានិងសមាបត្តិ លេងឈានរស់នៅក្នុងហិមវន្តប្រទេស ហែហមដោយអន្តេវាសិកប្រមាណ ៥០០ អង្គ ។ លុះដល់រដូវភ្លៀង ពួកអន្តេវាសិកនាំគ្នាប្រាប់អាចារ្យថា បពិត្រលោកអាចារ្យ ពួកយើងនាំគ្នាទៅកាន់ដែនមនុស្សបរិភោគរបស់ជូរ ប្រៃ ហើយសឹមត្រឡប់មកវិញ ។ ឥសីពោធិសត្វពោលថា អាវុសោយើងនឹងរង់ចាំនៅទីនេះ អ្នកទាំងឡាយនាំគ្នាទៅចុះ ទំនុកបម្រុងរាងកាយរហូតអស់រដូវភ្លៀងហើយ ចូរនាំគ្នាត្រឡប់មកវិញ ។ អន្តេវាសិកទាំងនោះយល់ព្រមដោយពាក្យថា ប្រពៃហើយលោកអាចារ្យ ហើយនាំគ្នាលាអាចារ្យទៅកាន់នគរពារាណសី ស្នាក់នៅក្នុងព្រះរាជឧទ្យាន ។ លុះព្រឹកឡើង ក៏នាំគ្នាត្រាច់ទៅភិក្ខាចារនៅក្នុងស្រុកមួយ ខាងក្រៅខ្លោងទ្វារនគរ បានទទួលការឧបត្ថម្ភយ៉ាងល្អ ។ ថ្ងៃស្អែកទៀត ក៏នាំគ្នាចូលទៅកាន់នគរ អ្នកនគរនាំគ្នារីករាយប្រគេនភិក្ខាចារ ។ កន្លងមកពីរ-បីថ្ងៃ អ្នកនគរក៏នាំគ្នា

ក្រាបទូលព្រះរាជាថា បពិត្រមហារាជ ឥសី ៥០០ អង្គ មកអំពីព្រៃហេមពាន្ត ស្នាក់នៅក្នុងព្រះរាជឧទ្យាន មានតបធម៌ដ៏ខ្លាំងក្លា មានឥន្ទ្រីយ៍ដែលឈ្នះហើយយ៉ាងកំពូល ជាអ្នកមានសីល ។ ព្រះបាទពារាណសីទ្រង់ព្រះសណ្តាប់គុណរបស់ឥសីទាំងនោះហើយ ស្តេចយាងទៅកាន់ព្រះរាជ-ឧទ្យាន ទ្រង់នមស្ការហើយធ្វើបដិសណ្ឋារៈ និមន្តឲ្យគង់នៅក្នុងព្រះរាជ-ឧទ្យាននោះ រហូត ៤ ខែរដូវភ្លៀង ។ ចាប់តាំងពីពេលនោះមក ឥសីទាំងនោះក៏ឆាន់ក្នុងព្រះរាជវាំង សម្រាកនៅក្នុងព្រះរាជឧទ្យាននោះឯង ។

ថ្ងៃមួយ ក្នុងនគរមានបុណ្យនក្ខត្តឫក្សមួយ ឈ្មោះថាសុរានក្ខត្តឫក្ស ព្រះរាជាទ្រង់ព្រះតម្រិះថា សុរាជារបស់ដែលបព្វជិតទាំងឡាយរកបានដោយកម្រ ទើបបញ្ជាឲ្យថ្វាយសុរាយ៉ាងល្អជាច្រើនដល់តាបសទាំងនោះ ។ តាបសទាំងនោះផឹកសុរាហើយត្រឡប់ទៅកាន់ព្រះរាជឧទ្យានវិញ មួយរូបៗក៏ស្រវឹងសុរា ពួកខ្លះក្រោកឡើងរាំ ពួកខ្លះច្រៀង លុះរាំច្រៀងហើយក៏នាំគ្នាដេកលក់សង្កត់បរិក្ខារមានឈើច្រត់ជាដើម លុះស្វាងសុរាក៏ភ្ញាក់ឡើងឃើញអាការដ៏ប្លែកមិនគួរដល់បព្វជិតឡើយ ក៏ពោលថា ពួកយើងនៅឆ្ងាយអំពីអាចារ្យ នាំគ្នាធ្វើអំពើដ៏លាមកយ៉ាងនេះ ភ្លាមនោះឯង ក៏នាំគ្នាបោះបង់ព្រះរាជឧទ្យានត្រឡប់ទៅកាន់ព្រៃហេមពាន្តវិញ ទុកដាក់បរិក្ខារត្រឹមត្រូវហើយ ចូលទៅថ្វាយបង្គំអាចារ្យ រួចអង្គុយក្នុងទីដ៏សមគួរ ។ កាលអាចារ្យសួរថា នែអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយមិនលំបាក

ដោយភិក្ខាទេឬ ? រស់នៅជាសុខសប្បាយក្នុងភូមិមនុស្សឬ ? អ្នកទាំង-ឡាយនៅតែសាមគ្គីគ្នាទេឬ ? ក៏ឆ្លើយថា បពិត្រលោកអាចារ្យដ៏ចម្រើន ពួកខ្ញុំរស់នៅជាសុខសប្បាយទេ ក៏ប៉ុន្តែពួកខ្ញុំនាំគ្នាផឹកទឹកដែលមិនគួរផឹក សន្ធប់បាត់ស្មារតីដេកស្តូកស្តឹងរៀងៗខ្លួន មិនអាចទប់ស្មារតីបាន នាំគ្នាច្រៀងរាំតាមទំនើងចិត្ត កាលប្រាប់រឿងនោះចំពោះអាចារ្យក៏នាំគ្នាពោលគាថានេះថា

**អបាយិម្ហ អនច្ចិម្ហ អគាយិម្ហ រុទិម្ហ ច**
**វិសញ្ញិករណឹ បិត្វា ទិដ្ឋា នាហុម្ហ វានរាតិ ។**

ពួកយើងបានផឹកសុរា បានរាំ បានច្រៀង បានយំ
ហើយ ពួកយើង មិនមែនជាពានរ ព្រោះតែផឹកសុរា
ដែលធ្វើឲ្យខូចសញ្ញា ទើបឃើញ ( អាក្រក់ជាល្អ ) ។

បណ្ដាបទទាំងនោះ បទថា **អបាយិម្ហ** ប្រែថា ពួកខ្ញុំនាំគ្នាផឹកសុរា ។

បទថា **អនច្ចិម្ហ** សេចក្ដីថា លុះផឹកហើយ ក៏ធ្គងដោយដៃ ធ្គងដោយជើង នាំគ្នារាំ ។

បទថា **អគាយិម្ហ** សេចក្ដីថា បើកមាត់ច្រៀងដោយមានសំឡេងខ្លាំង ។

បទថា **រុទិម្ហ ច** សេចក្ដីថា ត្រឡប់មានវិប្បដិសារៈ នាំគ្នាស្រែក

*យំថា ពួកយើងបានធ្វើនូវអំពើដែលមិនសមគួរ ។*

*បទថា* **ជិឃ្នា ជាហុម្ហ វាជរា** *សេចក្តីថា ព្រោះផឹកសុរាដែលជាហេតុធ្វើឲ្យសញ្ញាវិបរិត ព្រោះទម្លាយសញ្ញាចោល រឿងនោះនៅល្អដែរ ត្រង់ដែលថាពួកខ្ញុំមិនក្លាយទៅជាស្វា ពួកអន្តេវាសិកទាំងនោះ ពោលទោសរបស់ខ្លួនដោយប្រការដូច្នេះ ។*

*ព្រះបរមពោធិសត្វពោលថា ជម្មតានរជនដែលនៅឆ្ងាយអំពីគ្រូរមែងដូច្នេះឯង ព្រះបរមពោធិសត្វតិះដៀលតាបសទាំងនោះហើយ ឲ្យឱវាទថា អ្នកទាំងឡាយកុំធ្វើអំពើបែបនេះតទៅទៀត មានឈានមិនសាបសូន្យ ក្រោយអំពីចុតិបានទៅកាន់ព្រហ្មលោក ។*

*ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ពួកឥសីក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ចំណែកអាចារ្យ គឺ* **តថាគត** *នេះឯង ។ សូមប្រកាសថា ចាប់ពីរឿងនេះទៅនឹងមិនពោលដល់បទថា* **អនុសង្ខី ឃជេត្វា** *នេះតទៅទៀតទេ ៕*

ចប់ អដ្ឋកថា សុរាបានជាតក ទី ១ ។

# អដ្ឋកថា មិត្តវិន្ទជាតក ទី ២

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **អតិក្កម្ម រមណកំ** *ដូច្នេះជាដើម ។*

*ក្នុងជាតកនេះ ជារឿងកើតឡើងក្នុងសាសនានៃ* **ព្រះកស្សប-សម្មាសម្ពុទ្ធ** *នឹងជាក់ច្បាស់ក្នុង* **មហាមិត្តវិន្ទកជាតក** *។ ក្នុងកាលនោះព្រះបរមពោធិសត្វពោលគាថានេះថា*

អតិក្កម្ម រមណកំ　　　សទាមត្តញ្ច ទូភកំ
ស្វាសិ ចាសាណមាសីនោ យស្មា ជីវំ ន មោក្ខសីតិ។

*អ្នកនោះ កន្លងនូវប្រាសាទកែវផ្លេកផង ប្រាសាទប្រាក់ផង ប្រាសាទកែវមណីផង ជាអ្នកត្រូវថ្ម ( គឺចក្រមានមុខមុតដូចកាំបិតកោរ ) គ្របសង្កត់ហើយ អ្នកកាលរស់នៅមិនរួចអំពីចក្រនោះទេ ។*

*បណ្ដាបទទាំងនោះ បទថា* **រមណកំ** *ជាឈ្មោះនៃកែវផ្លេក ក្នុងកាលនោះ ព្រះបរមពោធិសត្វសម្ដែងថា អ្នកនោះកន្លងផុតប្រាសាទកែវផ្លេកទៅហើយ ។*

*បទថា* **សទាមត្តញ្ច** *ជាឈ្មោះនៃប្រាក់ ព្រះបរមពោធិសត្វសម្ដែងថា អ្នកនោះកន្លងនូវប្រាសាទប្រាក់ទៅហើយ ។*

*បទថា* **ទូភកំ** *ជាឈ្មោះនៃកែវមណី ព្រះបរមពោធិសត្វសម្ដែង*

ថា អ្នកនោះកន្ទង់នូវប្រាសាទកែវមណីទៅហើយ ។

បទថា **ស្វាសិ** កាត់បទជា **សោ អសិ** ប្រែថា អ្នកនោះ ។

បទថា **ចាសាណមាសីនោ** សេចក្ដីថា ចក្រនោះសម្រេចអំពីថ្ម ក៏មាន សម្រេចអំពីកែវមណីក៏មាន ប៉ុន្តែចក្រដែលវាយបំបែកក្បាលអ្នក នោះ សម្រេចអំពីថ្ម កាលបើពោល គួរពោលថា **ចាសាណាសីនោ** ប៉ុន្តែត្រូឡប់ជាពោលថា **ចាសាណមាសីនោ** ដោយកាន់យក **ម** អក្សរ ដោយអំណាចព្យញ្ជនសន្ធិ មានអធិប្បាយម្យ៉ាងទៀតថា ទូលកង់ចក្រ ដែលសម្រេចអំពីថ្ម គឺត្រូវកង់ចក្រនោះខៃក្បាល។

បទថា **យស្មា ជីវំ ន មោក្ខសិ** សេចក្ដីថា ទាំងដែលនៅរស់ នោះឯង នឹងមិនផុតអំពីកង់ចក្រនោះទេ ត្រូវទូលវាជានិច្ច រហូតបាបកម្ម របស់អ្នកអស់ ។

ព្រះបរមពោធិសត្វពោលគាថានេះហើយ ស្ដេចទៅកាន់ទេវលោក ភ្វាម ចំណែកមិត្តវិន្ទក៏នៅទូលកង់ចក្រសោយទុក្ខយ៉ាងមហន្ត លុះបាប-កម្មអស់ ក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ ប្រជុំជាតកថា មិត្តវិន្ទក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាល ឥឡូវនេះ ចំណែកទេវរាជ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា មិត្តវិន្ទជាតក ទី ២ ។

# អដ្ឋកថា កាឡកណ្ណិជាតក ទី ៣

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតវន ទ្រង់ប្រារព្ធមិត្តរបស់អនាថបិណ្ឌិកសេដ្ឋីម្នាក់ ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្ដើមថា* **មិត្តោ ហវេ សត្តបទេន ហោតិ** *ដូច្នេះជាដើម ។*

*បានឮមកថា បុរសនោះធ្លាប់ជាសម្លាញ់លេងដីជាមួយនឹងអនាថ-បិណ្ឌិកសេដ្ឋី តាំងពីកាលនៅរៀនសិល្បៈក្នុងសម្នាក់អាចារ្យជាមួយគ្នា ដោយឈ្មោះមានឈ្មោះថា កាឡកណ្ណី ។ កាឡកណ្ណីនោះក្រោយមកក៏ធ្លាក់ខ្លួនក្រ មិនអាចចិញ្ចឹមជីវិតបាន ក៏ទៅកាន់សម្នាក់អនាថបិណ្ឌិកសេដ្ឋី លោកសេដ្ឋីក៏លួងលោមសម្លាញ់នោះ ឲ្យស្បៀងហើយប្រគល់សម្បត្តិរបស់ខ្លួនឲ្យមួយចំណែក ។ កាឡកណ្ណីនោះជាអ្នកធ្វើឧបការៈចំពោះលោកសេដ្ឋី ធ្វើកិច្ចគ្រប់យ៉ាងពេលដែលគេមកកាន់សម្នាក់សេដ្ឋី ។ មនុស្សទាំងឡាយនាំគ្នាពោលថា ឈប់សិនកាឡកណ្ណី អង្គុយសិនចុះកាឡកណ្ណី បរិភោគសិនចុះកាឡកណ្ណី ។ ថ្ងៃមួយ មិត្តនិងអាមាត្យរបស់លោកសេដ្ឋីនាំគ្នាចូលទៅរកលោកសេដ្ឋីហើយនិយាយយ៉ាងនេះថា មហាសេដ្ឋី លោកកុំចិញ្ចឹមកាឡកណ្ណី កុំជិតស្និទ្ធនឹងបុរសនេះឡើយ ព្រោះសូម្បីយក្សក៏ត្រូវចៀសចេញទៅដោយសំឡេងនេះថា ឈប់សិនកាឡកណ្ណី អង្គុយសិនចុះកាឡកណ្ណី បរិភោគសិនចុះកាឡកណ្ណី គេក៏មិនស្មើនឹងលោក ធ្លាក់ខ្លួនក្រហើយ លោកចិញ្ចឹមមនុស្សបែបនេះធ្វើអ្វី ?*

អនាថបិណ្ឌិកសេដ្ឋីពោលថា ធម្មតាឈ្មោះសម្រាប់ហៅ បណ្ឌិតទាំងឡាយមិនកាន់យកជាប្រមាណទេ ( គាត់គិតថា ) មិនគួរជាប្រភេទមនុស្សដែលមានឈ្មោះថា សុតមង្គលិក ( ប្រកាន់មង្គលតាមសំឡេងដែលបានឮ ) អញមិនអាចអាស្រ័យហេតុត្រឹមតែឈ្មោះ ហើយបោះបង់សម្លាញ់ដែលលេងដីជាមួយគ្នាចោលបានទេ ។ លុះគិតដូច្នេះហើយ មិនបានកាន់យកពាក្យសម្តីរបស់មនុស្សទាំងនោះទេ ។ ថ្ងៃមួយ កាលនឹងទៅស្រុកសួយរបស់ខ្លួន បានប្រគល់កាឡកណ្ណិឲ្យជាអ្នករក្សាគេហដ្ឋាន ។

ពួកចោរគិតគ្នាថា បានឮថាសេដ្ឋីទៅស្រុកសួយរបស់គាត់ហើយ ពួកយើងទៅប្លន់ផ្ទះរបស់គាត់ចុះ នាំគ្នាកាន់អាវុធផ្សេងៗ មកក្នុងវេលាអធ្រាត្រព័ទ្ធផ្ទះលោកសេដ្ឋី ។ ចំណែកកាឡកណ្ណិសង្ស័យខ្លាចពួកចោរមកប្លន់ ទើបអង្គុយយាមមិនព្រមដេក លុះដឹងថាពួកចោរមក ដើម្បីនឹងដាស់ពួកមនុស្សទើបស្រែកឡើងថា អ្នកទាំងឡាយ ចូរផ្លុំស័ង្ខ ចូរវាយស្គរ លុះស្រែកដូច្នោះហើយ ក៏ធ្វើឲ្យដូចជាមានរោងមហោស្រពធំ ធ្វើនិវេសន៍ទាំងអស់ឲ្យមានសំឡេងកងរំពងទូទៅ ។ ពួកចោរនិយាយប្រាប់គ្នាថា ពួកយើងបានឮថា ផ្ទះគ្មានអ្នកណានៅ ពួកយើងបានស្តាប់មកមិនល្អហើយ សេដ្ឋីគ្មានធ្វើដំណើរទៅណាទេ គឺនៅក្នុងផ្ទះនេះឯង ហើយម្នាក់ៗ បោះដុំដី ដុំថ្មនិងដំបងជាដើមចោលទីនោះឯង រួចរត់ចៀសចេញទៅ ។ លុះព្រឹកឡើងមនុស្សទាំងឡាយឃើញដុំថ្មនិងដំបងជាដើម ដែលពួកចោរបោះចោល

នៅទីនោះៗ ម្នាក់ៗ ក៏តក់ស្លុតហើយនិយាយថា ប្រសិនបើថ្ងៃនេះ មិនមានអ្នកយាមផ្ទះដែលសម្បូរដោយការចេះដឹង និងឈ្លាសវៃបែបនេះទេ ពួកចោរនឹងចូលតាមការពេញចិត្ត ប្លន់ផ្ទះបានទាំងអស់ជាប្រាកដ ព្រោះអាស្រ័យមិត្តដែលមោះមុតអង់អាចក្លាហានបែបនេះ ទើបសេចក្ដីចម្រើនកើតមានដល់លោកសេដ្ឋី ម្នាក់ៗនាំគ្នាសរសើរកាឡកណ្ណិ ។ ពេលដែលសេដ្ឋីមកអំពីស្រុកសួយ ក៏នាំគ្នាប្រាប់រឿងរ៉ាវនោះឲ្យជ្រាបគ្រប់ប្រការ ។ គ្រានោះ សេដ្ឋីបាននិយាយទៅកាន់មនុស្សទាំងនោះថា អ្នកទាំងឡាយប្រើយើងឲ្យដេញមិត្តអ្នករក្សាផ្ទះយ៉ាងនេះ ចេញអំពីផ្ទះរបស់យើង ប្រសិនបើយើងបណ្ដេញគេឲ្យចេញអំពីផ្ទះតាមពាក្យរបស់អ្នកទាំងឡាយនោះ ថ្ងៃនេះ ទ្រព្យរបស់យើងនឹងមិនសេសសល់ឡើយ ធម្មតាថា ឈ្មោះមិនជាប្រមាណទេ ចិត្តដែលគិតជួយប៉ុណ្ណោះ ទើបជាប្រមាណ លុះពោលដូច្នេះហើយ ក៏ឲ្យទ្រព្យជាដើមទុនដល់កាឡកណ្ណិច្រើនឡើងៗ ។ សេដ្ឋីបានត្រិះរិះថា ពេលនេះអញមានរឿងដែលជាប្រធានល្មមក្រាបទូលព្រះដ៏មាន-ព្រះភាគបានហើយ ក៏ធ្វើដំណើរទៅកាន់សម្នាក់ទ្រង់ ក្រាបទូលរឿងរ៉ាវនោះតាំងអំពីដើមដល់ចប់ចំពោះព្រះអង្គ ។ ព្រះបរមសាស្ដាទ្រង់ត្រាស់ថា ម្នាលគហបតី មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលមិត្តឈ្មោះកាឡកណ្ណិរក្សាទ្រព្យក្នុងផ្ទះមិត្តរបស់ខ្លួនទុកនោះ សូម្បីក្នុងកាលមុនក៏រក្សាហើយដែរ ។ កាលសេដ្ឋីក្រាបទូលអារាធនា ទើបទ្រង់នាំយករឿង

ក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបានជាសេដ្ឋីមានយសដ៏ធំក្រៃលែង សេដ្ឋីមានមិត្តម្នាក់ឈ្មោះកាឡកណ្ណិ ។ រឿងរ៉ាវទាំងអស់ក៏ដូចរឿងបច្ចុប្បន្ននេះឯង ។ ព្រះបរមពោធិសត្វមកអំពីស្រុកស្លួយហើយ ស្តាប់រឿងនោះរួចពោលថា ប្រសិនបើយើងបណ្តេញមិត្តដូច្នេះចេញអំពីផ្ទះរបស់យើងតាមពាក្យរបស់អ្នកទាំងឡាយនោះ ម្ល៉េះសមថ្ងៃនេះទ្រព្យសម្បត្តិរបស់យើងនឹងមិនសេសសល់ឡើយ ហើយពោលគាថានេះថា

**មិត្តោ ហវេ សត្តបទេន ហោតិ**
**សហាយោ បន ទ្វាទសកេន ហោតិ**
**មាសឌ្ឍមាសេន ច ញាតិ ហោតិ**
**តតុត្តរឹ អត្តសមោបិ ហោតិ**
**សោហំ កថំ អត្តសុខស្ស ហេតុ**
**ចិរសន្ថុតំ កាលកណ្ណិំ ជហេយ្យន្តិ ។**

បុគ្គលដែលជាមិត្តបាន ដោយ ( ហេតុត្រឹមតែដើរជាមួយគ្នា ) ប្រាំពីរជំហាន បុគ្គលជាសម្លាញ់បាន ដោយ ( ហេតុត្រឹមតែដើរជាមួយគ្នា ) ដប់ពីរជំហាន បុគ្គលដែលជាញាតិបាន ដោយ ( ការនៅជាមួយគ្នា ) មួយខែ

ឬកន្លះខែ បុគ្គលដែលទុកស្មើនឹងខ្លួន ព្រោះនៅលើស
អំពីកាលនោះទៅទៀត ខ្ញុំនោះនឹងលះបង់នូវសម្លាញ់
ឈ្មោះកាឡកណ្ណិ ដែលធ្លាប់ស្និទ្ធស្នាលអស់កាលយូរ
ព្រោះហេតុនៃសេចក្តីសុខរបស់ខ្លួនដូចម្តេចបាន ។

បណ្តាបទទាំងនោះ បទថា **ហវេ** ត្រឹមតែជានិបាត ។ ដែលឈ្មោះថា មិត្ត ព្រោះអត្ថថា ប្រព្រឹត្តដោយមេត្រី អធិប្បាយថា ចូលទៅតាំងទុកនូវមេត្រីចិត្ត ធ្វើសេចក្តីស្និទ្ធស្នាល ក៏បុគ្គលដែលជាមិត្តបាន ដោយហេតុត្រឹមតែដើរជាមួយគ្នាប្រាំពីរជំហាន ។

បទថា **សហាយោ បន ទ្វាទសកេន ហោតិ** សេចក្តីថា ដែលឈ្មោះថា សម្លាញ់ ព្រោះអត្ថថា រួមគ្នាក្នុងឥរិយាបថទាំងពួងដោយអំណាចនៃការធ្វើកិច្ចគ្រប់យ៉ាងរួមគ្នា អធិប្បាយថា បុគ្គលដែលជាសម្លាញ់បាន ដោយហេតុត្រឹមតែដើរជាមួយគ្នាដប់ពីរជំហាន ។

បទថា **មាសឌ្ឍមាសេន** សេចក្តីថា នៅរួមគ្នាមួយខែ ឬ កន្លះខែ ។

បទថា **ញាតិ ហោតិ** សេចក្តីថា រមែងមានឈ្មោះថា ជាអ្នកស្មើនឹងញាតិ ។

បទថា **តតុត្តរឹ** សេចក្តីថា ព្រោះការនៅរួមគ្នាលើសអំពីកាលនោះ រមែងរាប់ថា ជាអ្នកស្មើនឹងខ្លួនបាន ។

*បទថា* **ជហេយ្យំ** *សេចក្តីថា ខ្ញុំនឹងបោះបង់នូវសម្លាញ់ដូច្នោះដូចម្តេចបាន ។*

*ព្រះបរមពោធិសត្វពោលដល់គុណនៃមិត្តនោះ ដោយប្រការដូច្នេះ ។ តាំងពីនោះមក គ្មានអ្នកណាហ៊ានប្រព្រឹត្តល្មើសកាឡកណ្ណិទៀតឡើយ ។*

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា កាឡកណ្ណិក្នុងកាលនោះ បានមកជាអានន្ទ ចំណែកពារាណសីសេដ្ឋី គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា កាឡកណ្ណិជាតក ទី ៣ ។

# អដ្ឋកថា អត្ថស្ស ទ្វារជាតក ទី ៤

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុលបុត្តដែលឈ្លាសវៃក្នុងប្រយោជន៍ម្នាក់ ត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា* **អារោគ្យមិច្ឆេ បរមញ្ច លាភំ** *ដូច្នេះជាដើម ។*

*មានរឿងសង្ខេបថា ក្នុងនគរសាវត្ថី បុត្តរបស់សេដ្ឋីអ្នកមានសម្បត្តិច្រើនម្នាក់ កើតមកបាន ៧ ឆ្នាំជាអ្នកមានបញ្ញាឈ្លាសវៃក្នុងប្រយោជន៍ ។ ថ្ងៃមួយ ក្មេងនោះបានចូលទៅរកសេដ្ឋីជាបិតា សួរបញ្ហាដែលជាទ្វារនៃប្រយោជន៍ សេដ្ឋីជាបិតាមិនដឹងបញ្ហានោះ ទើបកើតបរិវិតក្កថា បញ្ហានេះល្អិតសុខុមក្រៃលែងណាស់ វៀរព្រះសម្មាសម្ពុទ្ធចេញហើយ អ្នកដទៃ*

ក្នុងលោកសន្និវាស ដែលកំណត់ដោយភវគ្គព្រហ្មជាចំណែកខាងលើបំផុត និងដោយអវិចីជាចំណែកខាងក្រោមបំផុត ដែលអាចនឹងដោះស្រាយបញ្ហានេះបាន មិនមានឡើយ ។ លុះគិតដូច្នេះហើយ ឲ្យបុត្តកាន់ផ្កានិងគ្រឿងក្រអូបជាច្រើននាំទៅកាន់វត្តជេតពន បូជាព្រះបរមសាស្តាហើយថ្វាយបង្គំរួចអង្គុយក្នុងទីដ៏សមគួរ សេដ្ឋីក្រាបទូលរឿងនោះចំពោះព្រះដ៏មានព្រះ-ភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្មេងនេះមានបញ្ញាឈ្លាសក្នុងប្រយោជន៍ សួរបញ្ហានឹងខ្ញុំព្រះអង្គអំពីទ្វារនៃប្រយោជន៍ ខ្ញុំព្រះអង្គមិនអាចដោះ-ស្រាយបញ្ហានោះបាន ទើបមកកាន់សម្នាក់ព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមឱកាស សូមព្រះដ៏មានព្រះភាគដោះស្រាយបញ្ហានោះចុះ ។

ព្រះបរមសាស្តាទ្រង់ត្រាស់តបថា ម្នាលឧបាសក សូម្បីក្នុងកាលមុន តថាគតក៏ត្រូវក្មេងនេះសួរបញ្ហានោះដែរ ហើយតថាគតក៏ស្រាយបញ្ហានោះហើយដែរ គ្រានោះ ក្មេងនេះដឹងបញ្ហានោះ ប៉ុន្តែឥឡូវនេះ ក្មេងនេះចាំមិនបានព្រោះភពបិទបាំង ។ កាលសេដ្ឋីក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាសេដ្ឋីមានទ្រព្យសម្បត្តិច្រើន ។ គ្រានោះ បុត្តរបស់សេដ្ឋីកើតមកបាន ៧ ឆ្នាំ ជាអ្នកមាន

បញ្ញាឈ្វាសក្នុងប្រយោជន៍ ។ ថ្ងៃមួយ បុត្រនោះចូលទៅរកបិតាសួរបញ្ហា អំពីទ្វារនៃប្រយោជន៍ថា បពិត្របិតា អ្វីជាទ្វារនៃប្រយោជន៍ ? គ្រានោះ សេដ្ឋីកាលនឹងដោះស្រាយបញ្ហានោះ បានពោលគាថានេះថា

**អារោគ្យមិច្ឆេ បរមញ្ច លាភំ**
**សីលញ្ច ពុទ្ធានុមតំ សុតញ្ច**
**ធម្មានុវត្តី ច អលីនតា ច**
**អត្ថស្ស ទ្វារា បមុខា ឆឡេតេ ។**

បុគ្គលគប្បីប្រាថ្នាលាភដ៏ឧត្តម គឺការមិនមានរោគ ១ សីល (គឺមារយាទ) ១ ការយល់ឃើញតាមបណ្ឌិតអ្នកដឹង ១ ការឧស្សាហ៍ស្តាប់ ១ ការអនុវត្តន៍នូវសុចរិតធម៌ ១ ការមិនរួញរានៃចិត្ត ១ ធម៌ទាំង ៦ នេះ ជាទ្វារ ទាំងជាប្រធាននៃសេចក្តីចម្រើន ។

បណ្តាបទទាំងនោះ បទថា ច អក្សរក្នុងបទថា **អារោគ្យមិច្ឆេ បរមញ្ច លាភំ** ត្រឹមតែជានិបាត ។ ព្រះបរមពោធិសត្វកាលនឹងសម្តែងសេចក្តីនេះថា នៃកូនដ៏ចម្រើន មុនដំបូងគប្បីប្រាថ្នាលាភដ៏ឧត្តម ពោលគឺការមិនមានរោគ ទើបពោលយ៉ាងនេះ ។

ដែលឈ្មោះថាភាពជាអ្នកមិនមានរោគ ក្នុងបាទគាថាថា **អារោគ្យ-មិច្ឆេ បរមញ្ច លាភំ** នោះ បានដល់ អាការដែលមិនមានការចាក់សៀត មិនមានការរសាប់រសល់នៃកាយនិងចិត្ត ។ ព្រោះថា កាលរាងកាយត្រូវ

ចាក់សៀត ឈឺចាប់ក្រវល់ក្រវាយ បុគ្គលរមែងមិនអាចញ៉ាំងលាភដែលមិនទាន់កើតឲ្យកើតឡើងបានឡើយ លាភដែលបានហើយក៏មិនអាចប្រើប្រាស់បាន ប៉ុន្តែកាលកាយមិនមានរោគ រមែងញ៉ាំងលាភឲ្យកើតបានទាំងពីរយ៉ាង ម្យ៉ាងទៀត កាលចិត្តក្តៅក្រហាយព្រោះឧបក្កិលេស មនុស្សក៏មិនអាចញ៉ាំងលាភគឺគុណវិសេសមានឈានជាដើម ដែលមិនទាន់កើតឲ្យកើតឡើង ឈានដែលបានហើយក៏មិនអាចនឹងរីករាយដោយអំណាចនៃសមាបត្តិបាន កាលរោគនោះនៅមាន សូម្បីលាភដែលមិនទាន់បានក៏មិនបាន សូម្បីលាភដែលបានហើយក៏ឥតប្រយោជន៍ ប៉ុន្តែកាលមិនមានរោគ សូម្បីលាភដែលមិនទាន់បានក៏នឹងត្រូវបាន សូម្បីបានហើយក៏រមែងអំណោយផល ហេតុនោះការមិនមានរោគ ទើបឈ្មោះថាជាលាភដ៏ក្រៃលែង ចាំបាច់ត្រូវប្រាថ្នាការមិនមានរោគនោះ មុនគេទាំងអស់ នេះជាទ្វារឯកនៃប្រយោជន៍ ទាំងអស់នេះជាការអត្ថាធិប្បាយក្នុងសេចក្តីនោះ ។

បទថា **សីលញ្ច** បានដល់ អាចារសីល គឺរបៀបរបបក្នុងចំណែកនៃមារយាទ ព្រះបរមពោធិសត្វសម្តែងដល់ចរិតនៃសត្វលោកដោយបទនេះ ។

បទថា **ពុទ្ធានុមតំ** បានដល់ ការយល់តាមបណ្ឌិតអ្នកចម្រើនដោយគុណទាំងឡាយ ព្រះបរមពោធិសត្វសម្តែងឱវាទរបស់គ្រូទាំងឡាយ អ្នកសម្បូរដោយការចេះដឹងដោយបទនេះ ។

បទថា **សុតញ្ច** សេចក្ដីថា គឺការស្ដាប់ដែលអាងហេតុផល ព្រះ-បរមពោធិសត្វសម្ដែងដល់ពហុសច្ចៈ ភាពជាអ្នកឧស្សាហ៍ក្នុងការស្ដាប់ដែលអាស្រ័យខ្លួនក្នុងលោកនេះ ដោយបទនេះ ។

បទថា **ធម្មានុវត្តី ច** បានដល់ ការប្រព្រឹត្តិតាមសុចរិតធម៌ ៣ យ៉ាង ។ ព្រះបរមពោធិសត្វសម្ដែងដល់ការវៀរចាកទុច្ចរិតធម៌ ហើយប្រព្រឹត្តសុចរិតធម៌ដោយបទនេះ ។

បទថា **អលីនតា ច** បានដល់ ការដែលចិត្តមិនរួញរា មិនធ្លាក់ទាប ។ ព្រះបរមពោធិសត្វសម្ដែងដល់សភាពនៃចិត្តដែលជាជាសភាវៈប្រណីត និងជាសភាវៈដ៏ខ្ពស់បំផុត មិនសាបសូន្យដោយបទនេះ ។

បទថា **អត្ថស្ស ទ្វារា បមុខា ឆឡេតេ** សេចក្ដីថា សេចក្ដីចម្រើនឈ្មោះថា ប្រយោជន៍ ធម៌ទាំង ៦ ប្រការនេះ ជាទ្វារ ជាឧបាយ គឺជាផ្លូវដ៏ខ្ពង់ខ្ពស់នៃប្រយោជន៍ ជាលោកិយផង ជាលោកុត្តរផង ពោលគឺសេចក្ដីចម្រើន ។

ព្រះបរមពោធិសត្វដោះស្រាយបញ្ហាដែលជាទ្វារនៃប្រយោជន៍-ដល់បុត្រដោយប្រការដូច្នេះ តាំងពីនោះមកបុត្ររបស់ព្រះបរមពោធិសត្វនោះក៏ប្រព្រឹត្តធម៌ ៦ ប្រការនោះជានិច្ច ។ ព្រះបរមពោធិសត្វបំពេញបុណ្យមានឲ្យទានជាដើមហើយ លុះអស់ជីវិតក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ប្រជុំ

*ជាតកថា បុត្តក្នុងគ្រានោះ បានមកជាបុត្តសេដ្ឋីក្នុងបច្ចុប្បន្ននេះ ចំណែកមហាសេដ្ឋី គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា អត្ថស្ស ទ្វារជាតក ទី ៤ ។

# អដ្ឋកថា កិម្បក្កជាតក ទី ៥

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអផ្សុកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **អាយតឹ ទោសំ នាញ្ញាយ** *ដូច្នេះជាដើម ។*

*បានឮថា កុលបុត្តមួយរូបបួសឧទ្ទិសជីវិតចំពោះព្រះពុទ្ធសាសនា ។ ថ្ងៃមួយ ត្រាច់បិណ្ឌបាតក្នុងនគរសាវត្ថី ឃើញស្ត្រីម្នាក់តែងខ្លួនគួរឲ្យស្រឡាញ់ក៏កើតការអផ្សុក ។ គ្រានោះ អាចារ្យនិងឧបជ្ឈាយ៍របស់លោកនាំលោកមកកាន់សម្នាក់ព្រះបរមសាស្តា ។ ព្រះបរមសាស្តាត្រាស់សួរថា ម្នាលភិក្ខុ អ្នកកើតការអផ្សុកមែនឬ ? កាលភិក្ខុនោះក្រាបទូលថា ពិតមែនហើយព្រះអង្គ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុដែលឈ្មោះថាបញ្ចកាមគុណ ជាវត្ថុគួរឲ្យត្រេកអរក្នុងវេលាបរិភោគ ប៉ុន្តែការបរិភោគបញ្ចកាមគុណនោះ ប្រៀបដូចនឹងការបរិភោគផ្លែកិម្បក្កៈ ( ផ្លែឈើពុលមួយប្រភេទ ផ្លែកិម្បក្កៈនោះ ប៉ុនផ្លែស្វាយ ) ព្រោះជាហេតុឲ្យកើតក្នុងនរកជាដើម ផ្លែកិម្បក្កៈនោះ សម្បូរដោយពណ៌ ក្លិន និងរស ប៉ុន្តែបរិភោគទៅហើយកាត់*

ពោះវៀន ធ្វើឲ្យអស់ជីវិត ។ ក្នុងកាលមុនមនុស្សជាច្រើនមិនឃើញទោស របស់ផ្លែនេះ ជាប់ចិត្តក្នុងពណ៌ ក្លិន និងរស ម្នាក់ៗ បរិភោគផ្លែនោះ ក៏ អស់ជីវិត ។ កាលភិក្ខុទាំងនោះក្រាបទូលអារាធនា ទើបទ្រង់នាំយករឿង ក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុង នគរពារាណសី ព្រះបរមពោធិសត្វជាប្រធាននៃពួករទេះ គ្រប់គ្រងពួក រទេះ ៥០០ ធ្វើដំណើរទៅកាន់ជាយដែនដាច់ស្រយាល ទៅដល់មាត់ព្រៃ មួយឈប់សម្រាកហើយហៅអ្នករទេះនោះមកប្រជុំ ដាស់តឿនថា ក្នុងព្រៃ នេះ មានដើមឈើដែលមានឈ្មោះថា កិម្បក្កៈ (ឈើពុល) បើអ្នកមិនទាន់ បានសួរខ្ញុំជាមុនទេនោះ កុំបរិភោគផលាផលដែលមិនធ្លាប់បរិភោគមកពី មុនជាដាច់ខាត ។ អ្នកធ្វើដំណើរក៏បានដើរចូលទៅកាន់ព្រៃ បានឃើញ ដើមកិម្បក្កៈ (ដើមឈើពុលមួយប្រភេទ មានផ្លែប៉ុនផ្លែស្វាយ) មួយដើម មានមែកកោងចុះ ព្រោះផ្លែច្រើន ដើម មែក ស្លឹករបស់វាដូចដើមស្វាយ ទាំងសណ្ឋាន ពណ៌ ក្លិន និងរសក៏ដូចផ្លែស្វាយដែរ នាំគ្នាបរិភោគផ្លែឈើ នោះ ដោយសម្គាល់ថាជាផ្លែស្វាយ ពួកខ្លះក៏និយាយថា ត្រូវសួរប្រធាន រទេះសិន សឹមបរិភោគ កាន់ផ្លែឈើនោះឈររង់ចាំព្រះបរមពោធិសត្វ ។ លុះព្រះបរមពោធិសត្វមកដល់ ក៏ស្រែកប្រាប់ពួកដែលកាន់ផ្លែឈើរង់ចាំ នោះឲ្យបោះផ្លែនោះចោល ហើយឲ្យថ្នាំដល់ជនដែលបរិភោគចូលទៅ ឲ្យ

ក្អួតចេញមក អ្នកបរិភោគទាំងនោះ អ្នកខ្លះក៏រួចផុតពីការពុល ប៉ុន្តែពួកដែលបរិភោគចូលទៅយូរពេក ក៏ដល់នូវការអស់ជីវិត ។ ចំណែកព្រះ-បរមពោធិសត្វធ្វើដំណើរទៅដល់ទិសដៅដោយសុវត្ថិភាព បានលាភហើយត្រឡប់មកផ្ទះវិញ ធ្វើបុណ្យមានឲ្យទានជាដើមហើយ លុះអស់ជីវិតក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្តាទ្រង់ត្រាស់រឿងនោះហើយ ត្រាស់ព្រះគាថានេះថា

**អាយតឹ ទោសំ នាញ្ញាយ យោ កាមេ បដិសេវតិ**
**វិបាកន្តេ ហនន្តិ នំ កិម្បក្កមិវ ភក្ខិតន្តិ ។**

បុគ្គលណា មិនយល់ទោសក្នុងអនាគត ហើយសេពកាម
ទាំងឡាយ (កាមទាំងនោះ) តែងសម្លាប់បុគ្គលនោះ ក្នុង
ទីបំផុតនៃផល ដូចបុគ្គលស៊ីផ្លែឈើកិម្បក្កៈ ( ឈើពុល ) ។

បណ្តាបទទាំងនោះ បទថា **អាយតឹ ទោសំ នាញ្ញាយ** សេចក្តីថា មិនដឹង គឺ មិនជ្រាបទោសក្នុងកាលខាងមុខ ។

បទថា **យោ កាមេ បដិសេវតិ** សេចក្តីថា បុគ្គលសេពវត្ថុកាមនិងកិលេសកាម ។

បទថា **វិបាកន្តេ ហនន្តិ នំ** សេចក្តីថា កាមទាំងនោះ ក្នុងទីបំផុត នឹងញុំាងបុគ្គលនោះដែលកើតហើយក្នុងនរកជាដើម ពោលគឺវិបាករបស់ខ្លួន ឲ្យជួបប្រសព្វនូវទុក្ខមានប្រការផ្សេងៗ ឈ្មោះថារមែងកម្ចាត់នូវ

*បុគ្គលនោះ ។*

*សួរថា កម្មាត់ដូចម្ដេច ?*

*ឆ្លើយថា ដូចផ្លែកិម្បក្កៈដែលបុគ្គលបរិភោគហើយដូច្នោះ អធិប្បាយថា ឧបមាដូចផ្លែកិម្បក្កៈ គួរពេញចិត្ត ព្រោះដល់ព្រមដោយពណ៌ ក្លិន និងរស ក្នុងវេលាបរិភោគធ្វើឲ្យមនុស្សមិនឃើញទោសក្នុងអនាគត បរិភោគ ហើយដល់នូវការអស់ជីវិតយ៉ាងណា កាមទាំងឡាយសូម្បីធ្វើឲ្យត្រេកអរក្នុងវេលាបរិភោគ ក៏ប៉ុន្តែរមែងសម្លាប់បុគ្គលអ្នកបរិភោគនោះ ក្នុងវេលាឲ្យផលដូច្នោះ ។*

*ព្រះបរមសាស្ដា ទ្រង់សម្ដែងធម៌តាមអនុសន្ធិ ហើយទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ ភិក្ខុអ្នកអផ្សុកនោះ បានសម្រេចសោតាបត្តិផល បរិស័ទដ៏សេស ពួកខ្លះបានជាព្រះសោតាបន្ន ពួកខ្លះបានជាព្រះសកទាគាមី ពួកខ្លះបានជាព្រះអនាគាមី ពួកខ្លះបានជាព្រះអរហន្ត ។ ព្រះបរមសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា បរិស័ទក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកប្រធានពួករទេះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា កិម្បក្កជាតក ទី ៥ ។

# អដ្ឋកថា សីលវីមំសនជាតក ទី ៦

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ព្រាហ្មណ៍អ្នកសាកល្បងសីលម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សីលំ កិរេវ កល្យាណំ** ដូច្នេះជាដើម ។

បានឮថា ព្រាហ្មណ៍នោះចិញ្ចឹមជីវិតអាស្រ័យព្រះបាទកោសល ជាអ្នកដល់ត្រៃសរណគមន៍មានសីល ៥ មិនដាច់ រៀនចេះចប់ត្រៃវេទ ព្រះរាជាទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះមានសីល ដូច្នេះហើយ ទ្រង់ក៏សរសើរព្រាហ្មណ៍នោះយ៉ាងក្រៃលែង ។ ព្រាហ្មណ៍គិតថា ព្រះរាជាអង្គនេះ សរសើរអញក្រៃលែងជាងព្រាហ្មណ៍ដទៃៗ ទ្រង់ឃើញអញដូចអ្នកគួរឲ្យគោរពយ៉ាងក្រៃលែង ទ្រង់លើកតម្កើងអញយ៉ាងនេះ ព្រោះអាស្រ័យជាតិសម្បត្តិ គោត្រសម្បត្តិ កុលសម្បត្តិ បទេសសម្បត្តិ និងសីលសម្បត្តិរបស់អញឬ ? ឬថាទ្រង់អាស្រ័យសីលសម្បត្តិរបស់អញតែម្យ៉ាង ? អញនឹងពិសោធមើល ។ ថ្ងៃមួយ គាត់ចូលទៅគាល់ព្រះរាជា កាលត្រឡប់មកផ្ទះវិញ បានយកកហាបណៈ ១ អំពីកន្ទេងហិរញ្ញិកម្នាក់ដោយមិនបានប្រាប់ ។ គ្រានោះ ហិរញ្ញិកមិនបាននិយាយអ្វីនឹងព្រាហ្មណ៍នោះឡើយ អង្គុយធ្វើព្រងើយព្រោះគោរពព្រាហ្មណ៍ ។ ថ្ងៃស្អែក បានកាន់យក ២ កហាបណៈ ហិរញ្ញិកក៏អង្គុយធ្វើមិនដឹងទៀត ។ ថ្ងៃទី ៣ ស្រវាចាប់ពេញដៃ គ្រានោះ ហិរញ្ញិកក៏និយាយនឹងព្រាហ្មណ៍នោះថា ថ្ងៃនេះ ជាថ្ងៃទី ៣ ដែលលោក

លួចយកទ្រព្យរបស់ព្រះរាជា និយាយបណ្ដើរ ស្រែកបណ្ដើរ ៣ ដងថា យើងចាប់ចោរលួចទ្រព្យព្រះរាជាបានហើយ ។ គ្រានោះ មនុស្សទាំង-ឡាយនាំគ្នារត់មកអំពីទិសផ្សេងៗ រួចនិយាយនឹងព្រាហ្មណ៍ថា លោកធ្វើខ្លួនដូចជាអ្នកមានសីលអស់កាលប្រមាណប៉ុណ្ណោះ ដូច្នេះហើយ ម្នាក់ៗក៏តិះដៀលព្រាហ្មណ៍ រួចចាប់ចងយកទៅថ្វាយព្រះរាជា ។ ព្រះរាជាទ្រង់ក្ដៅព្រះទ័យ ត្រាស់សួរថា នែព្រាហ្មណ៍ ហេតុអ្វីទើបអ្នកធ្វើអំពើរបស់អ្នកទ្រុស្តសីលដូច្នេះ ? ហើយត្រាស់បន្តទៀតថា នែអ្នកទាំងឡាយ អ្នកទាំង-ឡាយ ចូរដាក់អាជ្ញាដល់ព្រាហ្មណ៍នេះចុះ ។

ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនមែនជាចោរទេ ។

ព្រះរាជាត្រាស់សួរថា ប្រសិនបើអ្នកមិនមែនជាចោរទេ ហេតុដូច-ម្ដេច ទើបយកកហាបណៈអំពីកន្ទេងនៃព្រះរាជទ្រព្យ ?

ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះសម្មតិទេព ការដែលទូលបង្គំធ្វើក្នុងកាលព្រះអង្គទ្រង់លើកតម្កើងទូលបង្គំយ៉ាងក្រៃលែងដូច្នេះនោះ ក៏ដើម្បីពិសោធមើលថា ព្រះរាជាទ្រង់លើកតម្កើងអញយ៉ាងនេះ ព្រោះទ្រង់អាស្រ័យសម្បត្តិមានជាតិជាដើមឬ ? ឬថាទ្រង់អាស្រ័យសីល ? តែពេលនេះទូលបង្គំជ្រាបដោយច្បាស់លាស់ហើយ ព្រោះព្រះអង្គទ្រង់បញ្ជាឲ្យរាជបុរសដាក់ព្រះរាជអាជ្ញាដល់ទូលបង្គំនៅពេលនេះ ជាការប្រៀបធៀប

បានថា ការស្ញើចសរសើរដែលព្រះអង្គធ្វើចំពោះទូលបង្គំនោះ អាស្រ័យសីលតែម្យ៉ាង ទ្រង់មិនបានធ្វើព្រោះអាស្រ័យសម្បត្តិមានជាតិជាដើមឡើយ ហើយក្រាបទូលតទៅទៀតថា ទូលបង្គំនោះបានយល់ឃើញថា ក្នុងលោកនេះ សីលប៉ុណ្ណោះខ្ពស់បំផុត សីលជាប្រមុខ កាលទូលបង្គំនឹងធ្វើឲ្យសមគួរដល់សីលនេះ ហើយនៅគ្រប់គ្រងផ្ទះបរិភោគកាមគុណនោះ នឹងមិនអាចធ្វើបានឡើយ ថ្ងៃនេះ ទូលបង្គំនឹងទៅកាន់វត្តជេតពនបួសក្នុងសម្នាក់ព្រះបរមសាស្តា សូមទ្រង់អនុញ្ញាតឲ្យទូលបង្គំចេញទៅបំពេញបព្វជ្ជាផងចុះ ។ លុះសូមព្រះបរមរាជានុញ្ញាតបានហើយ ក៏ធ្វើដំណើរសំដៅទៅកាន់វត្តជេតពន ។ គ្រានោះ ពួកញាតិនិងអ្នកស្និទ្ធស្នាលនាំគ្នាចោមរោម កាលមិនអាចឃាត់ព្រាហ្មណ៍នោះបាន ក៏នាំគ្នាត្រឡប់មកវិញ ។

ព្រាហ្មណ៍ទៅកាន់សម្នាក់ព្រះបរមសាស្តាទូលសូមបព្វជ្ជា លុះបានបព្វជ្ជានិងឧបសម្បទាហើយ ក៏មិនបោះបង់កម្មដ្ឋាន ចម្រើនវិបស្សនាបានសម្រេចអរហត្តផល ចូលគាល់ព្រះបរមសាស្តាក្រាបទូលព្យាករអរហត្តផលថា បពិត្រព្រះអង្គដ៏ចម្រើន បព្វជ្ជារបស់ខ្ញុំព្រះអង្គដល់ទីបំផុតហើយ ។ ពាក្យព្យាករអរហត្តផលរបស់លោកនោះ បានប្រាកដដល់ភិក្ខុសង្ឃ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា អង្គុយសន្ទនាអំពីគុណរបស់លោកថា អាវុសោទាំងឡាយ ព្រាហ្មណ៍អ្នកឧបដ្ឋាកព្រះរាជាឈ្មោះឯ-ណោះ សាកល្បងសីលរបស់ខ្លួនហើយ ក្រាបទូលព្រះរាជាសូមបព្វជ្ជា

ឥឡូវនេះបានសម្រេចអរហត្តផលហើយ ។ ព្រះបរមសាស្តា ស្តេចយាង មក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំង-ឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាប ទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិន មែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលព្រាហ្មណ៍នេះសាកល្បង សីលរបស់ខ្លួន ហើយបួសធ្វើទីពឹងឲ្យខ្លួនបាន សូម្បីក្នុងកាលមុន បណ្ឌិត ទាំងឡាយក៏ធ្លាប់សាកល្បងសីលរបស់ខ្លួន ហើយបួសធ្វើទីពឹងឲ្យដល់ខ្លួន ហើយដែរ ។ កាលភិក្ខុទាំងនោះក្រាបទូលអារាធនាហើយ ទើបទ្រង់នាំ យករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុង នគរពារាណសី ព្រះបរមពោធិសត្វបានជាបុរោហិតរបស់ព្រះបាទព្រហ្មទត្ត អង្គនោះ ជាអ្នកមានចិត្តបង្អោនទៅក្នុងទាន មានសីលជាអធ្យាស្រ័យ កាន់ សីល ៥ មិនដាច់ ព្រះរាជាទ្រង់លើកតម្កើងព្រះបរមពោធិសត្វក្រៃលែង ជាងព្រាហ្មណ៍ដ៏សេស រឿងទាំងអស់ដូចរឿងដំបូងនោះឯង ប្លែកតែថា កាលព្រះបរមពោធិសត្វត្រូវគេចងនាំយកទៅកាន់សម្នាក់ព្រះរាជា ពួកគ្រូ ពស់កំពុងបង្ហាត់ពស់ឲ្យលេងនៅក្បែរថ្នល់ នាំគ្នាចាប់ពស់ត្រង់កន្ទុយ ចាប់ ត្រង់ក យកពស់មករុំក ។ ព្រះបរមពោធិសត្វឃើញគ្រូពស់ទាំងនោះ ហើយពោលថា នែអ្នកទាំងឡាយ អ្នកទាំងឡាយកុំចាប់ពស់ត្រង់កន្ទុយ

កុំចាប់ត្រង់ក កុំយកវាទៅរុំក ព្រោះពស់នេះខាំហើយ ក៏នឹងដល់នូវការអស់ជីវិត ។

គ្រូពស់ទាំងនោះពោលថា នែព្រាហ្មណ៍ ពស់នេះមានសីល បរិបូរដោយមារយាទ មិនមែនជាអ្នកទ្រុស្តសីលដូចលោកទេ ចំណែកលោកជាមនុស្សមិនមានអាចារៈ ព្រោះភាពជាអ្នកទ្រុស្តសីល ត្រូវគេចោទថាជាចោរលួចព្រះរាជទ្រព្យ កំពុងត្រូវចងនាំខ្លួនទៅ ។ ព្រាហ្មណ៍បានគិតថា សូម្បីពស់ដែលមិនខាំអ្នកណា មិនបៀតបៀននរណា ក៏មានឈ្មោះថាជាអ្នកមានសីល ចាំបាច់ទៅពោលថ្វីដល់ពួកមនុស្ស ដែលនៅក្នុងលោកនេះសីលប៉ុណ្ណោះ ឈ្មោះថាជាធម្មជាតិដ៏ខ្ពង់ខ្ពស់បំផុត វត្ថុដទៃដែលក្រៃលែងជាងសីលនោះ មិនមាន ។

លុះរាជបុរសនាំព្រាហ្មណ៍ទៅថ្វាយព្រះរាជាហើយ ព្រះរាជាត្រាស់សួរថា នែអ្នកដ៏ចម្រើន តើរឿងនេះដូចម្ដេច ?

រាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព ចោរលួចព្រះរាជទ្រព្យ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ អ្នកទាំងឡាយចូរធ្វើតាមព្រះរាជ-អាជ្ញាចុះ ។

ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនមែនជាចោរទេ ។ កាលព្រះរាជាត្រាស់សួរថា កាលបើដូច្នោះ ហេតុដូចម្ដេចបាន ជាអ្នកយកកហាបណៈអំពីព្រះរាជឃ្លាំង ? ទើបព្រះបរមពោធិសត្វ

ក្រាបទូលរឿងរ៉ាវទាំងអស់ ដោយន័យដូចដែលមានខាងដើមនោះឯង ហើយក្រាបទូលថា ដោយហេតុនេះ ទូលបង្គំសម្រេចចិត្តហើយថា ក្នុងលោកនេះ សីលប៉ុណ្ណោះ ខ្ពង់ខ្ពស់បំផុត សីលជាប្រធាន ហើយក្រាបទូលតទៅទៀតថា រឿងនេះលើកទុកសិនចុះព្រះអង្គ សូម្បីតែអាសិរ្ពិសមិនខាំអ្នកណា មិនបៀតបៀនអ្នកណា គង់នៅមានឈ្មោះបោះសំឡេងថាជាអ្នកមានសីល ព្រោះហេតុនេះ សីលប៉ុណ្ណោះ ខ្ពង់ខ្ពស់បំផុត សីលជាធម្មជាតិដ៏ប្រសើរ កាលនឹងសរសើរសីលបានពោលគាថានេះថា

**សីលំ កិរេវ កល្យាណំ សីលំ លោកេ អនុត្តរំ**
**បស្ស ឃោរវិសោ នាគោ សីលវាតិ ន ហញ្ញតីតិ ។**

បានឮថា សីលជាគុណជាតល្អ សីលជាគុណជាតដ៏
លើសលុបក្នុងលោក សូមព្រះអង្គទតចុះ ពស់មានពិស
ដ៏ពន្លឹក មិនបៀតបៀនគេ ឈ្មោះថាជាសត្វមានសីល ។

បណ្ដាបទទាំងនោះ បទថា **សីលំ កិរេវ** បានដល់ សីល គឺមារយាទ ពោលគឺការមិនប្រព្រឹត្តល្មើសនោះឯង ។

បទថា **កិរ** សេចក្ដីថា ព្រះបរមពោធិសត្វពោលតាមដែលបានឮមក ។ បទថា **កល្យាណំ** ប្រែថា ល្អប្រសើរ ។

បទថា **អនុត្តរំ** សេចក្ដីថា ដ៏លើសលុប ដ៏កំពូល គឺឲ្យគុណបានគ្រប់យ៉ាង ។

*បទថា* **បស្ស** *បានដល់ ពោលសំដៅដល់ហេតុដែលខ្លួនបាន ឃើញ ។*

*បទថា* **សីលវាតិ ច ហញ្ញតិ** *សេចក្តីថា សូម្បីពស់មានពិស ដ៏ពន្លឹក នៅបានទទួលការសរសើរថាជាសត្វមានសីល ដោយហេតុត្រឹម តែមិនខាំអ្នកណា មិនបៀតបៀនអ្នកណា រមែងមិនត្រូវអ្នកណាបៀត-បៀន គឺមិនត្រូវអ្នកណាសម្លាប់ ដោយហេតុដូចពោលមកនេះ ទើបសីល នោះឯង ឈ្មោះថាជាគុណជាតិដ៏លើសលុប ។*

*ព្រះបរមពោធិសត្វសម្តែងធម៌ថ្វាយព្រះរាជាដោយគាថានេះ ដោយ-ប្រការដូច្នេះ លះបង់កាមទាំងឡាយ បួសជាឥសី ចូលកាន់ព្រៃហេមពាន្ត ញុំាងអភិញ្ញា ៥ សមាបត្តិ ៨ ឲ្យកើតហើយ មានព្រហ្មលោកជាទីទៅខាង មុខ ។*

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ បរិស័ទបាន មកជាពុទ្ធបរិស័ទ ចំណែកបុរោហិត គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា សីលវីមំសនជាតក ទី ៦ ។

# អដ្ឋកថា មង្គលជាតក ទី ៧

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រាហ្មណ៍អ្នកស្គាល់លក្ខណៈសំពត់សាដកម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យស្ស មង្គលា សមូហតា** ដូច្នេះជាដើម ។

បានឮថា ព្រាហ្មណ៍អ្នកនគររាជគ្រឹះម្នាក់ ជាអ្នកប្រកាន់មង្គលភ្ញាក់ផ្អើល មិនជ្រះថ្លាក្នុងព្រះរតនត្រ័យ ជាមនុស្សមិច្ឆាទិដ្ឋិ ជាអ្នកស្តុកស្តម្ភមានទ្រព្យច្រើន មានភោគច្រើន កណ្តុរខាំគូនៃសំពត់សាដកដែលគាត់ទុកក្នុងហិប លុះដល់ពេលដែលគាត់ងូតទឹក ក៏ពោលថា អ្នកទាំងឡាយ ចូរយកសំពត់សាដកមក អ្នកបម្រើក៏ប្រាប់ថា កណ្តុរខាំសំពត់សាដកនោះដាច់អស់ហើយ ។ ព្រាហ្មណ៍គិតថា ព្រោះអាស្រ័យសំពត់សាដកមួយគូដែលកណ្តុរខាំ ដែលមាននៅក្នុងផ្ទះនេះ សេចក្តីវិនាសធំនឹងកើតមានព្រោះសំពត់មួយគូជាអពមង្គល ដូចមនុស្សកាឡកណ្ណី ទាំងមិនអាចឲ្យដល់បុត្រធីតាឬទាសកម្មករបានឡើយ ព្រោះការវិនាសធំនឹងមានដល់អ្នកដែលទទួលសំពត់នេះគ្រប់គ្នា ត្រូវឲ្យយកវាទៅបោះចោលនៅព្រៃខ្មោច ។ ប៉ុន្តែព្រាហ្មណ៍មិនហ៊ានឲ្យពួកទាសៈជាដើមយកទៅ ព្រោះខ្លាចពួកទាសៈទាំងនោះ កើតលោភកាន់យកសំពត់មួយគូនេះ ហើយដល់នូវសេចក្តីវិនាសតៗគ្នា ( ទើបគាត់គិតបន្តទៀតថា ) អញនឹងឲ្យកូនរបស់អញយកទៅចោល គាត់ហៅកូនមកប្រាប់រឿងរ៉ាវទាំងនោះ ហើយប្រើឲ្យទៅដោយ

ពាក្យថា នៃកូនសម្លាញ់ កូនឯងក៏មិនត្រូវយកដៃចាប់វា កូនឯងចូរយក កំណាត់ឈើធ្គឹះយកទៅចោលក្នុងព្រៃខ្មោច រួចង្ងូតទឹកឲ្យស្អាត ហើយសឹមមកវិញ ។

ក្នុងថ្ងៃនោះ វេលាជិតភ្លឺ ព្រះបរមសាស្ដាទ្រង់ប្រមើលមើលពួកវេនេយ្យសត្វ ឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់ឪពុកកូនទាំងពីរ-នាក់នេះ ទ្រង់ក៏យាងទៅដូចព្រានម្រឹគដើរតាមស្នាមជើងម្រឹគដូច្នោះ ទ្រង់បានប្រថាប់ឈរនៅក្បែរព្រៃខ្មោច ទ្រង់ផ្សាយព្រះពុទ្ធរស្មី ៦ ប្រការ ។ ចំណែកមាណពទទួលពាក្យបិតាហើយ ធ្គឹះសំពត់មួយគូនោះដោយចុងឈើច្រត់ ដូចធ្គឹះពស់ឈ្មោះអជគរៈ ( ពស់ថ្លាន់ ) ដើរទៅដល់មាត់ព្រៃស្មសាន ។ គ្រានោះ ព្រះបរមសាស្ដាត្រាស់សួរមាណពនោះថា ម្នាលមាណព អ្នកធ្វើអ្វី?

មាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន សំពត់មួយគូនេះត្រូវកណ្ដុរកាត់ ជាវត្ថុនាំមកនូវសេចក្ដីវិនាស ប្រៀបដូចថ្នាំពុលដ៏កាចសាហាវ បិតារបស់ខ្ញុំព្រះអង្គខ្លាចក្រែងថា បើឲ្យអ្នកដទៃយកវាទៅចោល មនុស្សដទៃនោះ អាចកើតលោភឡើងកាន់យកវា ទើបប្រើខ្ញុំព្រះអង្គឲ្យយកមកចោលនៅទីនេះ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គមកទីនេះដោយបំណងថា នឹងចោលវានៅទីនេះ ។ ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា បើដូច្នោះ ចូរអ្នកចោលចុះ ។ មាណពក៏បោះចោល ព្រះបរមសាស្ដា

ត្រាស់ថា ពេលនេះសមគួរដល់តថាគតហើយ លុះទ្រង់ត្រាស់ដូច្នេះ ហើយទ្រង់ក៏កាន់យកសំពត់នោះចំពោះមុខមាណព ទាំងដែលមាណព នោះឃាត់ថា បពិត្រព្រះគោតមដ៏ចម្រើន នោះជាអពមង្គល ដូចមនុស្ស កាឡកណ្ណី កុំចាប់ កុំចាប់ឡើយ ។ ព្រះបរមសាស្ដាក៏ទ្រង់កាន់យក សំពត់នោះហើយ ទ្រង់បែរព្រះភក្ត្រឆ្ពោះទៅកាន់វត្តវេឡុវ័ន ។ មាណព ប្រញាប់ទៅប្រាប់ព្រាហ្មណ៍ជាបិតាថា បពិត្របិតា សំពត់ចាស់ដែលខ្ញុំយក ទៅចោលនៅព្រៃខ្មោចនោះ ព្រះសមណគោតមត្រាស់ថា គួរដល់តថាគត ទាំងដែលខ្ញុំឃាត់ ក៏ទ្រង់កាន់យក ហើយយាងទៅកាន់វត្តវេឡុវ័ន កាល ព្រះសមណគោតមទ្រង់ប្រើប្រាស់សំពត់សាដកនោះ ក៏នឹងត្រូវវិនាស សូម្បី ព្រះវិហារក៏នឹងត្រូវវិនាស ពេលនោះពួកយើងនឹងត្រូវគេតិះដៀល យើង ត្រូវថ្វាយសំពត់សាដកដទៃៗច្រើនផ្ទាំងចំពោះព្រះសមណគោតម ដើម្បី ឲ្យទ្រង់ចោលសំពត់នោះ ។ ព្រាហ្មណ៍ឲ្យអ្នកបម្រើកាន់សំពត់សាដក ច្រើនផ្ទាំងទៅកាន់វត្តវេឡុវ័នជាមួយនឹងបុត្រ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ហើយក្រាបទូលយ៉ាងនេះថា បពិត្រព្រះ-សមណគោតម បានឮថា ទ្រង់កាន់យកសំពត់សាដកមួយគូក្នុងព្រៃខ្មោច ពិតមែនឬ ? ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ពិតមែនហើយព្រាហ្មណ៍ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះសមណគោតម សំពត់សាដកនោះជា អពមង្គល កាលទ្រង់ប្រើប្រាស់វានឹងត្រូវវិនាស សូម្បីវិហារទាំងអស់ក៏នឹង

វិនាសដែរ ប្រសិនបើសំពត់ស្បៀកសំពត់ដណ្តប់របស់ព្រះអង្គមិនគ្រប់គ្រាន់ សូមព្រះអង្គទទួលសំពត់សាដកទាំងនេះទុក ហើយចោលសំពត់សាដកនោះចុះ ។ គ្រានោះ ព្រះបរមសាស្តាត្រាស់ទៅកាន់ព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ តថាគតមាននាមថាបព្វជិត សំពត់ចាស់ៗដែលគេចោល ឬធ្លាក់នៅក្នុងទីដូច្នោះ គឺក្នុងព្រៃខ្មោចក្តី តាមផ្លូវក្តី លើគំនរសំរាមក្តី នៅក្បែរកំពង់ទឹកក្តី នៅតាមផ្លូវធំក្តី រមែងសមគួរដល់តថាគតទាំងអស់ ចំណែកអ្នកមិនមែនទើបតែជាមនុស្សមានទិដ្ឋិយ៉ាងនេះ ក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ធ្លាប់មានការយល់ឃើញយ៉ាងនេះដែរ ។ កាលព្រាហ្មណ៍ក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទមគធរាជអ្នកទ្រទ្រង់ធម៌សោយរាជសម្បត្តិនៅក្នុងនគររាជគ្រឹះ ដែនមគធៈ ។ គ្រានោះ ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ធំពេញវ័យហើយ បួសជាឥសី ញ៉ាំងអភិញ្ញានិងសមាបត្តិឲ្យកើតហើយ សម្រាកនៅក្នុងព្រៃហេមពាន្ត ។ ក្នុងកាលមួយតាបសពោធិសត្វចេញអំពីព្រៃហេមពាន្ត ធ្វើដំណើរមកដល់ព្រះរាជ-ឧទ្យានក្នុងនគររាជគ្រឹះ សម្នាក់នៅទីនោះ ថ្ងៃទីពីរចូលកាន់នគរដើម្បីបិណ្ឌបាត ។ ព្រះរាជាទតឃើញព្រះបរមពោធិសត្វភ្លាមក៏ត្រាស់ឲ្យនិមន្តមក អារាធនាឲ្យគង់នៅក្នុងប្រាសាទឲ្យឆាន់ភោជនាហារ ហើយទ្រង់សូម

ឲ្យព្រះបរមពោធិសត្វកាន់យកការប្តេជ្ញា ដើម្បីការនៅក្នុងព្រះរាជឧទ្យាន ជានិច្ច ។ តាបសពោធិសត្វឆាន់នៅក្នុងព្រះរាជនិវេសន៍ ស្នាក់នៅក្នុងព្រះ-រាជឧទ្យាន ។ ក្នុងកាលនោះ នៅក្នុងនគររាជគ្រឹះ មានព្រាហ្មណ៍ម្នាក់ឈ្មោះ ទុស្សលក្ខណព្រាហ្មណ៍ ( ព្រាហ្មណ៍អ្នកស្គាល់លក្ខណៈសំពត់ ) រឿងទាំងអស់ តាំងពីគាត់ទុកសំពត់សាដកក្នុងហិបជាដើមទៅ ដូចរឿងមុននោះឯង ( ប្លែកតែមួយចំណុច ) កាលមាណពទៅដល់ព្រៃខ្មោច ព្រះ-បរមពោធិសត្វទៅរង់ចាំមុន រើសយកសំពត់សាដកដែលមាណពចោលហើយ ត្រឡប់ទៅកាន់ឧទ្យានវិញ ។ មាណពក៏ទៅប្រាប់បិតា ព្រាហ្មណ៍គិតថា តាបសអ្នកជិតស្និទ្ធនឹងរាជត្រកូលនេះនឹងវិនាស ទើបទៅកាន់សម្នាក់ព្រះបរមពោធិសត្វ រួចពោលថា បពិត្រតាបស សូមលោកចោលសំពត់សាដកដែលលោករើសយកហើយនោះចុះ សូមលោកកុំវិនាសឡើយ ។ តាបសពោធិសត្វសម្តែងធម៌ឲ្យព្រាហ្មណ៍ស្តាប់ថា សំពត់ចាស់ៗដែលគេចោលក្នុងព្រៃខ្មោច សមគួរដល់ពួកយើង ពួកយើងមិនមែនជាអ្នកប្រកាន់មង្គលភ្ញាក់ផ្អើលទេ ដែលឈ្មោះថាការប្រកាន់មង្គលភ្ញាក់ផ្អើលនេះ ព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះពោធិសត្វទាំងឡាយមិនសរសើរឡើយ ហេតុនោះ បណ្ឌិតមិនត្រូវជាមនុស្សប្រកាន់មង្គលភ្ញាក់ផ្អើលឡើយ ។ ព្រាហ្មណ៍ស្តាប់ធម៌ហើយទម្លាយទិដ្ឋិចោល ដល់ព្រះបរមពោធិ-សត្វជាសរណៈ ។ ព្រះបរមពោធិសត្វមានឈានមិនសាបសូន្យ បានជា

*អ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។*

*ព្រះបរមសាស្ដាទ្រង់នាំយករឿងក្នុងអតីតនេះមកហើយ លុះទ្រង់បានត្រាស់ដឹងព្រះសម្មាសម្ពោធិញ្ញាណហើយ កាលនឹងសម្ដែងធម៌ដល់ព្រាហ្មណ៍ ទ្រង់ត្រាស់ព្រះគាថានេះថា*

**យស្ស មង្គលា សមូហតា**
**ឧប្បាតា សុបិនា ច លក្ខណា ច**
**សោ មង្គលទោសវីតិវត្តោ**
**យុគយោគាធិគតោ ន ជាតុមេតីតិ ។**

*មង្គលទាំងឡាយក្ដី ឧត្បាតទាំងឡាយក្ដី សុបិនទាំងឡាយក្ដី លក្ខណៈទាំងឡាយក្ដី ដែលបុគ្គលណាបានផ្ដាច់បង់ហើយ បុគ្គលនោះ ឈ្មោះថា អ្នកកន្លងផុតនូវទោសនៃមង្គល ( ភ្ញាក់ផ្អើល ) ជាអ្នកគ្របសង្កត់នូវយុគក្កិលេស និងយោគក្កិលេស រមែងមិនមកកើតទៀត ។*

*បណ្ដាបទទាំងនោះ បទថា* **យស្ស មង្គលា សមូហតា** *សេចក្ដីថា មង្គលទាំងនេះគឺ* **ទិដ្ឋមង្គល** *មង្គលដែលកើតព្រោះវត្ថុដែលឃើញ ១* **សុតមង្គល** *មង្គលដែលកើតព្រោះការស្ដាប់ ១* **មុតមង្គល** *មង្គលដែលកើតព្រោះអារម្មណ៍ដែលបានដឹង ១ មង្គលទាំងនេះ ដែលព្រះអរហន្តខីណាស្រពដកបានហើយ ។*

*បទថា* **ឧប្បាតា សុបិនា ច លក្ខណា ច** *សេចក្តីថា ឧត្បាតដែលជារឿងធំ ៥ ប្រការគឺ ចន្ទ្រគ្រាសយ៉ាងនេះនឹងត្រូវមាន ១ សូរ្យគ្រាសយ៉ាងនេះនឹងត្រូវមាន ១ ផ្កាយនក្ខត្តឫក្សយ៉ាងនេះនឹងត្រូវមាន ១ ឧត្បាតយ៉ាងនេះនឹងត្រូវមាន ១ ទិសទាំងឡាយនឹងត្រូវមាន ១ ម្យ៉ាងទៀតទាំងការយល់សប្តិផ្សេងៗ លក្ខណៈទាំងឡាយមានជាអាទិ៍យ៉ាងនេះគឺ លក្ខណៈមនុស្សមានជោគល្អ លក្ខណៈមនុស្សមានជោគមិនល្អ លក្ខណៈស្ត្រី លក្ខណៈបុរស លក្ខណៈទាសៈ លក្ខណៈទាសី លក្ខណៈភូមិ លក្ខណៈសរ លក្ខណៈអាវុធ លក្ខណៈសំពត់ ទាំងនេះជាឋាននៃទិដ្ឋិ បុគ្គលណាដកបានអស់ហើយ គឺមិនជឿ មិនកាន់យកជាមង្គល ឬអពមង្គលដល់ខ្លួនដោយរឿងឧត្បាតជាដើមនេះ ។*

*បទថា* **សោ មង្គលទោសវីតិវត្តោ** *សេចក្តីថា បុគ្គលនោះជាភិក្ខុខីណាស្រព កន្លងផុត ឈានផុត លះបង់បាននូវទោសនៃមង្គលភ្ញាក់ផ្អើលគ្រប់យ៉ាង ។*

*បទថា* **យុគយោគាតិគតោ** *សេចក្តីថា កិលេសដែលមករួមគ្នាជាគូៗ ដោយន័យមានជាអាទិ៍ថា* **កោធ** *សេចក្តីក្រោធ និង* **ឧបនាហ** *ការចងសេចក្តីក្រោធ* **មក្ខ** *ការលុបគុណ និង* **បលាស** *ការវាយឫកស្មើ ដូច្នេះ ឈ្មោះ* **យុគ** *។ កិលេស ៤ យ៉ាងនេះគឺ* **កាមយោគ ភវយោគ ទិដ្ឋិយោគ អវិជ្ជាយោគ** *ឈ្មោះថា* **យោគ** *ព្រោះជាហេតុ*

ប្រកបសត្វទុកក្នុងវដ្តទុក្ខ ភិក្ខុខីណាស្រពសម្រេចហើយ គឺគ្របសង្កត់បាន ហើយ កន្ទងផុតហើយ បានឆ្លងទៅហើយដោយល្អ នូវ **យុគ** និង **យោគ** គឺទាំង **យុគ** និង **យោគ** ។

បទថា **ន ជាតុមេតិ** សេចក្តីថា បុគ្គលនោះរមែងមិនដល់ គឺមិនមកកាន់លោកនេះ ដោយអំណាចនៃបដិសន្ធិថ្មីដោយពិតប្រាកដ ។

ព្រះបរមសាស្តា ទ្រង់សម្តែងធម៌ដល់ព្រាហ្មណ៍ដោយព្រះគាថានេះ ដោយប្រការដូច្នេះហើយ ទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ ព្រាហ្មណ៍និងបុត្របានសម្រេចសោតាបត្តិផល ។ ព្រះបរមសាស្តាទ្រង់ប្រជុំជាតកថា បិតានិងបុត្រក្នុងកាលនោះ បានមកជាបិតានិងបុត្រក្នុងកាលឥឡូវនេះ ចំណែកតាបស គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា មង្គលជាតក ទី ៧ ។

# អដ្ឋកថា សារម្ភជាតក ទី ៨

*ព្រះបរមសាស្តា កាលទ្រង់អាស្រ័យនគរសាវត្ថី ទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ* **ឱមសវាទសិក្ខាបទ** *(សិក្ខាបទពោលអំពីការជេរ ) ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **កល្យាណិមេវ មុញ្ចេយ្យ** *ដូច្នេះជាដើម ។*

*រឿងទាំងពីរ ( រឿងបច្ចុប្បន្ន ១ រឿងអតីតៈ ១ ) ក៏ដូចរឿងដែលពោលទុកហើយក្នុង* **នន្ទិវិសាលជាតក** *នោះឯង ( ប្លែកតែថា ) ក្នុងជាតកនេះ ព្រះបរមពោធិសត្វសោយព្រះជាតិជាគោទ្រទ្រង់កម្លាំងខ្លាំងឈ្មោះ សារម្ភ របស់ព្រាហ្មណ៍ម្នាក់ ដែលមានប្រក្រតីនៅក្នុងនគរតក្កសិលា ។*

*ព្រះបរមសាស្តាទ្រង់ត្រាស់រឿងក្នុងអតីតនេះហើយ លុះទ្រង់បានត្រាស់ដឹងនូវសម្ពោធិញាណហើយ ត្រាស់ព្រះគាថានេះថា*

**កល្យាណិមេវ មុញ្ចេយ្យ ន ហិ មុញ្ចេយ្យ ចាបិកំ**
**មោក្ខោ កល្យាណិយា សាធុ មុត្វា តប្បតិ ចាបិកន្តិ ។**

*បុគ្គលគប្បីបញ្ចេញវាចាល្អតែម្យ៉ាង មិនគប្បីបញ្ចេញវាចាអាក្រក់ឡើយ ការបញ្ចេញវាចាល្អ ជាការប្រពៃ ព្រោះបុគ្គលបញ្ចេញវាចាអាក្រក់ រមែងក្តៅក្រហាយ ។*

*បណ្តាបទទាំងនោះ បទថា* **កល្យាណិមេវ មុញ្ចេយ្យ** *សេចក្តីថា*

*បុគ្គលគប្បីថ្លែង គឺគប្បីបន្ទឺ បានដល់ គប្បីពោលពាក្យដែលប្រាសចាក ទោស ៤ ប្រការ ឈ្មោះថាវាចាល្អ គឺមិនមានទោសប៉ុណ្ណោះ ។*

*បទថា* **ន ហិ មុញ្ចេយ្យ បាបិកំ** *សេចក្តីថា មិនគប្បីពោលពាក្យអាក្រក់ គឺវាចាលាមក បានដល់ ពាក្យដែលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តនៃអ្នកដទៃៗ ។*

*បទថា* **មោក្ខោ កល្យាណិយា សាធុ** *សេចក្តីថា ការពោលវាចាល្អប៉ុណ្ណោះ រមែងញ៉ាំងប្រយោជន៍ឲ្យសម្រេច គឺជាការល្អ ជាសេចក្តីចម្រើនក្នុងលោកនេះ ។*

*បទថា* **មុត្វា តប្បតិ បាបិកំ** *សេចក្តីថា កាលថ្លែង គឺបញ្ចេញបានដល់ ពោលពាក្យអាក្រក់ គឺពោលពាក្យគ្រោតគ្រាតហើយ បុគ្គលនោះរមែងក្តៅក្រហាយ គឺសោកសៅ ។*

*ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកដោយប្រការដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាអានន្ទ ព្រាហ្មណីបានមកជាឧប្បលវណ្ណា ចំណែកគោសារម្ភ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា សារម្ភជាតក ទី ៨ ។

# អដ្ឋកថា កុហកជាតក ទី ៩

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកច្រើនទៅដោយការនិយាយកុហកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វាចាវ កិរ តេ អាសិ** ដូច្នេះជាដើម ។

រឿងការកុហកឆបោកនឹងប្រាកដច្បាស់នៅក្នុង **ឧទ្ទាលកជាតក** ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិនៅក្នុងនគរពារាណសី ជដិលកោងម្នាក់ជាតាបសនិយាយកុហក អាស្រ័យនៅក្នុងស្រុកមួយ កុដុម្ពិកៈម្នាក់ជួយសាងបណ្ណសាលានៅក្នុងព្រៃឲ្យតាបសនោះ ហើយឲ្យតាបសនោះនៅក្នុងបណ្ណសាលា បម្រើដោយអាហារដ៏ប្រណីតក្នុងផ្ទះរបស់ខ្លួន កុដុម្ពិកៈនោះជឿតាបសកោងនោះថា តាបសនេះជាអ្នកមានសីល យកមាស ១០០ ដុំទៅកាន់សាលាដែលតាបសនោះនៅ កប់ទុកក្នុងដីព្រោះខ្លាចចោរលួច រួចពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ជួយមើលថែមាសនេះផង ។ គ្រានោះ តាបសពោលទៅកាន់កុដុម្ពិកៈថា នៃកុដុម្ពិកៈ ការនិយាយបែបនេះ ចំពោះពួកដែលមានឈ្មោះថាបព្វជិតមិនសមគួរឡើយ ដែលឈ្មោះថាការសម្លឹងរំពៃចង់បានទ្រព្យរបស់អ្នកដទៃរបស់ពួកយើង មិនមានឡើយ ។ កុដុម្ពិកៈពោលថា ប្រពៃហើយលោកម្ចាស់ ជឿពាក្យតាបសហើយចៀសចេញទៅ ។ តាបសអាក្រក់នោះគិតថា អញអាចចិញ្ចឹមជីវិតដោយទ្រព្យមានប្រមាណ

ប៉ុណ្ណោះបាន ។ កន្ទង់ទៅបានពីរ-បីថ្ងៃគាស់យកមាសនោះទៅទុកត្រង់ចន្លោះផ្លូវ ហើយត្រឡប់មកកាន់បណ្ណសាលាវិញ ។ លុះថ្ងៃស្អែកឡើងធ្វើភត្តកិច្ចក្នុងផ្ទះកុដុម្ពិកៈហើយ ពោលយ៉ាងនេះថា អ្នកមានអាយុ អាត្មាអាស្រ័យអ្នកយូរមកហើយ ការប្រឡូកប្រឡំនឹងពួកមនុស្សរមែងមាន ក៏ធម្មតាថាការប្រឡូកប្រឡំនោះជាមន្ទិលរបស់បព្វជិត ព្រោះហេតុដូច្នោះអាត្មានឹងចម្រើនពរលា សូម្បីកុដុម្ពិកៈអង្វរយ៉ាងណាក៏ដោយ ក៏មិនព្រមគ្រានោះ កុដុម្ពិកៈក៏ពោលទៅកាន់តាបសនោះថា បើដូច្នោះ សូមលោកម្ចាស់និមន្តទៅចុះ ដូច្នេះហើយ តាមជូនទៅរហូតដល់ទ្វារស្រុកហើយទើបត្រឡប់មកវិញ ។ តាបសដើរបានបន្តិចក៏គិតថា អញគួរបោកកុដុម្ពិកៈនេះ ក៏យកស្មៅដាក់ក្នុងចន្លោះជដាហើយត្រឡប់មកវិញ ។

កុដុម្ពិកៈសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ត្រឡប់មកវិញធ្វើអ្វី ?

តាបសឆ្លើយថា អ្នកមានអាយុ ស្មៅមួយទងជាប់នឹងជដារបស់អាត្មាដែលឈ្មោះថាអទិន្នាទានមិនសមគួរដល់បព្វជិតឡើយ ទើបអាត្មាប្រញាប់យកវាត្រឡប់មកវិញ ។

កុដុម្ពិកៈពោលថា សូមលោកម្ចាស់បោះវាចោល ហើយនិមន្តទៅចុះ ។ កុដុម្ពិកៈជ្រះថ្លាថា តាបសមិនកាន់យករបស់អ្នកដទៃ សូម្បីតែស្មៅមួយទង ឱ លោកម្ចាស់របស់យើង ប្រព្រឹត្តតឹងរ៉ឹងពិតមែនហ្ន៎ លុះគិត

ដូច្នេះហើយថ្វាយបង្គំ រួចបញ្ជូនតាបសទៅ ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វទៅកាន់ជនបទជាយដែនដើម្បីត្រូវការទ្រព្យ បានស្នាក់នៅក្នុងផ្ទះរបស់កុដុម្ពិកៈ ស្តាប់តាបសហើយគិតថា តាបសអាក្រក់នេះ នឹងកាន់យកទ្រព្យណាមួយរបស់កុដុម្ពិកៈនេះជាប្រាកដ ទើបសួរកុដុម្ពិកៈថា នែសម្លាញ់ អ្នកបានកប់អ្វីៗទុកក្នុងសម្នាក់តាបសនោះដែរឬ ?

កុដុម្ពិកៈឆ្លើយថា នែសម្លាញ់ មាន ខ្ញុំបានកប់មាស ១០០ ដុំ ។

ព្រះបរមពោធិសត្វពោលថា បើដូច្នោះ ចូរអ្នកប្រញាប់ទៅមើលមាសនោះចុះ ។ កុដុម្ពិកៈទៅកាន់បណ្ណសាលាមិនឃើញមាសនោះប្រញាប់ត្រឡប់មកប្រាប់ថា នែសម្លាញ់ មាសបាត់អស់ហើយ ។

ព្រះបរមពោធិសត្វប្រាប់ថា មាសរបស់អ្នកគ្មានអ្នកណាយកទេ មានតែតាបសអាក្រក់នោះម្នាក់ប៉ុណ្ណោះ លួចយកទៅ មកយើងដេញតាមចាប់តាបសនោះ ហើយប្រញាប់ដេញតាមចាប់តាបសអាក្រក់នោះ ចាប់បានហើយ គក់ផង ទាត់ផង ឲ្យយកមាសមកសងវិញ ។ ព្រះពោធិសត្វឃើញមាសហើយ ពោលថា តាបសនេះលួចមាស ១០០ ដុំយកទៅមិនរង្កៀសសោះ ត្រឡប់ជារង្កៀសក្នុងវត្ថុត្រឹមតែស្មៅមួយទង កាលនឹងតិះ-ដៀលតាបសនោះ បានពោលគាថានេះថា

**វាចាវ តិរ តេ អាសិ សណ្ហា សខិលភាណិនោ**

**តិណមត្តេ អសជ្ជិត្តោ ឡោ ច និក្ខសតំ ហរន្តិ ។**

*បានឮថា វាចារបស់អ្នកដែលពោលទន់ភ្លន់ ជាវាចាពីរោះ អ្នកបានជាប់ក្នុងវត្ថុត្រឹមតែស្មៅ ត្រង់នាំផ្គោរមាស ១០០ យកទៅ មិនជាប់សោះ។*

*បណ្ដាបទទាំងនោះ បទថា* **វាចាវ កិរ តេ អាសិ សណ្ហា សខិលភាណិនោ** *សេចក្ដីថា កាលអ្នកពោលពាក្យទន់ភ្លន់ជាវាចាពីរោះ គួរឲ្យរាប់អានយ៉ាងនេះថា ការកាន់យករបស់ដែលគេមិនបានឲ្យ សូម្បីត្រឹមតែស្មៅមួយទង ក៏មិនសមគួរដល់បព្វជិតដែរ ដូច្នេះពាក្យរបស់អ្នកនោះ ទន់ភ្លន់ជាវាចាពីរោះណាស់ អធិប្បាយថា ពាក្យរបស់អ្នកនោះពីរោះពិតៗ ។*

*បទថា* **តិណមត្តេ អសជ្ជិត្តោ** *សេចក្ដីថា នែជដិលកោងអ្នកសម្ដែងការមិនពេញចិត្តនឹងស្មៅមួយទង មើលទៅដូចជារង្កៀសពិតៗ ប៉ុន្តែត្រង់អ្នកលួចផ្គោរមាស ១០០ ហេតុដូចម្ដេចមិនរង្កៀសសោះ ។*

*ព្រះបរមពោធិសត្វ លុះតិះដៀលតាបសនោះដោយប្រការដូច្នេះហើយ ក៏ឲ្យឱវាទតាបសថា នែជដិលកោង អ្នកកុំធ្វើអំពើបែបនេះតទៅទៀត ដូច្នេះហើយ លុះអស់ជីវិតក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ*

ដែលភិក្ខុនេះជាអ្នកបោកបញ្ឆោតនោះ សូម្បីក្នុងកាលមុនក៏ធ្លាប់ជាអ្នកបោកបញ្ឆោតដែរ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា តាបសអាក្រក់ក្នុងកាលនោះ បានមកជាភិក្ខុដែលពោលពាក្យកុហកក្នុងកាលឥឡូវនេះ ចំណែកបុរសដែលជាបណ្ឌិត គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា កុហកជាតក ទី ៩ ។

## អដ្ឋកថា អកតញ្ញុជាតក ទី ១០

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនាថបិណ្ឌិកសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្តើមថា **យោ បុព្វេ កតកល្យាណោ** ដូច្នេះជាដើម ។

បានឮថា សេដ្ឋីដែលនៅបច្ចន្តជនបទម្នាក់ បានជាអទិដ្ឋសម្លាញ់ ( សម្លាញ់មិនដែលបានឃើញគ្នា ) របស់អនាថបិណ្ឌិកសេដ្ឋី ។ សម័យមួយ សេដ្ឋីនោះផ្ទុករបស់ដែលកើតឡើងក្នុងបច្ចន្តជនបទ ពេញក្នុងរទេះ ៥០០ រួចពោលនឹងអ្នកបម្រើថា នែអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយចូរនាំរបស់ទាំងនេះទៅកាន់នគរសាវត្ថី លក់ឲ្យមហាសេដ្ឋីអនាថបិណ្ឌិកជាសម្លាញ់របស់យើង ជំនួសយើង ហើយនាំគ្នាយករបស់ដែលមហាសេដ្ឋីឲ្យមកចុះ ។ អ្នកបម្រើទាំងនោះ ទទួលពាក្យរបស់សេដ្ឋីហើយនាំគ្នាទៅកាន់នគរសាវត្ថី ជួបមហាសេដ្ឋីអនាថបិណ្ឌិកហើយក៏ប្រគល់បណ្ណាការ

ដែលសេដ្ឋីនៅបច្ចន្តជនបទផ្ញើទៅ និងប្រាប់រឿងនោះឲ្យជ្រាប ។ ចំណែក មហាសេដ្ឋីឃើញអ្នកបម្រើទាំងនោះហើយពោលថា នែអ្នកដ៏ចម្រើនទាំង-ឡាយ អ្នកទាំងឡាយមកល្អហើយ ចាត់ចែងកន្លែងសម្រាប់ស្នាក់និងស្បៀង ឲ្យដល់អ្នកបម្រើទាំងនោះ សួរសុខទុក្ខរបស់សេដ្ឋីដែលជាសម្លាញ់ ទទួល ទិញរបស់ហើយឲ្យរបស់ជាបញ្ញើទៅ ។ អ្នកបម្រើទាំងនោះនាំគ្នាត្រឡប់ ទៅកាន់បច្ចន្តជនបទវិញ ប្រាប់រឿងនោះដល់សេដ្ឋីរបស់ខ្លួន ។ ក្រោយមក អនាថបិណ្ឌិកសេដ្ឋីក៏បញ្ជូនរទេះ ៥០០ ដែលពេញទៅដោយរបស់ទៅ កាន់បច្ចន្តជនបទនោះដែរ ។ អ្នកបម្រើទាំងនោះទៅដល់បច្ចន្តជនបទ នោះហើយ នាំបណ្ណាការទៅប្រគល់ឲ្យសេដ្ឋីក្នុងបច្ចន្តជនបទនោះ សេដ្ឋី នោះសួរថា អ្នកទាំងឡាយមកអំពីទីណា ? កាលអ្នកបម្រើទាំងនោះ ពោលថា មកពីនគរសាវត្ថី មកពីសម្លាក់របស់អនាថបិណ្ឌិកសេដ្ឋីដែលជា សម្លាញ់របស់លោក ក៏សើចចំអកថា ពាក្យថាអនាថបិណ្ឌិកនេះ នឹងជា ឈ្មោះរបស់អ្នកណាៗក៏បាន ហើយទទួលគ្រឿងបណ្ណាការទុក បញ្ជូនឲ្យ ត្រឡប់ទៅថា អ្នកទាំងឡាយចូរទៅចុះ មិនបានចាត់ចែងកន្លែងសម្រាក និងអាហារឲ្យឡើយ អ្នកបម្រើទាំងនោះត្រូវលក់របស់ទាំងនោះដោយ ខ្លួនឯង រួចនាំយកតម្លៃដែលលក់បានមកកាន់នគរសាវត្ថី ហើយប្រាប់រឿង នោះដល់លោកសេដ្ឋី ។ ក្រោយមកសេដ្ឋីដែលនៅក្នុងបច្ចន្តជនបទនោះ បញ្ជូនរទេះ ៥០០ ដែលពេញទៅដោយរបស់ទៅកាន់នគរសាវត្ថីម្តងទៀត ។

អ្នកបម្រើយកបណ្ណាការទៅជួបមហាសេដ្ឋី ។ ចំណែកអ្នកបម្រើរបស់អនាថបិណ្ឌិកសេដ្ឋីឃើញអ្នកទាំងនោះហើយពោលថា នែអ្នកដ៏ចម្រើនទាំងឡាយ ពួកខ្ញុំនឹងប្រាប់កន្លែងសម្រាក អាហារ និងស្បៀងរបស់ពួកអ្នក ហើយប្រាប់ឲ្យអ្នកបម្រើទាំងនោះដោះរទេះនៅខាងក្រៅនគរ ដោយពោលពាក្យថា អ្នកទាំងឡាយនៅទីនេះចុះ បបរនិងកត្តសម្រាប់ពួកអ្នក ក្នុងផ្ទះរបស់ពួកអ្នកនឹងមានគ្រប់គ្រាន់ហើយ ហើយនាំគ្នាទៅហៅពួកទាសកម្មករមកប្រជុំគ្នា លុះវេលាអធ្រាត្រក៏នាំគ្នាប្លន់រទេះទាំង ៥០០ ដណ្តើមយកសូម្បីតែសំពត់ស្លៀកនិងសំពត់ដណ្តប់របស់អ្នកបម្រើទាំងនោះ ដេញគោឲ្យរត់ខ្ចាត់ខ្ចាយអស់ ដោះកង់រទេះទាំង ៥០០ ដាក់លើផែនដី ហើយជញ្ជូនយកកង់រទេះទាំងឡាយទៅ អ្នកស្រុកបច្ចន្តជនបទ មិនសល់សូម្បីតែសំពត់ស្លៀក ម្នាក់ៗខ្លាចនាំគ្នាប្រញាប់រត់គេចទៅកាន់បច្ចន្តជនបទ ។ ចំណែកអ្នកបម្រើរបស់អនាថបិណ្ឌិកសេដ្ឋីនាំយករឿងនោះទៅប្រាប់មហាសេដ្ឋី ។ មហាសេដ្ឋីគិតថា ពេលនេះ មានរឿងដែលអាចយកទៅក្រាបទូលព្រះ-សម្មាសម្ពុទ្ធបានហើយ ទើបទៅកាន់សម្នាក់ព្រះបរមសាស្តា ក្រាបទូលរឿងរ៉ាវទាំងអស់តាំងអំពីដើមចំពោះទ្រង់ ។ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលគហបតី សេដ្ឋីក្នុងបច្ចន្តជនបទនោះ ជាអ្នកមានប្រក្រតីប្រព្រឹត្តយ៉ាងនេះ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ សូម្បីក្នុងកាលមុនក៏មានប្រក្រតីប្រព្រឹត្តយ៉ាងនេះដែរ ។ កាលសេដ្ឋីក្រាបទូលអារាធនា ទើបទ្រង់

នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបានជាសេដ្ឋីមានសម្បត្តិស្តុកស្តម្ភក្នុងនគរពារាណសី ។ សេដ្ឋីអ្នកបច្ចន្តជនបទម្នាក់បានជាអទិដ្ឋសម្លាញ់របស់ព្រះមហាសត្វ ។ រឿងក្នុងអតីតទាំងអស់ដូចរឿងក្នុងបច្ចុប្បន្នដែរ ( ប្លែកគ្នាតែថា ) សេដ្ឋីពោធិសត្វកាលអ្នកបម្រើរបស់ខ្លួនប្រាប់ឲ្យដឹងថា ថ្ងៃនេះ ពួកខ្ញុំធ្វើការងារឈ្មោះនេះ ដូច្នេះ ក៏ពោលថា អ្នកទាំងនោះមិនដឹងឧបការ-គុណដែលគេធ្វើហើយចំពោះខ្លួន ទើបបានទទួលកម្មដូច្នេះ ។ ក្នុងកាលជាខាងក្រោយ ដើម្បីនឹងសម្តែងធម៌ដល់បរិស័ទដែលមកប្រជុំគ្នា ទើបពោលគាថានេះថា

**យោ បុព្វេ កតកល្យាណោ កតត្ថោ នាវពុជ្ឈតិ**
**បច្ឆា កិច្ចេ សមុប្បន្នេ កត្តារំ នាធិគច្ឆតីតិ ។**

បុគ្គលណា មិនដឹង នូវអំពើល្អដែលគេធ្វើហើយ នូវប្រយោជន៍ដែលគេធ្វើហើយ ក្នុងកាលមុនទេ បុគ្គលនោះកាលបើកិច្ចកើតព្រមហើយ ក្នុងកាលខាងក្រោយ រមែងមិនបាននូវបុគ្គលអ្នកធ្វើ ( ឧបការគុណមុននោះជាគ្នា ) ឡើយ ។

ក្នុងព្រះគាថានោះ ប្រមូលសេចក្តីអធិប្បាយបានដូច្នេះ បណ្តា

ជនទាំងឡាយ មានក្សត្រជាដើម បុគ្គលណាមួយមានសេចក្ដីល្អដែលអ្នកដទៃ គឺមានឧបការៈដែលអ្នកដទៃធ្វើឲ្យមុន មានប្រយោជន៍ដែលអ្នកដទៃធ្វើឲ្យ គឺមានអ្នកជួយធ្វើកិច្ចការឲ្យសម្រេចបានមុន មិនបានដឹងគុណនិងប្រយោជន៍ដែលអ្នកដទៃធ្វើចំពោះខ្លួនសោះ បុគ្គលនោះកាលកិច្ចការរបស់ខ្លួនកើតឡើងក្នុងកាលខាងក្រោយ រមែងមិនបាននូវបុគ្គលអ្នកធ្វើឧបការៈគុណមុននោះជាគ្នាឡើយ ។

ព្រះបរមពោធិសត្វសម្ដែងធម៌ដោយគាថានេះ ដោយប្រការដូច្នេះហើយ ធ្វើបុណ្យទាំងឡាយមានឲ្យទានជាដើម លុះអស់ជីវិតក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា សេដ្ឋីអ្នកស្រុកបច្ចន្តជនបទក្នុងកាលនោះ បានមកជាសេដ្ឋីបច្ចន្តជនបទក្នុងកាលឥឡូវនេះ ចំណែកពារាណសីសេដ្ឋី គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា អកតញ្ញូជាតក ទី ១០ ។

ចប់ អដ្ឋកថា អបាយិម្ហវគ្គ ទី ៩ ។

# រួមជាតកដែលមានក្នុងវគ្គនេះគឺ

*សុរាបានជាតក ១ មិត្តវិន្ទជាតក ១ កាឡកណ្ណិជាតក ១ អត្ថស្ស ទ្វារជាតក ១ កិម្បក្កជាតក ១ សីលវីមំសនជាតក ១ មង្គលជាតក ១ សារម្ភជាតក ១ កុហកជាតក ១ អកតញ្ញូជាតក ១ ។*

# លិត្តវគ្គ ទី ១០
# អដ្ឋកថា លិត្តជាតក ទី ១

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបរិភោគបច្ច័យដែលមិនបានពិចារណា ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្តើមថា **លិត្តំ បរមេន តេជសា** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលនោះ ពួកភិក្ខុបានបច្ច័យទាំងឡាយ មានចីវរជាដើម ដោយច្រើនមិនបានពិចារណាហើយបរិភោគ បណ្តាភិក្ខុទាំងនោះ ភិក្ខុដែលមិនបានពិចារណាបច្ច័យ ៤ ហើយបរិភោគ ដោយច្រើនមិនផុតអំពីកំណើតនរកនិងកំណើតសត្វតិរច្ឆាន ។ ព្រះបរមសាស្តាទ្រង់ជ្រាបហេតុនោះ ទើបត្រាស់ព្រះធម្មកថាដល់ភិក្ខុទាំងឡាយដោយបរិយាយជាច្រើន ត្រាស់អំពីទោសក្នុងការមិនពិចារណាបច្ច័យ ៤ ហើយប្រើប្រាស់ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុបានទទួលបច្ច័យ ៤ ហើយ មិនពិចារណា មិនគួរបរិភោគឡើយ ព្រោះហេតុនោះចាប់ពីពេលនេះតទៅ អ្នកទាំងឡាយត្រូវពិចារណាហើយសឹមបរិភោគ កាលទ្រង់សម្តែងវិធីពិចារណា ទ្រង់ដាក់បែបផែនទុកដោយន័យមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុក្នុងធម្មវិន័យនេះ គប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរកំណាត់ទុកដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវសម្ពស្ស របោម

មូស ខ្យល់ កំដៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបិទបាំងនូវអវយវៈដែលធ្វើនូវសេចក្ដីខ្មាសឲ្យកម្រើក ហើយទ្រង់ត្រាស់បន្តទៀតថា ម្នាលភិក្ខុទាំងឡាយ កាលពិចារណាបច្ច័យ ៤ យ៉ាងនេះហើយសឹមបរិភោគ រមែងសមគួរ ដែលឈ្មោះថាការមិនពិចារណាហើយបរិភោគដូចបរិភោគថ្នាំពុលដ៏កាចសាហាវ ដ្បិតថា មនុស្សក្នុងកាលមុន មិនពិចារណា មិនដឹងទោស បរិភោគថ្នាំពុលលទ្ធផលចុងក្រោយត្រូវសោយទុក្ខធំ ដូច្នេះ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលដែលមានភោគច្រើន ចម្រើនវ័យជាអ្នកលេងបាសកា ក្រោយមកមានអ្នកលេងបាសកាអាក្រក់ម្នាក់លេងជាមួយនឹងព្រះបរមពោធិសត្វ កាលខ្លួនឈ្នះក៏មិនទម្លាយវង់លេង ប៉ុន្តែពេលខ្លួនចាញ់ក៏យកកូនបាសកាដាក់ក្នុងមាត់ហើយពោលថា កូនបាសការបស់ខ្ញុំបាត់ហើយ ឈប់លេងទៅ ។ ព្រះបរមពោធិសត្វដឹងគំនិតអាក្រក់របស់បុរសនោះក៏គិតថា ណ្ហើយចុះ អញនឹងរកឧបាយដោះស្រាយបញ្ហាក្នុងរឿងនេះ លុះគិតដូច្នេះហើយ ប្រមូលយកកូនបាសកាទៅជ្រលក់ដោយថ្នាំពុលក្នុងផ្ទះរបស់ខ្លួន រួចហើយហាលឲ្យស្ងួតបន្តិចក្រោយមក នាំយកកូនបាសកាទាំងនោះទៅកាន់សម្នាក់បុរសនោះរួចពោលថា មកសម្លាញ់ យើងលេងបាសកាជាមួយគ្នាទៀត ។ បុរសនោះ

ទទួលពាក្យថា ល្អហើយសម្លាញ់ ចាត់ចែងកន្លែងលេង លេងជាមួយព្រះ-បរមពោធិសត្វរឿយៗ លុះពេលខ្លួនចាញ់ក៏យកកូនបាសកាមួយដាក់ក្នុងមាត់ ព្រះបរមពោធិសត្វឃើញបុរសនោះធ្វើយ៉ាងនេះ ដើម្បីនឹងតឿនថា លេបចូលទៅចុះ ខាងក្រោយឯងនឹងដឹងក្នុងរឿងនេះ ទើបពោលគាថាថា

**លិត្តំ បរមេន តេជសា**

**គិលមក្ខំ បុរិសោ ន ពុជ្ឈតិ**

**គិល រេ គិល បាបធុត្តក**

**បច្ឆា តេ កដុកំ ភវិស្សតីតិ ។**

បុរស កាលលេបនូវកូនស្កា ប្រឡាក់ដោយថ្នាំពិស

មានតេជះដ៏ខ្លាំង ក៏មិនដឹងខ្លួន ម្នាលអ្នកចង្រៃ អ្នក

ចូរលេបទៅ នៃអ្នកលេងអាក្រក់ អ្នកចូរលេបទៅ

ពិសដ៏ផ្សាក្តៅ នឹងមានដល់អ្នក ក្នុងកាលជាខាង

ក្រោយ ។

បណ្តាបទទាំងនោះ បទថា **លិត្តំ** សេចក្តីថា កូនបាសកាដែលប្រឡាក់ហើយ គឺជ្រលក់ទុកហើយ ។

បទថា **បរមេន តេជសា** សេចក្តីថា ដោយថ្នាំពិសដ៏ពន្លឹក សម្បូរដោយតេជះដ៏ខ្លាំង ។

បទថា **គិលំ** ប្រែថា លេប ។

*បទថា* **អគ្គំ** *ប្រែថា កូនបាសកា ។*

*បទថា* **ន ពុជ្ឈតិ** *សេចក្តីថា មិនដឹងខ្លួនថា កាលអញលេប កូនបាសកានេះ ឈ្មោះថា ត្រូវធ្វើកម្មនេះ ។*

*បទថា* **គិល រេ** *សេចក្តីថា នែអ្នកចម្រើន អ្នកចូរលេបទៅ ។*

*ព្រះពោធិសត្វពោលដាស់តឿនដដែលទៀតថា* **គិល** *ចូរលេប ។*

*បទថា* **បច្ឆា តេ កដុកំ ភវិស្សតិ** *សេចក្តីថា កាលអ្នកលេប កូនបាសកានេះទៅហើយ ខាងក្រោយពិសដ៏ផ្សាក្តៅនឹងមានដល់អ្នក ។*

*កាលព្រះបរមពោធិសត្វកំពុងនិយាយយ៉ាងនោះ បុរសនោះក៏ សន្ធប់ដោយកម្លាំងថ្នាំពុល ត្រឡប់ភ្នែក ទន់ក ដួលទៅលើផែនដី ។ ព្រះ-បរមពោធិសត្វគិតថា គួរឲ្យជីវិតជាទានដល់គេ ទើបឲ្យថ្នាំបណ្តេញជាត ពុលដែលផ្សំដោយឱសថ រហូតបណ្តេញជាតពុលចេញមក ហើយឲ្យ ផឹកទឹកដោះ ទឹកអំពៅ ទឹកឃ្មុំនិងស្ករត្នោតជាដើម ធ្វើឲ្យជារោគហើយ ទូន្មានថា កុំធ្វើអំពើបែបនេះទៀត ដូច្នេះហើយ ធ្វើបុណ្យមានឲ្យទានជា ដើម ក្រោយអំពីចុតិក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការមិនពិចារណាហើយបរិភោគ រមែងដូច ការបរិភោគថ្នាំពុលដែលខ្លួនធ្លាប់ធ្វើទុក ហើយទ្រង់ប្រជុំជាតកថា អ្នក-លេងជាបណ្ឌិតក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ចំណែកអ្នកលេង*

*អាក្រក់នឹងមិនពោលដល់ក្នុងរឿងនេះ ឯបុគ្គលណាមិនប្រាកដក្នុងកាលនេះ បុគ្គលនោះក៏មិនពោលដល់ក្នុងរឿងទាំងពួង ៕*

ចប់ អដ្ឋកថា លិត្តជាតក ទី ១ ។

# អដ្ឋកថា មហាសារជាតក ទី ២

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះអានន្ទត្ថេរ ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្តើមថា* **ឧក្កដ្ឋេ សូរមិច្ឆន្តិ** *ដូច្នេះជាដើម ។*

*សម័យមួយ ពួកស្រីស្នំរបស់ព្រះបាទកោសលគិតប្រឹក្សាគ្នាថា ដែលឈ្មោះថា ការកើតឡើងនៃព្រះពុទ្ធជាសភាវៈរកបានដោយកម្រ ការត្រឡប់បានអត្តភាពជាមនុស្សនិងភាពជាអ្នកមានអាយតនៈបរិបូណ៌ ក៏រកបានដោយកម្រដែរ ម្យ៉ាងទៀត ពួកយើងបានជួបប្រសព្វការដល់ព្រមដោយខណៈដែលរកបានដោយកម្រនេះ ហើយមិនអាចទៅកាន់ព្រះវិហារដើម្បីស្តាប់ធម៌ ឬធ្វើការបូជា ឬឲ្យទានតាមការពេញចិត្តរបស់ខ្លួនបាន ដូចជាត្រូវគេទុកក្នុងហិប ពួកយើងនឹងក្រាបទូលព្រះរាជា សូមឲ្យទ្រង់និមន្តភិក្ខុមួយរូប ដែលអាចសម្តែងធម៌ប្រោសពួកយើង ពួកយើងនឹងនាំគ្នាស្តាប់ធម៌ក្នុងសម្នាក់របស់លោក ធម៌ណាដែលពួកយើងត្រូវសិក្សាក៏នឹងនាំគ្នាសិក្សាធម៌នោះអំពីលោក នាំគ្នាបំពេញបុណ្យមានឲ្យទានជាដើម ដោយ*

ប្រការដូច្នេះ ការបានចំពោះនូវខណៈរបស់ពួកយើងនឹងមានផល ។ ស្រី-ស្នំទាំងអស់នោះ នាំគ្នាចូលគាល់ព្រះរាជា ក្រាបទូលហេតុដែលប្រឹក្សាគ្នា ។ ព្រះរាជាត្រាស់ថា ប្រពៃហើយ ។ ថ្ងៃមួយ ព្រះរាជាមានព្រះរាជបំណង នឹងទ្រង់កំសាន្តព្រះរាជឧទ្យាន ក៏បញ្ជាឲ្យហៅនាយឧទ្យានបាលមកគាល់ ហើយត្រាស់ថា នែអ្នកដ៏ចម្រើន អ្នកចូរជម្រះឧទ្យាន ។ នាយឧទ្យានបាល កាលកំពុងជម្រះព្រះរាជឧទ្យានបានជួបនឹងព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ក្រោម ដើមឈើមួយដើម ក៏ប្រញាប់ទៅកាន់រាជដំណាក់ក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ឧទ្យានស្អាតគួរឲ្យមនោរម្យហើយ ប៉ុន្តែព្រះដ៏មាន-ព្រះភាគ ទ្រង់គង់ក្រោមដើមឈើមួយដើមក្នុងឧទ្យាននោះ ។

ព្រះរាជាត្រាស់ថា ប្រពៃហើយសម្លាញ់ យើងនឹងទៅស្តាប់ធម៌ក្នុង សម្នាក់ព្រះបរមសាស្តា ។ ព្រះរាជាស្តេចឡើងរាជរថដែលប្រដាប់ហើយ យាងទៅកាន់ព្រះរាជឧទ្យាន សំដៅទៅកាន់សម្នាក់ព្រះបរមសាស្តា ។

ក្នុងសម័យនោះ ឧបាសកជាព្រះអនាគាមិបុគ្គលម្នាក់ មានឈ្មោះ ថា ឆត្តបាណី អង្គុយស្តាប់ធម៌ក្នុងសម្នាក់ព្រះបរមសាស្តា ព្រះរាជាទត ឃើញឆត្តបាណិឧបាសកហើយ ទ្រង់រង្កៀស ទ្រង់នៅស្ងៀមបន្តិចហើយ ទ្រង់ព្រះតម្រិះថា ប្រសិនបើបុរសនេះជាមនុស្សអាក្រក់ក៏គង់មិនអង្គុយ ស្តាប់ធម៌ក្នុងសម្នាក់ព្រះបរមសាស្តា បុរសនេះប្រហែលមិនមែនជាមនុស្ស អាក្រក់ទេ ហើយស្តេចចូលគាល់ព្រះបរមសាស្តា ថ្វាយបង្គំហើយទ្រង់គង់

ក្នុងទីដ៏សមគួរមួយ ។ ឧបាសកមិនបានក្រោកទទួល ឬថ្វាយបង្គំព្រះរាជាឡើយ ដោយគោរពព្រះពុទ្ធ ព្រោះហេតុនោះ ទើបព្រះរាជាទ្រង់មិនពេញព្រះទ័យនឹងឆត្តបាណិឧបាសក ។ ព្រះបរមសាស្ដាទ្រង់ជ្រាបថា ព្រះរាជាទ្រង់មិនពេញព្រះទ័យនឹងឧបាសក ទើបទ្រង់ត្រាស់គុណរបស់ឧបាសកថា មហាបពិត្រ បុរសនេះជាឧបាសក ជាពហុស្សូត ប្រាសចាកសេចក្ដីត្រេកអរក្នុងកាម ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ព្រះបរមសាស្ដាទ្រង់ជ្រាបគុណរបស់បុគ្គលណា បុគ្គលនោះមិនមែនជាមនុស្សថោកថយឡើយ ទើបត្រាស់ថា នែឧបាសក អ្នកត្រូវការវត្ថុណា អាចប្រាប់ខ្ញុំបាន ។ ឧបាសកទទួលព្រះតម្រាស់ថា ប្រពៃហើយព្រះអង្គ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ធម៌ក្នុងសម្នាក់ព្រះបរមសាស្ដាហើយ ទ្រង់ប្រទក្សិណព្រះបរមសាស្ដាហើយស្ដេចត្រឡប់ទៅវិញ ។

ថ្ងៃមួយ ព្រះរាជាទ្រង់បើកសីហបញ្ជរប្រថាប់ឈរនៅលើប្រាសាទជាន់លើ ទតឃើញឧបាសកនោះបរិភោគអាហារហើយ ក្នុងវេលារសៀលកាន់ឆ័ត្រដើរទៅកាន់វត្តជេតពន ក៏ត្រាស់ឲ្យរាជបុរសទៅអញ្ជើញមកគាល់ហើយត្រាស់យ៉ាងនេះថា នែឧបាសក បានឮថា អ្នកជាពហុស្សូត ពួកស្រីស្នំរបស់ខ្ញុំត្រូវការស្ដាប់និងត្រូវការរៀនធម៌ ។ ឧបាសកនោះពោលថា បពិត្រព្រះសម្មតិទេព ជម្មតាគ្រហស្ថទាំងឡាយមិនសមគួរសម្ដែងធម៌ឬបង្រៀនធម៌ក្នុងព្រះរាជដ្ឋានឡើយ ការបង្រៀននិងការសម្ដែងធម៌

នោះ សមគួរតែលោកម្ចាស់ទាំងឡាយប៉ុណ្ណោះ ។ ព្រះរាជាទ្រង់ព្រះ-តម្រិះថា ឧបាសកនេះនិយាយត្រឹមត្រូវ ទ្រង់ក៏បញ្ជូនឧបាសកនោះទៅ ហើយបញ្ជាឲ្យហៅស្រីស្នំមកគាល់ រួចមានព្រះតម្រាស់ថា នៃនាងដ៏ចម្រើន យើងនឹងទៅកាន់សម្នាក់ព្រះបរមសាស្ដាក្រាបទូលសូមភិក្ខុមួយរូប ដើម្បីសម្ដែងធម៌និងបង្រៀនធម៌ដល់ពួកនាង បណ្ដាព្រះមហាសាវកទាំង ៨០ អង្គ យើងគួរទូលសូមអង្គណាល្អ ? ស្រីស្នំទាំងអស់ប្រឹក្សាគ្នាហើយ ក្រាបទូលថា ព្រះអានន្ទត្ថេរជាឃ្លាំងធម៌តែមួយអង្គ ។ ព្រះរាជាក៏យាង ទៅកាន់សម្នាក់ព្រះបរមសាស្ដា ថ្វាយបង្គំហើយទ្រង់គង់ក្នុងទីដ៏សមគួរ មួយ រួចក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកស្រីស្នំក្នុង វាំងរបស់ខ្ញុំព្រះអង្គ ប្រាថ្នាស្ដាប់ធម៌និងរៀនធម៌ក្នុងសម្នាក់ព្រះអានន្ទត្ថេរ ប្រសិនបើព្រះអានន្ទត្ថេរអាចសម្ដែងធម៌ អាចបង្រៀនធម៌ ក្នុងវាំងរបស់ខ្ញុំ ព្រះអង្គពិតមែននោះ ជាការល្អប្រពៃណាស់។ ព្រះបរមសាស្ដាទ្រង់ទទួល ព្រះតម្រាស់ថា ល្អហើយមហាបពិត្រ ហើយត្រាស់បញ្ជូនព្រះថេរៈឲ្យ ទៅ ។ ចាប់តាំងពីពេលនោះមក ស្រីស្នំរបស់ព្រះរាជាក៏នាំគ្នាស្ដាប់និង រៀនធម៌ក្នុងសម្នាក់ព្រះថេរៈ ។

នៅថ្ងៃមួយ ព្រះចូឡាមណីរបស់ព្រះរាជាបាត់ទៅ ព្រះរាជាទ្រង់ ជ្រាបថាព្រះចូឡាមណីនោះបាត់ ក៏ទ្រង់បង្គាប់ថា អ្នកទាំងឡាយ ចូរចាប់ អ្នកបម្រើខាងក្នុងទាំងអស់ រួចបញ្ជាឲ្យនាំចូឡាមណីឲ្យខាងតែបាន ពួក

អាមាត្យស៊ើបសួររកព្រះចូឡាមណីតាំងតែពីមាតុគ្រាមមក ក៏មិនបានការ ធ្វើឲ្យមហាជនលំបាក ។ ក្នុងថ្ងៃនោះ ព្រះអានន្ទត្ថេរចូលកាន់ព្រះរាជ-វាំង ពួកស្រីស្នំទាំងនោះ ដំបូងគ្រាន់តែឃើញព្រះថេរៈប៉ុណ្ណោះ ក៏នាំគ្នាត្រេកអរ តាំងចិត្តស្តាប់ តាំងចិត្តរៀនធម៌ មិនបានគិតដល់រឿងដែលព្រះរាជាបាត់ព្រះចូឡាមណីនោះឡើយ បន្តិចក្រោយមកក៏បាននាំគ្នាទោមនស្សគ្រប់គ្នា ។ ព្រះថេរៈក៏សួរថា ហេតុដូចម្តេច ទើបអ្នកទាំងឡាយមិនសប្បាយចិត្ត ?

ពួកស្រីស្នំឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកអាមាត្យពោលថា ពួកយើងនឹងស្វែងរកព្រះចូឡាមណីរបស់ព្រះរាជា ហើយនាំគ្នាចាប់មាតុគ្រាមធ្វើឲ្យអ្នកបម្រើខាងក្នុងលំបាកគ្រប់ៗគ្នា ពួកខ្ញុំព្រះករុណាក៏មិនដឹងថានឹងធ្វើយ៉ាងណា ហេតុនោះទើបខ្ញុំព្រះករុណាទាំងឡាយមិនសប្បាយចិត្ត ។ ព្រះថេរៈពោលទៅកាន់ស្រ្តីទាំងនោះថា កុំគិតថ្វីឡើយដូច្នេះហើយ ក៏និមន្តទៅកាន់សម្នាក់ព្រះរាជា គង់លើអាសនៈដែលគេក្រាលទុកហើយថ្វាយព្រះពរសួរថា បពិត្រមហារាជ បានឮថាកែវមណីរបស់ទ្រង់បាត់ឬ ?

ព្រះរាជាត្រាស់ថា ពិតមែនហើយ លោកម្ចាស់ ។

ព្រះអានន្ទថ្វាយព្រះពរសួរថា មហាបពិត្រ មិនអាចនឹងឲ្យអ្នកណានាំមកសងវិញឬ ?

ព្រះរាជាត្រាស់ថា លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះអង្គបញ្ជាឲ្យចាប់មនុស្សខាងក្នុងទាំងអស់ សូម្បីធ្វើឲ្យដល់នូវការលំបាក ក៏មិនទាន់មានអ្នកណានាំមកឲ្យ ។

ព្រះអានន្ទថ្វាយព្រះពរថា បពិត្រមហារាជ ឧបាយដែលមិនត្រូវឲ្យមហាជនលំបាក ហើយឲ្យគេនាំកែវមណីមកវិញនៅមាន ។

ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ តើត្រូវធ្វើយ៉ាងណា ?

ព្រះអានន្ទឆ្លើយថា បពិត្រមហារាជ បិណ្ឌទាន ។

ព្រះរាជាត្រាស់សួរទៀតថា បពិត្រលោកម្ចាស់ដ៏ចម្រើន បិណ្ឌទាននោះ ដូចម្តេច ?

ព្រះអានន្ទថ្វាយព្រះពរថា មហាបពិត្រ មានសេចក្តីសង្ស័យមនុស្សមានប្រមាណប៉ុណ្ណា ក៏ចាប់មនុស្សប្រមាណប៉ុណ្ណោះ ហើយឲ្យបាច់ចំបើង ឬដុំដី ម្នាក់មួយបាច់ ឬម្នាក់មួយដុំ ហើយប្រាប់ថា វេលាជិតភ្លឺឲ្យនាំបាច់ចំបើងឬដុំដីទៅចោលនៅទីឯណោះ អ្នកណាជាអ្នកយកកែវមណី អ្នកនោះនឹងលាក់កែវមណីទុកក្នុងបាច់ចំបើងឬដុំដីនោះ នាំទៅចោលនៅទីឯណោះ ប្រសិនបើនាំគ្នាយកមកចោលក្នុងថ្ងៃដំបូងនោះ ជាការល្អ បើមិននាំមកចោលទេ ក៏គប្បីធ្វើយ៉ាងនោះទៅទៀត សូម្បីក្នុងថ្ងៃទី ២ ទី ៣ ក៏គប្បីធ្វើដោយវិធីនេះដែរ មហាជននឹងមិនលំបាកផង នឹងត្រូវបានកែវមណីមកវិញផង លុះថ្វាយឧបាយយ៉ាងនេះហើយ ព្រះថេរៈក៏ចម្រើនពរ

លាទៅ ។

ព្រះរាជាបញ្ជាឲ្យព្រះរាជទានតាមន័យដែលព្រះថេរៈប្រាប់ អស់ ៣ ថ្ងៃ មិនមានអ្នកណានាំកែវមណីមកសោះ ថ្ងៃទី ៣ ព្រះថេរៈក៏និមន្ត មកសួរព្រះរាជាថា ចម្រើនពរមហាបពិត្រ មានអ្នកយកកែវមណីមក ថ្វាយឬទេ ?

ព្រះរាជាត្រាស់ថា មិនទាន់មានអ្នកណានាំមកឲ្យទេ លោកម្ចាស់ ។

ព្រះថេរៈពោលថា បើដូច្នោះ សូមមហាបពិត្រត្រាស់ឲ្យដាក់ពាងធំ ក្នុងទីកំបាំងក្នុងរោងដ៏ធំនោះ រួចបញ្ជាឲ្យដងទឹកដាក់ឲ្យពេញ ឲ្យបាំង វាំងនន ហើយបញ្ជាថា អ្នកបម្រើខាងក្នុងគ្រប់គ្នានិងពួកស្ត្រី ចូរដណ្តប់ សំពត់ ចូលទៅក្នុងវាំងននោះម្នាក់ម្តងៗ លាងដៃហើយចេញមក ។ ព្រះថេរៈថ្វាយឧបាយយ៉ាងនេះហើយក៏ចម្រើនពរលាទៅ ។ ព្រះរាជា បញ្ជាឲ្យធ្វើយ៉ាងនោះ អ្នកដែលលួចកែវមណីនោះ បានគិតថា ព្រះថេរៈ ដែលជាធម្មកណ្ឌាគារិកមកដោះស្រាយអធិករណ៍នេះ មិនទាន់បានកែវ-មណី ពេលនេះអញគួរចោលកែវមណីនោះ លុះគិតដូច្នេះហើយក៏យក កែវមណីលាក់ឲ្យជិតកាន់ដើរចូលទៅក្នុងវាំងនន បោះទៅក្នុងពាងហើយ ប្រញាប់ចេញមក ពេលមនុស្សគ្រប់គ្នាចេញអស់ហើយ ពួករាជបុរសចាក់ ទឹកចោលបានឃើញកែវមណី ព្រះរាជាទ្រង់សប្បាយព្រះទ័យថា អញ អាស្រ័យព្រះថេរៈបានកែវមណីមកវិញ ដោយមិនបាច់ធ្វើឲ្យមហាជន

លំបាក ។ ចំណែកអ្នកបម្រើក៏ត្រេកអរថា ពួកយើងអាស្រ័យព្រះថេរៈ ទើបផុតទុក្ខដ៏ធំ ។ ដំណឹងដែលថាព្រះរាជាបានព្រះចូឡាមណីមកវិញ ដោយអានុភាពរបស់ព្រះថេរៈបានផ្សព្វផ្សាយពេញនគរ រហូតដល់ភិក្ខុសង្ឃ ។

ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងធម្មសភា ពណ៌នាគុណរបស់ព្រះ-ថេរៈថា អ្នកមានអាយុទាំងឡាយ ព្រះអានន្ទត្តេរបានប្រើឧបាយដោយមិនធ្វើឲ្យមហាជនលំបាក ធ្វើឲ្យព្រះរាជាបានកែវមណីមកវិញ ព្រោះតែលោកជាពហុស្សូត ជាបណ្ឌិត និងជាអ្នកឈ្លាសក្នុងឧបាយ ។ ព្រះបរម-សាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់-មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា មិនមែនតែអានន្ទម្នាក់ប៉ុណ្ណោះទេ ដែលធ្វើឲ្យកែវមណីដែលធ្លាក់ទៅក្នុងដៃអ្នកដទៃបានមកដល់ព្រះហស្តព្រះរាជាវិញនោះ សូម្បីក្នុងកាលមុន បណ្ឌិតទាំង-ឡាយមិនបានធ្វើឲ្យមហាជនលំបាក ប្រើតែឧបាយប៉ុណ្ណោះ ក៏យកភណ្ឌដែលធ្លាក់ទៅក្នុងដៃសត្វតិរច្ឆានបាន ។ កាលភិក្ខុទាំងនោះក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វរៀនចប់សិល្បសាស្ត្រគ្រប់យ៉ាងហើយ

បានជាអាមាត្យរបស់ព្រះបាទព្រហ្មទត្តអង្គនោះឯង ។ ថ្ងៃមួយ ព្រះរាជា យាងទៅកាន់ព្រះរាជឧទ្យានដោយបរិវារជាច្រើន ស្តេចត្រាច់ទៅកាន់ទីជិតព្រៃ ហើយទ្រង់ប្រាថ្នានឹងលេងទឹក យាងចុះកាន់ស្រះបោក្ខរណីដែលជាមង្គល ត្រាស់ហៅស្រីស្នំឲ្យចុះលេងទឹកដែរ ពួកស្រីស្នំក៏ដោះអាភរណៈមានគ្រឿងប្រដាប់សីសៈនិងប្រដាប់កជាដើម ដាក់ក្នុងសំពត់ដណ្តប់ រួចដាក់លើហិបប្រគល់ឲ្យទាសីទាំងឡាយរក្សា ហើយនាំគ្នាចុះកាន់ស្រះបោក្ខរណី ។ គ្រានោះ មេស្វាមួយនៅក្នុងសួននោះអង្គុយច្រងក់លើមែកឈើ ឃើញព្រះ-ទេវីដោះគ្រឿងប្រដាប់ដាក់លើហិប នឹកចង់តែងខ្លួនដោយកម្រងកែវមុក្តារបស់ព្រះទេវី អង្គុយរង់ចាំការធ្វេសប្រហែសរបស់ទាសី ។ ចំណែកទាសីអ្នករក្សាគ្រឿងប្រដាប់របស់ព្រះទេវីនោះ រវល់តែមើលទៅក្នុងទីទាំងឡាយ រួចក៏ដេកលក់ទៅ ស្វាឃើញទាសីដេកលក់ ក៏លោតចុះយ៉ាងលឿនដូចខ្យល់បក់ យកកម្រងកែវមុក្តាមកពាក់ឰដ៏ក ហើយលោតឡើងយ៉ាងរហ័សដូចខ្យល់ដែរ ត្រឡប់អង្គុយលើមែកឈើវិញ ខ្លាចមេស្វាដទៃៗឃើញក៏លាក់ក្នុងប្រហោងឈើមួយ ក្លែងធ្វើដូចជាស្ងៀមស្ងាត់អង្គុយយាមគ្រឿងប្រដាប់នោះ ។ ចំណែកទាសីនោះភ្ញាក់ឡើងមិនឃើញកម្រងកែវមុក្តា ក៏ភ័យញ័រខ្លួន កាលមិនឃើញឧបាយដទៃ ក៏ស្រែកឡើងថា មានមនុស្សដណ្តើមកម្រងកែវមុក្តារបស់ព្រះទេវីទៅហើយ ។ ពួកអ្នកការពារប្រជុំគ្នាតាមតំណែងនោះៗ លុះបានឮពាក្យទាសីនោះ ក៏ក្រាបទូលព្រះរាជា ។

ព្រះរាជាបញ្ជាថា ពួកអ្នកចូរចាប់ចោរឲ្យបាន ។ ពួករាជបុរសទាំងឡាយក៏នាំគ្នាចេញអំពីព្រះរាជឧទ្យាន ហើយពោលថា អ្នកទាំងឡាយ ចូរចាប់ចោរ ចូរចាប់ចោរ រួចស្វែងរកខាងនេះខ្លះ ខាងនោះខ្លះ ។ គ្រានោះ បុរសអ្នកធ្វើពលិកម្មនៅជនបទម្នាក់បានឮសំឡេងនោះ ក៏ភ័យញាប់ញ័ររត់គេចពួករាជបុរសឃើញដូច្នោះក៏ដេញតាមទៅថា បុរសនេះជាចោរ ចាប់ឲ្យបាន លុះចាប់បានហើយវាយផងគំរាមផងថា នែបុរសអាក្រក់ ឯងហ៊ានលួចគ្រឿងប្រដាប់ឈ្មោះមហាសារៈ ( កម្រងកែវមុក្តា ) យ៉ាងនេះឬ? បុរសនោះគិតថា ប្រសិនបើអញប្រាប់ថា ខ្ញុំមិនបានយកទេ ថ្ងៃនេះគង់មិនរួចជីវិត ពួករាជបុរសគង់នឹងវាយអញរហូតទាល់តែស្លាប់ ដូច្នេះ អញចាំបាច់ត្រូវទទួលសារភាព បុរសនោះក៏ប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំបានយក ។ ពេលនោះ ពួករាជបុរសក៏ចងបុរសនោះនាំទៅកាន់សម្នាក់ព្រះរាជា ។ ព្រះរាជាត្រាស់សួរថា គ្រឿងប្រដាប់មានតម្លៃច្រើន អ្នកលួចយកទៅឬ ?

បុរសនោះក្រាបទូលថា ព្រះករុណាថ្លៃវិសេស ។

ព្រះរាជាត្រាស់សួរទៀតថា ពេលនេះអ្នកយកទៅទុកនៅឯណា ?

បុរសនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ដែលឈ្មោះថាវត្ថុមានតម្លៃច្រើន សូម្បីតែគ្រែតាំង ក៏ទូលបង្គំមិនធ្លាប់បានឃើញដែរ ប៉ុន្តែសេដ្ឋីប្រាប់ឲ្យទូលបង្គំលួចគ្រឿងប្រដាប់ដែលមានតម្លៃច្រើននោះ ទូលបង្គំក៏លួចយកទៅឲ្យសេដ្ឋីទៅ សេដ្ឋីនោះឯងទើបដឹង ។ ព្រះរាជាបញ្ជា

ឲ្យហៅសេដ្ឋីមកគាល់ ។ ពេលសេដ្ឋីចូលមកគាល់ក៏ត្រាស់សួរថា គ្រឿងប្រដាប់ដែលមានតម្លៃច្រើន អ្នកបានទទួលអំពីដៃបុរសនេះឬ ?

សេដ្ឋីក្រាបទូលថា ព្រះករុណាថ្លៃវិសេស ។

ព្រះរាជាក៏ត្រាស់សួរទៀតថា អ្នកយកទៅទុកនៅទីណា ?

សេដ្ឋីក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំឲ្យទៅបុរោហិតហើយ ។ ព្រះរាជាបញ្ជាឲ្យហៅបុរោហិតនោះមកគាល់ ហើយត្រាស់សួរដូច្នោះដែរ សូម្បីបុរោហិតក៏ទទួលសារភាពហើយក្រាបទូលថា ទូលបង្គំឲ្យទៅគន្ធព្វ ( អ្នកជំនាញក្នុងតន្ត្រី )ហើយ ។ ព្រះរាជាបញ្ជាឲ្យហៅគន្ធព្វមកគាល់ ហើយត្រាស់សួរទៀតថា អ្នកទទួលយកគ្រឿងប្រដាប់ដែលមានតម្លៃច្រើន អំពីដៃបុរោហិតឬ ?

គន្ធព្វក៏ក្រាបទូលថា ព្រះករុណាថ្លៃវិសេស ។

ព្រះរាជាត្រាស់សួរទៀតថា អ្នកយកទៅទុកនៅទីណា ?

គន្ធព្វក្រាបទូលថា ទូលបង្គំឲ្យទៅនាងវណ្ណទាសីហើយ ដោយអំណាចនៃកិលេស ។ ព្រះរាជាក៏បញ្ជាឲ្យហៅនាងវណ្ណទាសីមកត្រាស់សួរ នាងក្រាបទូលថា ខ្ញុំម្ចាស់មិនបានទទួលទេ ។ កាលសាកសួរមនុស្សទាំង ៥ នាក់នោះ ព្រះអាទិត្យក៏អស្តង្គត ព្រះរាជាត្រាស់ថា ពេលនេះងងឹតហើយ យើងនឹងដឹងរឿងនេះក្នុងថ្ងៃស្អែក ប្រគល់មនុស្សទាំង ៥ នាក់នោះឲ្យទៅអាមាត្យហើយទ្រង់យាងចូលកាន់នគរ ។ ព្រះបរមពោធិសត្វត្រិះរិះ

ថា គ្រឿងប្រដាប់នេះបាត់ក្នុងបរិវេណខាងក្នុង ចំណែកគហបតីនេះជាមនុស្សខាងក្រៅ ការយាមទ្វារក៏មាំទាំ ហេតុនោះ សូម្បីមនុស្សនៅខាងក្នុងលួចគ្រឿងប្រដាប់នោះ ក៏មិនអាចរត់រួច កាលបើដូច្នេះ ផ្លូវដែលមនុស្សខាងក្រៅលួចក្តី ដែលអ្នកបម្រើខាងក្នុងលួចក្តី មិនមានឱកាសឡើយ ពាក្យដែលទុគ្គតបុរសនេះពោលថា ទូលបង្គំឲ្យទៅសេដ្ឋីហើយ ប្រាកដជាពាក្យពោលដើម្បីដោះខ្លួន សូម្បីពាក្យដែលសេដ្ឋីពោលថា ទូលបង្គំឲ្យបុរោហិតហើយ ប្រាកដជាពាក្យពោលព្រោះគិតថា ពួកយើងត្រូវរួមគ្នាដោះស្រាយបញ្ហា សូម្បីពាក្យដែលបុរោហិតពោលថា ទូលបង្គំឲ្យទៅគន្ធព្វហើយ ក៏គង់ជាការពោលព្រោះគិតថា ពួកយើងត្រូវអាស្រ័យគន្ធព្វនឹងនាំគ្នានៅសប្បាយក្នុងគុក ពាក្យដែលគន្ធព្វនិយាយថា ឲ្យទៅនាងវណ្ណទាសីហើយក៏ជាការពោលព្រោះគិតថា ពួកយើងនឹងមិនអផ្សុក មនុស្សទាំង ៥ នាក់នេះ ពិតជាមិនមែនចោរ ក្នុងឧទ្យានមានស្វាជាច្រើន គ្រឿងប្រដាប់ប្រាកដជាធ្លាក់ទៅក្នុងដៃមេស្វាដោយមិនបាច់សង្ស័យ ។ ព្រះបរមពោធិសត្វក៏ចូលទៅគាល់ព្រះរាជា ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ប្រគល់ចោរទាំងនោះឲ្យទូលបង្គំ ទូលបង្គំនឹងជម្រះរឿងនោះ ។ ព្រះរាជាត្រាស់ថា ប្រពៃហើយបណ្ឌិត អ្នកចូរជម្រះចុះ ហើយទ្រង់ប្រគល់មនុស្សទាំង ៥ នាក់នោះឲ្យទៅព្រះបរមពោធិសត្វ ។ ព្រះបរមពោធិសត្វឲ្យហៅបម្រើរបស់ខ្លួនមក ឲ្យនាំមនុស្សទាំង ៥ នាក់នោះទៅនៅក្នុងទីជាមួយគ្នា

ហើយឲ្យធ្វើជញ្ជាំងបាំងឲ្យជិត បញ្ជាឲ្យលបស្តាប់អ្នកទាំង ៩ នាក់នោះនិយាយពាក្យអ្វីខ្លះ ឲ្យអ្នកបម្រើប្រាប់ពាក្យនោះដល់ខ្លួន ហើយចៀសចេញទៅ អ្នកបម្រើទាំងនោះក៏បានធ្វើដូច្នោះ ។

លុះពេលដែលមនុស្សទាំង ៩ នាក់នោះសន្ទនាគ្នា សេដ្ឋីពោលទៅកាន់គហបតីថា នែគហបតីអាក្រក់ ឯងធ្លាប់ជួបអញ ឬអញធ្លាប់ជួបឯងអំពីកាលណា? ឯងឲ្យគ្រឿងប្រដាប់នោះដល់អញអំពីកាលណា?

គហបតីពោលថា បពិត្រមហាសេដ្ឋីដ៏ចម្រើន ខ្ញុំមិនស្គាល់វត្ថុដែលមានឈ្មោះថា មហាសារៈ ទោះជាគ្រែតាំងដែលមានជើងធ្វើដោយឈើខ្លឹមក៏ខ្ញុំមិនស្គាល់ ការដែលខ្ញុំពោលយ៉ាងនេះ ព្រោះគិតថា នឹងអាស្រ័យលោកបានការរួចផុត សូមលោកកុំខឹងនឹងខ្ញុំឡើយ ។ សូម្បីបុរោហិតក៏និយាយទៅកាន់សេដ្ឋីថា លោកឲ្យគ្រឿងប្រដាប់ដែលគហបតីមិនបានឲ្យដល់លោក ដល់ខ្ញុំបានដូចម្តេច?

សេដ្ឋីពោលថា ខ្ញុំពោលទៅព្រោះថា យើងទាំងពីរនាក់ជាអ្នកធំពេលដែលយើងរួមគ្នានិយាយ ការងារនឹងសម្រេចដោយឆាប់ ។

ចំណែកគន្ធព្វក៏ពោលទៅកាន់បុរោហិតថា នែព្រាហ្មណ៍ អ្នកឲ្យគ្រឿងប្រដាប់ដល់ខ្ញុំអំពីកាលណា?

បុរោហិតពោលថា ខ្ញុំពោលទៅព្រោះគិតថា នឹងបានអាស្រ័យលោកនៅជាសុខក្នុងទីដែលត្រូវឃុំឃាំង ។ ចំណែកនាងវណ្ណទាសីក៏ពោល

ទៅកាន់គន្ធព្វថា នៃមនុស្សអាក្រក់ គន្ធព្វជួរជាតិ យើងធ្លាប់ទៅរកអ្នក ឬអ្នកធ្លាប់មករកយើងអំពីកាលណា ? អ្នកឲ្យគ្រឿងប្រដាប់ដល់យើងនៅពេលណា ?

គន្ធព្វពោលថា នែប្អូនស្រី ព្រោះហេតុដូចម្ដេចទើបមកខឹងនឹងខ្ញុំយ៉ាងនេះ ? កាលពួកយើងទាំង ៥ នាក់នៅរួមគ្នា រឿងកេទសម្ពន្ធនឹងត្រូវមាន ព្រោះអាស្រ័យនាង ពួកយើងនឹងមិនកណ្ដោចកណ្ដែង នៅរួមគ្នាយ៉ាងសប្បាយ ។

ព្រះបរមពោធិសត្វស្ដាប់ពាក្យនោះ អំពីសម្នាក់នៃអ្នកបម្រើក៏ដឹងច្បាស់ថា មនុស្សទាំង ៥ នាក់នោះមិនមែនជាចោរ គិតថា គ្រឿងប្រដាប់នោះពិតជាមេស្វាយកទៅ នឹងធ្វើឧបាយឲ្យវាយកមកវិញឲ្យទាល់តែបាន ។ គិតហើយធ្វើគ្រឿងប្រដាប់អំពីជ័រឈើ ឲ្យចាប់ស្វាញីទាំងឡាយក្នុងឧទ្យាន ហើយឲ្យបំពាក់គ្រឿងប្រដាប់ដែលធ្វើអំពីជ័រឈើនោះ ព្ធដ៏កដៃ កជើង និងព្ធដ៏ក ហើយលែងទៅ ចំណែកមេស្វាដែលអង្គុយចាំគ្រឿងប្រដាប់នោះក៏អង្គុយនៅក្នុងឧទ្យាននោះឯង ។ ព្រះបរមពោធិសត្វប្រាប់អ្នកបម្រើទាំង-ឡាយថា អ្នកទាំងឡាយ ចូរនាំគ្នាពិនិត្យហ្វូងស្វាក្នុងឧទ្យានឲ្យសព្វគ្រប់ ឃើញគ្រឿងប្រដាប់នោះនៅនឹងមេស្វាមួយណា ចូរធ្វើឲ្យវាភ័យ ហើយយកគ្រឿងប្រដាប់នោះមកឲ្យខាងតែបាន ។ ហ្វូងស្វាទាំងនោះក៏សប្បាយចិត្តថា ពួកយើងបានគ្រឿងតែងខ្លួនហើយ ក៏រត់ទៅមកក្នុងឧទ្យាន ទៅ

ដល់កន្ទែងមេស្វានោះ នាំគ្នាពោលថា ចូរមើលគ្រឿងប្រដាប់របស់ពួកយើង មេស្វានោះអត់ទ្រាំមិនបាន ក៏គិតថា ប្រយោជន៍អ្វីដោយគ្រឿងប្រដាប់ដែលធ្វើអំពីជ័រឈើនោះ ហើយតែងខ្លួនដោយកម្រងកែវមុក្តានោះចេញមកបង្អួត ។ ពេលនោះអ្នកបម្រើឃើញមេស្វានោះហើយ ក៏ធ្វើឲ្យវាបោះគ្រឿងប្រដាប់ចោល ហើយនាំមកប្រគល់ជូនព្រះបរមពោធិសត្វ ។ ព្រះបរមពោធិសត្វនាំគ្រឿងប្រដាប់នោះទៅថ្វាយព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះជាគ្រឿងប្រដាប់របស់ព្រះទេវី មនុស្សទាំង ៥ នាក់នោះ មិនមែនជាចោរទេ គ្រឿងប្រដាប់នេះបានមកអំពីមេស្វាក្នុងឧទ្យាន ។

ព្រះរាជាត្រាស់សួរថា នែបណ្ឌិត អ្នកដឹងថាគ្រឿងប្រដាប់នេះនៅក្នុងដៃស្វាបានដោយរបៀបណាដែរ ? ព្រះបរមពោធិសត្វក្រាបទូលរឿងទាំងអស់ឲ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់សប្បាយព្រះទ័យត្រាស់ថា ធម្មតាមនុស្សក្លាហាន ជាបុគ្គលដែលគួរប្រាថ្នាក្នុងតំណែងមេទ័ពជាដើម ដូច្នេះហើយ កាលទ្រង់សរសើរព្រះបរមពោធិសត្វ ទើបត្រាស់គាថានេះថា

**ឧក្កដ្ឋេ សូរមិច្ឆន្តិ មន្តីសុ អកុតូហលំ**
**បិយញ្ច អន្នបានម្ហិ អត្ថេ ជាតេ ច បណ្ឌិតន្តិ ។**

ក្នុងកាលសង្គ្រាម កើតឡើង ពួកជនរមែងប្រាថ្នានូវ
បុរសអ្នកក្លៀវក្លា ក្នុងពួកអ្នកប្រឹក្សាការ គេប្រាថ្នានូវ

បុរសអ្នកមានវាចាមិនពោយពាយ ក្នុងកាលមានបាយ
ទឹកឆ្ងាញ់ គេប្រាថ្នានូវបុរសជាទីស្រឡាញ់ ក្នុងកាល
អាថ៌ (កំបាំង) កើតឡើង គេប្រាថ្នានូវបណ្ឌិត ។

បណ្ដាបទទាំងនោះ បទថា **ឧក្កាដ្ឋេ** សេចក្ដីថា ក្នុងពេលតានតឹង គឺក្នុងពេលដែលទាហានទាំងពីរចំណែកចូលជិតគ្នា អធិប្បាយថា ក្នុងកាលចម្បាំង ក្នុងសង្គ្រាមកំពុងដំណើរទៅ ។

បទថា **សូរមិច្ឆន្តិ** សេចក្ដីថា គេរមែងប្រាថ្នានូវបុរសអ្នកក្លៀវក្លា ដែលមានប្រក្រតីមិនថយក្រោយ សូម្បីត្រូវអសនីបាត គឺរន្ទះធ្លាក់មកលើក្បាល ព្រោះថា ក្នុងពេលនោះ បុរសបែបនេះគួរបានទទួលការតែងតាំងឲ្យជាមេទ័ព ។

បទថា **មន្ដីសុ អកុតូហលំ** សេចក្ដីថា កាលមានកិច្ចដែលនឹងត្រូវប្រឹក្សាអំពីកិច្ចដែលគួរធ្វើនិងមិនគួរធ្វើ ក្នុងពេលប្រឹក្សាកិច្ចការ គេរមែងប្រាថ្នាអ្នកដែលមានវាចាមិនពោយពាយ មិននិយាយផ្ដេសផ្ដាស គឺមិនសុសសាយបើកបង្ហាញនូវរឿងដែលប្រឹក្សាគ្នានោះ ព្រោះមនុស្សដូច្នោះសមគួរតែងតាំងក្នុងតំណែងនោះៗ ។

បទថា **បិយញ្ច អន្នបានម្ហិ** សេចក្ដីថា កាលមានបាយទឹកឆ្ងាញ់ គេរមែងប្រាថ្នាមនុស្សដែលជាទីស្រឡាញ់ ដើម្បីបបួលឲ្យបរិភោគរួមគ្នា ព្រោះមនុស្សដូច្នោះ ចាំបាច់ក្នុងវេលានោះ ។

*បទថា* **អត្ថេ ជាតេ ច បណ្ឌិតំ** *សេចក្តីថា កាលអត្ថដ៏ជ្រាលជ្រៅកើតឡើង ឬកាលហេតុ ឬបញ្ហាណាមួយកើតឡើង គេរមែងប្រាថ្នាបណ្ឌិតអ្នកមានបញ្ញា ព្រោះអ្នកមានលក្ខណៈដូច្នោះ គេពេញចិត្តនឹងប្រាថ្នាក្នុងសម័យនោះ ។*

*ព្រះរាជាត្រាស់សរសើរព្រះបរមពោធិសត្វ ដោយប្រការដូច្នេះ ទ្រង់បូជាហើយដោយរតនៈ ៧ប្រការ ដូចមហាមេឃញុំាំងភ្លៀងព្រឹលឲ្យធ្លាក់ចុះដូច្នោះ តម្កល់ខ្លួនព្រះអង្គក្នុងឱវាទរបស់ព្រះបរមពោធិសត្វ ទ្រង់បំពេញបុណ្យមានឲ្យទានជាដើម ក្រោយអំពីសោយទិវង្គតស្តេចទៅតាមយថាកម្ម សូម្បីព្រះបរមពោធិសត្វក៏ទៅតាមយថាកម្មដែរ ។*

*ព្រះបរមសាស្តាទ្រង់នាំព្រះធម្មទេសនានេះមក ហើយត្រាស់គុណរបស់ព្រះថេរៈ ។ ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ចំណែកអាមាត្យដែលជាបណ្ឌិត គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា មហាសារជាតក ទី ២ ។

# អដ្ឋកថា វិស្សាសភោជនជាតក ទី ៣

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការបរិភោគដោយស្និទ្ធស្នាល ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន វិស្សសេ អវិស្សត្ថេ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ក្នុងសម័យនោះ ពួកភិក្ខុដោយច្រើនទុកចិត្តគ្នា មិនពិចារណាបរិភោគបច្ច័យ ៤ ដែលពួកញាតិប្រគេន ព្រោះគិតថា មាតារបស់ពួកយើងប្រគេន បិតារបស់ពួកយើងប្រគេន បងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី ពូ មីង អ៊ំប្រុស អ៊ំស្រីប្រគេន អ្នកទាំងអស់នេះសមគួរនឹងប្រគេនយើង សូម្បីក្នុងកាលនៅជាគ្រហស្ថ ដល់ពេលយើងបួសជាភិក្ខុក៏គង់ជាអ្នកសមគួរនឹងឲ្យ ។ ព្រះបរមសាស្តាទ្រង់ជ្រាបហេតុនោះ ទ្រង់ព្រះតម្រិះថា តថាគតគួរនឹងសម្តែងធម៌ទេសនាដល់ភិក្ខុទាំងឡាយ លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបទ្រង់ត្រាស់ឲ្យហៅភិក្ខុប្រជុំ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុត្រូវពិចារណាហើយសឹមបរិភោគបច្ច័យ ៤ សូម្បីបច្ច័យដែលពួកញាតិប្រគេនក៏ដោយ ដ្បិតថា ពួកភិក្ខុដែលមិនពិចារណាហើយបរិភោគ ធ្វើកាលកិរិយាទៅ រមែងមិនផុតអំពីអត្តភាពយក្សនិងប្រេត ដែលឈ្មោះថាការបរិភោគបច្ច័យ ៤ ដែលមិនពិចារណានេះដូចការបរិភោគថ្នាំពុល ទោះបីបច្ច័យដែលមនុស្សស្និទ្ធ-ស្នាលប្រគេនហើយក្តី មនុស្សដែលមិនស្និទ្ធស្នាលប្រគេនហើយក្តី រមែង

ធ្វើឲ្យស្លាប់បានទាំងអស់ សូម្បីក្នុងកាលមុនសត្វទាំងឡាយបរិភោគថ្នាំពុលដែលគេឲ្យដោយសេចក្តីស្រឡាញ់ ក៏ ដល់នូវការអស់ជីវិតហើយដែរ ។ កាលភិក្ខុទាំងនោះក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វកើតជាសេដ្ឋីមានសម្បត្តិច្រើន ។ អ្នកឃ្វាលគោរបស់ព្រះបរមពោធិសត្វម្នាក់ កៀងគោចូលព្រៃក្នុងសម័យដែលដីស្រែពោរពេញទៅដោយសន្ទូង ធ្វើក្រោលហើយឃ្វាលគោនៅក្នុងព្រៃនោះ ហើយនាំគោរសមកជូនលោកសេដ្ឋីតាមពេលវេលា ។ នៅក្នុងទីមិនឆ្ងាយអំពីអ្នកឃ្វាលគោនោះ សីហៈហ្វូងហែងយកធ្វើជាទីនៅ ហ្វូងគោស្គមព្រោះខ្លាចសីហៈ ទឹកដោះក៏ថ្ងា ។ ថ្ងៃមួយ អ្នកឃ្វាលគោយកទឹកដោះមកជូនលោកសេដ្ឋី ។ លោកសេដ្ឋីក៏សួរថា នែ សម្លាញ់គោបាល ហេតុដូចម្តេច ទើបទឹកដោះថ្ងា ? អ្នកឃ្វាលគោក៏ប្រាប់ហេតុនោះ ។

សេដ្ឋីសួរថា នែសម្លាញ់ តើសីហៈនោះជាប់ចិត្តនឹងអ្វី ?

អ្នកឃ្វាលគោឆ្លើយថា វាជាប់ចិត្តនឹងមេម្រឹគមួយ ។

សេដ្ឋីសួរថា អ្នកអាចចាប់មេម្រឹគនោះបានទេ ?

អ្នកឃ្វាលគោឆ្លើយថា បាន លោកម្ចាស់ ។

សេដ្ឋីពោលថា បើដូច្នោះ អ្នកចូរចាប់វាឲ្យបាន យកថ្នាំពុលលាប

រោមរបស់វា តាំងពីថ្ពាសរបស់វាចុះទៅដល់កន្ទុយ ធ្វើឲ្យស្ងួត ឃាត់ទុកពីរ-បីថ្ងៃ សឹមដោះលែងមម្រឹគនោះទៅ សីហៈនោះនឹងលិទ្ធសរីរៈរបស់មម្រឹគនោះដោយសេចក្ដីស្នេហា ដល់នូវការអស់ជីវិតមិនខាន ពេលនោះ អ្នកចូរយកស្បែក ក្រចក ចង្កូម និងសាច់របស់វាមកឲ្យយើង ហើយប្រគល់ថ្នាំពុលមានពិសដ៏ពន្លឹកឲ្យអ្នកឃ្វាលគោយកទៅ ។ អ្នកឃ្វាលគោដាក់អន្ទាក់ចាប់មម្រឹគនោះដោយឧបាយ ហើយបានធ្វើតាមការណែនាំរបស់សេដ្ឋី ។ ចំណែកសត្វសីហៈឃើញមម្រឹគនោះហើយ លិទ្ធសរីរៈរបស់មម្រឹគនោះដោយសេចក្ដីស្នេហាដ៏ខ្លាំងក្លា ហើយក៏ដល់នូវការអស់ទៅនូវជីវិត អ្នកឃ្វាលគោក៏យកស្បែកជាដើមទៅកាន់សម្នាក់ព្រះបរមពោធិសត្វ ។

ព្រះបរមពោធិសត្វជ្រាបហេតុនោះហើយពោលថា ដែលឈ្មោះថាស្នេហាក្នុងអ្នកដទៃមិនគួរធ្វើឡើយ សីហៈជាស្ដេចម្រឹគ សូម្បីសម្បូរដោយកម្លាំងយ៉ាងនេះ ប៉ុន្តែព្រោះអាស្រ័យសេចក្ដីស្រឡាញ់ ដោយអំណាចកិលេស លិទ្ធសរីរៈមម្រឹគ បរិភោគថ្នាំពុលដល់នូវការអស់ជីវិត កាលនឹងសម្ដែងធម៌ដល់បរិស័ទដែលប្រជុំគ្នា បានពោលគាថានេះថា

**ន វិស្សសេ អវិស្សត្ថេ វិស្សត្ថេបិ ន វិស្សសេ**
**វិស្សាសា ភយមន្វេតិ សីហំវ មិគមាតុកាតិ ។**

បុគ្គលមិនគប្បីស្និទ្ធស្នាល ក្នុងបុគ្គលដែលមិនធ្លាប់ស្និទ្ធ-ស្នាល មិនគប្បីស្និទ្ធស្នាលក្នុងបុគ្គល សូម្បីធ្លាប់ស្និទ្ធ-

ស្នាលហើយ ភ័យរមែងទៅតាមបុគ្គលនោះ ព្រោះ
សេចក្ដីស្និទ្ធស្នាល ដូចជាភ័យដែលជាប់តាមនូវសត្វ-
សីហៈ ព្រោះមេម្រឹគ។

ក្នុងគាថានោះ មានសេចក្ដីសង្ខេបដូច្នេះ បុគ្គលណា ក្នុងកាលមុន ជាទីនាំមកនូវភ័យ មិនទាន់ស្និទ្ធស្នាលនឹងខ្លួន មិនគប្បីទុកចិត្ត គឺមិនគប្បីធ្វើសេចក្ដីស្និទ្ធស្នាលនឹងបុគ្គលដែលមិនទាន់ស្និទ្ធស្នាលនោះ បុគ្គលណា សូម្បីក្នុងកាលមុនមិនមែនជាអ្នកនាំមកនូវភ័យ ជាអ្នកស្និទ្ធស្នាលនឹងខ្លួន សូម្បីបុគ្គលអ្នកស្និទ្ធស្នាលនោះ ក៏មិនគួរជឿទុកចិត្ត គឺមិនគប្បីធ្វើសេចក្ដីស្និទ្ធស្នាល។

សួរថា ព្រោះហេតុអ្វី?

ឆ្លើយថា ព្រោះភ័យរមែងកើតមកអំពីអ្នកស្និទ្ធស្នាល បានដល់ភ័យនោះឯង រមែងកើតអំពីការស្និទ្ធស្នាលទាំងក្នុងមិត្តទាំងក្នុងសត្រូវ ។

សួរថា សេចក្ដីនេះដូចម្ដេច ?

ឆ្លើយថា ដូចភ័យរបស់រាជសីហ៍កើតអំពីមេម្រឹគដូច្នោះ គឺដូចភ័យដែលកើតមានដល់សីហៈ ព្រោះមេម្រឹគដែលខ្លួនធ្លាប់ស្និទ្ធស្នាលដោយអំណាចមិត្តសន្ថវៈ ម្យ៉ាងទៀត មានសេចក្ដីអធិប្បាយថា ដូចមេម្រឹគដែលប្រាថ្នានឹងចូលជិតសីហៈដោយសេចក្ដីស្រឡាញ់ដូច្នោះ ។

ព្រះពោធិសត្វសម្ដែងធម៌ដល់បរិស័ទដែលមកប្រជុំគ្នា ដោយប្រការ

*ដូច្នេះ ធ្វើបុណ្យមានឲ្យទានជាដើម លុះអស់ជីវិតក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា មហាសេដ្ឋីក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា វិស្សាសភោជនជាតក ទី ៣ ។

# អដ្ឋកថា លោមហំសជាតក ទី ៤

*ព្រះបរមសាស្តា កាលទ្រង់អាស្រ័យនគរវេសាលី ទ្រង់គង់នៅក្នុងបាដិការាម ទ្រង់ប្រារព្ធសុនក្ខត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **សោតត្តោ សោសីតោ** *ដូច្នេះជាដើម ។*

*បានឮថា សម័យមួយ សុនក្ខត្តត្រូវជាឧបដ្ឋាករបស់ព្រះបរមសាស្តា កាន់បាត្រចីវរតាមក្រោយព្រះបរមសាស្តា កើតការពេញចិត្តចំពោះធម៌របស់កោរក្ខត្តិយបរិព្វាជក ថ្វាយបាត្រចីវរដល់ព្រះទសពល ទៅអាស្រ័យកោរក្ខត្តិយបរិព្វាជក ។ កាលកោរក្ខត្តិយបរិព្វាជកនោះទៅកើតក្នុងកំណើតអសុរពួកកាលកញ្ជិកៈ ក៏សឹកទៅជាគ្រហស្ថដើរពោលទោសព្រះបរមសាស្តាតាមកំពែងទាំងបីក្នុងនគរវេសាលីថា ឧត្តរិមនុស្សធម៌គឺញាណទស្សនៈដ៏វិសេស ដែលធ្វើឲ្យបានទៅជាព្រះអរិយបុគ្គលរបស់ព្រះសមណគោតមមិនមានទេ ព្រះសមណគោតមសម្តែងធម៌ដែលខ្លួននឹកគិតដោយខ្លួនឯង ស្រាវជ្រាវយកតាមដែលខ្លួនពិចារណាជាបដិភាណរបស់ខ្លួន*

ហើយធម៌ដែលព្រះសមណគោតមសម្តែងនោះ ក៏មិនបាននាំទៅដើម្បីការអស់ទុក្ខដោយប្រពៃដល់អ្នកបដិបត្តិតាមឡើយ ។ គ្រានោះ ព្រះសារីបុត្តត្ថេរ ត្រាច់បិណ្ឌបាតបានឮសុនក្ខត្តពោលទោសព្រះបរមសាស្តា ត្រឡប់មកអំពីបិណ្ឌបាតវិញ ក៏ក្រាបទូលរឿងនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត សុនក្ខត្តជាមនុស្សច្រើនទៅដោយសេចក្តីក្រោធ ជាមោឃបុរស ពោលយ៉ាងនេះដោយអំណាចសេចក្តីក្រោធប៉ុណ្ណោះ ពោលថា ធម៌នោះមិនមែននាំទៅដើម្បីការអស់ទុក្ខដោយប្រពៃដល់អ្នកបដិបត្តិតាមនោះ ដូច្នេះ សូម្បីត្រូវអំណាចនៃសេចក្តីក្រោធខ្លាំង ព្រោះតែមិនដឹងការពិត ទើបពោលទោសតថាគតមិនឈប់យ៉ាងនេះ សុនក្ខត្តជាមោឃបុរស ទើបមិនដឹងគុណតថាគត ម្នាលសារីបុត្ត គុណវិសេសដែលឈ្មោះថា អភិញ្ញា ៦ របស់តថាគតមាន សូម្បីធម៌នេះ ក៏ជាឧត្តរិមនុស្សធម៌របស់តថាគតដែរ ពលៈ ១០ ក៏មាន វេសារជ្ជញ្ញាណ ៤ ប្រការក៏មាន ញាណដែលកំណត់ដឹងកំណើតទាំង ៤ ក៏មាន ញាណដែលដឹងគតិទាំង ៥ ក៏មាន សូម្បីគុណធម៌ទាំងអស់នេះក៏ជាឧត្តរិមនុស្សធម៌របស់តថាគតដែរ បុគ្គលណាពោលចំពោះតថាគតដែលដល់ព្រមដោយឧត្តរិមនុស្សធម៌មានប្រមាណប៉ុណ្ណេះ យ៉ាងនេះថា ឧត្តរិមនុស្សធម៌របស់ព្រះសមណគោតមមិនមាន បុគ្គលនោះមិនលះបង់ពាក្យនោះទេ មិនលះបង់ការគិតនោះទេ មិនដកចោលនូវការយល់ឃើញនោះទេ រមែងត្រូវ

កប់ក្នុងនរកដូចត្រូវគេចាប់យកទៅកប់ដូច្នោះ ។ លុះទ្រង់ត្រាស់ព្រះគុណនៃឧត្តរិមនុស្សធម៌ដែលមាននៅក្នុងព្រះអង្គយ៉ាងនេះហើយ ទើបទ្រង់ត្រាស់ថា ម្នាលសារីបុត្ត បានឮថាសុនក្ខត្តជ្រះថ្លាចំពោះមិច្ឆាតបៈ ដោយកិរិយានៃកម្មដែលបុគ្គលធ្វើបានដោយកម្ររបស់កោរក្ខត្តិយៈ កាលជ្រះ-ថ្លាក៏មិនបានជ្រះថ្លាចំពោះតថាគតឡើយ ពិតណាស់ក្នុងទីបំផុតនៃកប្ប ៩១ អំពីភទ្ទកប្បនេះ តថាគតសាកល្បងមិច្ឆាតបៈរបស់ពាហិរលទ្ធិ គឺលទ្ធិខាងក្រៅ ដើម្បីឲ្យដឹងថាសារៈក្នុងតបៈនោះមានពិតឬទេ ? បំពេញព្រហ្មចរិយៈដែលប្រកបដោយអង្គ ៤ តថាគតបើពោលដោយរឿងតបៈ តថាគតប្រកបដោយតបៈដ៏កំពូល បើពោលដោយភាពសៅហ្មង តថាគតជាអ្នកសៅហ្មងយ៉ាងកំពូល បើពោលដោយភាពគួរខ្ពើម តថាគតគួរខ្ពើមបំផុត បើពោលដោយភាពស្ងប់ស្ងៀម តថាគតជាអ្នកស្ងប់ស្ងៀមបំផុត លុះទ្រង់ត្រាស់ដូច្នេះហើយ កាលព្រះថេរៈក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ទីបំផុតនៃកប្បទី ៩១ ព្រះបរមពោធិសត្វត្រិះរិះថា អញនឹងពិសោធពាហិរតបៈរបស់ពួកលទ្ធិខាងក្រៅ ក៏បួសជាអាជីវក មិនស្លៀកសំពត់ ប្រឡាក់ដោយធូលី នៅស្ងៀមស្ងាត់តែម្នាក់ឯង ឃើញពួកមនុស្សហើយរត់គេចដូចម្រឹគ មានមហាវិកតិជាភោជន បរិភោគអាចម៍កូនគោជាដើម ដើម្បីរស់នៅដោយការមិនប្រមាទ ទើបនៅក្នុងដងព្រៃមួយ

កាលនៅក្នុងទីនោះ ទឹកសន្សើមធ្លាក់ពេលអធ្រាត្រ ចេញអំពីដងព្រៃនៅកណ្ដាលវាល ជោកទៅដោយទឹកសន្សើម វេលាថ្ងៃត្រង់ក៏មានទំនងដូច្នេះដែរ ធ្វើខ្លួនឲ្យជោកដោយដំណក់ទឹកដែលហូរមកអំពីដងព្រៃ សោយទុក្ខព្រោះរងា ទាំងពេលថ្ងៃត្រង់ផង ពេលអធ្រាត្រផងយ៉ាងនេះ ។ ម្យ៉ាងទៀត ក្នុងខែជាខាងចុងនៃរដូវក្ដៅ ពេលថ្ងៃត្រង់ក៏ដល់នូវការក្ដៅធ្ងួលអន្ទះអន្ទែងដោយកំដៅថ្ងៃនៅក្នុងទីវាល ពេលអធ្រាត្រក៏ដូច្នេះដែរ គឺដល់នូវការអន្ទះអន្ទែងនៅក្នុងដងព្រៃដែលប្រាសចាកខ្យល់ ដំណក់ញើសហូរចេញអំពីសរីរៈ គ្រានោះ គាថានេះ មិនធ្លាប់បានឮមកអំពីមុនឡើយ បានប្រាកដច្បាស់ថា

**សោតត្តោ សោសីតោ ករោ ឯកោ ភឹសនកេ វនេ**
**នគ្គោ ន ចគ្គិមាសីនោ ឯសនា បសុតោ មុនីតិ ។**

អាត្មាអញ ក្ដៅណាស់ហើយ ត្រជាក់ណាស់ហើយ នៅតែម្នាក់ឯង ក្នុងព្រៃគួរខ្លាច ជាមនុស្សអាក្រាត ទាំងមិនអាំងភ្លើង ជាអ្នកខ្វល់ខ្វាយក្នុងការស្វែងរក (នូវព្រហ្មចរិយធម៌) ប្រតិបត្តិដើម្បីមោនៈ ។

បណ្ដាបទទាំងនោះ បទថា **សោតត្តោ** សេចក្ដីថា អាត្មាអញក្ដៅក្រហាយដោយការដុតពោលអំពីព្រះអាទិត្យ ។

បទថា **សោសីតោ** សេចក្ដីថា អាត្មាអញរងាណាស់ គឺជោកទៅ

ដោយទឹកសន្សើម ។

បទថា **ឯកោ ភឹសនកេ វនេ** នេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងថា អាត្មាអញនៅតែម្នាក់ឯងមិនមានសម្លាញ់ នៅក្នុងព្រៃស្ទុកដែលគួរខ្លាច ធ្វើឲ្យអ្នកដែលចូលទៅព្រឺរោមគ្រប់គ្នា ។

បទថា **នគ្គោ ន ចគ្គិនាសីនោ** នេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងថា អាត្មាអញជាមនុស្សអាក្រាតផង មិនបានអាំងភ្លើងផង គឺសូម្បីខ្យល់រងាបៀតបៀន ក៏មិនបានអាស្រ័យសំពត់ស្លៀកសំពត់ដណ្ដប់ជាដើម និងមិនបានអាំងភ្លើងទៀតផង ។

បទថា **ឯសនា បសុតោ** នេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងថា សូម្បីអព្រហ្មចរិយៈ ក៏មានន័យថា ជាព្រហ្មចរិយៈក្នុងសេចក្ដីព្យាយាមនោះ គឺជាអ្នកខ្វល់ខ្វាយក្នុងសេចក្ដីព្យាយាម ដល់នូវការប្រឹងប្រែងស្វែងរកនូវព្រហ្មចរិយៈយ៉ាងនេះថា អំពើនេះជាព្រហ្មចរិយៈពិត ការស្វែងរកជាឧបាយនៃព្រហ្មលោក ។

បទថា **មុនី** នេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងថា ជាអ្នកដែលសត្វលោកសរសើរយ៉ាងនេះថា បុគ្គលនេះបដិបត្តិដើម្បីញាណ ជាគ្រឿងត្រាស់ដឹង ដើម្បីបានទៅជាមុនី ។

ព្រះបរមពោធិសត្វប្រព្រឹត្តព្រហ្មចរិយៈប្រកបដោយអង្គ ៤ យ៉ាងនេះ សម្រឹងឃើញប្រផ្នូលនរកប្រាកដច្បាស់ឡើងក្នុងវេលាអរុណរះ ក៏ដឹងថា

ការសមាទានវត្តនេះឥតប្រយោជន៍ ទើបទម្លាយលទ្ធិនោះចោល ក្នុងខណៈនោះឯងត្រឡប់សមាទានសម្មាទិដ្ឋិ ក្រោយអំពីចុតិបដិសន្ធិក្នុងទេវលោក ។

ព្រះបរមសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា សម័យនោះ **តថាគត** បានជាអាជីវកនោះ ៕

ចប់ អដ្ឋកថា លោមហំសជាតក ទី ៤ ។

# អដ្ឋកថា មហាសុទស្សនជាតក ទី ៥

ព្រះបរមសាស្តា ទ្រង់ផ្ទំលើគ្រែបរិនិព្វាន ទ្រង់ប្រារព្ធពាក្យរបស់ព្រះអានន្ទត្ថេរដែលក្រាបទូលថា ព្រះដ៏មានព្រះភាគ ទ្រង់កុំបរិនិព្វានក្នុងនគរតូចៗ នេះឡើយ ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្ដើមថា **អនិច្ចា វត សង្ខារា** ដូច្នេះជាដើម ។

សេចក្ដីសង្ខេបថា កាលព្រះតថាគតទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរបរិនិព្វាននៅក្នុងបន្ទប់ដែលលោកប្រសូត ក្នុងស្រុកនាលកៈ ក្នុងថ្ងៃពេញបូណ៌មីខែកត្តិក ព្រះមហាមោគ្គល្លានត្ថេរបរិ-និព្វានក្នុងថ្ងៃអមាវសី ( ដាច់ខែ ) ក្នុងកាឡបក្ខនៃខែកត្តិកនោះឯង ព្រះ-បរមសាស្តាទ្រង់ព្រះតម្រិះថា កាលគូនៃអគ្គសាវកបរិនិព្វានហើយយ៉ាងនេះ សូម្បីតថាគតក៏នឹងបរិនិព្វានក្នុងនគរកុសិនារាដែរ ។ ស្ដេចចារិកទៅ

ដោយលំដាប់ក្នុងនគរនោះ ស្ដេចផ្ទំដោយអនុដ្ឋានសេយ្យាលើព្រះក្រឡា-បន្ទំ បែរព្រះសិរសាទៅទិសឧត្ដរ ចន្លោះដើមរាំងទាំងគូ ។ គ្រានោះព្រះអានន្ទត្ថេរក្រាបទូលអារាធនាព្រះអង្គថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គកុំបរិនិព្វានក្នុងនគរកុសិនារានេះ ដែលជានគរតូច នគរទួល ជាសាខានគរឡើយ បពិត្រព្រះអង្គដ៏ចម្រើន នគរធំៗឯទៀតក៏មាន ដូចយ៉ាងនគរចម្ប៉ា រាជគ្រឹះ សាវត្ថី សាកេត កោសម្ពី និងនគរពារាណសី សូមព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានក្នុងនគរទាំងនោះវិញ ។ ព្រះដ៏-មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកកុំពោលថា នគរនេះជានគរតូច នគរទួល ជាសាខានគរយ៉ាងនេះឡើយ ។ ម្នាលអានន្ទ កាលពីព្រេងនាយមក មានព្រះរាជាទ្រង់ព្រះនាមថាមហាសុទស្សន ជាក្សត្របានមុទ្ធាភិសេក ( ឥស្សរលើផែនដី ) មានមហាសមុទ្រទាំងបួនជាទីបំផុត ព្រះអង្គជាស្ដេចឈ្នះសង្គ្រាម ទ្រង់មានជនបទដល់នូវការមាំមួន មានកំពែងព័ទ្ធជុំវិញ ១២ យោជន៍ ជាមហានគរ ។ កាលព្រះថេរៈក្រាបទូលអារាធនា ទើបទ្រង់នាំយកមហាសុទស្សនសូត្រក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងគ្រានោះ កាលព្រះនាងសុភទ្ទាទេវីទ្រង់ទតឃើញព្រះបាទមហា-សុទស្សន ស្ដេចចុះចាកប្រាសាទសុធម្មា ទ្រង់ផ្ទំដោយអនុដ្ឋានសេយ្យាដោយបែរព្រះបិដ្ឋិមកខាងស្ដាំ លើក្រឡាព្រះបន្ទំដ៏សមគួរ ដែលសម្រេច

ដោយរតនៈ៧ប្រការ ដែលរាជបុរសចាត់ចែងទុកក្នុងព្រៃត្នោតមិនឆ្ងាយប៉ុន្មាន ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព នគរ ៨៤.០០០ មានរាជធានីកុសាវតីជាប្រមុខនេះ ជារបស់ព្រះអង្គ សូមទ្រង់ពេញព្រះទ័យក្នុងនគរទាំងនេះចុះ ។ ព្រះបាទមហាសុទស្សនត្រាស់ថា នែទេវី នាងកុំត្រាស់យ៉ាងនេះឡើយ នាងចូរដាស់តឿនយើងយ៉ាងនេះថា សូមព្រះអង្គទ្រង់កម្ចាត់ការពេញចិត្តក្នុងនគរទាំងនេះចុះ ទ្រង់កុំសម្ងំឡើយ ។

ព្រះទេវីទូលសួរថា ព្រោះហេតុអ្វី មហាបពិត្រ?

ព្រះរាជាត្រាស់ថា យើងនឹងត្រូវសោយទិវង្គតក្នុងថ្ងៃនេះ ។ ក្នុងនោះ ព្រះទេវីទ្រង់ព្រះកន្សែងជូតព្រះនេត្រ ត្រាស់ពាក្យនោះនឹងព្រះបាទមហាសុទស្សនដោយលំបាកព្រះទ័យ គិតតែពីទ្រង់ព្រះកន្សែង ពួកស្ត្រី ៨៤.០០០ នាក់ដ៏សេស ក៏នាំគ្នាសោកខ្សឹកខ្សួលដែរ សូម្បីពួកអាមាត្យជាដើម តែម្នាក់ក៏មិនអាចទប់សេចក្តីសោកបាន ម្នាក់ៗសោកខ្សឹកខ្សួលយំរៀបរាប់ ។ ព្រះបរមពោធិសត្វហាមមនុស្សទាំងអស់ថា កុំឡើយអ្នកទាំងឡាយ កុំបញ្ចេញសំឡេងខ្សឹកខ្សួលឡើយ ព្រោះសង្ខារដែលឈ្មោះថា **ទៀង** សូម្បីប៉ុនគ្រាប់ល្ងក៏មិនមានឡើយ សង្ខារទាំងអស់សុទ្ធតែមិនទៀង មានការបែកធ្លាយជាធម្មតា កាលនឹងទូន្មានព្រះទេវី បានត្រាស់គាថានេះថា

**អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ**

**ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោតិ ។**

*សង្ខារទាំងឡាយមិនទៀងទេ មានការកើតឡើងនឹងសូន្យ*

*ទៅជាធម្មតា ( ព្រោះ ) កើតឡើងហើយតែងរលត់ទៅវិញ*

*ការរម្ងាប់សង្ខារទាំងនោះបាន ទើបនាំមកនូវសេចក្ដីសុខ ។*

បណ្ដាបទទាំងនោះ បទថា **អនិច្ចា វត សង្ខារា** សេចក្ដីថា នែនាងសុភទ្ទាទេវីដ៏ចម្រើន សង្ខារទាំងឡាយមាន **ខន្ធ អាយតនៈ**ជាដើម ដែលបច្ច័យមានប្រមាណប៉ុណ្ណោ មកប្រជុំតាក់តែងហើយ សង្ខារទាំងអស់នោះ មិនទៀងមែនពិត ព្រោះបណ្ដាសង្ខារទាំងនេះ រូបមិនទៀង វេទនាមិនទៀង សញ្ញាមិនទៀង សង្ខារទាំងឡាយមិនទៀង វិញ្ញាណមិនទៀង ចក្ខុមិនទៀង សោតមិនទៀង ឃានមិនទៀង ជិវ្ហាមិនទៀង កាយមិនទៀង ធម៌ទាំងឡាយមិនទៀង រួមសេចក្ដីថា វត្ថុដែលញ៉ាំងសេចក្ដីត្រេកអរឲ្យកើត ទាំងដែលមានវិញ្ញាណនិងមិនមានវិញ្ញាណឯណា វត្ថុទាំងអស់នោះមិនទៀងមែនពិត ដោយហេតុនេះ ចូរកំណត់ដឹងថា សង្ខារទាំងឡាយមិនទៀងហ្ន៎ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះជាឧប្បាទវយធម៌ (ធម៌ដែលកើតឡើងហើយរលត់ទៅ ) គឺព្រោះសង្ខារទាំងនេះ មានការកើតឡើងជាធម្មតាផង និងមានការរលត់ទៅជាធម្មតាផង សុទ្ធតែមានការកើតឡើងហើយរលត់ទៅជាសភាវៈ

*ទាំងអស់ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា ជារបស់មិនទៀង ព្រោះមិនទៀង ទើបកើតហើយក៏រលត់ទៅ គឺសូម្បីកើតហើយដល់នូវការតាំងនៅបាន ក៏ត្រូវរលត់ទាំងអស់ ពិតណាស់ សង្ខារទាំងនេះកំពុងកើត ឈ្មោះថា រមែងកើត កំពុងបែកធ្លាយឈ្មោះថា រមែងបែកធ្លាយ កាលកើតនៃសង្ខារទាំងនោះមាន ទើបមានឋិតិ កាលឋិតិមាន ភង្គៈក៏មាន ព្រោះកាលសង្ខារមិនកើតឡើង ឋិតិក៏មិនមាន ឋិតិខណៈមិនប្រាកដហើយការមិនបែកធ្លាយក៏មិនមាន ព្រោះហេតុដូច្នោះ សង្ខារទាំងអស់ដល់ខណៈទាំង ៣ ហើយក៏រមែងរលត់ទៅក្នុងខណៈនោះៗឯង ព្រោះហេតុនោះសង្ខារទាំងអស់នេះ ជារបស់មិនទៀង ប្រព្រឹត្តទៅជាខណៈៗ ជារបស់ប្រែប្រួល ផ្លាស់ប្តូរមិនឋិតថេរ ពុកផុយ ញាប់ញ័រ តាំងនៅមិនបានយឺនយូរ គ្មានខ្លឹមសារ ដូចថ្ងៃបណ្តើរកូន និងដូចពពុះទឹក ដោយអត្ថថា ជារបស់ប្រព្រឹត្តទៅមួយជួរខណៈ ។ នៃនាងសុភទ្ទាទេវីដ៏ចម្រើន ព្រោះហេតុអ្វីទើបនាងញុាំងសុខសញ្ញា ( ការសម្គាល់ថាជាសុខ ) ឲ្យកើតឡើងក្នុងសង្ខារទាំងឡាយនោះ កុំកាន់យកយ៉ាងនោះឡើយ ។*

*បទថា* **តេសំ វូបសមោ សុខោ** *សេចក្តីថា នៃនាងសុភទ្ទាទេវីដ៏ចម្រើន សភាវៈដែលឈ្មោះថា រម្ងាប់នូវសង្ខារទាំងនោះ ព្រោះរលត់បាននូវវដ្តទាំងមូល បានដល់ព្រះនិព្វាន ហើយព្រះនិព្វាននេះតែម្យ៉ាងប៉ុណ្ណោះ ទើបជាសុខ របស់ដទៃៗ មិនជាសុខឡើយ ។*

*ព្រះបាទមហាសុទស្សន ទ្រង់កាន់យកកំពូលនៃទេសនាដោយអមតមហានិព្វានដោយប្រការដូច្នេះហើយ ទ្រង់ប្រទានឱវាទដល់មហាជនដ៏សេសទៀតថា អ្នកទាំងឡាយចូរឲ្យទាន ចូររក្សាសីល ចូរធ្វើឧបោសថ-កម្ម ដូច្នេះហើយ បានជាអ្នកមានទេវលោកជាទីទៅខាងមុខ ។*

*ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា សុភទ្ទាទេវីក្នុងកាលនោះ បានមកជារាហុលមាតា បរិនាយកកែវគឺបុត្រច្បងរបស់ស្តេចចក្រ បានមកជារាហុល ចំណែកព្រះបាទមហា-សុទស្សន គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា មហាសុទស្សនជាតក ទី ៥ ។

# អដ្ឋកថា តេលបត្តជាតក ទី ៦

*ព្រះបរមសាស្តា កាលទ្រង់គង់អាស្រ័យនៅនានិគមឈ្មោះសេតកៈក្នុងសុមភរដ្ឋ ទ្រង់គង់នៅក្នុងដងព្រៃមួយ ទ្រង់ប្រារព្ធជនបទកល្យាណីសូត្រ ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្តើមថា* **សមតិត្តិកំ អនវសេកំ** *ដូច្នេះជាដើម ។*

*ពិតណាស់ ក្នុងកាលនោះព្រះដ៏មានព្រះភាគត្រាស់* **ជនបទ-កល្យាណីសូត្រ** *ព្រមដោយអត្ថ មួយអន្ទើដោយព្យញ្ជនៈ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ឧបមាថា បានឮថា ស្ត្រីលំអក្នុងជនបទ ស្ត្រីលំអក្នុង*

ជនបទដូច្នេះ ពួកមហាជនគប្បីប្រជុំគ្នា លុះបានឮទៀតថា ស្ត្រីលំអជនបទនោះ ជាអ្នកស្ទាត់ជំនាញយ៉ាងកំពូលក្នុងការរាំ ក្នុងការច្រៀង ជនបទកល្យាណីនោះនឹងរាំ នឹងច្រៀង ពួកមហាជននឹងប្រជុំគ្នាយ៉ាងណែនតាន់តាប់ ពេលនោះ បុរសអ្នកតម្រង់អាជីពស្វែងរកការសប្បាយ ស្អប់ខ្ពើមទុក្ខក៏នឹងមក ព្រះរាជានឹងបញ្ជាពួកគេយ៉ាងនេះថា នែបុរសដ៏ចម្រើន ថាសប្រេងដែលពេញប្រៀបយ៉ាងនេះ អ្នកចូរនាំទៅក្នុងរវាងមហាជន និងនាងជនបទកល្យាណី ហើយនឹងមានមនុស្សផ្គាជាវដើរតាមក្រោយខ្នងអ្នក បើអ្នកធ្វើប្រេងនោះឲ្យកំពប់សូម្បីតែបន្តិច នៅទីណា យើងនឹងបញ្ជាឲ្យគេកាត់ក្បាលអ្នកនៅទីនោះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនឹងសម្គាល់សេចក្តីនោះដូចម្តេច ? តើបុរសនោះមិនយកចិត្តទុកដាក់នឹងថាសប្រេងនោះ ហើយរវល់តែប្រមាទក្នុងអារម្មណ៍ខាងក្រៅឬ ?

ភិក្ខុទាំងឡាយក្រាបទូលថា សេចក្តីនោះ មិនជាយ៉ាងនោះឡើយ ព្រះអង្គ ។

ទ្រង់ត្រាស់បន្តទៀតថា ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមានេះ តថាគតពោលដើម្បីឲ្យអ្នកទាំងឡាយដឹង ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះក្នុងរឿងនេះថា ថាសប្រេងពេញប្រៀបមាត់ ជាឈ្មោះនៃសតិដែលប្រព្រឹត្តទៅក្នុងកាយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីសិក្សាក្នុងសេចក្តីនេះថា សតិប្រព្រឹត្តទៅក្នុងកាយ នឹងជាការ

ដែលពួកយើងទាំងឡាយត្រូវធ្វើឲ្យមាន ផ្ដើមដោយល្អឲ្យបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះ ។

ក្នុងព្រះសូត្រនោះ មានសេចក្ដីអធិប្បាយសង្ខេបដូច្នេះ ដែលឈ្មោះថា ជនបទកល្យាណីនោះ បានដល់ស្ត្រីដែលស្អាតក្នុងជនបទ គឺស្ត្រីមានលំអប្រាសចាកទោសនៃសរីរៈ ៦ ប្រការ ដល់ព្រមដោយលំអ ៥ ប្រការ ព្រោះហេតុតែនាងជនបទកល្យាណីនោះ ជាស្ត្រីមិនខ្ពស់ពេក មិនទាបពេក មិនជាត់ពេក មិនស្គមពេក មិនខ្មៅពេក មិនសពេក មានពណ៌សម្បុរល្អក្រៃលែងជាងពណ៌សម្បុរមនុស្ស តែមិនដល់ពណ៌សម្បុរទេវតាដូច្នោះ ទើបនាងមានឈ្មោះថា វៀរចាកទោសនៃសរីរៈ ៦ ប្រការ និងព្រោះហេតុតែនាងប្រកបដោយលំអ ៥ ប្រការនេះ គឺលំអពណ៌សម្បុរ លំអសាច់ លំអសរសៃ លំអឆ្អឹង លំអវ័យ ដូច្នេះទើបឈ្មោះថាដល់ព្រមដោយលំអ ៥ ប្រការ ពិតណាស់ នាងបញ្ចកល្យាណីនោះ មិនចាំបាច់តាក់តែងទេ រមែងធ្វើឲ្យភ្លឺបានក្នុងទីប្រមាណ ១២ ហត្ថ ដោយពន្លឺនៃរាងកាយរបស់ខ្លួន ពណ៌សម្បុរនាងដូចផ្កាប្រយង្គុ ឬមិនដូច្នោះ ក៏ដូចមាសនេះជាការមានពណ៌សម្បុរល្អរបស់នាង ម្យ៉ាងទៀត ដៃនិងជើងរបស់នាងទាំង ៤ ព្រមទាំងបបូរមាត់ ដូចជ្រលក់ដោយល័ក្ត មានពណ៌សម្បុរដូចកែវប្រវាឡពណ៌ក្រហម និងសំពត់កម្ពលពណ៌ក្រហម នេះជាលំអសាច់របស់នាង ផ្ទាំងក្រចកទាំងម្ភៃក្នុងទីដែលមិនទាន់ផុតអំពីសាច់ មើលទៅដូចផ្អែតដោយ

ទឹកល័ក្ត ក្នុងទីដែលផុតសាច់មើលទៅដូចផ្ការនៃទឹកដោះ នេះជាលំអសរសៃរបស់នាង ធ្មេញទាំង ៣២ រាបស្មើល្អដូចកម្រងពេជ្រដែលគេធ្មៃហើយ នេះជាលំអធ្មឹងរបស់នាង ម្យ៉ាងទៀតសូម្បីនាងមានអាយុ ១២០ ឆ្នាំ ក៏មើលទៅនៅស្រស់ស្អាតដូចមានអាយុ ១៦ ឆ្នាំ ស្នាមជ្រួញ ស្នាកស្នាមក៏មិនប្រាកដ សក់ក៏មិនស្កូវ នេះជាលំអវ័យរបស់នាង ។ ក្នុងពាក្យថា " នាងជាអ្នកជំនាញយ៉ាងក្រៃលែង " មានសេចក្តីអធិប្បាយថា មានការជំនាញ គឺប៉ិនប្រសប់ ការជំនាញ ក៏គឺការប៉ិនប្រសប់នោះឯង ការជំនាញដល់កំពូល ឈ្មោះថា មានការជំនាញយ៉ាងក្រៃលែង នាងមានឈ្មោះថា បរមបាសាវិនី ព្រោះជាស្ត្រីមានការជំនាញយ៉ាងកំពូល លោកអធិប្បាយទុកថា មានខ្លួនល្វតល្វន់យ៉ាងក្រៃលែង គឺមានលំនាំដ៏ប្រសើរក្នុងការរាំនិងក្នុងការច្រៀង គឺរាំបានយ៉ាងទន់ភ្លន់ និងច្រៀងបានយ៉ាងពីរោះ ។

ពាក្យថា "គ្រានោះ បុរសគប្បីមក " នោះ មិនបានសំដៅយកបុរសមកដោយការពេញចិត្តរបស់ខ្លួន ក្នុងសេចក្តីនេះលោកអធិប្បាយថា កាលនាងជនបទកល្យាណីនោះ កំពុងរាំនៅកណ្តាលហ្វូងមហាជននោះ ហើយមានសំឡេងសាធុការថា ស្រស់ណាស់ ល្អណាស់ ទាំងសំឡេងផ្ទាត់ម្រាមដៃ ទាំងការគ្រវីសំពត់កំពុងប្រព្រឹត្តទៅយ៉ាងខ្ចរខ្ចារ ព្រះរាជាទ្រង់ជ្រាបរឿងនោះបញ្ជាឲ្យហៅអ្នកទោសម្នាក់ ចេញមកអំពីគុកស្រាយចំណងចេញ ប្រគល់ថាសប្រេងដែលមានប្រេងពេញប្រៀបមាត់ឲ្យបុរសនោះ ឲ្យ

កាន់ថាសប្រេងនោះដោយដៃទាំងពីរ ទ្រង់បញ្ជាបុរសអ្នកកាន់ដាវម្នាក់ថា ចូរនាំអ្នកទោសនេះ ទៅកាន់មហោស្រពរបស់នាងជនបទកល្យាណីចុះ ប្រសិនបើបុរសនេះប្រមាទ ធ្វើឲ្យកំពប់ប្រេងសូម្បីតែមួយតំណក់ក្នុងទីណា អ្នកចូរកាត់ក្បាលបុរសនោះក្នុងទីនោះចុះ ។ បុរសនោះងាដាវសម្មុត អ្នកទោសនោះ នាំទៅកាន់ទីនោះ ។ អ្នកទោសនោះត្រូវមរណភ័យគំរាមហើយ មិនដាក់ចិត្តចំពោះនាងជនបទកល្យាណី ដោយអំណាចនៃសេចក្តីប្រមាទឡើយ មិនដាក់ភ្នែកមើលនាងជនបទកល្យាណីនោះ សូម្បីតែម្តង ព្រោះត្រូវការរួចផុតអំពីសេចក្តីស្លាប់ រឿងនេះជារឿងដែលធ្លាប់មានមកហើយយ៉ាងនេះ ក៏រឿងនេះគប្បីជ្រាបថា ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់ហើយ ដោយអំណាចនៃការប្រៀបធៀបក្នុងព្រះសូត្រ ក្នុងបទថា **ឧបមា ខោ មយាយំ** នេះ ទ្រង់ធ្វើការឧបមាផ្តិលប្រេងនិងកាយគតាសតិជាទី-តាំង ។

ក្នុងរឿងនេះ កម្ម គប្បីឃើញដូចព្រះរាជា កិលេស ប្រៀបដូចដាវ មារ ដូចអ្នកងាដាវ ព្រះយោគាវចរអ្នកចម្រើនកាយគតាសតិ ដូចអ្នកកាន់ផ្តិលប្រេង ។

ព្រះមានដ៏ព្រះភាគទ្រង់នាំព្រះសូត្រនេះមកហើយ ទ្រង់សម្តែងថា ភិក្ខុអ្នកប្រាថ្នាចម្រើនកាយគតាសតិ មិនត្រូវបណ្តោតបណ្តោយសតិ ជាអ្នកមិនប្រមាទ ចម្រើនកាយគតាសតិ ដូចអ្នកកាន់ថាសប្រេងនោះ ដោយ

ប្រការដូច្នេះ ។ ភិក្ខុទាំងឡាយ លុះបានស្តាប់ព្រះសូត្រនេះនិងអត្ថាធិប្បាយហើយ ក៏ក្រាបទូលយ៉ាងនេះថា ការដែលបុរសនោះមិនសម្លឹងមើលនាងជនបទកល្យាណីអ្នកល្អដាច់គេ ខំប្រឹងទប់ស្មារតីកាន់ផ្តិលប្រេងដើរទៅជាការធ្វើបានដោយលំបាក ។ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ការដែលបុរសនោះធ្វើហើយ មិនមែនជាអំពើដែលធ្វើបានដោយលំបាកទេ នោះជាអំពើដែលធ្វើបានដោយងាយពិត ព្រោះហេតុអ្វី ? ព្រោះមានអ្នកងាដាវចាំសម្លុតពីក្រោយ ប៉ុន្តែអំពើដែលបណ្ឌិតទាំងឡាយធ្វើហើយក្នុងកាលមុន មិនបណ្តោតបណ្តោយសតិ មិនទម្លាយឥន្ទ្រីយ៍ មិនសម្លឹងមើលរូបសូម្បីជាទិព្វ ដើរទៅរហូតទាល់តែបានគ្រងរាជសម្បត្តិ ទើបធ្វើបានដោយកម្រ ។ កាលភិក្ខុទាំងនោះក្រាបទូលអារាធនា ទើបទ្រង់នាំយកអតីតនិទានមកត្រាស់សម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបានជាព្រះឱរសពៅនៃព្រះឱរស ១០០ អង្គរបស់ព្រះរាជាអង្គនោះ ។ ទ្រង់សម្រេចភាពជាអ្នកដឹងក្តីដោយលំដាប់ហើយក្នុងគ្រានោះ ព្រះបច្ចេកពុទ្ធច្រើនព្រះអង្គឆាន់ក្នុងព្រះរាជវាំង ព្រះ-ពោធិសត្វទ្រង់មាននាទីជាវេយ្យាវច្ចកររបស់ព្រះបច្ចេកពុទ្ធទាំងនោះ ។ ថ្ងៃមួយ ទ្រង់ព្រះតម្រិះថា បងប្រុសរបស់អញមានច្រើន អញនឹងបានរាជ-សម្បត្តិបន្តវង្សក្នុងនគរនេះដែរឬហ្ន៎ លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ទ្រង់

មានបរិវិតក្កថា ត្រូវសួរព្រះបច្ចេកពុទ្ធមើលទើបនឹងដឹងប្រាកដ ។ ក្នុងថ្ងៃទីពីរ កាលព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តមកហើយ យកជម្នក្រកមកត្រងទឹកសម្រាប់ឆាន់ លាងជើងលាបប្រេង ពេលដែលព្រះបច្ចេកពុទ្ធទាំងនោះឆាន់ភត្តហើយ ក៏ថ្វាយបង្គំហើយទ្រង់គង់ក្នុងទីដ៏សមគួរមួយ មានព្រះ-តម្រាស់សួរអំពីរឿងនោះ ។ ពេលនោះ ព្រះបច្ចេកពុទ្ធទាំងនោះបានប្រាប់ព្រះបរមពោធិសត្វថា នៃរាជកុមារ ទ្រង់នឹងមិនបានរាជសម្បត្តិក្នុងនគរនេះទេ ប៉ុន្តែអាចបានសោយរាជ្យក្នុងនគរដទៃ ដែលនៅឆ្ងាយអំពីទីនេះ ១២០ យោជន៍ ក្នុងគន្ធាររដ្ឋ ។ ទីនោះមាននគរឈ្មោះថា តក្កសិលា ទ្រង់អាចទៅកាន់នគរនោះ នឹងត្រូវបានរាជសម្បត្តិក្នុងថ្ងៃទី ៧ អំពីថ្ងៃនេះ ប៉ុន្តែក្នុងចន្លោះផ្លូវ ក្នុងព្រៃធំមួយមានអន្តរាយ កាលនឹងធ្វើដំណើរវាងព្រៃនោះ នឹងជាផ្លូវឆ្ងាយ ១២០ យោជន៍ កាលធ្វើដំណើរកាត់ត្រង់ក៏មានចម្ងាយផ្លូវតែ ៥០ យោជន៍ ផ្លូវនោះមានឈ្មោះថា អមនុស្សកន្តារ ក្នុងតំបន់នោះ ក្រុមយក្ខិនីនាំគ្នានិម្មិតផ្ទះនិងសាលាទុកតាមផ្លូវ តាក់តែងទីដេកដ៏មានតម្លៃ លើពិតានចងលម្អទៅដោយផ្កាយមាស បាំងវាំងននដែលជ្រលក់ដោយពណ៌ផ្សេងៗ តាក់តែងអត្តភាពដោយគ្រឿងអលង្ការដ៏ជាទិព្វ នាំគ្នាអង្គុយក្នុងសាលាទាំងឡាយ ទាក់ពួកបុរសដែលធ្វើដំណើរទៅមកដោយពាក្យដ៏ផ្អែមល្ហែមថា អ្នកទាំងឡាយមើលទៅដូចជាហត់នឿយខ្លាំងហើយ អញ្ជើញចូលអង្គុយក្នុងសាលានេះផឹកគ្រឿងផឹកហើយសឹម

ទៅចុះ ហើយឲ្យទីអង្គុយដល់អ្នកដែលមកដល់ នាំគ្នាលួងលោមដោយអកប្បកិរិយាប្រលោមរបស់ខ្លួន ធ្វើឲ្យធ្លាក់នៅក្នុងអំណាចកិលេសទាល់តែបាន កាលបានធ្វើអជ្ឈាចាររួមជាមួយនឹងខ្លួនហើយ ក៏ទំពាស៊ីបុរសទាំង-នោះ ក្នុងទីនោះឯង ធ្វើឲ្យដល់នូវការអស់ជីវិតទាំងដែលលោហិតនៅហូរនោះឯង ពួកយក្ខិនីរង់ចាំចាប់សត្វអ្នកមានរូបជាអារម្មណ៍ ដោយរូបនោះឯង អ្នកមានសំឡេងជាអារម្មណ៍ ដោយសំឡេងច្រៀងដ៏ពីរោះ អ្នកមានក្លិនជាអារម្មណ៍ ដោយក្លិនជាទិព្វ អ្នកមានរសជាអារម្មណ៍ ដោយភោជនដ៏មានរសផ្សេងៗ ដូចរសទិព្វ អ្នកមានផោដ្ឋព្វៈជាអារម្មណ៍ ដោយទីដេកដូចទីដេកទិព្វ ជាកម្រាលមានពណ៌ក្រហមទាំងពីរខាង ប្រសិនបើទ្រង់នឹងមិនទម្លាយឥន្ទ្រីយ៍ទាំង ៥ សម្លឹងមើលពួកវា តាំងសតិឲ្យមាំដើរទៅនឹងបានរាជសម្បត្តិក្នុងនគរនោះ ក្នុងថ្ងៃទី ៧ មិនខាន ។

ព្រះបរមពោធិសត្វត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន រឿងនេះលើកទុកសិនចុះ ខ្ញុំព្រះករុណាទទួលឱវាទរបស់លោកម្ចាស់ទាំងឡាយហើយ នឹងសម្លឹងមើលពួកវាដូចម្ដេច ដូច្នេះហើយ សូមឲ្យព្រះបច្ចេកពុទ្ធទាំងឡាយធ្វើព្រះបរិត្ត ទទួលខ្សែប្រោះព្រំដោយព្រះបរិត្តនិងអំបោះប្រោះព្រំដោយព្រះបរិត្ត ថ្វាយបង្គំលាព្រះបច្ចេកពុទ្ធ និងព្រះរាជមាតាព្រះរាជបិតាយាងទៅកាន់ព្រះរាជដំណាក់ ត្រាស់ទៅកាន់អ្នកបម្រើរបស់ព្រះអង្គថា យើងនឹងទៅគ្រប់គ្រងរាជសម្បត្តិនៅឯនគរតក្កសិលា ពួកអ្នក

ចូរនៅទីនេះចុះ ។ គ្រានោះ មនុស្សទាំង៥ នាក់ ក្រាបទូលព្រះបរមពោធិសត្វថា សូម្បីពួកទូលបង្គំក៏នឹងទៅតាមព្រះអង្គដែរ ។

ព្រះបរមពោធិសត្វត្រាស់ថា ពួកអ្នកមិនអាចតាមយើងទៅបានទេ ព្រោះបានឮថា តាមផ្លូវពួកយក្ខិនីរង់ចាំលួងលោមពួកមនុស្សមានរូបជាដើមជាអារម្មណ៍ ដោយកាមារម្មណ៍ មានរូបជាដើមច្រើនយ៉ាងដោយវិធីផ្សេងៗ ហើយចាប់ស៊ីជាអាហារ អន្តរាយមានយ៉ាងធំ យើងត្រៀមខ្លួនទុកហើយទើបទៅបាន ។

រាជបុរសពោលថា បពិត្រព្រះសម្មតិទេព កាលពួកទូលបង្គំតាមទ្រង់ទៅ នឹងសម្លឹងមើលរូបជាដើមដែលគួរស្រឡាញ់ដូចម្ដេចបាន សូម្បីពួកទូលបង្គំក៏នឹងទៅក្នុងទីនោះបានដែរ ។

ព្រះបរមពោធិសត្វត្រាស់ថា បើដូច្នោះ អ្នកទាំងឡាយ ចូរជាអ្នកមិនប្រមាទចុះ ហើយនាំអ្នកទាំង ៥ នាក់នោះទៅ ។

ពួកយក្ខិនីនាំគ្នានិម្មិតផ្ទះជាដើម អង្គុយរង់ចាំហើយជាស្រេច បណ្ដាអ្នកទាំងនោះ អ្នកដែលពេញចិត្តរូប សម្លឹងមើលយក្ខិនីនោះហើយ មានចិត្តប្រតិព័ទ្ធ ជាប់ជំពាក់នឹងរូបារម្មណ៍ រាងថយកម្លាំងបន្តិច ។ ព្រះបរមពោធិសត្វក៏ត្រាស់ថា នែអ្នកដ៏ចម្រើន ហេតុដូចម្ដេចទើបដំណើររបស់អ្នកទាំងឡាយខ្សោយម្ល៉េះ ?

រាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព ជើងរបស់ទូលបង្គំ

ឈើ សូមអង្គុយសម្រាកក្នុងសាលានេះបន្តិចសិន ហើយនឹងតាមព្រះអង្គទៀត ។

ព្រះបរមពោធិសត្វត្រាស់ថា នុ៎ះជាយក្ខិនី អ្នកទាំងឡាយកុំប្រាថ្នាឡើយ ។

រាជបុរសក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទោះជាយ៉ាងណាក៏ដោយចុះ ទូលបង្គំទ្រាំមិនបានទេ ។

ព្រះបរមពោធិសត្វត្រាស់ថា បើដូច្នោះ អ្នកនឹងដឹងខ្លួនឯងចុះ ទ្រង់នាំបុរស ៤ នាក់ យាងតទៅទៀត អ្នកដែលពេញចិត្តមើលរូប បានទៅកាន់សម្នាក់យក្ខិនី កាលបានធ្វើអជ្ឈាចារជាមួយនឹងខ្លួនហើយ ពួកយក្ខិនីក៏ធ្វើឲ្យបុរសនោះអស់ជីវិតក្នុងទីនោះឯង ។ ហើយទៅស្នាក់អំពីខាងមុខនិម្មិតសាលាមួយផ្សេង អង្គុយកាន់គ្រឿងតន្ត្រីទាំងឡាយ ច្រៀងយ៉ាងពីរោះ បណ្ដាអ្នកទាំងនោះ អ្នកដែលពេញចិត្តនឹងសំឡេងក៏ខ្សោយកម្លាំង យក្ខិនីក៏នាំគ្នាស៊ីបុរសនោះ ។ ហើយនាំគ្នាទៅស្នាក់អំពីខាងមុខ ចាត់ចែងកុណ្ឌីទឹកដែលបរិបូណ៌ដោយក្លិនក្រអូបផ្សេងៗ ក្រាលនូវសំពត់ហើយអង្គុយចាំនៅទីនោះ បុរសដែលពេញចិត្តនឹងក្លិនក៏ក្រាញនៅដោយការធុំក្លិនក្នុងទីនោះ យក្ខិនីក៏នាំគ្នាទំពាស៊ីបុរសនោះ តាមន័យមុននោះឯង ។ ហើយនាំគ្នាទៅស្នាក់អំពីខាងមុខ ចាត់ចែងភោជនដែលមានរសដូចជាទិព្វដាក់ពេញភាជនៈ អង្គុយបើកពានលក់ម្ហូបសម្ងនៅទីនោះ អ្នកដែលពេញ

ចិត្តក្នុងរសក៏ខ្សោយកម្លាំង ពួកវាក៏នាំគ្នាទំពាស៊ីបុរសនោះ ។ ហើយទៅស្ទាក់អំពីខាងមុខចាត់ចែងទីដេកដូចជាទិព្វ អង្គុយរង់ចាំនៅទីនោះ អ្នកដែលពេញចិត្តនឹងផោដ្ឋព្វៈក៏ខ្សោយកម្លាំង ពួកវាក៏នាំគ្នាទំពាស៊ីបុរសនោះទៀត ។ ទីបំផុតសល់តែព្រះមហាសត្វមួយព្រះអង្គប៉ុណ្ណោះ ។ គ្រានោះយក្ខិនីមួយគិតថា បុរសនេះមានមន្តខ្លាំងណាស់ អញនឹងស៊ីបុរសនេះឲ្យទាល់តែបាន ហើយដើរតាមក្រោយព្រះមហាបុរសជានិច្ច ដល់មាត់ព្រៃត្រើយខាងនាយ អ្នកដែលធ្វើការក្នុងព្រៃជាដើម ក៏សួរយក្ខិនីនោះថា

បុរសដែលដើរខាងមុខនាងនេះ ត្រូវជាអ្វីនឹងនាង ?

យក្ខិនីឆ្លើយថា ជាស្វាមីរបស់ខ្ញុំ ។

អ្នកទាំងនោះក៏ពោលថា នែបាដ៏ចម្រើន កុមារិកានេះខ្សោយកម្លាំងយ៉ាងនេះ អ្នកគួរតែថ្នមនាងដូចកម្រងផ្កា ពណ៌សម្បុរក៏ល្អដូចមាស បោះបង់ត្រកូលរបស់ខ្លួនចេញមក ព្រោះស្រឡាញ់អ្នកទើបព្រមតាមអ្នកមក នែបាដ៏ចម្រើន ហេតុដូចម្តេចទើបបណ្តោយឲ្យនាងលំបាកមិនដឹកដៃនាងទៅ ?

ព្រះមហាសត្វត្រាស់ថា នែអ្នកដ៏ចម្រើនទាំងឡាយ នាងនោះមិនមែនជាភរិយារបស់ខ្ញុំទេ នាងជាយក្ខិនី មនុស្សរបស់ខ្ញុំ ៥ នាក់ ត្រូវនាងស៊ីអស់ហើយ ។

យក្ខិនីពោលថា នែអ្នកដ៏ចម្រើនទាំងឡាយ ធម្មតាបុរសនៅពេល

ក្រោធខឹងតែងតែជាកិរិយារបស់ខ្លួនជាយក្ខិនី ឬក៏ជាកិរិយារបស់ខ្លួនជាប្រេត ។ យក្ខិនីដើរតាមព្រះពោធិសត្វ ក្លែងភេទជាស្ត្រីមានគភ៌ ហើយធ្វើឲ្យជាស្ត្រីប្រសូតហើយម្តង ពកូននឹងចង្កេះដើរតាមព្រះបរមពោធិសត្វ អ្នកដែលឃើញហើយក៏នាំគ្នាសួរដូចមុន ។ សូម្បីព្រះមហាសត្វក៏ត្រាស់យ៉ាងនោះជានិច្ច រហូតដល់នគរតក្កសិលាយក្ខិនីក៏ធ្វើឲ្យបាត់កូនហើយដើរតាមព្រះមហាសត្វតែម្នាក់ឯង ។ ព្រះមហាបុរសយាងដល់នគរហើយទ្រង់គង់នៅក្នុងសាលាមួយខ្នង ចំណែកយក្ខិនីនោះ មិនអាចចូលទៅបានដោយតេជះរបស់ព្រះមហាបុរស ក៏និម្មិតខ្លួនជាស្រីរបាំឈរនៅក្បែរមាត់ទ្វារសាលា ។

សម័យនោះ ព្រះរាជាកំពុងយាងចេញអំពីនគរតក្កសិលាទៅកាន់ព្រះរាជឧទ្យាន (ឃើញយក្ខិនីនោះ) ទ្រង់មានចិត្តប្រតិព័ទ្ធ ត្រាស់ប្រើរាជ-បុរសថា ទៅសួរនាងម្នាក់នោះ តើនាងមានស្វាមីហើយឬនៅ ? ពួករាជបុរសចូលទៅរកយក្ខិនី រួចសួរថា នាងមានស្វាមីហើយឬ ?

យក្ខិនីឆ្លើយថា នែអ្នកដ៏ចម្រើន អ្នកដែលអង្គុយលើសាលានេះ ជាស្វាមីរបស់ខ្ញុំ ។

ព្រះបរមពោធិសត្វត្រាស់ថា នាងមិនមែនជាកិរិយារបស់ខ្ញុំទេ នាងជាយក្ខិនី មនុស្សរបស់ខ្ញុំ ៥ នាក់ត្រូវនាងស៊ីអស់ហើយ ។ ចំណែកយក្ខិនីក៏ពោលថា នែអ្នកដ៏ចម្រើនទាំងឡាយ ធម្មតាបុរសដែលឋិតនៅក្នុងការ

ក្រោធ ក៏នឹងនិយាយតាមតែចិត្តដែលខ្លួនប្រាថ្នា ។ រាជបុរសនោះក៏ក្រាប ទូលពាក្យរបស់អ្នកទាំងពីរនាក់នោះ ចំពោះព្រះរាជា ។ ព្រះរាជាត្រាស់ថា ធម្មតាភណ្ឌដែលមិនមានម្ចាស់ តែងតែធ្លាក់ទៅជារបស់ស្តេច ហើយត្រាស់ហៅយក្ខិនីមក ឲ្យអង្គុយលើ-កដំរីរួមនឹងព្រះអង្គ ទ្រង់ប្រទក្សិណនគរ ហើយស្តេចឡើងកាន់ប្រាសាទ ទ្រង់ស្ថាបនាយក្ខិនីទុកក្នុងតំណែងអគ្គ-មហេសី ។ ព្រះរាជាទ្រង់ស្រង់ព្រះកាយរួចរាល់ហើយ សោយព្រះ-ក្រយាហារក្នុងវេលាល្ងាចហើយ ស្តេចឡើងកាន់ព្រះក្រឡាបន្ទំដ៏មានសិរី ។ យក្ខិនីនោះស៊ីអាហារដែលគួរដល់ខ្លួនហើយ ប្រដាប់តាក់តែងខ្លួនដេករួមជាមួយព្រះរាជាលើក្រឡាបន្ទំដ៏មានសិរី ពេលដែលព្រះរាជាបរិបូណ៌ទៅដោយសេចក្តីសុខ ដោយអំណាចសេចក្តីត្រេកអរ ទ្រង់ផ្ទំហើយ ក៏បម្រះទៅម្ខាងធ្វើដូចជាយំ ។ លុះព្រះរាជាត្រាស់សួរថា នែនាងដ៏ចម្រើន ហេតុអ្វី ទើបនាងយំ ?

យក្ខិនីក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់ជាស្ត្រីដែលទ្រង់ជួបតាមផ្លូវហើយនាំមក ម្យ៉ាងទៀត ក្នុងព្រះរាជវាំងរបស់ទ្រង់ក៏មានស្ត្រីជាច្រើន ខ្ញុំម្ចាស់កាលនៅក្នុងក្រុមស្ត្រីដែលរួមបម្រើព្រះបាទ កាលមានអ្នកនិយាយឡើងថា អ្នកណាស្គាល់មាតាបិតា គោត្ត ឬជាតិរបស់នាង នាងជាអ្នកដែលព្រះរាជាជួបតាមផ្លូវហើយទ្រង់នាំមក ដូច្នេះ ដូចត្រូវគេចាប់ក្បាលច្របាច់ ត្រូវខ្មាសអៀនជាពិតប្រាកដ ប្រសិនបើទ្រង់ព្រះរាជ-

ទានភាពជាធំនិងការគ្រប់គ្រងដែនទាំងអស់ដល់ខ្ញុំម្ចាស់ បុគ្គលណាមួយក៏មិនអាចកម្រើកចិត្តពោលអំពីខ្ញុំម្ចាស់ឡើយ ។

ព្រះរាជាទ្រង់ត្រាស់ថា នែនាងដ៏ចម្រើន អ្នកដែនទាំងអស់មិនបានជាសម្បត្តិចំណែកខ្លះរបស់ខ្ញុំ ខ្ញុំមិនបានជាម្ចាស់នៃអ្នកដែនទាំងអស់នោះទេ ប៉ុន្តែជនពួកណាល្មើសព្រះរាជអាជ្ញា ធ្វើអំពើដែលមិនគួរធ្វើ យើងជាម្ចាស់នៃជនទាំងនោះប៉ុណ្ណោះ ហេតុនេះទើបយើងមិនអាចឲ្យភាពជាធំនិងការគ្រប់គ្រងដែនទាំងអស់ដល់នាងបាន ។

យក្ខិនីក្រាបទូលថា បពិត្រព្រះសម្មតិទេព ប្រសិនបើព្រះអង្គមិនអាចនឹងព្រះរាជទានការគ្រប់គ្រងក្នុងដែន ឬក្នុងនគរ ក៏សូមទ្រង់មេត្តាព្រះរាជទានអំណាចលើពួកអ្នកបម្រើខាងក្នុងព្រះរាជវាំង ដើម្បីឲ្យប្រព្រឹត្តទៅក្នុងអំណាចនៃខ្ញុំម្ចាស់ ។

ព្រះរាជាទ្រង់ជាប់ព្រះទ័យនឹងផោដ្ឋព្វៈដូចជាទិព្វ មិនអាចប្រកែកនឹងពាក្យរបស់នាងបានទើបត្រាស់ថា នែនាងដ៏ចម្រើន យើងនឹងប្រគល់អំណាចលើពួកអ្នកបម្រើខាងក្នុងដល់នាង នាងចូរគ្រប់គ្រងអ្នកបម្រើទាំងនោះ ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់នាងចុះ ។

យក្ខិនីទទួលព្រះតម្រាស់ថា ប្រពៃហើយព្រះអង្គ ។ លុះព្រះរាជាផ្ទំលង់លក់ហើយក៏ទៅកាន់ក្រុងយក្ស បបួលពួកយក្សមក ញុំាងព្រះរាជារបស់ខ្លួនឲ្យដល់នូវការអស់ព្រះជន្ម ទំពាស៊ីស្បែក សាច់ និងឈាមរហូត

ទាល់តែអស់បន្សល់ទុកតែឆ្អឹង ពួកយក្សដ៏សេសក៏នាំគ្នាស៊ីមនុស្សនិងសត្វ តាំងតែពីមាន់និងសុនខ ខាងក្នុងវាំងតាំងពីទ្វារធំរហូតទាល់តែអស់ បន្សល់ទុកតែឆ្អឹង ។ លុះព្រឹកឡើង មនុស្សទាំងឡាយឃើញទ្វារវាំងនៅបិទដូចដើម ក៏នាំគ្នាកាប់ទ្វារដោយពូថៅ ហើយបបួលគ្នាចូលទៅខាងក្នុង ឃើញព្រះរាជវាំងគ្រប់កន្លែងដេរដាសទៅដោយឆ្អឹង ទើបនិយាយគ្នាថា ពាក្យដែលបុរសនោះនិយាយថា នាងនេះមិនមែនជាភរិយារបស់យើងទេ នាងជាយក្ខិនី ប៉ុន្តែព្រះរាជាទ្រង់មិនជ្រាបអ្វីទាំងអស់ ទ្រង់នាំវាមកតែងតាំងឲ្យទៅជាមហេសីរបស់ព្រះអង្គ លុះដល់ពេលយប់វាក៏បបួលពួកយក្សមកស៊ីមនុស្សអស់ជាពិតប្រាកដ ។

ក្នុងថ្ងៃនោះ ព្រះមហាបុរសក៏ទ្រង់ដាក់ខ្សាច់ដែលប្រោះព្រំដោយព្រះបរិត្តលើសីសៈ និងរុំអំបោះព្រះបរិត្ត ទ្រង់កាន់ព្រះខ័នប្រថាប់ឈរនៅក្នុងសាលានោះ រហូតទាល់តែភ្លឺ ។ មនុស្សទាំងឡាយនាំគ្នាសម្អាតព្រះរាជ-និវេសន៍ហើយ លាបពណ៌លឿង ប្រោះព្រំខាងលើដោយគ្រឿងក្រអូបរោយដោយផ្កា ព្យួរកម្រងផ្កាអប់ដោយផ្សែងក្រអូប ចងកម្រងផ្កាថ្មីៗហើយប្រឹក្សាគ្នាថា កាលពីម្សិលមិញ បុរសនោះមិនបានធ្វើ សូម្បីតែការទម្លាយឥន្ទ្រិយ៍ ហើយសម្លឹងមើលយក្ខិនីដែលជំណែងខ្លួនដូចជារូបទិព្វ ដើរមកខាងក្រោយឡើយ គេជាសត្វប្រសើរបំផុត ជាសត្វសម្បូរដោយញាណកាលបុរសដូច្នោះគ្រប់គ្រងដែន រដ្ឋសីមានឹងមានតែសុខសន្តិភាព ពួក

យើងចូរតែងតាំងបុរសនោះជាព្រះរាជាចុះ ។ គ្រានោះ ពួកអាមាត្យនិងអ្នកក្រុងគ្រប់គ្នា រួមគ្នាជាឯកច្ឆន្ទ ចូលទៅគាល់ព្រះមហាសត្វ ក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់គ្រប់គ្រងរាជ្យចុះ យាងព្រះមហាសត្វឲ្យចូលកាន់នគរហើយឲ្យឡើងគង់លើគំនររតនៈ អភិសេកឲ្យទៅជាព្រះរាជានៃតក្កសិលានគរ ។ ព្រះរាជាទ្រង់វៀរចាកអគតិ ៤ មិនឲ្យរាជធម៌ ១០ ប្រការកម្រើក គ្រប់គ្រងរាជសម្បត្តិដោយធម៌ ទ្រង់បំពេញបុណ្យមានឲ្យទានជាដើម លុះអស់ព្រះជន្មហើយ ស្តេចក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្តា ទ្រង់នាំយករឿងក្នុងអតីតមកសម្តែងហើយ លុះត្រាស់ដឹងព្រះសម្មាសម្ពោធិញាណហើយ ទ្រង់ត្រាស់ព្រះគាថានេះថា

**សមតិត្តិកំ អនវសេកំ**
**តេលបត្តំ យថា បរិហរេយ្យ**
**ឯវំ សចិត្តមនុរក្ខេ (សតិយា)**
**បត្ថយានោ ទិសំ អគតបុព្វន្តិ ។**

បុគ្គល គប្បីនាំទៅនូវភាជន៍ប្រេង ដែលពេញត្រឹមកណ្តាប់មាត់ មិនឲ្យស្រក់ទៅបាន យ៉ាងណាមិញ (ព្រះយោគាវចរ) កាលប្រាថ្នានូវទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វាន គប្បីរក្សានូវចិត្តរបស់ខ្លួន (ដោយសតិ) យ៉ាងនោះដែរ ។

*បណ្ដាបទទាំងនោះ បទថា* **សមតិត្តិកំ** *សេចក្ដីថា ពេញស្មើមាត់ គឺដល់កណ្ដាប់ដែលវង់ភាជន៍ខាងក្នុង ។*

*បទថា* **អនវសេកំ** *សេចក្ដីថា ធ្វើឲ្យដាក់មិនបានទៀត គឺស្រក់ចុះទៅមិនបានទៀត ។*

*បទថា* **តេលបត្តំ** *បានដល់ ភាជន៍ដែលគេដាក់ប្រេងល្ង ។*

*បទថា* **បរិហរេយ្យ** *សេចក្ដី គប្បីផ្គង គឺកាន់យកទៅ ។*

*បទថា* **ឯវំ សចិត្តមនុរក្ខេ** *សេចក្ដីថា ព្រះយោគាវចរដែលជាបណ្ឌិត គប្បីផ្គងចិត្តរបស់ខ្លួនឲ្យដូចជាគេរក្សាភាជន៍ ដែលពេញទៅដោយប្រេង ក្នុងចន្លោះនៃធម៌ទាំងពីរគឺ អារម្មណ៍និងសតិដែលប្រកបទុកដោយល្អ ហើយគប្បីរក្សាគឺ ឃុំគ្រងដោយកាយគតាសតិ ដោយធ្វើមិនឲ្យចិត្តត្រាច់ទៅរកអារម្មណ៍ខាងក្រៅ សូម្បីតែមួយស្របក់ ។*

*សួរថា ព្រោះហេតុអ្វី ?*

*ឆ្លើយថា ព្រោះការទូន្មានចិត្ត ដែលសង្កត់សង្កិន បានដោយលំបាក ជាធម្មជាតិរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណញាំងប្រយោជន៍ឲ្យសម្រេច (ព្រោះថា ) ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។*

*ព្រោះហេតុនោះ អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញបានដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដី*

ប្រាថ្នា ក្នុងអារម្មណ៍ណាមួយ ( ព្រោះថា ) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

ដ្បិតថា អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហាគឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។

ចំណែកអ្នកក្រៅពីនេះ គឺអ្នកដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្ដីជ្រះថ្លាអណ្ដែតទៅ រមែងមិនបរិបូណ៌ដោយបញ្ញា ។

ចំណែកអ្នកដែលជិតដិតនឹងព្រះកម្មដ្ឋានមកយូរ ភ័យរមែងមិនមានដល់បុគ្គលអ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសៈខ្ទាំងខ្ទប់មិនបាន មានបុណ្យនឹងបាបលះចោលហើយ ភ្ញាក់រឭកជានិច្ច ។

ព្រោះហេតុនោះ អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោងរក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បានដូចអ្នកធ្វើព្រួញ ពត់ព្រួញឲ្យត្រង់ដូច្នោះ ។

កាលព្រះយោគាវចរធ្វើចិត្តឲ្យត្រង់យ៉ាងនេះ ឈ្មោះថាតាមរក្សាចិត្តរបស់ខ្លួន ។

បទថា **បត្ថយានោ ទិសំ អគតបុព្វំ** សេចក្ដីថា ព្រះយោគាវចរកាលប្រាថ្នាបរិកម្មក្នុងកាយគតាសតិកម្មដ្ឋាននេះហើយ ប្រាថ្នាទិសដែល

មិនទាន់បានទៅ ក្នុងសង្សារវដ្តដែលមិនមានទីបំផុតខាងដើមនិងខាងចុង គប្បីរក្សាចិត្តរបស់ខ្លួនដោយន័យដូចពោលមកហើយ ។

ត្រង់ពាក្យថា ទិស នេះ គឺជាអ្វីទៅ?

ដំបូង បុត្រនិងភរិយាជាដើម លោកពោលថាជា ទិស ដូចក្នុងគាថានេះថា

មាតាបិតា ជាទិសខាងកើត អាចារ្យជាទិសខាងត្បូង បុត្រ
ភរិយា ជាទិសខាងលិច មិត្តនិងអាមាត្យជាទិសខាងជើង
ទាសៈ និងកម្មករទាំងឡាយ ជាទិសខាងក្រោម សមណៈ
និងព្រាហ្មណ៍ ជាទិសខាងលើ ជនក្នុងត្រកូលមិនគប្បី
ប្រមាទ គប្បីនមស្ការទិសទាំងអស់នេះ ។

នៅមានទិសផ្សេងៗ ចែកចេញជាប្រភេទដូចជាទិសបូព៌ជាដើម លោកក៏ហៅថា ទិស ដូចក្នុងគាថានេះថា

បណ្ដាទិសទាំង ១០ នេះ គឺ ទិសធំ ៤ ទិសតូច ៤ ទិស
ខាងលើ ១ ទិសខាងក្រោម ១ តើព្រះរាជបុត្រីទ្រង់ព្រះ-
សុបិនឃើញដំរីដ៏ប្រសើរ ដែលមានភ្លុក មានពណ៌ ៦
ឋិតនៅក្នុងទិសណា ។

ព្រះនិព្វានក៏ហៅថា ទិស ដូចក្នុងគាថានេះថា

ពួកជនជាគ្រហស្ថ ជាអ្នកឲ្យបាយ ទឹក និងសំពត់ ជាអ្នក

*ហៅរក ( នូវអ្នកទទួលទាន ) ណា អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ពោលនូវបុគ្គលនោះថា ជាទិស ( ខាងលើ ) ម្នាលសេតកេតុ បុគ្គលមានទុក្ខ ត្រឡប់ជាបានសេចក្តីសុខវិញ ព្រោះដល់នូវទិស ( និព្វាន ) ណា ទិសនុ៎ះ ជាទិសដ៏ប្រសើរ ។*

*សូម្បីក្នុងបាទគាថានេះថា ទិសដែលមិនធ្លាប់ទៅ ក៏ប្រាជ្ញាយកទិស គឺព្រះនិព្វាននោះឯង ព្រោះថា ព្រះនិព្វាននោះរមែងប្រាកដដោយលក្ខណៈជាដើមថា ការអស់ទៅ ការមិនមានសេចក្តីត្រេកអរ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ទិស ។ ចំណែកដែលទ្រង់ត្រាស់ថា ឈ្មោះថាទិសដែលមិនធ្លាប់ទៅ ព្រោះពាលបុថុជ្ជនណាមួយក្នុងសង្សារវដ្ត មិនធ្លាប់ទៅសូម្បីតែការយល់សប្តិ ។ ព្រះយោគាវចរអ្នកប្រាជ្ញាទិសនោះ គប្បីធ្វើសេចក្តីព្យាយាម ចម្រើនកាយគតាសតិ ។*

*ព្រះបរមសាស្តា ទ្រង់កាន់យកកំពូលនៃទេសនាដោយព្រះនិព្វានដោយប្រការដូច្នេះ ហើយទ្រង់ប្រជុំជាតកថា រាជបរិស័ទក្នុងកាលនោះបានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកព្រះរាជកុមារអ្នកគ្រងរាជសម្បត្តិក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា តេលបត្តជាតក ទី ៦ ។

# អដ្ឋកថា នាមសិទ្ធិជាតក ទី ៧

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកចង់បានឈ្មោះល្អមួយរូប ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្ដើមថា* **ជីវកាញ្ច មតំ ទិស្វា** *ដូច្នេះជាដើម ។*

*បានឮថា កុលបុត្រមួយរូបមានឈ្មោះថា បាបកៈ បួសឧទ្ទិសជីវិតចំពោះព្រះសាសនា កាលត្រូវពួកភិក្ខុហៅថា អាវុសោបាបកៈ មកនេះ អាវុសោបាបកៈ ឈប់សិន ក៏គិតថា ក្នុងលោកនេះ អ្នកដែលមានឈ្មោះថា បាបកៈ គេសម្គាល់ថា លាមក ជាមនុស្សកាឡកណ្ណី អញត្រូវឲ្យឧបជ្ឈាយ៍និងអាចារ្យរកឈ្មោះដែលប្រកបដោយមង្គលយ៉ាងដទៃឲ្យអញ លុះគិតដូច្នោះហើយ ក៏ចូលទៅរកអាចារ្យនិងឧបជ្ឈាយ៍ហើយប្រាប់ថា បពិត្រលោកអាចារ្យ ឈ្មោះរបស់ខ្ញុំជាអពមង្គល សូមលោកដាក់ឈ្មោះដទៃឲ្យខ្ញុំចុះ ។ គ្រានោះ អាចារ្យនិងឧបជ្ឈាយ៍ពោលនឹងលោកយ៉ាងនេះថា ឈ្មោះត្រឹមតែជាបញ្ញត្តិសម្រាប់ហៅប៉ុណ្ណោះ ដែលឈ្មោះថានាំឲ្យសម្រេចប្រយោជន៍អ្វីៗ មិនមានព្រោះឈ្មោះឡើយ អ្នកចូរពេញចិត្តនឹងឈ្មោះរបស់អ្នកនោះចុះ ។ លោកនៅតែអង្វររឿយៗ ការដែលភិក្ខុនោះចង់បានឈ្មោះល្អនេះ បានឮដល់ភិក្ខុសង្ឃ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងធម្មសភា លើករឿងឡើងសន្ទនាគ្នាថា អ្នកមានអាយុទាំងឡាយ បានឮថា ភិក្ខុឈ្មោះឯណោះប្រាថ្នាការសម្រេចដោយឈ្មោះ*

សូមឲ្យអាចារ្យជួយរកឈ្មោះដែលជាមង្គលឲ្យ ។ ព្រះបរមសាស្តា ស្តេចយាងមកកាន់ធម្មសភា ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់-មិញនេះ អ្នកទាំងឡាយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនេះក៏ប្រាថ្នាការសម្រេចដោយឈ្មោះដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះមហាសត្វសោយព្រះជាតិជាអាចារ្យទិសាបា-មោក្ខ បង្រៀនមន្តដល់មាណព ៥០០ នាក់ ក្នុងនគរតក្កសិលា ។ មាណពម្នាក់ដែលជាសិស្សរបស់ព្រះមហាសត្វ មានឈ្មោះថា បាបកៈ ត្រូវគេហៅថា នែបាបកៈ មកនេះ នែបាបកៈ ទៅចុះ ក៏គិតថា ឈ្មោះរបស់អញជាអពមង្គល អញត្រូវតែសូមឲ្យលោកអាចារ្យដាក់ឈ្មោះដទៃឲ្យសាជាថ្មី លុះគិតដូច្នេះហើយ ក៏ចូលទៅរកអាចារ្យប្រាប់ថា បពិត្រលោកអាចារ្យដ៏ចម្រើន ឈ្មោះរបស់ខ្ញុំជាអពមង្គល សូមលោកដាក់ឈ្មោះដទៃឲ្យខ្ញុំចុះ ។ គ្រានោះ អាចារ្យបានពោលនឹងមាណពនោះថា នែមាណព អ្នកចូរត្រាច់ទៅតាមជនបទ ហើយកំណត់យកឈ្មោះដែលជាមង្គលមួយ ដែលខ្លួនពេញចិត្តបំផុត ហើយមកវិញ យើងនឹងប្តូរឈ្មោះរបស់អ្នកឲ្យទៅជាឈ្មោះដទៃ ។ មាណពនោះទទួលថា ប្រពៃហើយលោកអាចារ្យ ។ ហើយកាន់

យកស្បៀងធ្វើដំណើរទៅតាមស្រុក និគម ជនបទ ទៅដល់នគរមួយ ។ នគរនោះឯងមានបុរសម្នាក់ឈ្មោះថា ជីវក ( អ្នកមានឈ្មោះថា រស់ ) ប៉ុន្តែស្លាប់ ឃើញពួកញាតិកំពុងសែងសាកសពបុរសនោះទៅកាន់ព្រៃខ្មោច ក៏សួរថា បុរសនេះឈ្មោះអ្វី ?

ពួកញាតិឆ្លើយថា ឈ្មោះ ជីវក ។

មាណពសួរថា សូម្បីមានឈ្មោះថា ជីវក ក៏អាចស្លាប់បានឬ?

ពួកញាតិឆ្លើយថា ទោះបីមានឈ្មោះថាជីវក ប្រែមកថារស់ក្តី អជីវក ប្រែមកថា មិនរស់ក្តី ក៏ស្លាប់ទាំងអស់ ឈ្មោះត្រឹមតែជាបញ្ញត្តិសម្រាប់ហៅប៉ុណ្ណោះ បុរសនេះឆ្កួតទេដឹង ។ មាណពនោះស្តាប់ពាក្យនោះហើយ មានការយល់ដឹងខ្លះៗ ក្នុងរឿងឈ្មោះ ធ្វើដំណើរត្រឡប់ចូលកាន់នគររបស់ខ្លួនវិញ ។ គ្រានោះ ពួកនាយទុនកំពុងចាប់នាងទាសីម្នាក់ ដែលមិនឲ្យការប្រាក់ ឲ្យអង្គុយក្បែរមាត់ទ្វារចងដោយខ្សែ ហើយនាងទាសីនោះក៏មានឈ្មោះថា ធនបាលី ( អ្នកមានទ្រព្យ ) មាណពនោះធ្វើដំណើរតាមផ្លូវ ឃើញទាសីនោះត្រូវគេចង ក៏សួរថា ហេតុអ្វីទើបគេចងនាង ?

ពួកនាយទុនឆ្លើយថា នាងមិនព្រមឲ្យការប្រាក់ ។

មាណពសួរថា នាងមានឈ្មោះអ្វី ?

ពួកនាយទុនឆ្លើយថា នាងមានឈ្មោះថា ធនបាលី ។

មាណពនោះសួរថា សូម្បីមានឈ្មោះថា ធនបាលី ក៏មិនអាចឲ្យ

ត្រឹមតែការប្រាក់ឬ ?

ពួកនាយទុនឆ្លើយថា ទោះមានឈ្មោះថា ធនបាលី ដែលប្រែថា អ្នកមានក្តី មានឈ្មោះថា អធនបាលី ប្រែថា អ្នកក្រក្តី ក៏អាចជាមនុស្សក្រ បានទាំងអស់ ឈ្មោះត្រឹមតែជាបញ្ញត្តិសម្រាប់ហៅប៉ុណ្ណោះ បុរសនេះល្ងង់ ពិតមែនហ្ន៎ ។ មាណពនោះរឹតតែភ្លឺច្បាស់ក្នុងរឿងឈ្មោះនោះក្រៃលែង ឡើង ធ្វើដំណើរចេញអំពីក្រុងទៅតាមផ្លូវបានជួបអ្នកវង្វេងផ្លូវម្នាក់ក៏សួរ ថា អ្នកដើរធ្វើអ្វីនៅទីនេះ ?

បុរសនោះឆ្លើយថា ខ្ញុំវង្វេងផ្លូវហើយ ។

មាណពសួរថា អ្នកឈ្មោះអ្វី ?

បុរសនោះឆ្លើយថា ខ្ញុំឈ្មោះ បន្ថក: ( អ្នកស្គាល់ផ្លូវ ) ។

មាណពសួរថា អ្នកមានឈ្មោះថា បន្ថក: នៅវង្វេងផ្លូវទៀតឬ ?

បុរសដែលវង្វេងផ្លូវនោះពោលថា បន្ថក:ក្តី អបន្ថក:ក្តី ក៏អាច វង្វេងផ្លូវបានទាំងអស់ ឈ្មោះត្រឹមតែជាបញ្ញត្តិសម្រាប់ហៅប៉ុណ្ណោះ អ្នក ប្រហែលជាឆ្កួតពិតមែនហើយ ។ មាណពនោះព្រងើយកន្តើយក្នុងរឿង ឈ្មោះ ធ្វើដំណើរទៅកាន់សម្នាក់ព្រះមហាសត្វ ។ កាលព្រះមហាសត្វ សួរថា នៃមាណព ដូចម្តេចដែរ អ្នកបានឈ្មោះដែលជាទីពេញចិត្តហើយ ឬ ? ក៏ប្រាប់ថា បពិត្រលោកអាចារ្យ ធម្មតាមនុស្សយើង ទោះបីមាន ឈ្មោះថា ជីវកក្តី មានឈ្មោះថាអាជីវកក្តី ក៏គង់ស្លាប់ដូចគ្នា សូម្បីមាន

ឈ្មោះថា ធនបាលីក្តី ឬអធនបាលីក្តី ក៏ជាមនុស្សទុគ៌តបានទាំងអស់ ទោះបីមានឈ្មោះថា បន្ថកៈក្តី អបន្ថកៈក្តី ក៏អាចវង្វេងផ្លូវដូចគ្នា ឈ្មោះត្រឹមតែជាបញ្ញត្តិសម្រាប់ហៅតែប៉ុណ្ណោះ សេចក្តីចម្រើនក្តី សេចក្តីវិនាសក្តី មិនទាក់ទងនឹងឈ្មោះឡើយ សេចក្តីចម្រើននិងសេចក្តីវិនាសកើតមានព្រោះការធ្វើប៉ុណ្ណោះ រឿងឈ្មោះសម្រាប់ខ្ញុំ ខ្ញុំសូមប្រើឈ្មោះដើមដដែល ។ ព្រះបរមពោធិសត្វប្រៀបធៀបរឿងដែលមាណពនោះឃើញនិងកម្មដែលគេធ្វើហើយ បានពោលគាថានេះថា

**ជីវកញ្ច មតំ ទិស្វា ធនបាលិញ្ច ទុគ្គតំ**
**បន្ថកញ្ច វនេ មូឡ្ហំ បាបកោ បុនរាគតោតិ ។**

មាណពឈ្មោះ បាបកៈ បានឃើញបុរសរស់ហើយ
ស្លាប់ផង ឃើញនាងទាសីឈ្មោះ នាងរក្សាទ្រព្យ
ហើយខ្សត់ទ្រព្យផង ឃើញបុរសអ្នកដើរផ្លូវ ហើយ
វង្វេង ក្នុងព្រៃផង មកវិញហើយ ។

បណ្តាបទទាំងនោះ បទថា **បុនរាគតោ** សេចក្តីថា ព្រោះឃើញហេតុបីយ៉ាងនេះ ទើបត្រឡប់មកវិញ រ អក្សរ លោកពោលទុកដោយអំណាចនៃសន្ធិ ។

ព្រះដ៏មានព្រះភាគ ទ្រង់នាំអតីតនិទាននេះមកហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែល

ភិក្ខុនេះ ជាអ្នកប្រាជ្ញាការសម្រេចដោយឈ្មោះនោះ សូម្បីក្នុងកាលមុន ភិក្ខុនេះ ក៏ជាអ្នកប្រាជ្ញាការសម្រេចដោយឈ្មោះមកហើយដែរ ហើយទ្រង់ប្រជុំជាតកថា មាណពអ្នកប្រាជ្ញាការសម្រេចដោយឈ្មោះក្នុងកាលនោះ បានមកជាភិក្ខុអ្នកប្រាជ្ញាការសម្រេចដោយឈ្មោះក្នុងកាលឥឡូវនេះ បរិស័ទរបស់អាចារ្យ បានមកជាពុទ្ធបរិស័ទ ចំណែកអាចារ្យ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា នាមសិទ្ធិជាតក ទី ៧ ។

# អដ្ឋកថា កូដវាណិជជាតក ទី ៨

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឈ្មួញអាក្រក់ម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សាធុ ខោ បណ្ឌិតោ នាម** ដូច្នេះជាដើម ។

សេចក្ដីសង្ខេបថា មនុស្សពីរនាក់ដែលនៅក្នុងក្រុងសាវត្ថី ចូលហ៊ុនគ្នាធ្វើជំនួញ រៀបចំរទេះដឹកទំនិញទៅកាន់ជនបទ លក់ទំនិញអស់ហើយនាំគ្នាត្រឡប់មកវិញ ។ បណ្ដាឈ្មួញទាំងពីរនាក់នោះ ឈ្មួញដែលមានគំនិតអាក្រក់បានគិតថា សម្លាញ់របស់អញនេះ លំបាកក្នុងការបរិភោគលំបាកក្នុងការដេកអស់ច្រើនថ្ងៃហើយ ពេលនេះគេនឹងបរិភោគភោជនល្អៗ ដោយរសដ៏ប្រណីតៗ ក្នុងផ្ទះរបស់គេរហូតទាល់តែឆ្អែត គេនឹងស្លាប់

ដោយរោគអាហារមិនរលាយ កាលបើដូច្នេះ អញនឹងចែកទ្រព្យនេះចេញជាបីចំណែក ឲ្យកូនៗ របស់គេមួយចំណែក នៅសល់ពីរចំណែកទៀតអញនឹងយកខ្លួនឯង ។ ឈ្មួញអាក្រក់នោះពន្យារថ្ងៃថា នឹងចែកក្នុងថ្ងៃនេះនឹងចែកក្នុងថ្ងៃស្អែក ដូច្នេះហើយ មិនចង់ចែកទ្រព្យឡើយ ។ ចំណែកឈ្មួញដែលជាបណ្ឌិតក៏ជំទាស់សម្លាញ់នោះដែលមិនចង់ចែក ឲ្យចែកទាល់តែបាន ហើយទៅកាន់វិហារថ្វាយបង្គំព្រះបរមសាស្តា បានទទួលបដិសណ្ឋារៈអំពីព្រះអង្គ ។ កាលព្រះតថាគតត្រាស់សួរថា ម្នាលឧបាសក អ្នកមកដល់នគរនេះហើយ ព្រោះហេតុអ្វីទើបយឺតយូរក្នុងការចូលគាល់តថាគត ? ក៏ក្រាបទូលរឿងនោះឲ្យព្រះដ៏មានព្រះភាគទ្រង់ជ្រាប ។ ព្រះដ៏មានព្រះ-ភាគទ្រង់ត្រាស់ថា ម្នាលឧបាសក មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលពាណិជនោះ ជាពាណិជអាក្រក់ សូម្បីក្នុងកាលមុន ក៏ធ្លាប់ជាពាណិជអាក្រក់ដែរ ប៉ុន្តែក្នុងពេលនេះប្រាថ្នានឹងបោកប្រាស់អ្នក សូម្បីក្នុងកាលមុន ក៏មិនអាចបោកប្រាស់បណ្ឌិតបាន ។ កាលឧបាសកនោះក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឈ្មួញ ក្នុងនគរពារាណសី ក្នុងថ្ងៃដាក់ឈ្មោះ ពួកញាតិបានដាក់ឈ្មោះឲ្យព្រះពោធិសត្វថាបណ្ឌិត ។ កាលព្រះពោធិសត្វចម្រើនវ័យហើយ បានចូលហ៊ុននឹង

ឈ្មួញដទៃធ្វើជំនួញ ឈ្មួញនោះឈ្មោះថា អតិបណ្ឌិត ទាំងពីរនាក់បបួលគ្នាផ្ទុកភណ្ឌដោយរទេះ ៥០០ ទៅកាន់ជនបទ លក់ទំនិញបានទ្រព្យយ៉ាងច្រើន នាំគ្នាត្រឡប់មកកាន់នគរពារាណសីវិញ ។ លុះដល់ពេលបែងចែកទ្រព្យសម្បត្តិគ្នា អតិបណ្ឌិតក៏ពោលថា ខ្ញុំគួរបានពីរចំណែក ។

ព្រះមហាសត្វសួរថា ព្រោះហេតុអ្វី?

អតិបណ្ឌិតឆ្លើយថា អ្នកឈ្មោះបណ្ឌិត ខ្ញុំឈ្មោះអតិបណ្ឌិត បណ្ឌិតគួរបានមួយចំណែក អតិបណ្ឌិតគួរបានពីរចំណែក ។

ព្រះមហាសត្វសួរថា ទុនដែលទិញរបស់ក្តី ពាហនៈមានគោជាដើមក្តី សូម្បីរបស់ទាំងពីរចំណែក ក៏យើងចេញស្មើៗ គ្នា មិនមែនឬ ហេតុអ្វីទើបអ្នកគួរបានពីរចំណែក?

អតិបណ្ឌិតឆ្លើយថា ព្រោះខ្ញុំជាអតិបណ្ឌិត ។ ទាំងពីរនាក់ប្រកែកគ្នា ហើយក៏ឈ្លោះគ្នា ។ ពេលនោះ អតិបណ្ឌិតគិតឃើញថានៅមានឧបាយមួយទៀត ទើបឲ្យបិតារបស់ខ្លួនចូលទៅពួនក្នុងប្រហោងឈើមួយដោយប្រាប់ថា នៅពេលដែលពួកខ្ញុំទាំងពីរមកដល់ ពុកត្រូវនិយាយថា អតិបណ្ឌិតគួរបានទ្រព្យពីរចំណែក ។ អតិបណ្ឌិតក៏ទៅរកព្រះពោធិសត្វហើយពោលថា នៃសម្លាញ់ជាទីស្រឡាញ់ រុក្ខទេវតានោះរមែងដឹងការដែលយើងគួរបានពីរចំណែកឬមិនគួរ មកចុះ យើងនឹងសួររុក្ខទេវតានោះហើយនាំគ្នាទៅកាន់ដើមឈើនោះ ។ អតិបណ្ឌិតពោលថា បពិត្ររុក្ខទេវតា

អ្នកជាម្ចាស់ព្រៃ សូមជួយកាត់ក្តីឲ្យយើងទាំងពីរនាក់ផង ។ គ្រានោះ បិតារបស់អតិបណ្ឌិតក៏ប្តូរសំឡេងឲ្យប្លែកពោលថា បើដូច្នោះ អ្នកទាំងពីរ ចូរប្រាប់រឿងរ៉ាវដល់យើង ។

អតិបណ្ឌិតក៏ប្រាប់ថា បពិត្រម្ចាស់ព្រៃ បុរសនេះឈ្មោះ បណ្ឌិត ខ្ញុំឈ្មោះ អតិបណ្ឌិត យើងខ្ញុំទាំងពីរចូលហ៊ុនគ្នាធ្វើជំនួញ ក្នុងរឿងនោះ បុរសនេះ គួរបានទទួលទ្រព្យដូចម្តេច ?

( រុក្ខទេវតាក្លែងក្លាយនោះពោលថា ) បណ្ឌិតបានមួយចំណែក អតិបណ្ឌិតបានពីរចំណែក ។ ឈ្មួញពោធិសត្វស្តាប់រឿងក្តីដែលទេវតាវិនិច្ឆ័យហើយយ៉ាងនេះ ក៏គិតថា ណ្ហើយចុះ អញនឹងដឹងឲ្យបានច្បាស់ថាជាទេវតា ឬមិនមែនទេវតា ? គិតដូច្នេះហើយ ក៏ទៅយកចំបើងមកដាក់ក្នុងប្រហោងឈើរួចដុតភ្លើងភ្លាម ។ បិតារបស់អតិបណ្ឌិត ពេលដែលអណ្តាតភ្លើងពាល់ត្រូវខ្លួនក៏ក្តៅព្រោះសរីរៈជិតនឹងឆេះ ទើបស្ទុះឡើងទៅខាងលើស្រវាមែកឈើ ហើយលោតចុះទៅដី រួចពោលគាថានេះថា

**សាធុ ខោ បណ្ឌិតោ នាម ន ត្វេវ អតិបណ្ឌិតោ**
**អតិបណ្ឌិតេន បុត្តេន មនម្ហិ ឧបកុដ្ឋិតោតិ ។**

បុគ្គលដែលឈ្មោះថា បណ្ឌិត ជាអ្នកប្រពៃពិត ឯបុគ្គល
ឈ្មោះថា អតិបណ្ឌិត មិនប្រពៃទេ អាត្មាអញត្រូវភ្លើង
រោល ព្រោះតែកូនឈ្មោះ អតិបណ្ឌិត ។

*បណ្ដាបទទាំងនោះ បទថា* **សាធុ ខោ បណ្ឌិតោ នាម** *សេចក្ដីថា បុគ្គលអ្នកប្រកបដោយភាពជាបណ្ឌិត ដឹងហេតុនិងមិនមែនហេតុ ចាត់ជាមនុស្សល្អក្នុងលោកនេះ ។*

*បទថា* **អតិបណ្ឌិតោ** *សេចក្ដីថា មនុស្សអាក្រក់ជាអតិបណ្ឌិត ដោយហេតុត្រឹមតែឈ្មោះ មិនប្រសើរឡើយ ។*

*បទថា* **មនម្ហិ ឧបកុដ្ឋិតោ** *សេចក្ដីថា យើងត្រូវភ្លើងឆេះបន្តិចរួចផុតអំពីការឆេះពាក់កណ្ដាលខ្លួន អ្នកទាំងពីរចូរបែងចែកស្មើៗ គ្នាចុះ ។ ជនទាំងពីរនោះក៏បែងចែកទ្រព្យគ្នាម្នាក់ពាក់កណ្ដាល កាន់យកចំណែកស្មើៗគ្នា ក្រោយអំពីអស់ជីវិត ជនទាំងពីរនាក់នោះក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្ដាទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងថា សូម្បីក្នុងកាលមុនពាណិជនោះ ក៏ជាពាណិជអាក្រក់ដែរ ហើយទ្រង់ប្រជុំជាតកថា ពាណិជអាក្រក់ក្នុងកាលនោះ បានមកជាពាណិជអាក្រក់ក្នុងកាលឥឡូវនេះ ចំណែកពាណិជដែលជាបណ្ឌិត គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា កូដវាណិជជាតក ទី ៨ ។

# អដ្ឋកថា បរោសហស្សជាតក ទី ៩

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ហារបស់បុថុជ្ជន មានបុគ្គលជាទី ៥ ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្តើមថា **បរោសហស្សម្បិ សមាគតានំ** ដូច្នេះជាដើម ។

រឿងនឹងប្រាកដច្បាស់នៅក្នុង **សរភង្គជាតក** សម័យមួយ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា អង្គុយសន្ទនាគ្នាអំពីរឿងរបស់ព្រះថេរៈថា អ្នកមានអាយុទាំងឡាយ ព្រះធម្មសេនាបតីសារីបុត្តព្យាករបញ្ហាដែលព្រះទសពលត្រាស់ដោយសង្ខេបឲ្យពិស្តារ ។ ព្រះបរមសាស្តា ស្តេចយាងមកទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះអ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលសារីបុត្តព្យាករបញ្ហាដែលតថាគតសម្តែងដោយសង្ខេបបានយ៉ាងពិស្តារ សូម្បីក្នុងកាលមុនក៏ព្យាករបានយ៉ាងពិស្តារហើយដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ចម្រើនវ័យហើយ រៀនសព្វសិល្បវិទ្យាក្នុងនគរតក្កសិលា លះបង់កាមទាំងឡាយ ហើយបួសជាឥសី ញុំាងអភិញ្ញា៥ សមាបត្តិ៨ ឲ្យកើតហើយ

នៅក្នុងព្រៃហេមពាន្ត សូម្បីបរិវាររបស់ព្រះបរមពោធិសត្វក៏បួសជាតាបស ៥០០ រូប ។ គ្រានោះ ជារដូវភ្លៀង អន្តេវាសិកច្បងរបស់ឥសីពោធិសត្វនាំគណៈឥសីប្រមាណពាក់កណ្ដាលទៅកាន់ដែនដីមនុស្ស ដើម្បីត្រូវការសេពរសជូរ ប្រៃ ។ ក្នុងកាលនោះ ជាកាលដែលព្រះមហាសត្វនឹងធ្វើកាលកិរិយា ពួកអន្តេវាសិកទាំងឡាយនាំគ្នាសួរព្រះមហាសត្វអំពីការបានសម្រេចគុណវិសេសថា បពិត្រអាចារ្យ លោកបានសម្រេចគុណវិសេសប្រភេទណា ?

ព្រះមហាសត្វឆ្លើយថា អ្វីតិចតួចមិនមាន ។ ( ឥសីពោធិសត្វក៏ធ្វើកាលកិរិយា ) លោកទៅបដិសន្ធិក្នុងព្រហ្មលោកជាន់អាភស្សរៈ ដ្បិតថាព្រះបរមពោធិសត្វទាំងឡាយ សូម្បីបានអរូបសមាបត្តិក៏ដោយ ក៏មិនបានទៅបដិសន្ធិក្នុងអរូបភពជាស្ថានដែលមិនគួរ ។ ពួកអន្តេវាសិកគិតថាលោកអាចារ្យមិនមានគុណវិសេសអ្វីសោះ លុះគិតដូច្នោះហើយ ក៏មិនធ្វើសក្ការៈក្នុងព្រៃខ្មោច អន្តេវាសិកដែលជាធំត្រឡប់មកវិញ ក៏សួរថា លោកអាចារ្យទៅណា ? លុះដឹងថា លោកអាចារ្យធ្វើកាលកិរិយា ក៏សួរថា តើពួកអ្នកមានបានសួរដល់គុណវិសេសដែលលោកបានសម្រេចដែរឬទេ ?

ពួកអន្តេវាសិកទាំងនោះឆ្លើយថា ពួកខ្ញុំបានសួរដែរ ។

ប្រធានអន្តេវាសិកសួរថា លោកអាចារ្យឆ្លើយដូចម្ដេចដែរ ?

ពួកអន្តេវាសិកទាំងនោះឆ្លើយថា លោកឆ្លើយថា អ្វីតិចតួចមិនមាន

ហេតុនោះ ទើបពួកខ្ញុំមិនធ្វើសក្ការៈចំពោះលោក ។ អន្តេវាសិកដែលជាធំនោះពោលថា ពួកអ្នកមិនយល់សេចក្តីនៃពាក្យរបស់លោកអាចារ្យទេ លោកអាចារ្យបានសម្រេចអាកិញ្ចញ្ញាយតនសមាបត្តិ សូម្បីអន្តេវាសិកដែលជាធំនោះពោលដដែលៗ យ៉ាងណាក៏ដោយ ក៏ពួកអន្តេវាសិកទាំងនោះនៅតែមិនជឿដដែល ព្រះមហាបុរសជ្រាបហេតុនោះ ក៏ត្រិះរិះថា ពួកអន្ធពាលមិនជឿសម្តីនៃអន្តេវាសិកដែលជាធំរបស់អញ អញចាំបាច់ធ្វើហេតុនេះឲ្យប្រាកដដល់អន្តេវាសិកទាំងនោះ ហើយក៏ចុះអំពីព្រហ្មលោកមកឈរនៅលើអាកាសដោយអានុភាពដ៏ធំខាងលើអាស្រមបទ កាលនឹងពណ៌នាបញ្ញានុភាពរបស់អន្តេវាសិកដែលជាធំ បានពោលគាថានេះថា

**បរោសហស្សម្បិ សមាគតានំ**
**កន្ទេយ្យុំ តេ វស្សសតំ អបញ្ញា**
**ឯកោវ សេយ្យោ បុរិសោ សបញ្ញោ**
**យោ ភាសិតស្ស វិជានាតិ អត្ថំ ។**

ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងពាន់នាក់ ជនទាំងនោះឥតប្រាជ្ញា គប្បីកន្ទក់កន្ទេញអស់ ១០០ ឆ្នាំ បុរសណា ប្រកបដោយប្រាជ្ញា បានដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះ តែម្នាក់ឯង ប្រសើរជាង ។

បណ្តាបទទាំងនោះ បទថា **បរោសហស្សម្បិ** ប្រែថា សូម្បី

ច្រើនជាង ១ ពាន់នាក់ ។ បទថា **សមាគតានំ** សេចក្តីថា ជនលួងខ្លៅទាំងនោះ មិនបានដឹងច្បាស់នូវអត្ថនៃភាសិតដែលយើងពោលហើយ ជនទាំងនោះបានមកប្រជុំគ្នាហើយ ។

ដោយបទថា **កន្ទេយ្យុំ តេ វស្សសតំ អបញ្ញា** នេះ ព្រះមហាបុរសសម្តែងថា ជនទាំងនោះមករួមគ្នាយ៉ាងនេះ ឥតបញ្ញា ដូចពួកតាបសលួងខ្លៅទាំងនេះ នាំគ្នាកន្ទក់កន្ទេញអស់ ១ រយឆ្នាំ សូម្បីអស់ ១ ពាន់ឆ្នាំ ១ សែនឆ្នាំ ក៏មិនបានដឹងនូវអត្ថឬហេតុឡើយ ។

បទថា **ឯកោវ សេយ្យោ បុរិសោ សបញ្ញោ** សេចក្តីថា បុរសដែលជាបណ្ឌិតតែម្នាក់ប៉ុណ្ណោះ ល្អជាង ប្រសើរជាងបុគ្គលអន្ធពាលបែបនោះ សូម្បីទាំងពាន់នាក់ ។

សួរថា អ្នកមានបញ្ញានោះតើដូចម្តេច ?

ឆ្លើយថា អ្នកមានបញ្ញាដឹងច្បាស់នូវអត្ថនៃសុភាសិតដែលយើងពោលហើយ ដូចអន្តេវាសិកដែលជាធំ ។

ព្រះមហាបុរសឈរនៅលើអាកាសនោះឯង សម្តែងធម៌ពន្យល់ពួកតាបសទាំងនោះឲ្យបានយល់ច្បាស់ ដោយប្រការដូច្នេះហើយ ក៏ទៅកាន់ព្រហ្មលោកវិញ ពួកតាបសទាំងអស់នោះ លុះអស់ជីវិតក៏បានទៅបដិសន្ធិក្នុងព្រហ្មលោកដែរ ។

ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំ

*ជាតកថា អន្តេវាសិកដែលជាប្រធាននោះ បានមកជាសារីបុត្ត ចំណែកមហាព្រហ្ម គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា បរោសហស្សជាតក ទី ៩ ។

# អដ្ឋកថា អសាតរូបជាតក ទី ១០

*ព្រះបរមសាស្តា កាលទ្រង់អាស្រ័យនៅក្នុងកុណ្ឌិយនគរ ទ្រង់គង់នៅក្នុងកុណ្ឌធានវ័ន ទ្រង់ប្រារព្ធឧបាសិកាសុប្បវាសាជាធីតានៃកោលិយក្សត្រ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **អសាតំ សាតរូបេឆ** *ដូច្នេះជាដើម ។*

*សេចក្តីពិស្តារថា ក្នុងសម័យនោះ ព្រះនាងសុប្បវាសាត្រូវបរិហារព្រះគភ៌អស់ ៧ ឆ្នាំ ហើយត្រូវប្រឈួនព្រះគភ៌អស់ ៧ថ្ងៃទៀត ទុក្ខវេទនាប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា ព្រះនាងសូម្បីត្រូវទុក្ខវេទនាយ៉ាងខ្លាំងពាល់ត្រូវយ៉ាងនេះក៏ដោយ ក៏អត់ទ្រាំសង្កត់ទុក្ខវេទនានោះបានដោយវិតក្កបីប្រការ គឺ ព្រះដ៏មានព្រះភាគអង្គណាទ្រង់សម្តែងព្រះធម៌ ដើម្បីលះបង់នូវទុក្ខបែបនេះ ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតមែន ពួកនៃសាវករបស់ព្រះដ៏មានព្រះភាគអង្គនោះឯណា បដិបត្តិហើយដើម្បីលះបង់ទុក្ខបែបនេះ ពួកនៃសាវករបស់ព្រះដ៏មានព្រះភាគអង្គនោះ ជាអ្នកបដិបត្តិដ៏ប្រពៃមែនពិត ទុក្ខបែបនេះមិនមានក្នុងព្រះនិព្វានឯណា ព្រះ-*

និព្វាននោះជាសុខពិតមែនហ្ន៎ ។ ព្រះនាងត្រាស់ហៅព្រះស្វាមីមកហើយ សូមឲ្យទៅគាល់ព្រះដ៏មានព្រះភាគ ដើម្បីក្រាបទូលការប្រព្រឹត្តិទៅរបស់ព្រះនាង ហើយផ្ញើការថ្វាយបង្គំចំពោះព្រះសាស្តា ។ ព្រះសាស្តាទ្រង់ជ្រាបដំណឹងការថ្វាយបង្គំរបស់ព្រះនាងហើយ ទ្រង់ត្រាស់ថា សុប្បវាសា-កោលិយធីតា ចូរមានសេចក្តីសុខចុះ ចូរមានសេចក្តីសុខមិនមានរោគប្រសូតព្រះឱរសដោយប្រាសចាករោគចុះ ដំណាលគ្នានឹងព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគនោះ ព្រះនាងសុប្បវាសាកោលិយធីតានោះ ក៏ទ្រង់ប្រសូតព្រះឱរសដោយប្រាសចាករោគាពាធ ប្រសូតព្រះឱរសអ្នកមិនមានរោគហើយ ។ កាលព្រះស្វាមីរបស់ព្រះនាងយាងមកដល់និវេសន៍ហើយ ទតឃើញព្រះនាងប្រសូតព្រះឱរសហើយ ទ្រង់កើតការអស្ចារ្យក្នុងព្រះទ័យថា គួរឲ្យអស្ចារ្យពិតមែនហ្ន៎ អានុភាពរបស់ព្រះតថាគតហួសប្រមាណ ។ ចំណែកព្រះនាងសុប្បវាសាទ្រង់ប្រសូតព្រះកុមារហើយ ក៏ប្រាថ្នានឹងថ្វាយមហាទានចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ទើបបញ្ជូនព្រះស្វាមីត្រឡប់ទៅដើម្បីនិមន្តភិក្ខុសង្ឃ ។ ក្នុងសម័យនោះ ឧបដ្ឋាករបស់ព្រះមហាមោគ្គល្លានត្ថេរ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានទុកហើយ ព្រះដ៏មានព្រះភាគក៏ទ្រង់បញ្ជូនព្រះស្វាមីរបស់ព្រះនាងទៅកាន់សម្នាក់ព្រះមហាមោគ្គល្លានត្ថេរ ព្រះថេរៈធ្វើឲ្យឧបដ្ឋាកយល់ព្រមដើម្បីឲ្យឱកាសដល់ទានរបស់ព្រះនាងសុប្បវាសាហើយ ព្រះដ៏មានព្រះភាគ ទ្រង់

ទទួលទានរបស់ព្រះនាងអស់ ៧ ថ្ងៃជាមួយនឹងព្រះភិក្ខុសង្ឃ ។

លុះដល់ថ្ងៃទី ៧ ព្រះនាងសុប្បវាសាតាក់តែងព្រះសីវលីកុមារ ឲ្យថ្វាយបង្គំព្រះបរមសាស្ដានិងព្រះភិក្ខុសង្ឃ កាលព្រះកុមារត្រូវនាំចូលទៅកាន់សម្នាក់ព្រះថេរៈដោយលំដាប់ ព្រះថេរៈបានធ្វើបដិសណ្ឋារៈចំពោះព្រះកុមារថា សីវលី អ្នកល្មមអត់ធន់បានឬ?

ព្រះកុមារត្រាស់ពាក្យបែបនេះនឹងព្រះថេរៈថា បពិត្រលោកម្ចាស់ ខ្ញុំនឹងមានសេចក្ដីសុខអំពីណាបាន ខ្ញុំនោះត្រូវនៅក្នុងលោហគម្ភីរអស់ ៧ ឆ្នាំ ។ ព្រះនាងសុប្បវាសាទ្រង់ព្រះសណ្ដាប់ពាក្យរបស់ព្រះកុមារហើយព្រះនាងសោមនស្សថា កូនរបស់អញកើតបាន ៧ ថ្ងៃ អាចសន្ទនាជាមួយនឹងព្រះអនុពុទ្ធធម្មសេនាបតីបាន ។ ព្រះតថាគតត្រាស់សួរថា ម្នាលនាងសុប្បវាសា នាងនៅប្រាថ្នាបុត្តយ៉ាងនេះដទៃៗ ប៉ុន្មាននាក់ទៀត?

ព្រះនាងក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើខ្ញុំព្រះអង្គគប្បីបានឱរសដទៃៗ បែបនេះ ៧ នាក់ទៀត ខ្ញុំព្រះអង្គក៏ប្រាថ្នាដែរ ។ ព្រះបរមសាស្ដាទ្រង់បន្លឺឧទាន ទ្រង់អនុមោទនាទានរបស់ព្រះនាងហើយស្ដេចយាងទៅវិញ ។ ចំណែកព្រះកុមារសីវលី លុះបានព្រះជន្ម ៧ ព្រះ-វស្សាហើយ ក៏ទ្រង់បួសឧទ្ទិសជីវិតចំពោះព្រះសាសនា ។ លុះមានព្រះជន្មគ្រប់ក៏បានឧបសម្បទា លុះឧបសម្បទាហើយជាអ្នកមានបុណ្យ ដល់នូវភាពជាអ្នកលើសទៅដោយលាភនិងយសល្បីពេញប្រឹថពី បានសម្រេច

អរហត្តផលហើយ បានទទួលតំណែងជាឯតទគ្គផ្នែកខាងអ្នកមានលាភច្រើន ។ ថ្ងៃមួយ ពួកភិក្ខុអង្គុយប្រជុំគ្នាក្នុងធម្មសភា ផ្តើមសន្ទនាគ្នាថា អ្នកមានអាយុទាំងឡាយ ព្រះថេរៈដែលមានឈ្មោះថា សីវលី មានបុណ្យច្រើន មានសេចក្តីប្រាថ្នាដែលតាំងទុកហើយ ជាសត្វដែលឧប្បត្តិក្នុងជាតិចុងក្រោយបែបនេះ ត្រូវនៅក្នុងលោហគម្ភីរ គឺផ្ទៃមាតាអស់ ៧ ឆ្នាំ ហើយត្រូវដល់នូវការវង្វេងគភ៌អស់ ៧ ថ្ងៃទៀត គួរឲ្យអាណិតណាស់ ព្រះមាតាត្រូវសោយទុក្ខវេទនាយ៉ាងខ្លាំងក្លា លោកបានធ្វើកម្មអ្វីទុកហ្ន៎ ។ ព្រះដ៏មានព្រះភាគ ស្តេចទ្រង់យាងមកកាន់ធម្មសភានោះ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយកំពុងសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការនៅក្នុងលោហគម្ភីរអស់ ៧ ឆ្នាំ ហើយដល់នូវការវង្វេងគភ៌អស់ ៧ ថ្ងៃទៀត របស់សីវលីអ្នកមានបុណ្យច្រើន មានកម្មដែលខ្លួនបានធ្វើទុកហើយជាមូល សេចក្តីទុក្ខព្រោះការបរិហារគភ៌ដោយការពផ្ទៃអស់ ៧ ឆ្នាំ និងទុក្ខព្រោះការវង្វេងគភ៌អស់ ៧ ថ្ងៃ របស់ព្រះនាងសុប្បវាសានោះ ក៏មានកម្មដែលខ្លួនធ្វើទុកហើយជាមូលដែរ កាលភិក្ខុទាំងឡាយក្រាបទូលអារាធនាហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុង

នគរពារាណសី ព្រះបរមពោធិសត្វទ្រង់បដិសន្ធិក្នុងព្រះគភ៌នៃព្រះអគ្គ-មហេសីព្រះបាទព្រហ្មទត្តអង្គនោះ ទ្រង់ចម្រើនវ័យហើយ ទ្រង់សិក្សាសព្វសិល្បវិទ្យានៅក្នុងនគរតក្កសិលា លុះព្រះបិតាសោយទិវង្គតហើយ ក៏ទ្រង់សោយរាជសម្បត្តិដោយធម៌ ។ សម័យនោះ ព្រះបាទកោសលទ្រង់លើកកងទ័ពមកដណ្ដើមយកនគរពារាណសីបាន ដាក់ទោសព្រះរាជាហើយធ្វើអគ្គមហេសីរបស់ព្រះរាជានោះឯង ឲ្យជាមហេសីរបស់ព្រះអង្គ ។ ចំណែកព្រះឱរសរបស់ព្រះរាជាពារាណសី ពេលដែលព្រះរាជបិតាសោយទិវង្គតទៅ ទ្រង់គេចចេញទៅតាមលូទឹក ទ្រង់ប្រមូលកម្លាំងបានហើយលើកមកកាន់នគរពារាណសី ដាក់បន្ទាយកងទ័ពនៅជិតនគរ ទ្រង់បញ្ជូនសារទៅថ្វាយព្រះរាជាថា សូមព្រះអង្គប្រគល់រាជសម្បត្តិឲ្យទូលបង្គំវិញ បើមិនដូច្នោះទេ សូមទ្រង់ធ្វើចម្បាំងជាមួយទូលបង្គំចុះ ។ ព្រះរាជាអង្គនោះ ទ្រង់ឆ្លើយតបព្រះរាជសារថា យើងនឹងធ្វើសង្គ្រាម ។ ចំណែកព្រះរាជមាតារបស់ព្រះរាជកុមារអង្គនោះ ទ្រង់ព្រះសណ្ដាប់ព្រះរាជសារនោះហើយ ទ្រង់បញ្ជូនសារទៅថា កុំធ្វើសង្គ្រាម ចូរព័ទ្ធនគរពារាណសី កាត់ផ្ដាច់ការទៅមកនៃនគរឲ្យបាន ៧ ថ្ងៃ បន្ទាប់ពីនោះអាចដណ្ដើមយកនគរ កាលដែលអ្នកនគរលំបាកដោយអស់ឧស ទឹក និងភត្ត ដោយមិនចាំបាច់ធ្វើចម្បាំងឡើយ ។ ព្រះរាជកុមារស្ដាប់ដំណឹងរបស់ព្រះមាតាហើយ ក៏ព័ទ្ធនគរផ្ដាច់ការទៅមកអស់ ៧ ថ្ងៃ អ្នកនគរទៅមកមិនបាន ក៏កាត់ព្រះសិរសារបស់

ព្រះរាជាអង្គនោះទៅថ្វាយព្រះរាជកុមារក្នុងថ្ងៃទី ៧ ។ ព្រះរាជកុមារក៏យាងចូលនគរគ្រងរាជសម្បត្តិ កាលអស់ព្រះជន្មហើយ ស្តេចក៏ទៅតាមយថាកម្ម ។

ក្នុងពេលនេះ សីវលីត្រូវនៅក្នុងលោហគម្ភីរគឺផ្ទៃមាតាអស់ ៧ ឆ្នាំ ដល់នូវភាពជាអ្នកវង្វេងគភ៌អស់ ៧ ថ្ងៃ ដោយកម្មដែលបិទនគរ កាត់ផ្តាច់ការទៅមកអស់ ៧ ថ្ងៃហើយដណ្តើមយកនគរនោះ ប៉ុន្តែសីវលីបានឲ្យមហាទាន ធ្វើសេចក្តីប្រាថ្នាទុកទៀបព្រះបាទនៃ **ព្រះបទុមុត្តរសម្មាសម្ពុទ្ធ** ថា ខ្ញុំព្រះអង្គគប្បីជាអ្នកកំពូលជាងបុគ្គលអ្នកសម្បូណ៌ដោយលាភទាំងឡាយ ហើយក្នុងសម័យ **ព្រះពុទ្ធវិបស្សី** រួមនឹងអ្នកនគរថ្វាយ គុឡទធិ គឺទឹកដោះជូរដែលផ្សំដោយរសផ្សេងៗ មានតម្លៃមួយពាន់ ហើយបានធ្វើសេចក្តីប្រាថ្នាទុក ដោយអានុភាពនៃទាននោះ ទើបបានជាឯតទគ្គផ្នែកខាងអ្នកមានលាភច្រើន ។ ចំណែកនាងសុប្បវាសាព្រោះបញ្ជូនសារទៅថា ចូរឡោមព័ទ្ធនគរដណ្តើមយកចុះ ទើបត្រូវបរិហារគភ៌ ពព្រះឧទរអស់ ៧ ឆ្នាំ ហើយត្រូវឈឺព្រះគភ៌យ៉ាងខ្លាំងក្លាអស់ ៧ ថ្ងៃទៀត ។ ព្រះបរមសាស្តាទ្រង់នាំយករឿងក្នុងអតីតមកសម្តែងហើយទ្រង់ត្រាស់ព្រះគាថានេះ ជាអភិសម្ពុទ្ធគាថាថា

**អសាតំ សាតរូបេន បិយរូបេន អប្បិយំ**
**ទុក្ខំ សុខស្ស រូបេន បមត្តមតិវត្តតីតិ ។**

របស់មិនគួរត្រេកអរ រមែងគ្របសង្កត់ នូវបុគ្គលប្រមាទ ដោយសភាពនៃរបស់ដែលគួរត្រេកអរ របស់មិនគួរស្រឡាញ់ រមែងគ្របសង្កត់ នូវបុគ្គលប្រមាទ ដោយសភាពនៃរបស់គួរស្រឡាញ់ សេចក្ដីទុក្ខ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោយសភាពនៃសេចក្ដីសុខ ។

បណ្ដាបទទាំងនោះ បទថា **អសាតំ សាតរូបេន** សេចក្ដីថា របស់មិនគួរត្រេកអរ គឺមិនមានរសផ្អែម រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោយសភាពនៃរបស់ឆ្ងាញ់ ។

បទថា **បមត្តមតិវត្តតិ** មានអធិប្បាយថា របស់ទាំងបីយ៉ាងនេះ គឺរបស់ដែលមិនគួរត្រេកអរ របស់ដែលមិនគួរស្រឡាញ់ និងទុក្ខ រមែងគ្របសង្កត់បុគ្គលប្រមាទដោយអំណាចនៃការនៅប្រាសចាកសតិ ដោយសភាពនៃរបស់ដែលគួរត្រេកអរជាដើម រឿងនេះគប្បីជ្រាបថា មាតានិងបុត្តទាំងពីរនាក់នេះ ត្រូវរបស់ដែលមិនគួរត្រេកអរ ពោលគឺការបរិហារគភ៌ និងការនៅក្នុងគភ៌ជាដើមនេះ គ្របសង្កត់ហើយ ដោយអំណាចកម្មដែលព័ទ្ធបិទនគរ ក្នុងកាលមុនជាដើមឯណា ពេលនេះ ឧបាសិកានោះ រមែងឲ្យរបស់ដែលមិនគួរត្រេកអរ មិនគួរស្រឡាញ់ ជាទុក្ខបែបនេះ គ្របសង្កត់អស់ ៧ ដងទៀត ដោយរូបក្លែងក្លាយគឺសញ្ញាវិបល្លាសដែលធ្វើឲ្យយល់ខុសថា គួរឲ្យត្រេកអរ ពោលគឺបុត្តដែលជាទីតាំងនៃសេចក្ដីស្រឡាញ់ជា

*ដើម ទើបក្រាបទូលយ៉ាងនេះឯណាក្តី ព្រះដ៏មានព្រះភាគទ្រង់សំដៅយកការក្រាបទូលទាំងអស់នោះ ទើបទ្រង់ត្រាស់ព្រះគាថានេះ ។*

*ព្រះបរមសាស្តា ទ្រង់នាំយករឿងនេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជកុមារដែលព័ទ្ធបិទនគរ ហើយដណ្តើមយករាជសម្បត្តិក្នុងកាលនោះ បានមកជាសីវលី ព្រះមាតាបានមកជាព្រះនាងសុប្បវាសា ចំណែកព្រះរាជានគរពារាណសីដែលជាព្រះរាជបិតានោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា អសាតរូបជាតក ទី ១០ ។

ចប់ អដ្ឋកថា លិត្តវគ្គ ទី ១០ ។

ចប់ មជ្ឈិមបណ្ណាសក ។

# រួមជាតកដែលមានក្នុងវគ្គនេះគឺ

*លិត្តជាតក ១ មហាសារជាតក ១ វិស្សាសភោជនជាតក ១ លោមហំសជាតក ១ មហាសុទស្សនជាតក ១ តេលបត្តជាតក ១ នាមសិទ្ធិជាតក ១ កូដវាណិជជាតក ១ បរោសហស្សជាតក ១ អសាតរូបជាតក ១ ។*

# បរោសតវគ្គ ទី ១១

## អដ្ឋកថា បរោសតជាតក ទី ១

*នៅក្នុងរឿងនេះ មានគាថាថា*

**បរោសតំ វេបិ សមាគតានំ**

**ឈាយេយ្យុំ តេ វស្សសតំ អបញ្ញា**

**ឯកោវ សេយ្យោ បុរិសោ សបញ្ញោ**

**យោ ភាសិតស្ស វិជានាតិ អត្ថន្តិ ។**

*ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងរយនាក់ ជនទាំងនោះឥតប្រាជ្ញា គប្បីពិចារណា ( នូវអត្ថនៃភាសិត ) អស់ ១០០ ឆ្នាំ បុរសណាប្រកបដោយប្រាជ្ញា ដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះ តែម្នាក់ឯងប្រសើរវិញ ។*

*សាច់រឿងវេយ្យាករណ៍និងប្រជុំជាតកដូចគ្នានឹងរឿង* **បរោសហស្ស ជាតក** *ប៉ុន្តែក្នុងជាតកនេះ មានការប្លែកត្រឹមតែបទ* ឈាយេយ្យុ *មួយបទប៉ុណ្ណោះ ។ គាថានោះ មានអត្ថាធិប្បាយថា ជនទាំងនោះឥតប្រាជ្ញា គប្បីពិចារណានូវអត្ថនៃសុភាសិត រហូតអស់ ១០០ ឆ្នាំយ៉ាងនេះ ក៏រមែងមិនឃើញហេតុឬផល ហេតុនោះ បុគ្គលណាដឹងច្បាស់នូវអត្ថនៃសុភាសិត ដែលតថាគតសម្តែងហើយ បុគ្គលនោះតែម្នាក់ប៉ុណ្ណោះ ប្រសើរជាង ។*

ចប់ អដ្ឋកថា បរោសតជាតក ទី ១ ។

# អដ្ឋកថា បណ្ណិកជាតក ទី ២

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកដែលជាឈ្មួញបន្លែម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យោ ទុក្ខផុដ្ឋាយ ភវេយ្យ តាណំ** ដូច្នេះជាដើម ។

បានឮថា ឧបាសកនោះមានប្រក្រតីនៅក្នុងក្រុងសាវត្ថី លក់បន្លែផ្សេងៗ មានសណ្ដែកទ្រើង ឃ្មោក និងអន្ទក់ជាដើមចិញ្ចឹមជីវិត ឧបាសកនោះមានកូនស្រីមួយ មានរូបរាងល្អឥតខ្ចោះ គ្រប់គ្រាន់ សម្បូរដោយមារយាទ ការប្រព្រឹត្តិប្រកបដោយហិរិនិងឱត្តប្បៈ ទាស់តែម្យ៉ាង ត្រង់ដែលចូលចិត្តសើចជានិច្ច កាលត្រកូលដែលសមគួរមកស្ដីដណ្ដឹងនាង ឧបាសកនោះគិតថា ការស្ដីដណ្ដឹងកំពុងតែដំណើរទៅ ចំណែកកូនស្រីរបស់អញចូលចិត្តសើចជានិច្ច កាលកូនរបស់អញមិនទាន់មានសម្បត្តិជាកូនស្រី ទៅកាន់ត្រកូលស្វាមី រមែងជាទីតិះដៀលដល់មាតាបិតាបាន អញត្រូវពិសោធកូនស្រីអញមើលថា មានកុមារិកាធម៌ឬក៏មិនទាន់មាន ។ ថ្ងៃមួយ គាត់ឲ្យកូនស្រីកាន់កំប្រោងទៅព្រៃដើម្បីបេះបន្លែ ហើយធ្វើដូចជាត្រូវកិលេសរួមរឹតដោយប្រាថ្នានឹងសាកល្បង ពោលពាក្យលួងលោមហើយចាប់ដៃនាង ។ កូនស្រីត្រូវបិតាចាប់ដៃភ្លាមក៏ស្រែកឡើងថា បពិត្របិតា រឿងនេះមិនសមគួរទេ ដូចភ្លើងប្រាកដឡើងអំពីទឹក លោកឪពុកកុំធ្វើយ៉ាងនេះឡើយ ។ ឧបាសកនោះពោលថា កូនជាទីស្រឡាញ់ បិតាចាប់ដៃកូនឯងដើម្បី

សាកល្បង ពេលនេះកូនឯងមានកុមារិកាធម៌ហើយ ។ នាងឆ្លើយថា ចាំបិតា ព្រោះកូនមិនធ្លាប់សម្លឹងមើលបុរសណាដោយគិតចង់បានឡើយ ។ ឧបាសកនោះ លួងលោមកូនស្រីហើយរៀបការឲ្យ បញ្ជូនកូនស្រីទៅកាន់ត្រកូលស្វាមី ហើយគិតថា អញនឹងទៅថ្វាយបង្គំព្រះសាស្តា កាន់គ្រឿងក្រអូបនិងកម្រងផ្កាជាដើមទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ បូជាគ្រឿងក្រអូបនិងកម្រងផ្កាហើយអង្គុយក្នុងទីដ៏សមគួរមួយ កាលព្រះ-សម្មាសម្ពុទ្ធត្រាស់ថា ម្នាលឧបាសក អ្នកទៅណាបាត់យូរម៉្លេះ? ក៏ក្រាបទូលរឿងនោះចំពោះទ្រង់ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ឧបាសក កុមារិកានោះ ដល់ព្រមដោយមារយាទនិងសីលមកយូរហើយ ម្យ៉ាងទៀត អ្នកមិនមែនទើបតែពិសោធនាងយ៉ាងនេះ ក្នុងជាតិនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ធ្លាប់ពិសោធនាងដែរ កាលឧបាសកនោះក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វជារុក្ខទេវតាអាស្រ័យនៅក្នុងព្រៃនោះ ។ រឿងរ៉ាវមានដូច្នេះថា កាលនោះ នៅក្នុងនគរពារាណសី មានអ្នកលក់បន្លែម្នាក់ ... រឿងតទៅដូចរឿងក្នុងបច្ចុប្បន្ននេះឯង ខុសត្រង់កន្លែងដែលនាងកាលត្រូវឪពុកចាប់ដៃដើម្បីសាកល្បងភ្លាម ក៏ស្រែកយំពោលគាថានេះថា

**យោ ទុក្ខផុដ្ឋាយ ភវេយ្យ តាណំ**
**សោ មេ បិតា ទុព្ភិ វនេ ករោតិ**
**សា កស្ស កន្ទាមិ វនស្ស មជ្ឈេ**
**យោ តាយិតា សោ សហសា ករោតីតិ ។**

*បុគ្គលណាគប្បីជាទីពឹងរបស់ខ្ញុំ ដែលមានទុក្ខពាល់ត្រូវហើយ បុគ្គលនោះឈ្មោះថាជាបិតារបស់ខ្ញុំ នឹងធ្វើនូវការប្រទូស្តក្នុងព្រៃ ខ្ញុំនោះកន្ទក់កន្ទេញ ក្នុងកណ្ដាលព្រៃ ដើម្បីបុគ្គលដូចម្ដេច បុគ្គលណាជាអ្នករក្សា បុគ្គលនោះនឹងធ្វើនូវកម្មដ៏ខ្លាំងក្លា (មេថុន) ។*

*បណ្ដាបទទាំងនោះ បទថា* **យោ ទុក្ខផុដ្ឋាយ ភវេយ្យ តាណំ** *សេចក្ដីថា កាលទុក្ខផ្លូវកាយទុក្ខផ្លូវចិត្តមកដល់ព្រម អ្នកណាគប្បីជាទីពឹង គឺជាទីពំនាក់ ។*

*បទថា* **សោ មេ បិតា ទុព្ភិ វនេ ករោតិ** *សេចក្ដីថា បុគ្គលនោះគឺជាបិតារបស់ខ្ញុំ ធ្លាប់ជួយការពារទុក្ខឲ្យ កំពុងធ្វើកម្មដែលដាច់មេត្តាដែលគួរឲ្យស្អប់ខ្ពើមកណ្ដាលព្រៃនេះឯង គឺកំពុងគិតនឹងធ្វើការប្រទូស-រ៉ាយចំពោះកូនស្រីដែលខ្លួនផ្ដល់កំណើតឲ្យ ។*

*ដោយបទថា* **កស្ស កន្ទាមិ** *នេះ នាងសម្ដែងថា ខ្ញុំនឹងកន្ទក់កន្ទេញយំរកអ្នកណា គឺអ្នកណានឹងមកជាទីពឹងឲ្យខ្ញុំ ។*

*បទថា* **យោ តាយិតា សោ សហាសា ករោតិ** *សេចក្ដីថា អ្នកណាទឹងការពារឃុំគ្រងខ្ញុំ គួរជាទីពឹងពំនាក់បាន អ្នកនោះគឺបិតាតែម្នាក់ កំពុងធ្វើកម្មដ៏គួរឲ្យអាម៉ាស់ ។*

*គ្រានោះ ឧបាសកក៏លួងលោមកូនស្រីហើយសួរថា កូនសម្លាញ់ កូនឯងរក្សាខ្លួនបានហើយឬ?*

*នាងឆ្លើយថា បពិត្របិតា ខ្ញុំរក្សាខ្លួនឯងបានហើយ ។ ឧបាសកនោះក៏នាំកូនស្រីមកផ្ទះ ប្រដាប់តាក់តែងឲ្យ ធ្វើមង្គលការហើយបញ្ជូនទៅកាន់ត្រកូលស្វាមី ។*

*ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈ ពេលចប់សច្ចៈ ឧបាសកនោះបានសម្រេចសោតាបត្តិផល ។ ទ្រង់ប្រជុំជាតកថា បិតាក្នុងកាលនោះ បានមកជាបិតាក្នុងកាលឥឡូវនេះ ធីតាក៏បានមកជាធីតា ចំណែករុក្ខទេវតាអ្នកឃើញហេតុការណ៍នោះដោយប្រចក្ស គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា បណ្ណិកជាតក ទី ២ ។

# អដ្ឋកថា ទេរិវាតក ទី ៣

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ អនាថបិណ្ឌិកសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យត្ថ វេរី និវីសតិ** ដូច្នេះជាដើម ។

បានឮថា អនាថបិណ្ឌិកសេដ្ឋីទៅកាន់ស្រុកសួយហើយ កំពុងធ្វើដំណើរត្រឡប់មកវិញ ក៏ជួបពួកចោរតាមផ្លូវគិតថា មិនគួរសម្រាកតាមផ្លូវ ត្រូវទៅឲ្យដល់នគរសាវត្ថី ហើយបររទេះមកកាន់នគរសាវត្ថីយ៉ាងលឿន ព្រឹកឡើងទៅកាន់ព្រះវិហារក្រាបទូលរឿងនោះចំពោះព្រះបរមសាស្តា ។ ព្រះបរមសាស្តាត្រាស់ថា ម្នាលគហបតី សូម្បីកាលពីមុនបណ្ឌិតបានជួបពួកចោរតាមផ្លូវហើយមិនព្រមសម្រាកតាមផ្លូវ ធ្វើដំណើរទៅរហូតដល់លំនៅរបស់ខ្លួនតែម្តង ។ កាលអនាថបិណ្ឌិកសេដ្ឋីក្រាបទូលអារាធនាហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាសេដ្ឋីមានសម្បត្តិច្រើន ។ ( ថ្ងៃមួយ ) ទៅកាន់ទីអញ្ជើញក្នុងស្រុកដើម្បីការបរិភោគ កាលធ្វើដំណើរត្រឡប់មកវិញ បានជួបពួកចោរនៅក្នុងចន្លោះផ្លូវ មិនឈប់សម្រាកតាមផ្លូវ ប្រញាប់បរគោទាំងឡាយមកកាន់លំនៅរបស់ខ្លួន បរិភោគអាហារដែលមានរសជាតដ៏ប្រណីត អង្គុយលើអាសនៈដ៏មានតម្លៃ ត្រិះរិះ

ថា អញរួចផុតអំពីកណ្ដាប់ដៃចោរ មកដល់ផ្ទះរបស់ខ្លួនដោយសិរីសួស្ដី ហើយពោលគាថានេះ ដោយអំណាចនៃឧទានថា

**យត្ថ វេរី និវីសតិ ន វសេ តត្ថ បណ្ឌិតោ**
**ឯករត្តំ ទ្វិរត្តំ វា ទុក្ខំ វសតិ វេរិសូតិ ។**

បុគ្គលមានពៀរ អាស្រ័យនៅក្នុងទីណា អ្នកប្រាជ្ញមិន
គប្បីនៅក្នុងទីនោះ បុគ្គលនៅក្នុងសម្នាក់នៃបុគ្គលមាន
ពៀរ អស់មួយរាត្រី ឬពីររាត្រី ក៏នាំមកនូវសេចក្ដីទុក្ខ ។

បណ្ដាបទទាំងនោះ បទថា **វេរី** បានដល់ បុគ្គលអ្នកមានចេតនាគិតបង្ករពៀរ ។

បទថា **និវី សតិ** ប្រែថា រមែងស្នាក់ ។

បទថា **ន វសេ តត្ថ បណ្ឌិតោ** សេចក្ដីថា បុគ្គលដែលជាសត្រូវនោះ ស្នាក់ គឺអាស្រ័យនៅទីណា បណ្ឌិត គឺអ្នកប្រកបដោយគុណជាបណ្ឌិត មិនគួរនៅទីនោះឡើយ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះបុគ្គលនៅក្នុងសម្នាក់របស់សត្រូវអស់មួយរាត្រី ឬពីររាត្រី រមែងជាទុក្ខ អធិប្បាយថា បុគ្គលកាលនៅក្នុងសម្នាក់នៃសត្រូវសូម្បីមួយថ្ងៃ ពីរថ្ងៃ ក៏ឈ្មោះថានៅជាទុក្ខទាំងអស់ ។

ព្រះបរមពោធិសត្វបន្លឺឧទានដោយប្រការដូច្នេះ ធ្វើបុណ្យមានឲ្យ

*ទានជាដើម លុះអស់ជីវិតហើយក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ក្នុងកាលនោះ* **តថាគត** *ជាសេដ្ឋីនគរពារាណសី ៕*

ចប់ អដ្ឋកថា វេរិជាតក ទី ៣ ។

# អដ្ឋកថា មិត្តវិន្ទជាតក ទី ៤

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **ចតុព្ភិ អដ្ឋជ្ឈគមា** *ដូច្នេះជាដើម ។*

*រឿងរ៉ាវគប្បីឲ្យពិស្ដារតាមន័យដែលបានពោលហើយ ក្នុង* **មិត្តវិន្ទជាតក** *ខាងដើមនោះចុះ ចំណែកជាតកនេះ ជារឿងរ៉ាវដែលកើតក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថា* **កស្សបសម្មាសម្ពុទ្ធ** *។ ក្នុងកាលនោះ នេរយិកសត្វមួយទូលខុរចក្រឆេះនៅក្នុងនរក សួរព្រះបរមពោធិសត្វថា ខ្ញុំបានធ្វើកម្មអ្វី ? ព្រះមហាសត្វឆ្លើយថា អ្នកបានធ្វើបាបកម្មនេះៗ ហើយពោលគាថានេះថា*

ចតុព្ភិ អដ្ឋជ្ឈគមា អដ្ឋាភិបិ ច សោឡស
សោឡសាភិ ច ពត្តឹស អត្រិច្ឆំ ចក្កមាសទោ
ឥច្ឆាហតស្ស បោសស្ស ចក្កំ ភមតិ មត្ថកេតិ ។

អ្នក (បេញ) អំពីវិមានិកប្រេត ៤ បានវិមានិកប្រេត ៨ (បេញ) អំពីវិមានិកប្រេត ៨ បានវិមានិកប្រេត ១៦ (បេញ) អំពីវិមានិកប្រេត ១៦ បានវិមានិកប្រេត ៣២ (ក៏នៅតែមិនស្កប់ស្កល់) ចក្រក៏វិលលើក្បាលនៃបុរស កាលប្រាថ្នា ក្នុងទីនោះៗ ទើបមកដល់កង់ចក្រ កង់ចក្រ រមែងវិលលើក្បាលបុគ្គលដែលមានសេចក្ដីប្រាថ្នាគ្របសង្កត់ ។

បណ្ដាបទទាំងនោះ បទថា **ចតុព្ភិ អដ្ឋជ្ឈគមា** សេចក្ដីថា អ្នកបានវិមានិកប្រេត ៤ នៅក្នុងចន្លោះសមុទ្រ មិនទាន់ស្កប់ស្កល់ដោយនាងវិមានិកប្រេតទាំងនោះ ទើបដើរសំដៅទៅខាងមុខ ដោយសេចក្ដីប្រាថ្នាខ្លាំងក្លា បានគ្រប់គ្រងនាងវិមានិកប្រេត ៨ នាក់ទៀត សូម្បីក្នុងបទទាំងពីរដ៏សេស ក៏មានន័យដូច្នេះដែរ ។

បទថា **អត្រិច្ឆំ ចក្កមាសទោ** សេចក្ដីថា អ្នកមិនស្កប់ស្កល់ដោយលាភរបស់ខ្លួនយ៉ាងនេះ នៅប្រាថ្នាតទៅទៀត គឺត្រូវការតទៅទៀត មិនចេះឈប់ ប្រាថ្នាលាភតទៅទៀត ពេលនេះទើបមកទូលកង់ចក្រ គឺត្រូវកង់ចក្រខែក្បាល អ្នកនោះត្រូវសេចក្ដីប្រាថ្នាកម្ចាត់ហើយ គឺត្រូវតណ្ហាកម្ចាត់ គឺចូលទៅកាត់ផ្ដាច់ហើយ ទើបកង់ចក្រវិលខែលើក្បាល បណ្ដាកង់ចក្រទាំងពីរ គឺកង់ចក្រថ្ម និងកង់ចក្រដែក ព្រះបរមពោធិសត្វឃើញកង់ចក្រដែក មុតដូចកាំបិតកោរ ខែក្បាលរបស់គេដោយអំណាចនៃការ

ខែទៅខែមក តជាប់គ្នា ទើបពោលយ៉ាងនេះ ។

លុះពោលយ៉ាងនេះហើយ ក៏ត្រឡប់ទៅកាន់ទេវលោករបស់ខ្លួន ។

ចំណែកនេរយិកសត្វនោះ កាលបាបកម្មរបស់ខ្លួនអស់ហើយ ក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្តាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា មិត្តវិន្ទក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាលឥឡូវនេះ ចំណែកទេវបុត្រ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា មិត្តវិន្ទជាតក ទី ៤ ។

# អដ្ឋកថា ទុព្វលកដ្ឋជាតក ទី ៥

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលខ្លាចស្លាប់មួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ពហុម្បេតំ វនេ កដ្ឋំ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះជាកុលបុត្រអ្នកនគរសាវត្ថី ស្តាប់ធម៌របស់ព្រះមានព្រះភាគហើយបព្វជ្ជា ជាអ្នកខ្លាចស្លាប់ក្រៃលែងណាស់ គ្រាន់តែឮសំឡេងខ្យល់បក់ សំឡេងមែកឈើធ្លាប់ធ្លាក់ ឬសំឡេងសត្វបក្សី សំឡេងសត្វចតុបាទ ក៏ខ្លាចស្លាប់ រត់ស្រែក រត់ស្រែក ហេតុត្រឹមតែការរឭកឃើញថា យើងត្រូវស្លាប់ដូច្នេះ ក៏មិនកើតមានដល់លោកឡើយ ប្រសិនបើ

លោកដឹងថាយើងត្រូវស្លាប់ ក៏នឹងមិនខ្លាចស្លាប់ឡើយ ប៉ុន្តែព្រោះលោកមិនដែលចម្រើនមរណានុស្សតិកម្មដ្ឋាន ទើបខ្លាចយ៉ាងនេះ ការខ្លាចស្លាប់របស់លោកបានឮទៅដល់ពួកភិក្ខុ ។ ក្រោយមកនៅថ្ងៃមួយ ភិក្ខុទាំងឡាយលើកយករឿងនេះឡើងសន្ទនាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ ភិក្ខុឈ្មោះឯណោះខ្លាចស្លាប់ ធម្មតាភិក្ខុគួរចម្រើនមរណានុស្សតិកម្មដ្ឋានថាយើងទៀងតែស្លាប់ដូច្នេះ ។ ព្រះតថាគត ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទ្រង់ត្រាស់ឲ្យហៅភិក្ខុនោះចូលគាល់ ហើយត្រាស់សួរថា ម្នាលភិក្ខុ ពិតមែនឬ ? កាលភិក្ខុនោះក្រាបទូលថា ពិតមែនហើយព្រះអង្គ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំទោមនស្សចំពោះភិក្ខុនេះឡើយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះជាអ្នកខ្លាចស្លាប់នោះ សូម្បីកាលពីមុនភិក្ខុនេះក៏ជាអ្នកខ្លាចស្លាប់ដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជារុក្ខទេវតានៅក្នុងព្រៃហិមពាន្ត ។ ក្នុងកាលនោះ ព្រះបាទពារាណសីទ្រង់ប្រគល់មង្គលហត្ថីរបស់ព្រះអង្គឲ្យដល់ពួកហត្ថាចារ្យ ដើម្បីឲ្យហ្វឹកហាត់ដល់ហេតុនៃ

ការមិនភ្ញាក់ផ្អើល ពួកហត្ថាចារ្យក៏ចងដំរីនោះនឹងសសរដោយមិនឲ្យរើបាន មនុស្សទាំងឡាយនាំគ្នាកាន់លំពែងចាក់ជុំវិញ ធ្វើឲ្យកើតការភ័យខ្លាច ដំរីត្រូវគេចាក់ដោយលំពែងដូច្នោះ មិនអាចអត់ទ្រាំចំពោះទុក្ខវេទនាបាន ក៏ទម្លាយសសរដេញមនុស្សឲ្យរត់អស់ ហើយចូលព្រៃហិមពាន្ត ពួកមនុស្សមិនអាចចាប់ដំរីនោះបាន ក៏ត្រឡប់មកវិញ ។ ដំរីនោះបានជាសត្វខ្លាចស្លាប់ព្រោះរឿងនោះ បានឮសំឡេងខ្យល់បក់ជាដើម ក៏ខ្លាចញ័រខ្លួន បោះ-បង់ចោលហ្វូងរត់គេចយ៉ាងលឿន ដូចពេលដែលត្រូវចងជាប់នឹងសសរត្រូវចាក់ដោយលំពែងមិនឲ្យរើបានដូច្នោះ ដំរីនោះមិនបានសប្បាយកាយឬសប្បាយចិត្តឡើយ មានតែការភ័យខ្លាចញាប់ញ័រប៉ុណ្ណោះ ។ រុក្ខទេវតាឃើញដំរីនោះហើយ ឈរលើប្រគាបឈើពោលគាថានេះថា

**ពហុម្បេតំ វនេ កដ្ឋំ វាតោ ភញ្ជតិ ទុព្វលំ**
**តស្ស ចេ ភាយសិ នាគ កីសោ នូន ភវិស្សសីតិ ។**

ឈើគ្រាំគ្រា ដែលខ្យល់កាច់បំបាក់បានក្នុងព្រៃនោះ មាន
ច្រើន ម្នាលដំរី ប្រសិនបើអ្នកខ្លាចឈើនោះ អ្នកមុខជានឹង
ស្គមមិនខាន ។

ក្នុងគាថានោះ ប្រមូលអត្ថាធិប្បាយបានដូចតទៅនេះ ខ្យល់អំពីទិសទាំងឡាយ មានទិសបូព៌ាជាដើម រមែងកាច់បំបាក់ដើមឈើដែលទុព្វលណា ដើមឈើនោះមានច្រើនសន្ធឹកសន្ធាប់នៅក្នុងព្រៃនេះ គឺរក

*បានដោយងាយ មាននៅក្នុងព្រៃនោះៗ ប្រសិនបើអ្នកខ្លាចខ្យល់នោះ ក៏ត្រូវខ្លាចជានិច្ច នឹងដល់នូវការអស់សាច់អស់ឈាមមិនខាន ហេតុនោះចាប់ពីពេលនេះទៅ អ្នកកុំខ្លាចឡើយ ។*

*ទេវតាឲ្យឱវាទដំរីនោះដោយប្រការដូច្នេះ តាំងពីនោះមក ដំរីនោះក៏អស់ខ្លាច ។*

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ ហើយប្រជុំជាតកថា ដំរីក្នុងកាលនោះ បានមកជាភិក្ខុដែលខ្លាចស្លាប់ក្នុងកាលឥឡូវនេះ ចំណែករុក្ខទេវតាគឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា ទុព្វលកដ្ឋជាតក ទី ៥ ។

# អដ្ឋកថា ឧទញ្ចនីជាតក ទី ៦

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ថុល្លកុមារិកា ( ក្រមុំចាស់ ) ត្រាស់ព្រះធម្មទេសនានេះដែលមានពាក្យផ្តើមថា* ***សុខំ វត មំ ជីវន្តំ*** *ដូច្នេះជាដើម ។*

*សាច់រឿងនឹងជាក់ច្បាស់នៅក្នុង* **ចូឡនារទកស្សបជាតក តេរសកនិបាត** *នោះឯង ។ ព្រះបរមសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកចង់សឹកពិតមែនឬ ? កាលភិក្ខុនោះ*

ក្រាបទូលថា ពិតមែនហើយព្រះអង្គ ទើបទ្រង់ត្រាស់សួរតទៅទៀតថា ចិត្តរបស់អ្នកប្រតិព័ទ្ធអ្វី ? ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គស្រឡាញ់ស្រីម្នាក់ ។ គ្រានោះ ព្រះបរមសាស្តាក៏ត្រាស់ទៅកាន់ភិក្ខុនោះថា ម្នាលភិក្ខុ ស្ត្រីនេះធ្លាប់ធ្វើសេចក្តីវិនាសឲ្យអ្នក សូម្បីក្នុងកាលមុន អ្នកអាស្រ័យស្ត្រីនេះ ដល់នូវការវិនាសសីល ត្រាច់សោកសៅ ក្រោយមកអាស្រ័យបណ្ឌិតទើបបានសេចក្តីសុខ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

រឿងក្នុងអតីត តាំងតែពីពាក្យថាក្នុងអតីតកាល កាលព្រះបាទ-ព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសីជាដើម ក៏ជាក់ច្បាស់ក្នុង **ចូឡនារទកស្សបជាតក** ដែរ ។ ក្នុងកាលនោះ ព្រះមហាសត្វកាន់ផលាផលមកក្នុងវេលារសៀល បើកទ្វារបណ្ណសាលាចូលទៅបាន ពោលពាក្យនេះនឹងតាបសដែលជាបុត្តថា កូនសម្លាញ់ ថ្ងៃមុនៗ កូនឯងទៅរកឧស ដងទឹកផឹក បង្កាត់ភ្លើង ប៉ុន្តែថ្ងៃនេះមិនធ្វើសូម្បីតែម្យ៉ាង ហេតុដូចម្តេចទើបកូនឯងមានមុខក្រៀមក្រំ មិនស្រស់បស់ អង្គុយសោកសៅ ?

តាបសដែលជាបុត្តឆ្លើយថា បពិត្របិតា កាលបិតាទៅរកផលា-ផល ស្ត្រីម្នាក់មកលួងលោមខ្ញុំ បបួលខ្ញុំឲ្យទៅជាមួយ ប៉ុន្តែខ្ញុំពន្យារទុកថា ចាំបិតាអនុញ្ញាតឲ្យហើយសឹមទៅ ទើបមិនទាន់ទៅ ខ្ញុំឲ្យនាងអង្គុយរង់ចាំនៅត្រង់ទីឯណោះ បពិត្របិតាពេលនេះខ្ញុំនឹងទៅ ។ តាបសពោធិសត្វ

ដឹងថា ពេលនេះអញមិនអាចហាមបានទេ ទើបអនុញ្ញាតដោយផ្ដាំថា បើដូច្នោះ កូនឯងទៅចុះ តែនាងនាំកូនឯងទៅហើយ កាលណានាងចង់បរិភោគ ត្រី សាច់ ឬមានសេចក្ដីត្រូវការទឹកដោះ អំបិល និងអង្ករជាដើម កាលនោះនាងនឹងបង្ខិតបង្ខំកូនថា ចូរទៅរកវត្ថុនេះៗ មកឲ្យខ្ញុំ ពេលនោះចូរកូននឹកដល់គុណបិតាហើយ គប្បីគេចមកនៅទីនេះចុះ ។ តាបសនោះបានទៅកាន់ដែនដីមនុស្សជាមួយនាង ។ គ្រានោះ នាងក៏ឲ្យតាបសនោះនៅក្នុងអំណាចរបស់ខ្លួន ហើយត្រូវការវត្ថុណាៗ ក៏ប្រើឲ្យទៅរកវត្ថុនោះៗមក ដូចប្រើថា ចូរទៅរកសាច់មក ចូរទៅរកត្រីមក ។ ពេលនោះ តាបសនោះក៏គិតថា ស្រីនេះបង្ខិតបង្ខំឲ្យអញធ្វើដូចជាទាសកម្មកររបស់ខ្លួន ហើយគេចមកកាន់សម្នាក់បិតា ថ្វាយបង្គំបិតាហើយ ទាំងដែលនៅឈរនោះឯង បានពោលគាថានេះថា

**សុខំ វត មំ ជីវន្តំ   បចមានា ឧចញ្ចជី**
**ចោរី ជាយប្បវាទេន   តេលំ លោណញ្ច យាចតីតិ។**

*មេចោរដុតចំអិនល្មោភស៊ី ដូចជាភាជន៍ដងនូវទឹក រមែង*
*សូមនូវប្រេងផង នូវអំបិលផង នឹងខ្ញុំដែលធ្លាប់រស់នៅជា*
*សុខ ដោយសម្ដីហាក់ដូចជាប្រពន្ធ ។*

បណ្ដាបទទាំងនោះ បទថា **សុខំ វត មំ ជីវន្តំ** សេចក្ដីថា បពិត្របិតា ស្ត្រីនោះ ធ្វើខ្ញុំអ្នកធ្លាប់នៅជាសុខក្នុងសម្នាក់បិតាឲ្យក្ដៅក្រហាយ ។

*បទថា* **បចមានា** *សេចក្ដីថា ត្រូវវាធ្វើឲ្យក្ដៅក្រហាយ បង្ខិតបង្ខំខ្ញុំ ចង់បរិភោគវត្ថុណាៗ ក៏ទាររកវត្ថុនោះៗ ។ ស្ត្រីឈ្មោះ ឧទញ្ចនី ព្រោះនាំទៅដោយផ្ទាំង ។ បទថា* **ឧទញ្ចនី** *នេះជាឈ្មោះរបស់ស្ត្រីអ្នកដងទឹកអំពីពាងឬអំពីអណ្ដូង ស្ត្រីប្រភេទឧទញ្ចនីនោះ ចង់បានវត្ថុណាៗ ហើយក៏ប្រើឲ្យទៅរកវត្ថុនោះៗ មកឲ្យទាល់តែបាន ដូចជាដួសទឹកដោយផ្ទាំង ។*

*បទថា* **ចោរី ជាយប្បវាទេន** *សេចក្ដីថា ស្រីចោតម្នាក់អាងខ្លួនជាភរិយា លួងលោមខ្ញុំដោយពាក្យផ្អែមល្ហែម នាំទៅកាន់ដែនដីមនុស្ស នាងត្រូវការទឹកដោះ ឬអំបិលយ៉ាងណាមួយ ក៏បង្ខិតបង្ខំសុំរបស់នោះៗ គ្រប់យ៉ាង ឲ្យនាំមកឲ្យដូចជាទាសៈ ដូចជាកម្មករ ហេតុនោះ ទើបខ្ញុំពោលទោសរបស់នាង ។*

*គ្រានោះ តាបសពោធិសត្វក៏លួងលោមបុត្រថា ណ្ហើយចុះ កូនសម្លាញ់ កូនឯងចូរចម្រើនមេត្តា ករុណាចុះ ហើយប្រាប់ព្រហ្មវិហារ ៤ ប្រាប់កសិណបរិកម្ម មិនយូរប៉ុន្មានតាបសនោះក៏ញុំាងអភិញ្ញានិងសមាបត្តិឲ្យកើត បានចម្រើនព្រហ្មវិហារក្រោយអំពីចុតិ បានទៅកាន់ព្រហ្មលោកព្រមជាមួយបិតា ។*

*ព្រះបរមសាស្ដា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈ លុះចប់សច្ចៈ ភិក្ខុនោះបានសម្រេចសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ថុល្លកុមារិកាក្នុងកាលនោះ បានមកជាថុល្លកុមារិកា*

*ក្នុងកាលឥឡូវនេះ តាបសដែលជាបុត្រ បានមកជាភិក្ខុដែលអផ្សុកចង់សឹក ចំណែកតាបសដែលជាបិតា គឺ* **តថាគត** *នេះឯង ។*

ចប់ អដ្ឋកថា ឧទញ្ចនីជាតក ទី ៦ ។

# អដ្ឋកថា សាលិត្តកជាតក ទី ៧

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកសម្លាប់ហង្សមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **សាធុ ខោ សិប្បកន្នាម** *ដូច្នេះជាដើម ។*

*បានឮថា ភិក្ខុនោះ ជាកុលបុត្រអ្នកក្រុងសាវត្ថីមួយរូប ចេះចប់សាលិត្តកសិល្បៈ ដែលហៅថា សាលិត្តកសិល្បៈ បានដល់សិល្បៈក្នុងការផ្ទាត់គ្រាប់ក្រួស ។ ថ្ងៃមួយ កុលបុត្រនោះស្ដាប់ធម៌ហើយ មានសទ្ធាបួសថ្វាយជីវិតចំពោះព្រះសាសនា បានឧបសម្បទាហើយ ប៉ុន្តែមិនមែនជាអ្នកប្រាថ្នាការសិក្សា មិនមែនជាអ្នកញុំាងការបដិបត្តិឲ្យសម្រេច ។ ថ្ងៃមួយ ភិក្ខុនោះបបួលភិក្ខុកម្លោះមួយរូបទៅកាន់ស្ទឹងអចិរវតី ស្រង់ទឹកហើយគង់ហាលថ្ងៃលើមាត់ស្ទឹង ពេលនោះ ហង្សពណ៌សពីរហើរមកតាមអាកាស ភិក្ខុនោះក៏ពោលទៅកាន់ភិក្ខុកម្លោះនោះថា ខ្ញុំនឹងផ្ទាត់គ្រាប់ក្រួសប្រហារហង្សមួយក្រោយឲ្យចំភ្នែក ឲ្យធ្លាក់ចុះមកក្បែរជើងលោក ។*

*ភិក្ខុមួយរូបទៀតសួរថា លោកនឹងធ្វើវាឲ្យធ្លាក់បានដូចម្ដេច ?*

លោកមិនអាចប្រហារវាបានទេ ។

ភិក្ខុនោះឆ្លើយថា រឿងនោះលើកទុកសិនចុះ ខ្ញុំនឹងប្រហារវាឲ្យបំភ្នែកខាងនោះ ឲ្យធ្លុះមកខាងនេះ ។

ភិក្ខុកម្លោះនោះក៏ពោលជំទាស់ថា លោកពោលពាក្យមិនពិត ។

ភិក្ខុនោះប្រាប់ថា បើដូច្នោះ លោកចាំមើលចុះ ហើយចាប់គ្រាប់ក្រួសដែលមានជ្រុងមុត ១ គ្រាប់ អង្អែលដោយម្រាមដៃចង្អុល ហើយផ្ទាត់ទៅខាងក្រោយហង្សនោះ គ្រាប់ក្រួសនោះបញ្ចេញសំឡេងឮសូរដូចសំឡេងឃ្មុំហើរ ហង្សគិតថា ប្រហែលជាមានអន្តរាយ បែរមកដោយបំណងនឹងស្តាប់សំឡេងនោះ ភិក្ខុនោះក៏រើសគ្រាប់ក្រួស ១ គ្រាប់ទៀតទុក ពេលនោះ កាលហង្សងាកក្រោយនោះ ក៏ផ្ទាត់ទៅចំភ្នែកម្ខាងទៀត គ្រាប់ក្រួសធ្លុះទៅដល់ភ្នែកម្ខាងទៀត ហង្សស្រែកដោយសំឡេងខ្លាំង រួចធ្លាក់ចុះមកជិតជើងភ្នាម ពួកភិក្ខុមកអំពីទីផ្សេងៗតិះដៀលថា លោកធ្វើអំពើនេះមិនសមគួរឡើយ ហើយនាំភិក្ខុនោះទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលរឿងនោះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុរូបនេះធ្វើកម្មឈ្មោះនេះ ។ ព្រះបរមសាស្តាទ្រង់តិះដៀលភិក្ខុនោះ រួចទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះជំនាញក្នុងសិល្បៈនោះ សូម្បីក្នុងកាលមុនក៏បានជាអ្នកជំនាញហើយដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាអាមាត្យនៃព្រះរាជាអង្គនោះ ។ គ្រានោះ បុរោហិតរបស់ព្រះរាជាជាអ្នកមានមាត់រឹងក្រៃលែងចូលចិត្តនិយាយ កាលបើគាត់ចាប់ផ្តើមនិយាយហើយ អ្នកដទៃនឹងមិនមានឱកាសបាននិយាយឡើយ ។ ចំណែកព្រះបាទពារាណសីទ្រង់ព្រះ-តម្រិះថា កាលណាហ្ន៎ ទើបយើងនឹងបានមនុស្សអ្នកជួយស្កាត់ពាក្យសម្តីរបស់បុរោហិតបាន ។ តាំងពីពេលនោះមក ព្រះរាជាទ្រង់ស្វែងរកមនុស្សបែបហ្នឹងម្នាក់ ។ គ្រានោះ នៅក្នុងនគរពារាណសីមានបុរសខ្វិនម្នាក់ ជំនាញក្នុងសិល្ប: គឺការផ្ទាត់គ្រាប់ក្រួស ពួកក្មេងអ្នកស្រុកលើកបុរសខ្វិននោះឡើងកាន់រថ នាំគ្នារុញមកកាន់ទីជិតដើមជ្រៃ ដែលមានស្លឹកច្រើនមួយដើម ដែលនៅក្បែរខ្លោងទ្វារនគរពារាណសី នាំគ្នាអង្គុយជុំវិញ ហើយឲ្យប្រាក់មានមួយកាកណិក[១] ជាដើម ស្រែកប្រាប់ថា ចូរធ្វើរូបដំរី ចូរធ្វើរូបសេះ បុរសខ្វិននោះ ក៏ផ្ទាត់គ្រាប់ក្រួសបង្ហាញរូបផ្សេងៗ នៅនឹងស្លឹកជ្រៃទាំងឡាយ ស្លឹកជ្រៃទាំងឡាយសុទ្ធតែមានប្រហោងតូច ប្រហោងធំទាំងអស់ ។ គ្រានោះ ព្រះបាទពារាណសីស្តេចយាងទៅកាន់ព្រះរាជឧទ្យាន*

---

*១- ប្រាក់ដែលមានតម្លៃល្មមទិញសាច់ឲ្យក្អែកស៊ីឆ្អែត ។*

ស្តេចទៅដល់ទីនោះ ពួកក្មេងៗក៏នាំគ្នារត់អស់ ព្រោះខ្លាចត្រូវបណ្តេញចេញ ចំណែកបុរសខ្វិនពួននៅទីនោះឯង ។ ព្រះរាជាស្តេចយាងទៅដល់ដើមជ្រៃនោះ ទ្រង់គង់ក្នុងរាជរថនោះឯង ទតឃើញស្រមោលផ្សេងៗ ព្រោះស្លឹកឈើទាំងឡាយដាច់មានប្រហោង ទ្រង់សម្លឹងមើល លុះឃើញស្លឹកឈើទាំងឡាយដេរដាសទៅដោយរូប ក៏ត្រាស់សួរថា ស្លឹកឈើទាំងនេះអ្នកណាធ្វើឲ្យទៅជាយ៉ាងនេះ ? រាជបុរសក្រាបទូលថា បពិត្រព្រះ-សម្មតិទេព បុរសខ្វិនជាអ្នកធ្វើ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អាស្រ័យបុរសនេះ អញអាចទប់ស្កាត់ពាក្យសម្តីរបស់ព្រាហ្មណ៍បាន ទើបត្រាស់សួរថា នៃអ្នកទាំងឡាយ បុរសខ្វិននោះនៅឯណា ? រាជបុរសដើររក ក៏ឃើញបុរសខ្វិននោះនៅពួនក្រោមដើមឈើក៏នាំមក ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរសខ្វិននេះឯង ។ ព្រះរាជាត្រាស់ឲ្យចូលគាល់ ហើយទ្រង់បញ្ជាឲ្យបរិស័ទចេញទៅឆ្ងាយ ទើបត្រាស់សួរថា នៅក្នុងសម្នាក់របស់យើង មានព្រាហ្មណ៍មាត់ច្រើនម្នាក់ អ្នកអាចធ្វើឲ្យព្រាហ្មណ៍នោះឈប់មាត់បានទេ ? បុរសខ្វិនក្រាបទូលថា កាលបានអាចម៍ពពែប្រមាណ ១ នាឡិ ទូលបង្គំក៏អាចធ្វើបាន ។ ព្រះរាជាត្រាស់ឲ្យរាជបុរសនាំបុរសខ្វិននោះចូលទៅកាន់ព្រះរាជវាំង ឲ្យអង្គុយខាងក្នុងវាំងនន ចោះវាំងននឲ្យមានប្រហោង ទ្រង់បញ្ជាឲ្យចាត់ចែងទីអង្គុយរបស់ព្រាហ្មណ៍ត្រង់ប្រហោងវាំងនន ហើយឲ្យដាក់អាចម៍ពពែស្ងួតប្រមាណមួយនាឡិជិតបុរសខ្វិន ។

ពេលព្រាហ្មណ៍មកគាល់ ទ្រង់ត្រាស់ឲ្យអង្គុយលើអាសនៈនោះ ទ្រង់ផ្ដើមរឿងសន្ទនាឡើង ។ ព្រាហ្មណ៍មិនព្រមឲ្យឱកាសដល់អ្នកដទៃៗ ផ្ដើមក្រាបទូលព្រះរាជា ។ គ្រានោះ បុរសខ្វិនក៏ផ្ទាត់អាចម៍ពពែម្ដងមួយគ្រាប់ៗ តាមប្រហោងវាំងននធ្វើឲ្យអាចម៍ពពែចូលទៅក្នុងមាត់ព្រាហ្មណ៍នោះ គ្រប់ពេលដែលគាត់ហាមាត់និយាយ ដូចបោះដាក់កំប្រោងដូច្នោះ ព្រាហ្មណ៍ក៏លេបអាចម៍ពពែដែលផ្ទាត់មកហើយ ម្ដងមួយគ្រាប់ៗ ដូចច្រកប្រេងដាក់នាឡិ ។ បុរសខ្វិនផ្ទាត់អាចម៍ពពែអស់មួយនាឡិ អាចម៍ពពែប្រមាណមួយនាឡិនោះ ចូលទៅក្នុងពោះព្រាហ្មណ៍ប្រមាណពាក់កណ្ដាលអាឡ្ហក ។ ព្រះរាជាទ្រង់ជ្រាបថា អាចម៍ពពែអស់ហើយ ក៏ត្រាស់ថា នែអាចារ្យ លោកលេបអាចម៍ពពែអស់ទាំងនាឡិ ព្រោះជាមនុស្សមាត់ច្រើន លោកមិនទាន់ដឹងខ្លួនទៀតឬ ? ពោះរបស់លោកនឹងមិនអាចឲ្យអាចម៍ពពែច្រើនជាងនេះរលាយបានទេ ចូរទៅផឹកថ្នាំបញ្ចុះ ធ្វើខ្លួនឲ្យប្រាសចាករោគចុះ ។ ចាប់ពីពេលនោះមក ព្រាហ្មណ៍ដូចមានមាត់ត្រូវបិទជិត សូម្បីអ្នកណានិយាយក៏មិនហ៊ាននិយាយជាមួយ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា បុរសនេះធ្វើសេចក្ដីសុខឲ្យដល់អញ ព្រះរាជទានស្រុកសួយ ៤ ក្នុងទិសទាំង ៤ ដោយមានសួយប្រមាណ ១ សែនកហាបណៈ ។ ព្រះបរមពោធិសត្វចូលគាល់ព្រះរាជាហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព ធម្មតាសិល្បៈក្នុងលោក បណ្ឌិតទាំងឡាយគប្បីរៀន សូម្បីតែការផ្ទាត់គ្រាប់ក្រួសក៏នៅ

ជួយឲ្យបុរសខ្វិនបានសម្បត្តិនេះ ហើយពោលគាថានេះថា

**សាធុ ខោ សិប្បកន្នាម អបិ យាទិសកីទិសំ**

**បស្ស ខញ្ជប្បហារេន លទ្ធា គាមា ចតុទ្ទិសាតិ ។**

ធម្មតាសិល្បសាស្ត្រយ៉ាងណាក៏ដោយ សុទ្ធតែសម្រេចប្រយោជន៍ សូមព្រះអង្គទត ស្រុកសួយទាំង ៤ ទិស ដែលបុរសខ្វិនបាន ហើយ ដោយការផ្ទាត់ (អាចម៍ពពែ) នៃបុរសខ្វិន ។

បណ្តាបទទាំងនោះ បទថា **បស្ស ខញ្ជប្បហារេន** សេចក្តីថា ព្រះមហាសត្វពោលសរសើរគុណនៃសិល្បសាស្ត្រថា បពិត្រព្រះសម្មតិ-ទេព សូមព្រះអង្គទត បុរសខ្វិននេះបានទទួលព្រះរាជទានស្រុកសួយទាំង ៤ ទិស ក៏ដោយការផ្ទាត់អាចម៍ពពែ អ្វីជាប្រការដែលកំណត់អានិសង្សនៃសិល្បៈដទៃៗ ទៅ ។

ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា បុរសខ្វិនក្នុងកាលនោះ បានមកជាភិក្ខុដែលជំនាញក្នុងសិល្បៈ ក្នុងកាលឥឡូវនេះ ព្រះរាជាបានមកជាអានន្ទ ចំណែកអាមាត្យដែលជាបណ្ឌិត គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា សាលិត្តកជាតក ទី ៧ ។

# អដ្ឋកថា ពាហិយជាតក ទី ៨

ព្រះបរមសាស្តា កាលទ្រង់អាស្រ័យនគរវេសាលី ទ្រង់គង់នៅក្នុងកូដាគារសាលានាព្រៃមហាវន ទ្រង់ប្រារព្ធស្តេចលិច្ឆវីមួយអង្គ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សិក្ខេយ្យ សិក្ខិតព្វានិ** ដូច្នេះជាដើម ។

បានឮថា ស្តេចលិច្ឆវីអង្គនោះទ្រង់មានសទ្ធាជ្រះថ្លា និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ទ្រង់ញុំាងមហាទានឲ្យប្រព្រឹត្តទៅក្នុងវាំងរបស់ព្រះអង្គ ប៉ុន្តែទេវីរបស់ព្រះអង្គមានអវយវៈគ្រប់កន្ទែងជាត់ មើលទៅដូចជាសាកសពហើមប៉ោង មិនសម្បូរដោយមារយាទ ។ ព្រះបរមសាស្តាទ្រង់ធ្វើអនុមោទនាក្នុងពេលស្រេចភត្តកិច្ចហើយ ស្តេចយាងទៅកាន់ព្រះវិហារប្រទានឱវាទដល់ភិក្ខុទាំងឡាយ ស្តេចចូលកាន់ព្រះគន្ធកុដិ ។ ភិក្ខុទាំងឡាយនាំគ្នាផ្តើមរឿងសន្ទនាគ្នាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយស្តេចលិច្ឆវីអង្គនោះ មានព្រះរូបឆោមលោមស្អាត តែព្រះទេវីមានលក្ខណៈផ្ទុយ មានអវយវៈតូចធំនោះជាត់ មិនមានកិរិយាមារយាទ ស្តេចលិច្ឆវីអង្គនោះ នឹងអភិរម្យជាមួយនឹងព្រះទេវីនោះបានដូចម្តេច ។ ព្រះបរមសាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ

ទាំងឡាយ ស្តេចលិច្ឆវីអង្គនេះ មិនមែនតែពេលនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ទ្រង់អភិរម្យជាមួយនឹងស្ត្រីដែលមានរាងកាយជាត់ដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាអាមាត្យរបស់ព្រះ-អង្គ ។ គ្រានោះ ស្ត្រីជនបទម្នាក់មានរាងកាយជាត់ មិនមានមារយាទ ធ្វើការបម្រើគេ ដើរឆ្វេងកាត់ទៅមកមិនឆ្ងាយអំពីលានព្រះរាជវាំង ឈឺឧច្ចារៈក៏យកសំពត់ដណ្តប់ទទូរក្បាលអង្គុយបន្ទោបង់ឧច្ចារៈ ហើយប្រញាប់ក្រោកឡើង ។ ពេលនោះ ព្រះបាទពារាណសីទ្រង់ទតលានព្រះរាជវាំងតាមសីហបញ្ជរ ទ្រង់ឃើញនាងហើយ ទ្រង់ព្រះតម្រិះថា ស្ត្រីនេះបន្ទោបង់ឧច្ចារៈក្នុងលានព្រះរាជវាំងយ៉ាងនេះ មិនបានលះបង់ហិរិនិងឱត្តប្បៈ យកសំពត់ដណ្តប់គ្របក្បាលបន្ទោបង់ឧច្ចារៈហើយប្រញាប់ក្រោកឡើង ប្រហែលជានាងជាស្ត្រីមិនមានរោគ វត្ថុរបស់នាងប្រាកដជាបរិសុទ្ធ កូនម្នាក់ដែលបានអាស្រ័យវត្ថុបរិសុទ្ធ នឹងជាអ្នកបរិសុទ្ធមានបុណ្យ អញគួរតែតែងតាំងនាងជាអគ្គមហេសី ទ្រង់ជ្រាបថា នាងមិនទាន់មានគូគ្រង ក៏ត្រាស់បញ្ជាឲ្យអភិសេកនាងជាអគ្គមហេសី ។ ស្រីនោះបានជាទីប្រោសប្រាណនៃព្រះរាជា មិនយូរប៉ុន្មានក៏ប្រសូតព្រះឱរសមួយព្រះអង្គ ហើយព្រះឱរសរបស់ព្រះនាងក៏បានជាស្តេចចក្រពត្តិ ។ ព្រះមហាបុរសឃើញការដល់

*ព្រមដោយយសរបស់ព្រះនាង បានឱកាសដែលនឹងក្រាបទូលដូច្នោះបាន ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ដែលឈ្មោះថាសិល្បៈគួរសិក្សា អ្វីដែលមិនគួរសិក្សាទៅ ប៉ុន្តែព្រះអគ្គមហេសីអ្នកមានបុណ្យច្រើន ព្រះនាងមិនលះបង់ហិរិនិងឱត្តប្បៈ ទ្រង់ធ្វើសរីរវលញ្ជៈដោយអាការបិទបាំង នៅធ្វើឲ្យព្រះអង្គប្រោសប្រាណបាន ព្រះនាងសម្រេចសម្បត្តិបែបនេះបាន កាលនឹងក្រាបទូលគុណនៃសិល្បៈដែលគួរសិក្សាទាំងឡាយ ទើបពោលគាថានេះថា*

**សិក្ខេយ្យ សិក្ខិតព្វានិ សន្តិ តច្ឆន្ទិនោ ជនា**
**ពាហិយាបិ សុហន្នេន រាជានំ អភិរាធយីតិ ។**

*ជនគប្បីសិក្សានូវកិច្ចដែលត្រូវសិក្សា ពួកជន រមែងមានសេចក្តីពេញចិត្តក្នុងកិច្ចនោះ ចំណែកស្រីអ្នកស្រុកពាហិយៈ បានញុំាងព្រះរាជាឲ្យត្រេកអរ ដោយការខ្មាសអៀន (របស់ខ្លួន) ។*

*បណ្តាបទទាំងនោះ បទថា* **សន្តិ តច្ឆន្ទិនោ ជនា** *សេចក្តីថា ពួកជនដែលមានសេចក្តីពេញចិត្តចំពោះសិល្បៈទាំងនោះ គង់មានជាប្រាកដ ។*

*បទថា* **ពាហិយា** *បានដល់ ស្ត្រីដែលកើត ចម្រើនធំពេញវ័យក្នុងជនបទខាងក្រៅ ។ បទថា* **សុហន្នេន** *សេចក្តីថា មិនលះបង់ហិរិនិងឱត្តប្បៈ បន្ទោបង់ដោយអាការបិទបាំង ឈ្មោះថាអាការដ៏កំបាំង បន្ទោបង់*

ដោយអាការខ្មាសអៀននោះ ។

បទថា **រាជានំ អភិរាធយិ** សេចក្ដីថា បានញុំាំងព្រះរាជាឲ្យទ្រង់ត្រេកអរ បាននូវសម្បត្តិបែបនេះ ។

ព្រះពោធិសត្វពោលដល់គុណនៃសិល្បៈទាំងឡាយ ដែលសមគួរដល់គុណតម្លៃនៃការសិក្សា ដោយប្រការដូច្នេះ ។

ព្រះបរមសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា គូស្វាមីភរិយាក្នុងកាលនោះ បានមកជាគូស្វាមីភរិយាក្នុងកាលឥឡូវនេះ ចំណែកអាមាត្យដែលជាបណ្ឌិត គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ពាហិយជាតក ទី ៨ ។

# អដ្ឋកថា កុណ្ឌកបូវជាតក ទី ៩

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងនគរសាវត្ថី ទ្រង់ប្រារព្ធបុរសអ្នកក្រីក្រម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យថន្នោ បុរិសោ ហោតិ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា នៅក្នុងនគរសាវត្ថី ពេលខ្លះមានត្រកូលតែមួយប៉ុណ្ណោះ ថ្វាយមហាទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ពេលខ្លះមាន ៣-៤ ត្រកូលរួមគ្នា ពេលខ្លះដោយការរួមដៃគ្នាជាគណៈ ពេលខ្លះ ដោយការរួមចិត្តគ្នានៃអ្នកដែលនៅរួមថ្នល់ ពេលខ្លះ រួមមនុស្សដែល

មានឆន្ទៈ មានការពេញចិត្តអស់ទាំងក្រុងថ្វាយមហាទានចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ក្នុងគ្រានោះ ភត្តដែលមានឈ្មោះថា វិថីភត្ត (គឺការថ្វាយភត្តាហាររបស់អ្នកដែលរស់នៅរួមថ្នល់ ) ក៏កើតមានឡើង ។ គ្រានោះ មនុស្សទាំងឡាយពោលពាក្យបបួលគ្នាថា អញ្ជើញអ្នកទាំង-ឡាយថ្វាយយាគូ នាំខាទនីយៈ (របស់គួរទំពា ) មកប្រគេនភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានចុះ ។ ក្នុងកាលនោះ មានកូនឈ្នួលនៃអ្នកដទៃម្នាក់ ជាអ្នកក្រីក្រនៅក្នុងថ្នល់នោះ គិតថា អញមិនអាចថ្វាយយាគូបាន តែរបស់គួរបរិភោគអាចចាត់ចែងថ្វាយបាន ហើយប្រចាប់កុណ្ឌកឲ្យល្អិតជ្រលក់ទឹក ខ្ចប់ដោយស្លឹករាក់យកទៅដុត គិតថា អញនឹងថ្វាយនំនេះចំពោះព្រះសម្ពុទ្ធ កាន់នំនោះទៅឈរនៅក្នុងសម្នាក់ព្រះបរមសាស្តា គ្រាន់តែព្រះបរមសាស្តាទ្រង់ត្រាស់ថា អ្នកទាំងឡាយចូរនាំយកខាទនីយៈមកចុះ ក៏ទៅមុនគេបង្អស់ដាក់នំនោះក្នុងបាត្រព្រះបរមសាស្តា ហើយឈរនៅក្នុងទីដ៏សមគួរមួយ ព្រះបរមសាស្តា ទ្រង់មិនទទួលខាទនីយៈ អំពីអ្នកដទៃទៀត ទ្រង់សោយតែនំនោះប៉ុណ្ណោះ ។

គ្រានោះឯង នគរទាំងមូលក៏មានសំឡេងផ្សាយទៅថា បានឮថាព្រះសម្មាសម្ពុទ្ធទ្រង់មិនខ្ពើមនំដែលធ្វើអំពីកុណ្ឌក របស់មហាទុគ្គតបុរសទ្រង់សោយដូចសោយអមតភោជនដូច្នោះ ។ ឥស្សរជនមានព្រះរាជានិងអាមាត្យរបស់ព្រះរាជាជាដើម រហូតដល់អ្នកយាមទ្វារប្រជុំគ្នាទាំងអស់

ថ្វាយបង្គំព្រះបរមសាស្តា ហើយចូលទៅរកមហាទុគ្គតបុរសពោលថា បាមហាចម្រើន សូមអ្នកទទួលយកទ្រព្យ ១ រយ ២ រយ ៥ រយ ហើយឲ្យចំណែកបុណ្យដល់ពួកយើងចុះ ។ មហាទុគ្គតបុរសឆ្លើយថា ចាំក្រាបទូលសួរព្រះបរមសាស្តាសិន ទើបដឹង ហើយទៅកាន់សម្នាក់ព្រះបរមសាស្តាក្រាបទូលរឿងនោះ ។ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលទុគ្គត អ្នកចូរទទួលយកទ្រព្យហើយឲ្យចំណែកបុណ្យដល់សព្វសត្វចុះ ។ មហាទុគ្គតបុរសផ្តើមទទួលយកទ្រព្យ មនុស្សទាំងឡាយនាំគ្នាឲ្យដោយការប្រមូលឲ្យជាទ្វេគុណ ចតុគុណ និងអដ្ឋគុណជាដើម បានឲ្យទ្រព្យដល់ ៩ កោដិ ។ ព្រះបរមសាស្តាទ្រង់ធ្វើអនុមោទនាហើយ ស្តេចយាងទៅកាន់ព្រះវិហារ កាលពួកភិក្ខុសម្តែងវត្តបដិបត្តិហើយ ទ្រង់ប្រទានសុគតោវាទ ស្តេចចូលកាន់ព្រះគន្ធកុដិ ។ វេលារសៀលថ្ងៃនោះ ព្រះរាជាត្រាស់ឲ្យមហាទុគ្គតបុរសចូលគាល់ ទ្រង់បូជាដោយតំណែងសេដ្ឋី ។ ពួកភិក្ខុផ្តើមរឿងសន្ទនាគ្នាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ ព្រះសម្មាសម្ពុទ្ធទ្រង់មិនខ្ពើមនំដែលធ្វើអំពីកុណ្ឌកដែលមហាទុគ្គតបុរសថ្វាយឡើយ ទ្រង់សោយដូចសោយអមតភោជន ចំណែកមហាទុគ្គតបុរសបានទ្រព្យដ៏ច្រើនផង បានទាំងតំណែងសេដ្ឋីផង ដល់នូវសម្បត្តិដ៏ក្រៃលែង ។ ព្រះតថាគត ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយ អង្គុយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាប

ទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលតថាគតមិនខ្ពើមសោយនំកុណ្ឌករបស់មហាទុគ្គតបុរសនោះ សូម្បីកាលដែលតថាគតជារុក្ខទេវតាក្នុងកាលមុនក៏ធ្លាប់សោយដែរ ក្នុងកាលនោះមហាទុគ្គតបុរសអាស្រ័យតថាគតក៏បានតំណែងសេដ្ឋីដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាទេវតានៅនឹងដើមល្ហុងមួយដើម ។ គ្រានោះ ពួកមនុស្សនៅនឹងស្រុកនោះ នាំគ្នាកាន់យករុក្ខទេវតាជាមង្គល កាលដល់ថ្ងៃមហោស្រពមួយ ពួកមនុស្សនាំគ្នាធ្វើពលិកម្មដល់រុក្ខទេវតារៀងៗខ្លួន ។ គ្រានោះ មានទុគ្គតបុរសម្នាក់ឃើញមនុស្សទាំងនោះនាំគ្នាគោរពទេវតា ក៏គោរពដើមល្ហុងមួយដើម មនុស្សទាំងនោះកាន់យកផ្កា គ្រឿងក្រអូប គ្រឿងលាប និងរបស់បរិភោគជាដើមយ៉ាងច្រើនទៅដើម្បីបូជាទេវតារបស់ខ្លួន ។ ចំណែកទុគ្គតបុរសមានតែនំកុណ្ឌក ក៏កាន់យកទៅជាមួយនឹងប្មោយដងទឹក ឈប់ឈរនៅមិនឆ្ងាយអំពីដើមល្ហុងគិតថា ធម្មតាទេវតាតែងសោយរបស់ទិព្វ ទេវតាគង់មិនសោយនំកុណ្ឌករបស់អញទេ អញមិនសុខចិត្តឲ្យនំវិនាសទៅដោយហេតុនេះទេ អញបរិភោគនំនេះខ្លួនឯង ហើយត្រឡប់អំពីទីនោះ ។ ព្រះមហាសត្វស្ថិតនៅ

លើដើមល្ហុងពោលថា នៃបុរសដ៏ចម្រើន ប្រសិនបើអ្នកជាអ្នកមាន ក៏ត្រូវឲ្យរបស់បរិភោគឆ្ងាញ់ដល់ខ្ញុំ ប៉ុន្តែអ្នកជាទុគ្គតបុរស ខ្ញុំមិនសោយនំរបស់អ្នក ហើយទៅសោយនំរបស់អ្នកដទៃដូចម្ដេចបានទៅ កុំធ្វើឲ្យនំចំណែករបស់ខ្ញុំត្រូវវិនាសឡើយ ហើយពោលគាថានេះថា

**យថន្នោ បុរិសោ ហោតិ តថន្នា តស្ស ទេវតា**
**អាហរេតំ កុណ្ឌបូវំ មា មេ ភាគំ វិនាសយាតិ ។**

បុរសស៊ីយ៉ាងណា ទេវតារបស់បុរសនោះ ក៏ស៊ីយ៉ាងនោះដែរ អ្នកចូរនាំយកនូវនំកុណ្ឌកនុំះមក អ្នកកុំញុំាំងនំកុណ្ឌក ជាចំណែករបស់ខ្ញុំឲ្យវិនាសទៅ ។

បណ្ដាបទទាំងនោះ បទថា **យថន្នោ** សេចក្ដីថា អ្នកបរិភោគយ៉ាងណា ។

បទថា **តថន្នា** សេចក្ដីថា សូម្បីទេវតារបស់អ្នកក៏សោយយ៉ាងនោះដែរ ។

បទថា **អាហរេតំ កុណ្ឌបូវំ** សេចក្ដីថា អ្នកចូរនាំយកនំដែលធ្វើអំពីកុណ្ឌកនោះមកចុះ កុំធ្វើនំដែលជាចំណែករបស់ខ្ញុំឲ្យវិនាសឡើយ ។ ទុគ្គតបុរសបែរមកមើលព្រះមហាសត្វហើយធ្វើពលិកម្ម ។ ព្រះមហាសត្វក៏សោយឱជាអំពីនំនោះ ហើយសួរថា នៃបុរសដ៏ចម្រើន អ្នកគោរពខ្ញុំដើម្បីអ្វី ?

ទុគ្គតបុរសពោលថា បពិត្រអ្នកជាធំ ខ្ញុំជាអ្នកក្រីក្រ មកបូជាលោកក៏ដោយប្រាថ្នាថា នឹងអាស្រ័យលោកហើយ នឹងរួចផុតចាកអំពីភាពទុគ៌ត ។ ព្រះពោធិសត្វពោលថា នែបុរសដ៏ចម្រើន អ្នកកុំព្រួយឡើយ អ្នកបូជាខ្ញុំ អ្នកមានកតញ្ញូកតវេទី នៅជុំវិញដើមល្ហុងនេះ មានឆ្នាំងដាក់ទ្រព្យត្រួតលើគ្នារហូតខ្ពស់ត្រឹមក អ្នកចូរក្រាបទូលព្រះរាជាឲ្យយករទេះមកដឹកជញ្ជូនទ្រព្យទៅគរទុកនៅក្នុងលានព្រះរាជវាំងចុះ ព្រះរាជានឹងសប្បាយព្រះទ័យប្រទានតំណែងសេដ្ឋីឲ្យដល់អ្នក ។ លុះប្រាប់ដូច្នេះហើយ ព្រះបរមពោធិសត្វក៏អន្តរធានទៅ ទុគ្គតបុរសក៏ធ្វើតាមនោះ ។ ចំណែកព្រះរាជាក៏សប្បាយព្រះទ័យ ប្រទានតំណែងសេដ្ឋីដល់បុរសនោះ ។ ទុគ្គតបុរសអាស្រ័យព្រះមហាបុរសដល់ព្រមដោយសម្បត្តិដ៏ធំ ហើយក្រោយអំពីចុតិក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ទុគ្គតបុរសក្នុងកាលនោះ បានមកជាទុគ្គតបុរសក្នុងកាលឥឡូវនេះ ចំណែកទេវតាដែលនៅនឹងដើមល្ហុងនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា កុណ្ឌកបូវជាតក ទី ៩ ។

# អដ្ឋកថា សព្វសំហារកបញ្ហា ទី ១០

*បញ្ហាក្នុងរឿងគ្រឿងប្រដាប់អប់ដោយក្លិនក្រអូបគ្រប់យ៉ាង មានពាក្យផ្តើមថា* **សព្វសំហារកោ នត្ថិ** *ដូច្នេះ នឹងជាក់ច្បាស់ដោយអាការទាំងពួងក្នុង* **ឧម្មង្គជាតក** [១] *។*

ចប់ អដ្ឋកថា សព្វសំហារកបញ្ហា ទី ១០ ។

ចប់ អដ្ឋកថា បរោសតវគ្គ ទី ១១ ។

# រួមជាតកដែលមានក្នុងវគ្គនេះគឺ

*បរោសតជាតក ១ បណ្ណិកជាតក ១ វេរិជាតក ១ មិត្តវិន្ទជាតក ១ ទុព្វលកដ្ឋជាតក ១ ឧទញ្ចនីជាតក ១ សាលិត្តកជាតក ១ ពាហិយជាតក ១ កុណ្ឌកបូវជាតក ១ សព្វសំហារកបញ្ហា ១ ។*

---

*១- មហោសថជាតក ។*

# ហំសិវគ្គ ទី ១២

## អដ្ឋកថា គទ្រភបញ្ហា ទី ១

*គទ្រភបញ្ហានេះ មានពាក្យផ្ដើមថា* ហំសិ តុវំ ឯវំ មញ្ញសិ *ដូច្នេះ ក៏នឹងជាក់ច្បាស់នៅក្នុង* **ឧម្មង្គជាតក** [១] *ដែរ ៕*

ចប់ អដ្ឋកថា គទ្រភបញ្ហា ទី ១ ។

## អដ្ឋកថា អមរាទេវិបញ្ហា ទី ២

*អមរាទេវិបញ្ហានេះ មានពាក្យផ្ដើមថា* យេន សត្តុវិលង្កា ច *ដូច្នេះ ក៏នឹងជាក់ច្បាស់នៅក្នុង* **ឧម្មង្គជាតក** [២] *ដែរ ៕*

ចប់ អដ្ឋកថា អមរាទេវិបញ្ហា ទី ២ ។

---

*១-២- មហោសថជាតក ។*

# អដ្ឋកថា សិគាលជាតក ទី ៣

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សទ្ធហាសិ សិគាលស្ស** ដូច្នេះជាដើម ។

ក្នុងសម័យនោះ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា គង់សន្ទនាគ្នាអំពីទោសរបស់ភិក្ខុទេវទត្តថា អ្នកមានអាយុទាំងឡាយ ភិក្ខុទេវទត្តបបួលភិក្ខុប្រមាណ ៥០០ រូបទៅកាន់គយាសីសប្រទេស ឲ្យភិក្ខុទាំងនោះកាន់យកលទ្ធិរបស់ខ្លួនថា ព្រះសមណគោតមត្រាស់ប្រការណា ប្រការនោះមិនមែនជាធម៌ យើងពោលប្រការណា ប្រការនោះប៉ុណ្ណោះ ទើបជាធម៌ ដូច្នេះហើយធ្វើមុសាវាទដែលដល់ឋានវិបត្តិ បំបែកសង្ឃ ធ្វើឧបោសថពីរដងក្នុងសីមាជាមួយគ្នា ។ ព្រះបរមសាស្ដា ស្ដេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលទេវទត្តពោលមុសាវាទនោះ សូម្បីកាលពីមុនក៏ជាអ្នកពោលមុសាវាទដែរ ហើយទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជារុក្ខទេវតានៅក្នុង

ព្រៃស្មសាន ។ ក្នុងកាលនោះ នៅក្នុងនគរពារាណសីមានបុណ្យនក្ខត្តឫក្សអ៊ូអរណាស់ មនុស្សទាំងឡាយគិតថា ពួកយើងនឹងធ្វើពលិកម្មចំពោះយក្ស ហើយចាត់ចែងត្រីនិងសាច់ជាដើមត្រៀមទុក ចាក់សុរាជាច្រើនដាក់កែវទាំងឡាយ តម្កល់ទុកក្នុងទីនោះៗ មានផ្លូវប្រេកនិងផ្លូវបែកជាបួនជាដើម ។ គ្រានោះ មានចចកមួយចូលទៅកាន់នគរតាមប្រឡាយទឹកក្នុងវេលាអធ្រាត្រ ស៊ីត្រីនិងសាច់ជាដើម ផឹកសុរាហើយចូលទៅកាន់គុម្ពបុន្នាគដេកលក់រហូតទល់ភ្លឺ ។ ភ្ញាក់ឡើងឃើញភ្លឺហើយ គិតថា អញមិនអាចចេញទៅពេលនេះបានទេ លុះគិតដូច្នេះហើយក៏ដើរទៅជិតផ្លូវដេកលាក់ខ្លួន ពេលឃើញមនុស្សម្នាមិននិយាយអ្វីទាំងអស់ លុះឃើញព្រាហ្មណ៍កំពុងដើរពីខាងក្រោយ ក៏គិតថា ដែលឈ្មោះថាព្រាហ្មណ៍តែងតែជាអ្នកមានការល្មោភចង់បានទ្រព្យ អញត្រូវយកទ្រព្យបញ្ឆោតព្រាហ្មណ៍នេះ ធ្វើឲ្យគាត់ស្ពាយអញចេញអំពីក្រុងឲ្យទាល់តែបាន ចចកពោលពាក្យដោយភាសាមនុស្សថា អឺព្រាហ្មណ៍ ។

ព្រាហ្មណ៍បែរទៅសួរថា អ្នកណាហៅយើង ?

ចចកឆ្លើយថា ព្រាហ្មណ៍ ខ្ញុំនេះឯង ( ហៅលោក ) ។

ព្រាហ្មណ៍សួរថា ហៅយើងធ្វើអ្វី ?

ចចកឆ្លើយថា បពិត្រព្រាហ្មណ៍ ខ្ញុំមានទ្រព្យពីររយកហាបណៈ ប្រសិនបើលោកអាចបីខ្ញុំ យកសំពត់ឆៀងស្មាគ្របខ្ញុំឲ្យជិត កុំឲ្យអ្នកណា

មើលឃើញ នាំខ្ញុំចេញអំពីក្រុងបាន ខ្ញុំនឹងឲ្យកហាបណៈទាំងនោះដល់លោក ។ ដោយការល្មោភចង់បានទ្រព្យ ព្រាហ្មណ៍ក៏យល់ព្រមធ្វើតាមពាក្យរបស់ចចក ។ លុះព្រាហ្មណ៍នាំចចកចេញអំពីក្រុងបានបន្តិច ចចកក៏សួរព្រាហ្មណ៍ថា បពិត្រព្រាហ្មណ៍ ដល់ណាហើយ ?

ព្រាហ្មណ៍ក៏ឆ្លើយថា ដល់ទីឯណោះហើយ ។

ចចកប្រាប់ថា ទៅបន្តិចទៀតទៅ ចចកនិយាយយ៉ាងនោះរឿយៗ រហូតដល់ព្រៃធំទើបប្រាប់ថា ដាក់ខ្ញុំត្រង់នេះចុះ ។ លុះព្រាហ្មណ៍ដាក់ចុះភ្លាម ក៏ពោលប្រាប់ព្រាហ្មណ៍ទៀតថា បពិត្រព្រាហ្មណ៍ លោកចូរក្រាលសំពត់ឆៀងស្មានៅទីនេះចុះ ។ ព្រាហ្មណ៍ក៏ក្រាលដោយការល្មោភចង់បានទ្រព្យ ពេលនោះចចកក៏ប្រាប់ព្រាហ្មណ៍ថា ចូរជីកដើមឈើនេះចុះ ឲ្យព្រាហ្មណ៍ជីកដីទៅ រួចហើយចចកនោះឡើងជាន់សំពត់ឆៀងស្មារបស់ព្រាហ្មណ៍ បន្ទោបង់មូត្រ លាមក ៥ កន្លែង គឺត្រង់មុំទាំង ៤ និងត្រង់កណ្តាល ជូតផង ធ្វើឲ្យទទឹកផង ហើយលោតចូលព្រៃ ។ ព្រះពោធិសត្វជារុក្ខទេវតានៅលើដើមឈើពោលគាថានេះថា

**សទ្ទហាសិ សិគាលស្ស សុរាបីតស្ស ព្រាហ្មណ**
**សិប្បិកានំ សតំ នត្ថិ កុតោ កំសសតា ទុវេតិ ។**

ម្នាលព្រាហ្មណ៍ អ្នកជឿពាក្យចចកដែលផឹកសុរាដូចម្តេចបាន (សូម្បីសម្បក) ខ្យងចំនួនមួយរយ មិនមានទេ តើ

*កហាបណៈពីររយ នឹងមានមកអំពីទីណា ។*

*បណ្ដាបទទាំងនោះ បទថា* **សទ្ធហាសិ** *ប្រែថា ជឿ ។ ន័យម្យ៉ាងទៀត បាឋយ៉ាងនេះ ប៉ុន្ដែមានសេចក្ដីថា ជឿមាំ ។*

*បទថា* **សិប្បិកានំ សតំ នត្ថិ** *សេចក្ដីថា ព្រោះថា សម្បកខ្យងមួយរយ របស់វាក៏មិនមាន ។*

*បទថា* **កុតោ កំសសតា ទុវេ** *សេចក្ដីថា តើវាមានប្រាក់ពីររយកហាបណៈ មកអំពីណា ។*

*ព្រះមហាបុរសពោលគាថានេះហើយប្រាប់ថា នែព្រាហ្មណ៍ ទៅចុះ ចូរបោកសំពត់របស់អ្នក ងូតទឹកធ្វើកិច្ចរបស់ខ្លួនចុះ ពោលដូច្នោះហើយក៏អន្តរធានទៅ ។ ព្រាហ្មណ៍ក៏បានធ្វើតាមនោះ កើតទុក្ខទោមនស្សថា ឱ អញត្រូវចចកបោកប្រាស់ហើយ ហើយដើរចៀសចេញទៅ ។*

*ព្រះបរមសាស្ដា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះ បានមកជាទេវទត្ត ចំណែករុក្ខទេវតាគឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា សិគាលជាតក ទី ៣ ។

# អដ្ឋកថា មិតចិន្តិជាតក ទី ៤

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះ-ថេរៈចាស់ពីរអង្គ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ពហុចិន្តី អប្បចិន្តី** ច ដូច្នេះជាដើម ។

បានឮថា ព្រះថេរៈចាស់ពីរអង្គនោះ ចាំវស្សានៅក្នុងអរញ្ញាវាសជនបទមួយកន្លែង ប្រឹក្សាគ្នាថា យើងទាំងពីរនាក់នឹងទៅគាល់ព្រះសាស្តាហើយត្រៀមស្បៀងទុក រវល់តែផ្លាស់ប្តូរថា ទៅថ្ងៃនេះ ទៅថ្ងៃស្អែក រហូតកន្លងទៅមួយខែហើយមួយខែទៀត ទាំងអស់នេះព្រោះខ្លួនជាមនុស្សខ្ជិលច្រអូសនិងព្រោះខ្លួនជាមនុស្សហួងហែងទីលំនៅ ។ បីខែកន្លងទៅ ទើបចេញអំពីទីនោះទៅកាន់វត្តជេតពន ទុកដាក់បាត្រចីវរក្នុងលំនៅរបស់ភិក្ខុដែលខ្លួនពេញចិត្តហើយ នាំគ្នាទៅគាល់ព្រះសម្មាសម្ពុទ្ធ ។ គ្រានោះ ពួកភិក្ខុសួរព្រះថេរៈចាស់ទាំងពីររូបថា បពិត្រលោកម្ចាស់ដ៏ចម្រើន យូរណាស់ហើយ ដែលលោកម្ចាស់ទាំងពីរមិនបានមកគាល់ព្រះសាស្តា ហេតុដូចម្តេច លោកម្ចាស់ទាំងពីរខានមកយូរម្ល៉េះ ? ព្រះថេរៈចាស់ទាំងពីរអង្គក៏ប្រាប់រឿងនោះ ។ ពេលនោះ ការខ្ជិលច្រអូស ការយឺតយ៉ាវរបស់ព្រះថេរៈទាំងពីរអង្គនោះ ក៏ល្បីខ្ចរខ្ចាយទៅក្នុងពួកភិក្ខុសង្ឃ សូម្បីក្នុងធម្មសភា ពួកភិក្ខុក៏អាស្រ័យភាពខ្ជិលច្រអូសរបស់ព្រះថេរៈទាំងពីរអង្គនោះ ផ្តើមជារឿងឡើង ។ ព្រះបរមសាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ

ទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ឲ្យហៅព្រះថេរៈទាំងពីរអង្គនោះមកគាល់ ហើយទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកទាំងពីរជាអ្នកខ្ជិលច្រអូសឃឹតយ៉ាវពិតមែនឬ? កាលភិក្ខុទាំង-ពីរអង្គនោះក្រាបទូលថា ព្រះករុណាព្រះអង្គ ពិតមែនហើយ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលភិក្ខុទាំងពីរនេះជាមនុស្សខ្ជិលច្រអូសនោះ សូម្បីកាលពីមុនក៏ជាអ្នកខ្ជិលច្រអូសនិងជាអ្នកមានសេចក្តីអាល័យហួងហែងទីលំនៅដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី មានត្រី ៣ នៅក្នុងនគរពារាណសី ត្រីទាំង ៣ នោះមានឈ្មោះដូច្នេះគឺ ពហុចិន្តី អប្បចិន្តី និង មិតចិន្តី ។ ត្រីទាំង ៣ នោះនាំគ្នាចេញអំពីព្រៃមកកាន់ស្រុកមនុស្ស បណ្តាត្រីទាំង ៣ នោះ មិតចិន្តីប្រាប់ត្រីទាំងពីរថា ដែលឈ្មោះថាស្រុកមនុស្សនេះ ពេញទៅដោយការរង្កៀសមានភ័យនៅចំពោះមុខ ពួកអ្នកនេសាទនាំគ្នាបង់សំណាញ់និងដាក់ទ្រូជាដើម មានប្រការផ្សេងៗ ហើយចាប់យកត្រី ពួកយើងនាំគ្នាចូលកាន់ព្រៃវិញចុះ ។ ត្រីទាំងពីរក្រៅនេះ នាំគ្នានិយាយម្តងម្នាក់ថា ពួកយើងនឹងទៅថ្ងៃនេះ ឬថ្ងៃស្អែកចាំទៅចុះ ព្រោះភាពជាអ្នកខ្ជិលច្រអូស និងព្រោះការ

*ជាប់ចិត្តក្នុងចំណី រហូតពេលវេលាកន្លងទៅ ៣ ខែ ។ គ្រានោះ ពួកអ្នកនេសាទនាំគ្នាដាក់សំណាញ់ក្នុងស្ទឹង ត្រីពហុចិន្តីនិងត្រីឈ្មោះអប្បចិន្តី កាលចេញទៅរកអាហារបានហែលទៅខាងមុខ មិនកំណត់ក្លិនសំណាញ់ ព្រោះជាសត្វល្ងង់ខ្លៅក៏ចូលទៅក្នុងសំណាញ់ភ្លាម ត្រីឈ្មោះ មិតចិន្តី តាមមកពីក្រោយកំណត់ដឹងក្លិនសំណាញ់បាន ហើយដឹងថាត្រីទាំងពីរនោះចូលទៅក្នុងសំណាញ់ហើយ ក៏គិតថា អញនឹងឲ្យជីវិតទានដល់ត្រីអន្ធពាល អ្នកខ្ជិលច្រអូសទាំងពីរនេះ ហើយក៏ហែលទៅកាន់ទីជិតសំណាញ់ខាងក្រៅ ធ្វើឲ្យទឹករំជួល ធ្វើឲ្យសំណាញ់ដាច់ ហើយលោតចេញទៅបាន ហើយក៏លោតទៅខាងមុខសំណាញ់ ហែលចូលទៅកាន់សំណាញ់ម្តងទៀត ធ្វើឲ្យទឹករំជួល ដូចធ្វើឲ្យសំណាញ់ខាងក្រោយដាច់ លោតចេញទៅបាន ហើយក៏លោតចេញទៅខាងក្រោយសំណាញ់ ពួកអ្នកនេសាទសម្គាល់ថា ត្រីទម្លាយសំណាញ់ហើយ ក៏នាំគ្នាចាប់ចុងសំណាញ់លើកឡើង ត្រីទាំងពីរនោះក៏របូតអំពីសំណាញ់ធ្លាក់ទៅក្នុងទឹកអស់ ត្រីទាំងពីរនោះអាស្រ័យត្រីឈ្មោះ មិតចិន្តី ទើបមានជីវិត ។ ព្រះបរមសាស្តា លុះទ្រង់នាំយករឿងក្នុងអតីតនេះមកសម្តែងហើយ ព្រះអង្គបានត្រាស់ដឹងដោយប្រពៃហើយ ទើបត្រាស់ព្រះគាថានេះថា*

**ពហុចិន្តី អប្បចិន្តី ច ឧភោ ជាលេ អពជ្ឈរេ**
**មិតចិន្តិ អមោចេសិ ឧភោ តត្ថ សមាគតាតិ ។**

*ត្រីឈ្មោះពហុចិន្តី និងអប្បចិន្តីទាំងពីរ បានជាប់នៅ ក្នុងសំណាញ់ ត្រីឈ្មោះមិតចិន្តី បានដោះឲ្យរួចខ្លួន ត្រីទាំងពីរ បានជួបគ្នាក្នុងទឹកនោះ ។*

*បណ្តាបទទាំងនោះ បទថា* **ពហុចិន្តី** *សេចក្តីថា ត្រីដែលមានឈ្មោះយ៉ាងនេះថា* **ពហុចិន្តី** *ព្រោះមានការគិតច្រើន មានការត្រិះរិះច្រើន សូម្បីឈ្មោះទាំងពីរក្រៅនេះ ក៏មានន័យនេះ ។*

*បទថា* **ឧភោ តត្ថ សមាគតា** *សេចក្តីថា ត្រីទាំងពីរជាប់នៅក្នុងសំណាញ់ អាស្រ័យត្រីឈ្មោះ មិតចិន្តី ទើបបានរួចជីវិត ត្រឡប់មកបានជួបជុំគ្នានៅក្នុងទឹកនោះទៀត ។*

*ព្រះបរមសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកដោយប្រការដូច្នេះហើយ ទ្រង់ប្រកាសសច្ចធម៌ ពេលចប់សច្ចធម៌ ភិក្ខុចាស់ទាំងពីរអង្គនោះ តាំងនៅក្នុងសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា ត្រីឈ្មោះពហុចិន្តីនិងអប្បចិន្តីក្នុងកាលនោះ បានមកជាភិក្ខុចាស់ទាំងពីរអង្គក្នុងកាលឥឡូវនេះ ចំណែកត្រីឈ្មោះ មិតចិន្តី គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា មិតចិន្តិជាតក ទី ៤ ។

# អដ្ឋកថា អនុសាសិកជាតក ទី ៥

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុនីអ្នកចូលចិត្តប្រៀនប្រដៅគេមួយរូប ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្តើមថា* **យាយញ្ញមនុសាសតិ** *ដូច្នេះជាដើម ។*

*បានឮថា ភិក្ខុនីនោះ ជាកុលធីតារបស់អ្នកនគរសាវត្ថីម្នាក់ តាំងពីកាលដែលខ្លួនបួសហើយ មិនបានយកចិត្តទុកដាក់ក្នុងសមណធម៌ទេ ជាប់ចិត្តតែក្នុងអាមិស ត្រាច់ទៅបិណ្ឌបាតនៅក្នុងកន្លែងតែមួយនៃនគរ ដែលភិក្ខុនីដទៃៗមិននាំគ្នាទៅ ។ គ្រានោះ ពួកមនុស្សនាំគ្នាប្រគេនបិណ្ឌបាតដ៏ប្រណីតចំពោះនាង នាងត្រូវចំណង់ក្នុងរសគ្រប់សង្កត់ គិតថា ប្រសិនបើភិក្ខុនីដទៃៗ នឹងត្រាច់បិណ្ឌបាតក្នុងប្រទេសនេះ លាភរបស់អញនឹងសាបសូន្យ អញគួរធ្វើឲ្យភិក្ខុនីដទៃៗ មិនមកដល់ប្រទេសនេះ ដូច្នេះហើយ ទៅកាន់សម្នាក់ភិក្ខុនីទាំងឡាយ ទូន្មានភិក្ខុនីទាំងឡាយថា នែនាងម្ចាស់ដ៏ចម្រើនទាំងឡាយ ក្នុងទីឯណោះមានដំរីកាច សេះកាច ឆ្កែកាចជាច្រើន ជាទីមានអន្តរាយដោយជុំវិញ នាងម្ចាស់ទាំងឡាយកុំត្រាច់ទៅបិណ្ឌបាតនៅទីនោះឡើយ ។ ស្តាប់ពាក្យរបស់នាងហើយ ភិក្ខុនីសូម្បីតែមួយរូបក៏មិនសម្លឹងមើលប្រទេសនោះ ។ ថ្ងៃមួយ ពេលដែលភិក្ខុនីនោះកំពុងនិមន្តបិណ្ឌបាតចូលទៅកាន់ផ្ទះមួយដោយរហ័ស ពពែកាចក៏ជល់ហើយឆ្អឹងជើងក៏បាក់ មនុស្សទាំងឡាយប្រញាប់ចូលទៅពិនិត្យមើល ដាក់*

សម្រួលឆ្អឹងដែលបាក់ជាពីរកំណាត់នោះឲ្យជាប់គ្នា ហើយសែងភិក្ខុនីនោះដោយគ្រែនាំទៅកាន់សម្នាក់ភិក្ខុនី ។ ពួកភិក្ខុនីសើចចំអកថា ភិក្ខុនីរូបនេះចូលចិត្តតែទូន្មានប្រៀនប្រដៅភិក្ខុនីដទៃៗ ខ្លួនឯងបែរជានិមន្តទៅបិណ្ឌ-បាតក្នុងប្រទេសនោះ រហូតទាល់តែបាក់ជើងទើបត្រឡប់មកវិញ អំពើដែលនាងធ្វើនោះបានប្រាកដក្នុងពួកភិក្ខុសង្ឃ ។ ថ្ងៃមួយ ពួកភិក្ខុពោលទោសរបស់ភិក្ខុនីនោះក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ ភិក្ខុនីអ្នកពេញចិត្តទូន្មានភិក្ខុនីដទៃៗ ខ្លួនឯងត្រាច់ទៅបិណ្ឌបាតក្នុងប្រទេសនោះត្រូវពពែកាចជល់បាក់ជើង ។ ព្រះបរមសាស្ដា ស្ដេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនីនោះក៏គិតតែទូន្មានអ្នកដទៃ ប៉ុន្តែខ្លួនឯងមិនប្រព្រឹត្តត្រូវសោយទុក្ខរហូតអស់កាលជានិច្ច ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាបក្សីព្រៃ ចម្រើនវ័យហើយបានជាមេហ្វូង មានបក្សីច្រើនរយជាបរិវារ ចូលទៅកាន់ព្រៃហេមពាន្ត ។ ក្នុងកាលដែលព្រះបរមពោធិសត្វនៅក្នុងព្រៃហេមពាន្តនោះ

*បក្សីញីចណ្ឌាលមួយទៅកាន់ព្រៃជ្រៅដើម្បីរកចំណី បក្សីញីនោះបានគ្រាប់ស្រូវនិងសណ្ដែកជាដើម ដែលជ្រុះចាករទេះក្នុងទីនោះហើយគិតថា ពេលនេះអញត្រូវរកវិធីធ្វើមិនឲ្យបក្សីដទៃទៅកាន់ប្រទេសនោះ ដូច្នេះហើយ ឲ្យឱវាទដល់បក្សីដទៃថា ដែលឈ្មោះថា ផ្លូវធំក្នុងព្រៃក្រាស់ ជាផ្លូវមានភ័យចំពោះមុខ ដូចជាសត្វដំរី សេះ និងយានជំនិះទឹមដោយគោកាចៗជាដើម រមែងច្ចងទៅមក បើមិនអាចហើរឡើងបានរហ័សទេ ក៏មិនគួរទៅកាន់ទីនោះឡើយ ហ្វូងបក្សីដាក់ឈ្មោះឲ្យបក្សីញីនោះថា អនុសាសិកា ។ ថ្ងៃមួយ បក្សីនោះកំពុងហើរទៅតាមផ្លូវក្នុងព្រៃក្រាស់នោះបានឮសំឡេងរទេះ ដែលបរមកយ៉ាងលឿន ងាកមកសម្លឹងមើលដោយគិតថា រទេះនៅឆ្ងាយ អញនឹងស៊ីតទៅទៀត គ្រានោះ រទេះក៏មកដល់ខ្លួនល្មមដោយសន្ទុះដូចខ្យល់បក់ បក្សីនោះមិនអាចហើរឡើងទាន់ កង់រទេះកិនខ្លួនរួចកន្លងហួសទៅ បក្សីមេហ្វូងហៅពួកបក្សីប្រជុំមិនឃើញបក្សីនោះ ក៏ពោលថា អនុសាសិកាទៅណាមិនឃើញ អ្នកទាំងឡាយចូរនាំគ្នាស្វែងរក ។ បក្សីទាំងឡាយនាំគ្នាស្វែងរក ឃើញបក្សីនោះដាច់ជាពីរកំណាត់នៅត្រង់ផ្លូវធំនោះ ក៏នាំដំណឹងទៅប្រាប់បក្សីមេហ្វូង ។ បក្សីពោធិសត្វពោលថា បក្សីនោះហាមឃាត់បក្សីដទៃៗ ប៉ុន្តែខ្លួនត្រាច់ទៅកាន់ទីនោះទើបដាច់ជាពីរកំណាត់ ដូច្នេះហើយពោលគាថានេះថា*

**យាយញ្ញមនុសាសតិ សយំ លោលុប្បចារិនី**

**សាយំ វិបក្ខិកា សេតិ ហតា ចក្កេន សាលិកាតិ ។**

*មេបក្សីណា ប្រៀនប្រដៅនូវបក្សីដទៃ តែជាអ្នកប្រព្រឹត្ត លោភដោយខ្លួនឯង មេបក្សីនោះ ដេកបាក់ស្លាប ដូចជាសត្វសាលិកាដែលកង់កិនហើយ ។*

*បណ្តាបទទាំងនោះ បទថា* **យ** *អក្សរក្នុងបទថា* **យាយញ្ញមនុសាសតិ** *ធ្វើការភ្ជាប់បទ សេចក្តីថា មេបក្សីណាប្រៀនប្រដៅអ្នកដទៃ ។*

*បទថា* **សយំ លោលុប្បចារិនី** *សេចក្តីថា តែជាអ្នកមានប្រក្រតីត្រាច់ទៅដោយខ្លួនឯង ។*

*បទថា* **សាយំ វិបក្ខិកា សេតិ** *សេចក្តីថា បក្សីនោះ គឺនាងសាលិកានេះ មានស្លាបខ្ចាត់ខ្ចាយ ដេកស្លាប់នៅត្រង់ផ្លូវធំ ។*

*បទថា* **ហតា ចក្កេន សាលិកា** *សេចក្តីថា មេបក្សីឈ្មោះសាលិកានោះ ត្រូវកង់កិនបំបាក់ស្លាប ដេកស្លាប់នៅក្នុងទីនោះឯង ។*

*ព្រះបរមសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា សត្វសាលិកាក្នុងកាលនោះ បានមកជាអនុសាសិកាភិក្ខុនីក្នុងកាលឥឡូវនេះ ចំណែកបក្សីមេហ្វូង គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា អនុសាសិកជាតក ទី ៥ ។

# អដ្ឋកថា ទុព្វចជាតក ទី ៦

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អតិ-ការមកាពចរិយ** ដូច្នេះជាដើម ។

រឿងរបស់ភិក្ខុនោះ នឹងជាក់ច្បាស់ក្នុង **គិជ្ឈជាតក នវកនិបាត** ( ប៉ុន្តែក្នុងជាតកនេះ ) ព្រះបរមសាស្ដា ទ្រង់ត្រាស់ហៅភិក្ខុនោះមក ហើយត្រាស់ថា ម្នាលភិក្ខុ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលអ្នកជាមនុស្សប្រដៅក្រនោះ សូម្បីក្នុងកាលមុនក៏ជាមនុស្សប្រដៅក្រដែរ ព្រោះភាពជាអ្នកប្រដៅក្រ មិនធ្វើតាមឱវាទរបស់បណ្ឌិត ទើបត្រូវលំពែងដុងរហូតអស់ជីវិត ដូច្នេះ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះមហាសត្វបដិសន្ធិក្នុងត្រកូលអ្នករាំផ្នែកខាងលោត ។ លុះចម្រើនវ័យហើយបានជាអ្នកមានបញ្ញា ឈ្លាសវៃក្នុងឧបាយ សិក្សាសិល្បៈផ្នែកខាងលោតធ្លងលំពែងក្នុងសម្នាក់នៃអ្នកលោតម្នាក់ ដើរសម្ដែងសិល្បៈជាមួយនឹងអាចារ្យ ប៉ុន្តែអាចារ្យនោះ ចេះវិជ្ជាក្នុងការលោតធ្លងលំពែងបាន ៤ ប៉ុណ្ណោះ មិនអាចលោតធ្លងបាន ៥ ទេ ។ ថ្ងៃមួយ អាចារ្យនោះទៅសម្ដែងសិល្បៈក្នុងស្រុកមួយ ស្រវឹងស្រាហើយនិយាយថា យើងនឹងលោតធ្លងលំពែងបាន ៥ ដោយដោតលំពែងរៀងបន្ត ។ គ្រានោះ

ព្រះពោធិសត្វក៏ពោលប្រាប់អាចារ្យថា បពិត្រលោកអាចារ្យ លោកមិនចេះវិជ្ជាក្នុងការលោតធ្ទង់លំពែងបាន ៥ ទេ យកលំពែងមួយចេញចុះ ប្រសិនបើលោកលោតនឹងត្រូវលំពែងទី ៥ ជុងស្លាប់មិនខាន ប៉ុន្តែព្រោះតែស្រវឹងស្រាទើបពោលថា នែមាណព អ្នកមិនដឹងអំពីអំណាចរបស់យើងទេ មិនបានយកចិត្តទុកដាក់ចំពោះពាក្យសម្ដីរបស់ព្រះបរមពោធិសត្វ លោតធ្ទង់ទៅបាន ៤ លំពែង ត្រូវលំពែងទី ៥ ជុង ដូចគេដោតផ្កាស្រគំដោយឈើអណ្ដោតដូច្នោះ ដេកសោយសោកនៅទីនោះឯង ។ គ្រានោះ ព្រះមហាសត្វពោលថា បពិត្រអាចារ្យ លោកមិនជឿពាក្យសម្ដីរបស់បណ្ឌិតទើបដល់នូវសេចក្ដីវិនាសយ៉ាងនេះ ដូច្នេះហើយ ពោលគាថានេះថា

**អតិករមករាចរិយ មយ្ហម្បេតំ ន រុច្ចតិ**
**ចតុត្ថេ លង្ឃយិត្វាន បញ្ចមាយសិ អាវុតោតិ ។**

បពិត្រលោកអាចារ្យ អំពើដែលធ្វើជ្រុលនេះ មិនគាប់ចិត្តខ្ញុំទេ លោកលោតបានតែផ្ទៃលំពែងទី ៤ ហើយត្រូវលំពែងទី ៥ មុតហើយ ។

បណ្ដាបទទាំងនោះ បទថា **អតិករមករាចរិយ** សេចក្ដីថា បពិត្រលោកអាចារ្យ លោកបានធ្វើការជ្រុល អធិប្បាយថា បានធ្វើការជ្រុលហួសដែលខ្លួនអាចធ្វើបាន ។

បទថា **មយ្ហម្បេតំ ន រុច្ចតិ** នេះ ព្រះបរមពោធិសត្វសម្ដែង

*សេចក្តីថា ការធ្វើរបស់លោកនេះ មិនពេញចិត្តខ្ញុំដែលជាអន្តេវាសិកទេ ព្រោះហេតុនោះ ទើបខ្ញុំប្រាប់លោកជាមុន ។*

*បទថា* **ចតុត្ថេ លង្ឃយិត្វាន** *សេចក្តីថា លោកមិនធ្លាក់មកលើលំពែងទី ៤ គឺឆ្លងផុតលំពែងទី ៤ បាន ។*

*បទថា* **បញ្ចមាយសិ អាវុតោ** *សេចក្តីថា លោកមិនជឿពាក្យសម្តីរបស់បណ្ឌិត ទើបត្រូវលំពែងទី ៥ ជុង ។*

*ព្រះពោធិសត្វ លុះពោលគាថានេះហើយ ក៏នាំអាចារ្យចេញអំពីលំពែង ធ្វើកិច្ចដែលគួរធ្វើឲ្យ ។*

*ព្រះបរមសាស្តា ទ្រង់នាំយកអតីតនិទាននេះមកហើយ ទ្រង់ប្រជុំជាតកថា អាចារ្យក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាលឥឡូវនេះ ចំណែកអន្តេវាសិក គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា ទុព្ភចជាតក ទី ៦ ។

# អដ្ឋកថា តិត្តិរជាតក ទី ៧

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុឈ្មោះ កោកាលិកៈ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **អច្ចុគ្គតា អតិពលតា** *ដូច្នេះជាដើម រឿងរបស់កោកាលិកភិក្ខុនោះ នឹងជាក់ច្បាស់ក្នុង* **តក្ការិយជាតក តេរសកនិបាត** *។*

*ប៉ុន្តែក្នុងជាតកនេះ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលកោកាលិកភិក្ខុអាស្រ័យវាចារបស់ខ្លួនត្រូវវិនាសនោះ សូម្បីក្នុងកាលមុន ក៏ធ្លាប់វិនាសហើយដែរ ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ចម្រើនវ័យហើយរៀនសិល្បៈគ្រប់យ៉ាង នៅក្នុងនគរតក្កសិលា លះបង់កាមហើយបួសជាឥសី ញ៉ាំងអភិញ្ញា៥ សមាបត្តិ៨ ឲ្យកើតហើយ ពួកឥសីប្រជុំគ្នានៅក្នុងហិមវន្តប្រទេស តែងតាំងព្រះបរមពោធិសត្វឲ្យធ្វើជាអាចារ្យអ្នកឲ្យឱវាទ ។ ព្រះមហាបុរសបានជាអាចារ្យអ្នកឲ្យឱវាទហើយនាំឥសី ៥០០ រូបលេងឈានទាំងឡាយក្នុងព្រៃហិមពាន្ត ។ គ្រានោះ តាបសមួយរូបកើតរោគស្គមលឿង កាន់កាំបិតទៅកាប់ឈើ ។ គ្រានោះ មានតាបសមាត់ច្រើនមួយរូប អង្គុយនៅជិតតាបសស្គមនោះ និយាយថា ចូរកាប់ក្នុង*

ទីនេះ ចូរកាប់ទីនេះ ធ្វើឲ្យតាបសស្គមនោះខឹង តាបសនោះខឹងហើយពោលថា ពេលនេះលោកមិនមែនជាអាចារ្យបង្រៀនសិល្បៈក្នុងការកាប់ឈើរបស់ខ្ញុំទេ ហើយផាកាំបិតធំដ៏មុតកាប់តែម្តងប៉ុណ្ណោះ ធ្វើឲ្យតាបសមាត់ដាចនោះអស់ជីវិត ។ ក្នុងកាលនោះ ឥសីពោធិសត្វប្រើឲ្យធ្វើសរីរកិច្ចសពតាបសនោះ ត្រង់ជើងដំបូកមួយកន្ទែង ។ មិនឆ្ងាយអំពីអាស្រមបទនោះ មានសត្វទទាមួយនៅទីនោះ រាល់ព្រឹករាល់ល្ងាចសត្វទទានោះឈរនៅលើដំបូកនោះ រងាវដោយមានសំឡេងខ្លាំង ។ ព្រានម្នាក់ ឮសំឡេងនោះហើយគិតថា គួរមានសត្វទទានៅទីនោះ ទើបដើរទៅរកតាមសំឡេងនោះ សម្លាប់ទទានោះហើយកាន់យកទៅ ។ ព្រះបរមពោធិសត្វមិនបានឮសំឡេងរបស់សត្វទទានោះ សួរពួកតាបសថា នៅទីឯណោះមានសត្វទទានៅ ព្រោះហេតុអ្វីទើបមិនឮសំឡេងរបស់វា ? តាបសទាំងនោះប្រាប់រឿងនោះដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វប្រៀបធៀបរឿងទាំងពីរនោះហើយ ពោលគាថានេះក្នុងកណ្តាលពួកឥសីថា

**អច្ចុគ្គតា អតិពលតា អតិវេលំ បភាសិតា**
**វាចា ហនតិ ទុម្មេធំ តិត្តិរំ វាតិវស្សិតន្តិ ។**

វាចាដែលខ្ពស់ហួស ខ្លាំងហួស ពោលហួសកាលវេលា
រមែងសម្លាប់បុគ្គលពាល អ្នកឥតបញ្ញា ដូចជាវាចា
ដែលសម្លាប់ នូវសត្វទទាដែលរងាវហួស ។

*បណ្ដាបទទាំងនោះ បទថា* **អច្ចុគ្គតា** *ប្រែថា វាចាដែលខ្ពស់ហួស ។ បទថា* **អតិពលតា** *បានដល់ វាចាដែលខ្លាំងហួស ព្រោះពោលដដែល ៗ ។*

*បទថា* **អតិវេលំ បភាសិតា** *បានដល់ វាចាដែលពោលហួសកាលវេលា គឺវាចាដែលពោលហួសប្រមាណ ។*

*បទថា* **តិត្តិរំ វាតិវស្សិតំ** *សេចក្ដីថា សំឡេងរងាវខ្លាំងហួសពេករមែងកម្ចាត់សត្វទទាយ៉ាងណា វាចាបែបនេះ រមែងសម្លាប់បុគ្គលពាល គឺបុគ្គលល្ងង់ខ្លៅដូច្នោះ ។*

*ព្រះពោធិសត្វឲ្យឱវាទពួកឥសីដោយប្រការដូច្នោះ ចម្រើនព្រហ្មវិហារ ៤ ក្រោយអំពីចុតិ មានព្រហ្មលោកជាទីទៅខាងមុខ ។*

*ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលកោកាលិកភិក្ខុអាស្រ័យវាចារបស់ខ្លួនត្រូវវិនាសនោះ សូម្បីក្នុងកាលមុនក៏ធ្លាប់វិនាសហើយដែរ លុះទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា តាបសអ្នកប្រដៅក្រក្នុងកាលនោះ បានមកជាកោកាលិកភិក្ខុ ពួកឥសីបានមកជាពុទ្ធបរិស័ទ ចំណែកសាស្ដានៃគណៈ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា តិត្តិរជាតក ទី ៧ ។

# អដ្ឋកថា ចង្គកជាតក ទី ៨

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបុត្ររបស់ឧត្តរសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្ដើមថា **ជា ចិន្តយន្ដោ បុរិសោ** ដូច្នេះជាដើម ។

បានឮថា នៅក្នុងនគរសាវត្ថីមានសេដ្ឋីឈ្មោះឧត្តរៈ មានសម្បត្តិច្រើន ។ សត្វអ្នកមានបុណ្យម្នាក់ចុតិចាកព្រហ្មលោកបដិសន្ធិក្នុងផ្ទៃនៃភរិយារបស់សេដ្ឋី ចម្រើនវ័យហើយ មានរូបសម្បត្តិស្រស់ស្អាត គួរជាទីជ្រះថ្លា មានពណ៌សម្បុរដូចព្រហ្ម ។ ថ្ងៃមួយ នៅក្នុងនគរសាវត្ថីមានបុណ្យនក្ខត្តឫក្សប្រចាំខែកត្តិក មនុស្សទាំងឡាយបានដើរប្រកាសទូទៅពេញព្រះនគរ បុត្តសេដ្ឋីដទៃៗ ដែលជាសម្លាញ់របស់សេដ្ឋីបុត្តនោះ មានភរិយាហើយ ប៉ុន្តែព្រោះហេតុតែបុត្តរបស់ឧត្តរសេដ្ឋីនោះនៅក្នុងព្រហ្មលោកយូរពេក ទើបមិនមានចិត្តត្រេកអរក្នុងកងកិលេស ។

គ្រានោះ សម្លាញ់របស់សេដ្ឋីបុត្រនោះប្រឹក្សាគ្នាថា ពួកយើងនឹងនាំស្ត្រីម្នាក់មកឲ្យបុត្តរបស់ឧត្តរសេដ្ឋី ហើយបបួលទៅលេងបុណ្យនក្ខត្តឫក្ស ។ លុះប្រឹក្សាគ្នាដូច្នោះហើយ ចូលទៅរកសេដ្ឋីបុត្តពោលថា នែសម្លាញ់ នៅក្នុងនគរសាវត្ថីមានបុណ្យនក្ខត្តឫក្សប្រចាំខែកត្តិក គេបានប្រកាសទូទៅពេញនគរហើយ ពួកយើងនឹងនាំស្ត្រីម្នាក់មកឲ្យអ្នក ហើយទៅលេងបុណ្យនក្ខត្តឫក្សជាមួយគ្នា សូម្បីសេដ្ឋីបុត្តនោះប្រាប់ថា ខ្ញុំមិនត្រូវការស្ត្រីទេ ក៏

នៅតែជម្ទះចិត្តបបួលជានិច្ច រហូតទាល់តែសេដ្ឋីបុត្តនោះយល់ព្រម ទើបទៅតាក់តែងនាងវណ្ណទាសីមួយរូបដោយគ្រឿងអលង្ការទាំងពួង នាំទៅផ្ទះសេដ្ឋីបុត្តហើយពោលថា នាងចូរទៅកាន់សម្នាក់សេដ្ឋីបុត្តចុះ ដូច្នេះហើយបញ្ជូនចូលទៅកាន់បន្ទប់ដេក ហើយនាំគ្នាចេញទៅ ។ ចំណែកសេដ្ឋីបុត្តនោះ សូម្បីនាងចូលទៅដល់បន្ទប់ដេកក៏ដោយ ក៏មិនសម្លឹងមើល មិននិយាយរក នាងគិតថា បុរសនេះ មិនសម្លឹងមើលអញដែលមានរូបស្រស់ស្អាត សម្បុរដោយលម្អដ៏ត្រកាលបែបនេះ ទាំងមិននិយាយរកផង ដូច្នេះ អញនឹងធ្វើឲ្យគេសម្លឹងមើលអញដោយការកែក្រាយ និងមាយារបស់ស្ត្រីឲ្យខាងតែបាន ដូច្នេះ ។ ហើយក៏ផ្ដើមបញ្ចេញមាយាស្ត្រី បញ្ចេញគល់ធ្មេញដោយការញញឹម ធ្វើអៀនប្រៀន ។ សេដ្ឋីបុត្តសម្លឹងមើលអាការរបស់នាង កាន់យកនិមិត្តក្នុងធ្មេញកើតអដ្ឋិកសញ្ញា រូបរាងស្រស់ស្អាតទាំងអស់នោះក៏ប្រាកដដូចគ្រោងឆ្អឹង សេដ្ឋីបុត្តក៏ឲ្យរង្វាន់ដល់នាង ហើយឲ្យនាងត្រឡប់ទៅវិញ ។

ឥស្សរជនម្នាក់ឃើញនាងវណ្ណទាសីចុះអំពីផ្ទះនោះ ដើរតាមផ្លូវក៏ឲ្យរង្វាន់ហើយនាំទៅផ្ទះរបស់ខ្លួន ។ កន្លងទៅបាន ៧ ថ្ងៃ បុណ្យនក្ខត្តឫក្សក៏ចប់ មាតារបស់នាងវណ្ណទាសីមិនឃើញនាងត្រឡប់មកផ្ទះ ក៏ទៅរកសេដ្ឋីបុត្តទាំងឡាយសួរថា កូនស្រីរបស់ខ្ញុំទៅណា ? សេដ្ឋីបុត្តទាំងនោះក៏នាំគ្នាទៅកាន់ផ្ទះរបស់ឧត្តរសេដ្ឋីបុត្តសួរថា នាងទៅណា ? សេដ្ឋីបុត្ត

ប្រាប់ថា ខ្ញុំឲ្យវង្វាន់នាងហើយ ឲ្យនាងត្រឡប់ទៅវិញនៅពេលនោះឯង ។ ពេលនោះ មាតារបស់នាងស្រែកយំបណ្តើរពោលបណ្តើរថា ប្រសិនបើខ្ញុំមិនបានឃើញកូនស្រីរបស់ខ្ញុំទេ ខ្ញុំមិនទៅណាទេ ពួកលោកត្រូវនាំកូនស្រីរបស់ខ្ញុំមកឲ្យខ្ញុំវិញ ហើយចាប់ឧត្តរសេដ្ឋីបុត្តទៅកាន់រាជដំណាក់ ។ ព្រះរាជាកាលទ្រង់កាត់ក្តី ទ្រង់ត្រាស់សួរថា សេដ្ឋីបុត្តទាំងនេះ នាំនាងទៅឲ្យអ្នកឬ? ឧត្តរសេដ្ឋីបុត្តក្រាបទូលថា បពិត្រព្រះសម្មតិទេព ពិតមែន ។

ព្រះរាជាត្រាស់សួរថា ពេលនេះ នាងទៅណា ?

ឧត្តរសេដ្ឋីបុត្តក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនដឹងទេ ទូលបង្គំឲ្យនាងត្រឡប់ទៅវិញនៅពេលនោះឯង ។

ព្រះរាជាត្រាស់សួរថា ពេលនេះអ្នកអាចនាំនាងមកវិញបានទេ ?

ឧត្តរសេដ្ឋីបុត្តក្រាបទូលថា ទូលបង្គំមិនអាចទេ ។

ព្រះរាជាត្រាស់បញ្ជារាជបុរសថា ប្រសិនបើមិនអាចនាំនាងមកបានទេនោះ ពួកអ្នកចូរដាក់ទោសគេចុះ ។ គ្រានោះ ពួករាជបុរសចាប់ឧត្តរសេដ្ឋីបុត្តចងស្លាបសេកឃុំខ្លួនដោយគិតថា ពួកយើងនឹងដាក់ទោស ។ ដំណឹងនោះលេចឮទូទៅពេញនគរថា ព្រះរាជាបញ្ជាឲ្យដាក់ព្រះរាជអាជ្ញាដល់ឧត្តរសេដ្ឋីបុត្ត ដែលមិនអាចនាំនាងវណ្ណទាសីមកវិញបាន ។ មហាជនឱបទ្រូងស្រែកយំថា ឱ ហេតុអ្វីទើបមានរឿងដូច្នេះ លោកបានវត្ថុដែលមិនគួរបានហើយ ពោលហើយនាំគ្នាយំរៀបរាប់ដើរតាមក្រោយសេដ្ឋីបុត្ត ។

សេដ្ឋីបុត្តគិតថា ទុក្ខបែបនេះ អញបានទទួលព្រោះការនៅគ្រប់គ្រងផ្ទះ ប្រសិនបើអញបានរួចផុតអំពីទុក្ខនេះ អញនឹងបួសក្នុងសម្នាក់ព្រះមហាគោតមសម្មាសម្ពុទ្ធ ។

ចំណែកនាងវណ្ណទាសីនោះ បានឮសំឡេងកោលាហលនោះហើយ ក៏សួរថា នុ៎ះជាសំឡេងអ្វី ? លុះដឹងរឿងរ៉ាវនោះហើយក៏ប្រញាប់ចុះមករួចពោលថា អ្នកទាំងឡាយចូរចៀសចេញ ចូរឲ្យឱកាសដល់ខ្ញុំបានជួបរាជបុរសចុះ ហើយបង្ហាញខ្លួន ។ ពួករាជបុរសឃើញនាងហើយ ក៏ហៅមាតារបស់នាងមកទទួលយកនាងទៅ ដោះលែងសេដ្ឋីបុត្តហើយចៀសចេញទៅរៀងៗខ្លួន ។ ពួកសម្លាញ់ទាំងឡាយរបស់សេដ្ឋីបុត្តនោះក៏មកនាំសេដ្ឋីបុត្តនោះទៅកាន់ស្ទឹង ង្ងូតទឹកជម្រះកាយហើយ ក៏ទៅផ្ទះបរិភោគអាហារពេលព្រឹក សូមឲ្យមាតាបិតាអនុញ្ញាតឲ្យបព្វជ្ជា ។ សេដ្ឋីបុត្តនោះកាន់សំពត់ចីវរទៅកាន់សម្នាក់ព្រះបរមសាស្ដាដោយបរិវារជាច្រើន ថ្វាយបង្គំហើយក្រាបទូលសូមបព្វជ្ជា បានបព្វជ្ជាឧបសម្បទាហើយ មិនលះបង់កម្មដ្ឋានឡើយ ចម្រើនវិបស្សនា មិនយូរប៉ុន្មានបានសម្រេចអរហត្តផល ។

ថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងធម្មសភា ពោលអំពីគុណរបស់សេដ្ឋីបុត្តថា អ្នកមានអាយុទាំងឡាយ បុត្តរបស់ឧត្តរសេដ្ឋី កាលភ័យកើតឡើងចំពោះខ្លួន ដឹងគុណព្រះបរមសាស្ដា បានគិតថា កាលរួចផុតចាកទុក្ខនេះនឹងបព្វជ្ជា ដោយការគិតល្អដូច្នោះ ទើបរួចផុតអំពីមរណ-

ភ័យផង បួសហើយបានសម្រេចផលដ៏ប្រសើរផង ។ ព្រះបរមសាស្តាស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះអ្នកទាំងឡាយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយ ក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែបុត្តរបស់ឧត្តរសេដ្ឋីប៉ុណ្ណោះទេ ដែលកាលភ័យកើតហើយ បានគិតថាអញនឹងរួចផុតទុក្ខនេះ ដោយឧបាយនេះ សូម្បីបណ្ឌិតក្នុងកាលមុនកាលភ័យកើតដល់ខ្លួនហើយ ក៏បានគិតថា អញនឹងរួចផុតចាកទុក្ខនេះដោយឧបាយនេះ ដូច្នេះហើយក៏រួចផុតចាកទុក្ខគឺមរណភ័យបាន ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វកាលកម្ចាំងកម្មប្ដូរផ្លាស់ឲ្យវិលវល់ទៅដោយអំណាចនៃចុតិនិងបដិសន្ធិ កើតក្នុងកំណើតសត្វចាប ។ គ្រានោះព្រានបក្សីម្នាក់ ចាប់ចាបជាច្រើនមកអំពីព្រៃ ដាក់ទ្រុងទុកក្នុងផ្ទះ ។ កាលមនុស្សទាំងឡាយមកទិញ ក៏លក់សត្វចាបចិញ្ចឹមជីវិត ។ ព្រះពោធិសត្វគិតថា ប្រសិនបើអញបរិភោគបាយទឹកដែលព្រាននេះឲ្យហើយ ព្រាននេះនឹងចាប់អញលក់ឲ្យអ្នកដែលមកទិញ បើអញមិនបរិភោគក៏គង់ស្គាំងស្គម កាលមនុស្សឃើញអញស្គមក៏នឹងមិនទទួលយក ការមិនមានភ័យនឹងមានដល់អញដោយឧបាយនេះ អញនឹងធ្វើឧបាយនេះ ។ កាលព្រះ-

មហាសត្វធ្វើយ៉ាងនោះ ក៏ស្គមសល់តែស្បែកដណ្តប់ឆ្អឹង អ្នកទិញទាំង-ឡាយឃើញព្រះពោធិសត្វហើយ ក៏មិនហ៊ានប៉ះពាល់ ។ នាយព្រានកាលសត្វចាបដទៃអស់ហើយ ក៏យកព្រះពោធិសត្វចេញអំពីទ្រុង ឈរនៅក្បែរមាត់ទ្វារដាក់ព្រះពោធិសត្វលើបាតដៃ ផ្តើមនឹងពិនិត្យមើលថា តើសត្វចាបមួយនេះ កើតអ្វីហ្ន៎ កាលព្រះមហាសត្វដឹងថា នាយព្រានភ្លេចខ្លួនក៏ត្រដាងស្លាបហើរចូលព្រៃទៅ ។ ចាបដទៃឃើញព្រះមហាសត្វ ក៏សួរថា អ្នកទៅណាបាត់យូរម្ល េះ ពួកយើងមិនដែលឃើញអ្នក ? កាលព្រះមហា-សត្វប្រាប់ថា ខ្ញុំត្រូវព្រានចាប់ ក៏នាំគ្នាសួរថា តើអ្នកធ្វើដូចម្តេចទើបរួចមកបាន ? ព្រះពោធិសត្វប្រាប់ថា ខ្ញុំមិនស៊ីអាហារដែលព្រានឲ្យ មិនផឹកទឹក ទើបរួចមកបានដោយឧបាយ ដូច្នេះហើយ ពោលគាថានេះថា

**នា ចិន្តយន្តោ បុរិសោ វិសេសមធិគច្ឆតិ**
**ចិន្តិតស្ស ផលំ បស្ស មុត្តោស្មិ វធពន្ធនាតិ ។**

បុរសកាលមិនបានរិះគិត រមែងមិនបានសម្រេច នូវ
គុណវិសេសឡើយ អ្នកចូរឃើញផលនៃឧបាយដែល
ខ្ញុំគិតហើយ ព្រោះខ្ញុំរួចអំពីសេចក្តីស្លាប់និងចំណង ។

គាថានោះ ប្រមូលសេចក្តីបានដូច្នេះថា អ្នកដែលជួបប្រសព្វទុក្ខហើយ កាលមិនបានរិះគិតថា អញនឹងរួចអំពីទុក្ខនេះ ដោយឧបាយនេះ រមែងមិនបានសម្រេចនូវគុណវិសេស គឺការរួចផុតអំពីទុក្ខរបស់ខ្លួនបាន

ឥឡូវនេះអ្នកចូរមើលផលនៃកម្មដែលយើងគិតហើយ ដោយឧបាយនេះ ប៉ុណ្ណោះ ដែលយើងបានរួចផុតអំពីការសម្លាប់និងការឃុំឃាំង គឺរួចអំពីសេចក្ដីស្លាប់និងចំណង ។

ព្រះមហាបុរសប្រាប់ហេតុការណ៍ដែលខ្លួនធ្វើហើយ ដោយប្រការដូច្នេះ ។

ព្រះបរមសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា សត្វចាបដែលរួចអំពីសេចក្ដីស្លាប់ក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា វដ្ដកជាតក ទី ៨ ។

# អដ្ឋកថា អកាលរាវិជាតក ទី ៩

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកនិយាយមិនដឹងកាលវេលាមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **អមាតាបិតុសំវឌ្ឍោ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះជាកុលបុត្រអ្នកនគរសាវត្ថី បួសក្នុងព្រះ-សាសនាហើយ មិនរៀនវត្តឬសិក្ខា លោកមិនដឹងថា ពេលនេះគួរធ្វើវត្ត ពេលនេះគួរប្រតិបត្តិ ពេលនេះគួររៀន ពេលនេះគួរទន្ទេញ ធ្វើសំឡេងខ្លាំងៗ នៅពេលដែលលោកភ្ញាក់ឡើង ទាំងក្នុងបឋមយាម ទាំងក្នុងមជ្ឈិម

យាម ទាំងក្នុងបច្ឆិមយាម ភិក្ខុទាំងឡាយសិងមិនលក់ ភិក្ខុទាំងឡាយពោលទោសភិក្ខុនោះក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ ភិក្ខុឯ-ណោះបួសក្នុងសាសនា គឺរតនៈបែបនេះ មិនដឹងវត្តឬសិក្ខា កាលឬមិនមែនកាល ។ ព្រះបរមសាស្ដា ស្ដេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះបញ្ចេញសំឡេងមិនត្រូវកាល សូម្បីក្នុងកាលមុនក៏បញ្ចេញសំឡេងមិនត្រូវកាលដែរ និងព្រោះការដែលមិនដឹងកាលឬមិនមែនកាល ត្រូវមួលក រហូតអស់ជីវិត ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ចម្រើនវ័យហើយ សម្រេចការសិក្សាសិល្បៈគ្រប់យ៉ាង បានជាអាចារ្យ-ទិសាបាមោក្ខក្នុងនគរពារាណសី បង្រៀនសិល្បៈដល់មាណពប្រមាណ ៥០០ នាក់ ពួកមាណពទាំងនោះមានមាន់ឈ្មោលមួយ ។ មាណពទាំង-នោះ ក្រោកតាមសំឡេងរងាវរបស់មាន់នោះសិក្សាសិល្បៈ ( ក្រោយមកមាន់នោះ ) ក៏បានងាប់ទៅ មាណពទាំងនោះក៏ដើររកមាន់ដទៃ ។ គ្រា-នោះ មាណពមួយរូបកាច់ឧសក្នុងព្រៃឃើញមាន់មួយ ក៏ចាប់មកដាក់ក្នុង

ទ្រង់ចិញ្ចឹមរក្សាទុក ។ មាន់នោះមិនដឹងថា គួររងាវក្នុងពេលណា ព្រោះខ្លួនធំឡើងនៅក្នុងព្រៃខ្មោច ពេលខ្លះក៏រងាវយប់ជ្រៅពេក ពេលខ្លះរងាវនៅពេលអរុណរះឡើង ពួកមាណពនាំគ្នាសិក្សាសិល្បៈ ក្នុងពេលដែលមាន់នោះរងាវយប់ជ្រៅ មិនអាចសិក្សាបាន រហូតអរុណរះឡើងម្នាក់ៗដេកលក់ទៅវិញអស់ សូម្បីមេរៀនដែលទន្ទេញចាំហើយក៏ភ្លេច ពេលដែលមាន់នោះរងាវនៅពេលភ្លឺពេក មាណពទាំងនោះមិនបានទន្ទេញមេរៀន ។ មាណពទាំងឡាយនោះក៏ប្រឹក្សាគ្នាថា មាន់នេះ ពេលខ្លះឆាប់រងាវ ពេលខ្លះក្រៀរងាវ អាស្រ័យមាន់មួយនេះ ពួកយើងប្រាកដជារៀនសិល្បៈមិនបានសម្រេចឡើយ ហើយក៏នាំគ្នាចាប់មួលកឲ្យមាន់នោះអស់ជីវិតទៅ ហើយទៅប្រាប់អាចារ្យថា បពិត្រលោកអាចារ្យ មាន់ដែលរងាវខុសកាលវេលានោះ ពួកខ្ញុំសម្លាប់ហើយ ។ អាចារ្យពោធិសត្វពោលថា មាន់នេះដល់នូវសេចក្តីស្លាប់ ព្រោះចម្រើនធំឡើងដោយមិនបានទទួលការណែនាំទូន្មានប្រៀនប្រដៅ ដូច្នេះហើយពោលគាថានេះថា

**អមាតាបិតុសំវឌ្ឍោ អនាចរិយកុលេ វសំ**
**នាយំ កាលមកាលំ វា អភិជានាតិ កុក្កុដោតិ ។**

មាន់នេះ ចម្រើននៅក្នុងសម្នាក់នៃបុគ្គល មិនមែនជាមាតាបិតា កាលនៅក្នុងត្រកូលនៃបុគ្គលមិនមែនជាអាចារ្យ រមែងមិនដឹងច្បាស់នូវកាលគួររងាវ ឬកាល មិនគួររងាវ ។

*បណ្ដាបទទាំងនោះ បទថា* **អមាតាបិតុសំវឌ្ឍោ** *សេចក្ដីថា មាន់នេះធំឡើងដោយមិនបានអាស្រ័យមាតាបិតា ហើយទទួលឱវាទ ។*

*បទថា* **អនាចរិយកុលេ វសំ** *សេចក្ដីថា ក្នុងសម្នាក់អាចារ្យក៏មិនបាននៅ ព្រោះមិនបានអាស្រ័យបុគ្គលណាមួយដែលជាអាចារ្យអ្នកទូន្មានឡើយ ។*

*បទថា* **នាយំ កាលមកាលំ វា** *សេចក្ដីថា មាន់នេះមិនដឹងកាល ឬមិនមែនកាលដែលខ្លួនគួររងាវយ៉ាងនេះថា គួររងាវក្នុងពេលនេះ មិនគួររងាវក្នុងពេលនេះ ព្រោះការមិនដឹងកាលនោះឯង ទើបអស់ជីវិត ។*

*ព្រះមហាសត្វសម្ដែងហេតុនេះហើយ រស់នៅរហូតអស់អាយុក្ខ័យ ក្រោយអំពីចុតិក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា មាន់ដែលរងាវមិនស្គាល់កាលក្នុងកាលនោះ បានមកជាភិក្ខុដែលនិយាយមិនដឹងកាលវេលាក្នុងកាលឥឡូវនេះ អន្តេវាសិកបានមកជាពុទ្ធបរិស័ទ ចំណែកអាចារ្យ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា អកាលរាវិជាតក ទី ៩ ។

# អដ្ឋកថា ពន្ធនមោក្ខជាតក ទី ១០

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងចិញ្ចមាណវិកា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **អពទ្ធា តត្ថ ពជ្ឈន្តិ** *ដូច្នេះជាដើម ។*

*រឿងរបស់នាងនឹងជាក់ច្បាស់នៅក្នុង* **មហាបទុមជាតក ទ្វាទសកនិបាត** *។*

*ក្នុងគ្រានោះ ព្រះបរមសាស្ដាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលនាងចិញ្ចមាណវិកាចោទតថាគតដោយរឿងមិនពិតនោះ សូម្បីក្នុងកាលមុន ក៏ធ្លាប់ចោទតថាគតហើយដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងផ្ទៃនៃភរិយារបស់បុរោហិតចម្រើនវ័យហើយ បានជាបុរោហិតរបស់ព្រះបាទព្រហ្មទត្តជំនួសបិតាដែលស្លាប់ទៅហើយ ។ ព្រះបាទព្រហ្មទត្តបានព្រះរាជទានពរដល់អគ្គមហេសីថា នែនាងដ៏ចម្រើន នាងត្រូវការវត្ថុណា ចូរប្រាប់វត្ថុនោះចុះ ។ អគ្គមហេសីក្រាបទូលថា បពិត្រព្រះសម្មតិទេព ពរដទៃមិនមែនជាវត្ថុដែលខ្ញុំម្ចាស់បានដោយកម្រនោះទេ សូមទ្រង់ព្រះរាជទានត្រឹមតែថា តាំងពីពេលនេះទៅ ទ្រង់មិនគប្បីទតស្ដ្រីដទៃដោយអំណាចកិលេស ។ សូម្បី*

ព្រះរាជាទ្រង់ហាមយ៉ាងណាក៏ដោយ ក៏ព្រះអគ្គមហេសីសូមពរដូច្នោះ ដដែលៗ មិនអាចបដិសេធពាក្យរបស់ព្រះនាងបាន ទ្រង់ក៏ទទួល តាំងពីពេលនោះមក ព្រះរាជាទ្រង់មិនទតបណ្តាស្រីរបាំ ១៦.០០០ នាក់ សូម្បីតែម្នាក់ ដោយអំណាចកិលេសឡើយ ។

សម័យមួយ នៅបច្ចន្តជនបទរបស់ព្រះរាជាកើតនូវការបះបោរ ពួកយោធាដែលបោះជំរំនៅក្នុងបច្ចន្តជនបទនោះ ធ្វើសង្គ្រាមនឹងពួកចោរពីរ-បីដង ក៏បញ្ជូនសារទៅក្រាបទូលព្រះរាជាថា ប្រសិនបើសង្គ្រាមខ្លាំងដាងនេះ ពួកទូលបង្គំមិនអាចរំលងព្រះអង្គបាន ។ ព្រះរាជាមានព្រះរាជបំណងនឹងយាងទៅទីនោះ ទ្រង់កែនទ័ពហើយបញ្ជាឲ្យព្រះអគ្គមហេសីចូលគាល់ត្រាស់ថា នែនាងដ៏ចម្រើន យើងត្រូវទៅបច្ចន្តជនបទ នៅទីនោះ ការប្រយុទ្ធ មានច្រើនបែបយ៉ាង ឈ្នះឬចាញ់ក៏មិនប្រាកដ ក្នុងស្ថានភាពដូច្នោះ មាតុគ្រាមគ្រប់គ្រងបានដោយលំបាក ចូរនាងនៅក្នុងព្រះរាជវាំងចុះ ។ ចំណែកព្រះអគ្គមហេសីក៏ក្រាបទូលថា ខ្ញុំម្ចាស់មិនអាចនឹងនៅខាងក្រោយដូចព្រះតម្រាស់បាន ។ កាលព្រះរាជាត្រាស់ហាមហើយហាមទៀត ក៏ក្រាបទូលថា បើដូច្នោះ កាលព្រះអង្គយាងទៅបានមួយយោជន៍ សូមព្រះអង្គបញ្ជាឲ្យមនុស្សត្រឡប់មកម្នាក់ ដើម្បីទ្រង់ជ្រាបសុខទុក្ខរបស់ខ្ញុំម្ចាស់ ។ ព្រះរាជាទ្រង់យល់ព្រមហើយ ទ្រង់តែងតាំងព្រះមហាសត្វឲ្យជាអ្នករក្សានគរទ្រង់លើកកងទ័ពធំចេញទៅ ។ កាលយាងទៅបានមួយ

យោជន៍ក៏បញ្ជូនបុរសម្នាក់ឲ្យទៅដោយព្រះតម្រាស់ថា អ្នកចូរប្រាប់ការមិនមានរោគរបស់យើង ហើយចូរដឹងសុខទុក្ខរបស់ព្រះទេវី សឹមមក ។ ព្រះទេវីទ្រង់សួរបុរសដែលមកដល់ហើយថា ព្រះរាជាទ្រង់បញ្ជូនអ្នកមកធ្វើអ្វី ? កាលរាជបុរសក្រាបទូលថា ដើម្បីដឹងសុខទុក្ខរបស់ព្រះនាង ក៏ត្រាស់ថា បើដូច្នោះ ចូរមកនេះ ហើយក៏សេពអសទ្ធម្មនឹងបុរសនោះ ។ ព្រះរាជាទ្រង់យាងទៅអស់ផ្លូវ ៣២ យោជន៍ ទ្រង់បញ្ជូនមនុស្សមក ៣២ នាក់ ព្រះទេវីបានសេពអសទ្ធម្មនឹងបុរសទាំងនោះគ្រប់គ្នា ដោយទំនងដូចគ្នាទាំងអស់ ។

ព្រះរាជាទ្រង់បង្ក្រាបបច្ចន្តជនបទដោយប្រពៃហើយ បញ្ចុះបញ្ចូលអ្នកជនបទដោយល្អហើយ កាលស្ដេចត្រឡប់មកវិញ ទ្រង់បញ្ជូនរាជបុរសមក ៣២ នាក់ដូចលើកមុនទៀត ព្រះទេវីក៏ប្រព្រឹត្តខុសនឹងបុរសទាំងនោះទៀត ។ ព្រះរាជាស្ដេចមកដល់សាលាសម្នាក់ដើម្បីធ្វើការជោគជ័យ ទ្រង់បញ្ជូនព្រះរាជសារទៅប្រាប់ព្រះពោធិសត្វថា ចូរកែនគ្នាតាក់តែងនគរចុះ ។ ព្រះពោធិសត្វក៏បញ្ជាឲ្យតាក់តែងព្រះនគរ កាលនឹងប្រើមនុស្សឲ្យតាក់តែងព្រះរាជនិវេសន៍ បានទៅកាន់សម្នាក់ព្រះទេវី ។ ព្រះនាងទតឃើញរូបរាងរបស់ព្រះមហាបុរស ដល់នូវភាពដ៏លើសដោយរូបសម្បត្តិក៏មិនអាចទប់ព្រះទ័យបាន ទើបមានព្រះសវនីយ៍ថា នែព្រាហ្មណ៍មកនេះអញ្ជើញឡើងទីដេកចុះ ។

ព្រះមហាបុរសក្រាបទូលថា បពិត្រព្រះនាង កុំត្រាស់យ៉ាងនេះឡើយ ព្រះរាជាក៏ជាទីគោរពរបស់ទូលបង្គំ ទូលបង្គំក៏ខ្លាចនូវអកុសល ទូលបង្គំមិនអាចធ្វើយ៉ាងនោះបានទេ ។

ព្រះទេវីត្រាស់ថា ព្រះរាជាមិនជាទីគោរពរបស់បុរសទាំង ៦៤ នាក់ទេ ហើយអ្នកទាំងនោះក៏មិនខ្លាចអកុសលដែរ អ្នកតែម្នាក់ប៉ុណ្ណោះ គោរពព្រះរាជា អ្នកតែម្នាក់ប៉ុណ្ណោះ ខ្លាចអកុសល ។

បុរោហិតពោធិសត្វក៏ក្រាបទូលថា ប្រសិនបើមនុស្សទាំងនោះគប្បីធ្វើយ៉ាងនោះសោត ទូលបង្គំមិនគប្បីធ្វើយ៉ាងនោះ ទូលបង្គំដឹងហើយ នឹងធ្វើកម្មដ៏លាមកយ៉ាងនោះដូចម្ដេចបាន ។

ព្រះទេវីត្រាស់ថា អ្នកនិយាយដដែលៗ ឲ្យច្រើនយ៉ាងណាក៏ដោយ ប្រសិនបើមិនធ្វើតាមពាក្យរបស់យើងទេនោះ យើងនឹងកាត់ក្បាលរបស់អ្នក ។

បុរោហិតពោធិសត្វក្រាបទូលថា ត្រូវកាត់ក្បាលក្នុងអត្តភាពមួយ ក៏មិនស្មើនឹងត្រូវកាត់ក្បាលមួយពាន់អត្តភាពដែរ ទូលបង្គំមិនអាចធ្វើយ៉ាងនេះទេ ។

ព្រះនាងត្រាស់ថា ល្អើយចុះ យើងនឹងដឹង ។ មានព្រះសវនីយ៍ហើយក៏យាងចូលដំណាក់របស់ព្រះនាង សម្ដែងស្នាមក្រចកពេញព្រះ-កាយ លាបព្រះកាយដោយប្រេង ទ្រទ្រង់សំពត់ចាស់ធ្វើអាកប្បកិរិយាដូច

ជាប្រឈួន ផ្តាំទាសីទាំងឡាយថា កាលបើព្រះរាជាត្រាស់សួរថា ព្រះទេវីយាងទៅណា ? នាងទាំងឡាយគប្បីទូលថា បពិត្រព្រះសម្មតិទេព ព្រះ-ទេវីទ្រង់ប្រឈួន ។

ចំណែកព្រះមហាសត្វក៏បានទៅទទួលព្រះរាជា ។ ព្រះរាជា ទ្រង់ប្រទក្សិណព្រះនគរហើយ ស្តេចឡើងកាន់ប្រាសាទ ត្រាស់សួរថា

ព្រះទេវីយាងទៅណា ?

ពួកទាសីក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះទេវី ព្រះនាងប្រឈួន ។ ព្រះរាជាស្តេចចូលកាន់បន្ទប់ដ៏មានសិរី ទ្រង់អង្អែលខ្នងព្រះ-ទេវីបណ្តើរ សួរបណ្តើរថា នែនាងដ៏ចម្រើន នាងមិនស្រួលព្រះកាយឬ ? ព្រះនាងនៅស្ងៀម ក្នុងវារៈទី ៣ ទើបទតព្រះរាជាបណ្តើរ ក្រាបទូលបណ្តើរថា បពិត្រព្រះស្វាមី សូមរ្បីទ្រង់នៅមានព្រះជន្ម ស្ត្រីទាំងឡាយដូចខ្ញុំម្ចាស់ ក៏ជាស្ត្រីនៅមានស្វាមីដោយពិត ។

ព្រះរាជាត្រាស់សួរថា នែនាងដ៏ចម្រើន តើរឿងនោះដូចម្តេច ?

នាងក្រាបទូលថា បុរោហិតដែលព្រះអង្គតែងតាំងឲ្យជាអ្នករក្សានគរនោះបានមកទីនេះ ប្រាប់ថានឹងរៀបចំនិវេសន៍ ហើយបង្ខិតបង្ខំខ្ញុំម្ចាស់ដែលមិនធ្វើតាមពាក្យរបស់ខ្លួន ធ្វើតាមអំពើចិត្តបានសម្រេចហើយ ទើបចេញទៅ ។ ព្រះរាជាទ្រង់បន្លឺសំឡេងខ្លាំងៗ ដោយទ្រង់ព្រះពិរោធ ដូចបោះអំបិលចូលទៅក្នុងគំនរភ្លើងដូច្នេះ ។ ស្តេចចេញអំពីបន្ទប់ដ៏មានសិរី

បញ្ជាឲ្យរាជបុរសទៅចាប់បុរោហិតមក ដោយព្រះតម្រាស់ថា នែអ្នកដ៏-ចម្រើនទាំងឡាយ អ្នកទាំងឡាយចូរទៅចាប់បុរោហិត ចងស្លាបសេក ធ្វើឲ្យសមនឹងភាពជាអ្នកដែលត្រូវសម្លាប់ នាំចេញចាកនគរ នាំទៅកាន់ផ្លូវបែកជា ៤ ហើយកាត់ក្បាលចោលទៅ ។ ពួករាជបុរសប្រញាប់នាំគ្នាទៅចាប់ព្រះពោធិសត្វចងស្លាបសេក ហើយវាយបណ្តើរទូងស្គរប្រកាស ។ ព្រះពោធិសត្វត្រិះរិះថា ព្រះរាជាប្រាកដជាត្រូវព្រះទេវីអាក្រក់នោះ ក្រាបទូលញុះញង់មុន គ្រានេះ អញត្រូវដោះខ្លួនដោយប្រាជ្ញារបស់អញក្នុងថ្ងៃនេះឲ្យទាល់តែបាន ព្រះពោធិសត្វក៏ពោលទៅកាន់រាជបុរសទាំងនោះថា

នែអ្នកទាំងឡាយ អ្នកទាំងឡាយកុំអាលសម្លាប់ខ្ញុំអី នាំខ្ញុំចូលគាល់ព្រះរាជាសិន សឹមសម្លាប់ចុះ ។

ពួករាជបុរសសួរថា ព្រោះហេតុអ្វី ?

ព្រះពោធិសត្វប្រាប់ថា ខ្ញុំជាអ្នករាជការ ការងារដែលខ្ញុំត្រូវធ្វើនៅមានច្រើន ខ្ញុំរមែងដឹងទីតាំងនៃកំណប់ទ្រព្យច្រើនកន្លែង ព្រះរាជឃ្លាំងក៏ខ្ញុំត្រួតត្រាដែរ ប្រសិនបើមិននាំខ្ញុំចូលគាល់ព្រះរាជាទេ ទ្រព្យជាច្រើននឹងត្រូវវិនាស សូមឲ្យឱកាសខ្ញុំបានប្រាប់សម្បត្តិថ្វាយព្រះរាជា ពួកអ្នករង់ចាំដាក់ទោសខ្ញុំនៅពេលក្រោយចុះ ។ ពួករាជបុរសក៏នាំព្រះពោធិសត្វចូលគាល់ព្រះរាជា ។ ព្រះរាជាគ្រាន់តែទតឃើញព្រះពោធិសត្វភ្លាម ក៏ត្រាស់ថា នែព្រាហ្មណ៍ ហេតុអ្វីទើបមិនខ្លាចយើង ហេតុអ្វីទើបអ្នកធ្វើកម្មអាក្រក់

សាមាន្យបែបនេះ ?

ព្រះបរមពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំកើតក្នុងត្រកូលសោត្ថិយព្រាហ្មណ៍ ការសម្លាប់សត្វ ផ្តាច់ជីវិតត្រឹមតែស្រមោចក្រហម ស្រមោចខ្មៅក៏ទូលបង្គំមិនធ្លាប់ធ្វើដែរ វត្ថុដែលគេមិនបានឲ្យសូម្បីតែស្មៅមួយទង ទូលបង្គំក៏មិនធ្លាប់កាន់យកដែរ ស្ត្រីរបស់អ្នកដទៃ ទូលបង្គំក៏មិនដែលសូម្បីត្រឹមតែបើកភ្នែកសម្លឹងមើលដោយអំណាចលោភៈដែរ ពាក្យកុហកដើម្បីសើចលេង ទូលបង្គំក៏មិនធ្លាប់ពោល ទឹកស្រវឹងត្រឹមតែមួយតំណក់ដែលជាប់ត្រង់ចុងស្បូវ ទូលបង្គំក៏មិនធ្លាប់ផឹកដែរ ទូលបង្គំមិនបានធ្វើខុសចំពោះព្រះអង្គទេ ប៉ុន្តែព្រះទេវីជាមនុស្សពាល ចាប់ដៃទូលបង្គំដោយអំណាចរាគៈ ទាំងដែលទូលបង្គំហាមឃាត់ត្រឡប់ជាស្តីបន្ទោសទូលបង្គំ បើកបង្ហាញកំហុសដែលខ្លួនធ្វើហើយប្រាប់ទូលបង្គំ ហើយចូលកាន់បន្ទប់ ទូលបង្គំប្រាសចាកកំហុស ប៉ុន្តែបុរសទាំង ៦៤ នាក់ ដែលកាន់រាជសារមកទើបមានកំហុស បពិត្រព្រះសម្មតិទេព សូមទ្រង់ត្រាស់ហៅបុរសទាំងនោះមកសួរថា បុរសទាំងនោះបានធ្វើតាមពាក្យរបស់ព្រះទេវី ឬមិនបានធ្វើ ។ ព្រះរាជាបញ្ជាឲ្យឃុំបុរសទាំង ៦៤ នាក់នោះ ហើយបញ្ជាឲ្យហៅព្រះទេវីចូលគាល់ មានព្រះតម្រាស់សួរថា នាងធ្វើកម្មអាក្រក់ជាមួយបុរសទាំងនេះ ឬមិនបានធ្វើ ? គ្រានោះ នាងក្រាបទូលទទួលថា ខ្ញុំម្ចាស់ធ្វើមែន ។ ព្រះរាជាបញ្ជាឲ្យចាប់ព្រះទេវីចង

ស្វាបសេក ហើយទ្រង់ត្រាស់ថា ពួកឯងចូរកាត់ក្បាលបុរសទាំង ៦៤ នាក់នេះ ។ គ្រានោះ ព្រះពោធិសត្វក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព បុរសទាំងនេះក៏មិនមានទោស ព្រះទេវីបង្គាប់ឲ្យធ្វើតាមការពេញចិត្តរបស់ខ្លួន បុរសទាំងនេះឥតកំហុស ហេតុនោះ សូមទ្រង់អត់ទោសឲ្យបុរសទាំងនេះផង សូម្បីព្រះទេវីក៏គ្មានកំហុសដែរ ធម្មតាស្រ្តីទាំងឡាយជាអ្នកមិនឆ្អែតដោយមេថុនធម្ម ពិតណាស់ ការមិនឆ្អែតដោយមេថុនធម្មនេះជាសភាវធម៌ប្រចាំកំណើត វត្ថុដែលត្រូវមាន ក៏រមែងមានដល់ពួកស្រ្តីប៉ុណ្ណោះ ព្រោះហេតុនោះ សូមទ្រង់អត់ទោសឲ្យព្រះទេវីផងចុះ ។ ព្រះមហាបុរសក្រាបទូលឲ្យព្រះរាជាយល់ព្រមដោយប្រការផ្សេងៗ រហូតទាល់តែព្រះរាជាដោះលែងបុរសទាំង ៦៤ នាក់ និងព្រះទេវីដែលជាបុគ្គលពាល សូមឲ្យព្រះរាជទានតំណែងដើមរបស់ខ្លួនដល់មនុស្សទាំងនោះ ។ ព្រះមហាសត្វ លុះសូមឲ្យព្រះរាជាដោះលែងមនុស្សទាំងអស់ហើយ ទ្រង់តែងតាំងនៅក្នុងតំណែងដើមរបស់ខ្លួនយ៉ាងនេះហើយ ចូលគាល់ព្រះរាជាក្រាបទូលថា បពិត្រមហារាជ ពួកបណ្ឌិតមិនគួរជាប់ឃុំឃាំង ប៉ុន្តែត្រូវជាប់ឃុំ ព្រោះពាក្យសម្តីដែលមិនពិតរបស់បុគ្គលដែលហៅថា បុគ្គលអន្ធពាល ពួកបណ្ឌិតរួចផុតបាន សូម្បីអំពីចំណង ដោយពាក្យដ៏ប្រពៃមានហេតុមានផល ធម្មតាពួកបុគ្គលពាល សូម្បីពួកជនដែលមិនគួរចាប់ចង ក៏ធ្វើឲ្យត្រូវចាប់ចងបាន បណ្ឌិតរមែងដោះឲ្យរួចផុតអំពីការចងទាំងឡាយ

បានយ៉ាងនេះ ហើយពោលគាថានេះថា

**អពន្ធា តត្ថ ពជ្ឈន្តិ យត្ថ ពាលា បកាសរេ**

**ពទ្ធាបិ តត្ថ មុច្ចន្តិ យត្ថ ធីរា បកាសរេតិ ។**

ជនពាលទាំងឡាយ ពោលក្នុងទីណា ពួកជនដែលមិនទាន់ជាប់ រមែងជាប់នៅក្នុងទីនោះ អ្នកប្រាជ្ញទាំងឡាយ ពោលក្នុងទីណា ពួកជនសូម្បីជាប់ហើយ រមែងរួចក្នុងទីនោះ ។

បណ្ដាបទទាំងនោះ បទថា **អពទ្ធា** ប្រែថា ពួកជនមិនទាន់ចង ។ បទថា **បកាសរេ** ប្រែថា រមែងបើកបង្ហាញ គឺរមែងប្រាប់ រមែងពោល ។

ព្រះបរមពោធិសត្វសម្ដែងធម៌ថ្វាយព្រះរាជាដោយគាថានេះ ដោយប្រការដូច្នេះហើយ ក្រាបទូលសូមអនុញ្ញាតការចេញទៅបួសថា បពិត្រព្រះសម្មតិទេព ទុក្ខទាំងនេះ ទូលបង្គំបានទទួលព្រោះការនៅគ្រប់គ្រងផ្ទះ សូមទ្រង់អនុញ្ញាតឲ្យទូលបង្គំចេញទៅបួសផងចុះ ហើយលះបង់ពួកញាតិដែលមានមុខជោកដោយទឹកភ្នែក និងលះបង់ទ្រព្យសម្បត្តិដ៏ច្រើន បួសជាតាបសនៅក្នុងព្រៃហេមពាន្ត ញ៉ាំងឈាននិងសមាបត្តិឲ្យកើតឡើង ក្រោយអំពីចុតិ មានព្រហ្មលោកជាទីទៅខាងមុខ ។

ព្រះបរមសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រះទេវីអាក្រក់ក្នុងកាលនោះ បានមកជានាងចិញ្ចមាណវិកា

*ក្នុងកាលឥឡូវនេះ ព្រះរាជាបានមកជាអានន្ទ ចំណែកបុរោហិត គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា ពន្ធនមោក្ខជាតក ទី ១០ ។

ចប់ អដ្ឋកថា ហំសិវគ្គ ទី ១២ ។

## រួមជាតកដែលមានក្នុងវគ្គនេះគឺ

*គទ្រភបញ្ហា ១ អមរាទេវិបញ្ហា ១ សិគាលជាតក ១ មិតចិន្តិជាតក ១ អនុសាសិកជាតក ១ ទុព្វចជាតក ១ តិត្តិរជាតក ១ វដ្តកជាតក ១ អកាលរាវិជាតក ១ ពន្ធនមោក្ខជាតក ១ ។*

# កុសនាឡិវគ្គ ទី ១៣

# អដ្ឋកថា កុសនាឡិជាតក ទី ១

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមិត្តអ្នកចង្អុលបង្ហាញការងាររបស់អនាថបិណ្ឌិកសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្តើមថា **ករេ សរិក្ខោ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា មិត្តស្និទ្ធស្នាលញាតិភូមិផងរបស់អនាថបិណ្ឌិក-សេដ្ឋីរួមគ្នាហាមប្រាមរឿយៗថា បពិត្រមហាសេដ្ឋី បុគ្គលនេះមិនស្មើនឹងលោកដោយជាតិ គោត្រ ទ្រព្យ និងធញ្ញជាតិជាដើម ទាំងមិនដូចលោកទៅទៀត ហេតុអ្វីទើបលោកធ្វើសេចក្តីស្និទ្ធស្នាលនឹងបុគ្គលបែបនេះ ? សូមលោកកុំធ្វើសេចក្តីស្និទ្ធស្នាលនឹងបុគ្គលបែបនេះឡើយ ចំណែកអនាថ - បិណ្ឌិកត្រឡប់ជានិយាយថា ធម្មតាសេចក្តីស្និទ្ធស្នាលគ្នានិងឆន្ទមិត្ត គឺមិត្តដែលមានឆន្ទស្មើគ្នាក្តី ជាមួយនឹងបុគ្គលដែលទាបជាងក្តី ស្មើគ្នាក្តី ខ្ពស់ជាងក្តី គួរធ្វើទាំងអស់ ហើយមិនយកចិត្តទុកដាក់នឹងពាក្យសម្តីអ្នកទាំង-នោះ កាលនឹងទៅស្រុកសួយ ក៏តែងតាំងបុរសនោះឲ្យជាអ្នកមើលថៃទ្រព្យសម្បត្តិហើយទើបចេញទៅ រឿងរ៉ាវទាំងអស់ គប្បីជ្រាបតាមន័យដូចដែលបានពោលហើយនៅក្នុងរឿង **កាឡកណ្ណិជាតក** នោះចុះ ប្លែកតែថាក្នុងរឿងនេះ កាលអនាថបិណ្ឌិកក្រាបទូលរឿងរ៉ាវក្នុងផ្ទះរបស់ខ្លួនហើយ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលគហបតី ធម្មតាមិត្តនឹង

ជាអ្នកតូចទាបមិនមាន ក៏ភាពជាអ្នករក្សាមិត្តធម៌ទុក បានជាប្រមាណក្នុងរឿងមិត្តនេះ ធម្មតាមិត្តស្មើនឹងខ្លួនក្តី ថោកទាបជាងខ្លួនក្តី ខ្ពស់ជាងខ្លួនក្តី គួរសេពគប់ទាំងអស់ ដ្បិតថា មិត្តទាំងអស់នោះ រមែងជួយសម្រាលភារៈដែលមកដល់ខ្លួនបានទាំងអស់ ពេលនេះអ្នកអាស្រ័យមិត្តអ្នកចង្អុលបង្ហាញការងាររបស់ខ្លួន ទើបជាម្ចាស់កំណប់ទ្រព្យតទៅបាន ចំណែកបុរាណបណ្ឌិតអាស្រ័យមិត្តអ្នកចង្អុលបង្ហាញ ទើបជាម្ចាស់នៃវិមានបាន ។ កាលអនាថបិណ្ឌិកក្រាបទូលអារាធនា ទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាទេវតានៅនឹងគុម្ពស្បូវភ្លាំងក្នុងព្រះរាជឧទ្យានរបស់ព្រះរាជា ។ ក្នុងឧទ្យាននោះមានដើមឈើមួយដើមបែកមែកសាខា អាស្រ័យមង្គលសិលា មានដើមត្រង់ ដល់ព្រមដោយបរិមណ្ឌលមែកនិងប្រគាប បានទទួលការសរសើរអំពីរាជសម្នាក់មានឈ្មោះហៅថា រុចមង្គលព្រឹក្ស ព្រោះមានទេវរាជមានសក្តិធំមួយអង្គកើតនៅនឹងដើមឈើនោះ ព្រះបរមពោធិសត្វស្និទ្ធស្នាលនឹងទេវរាជនោះ ។ គ្រានោះ ព្រះរាជាស្តេចគង់នៅលើប្រាសាទសសរមួយ សសរប្រាសាទនោះញ័រ ពេលនោះ ពួករាជបុរសក្រាបទូលអំពីការញ័រនៃសសរនោះចំពោះព្រះរាជា ។ ព្រះរាជាត្រាស់ឲ្យហៅពួកជាងឈើមកគាល់ហើយត្រាស់ថា

នៃអ្នកដ៏ចម្រើនទាំងឡាយ សសរមួយនៃប្រាសាទមង្គលញ័រហើយ អ្នកទាំងឡាយចូរយកសសរឈើខ្ទឹមដទៃមកជំនួស ធ្វើសសរនោះកុំឲ្យញ័រចុះ ។ ជាងទាំងនោះទទួលព្រះរាជតម្រាស់របស់ព្រះរាជាថា សាធុ ហើយនាំគ្នាស្វែងរកឈើដែលសមគួរដល់សសរនោះ មិនបានក្នុងទីដទៃ ទើបចូលទៅកាន់ឧទ្យានឃើញដើមឈើដែលមានឈ្មោះថា រុចមង្គលនោះ ក៏នាំគ្នាទៅកាន់សម្នាក់ព្រះរាជា ។ កាលព្រះរាជាត្រាស់សួរថា នៃអ្នកទាំង-ឡាយ ដើមឈើដែលសមគួរដល់យើងនោះ អ្នកទាំងឡាយរកបានហើយឬ ?

ពួកជាងក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកទូលបង្គំរកឃើញហើយ ក៏ប៉ុន្តែថា មិនអាចកាត់ដើមឈើនោះបាន ។

ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ?

ពួកជាងក្រាបទូលថា ពួកទូលបង្គំរកដើមឈើក្នុងទីដទៃមិនបានក៏នាំគ្នាចូលកាន់ព្រះរាជឧទ្យាន ក្នុងព្រះរាជឧទ្យាននោះវៀររុចមង្គលព្រឹក្សចេញ មិនឃើញមានដើមឈើណាមួយដូច្នោះ ពួកទូលបង្គំមិនហ៊ានកាត់ដើមឈើនោះ ។

ព្រះរាជាត្រាស់ថា អ្នកទាំងឡាយចូរកាត់ដើមឈើនោះ ធ្វើប្រាសាទឲ្យមាំចុះ យើងនឹងតែងតាំងដើមឈើដទៃឲ្យជាមង្គលព្រឹក្សជំនួសវិញ ។ ពួកជាងទាំងនោះទទួលព្រះតម្រាស់ហើយ នាំគ្នាកាន់គ្រឿងពលិកម្មទៅ

កាន់ឧទ្យានសម្រេចចិត្តថា នឹងកាត់ក្នុងថ្ងៃស្អែក ធ្វើពលិកម្មដើមឈើនោះហើយ ទើបដើរចេញទៅ ។ រុក្ខទេវតាដឹងរឿងនោះហើយ គិតថា ស្អែកនេះ វិមានរបស់អញនឹងវិនាស អញនឹងកូនៗទៅកាន់ទីណាហ្ន៎ កាលមិនឃើញទីដែលគួរទៅក៏ឱបកូនតូចៗយំ ។ ពួករុក្ខទេវតាដែលស្និទ្ធស្នាលនឹងរុក្ខទេវតានោះក៏សួរថា មានរឿងអ្វី ? លុះបានដឹងរឿងនោះហើយខ្លួនឯងក៏មិនមានឧបាយដែលនឹងហាមជាងឈើបាន ក៏ពោះបង់ទេវតានោះ ផ្ដើមយំតាមគ្នា ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វត្រិះរិះថា អញនឹងទៅសួរសុខទុក្ខរុក្ខទេវតា ទើបទៅកាន់ទីនោះ ដឹងរឿងនោះហើយ ក៏លួងលោមរុក្ខទេវតាទាំងនោះថា ណ្ហើយចុះ អ្នកទាំងឡាយកុំព្រួយ ខ្ញុំនឹងមិនឲ្យកាប់ដើមឈើនោះទេ ស្អែកនេះពេលពួកជាងមក អ្នកទាំងឡាយចាំមើលហេតុការណ៍របស់ខ្ញុំចុះ ។ លុះស្អែកឡើង ពេលពួកជាងនាំគ្នាមកដល់ ក៏កាឡាខ្លួនធ្វើជាសត្វបង្កួយរត់នាំមុខពួកជាងឈើ ចូលកាន់គល់រុចមង្គលព្រឹក្ស ធ្វើដូចជាដើមឈើនោះមានប្រហោង ចូលទៅតាមពកនៃដើមឈើនោះ ទៅចេញនៅចុងឈើ ដេកផ្ងក់ក្បាលនៅលើចុងឈើនោះ ។ មេជាងឃើញបង្កួយនោះហើយ ក៏យកដៃទះដើមឈើនោះ រួចតិះដៀលដើមឈើដែលមានខ្លឹមនោះយ៉ាងចាស់ដៃថា ដើមឈើនេះមានប្រហោងឥតខ្លឹមកាលពីម្សិលមិញអញមិនបានពិនិត្យឲ្យបានល្អិតល្អន់ លួងនាំគ្នាធ្វើពលិ-

*កម្មដើមឈើនេះ ដូច្នោះហើយ ក៏នាំគ្នាចៀសចេញទៅ ។ រុក្ខទេវតាអាស្រ័យព្រះបរមពោធិសត្វទើបបានជាម្ចាស់វិមានដដែល ដើម្បីអបអររុក្ខទេវតានោះ ទេវតាដែលស្និទ្ធស្នាលជាច្រើនប្រជុំគ្នា ។ រុក្ខទេវតាសប្បាយចិត្តថា ខ្ញុំបានវិមានវិញហើយ កាលនឹងពោលគុណរបស់ព្រះបរមពោធិសត្វក្នុងកណ្ដាលទីប្រជុំទេវតាទាំងនោះ ទើបពោលថា នៃទេពដ៏ចម្រើនទាំងឡាយ ពួកយើងសូម្បីបានជាទេវតាអ្នកមានសក្តិយ៉ាងនេះក៏ដោយ ក៏មិនបានដឹងឧបាយនេះ ព្រោះបញ្ញាដ៏ក្រាស់របស់កុសនាឡិទេវតា ទើបធ្វើឲ្យយើងជាម្ចាស់វិមានវិញបាន ព្រោះញាណសម្បត្តិរបស់ខ្លួន ធម្មតាមិត្តមិនរើសថាស្មើគ្នា ក្រៃលែងជាង ឬថោកទាបជាងឡើយ គឺគួរសេពបានទាំងអស់ មិត្តសូម្បីគ្រប់គ្នា អាចកម្ចាត់ទុក្ខដែលកើតឡើងដល់មិត្ត ឲ្យតាំងនៅក្នុងសេចក្ដីសុខបានតាមកម្លាំងរបស់ខ្លួន ។ លុះពណ៌នាអំពីមិត្តធម៌ហើយ បានពោលគាថានេះថា*

**ករេ សរិក្ខោ អថវាបិ សេដ្ឋោ**
**និហីនកោ វាបិ ករេយ្យ ឯកោ**
**ករេយ្យុមេតេ ព្យសនេ ឧត្តមត្ថំ**
**យថា អហំ កុសនាឡិ រុចាយន្តិ ។**

*ជនស្មើគ្នាក្តី ទាំងជនប្រសើរជាងក្តី ថោកទាបជាងក្តី គប្បីធ្វើ (នូវមិត្តធម៌) សូម្បីជនម្នាក់ជាអ្នកថោកទាប ក៏គប្បីធ្វើ*

*(នូវមិត្តធម៌ដែរ) ព្រោះមិត្តទាំងនោះ គប្បីធ្វើនូវប្រយោជន៍ដ៏ឧត្តម ក្នុងកាលដែលមានសេចក្ដីវិនាស ដូចជាខ្ញុំជាទេវតាឈ្មោះរុចា និងទេវតា ឈ្មោះកុសនាឡិ ធ្វើនូវប្រយោជន៍ដ៏ឧត្តម (ក្នុងកាលដែលមានសេចក្ដីវិនាស)។*

*បណ្ដាបទទាំងនោះ បទថា* **ករេ សរិក្ខោ** *សេចក្ដីថា សូម្បីជាមនុស្សថោកទាប ដោយជាតិជាដើម ក៏គប្បីធ្វើនូវមិត្តធម៌ ព្រះសម្មាសម្ពុទ្ធសម្ដែងសេចក្ដីថា ហេតុនោះ ជនទាំងអស់នោះ គួរធ្វើឲ្យជាមិត្តបានទាំងអស់។*

*បទថា* **អថវាបិ សេដ្ឋោ** *សេចក្ដីថា អ្នកខ្ពស់ជាង គឺក្រៃលែងជាងដោយជាតិជាដើម ក៏គួរគប់រក។*

*បទថា* **និហីនកោ វាបិ ករេយ្យ ឯកោ** *សេចក្ដីថា សូម្បីអ្នកស្មើគ្នាដោយឋានៈ មានជាតិជាដើម ក៏គួរគប់រកគ្នាដែរ ។*

*សួរថា ព្រោះហេតុអ្វី?*

*ឆ្លើយថា ព្រោះមិត្តទាំងនោះ កាលដែលសេចក្ដីវិនាសកើតឡើង ក៏អាចធ្វើនូវប្រយោជន៍ដ៏ឧត្តមឲ្យបាន អធិប្បាយថា ព្រោះមិត្តទាំងអស់នេះ កាលដែលវិបត្តិកើតឡើងដល់សម្លាញ់ហើយ ក៏ជួយបែងចែកសម្រាលភារៈដែលមកដល់ខ្លួន ធ្វើនូវប្រយោជន៍ដ៏ឧត្តមបាន គឺជួយដោះសម្លាញ់នោះ ឲ្យរួចចាកផុតអំពីទុក្ខតាមផ្លូវកាយ ទុក្ខតាមផ្លូវចិត្តបាន ព្រោះហេតុ-*

នោះ សូម្បីជនម្នាក់ជាអ្នកថោកទាបជាង ក៏គប្បីគប់រកមិត្តធម៌ដែរ ចាំ-
បាច់ពោលទៅថ្វីដល់មិត្តក្រៅពីនេះ ក្នុងសេចក្តីនោះ មានរឿងនេះជា
គ្រឿងឧបមា ដូចជាខ្ញុំជាទេវតាកើតនៅនឹងដើមរុចា និងទេវតាកើតនៅនឹង
គុម្ពស្បូវភ្ញាំងមានសក្តិតូច ធ្វើនូវសេចក្តីស្និទ្ធស្នាលនឹងគ្នា យើងទាំងពីរ-
នាក់ សូម្បីខ្ញុំមានសក្តិធំ ក៏មិនអាចកម្ចាត់ទុក្ខដែលកើតដល់ខ្លួនបាន ព្រោះ
ជាមនុស្សល្ងង់ខ្លៅ មិនឈ្លាសក្នុងឧបាយ ប៉ុន្តែបានអាស្រ័យទេវតានេះ
សូម្បីមានសក្តិតូច តែជាបណ្ឌិត ទើបរួចផុតអំពីទុក្ខបានដូច្នោះ ។ ព្រោះ
ហេតុនោះ សូម្បីបុគ្គលដទៃៗ ប្រាថ្នាផុតទុក្ខ ក៏មិនចាំបាច់នឹកដល់ការស្មើ
ឬការវិសេសជាងគ្នា គប្បីគប់មិត្ត ទាំងថោកទាប ទាំងប្រណីត ។

រុចាទេវតាសម្តែងធម៌ដល់ទេវតាដោយគាថានេះ រស់នៅអស់អាយុ-
ក្ខ័យហើយ ក្រោយអំពីចុតិក៏ទៅតាមយថាកម្ម ឯកុសនាឡិទេវតាក៏ដូចគ្នា ។

ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់
ប្រជុំជាតកថា រុចាទេវតាក្នុងកាលនោះ បានមកជាអានន្ទ ចំណែក
កុសនាឡិទេវតា គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា កុសនាឡិជាតក ទី ១ ។

# អដ្ឋកថា ទុម្មេធជាតក ទី ២

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យសំ លទ្ធា ន ទុម្មេធោ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ភិក្ខុទាំងឡាយនាំគ្នាពោលទោសភិក្ខុទេវទត្តក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ ភិក្ខុទេវទត្តសម្លឹងមើលព្រះភក្រ្តដ៏មានសិរីដូចព្រះចន្ទពេញវង់ ព្រះកាយដែលប្រដាប់ដោយអនុព្យញ្ជនៈ ៨០ និងមហាបុរិសលក្ខណៈ ៣២ ប្រការ ព័ទ្ធជុំវិញដោយព្រះរស្មីដែលផ្សាយចេញប្រមាណ ១ ព្យាម ដល់នូវលម្អដ៏លើស ផ្សាយព្រះពុទ្ធរស្មីជាគូៗ ដោយអាការផ្សេងៗ ធ្លាស់គ្នារបស់ព្រះតថាគតហើយ មិនអាចញុំាងចិត្តឲ្យជ្រះថ្លាបាន មិនតែប៉ុណ្ណោះ នៅញុំាងសេចក្តីប្រណែនឲ្យកើតឡើងនៅពេលដែលមានអ្នកណាពោលថា ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់ប្រកបដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈយ៉ាងនេះ ញុំាងសេចក្តីប្រណែនតែម្យ៉ាងឲ្យកើតឡើង ។ ព្រះបរមសាស្តា ស្តេចយាងមកទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយ ក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលភិក្ខុទេវទត្តញុំាងឥស្សាឲ្យកើតឡើងចំពោះតថាគត

ក្នុងកាលដែលមានអ្នកពោលដល់គុណរបស់តថាគតនោះ សូម្បីក្នុងកាលមុនក៏ធ្លាប់ធ្វើហើយដែរ ហើយទ្រង់ក៏នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទមគធៈមួយអង្គគ្រងរាជសម្បត្តិនៅក្នុងនគររាជគ្រឹះ ព្រះបរមពោធិសត្វសោយព្រះជាតិជាដំរីសដល់ព្រមដោយរូបសម្បត្តិ ដូចដែលពណ៌នាមកហើយខាងដើម ( សីលវនាគជាតក ) ។ ព្រះរាជាអង្គនោះទ្រង់ព្រះតម្រិះថា ដំរីនេះសម្បូរដោយលក្ខណៈ ទើបទ្រង់តែងតាំងដំរីនោះ ឲ្យជាមង្គលហត្ថី ។ លុះដល់ថ្ងៃមហោស្រពមួយ ទ្រង់បញ្ជាឲ្យតាក់តែងនគរទាំងអស់ឲ្យល្អដូចទេវនគរ ស្ដេចឡើងកាន់មង្គលហត្ថីដែលប្រដាប់ដោយគ្រឿងអលង្ការសព្វគ្រប់ ទ្រង់ប្រទក្សិណនគរដោយរាជានុភាពដ៏ធំ មហាជនឈរមើលក្នុងទីផ្សេងៗឃើញសរីរៈដែលដល់នូវលម្អដ៏ប្រសើរដោយសម្បត្តិនៃមង្គលហត្ថី ក៏នាំគ្នាពណ៌នាអំពីមង្គលហត្ថីប៉ុណ្ណោះថា រូបល្អ ដើរសង្ហា អាកប្បកិរិយាអង់អាច បរិបូណ៌ដោយលក្ខណៈពិតៗ ស្ដេចដំរីសមានសភាពបែបនេះ សមគួរជាគូនឹងបុញ្ញបារមីនៃស្ដេចចក្រពត្តិ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវការសរសើរមង្គលហត្ថីដូច្នោះ ទ្រង់មិនអាចទប់ព្រះទ័យបាន ទ្រង់កើតឥស្សា ទ្រង់ត្រិះរិះថា ថ្ងៃនេះអញនឹងឲ្យដំរីនេះធ្លាក់ពីលើភ្នំស្លាប់ឲ្យទាល់តែបាន លុះទ្រង់ត្រិះរិះដូច្នោះហើយត្រាស់ឲ្យហៅនាយហត្ថាចារ្យមកសួរថា ដំរីនេះត្រូវធ្វើយ៉ាងណាខ្លះ អ្នក

ឲ្យសិក្សាហើយឬ ? នាយហត្ថាចារ្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំឲ្យសិក្សាល្អហើយ ។ ព្រះរាជាត្រាស់ជំទាស់ថា នៅសិក្សាមិនទាន់ល្អទេ នាយហត្ថាចារ្យក្រាបទូលជដែលទៀតថា បពិត្រព្រះសម្មតិទេព ហ្វឹកហាត់ល្អហើយ ។ ទ្រង់ត្រាស់ថា ប្រសិនបើហ្វឹកហាត់ល្អហើយ អ្នកអាចឲ្យដំរីនោះឡើងកំពូលភ្នំវេបុល្លៈបានឬ ? នាយហត្ថាចារ្យក្រាបទូលថា អាចព្រះអង្គ ។ ទ្រង់ត្រាស់ថា បើដូច្នោះ មកចុះ ហើយទ្រង់ចុះអំពីដំរី ឲ្យនាយហត្ថាចារ្យឡើងអង្គុយបរទៅដល់ជើងភ្នំ កាលនាយហត្ថាចារ្យអង្គុយលើខ្នងដំរីបរទៅដល់កំពូលភ្នំវេបុល្លៈហើយ សូម្បីព្រះរាជាដែលហែហមដោយពួកអាមាត្យក៏ស្តេចឡើងកាន់កំពូលភ្នំ ហើយទ្រង់ប្រាប់នាយហត្ថាចារ្យឲ្យដាក់ដំរីបែរមុខទៅរកជ្រោះ បញ្ជាថា អ្នកចូរប្រាប់ដំរីដែលហ្វឹកហាត់ល្អហើយឲ្យឈរជើងបី ។ នាយហត្ថាចារ្យអង្គុយលើខ្នងបានឲ្យសញ្ញាដល់ដំរីដោយកែងជើង ឲ្យដំរីដឹងថា នៃបា ចូរឈរជើងបីចុះ ។ ព្រះរាជាបញ្ជាថា ឲ្យដំរីឈរដោយជើងមុខពីរប៉ុណ្ណោះចុះ ។ ដំរីពោធិសត្វក៏លើកជើងក្រោយទាំងពីរឡើងឈរដោយជើងមុខពីរប៉ុណ្ណោះ សូម្បីកាលព្រះរាជាត្រាស់ថា ឲ្យដំរីឈរដោយជើងក្រោយទាំងពីរចុះ ក៏លើកជើងមុខទាំងពីរឡើងឈរដោយជើងក្រោយ សូម្បីកាលព្រះរាជាត្រាស់ថា ឲ្យដំរីឈរដោយជើងមួយ ក៏លើកជើងទាំងបីឡើងឈរដោយជើងមួយប៉ុណ្ណោះ ។ ព្រះរាជា លុះទ្រង់ដឹងថាស្តេចដំរីនោះ មិនធ្លាក់ទៅក្នុងជ្រោះ ក៏ត្រាស់ថា

ប្រសិនបើអាចពិត ក៏ចូរឲ្យដំរីឈរក្នុងអាកាសចុះ ។ នាយហត្ថាចារ្យគិតថា ក្នុងជម្ពូទ្វីបទាំងមូល ដំរីដែលបានហ្វឹកហាត់ល្អហើយ ដូចស្តេចដំរីនេះមិនមានឡើយ ក៏ប៉ុន្តែព្រះរាជាអង្គនេះ មានបំណងឲ្យស្តេចដំរីនេះធ្លាក់ពីលើភ្នំស្លាប់ជាពិតប្រាកដដោយឥតសង្ស័យ គិតហើយក៏ខ្សឹបជិតត្រចៀកដំរីថា នែបា ព្រះរាជាអង្គនេះមានព្រះរាជបំណងនឹងឲ្យអ្នកធ្លាក់ពីលើភ្នំស្លាប់ អ្នកមិនមែនជាគូនឹងព្រះរាជានេះទេ ប្រសិនបើអ្នកមានកម្លាំងអាចទៅតាមផ្លូវអាកាសបាន ក៏ចូរនាំយើងដែលអង្គុយលើខ្នងហោះឡើងកាន់វេហាស៍ ឆ្ពោះទៅកាន់នគរពារាណសីចុះ ។ ព្រះបរមពោធិសត្វដល់ព្រមដោយបុញ្ញឫទ្ធិ បានឈរនៅក្នុងអាកាស ក្នុងខណៈនោះឯង ។ នាយហត្ថាចារ្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ដំរីដែលដល់ព្រមដោយបុញ្ញឫទ្ធិ មិនសមគួរដល់អ្នកដែលមានបុណ្យតិច ឥតបញ្ញាដូចព្រះអង្គទេ សមគួរដល់ព្រះរាជាដែលជាបណ្ឌិតដល់ព្រមដោយបុណ្យដែលឈ្មោះថា បុគ្គលមានបុណ្យតិចដូចព្រះអង្គ សូម្បីបានពាហនៈដូច្នេះ ក៏មិនបានដឹងគុណ គិតតែញុំាងពាហនៈនោះនិងយសដ៏សេសឲ្យវិនាសតែម្យ៉ាងប៉ុណ្ណោះ ទាំងដែលនៅអង្គុយលើកដំរីនោះឯងបានពោលគាថានេះថា

យសំ លទ្ធា ន ទុម្មេធោ អនត្ថំ ចរតិ អត្តនោ
អត្តនោ ច បរេសញ្ច ហឹសាយ បដិបជ្ជតីតិ ។

*បុគ្គលឥតប្រាជ្ញា បានយសបរិវារហើយ តែងប្រព្រឹត្តនូវ*
*កម្មមិនជាប្រយោជន៍ដល់ខ្លួន ទាំងប្រតិបត្តិ ដើម្បីបៀត-*
*បៀនដល់ខ្លួនឯងផង ដល់ជនទាំងឡាយដទៃផង ។*

ក្នុងគាថានោះ មានសេចក្ដីសង្ខេបដូច្នេះថា បពិត្រព្រះសម្មតិទេព បុគ្គលល្ងង់ គឺបុគ្គលឥតប្រាជ្ញាដូចព្រះអង្គ បានបរិវារសម្បត្តិហើយ តែងតែប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់ខ្លួន ព្រោះហេតុអ្វី ? ព្រោះថា បុគ្គលល្ងង់ខ្លៅទាំងនោះ ស្រវឹងក្នុងយសហើយ មិនបានដឹងថា អំពើណាដែលខ្លួនគួរធ្វើ ឬមិនគួរធ្វើ រមែងធ្វើនូវអំពើបៀតបៀនខ្លួនឯងនិងអ្នកដទៃ គឺរមែងប្រព្រឹត្តទៅដើម្បីញ៉ាំងនូវសេចក្ដីលំបាក និងសេចក្ដីទុក្ខឲ្យកើតឡើង ដែលហៅថាបៀតបៀនប៉ុណ្ណោះឯង ។

នាយហត្ថាចារ្យសម្ដែងធម៌ថ្វាយព្រះរាជាដោយគាថានេះហើយ ក្រាបទូលថា ពេលនេះសូមព្រះអង្គស្ដេចគង់ចុះ ហើយនាំដំរីហោះឡើងទៅក្នុងអាកាសឆ្ពោះមុខទៅកាន់នគរពារាណសី ហើយឈប់នៅកណ្ដាលអាកាសលើលានព្រះរាជវាំង ។ មនុស្សទាំងនគរស្រែកដោយមានសំឡេងតែមួយថា ដំរីសរបស់ព្រះរាជានៃពួកយើងមកតាមផ្លូវអាកាស ឈប់លើលានព្រះរាជវាំង ។ រាជបុរសទាំងឡាយប្រញាប់ទៅក្រាបទូលព្រះរាជា ព្រះរាជាស្ដេចយាងមកត្រាស់សួរថា ប្រសិនបើអ្នកមកដើម្បីជាឧបភោគដល់យើង អញ្ជើញចុះមក ឈរលើផែនដីចុះ ។ ព្រះបរមពោធិសត្វក៏ចុះ

*មកឈរនៅលើផែនដី នាយហត្ថាចារ្យក៏ចុះអំពីកដំរីថ្វាយបង្គំព្រះរាជា បាន ទទួលព្រះរាជតម្រាស់ថា នែបា អ្នកមកអំពីទីណា ? នាយហត្ថាចារ្យ ក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមកអំពីនគររាជគ្រឹះ ហើយ ក្រាបទូលរឿងទាំងអស់ឲ្យទ្រង់ជ្រាប ។ ព្រះរាជាត្រាស់ថា នែបាដ៏ចម្រើន ការដែលអ្នកមកទីនេះ បានធ្វើអំពើដែលគួររីករាយពិតហើយ ទ្រង់មាន ព្រះទ័យត្រេកអរត្រាស់ឲ្យរៀបចំនគរ ទ្រង់តាំងស្តេចដំរីក្នុងតំណែងមង្គល-ហត្ថី ទ្រង់ចែករាជសម្បត្តិទាំងអស់ជាបីចំណែក មួយចំណែកព្រះរាជទាន ដល់ដំរីពោធិសត្វ មួយចំណែកព្រះរាជទានដល់ហត្ថាចារ្យ មួយចំណែក ព្រះអង្គគ្រប់គ្រង ។ ចាប់តាំងពីពេលដែលព្រះបរមពោធិសត្វមកដល់ នគរពារាណសីនោះឯង រាជសម្បត្តិនៅក្នុងជម្ពូទ្វីបទាំងអស់ក៏បិតនៅក្នុង កណ្តាប់ព្រះហស្តរបស់ព្រះរាជា ទ្រង់ជាព្រះរាជាដ៏ក្រៃលែងក្នុងជម្ពូទ្វីប ទ្រង់បំពេញបុណ្យមានឲ្យទានជាដើម ក្រោយអំពីសោយទិវង្គត ស្តេច ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ ប្រជុំជាតកថា ព្រះរាជានគរមគធៈក្នុងកាលនោះ បានមកជាទេវទត្ត ព្រះបាទពារាណសី បានមកជាសារីបុត្ត នាយហត្ថាចារ្យបានមកជាអានន្ទ ចំណែកស្តេចដំរីស គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា ទុម្មេធជាតក ទី ២ ។

# អដ្ឋកថា នង្គលីសជាតក ទី ៣

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះ-លោឡុទាយិត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អសព្វត្ថគាមឹ វាចំ** ដូច្នេះជាដើម ។

បានឮថា ព្រះថេរៈនោះ កាលពោលធម៌ មិនបានដឹងធម៌ដែលគួរនិងមិនគួរថា ក្នុងទីនេះគួរពោលធម៌នេះ ក្នុងទីនេះមិនគួរពោលធម៌នេះ ក្នុងមង្គលការក៏ពោលអវមង្គល ពោលអនុមោទនាអវមង្គលនេះថា ពួកប្រេតទាំងឡាយនាំគ្នាមកឈរនៅខាងក្រៅជញ្ជាំង ជិតទ្វារក្រុងនិងទ្វារផ្ទះជាដើម លុះដល់អវមង្គល កាលធ្វើការអនុមោទនា ត្រឡប់ពោលថា ទេវតានិងមនុស្សទាំងឡាយជាច្រើន បានគិតរកនូវមង្គលទាំងឡាយជាដើម ហើយពោលដដែលៗ ថា សូមឲ្យអ្នកទាំងឡាយអាចធ្វើមង្គលបែបនោះ ឲ្យបាន ១ រយដង ១ ពាន់ដងចុះ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយលើករឿងនេះឡើងសន្ទនាគ្នាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ ព្រះ-លោឡុទាយិត្ថេរ មិនបានដឹងធម៌ដែលគួរនិងមិនគួរ ពោលវាចាដែលមិនគួរពោលទូទៅគ្រប់ទីកន្លែង ។ ព្រះបរមសាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះទេ ដែល

លោឡុទាយិត្ថេរនេះមិនឈ្លាសវៃ កាលពោលធម៌ ក៏មិនដឹងធម៌ដែលគួរ និងមិនគួរនោះ សូម្បីក្នុងកាលមុនក៏ជាអ្នកនិយាយផ្ដេសផ្ដាសដូច្នោះដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍មហាសាល ចម្រើនវ័យហើយ រៀនសព្វសិល្បវិទ្យាក្នុងនគរតក្កសិលា បានជាអាចារ្យទិសាបាមោក្ខក្នុងនគរពារាណសី បង្រៀនសិល្បវិទ្យាដល់មាណព ៥០០ រូប ។ គ្រានោះ បណ្ដាមាណពទាំងនោះ មានមាណពម្នាក់មិនឈ្លាសវៃ ( បញ្ញាទន់ខ្សោយ ) និយាយផ្ដេសផ្ដាស ជាធម្មន្តេវាសិក (សិស្សដែលបម្រើគ្រូសុំរៀន មិនមានរង្វាន់សម្រាប់គ្រូ) ប៉ុន្តែមិនអាចរៀនបាន ( រៀនមិនចេះ ) ព្រោះជាអ្នកអាប់ប្រាជ្ញា ប៉ុន្តែជាអ្នកមានឧបការៈចំពោះព្រះបរមពោធិសត្វ ធ្វើកិច្ចគ្រប់យ៉ាងដូចជាទាសៈ ។ ថ្ងៃមួយ ព្រះពោធិសត្វបរិភោគអាហារល្ងាចហើយសម្រាន្តនៅលើគ្រែ ពោលនឹងមាណពដែលមកប្រាប់ដៃ ជើង និងខ្នងឲ្យថា នែអ្នកដ៏ចម្រើន អ្នកជួយកល់ជើងគ្រែឲ្យបន្តិចសិន សឹមទៅ ។ មាណពកល់ជើងគ្រែម្ខាងហើយ មិនមានអ្វីកល់ជើងគ្រែម្ខាងទៀត ក៏លើកដាក់លើជើងរបស់ខ្លួនរហូតមួយយប់ ។ ព្រះបរមពោធិសត្វក្រោកឡើងពេលព្រឹក ឃើញមាណពនោះក៏សួរថា នែអ្នកដ៏ចម្រើន អ្នកអង្គុយធ្វើអ្វី? មាណពឆ្លើយថា បពិត្រលោកអាចារ្យ ខ្ញុំ

រកអ្វីកល់ជើងគ្រែមិនបាន ទើបខ្ញុំលើកដាក់លើជើងរបស់ខ្ញុំហើយអង្គុយ ។ ព្រះបរមពោធិសត្វសង្វេគ គិតថា មាណពនេះមានឧបការគុណចំពោះអញក្រៃលែងណាស់ ក្នុងក្រុមមាណពមានប្រមាណប៉ុណ្ណេះ មាណពនេះល្ងង់ជាងគេ រៀនសិល្បៈមិនចេះ ធ្វើដូចម្តេចទៅហ្ន៎ ទើបធ្វើឲ្យមាណពនេះឈ្លាសវៃបាន លុះគិតដូច្នោះហើយ ក៏មានគំនិតថា មានឧបាយមួយ អញចាំសួរមាណពនេះ ពេលដែលមាណពនេះទៅរកឧសរកបន្លែមកថា ថ្ងៃនេះអ្នកឃើញអ្វី ? អ្នកធ្វើអ្វី ? កាលបើដូច្នោះ មាណពនេះនឹងប្រាប់អញថា ថ្ងៃនេះខ្ញុំឃើញវត្ថុឈ្មោះនេះ ធ្វើកិច្ចនេះ ពេលនោះអញនឹងសួរថា កន្លែងដែលអ្នកឃើញ កន្លែងដែលអ្នកធ្វើនោះដូចអ្វី ? មាណពនេះនឹងប្រាប់អញដោយឧបមានិងដោយហេតុថា យ៉ាងនេះ ដោយវិធីនេះអញឲ្យមាណពពោលឧបមានិងដោយហេតុហើយ នឹងធ្វើឲ្យមាណពនោះឈ្លាសវៃបានដោយឧបាយនេះ ( គិតដូច្នេះហើយ ) ទើបហៅមាណពនោះមកប្រាប់ថា នែមាណព ចាប់ពីពេលនេះទៅ ក្នុងទីកន្លែងដែលអ្នកទៅរកឧសនិងរកបន្លែនោះ អ្នកបានឃើញ បានបរិភោគ បានផឹក ឬបានទំពាវត្ថុណាក្នុងទីនោះ ពេលមកដល់កន្លែងត្រូវប្រាប់វត្ថុនោះដល់យើង ។

មាណពនោះយល់ព្រមថា ប្រពៃហើយលោកអាចារ្យ ។ ថ្ងៃមួយ មាណពទៅព្រៃដើម្បីរកឧសជាមួយនឹងមាណពទាំងឡាយ ឃើញពស់

ក្នុងព្រៃ ពេលត្រឡប់មកវិញប្រាប់អាចារ្យថា បពិត្រលោកអាចារ្យ ខ្ញុំឃើញពស់ ។

អាចារ្យសួរថា នៃមាណព ដែលឈ្មោះថាពស់ ដូចអ្វី?

មាណពឆ្លើយថា ដូចចន្ទោលនង្គ័ល ។

អាចារ្យត្រេកអរថា ល្អហើយ ល្អហើយ មាណព ឧបមាដែលអ្នកនាំមកថា ពស់ដូចចន្ទោលនង្គ័ល ជាទីពេញចិត្តយើងហើយ ។ គ្រានោះព្រះបរមពោធិសត្វត្រិះរិះថា ឧបមាគួរពេញចិត្ត មាណពនាំមកបាន អញអាចនឹងធ្វើឲ្យមាណពនេះឆ្លាតបាន ។ ចំណែកមាណព ថ្ងៃមួយបានឃើញដំរីក្នុងព្រៃ ក៏មកប្រាប់ថា បពិត្រលោកអាចារ្យ ខ្ញុំឃើញដំរី ។

អាចារ្យសួរថា ដំរីដូចអ្វី?

មាណពឆ្លើយថា ក៏ដូចចន្ទោលនង្គ័លដែរ ។ ព្រះបរមពោធិសត្វគិតថា ប្រមោយដំរីក៏ង ដូចចន្ទោលនង្គ័ល អវយវៈដទៃៗ ដូចជាភ្លុកជាដើមអាចមានរូបរាងដូច្នេះបាន ប៉ុន្តែមាណពនេះមិនអាចចែកហើយពោលបានព្រោះខ្លួនល្ងង់ ប្រហែលនិយាយសំដៅយកប្រមោយដំរី ហើយក៏នៅស្ងៀម ។ ថ្ងៃមួយ មាណពនោះបានបរិភោគអំពៅក្នុងទីដែលគេអញ្ជើញទៅ ក៏មកប្រាប់ថា បពិត្រលោកអាចារ្យ ថ្ងៃនេះខ្ញុំបានបរិភោគអំពៅ ។ កាលអាចារ្យសួរថា អំពៅដូចអ្វី? ក៏ពោលថា ដូចចន្ទោលនង្គ័ល ។ ព្រះបរមពោធិសត្វគិតថា មាណពនេះពោលហេតុផលសមគួរបន្តិច ហើយ

*ក៏នៅស្ងៀម ។ ថ្ងៃមួយទៀត ក្នុងទីដែលបានទទួលអញ្ជើញ មាណព ពួកខ្លះបានបរិភោគស្ករអំពៅនិងទឹកដោះជូរ ពួកខ្លះបរិភោគស្ករអំពៅនិងទឹកដោះស្រស់ ។ មាណពនោះមកដល់កន្លែងវិញប្រាប់អាចារ្យថា បពិត្រលោកអាចារ្យ ថ្ងៃនេះ ខ្ញុំបរិភោគទឹកដោះជូរផង ទឹកដោះស្រស់ផង កាលត្រូវអាចារ្យសួរថា នែមាណព ទឹកដោះជូរនិងទឹកដោះស្រស់ដូចអ្វី ? ក៏ឆ្លើយថា ដូចចន្ទោលនង្គ័ល ។ ព្រះបរមពោធិសត្វពោលថា មាណពនេះ កាលពោលថា ពស់ដូចចន្ទោលនង្គ័ល ពោលបានត្រឹមត្រូវ សូម្បីពោលថា ដំរីដូចចន្ទោលនង្គ័ល ក៏អាចពោលបាន ដោយសំដៅយកប្រមោយ សូម្បីដែលពោលថា អំពៅដូចចន្ទោលនង្គ័លក៏នៅសមគួរ ប៉ុន្តែទឹកដោះជូរ ទឹកដោះស្រស់ ពណ៌សជានិច្ច ទ្រទ្រង់ខ្លួនដោយភាជនៈ មិនគួរនឹងពោលឧបមាក្នុងរឿងនេះបាន ដោយប្រការទាំងពួង អញមិនអាចឲ្យមនុស្សល្ងង់ម្នាក់នេះសិក្សាបាន ទើបពោលគាថានេះថា*

**អសព្វត្ថ គាមី វាចំ ពាលោ សព្វត្ថ ភាសតិ**
**នាយំ ទធឹ វេទិ ន នង្គលីសំ**
**ទធិប្បយំ មញ្ញតិ នង្គលីសន្តិ ។**

*បុគ្គលពាលរមែងពោលនូវវាចា ដែលមិនគួរពោល*
*គ្រប់យ៉ាងបាន ក្នុងទីទាំងពួង មាណពនេះមិន*
*ស្គាល់ទឹកដោះជូរ មិនស្គាល់ចន្ទោលនង្គ័លឡើយ*

*ទើបសម្គាល់នូវទឹកដោះជូរនិងទឹកដោះស្រស់ ថា*
*ដូចចន្ទោលនៃនង្គ័លទៅវិញ ។*

*ក្នុងគាថានោះ មានសេចក្តីសង្ខេបដូច្នេះថា វាចាណាដែលមិនសមគួរក្នុងទីទាំងពួងដោយអំណាចនៃឧបមា វាចាដែលមិនសមគួរក្នុងទីទាំងពួងនោះ បុគ្គលពាលតែងពោលបានក្នុងទីគ្រប់អន្លើ ដូចត្រូវសួរថា ទឹកដោះជូរដូចអ្វី? ក៏ឆ្លើយភ្លាមថា ដូចចន្ទោលនង្គ័ល កាលពោលយ៉ាងនេះ ព្រោះមិនស្គាល់ទឹកដោះជូរនិងទឹកដោះស្រស់ ។*

*សួរថា ព្រោះហេតុអ្វី?*

*ឆ្លើយថា ព្រោះថា សូម្បីតែទឹកដោះជូរក៏គេសម្គាល់ថាជា ចន្ទោលនង្គ័លបាន ។ ន័យម្យ៉ាងទៀត ព្រោះគេសម្គាល់ទឹកដោះជូរនិងទឹកដោះស្រស់ថា ដូចចន្ទោលនង្គ័ល មាណពនេះល្ងង់ដល់កម្រិតនេះ ព្រះបរមពោធិសត្វគិតថា ប្រយោជន៍អ្វីដោយមាណពនេះ ទើបប្រាប់អន្តេវាសិកទាំងឡាយឲ្យស្បៀងហើយបញ្ជូនមាណពនោះ ឲ្យត្រឡប់ទៅផ្ទះវិញ ។*

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា មាណពល្ងង់ក្នុងកាលនោះ បានមកជាលោឡុទាយី ចំណែកអាចារ្យទិសាបាមោក្ខ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា នង្គលីសជាតក ទី ៣ ។

# អដ្ឋកថា អម្ពជាតក ទី ៤

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធព្រាហ្មណ៍ដែលបរិបូណ៌ដោយវត្តមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **វាយមេថេវ បុរិសោ** *ដូច្នេះជាដើម ។*

*បានឮថា ព្រាហ្មណ៍នោះជាកុលបុត្រអ្នកនគរសាវត្ថី បួសឧទ្ទិសជីវិតចំពោះព្រះសាសនា ជាអ្នកដល់ព្រមដោយវត្ត ធ្វើអាចរិយវត្ត ឧបជ្ឈាយវត្ត និងវត្តមានការតម្កល់ទឹកផឹក និងទឹកប្រើប្រាស់ ទាំងវត្តក្នុងរោងឧបោសថ និងវត្តក្នុងរោងភ្លើងជាដើម ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងមហាវត្តទាំង១៤ និងខន្ធកវត្តទាំង៨០ បោសវិហារ បរិវេណវិហារ ឲ្យទឹកផឹកដល់ពួកមនុស្ស ពួកមនុស្សជ្រះថ្លាក្នុងការសម្បូណ៌ដោយវត្តរបស់លោក នាំគ្នាប្រគេនភត្តជាប្រចាំប្រមាណ ៥០០ សម្រាប់ លាភនិងសក្ការៈជាច្រើនកើតឡើង ការនៅជាសុខកើតឡើងហើយដល់ភិក្ខុជាច្រើន ព្រោះអាស្រ័យភិក្ខុនោះ ។ ថ្ងៃមួយ ភិក្ខុជាច្រើនលើករឿងឡើងសន្ទនាគ្នាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ ភិក្ខុឈ្មោះឯណោះ ញុំាងលាភសក្ការៈយ៉ាងច្រើនសន្ធឹកសន្ធាប់ឲ្យកើតដល់ខ្លួន ព្រោះដល់ព្រមដោយវត្ត ការរស់នៅជាសុខកើតឡើងដល់ភិក្ខុជាច្រើន ព្រោះអាស្រ័យភិក្ខុនោះតែមួយរូប ។ ព្រះសាស្ដាស្ដេចយាងមកទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយ*

ក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនេះក៏ធ្លាប់ជាអ្នកដល់ព្រមដោយវត្តដែរ ក្នុងកាលមុនអាស្រ័យភិក្ខុនេះតែមួយរូប ឥសី ៥០០ រូប មិនចាំបាច់ទៅរកផលាផលឡើយ ចិញ្ចឹមជីវិតអាស្រ័យផ្លែឈើដែលភិក្ខុនេះនាំមក ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ចម្រើនវ័យហើយ បួសជាឥសី មានឥសី ៥០០រូបជាបរិវារ នៅអាស្រ័យជើងភ្នំ ។ គ្រានោះ ក្នុងព្រៃហេមពាន្តស្ងួតហួតហែងយ៉ាងខ្លាំង ទឹកផឹកក្នុងទីទាំងឡាយក៏រីងស្ងួត ពួកសត្វតិរច្ឆានកាលមិនបានផឹកទឹកក៏ដល់នូវការលំបាក ។ គ្រានោះ បណ្ដាតាបសទាំងនោះ មានតាបសមួយរូបឃើញសេចក្ដីទុក្ខដែលកើតអំពីការក្រវល់ក្រវាយរបស់ពួកសត្វតិរច្ឆានទាំងនោះ ក៏កាត់ដើមឈើមួយដើមធ្វើស្នូកទឹក យោងទឹកដាក់ឲ្យសត្វតិរច្ឆានទាំង-នោះផឹក កាលពួកសត្វតិរិច្ឆានចំនួនច្រើនមកប្រជុំផឹកទឹក តាបសមិនមានឱកាសទៅរកផ្លែឈើ សូម្បីត្រូវអត់អាហារក៏ដោយ ក៏លោកនៅតែយោងទឹកឲ្យសត្វតិរិច្ឆានផឹកដដែល ពួកម្រឹគក៏គិតថា តាបសអង្គនេះឲ្យទឹកផឹកដល់ពួកយើង លោកមិនមានឱកាសទៅរកផ្លែឈើ លំបាកយ៉ាងក្រៃលែងព្រោះអត់អាហារ ណ្ហើយចុះ ពួកយើងចូរដាក់កតិកាគ្នា ។ សត្វទាំងនោះ

*ក៏ដាក់កតិកាថា ចាប់ពីពេលនេះទៅ អ្នកណាមកផឹកទឹកត្រូវពាំផ្លែឈើមកតាមសមគួរដល់កម្លាំងរបស់ខ្លួន ។ ចាប់ពីពេលនោះមក សត្វតិរច្ឆានទាំងឡាយក៏ពាំផ្លែឈើ មានផ្លែស្វាយនិងផ្លែខ្នុរជាដើម ដែលឆ្ងាញ់ៗ មកតាមកម្លាំងរបស់ខ្លួនរៀងមក ។ ផ្លែឈើដែលពួកសត្វតិរច្ឆាននាំមកដើម្បីតាបសមានប្រមាណពីររទេះ តាបសទាំង ៥០០ អង្គឆាន់ផ្លែនោះឆ្អែតគ្រប់អង្គហើយ នៅបោះផ្លែឈើនោះចោលជាច្រើនទៀត ។ ព្រះបរមពោធិសត្វឃើញហេតុនោះហើយក៏ពោលថា អាស្រ័យតាបសអ្នកដល់ព្រមដោយវត្តមួយរូប តាបសមានប្រមាណប៉ុណ្ណោះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានដោយមិនចាំបាច់ទៅរកផ្លែឈើ ធម្មតាសេចក្តីព្យាយាមជាកិច្ចគួរធ្វើដោយពិត ហើយពោលគាថានេះថា*

**វាយមេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ**
**វាយាមស្ស ផលំ បស្ស ភុត្តា អម្ពា អនីតិហន្តិ ។**

*បុរសជាបណ្ឌិតគប្បីប្រឹងប្រែង មិនគប្បីធុញទ្រាន់ឡើយ*
*អ្នកចូរឃើញផលនៃសេចក្តីព្យាយាមដ៏ជាក់ស្តែង (ព្រោះ)*
*ផ្លែស្វាយទាំងឡាយជាដើម ដែលពួកឥសីបរិភោគហើយ។*

*ក្នុងគាថានោះ មានសេចក្តីសង្ខេបដូច្នេះថា បុរសជាបណ្ឌិត គប្បីព្យាយាមរឿយៗ មិនគប្បីរាថយក្នុងការងារ មានការបំពេញវត្តជាដើមរបស់ខ្លួនឡើយ ។*

*សួរថា ព្រោះហេតុអ្វី ?*

*ឆ្លើយថា ព្រោះសេចក្ដីព្យាយាមដែលឥតផល មិនមានឡើយ ដោយហេតុនេះ ព្រះមហាសត្វកាលដាស់តឿនពួកឥសីថា ធម្មតាសេចក្ដីព្យាយាមតែងតែមានផលជានិច្ច ទើបពោលថា អ្នកទាំងឡាយចូរមើលផលនៃសេចក្ដីព្យាយាមដ៏ជាក់ស្ដែងចុះ សេចក្ដីនេះដូចម្ដេច ? ដូចពួកឥសីទាំង ៥០០ អង្គឆាន់ផ្លែឈើ មានផ្លែស្វាយជាដើម ។ បណ្ដាបទទាំងនោះ បទថា* **អម្ព** *គ្រាន់តែលើកមកជាឧបមាប៉ុណ្ណោះ សេចក្ដីថា ផលាផលដែលពួកសត្វតិរច្ឆានទាំងនោះនាំមក មានច្រើន ប៉ុន្តែពោលសំដៅយកតែផ្លែស្វាយជាដើម ដោយអំណាចជាផ្លែឈើច្រើនសន្ធឹកសន្ធាប់ជាងផ្លែឈើដទៃៗ ការដែលពួកឥសី ៥០០ រូបមិនបាច់ទៅព្រៃដោយខ្លួនឯង នាំគ្នាឆាន់ផ្លែឈើទាំងឡាយ ដែលសត្វតិរច្ឆានទាំងឡាយនាំមកដើម្បីប្រយោជន៍ដល់តាបសនោះ នេះជាផលនៃសេចក្ដីព្យាយាម ការដែលបានឆាន់ផ្លែឈើនោះ ដឹងខ្លួនឯង មិនចាំបាច់មានអ្នកណាប្រាប់ សេចក្ដីថា នឹងត្រូវកាន់យកដោយការប្រាប់ថា នេះយ៉ាងនេះ ដូច្នេះ ចូរមើលផ្លែឈើដ៏ប្រចក្សជាក់ស្ដែងចុះ ព្រះបរមពោធិសត្វបានឲ្យឱវាទដល់ពួកឥសីដោយប្រការដូច្នេះ ។*

*ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា តាបសដែលដល់ព្រមដោយវត្តក្នុងកាលនោះ បានមកជា*

*ភិក្ខុនេះ ចំណែកសាស្ដានៃគណៈ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា អម្ពជាតក ទី ៤ ។

# អដ្ឋកថា កដាហកជាតក ទី ៥

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកច្រើនទៅដោយការអួតមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **ពហុម្បិ សោ វិកត្ថេយ្យ** *ដូច្នេះជាដើម ។*

*រឿងរបស់ភិក្ខុនោះ ដូចរឿងដែលបានពោលហើយក្នុងកាលមុននោះឯង* (១) *។*

*ប្លែកតែថា ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាសេដ្ឋីអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ ។ ភរិយារបស់សេដ្ឋីប្រសូតបុត្ត ចំណែកទាសីរបស់សេដ្ឋីក៏ប្រសូតបុត្តក្នុងថ្ងៃនោះដែរ ។ ក្មេងទាំងពីរនោះ ធំឡើងជាមួយគ្នា កាលបុត្តសេដ្ឋីទៅរៀនអក្សរ កូនទាសីក៏កាន់ក្ដារឈ្នួនទៅតាមរៀនអក្សរជាមួយបុត្តសេដ្ឋីនោះដែរ បានសរសេរ បានអានពីរ-បីដង កូនទាសីនោះក៏ចាំពាក្យនោះ ឈ្លាសវៃក្នុងវោហារដោយលំដាប់ ។ លុះធំពេញវ័យ*

---

*១-ភីមសេនជាតក ។*

កំលោះមានរូបរាងសង្ហាមានឈ្មោះថា កដាហកៈ ។ កូនទាសីនោះមាននាទីជាអ្នករក្សាឃ្លាំងក្នុងផ្ទះរបស់សេដ្ឋី គេគិតថា មនុស្សទាំងនេះគង់នឹងមិនប្រើអញឲ្យធ្វើជាអ្នករក្សាឃ្លាំងរហូតទៅទេ ពេលឃើញទោសអ្វីបន្តិចបន្តួច គង់នឹងវាយចាប់ចងបោះត្រាដើម្បីជាគ្រឿងសម្គាល់ ហើយប្រើប្រាស់ដូចជាទាសៈតទៅ នៅឯជាយដែនមានសេដ្ឋីម្នាក់ដែលជាសម្លាញ់នឹងសេដ្ឋីនេះ បើដូច្នោះ អញកាន់សំបុត្រដែលជាពាក្យរបស់សេដ្ឋីទៅកាន់ទីនោះ ប្រាប់ថាអញជាកូនសេដ្ឋី កុហកសេដ្ឋីនោះហើយ សូមធីតារបស់សេដ្ឋីនោះធ្វើជាគូគ្រងគប្បីនៅយ៉ាងសុខ ។ កូនទាសីនោះ សរសេរសំបុត្រដោយខ្លួនឯងថា ខ្ញុំបញ្ជូនកូនប្រុសខ្ញុំឈ្មោះនេះទៅកាន់សម្នាក់របស់លោក ធម្មតាសម្ពន្ធគ្នារវាងលោកជាមួយខ្ញុំ ខ្ញុំជាមួយលោកជាការសមគួរណាស់ ព្រោះហេតុនោះ សូមលោកលើកធីតារបស់លោកឲ្យទារកនេះ ហើយឲ្យគេនៅទីនោះចុះ ចាំមានឱកាសខ្ញុំនឹងទៅលេងលោក ដូច្នេះហើយ យកត្រារបស់សេដ្ឋីមកបោះលើសំបុត្រនោះ កាន់យកស្បៀងនិងគ្រឿងឧបភោគនិងសំពត់ជាដើមទៅតាមការពេញចិត្ត ។ លុះទៅដល់បច្ចន្តជនបទជួបសេដ្ឋី ថ្វាយបង្គំហើយឈរក្នុងទីដ៏សមគួរមួយ ។ ពេលនោះសេដ្ឋីសួរថា នែមាណព អ្នកមកអំពីណា ?

កដាហកៈឆ្លើយថា បពិត្រលោកសេដ្ឋី ខ្ញុំមកពីនគរពារាណសី ។

សេដ្ឋីសួរថា មាណពឯងជាកូនរបស់អ្នកណា ?

កដាហកៈឆ្លើយថា ខ្ញុំជាបុត្តសេដ្ឋីនគរពារាណសី ។

សេដ្ឋីសួរថា មកទីនេះមានការអ្វី ? ពេលនោះកដាហកៈក៏ឲ្យសំបុត្រព្រមនឹងពោលថា បពិត្រសេដ្ឋី លោកមើលសំបុត្រនេះហើយនឹងជ្រាប ។ សេដ្ឋីអានសំបុត្រហើយសប្បាយចិត្តថា ពេលនេះអញនឹងរស់នៅយ៉ាងសុខសប្បាយ ចាត់ចែងលើកធីតាឲ្យ ។ សេដ្ឋីនោះមានបរិវារច្រើន កាលមានអ្នកនាំយាគូនិងរបស់បរិភោគជាដើមទៅឲ្យ ឬនាំសំពត់ដែលអប់ដោយគ្រឿងក្រអូបចូលទៅឲ្យ កដាហកៈក៏តិះដៀលយាគូជាដើមថា ឱ អ្នកស្រុកក្រៅដាំយាគូស្អីបែបនេះ ធ្វើរបស់គួរបរិភោគស្អីបែបនេះ ដាំបាយស្អីបែបនេះ តិះដៀលសំពត់និងកម្មករជាដើមថា ព្រោះជាមនុស្សស្រុកស្រែ ទើបមិនចេះប្រើប្រាស់សំពត់ថ្មីៗ មិនចេះប្រើប្រាស់គ្រឿងក្រអូប មិនចេះទ្រទ្រង់ផ្កាកម្រង ។

ព្រះបរមពោធិសត្វកាលមិនឃើញទាសៈក៏សួរថា យើងមិនបានឃើញកដាហកៈ វាទៅណា ? នាំគ្នាតាមរកវាចុះ ដូច្នេះហើយប្រើឲ្យមនុស្សដើររកដោយជុំវិញ ។ បណ្ដាមនុស្សទាំងនោះ បុរសម្នាក់ទៅកាន់ទីនោះ បានឃើញកូនទាសីនោះហើយចាំបាន កូនទាសីនោះមិនបានដឹងថា មានគេឃើញខ្លួន ។ បុរសដែលឃើញកូនទាសីនោះ ទៅប្រាប់សេដ្ឋីពោធិសត្វ ។ សេដ្ឋីពោធិសត្វស្ដាប់រឿងនោះហើយគិតថា កដាហកៈនោះធ្វើយ៉ាងនោះមិនសមគួរឡើយ ត្រូវទៅចាប់វាមកក្រាបទូលព្រះរាជា ។

សេដ្ឋីពោធិសត្វចេញអំពីផ្ទះទៅជាមួយបរិវារជាច្រើន ដំណឹងបានផ្សាយទូទៅថា បានឮថា លោកសេដ្ឋីទៅកាន់បច្ចន្តជនបទ ។ កដាហកៈស្តាប់ឮថាសេដ្ឋីមក គិតថា សេដ្ឋីមកដោយរឿងដទៃក៏ទេ គឺមកដោយរឿងអញនោះឯង ប្រសិនបើអញគេចចេញទៅ មិនអាចត្រឡប់មកបានទៀតទេ ឧបាយនោះនៅមាន អញត្រូវទៅជួបសេដ្ឋីដែលជាចៅហ្វាយនាយ ហើយធ្វើកិច្ចរបស់ទាសៈ ធ្វើឲ្យសេដ្ឋីអត់ទោសឲ្យទាល់តែបាន ។ ចាប់ពីពេលនោះមក កូនទាសីនោះពោលយ៉ាងនេះកណ្តាលបរិស័ទថា ពួកបុគ្គលពាលដទៃៗ មិនដឹងគុណមាតាបិតាព្រោះខ្លួនជាបុគ្គលពាល ពេលដែលមាតាបិតាបរិភោគ មិនមានការគោរព បរិភោគរួមជាមួយមាតាបិតាជានិច្ច ចំណែកយើងពេលមាតាបិតាបរិភោគតែងតែរង់ចាំលើកវត្ថុចូលទៅលើកកន្ទោរចូលទៅ លើករបស់បរិភោគចូលទៅជូន ពេលខ្លះក៏លើកទឹកផឹកចូលទៅជូន ពេលខ្លះក៏បក់ផ្លិតជូន ចូលទៅឈរជិតៗ លុះពោលដូច្នេះហើយ ប្រកាសកិច្ចដែលពួកទាសៈត្រូវធ្វើចំពោះចៅហ្វាយនាយគ្រប់យ៉ាង រហូតដល់ការកាន់ផ្តិលទឹកទៅកាន់ទីកំបាំងក្នុងពេលដែលចៅហ្វាយនាយបន្ទោបង់ឧច្ចារៈបស្សាវៈជាដើម ។ លុះធ្វើឲ្យបរិស័ទដឹងយ៉ាងនេះហើយ ពេលដែលព្រះបរមពោធិសត្វមកជិតដល់បច្ចន្តជនបទក៏ប្រាប់សេដ្ឋីដែលជាឪពុកក្មេកថា បពិត្របិតា បានឮថា បិតារបស់ខ្ញុំមកដើម្បីជួបបិតា សូមបិតាបញ្ជាឲ្យគេត្រៀមខាទនីយភោជនីយាហារចុះ ខ្ញុំ

នឹងកាន់យកគ្រឿងបណ្ណាការ ( ចេញទៅទទួលបិតារបស់ខ្ញុំ ) ។ សេដ្ឋីពោលថា ប្រពៃហើយកូន ។

កដាហកៈកាន់បណ្ណាការធ្វើដំណើរទៅជាមួយបរិវារជាច្រើន ថ្វាយបង្គំសេដ្ឋីពោធិសត្វហើយជូនបណ្ណាការ ។ ចំណែកសេដ្ឋីពោធិសត្វទទួលបណ្ណាការហើយធ្វើបដិសណ្ឋារៈនឹងកូនទាសីនោះ ដល់វេលាបរិភោគអាហារពេលព្រឹកក៏ឲ្យបោះជំរំសម្រាកហើយ ចូលទៅកាន់ទីកំបាំងដើម្បីបន្ទោបង់ឧច្ចារៈបស្សាវៈ កដាហកៈឲ្យបរិវាររបស់ខ្លួនត្រឡប់ហើយ កាន់ផ្តិលទឹកទៅកាន់សម្នាក់ព្រះបរមពោធិសត្វ ។ កាលសម្រេចឧទកកិច្ចហើយ ក៏ក្រាបទៀបជើងទាំងពីរពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងជូនទ្រព្យដល់លោកតាមដែលលោកត្រូវការ សូមមេត្តាកុំធ្វើយសរបស់ខ្ញុំឲ្យវិនាសឡើយ ។ ព្រះពោធិសត្វជ្រះថ្លាក្នុងការសម្បូណ៌ដោយវត្តរបស់កូនទាសីនោះ ក៏លួងលោមថា នែអ្នកដ៏ចម្រើន អ្នកកុំខ្លាចឡើយ អន្តរាយអំពីសម្នាក់របស់យើងមិនមានដល់អ្នកទេ ហើយចូលទៅកាន់បច្ចន្តនគរ សក្ការៈយ៉ាងច្រើនមានដល់ព្រះមហាសត្វ ។ ចំណែកកដាហកៈ ក៏ធ្វើកិច្ចដែលទាសៈត្រូវធ្វើដល់សេដ្ឋីពោធិសត្វរហូតគ្រប់វេលា ។ គ្រានោះ បច្ចន្តសេដ្ឋីពោលជាមួយនឹងព្រះពោធិសត្វដែលអង្គុយយ៉ាងសប្បាយក្នុងពេលមួយថា បពិត្រសេដ្ឋីខ្ញុំឃើញសំបុត្ររបស់លោកភ្ជាម ក៏លើកកូនស្រីឲ្យកូនរបស់លោកភ្ជាមដែរ ។ ព្រះមហាសត្វក៏ធ្វើកដាហកៈឲ្យជាកូនដែរ ពោលពាក្យជាទីស្រឡាញ់

ពេញចិត្តឲ្យសេដ្ឋីត្រេកអរ តាំងពីពេលនោះមកក៏គ្មានអ្នកណាហ៊ានសម្លឹង មើលមុខកដាហកៈឡើយ ។ ថ្ងៃមួយ ព្រះបរមពោធិសត្វហៅធីតារបស់ សេដ្ឋីមកពោលថា នែកូនស្រី មកនេះ ជួយរកចៃលើក្បាលឲ្យពុកបន្តិច ដូច្នេះហើយ ពោលពាក្យជាទីស្រឡាញ់ដល់កូនប្រសាដែលមកឈររកចៃ ឲ្យ រួចសួរថា នែកូនស្រី កូនរបស់ឪពុកមិនប្រមាទក្នុងសុខទុក្ខរបស់កូនទេ ឬ? អ្នកទាំងពីរនៅស្រឡាញ់គ្នាទេឬ?

នាងឆ្លើយថា បពិត្រលោកឪពុក បុត្តរបស់លោកឪពុកមិនមាន ចំណុចដទៃដែលគួរឲ្យតិះដៀលទេ គ្រាន់តែរអ៊ូរទាំរឿងអាហារប៉ុណ្ណោះ ។

សេដ្ឋីពោលថា នែកូនស្រី កូនពុកម្នាក់នេះ មានប្រក្រតីស៊ីរើស បន្តិច ណ្ហើយចុះ ពុកនឹងឲ្យមន្តសម្រាប់ចងមាត់វាដល់កូន កូនចូររៀន មន្តនោះឲ្យល្អ កាលកូនរបស់ពុករអ៊ូរទាំក្នុងពេលបរិភោគ កូនចូរឈរអំពី មុខហើយ ពោលតាមដែលបានរៀនមក ហើយឲ្យធីតារបស់សេដ្ឋីរៀន គាថា សម្រាកនៅពីរ-បីថ្ងៃក៏ត្រឡប់ទៅនគរពារាណសីវិញ ។ ចំណែក កដាហកៈក៏យកខាទនីយភោជនីយាហារច្រើនសន្ធឹកសន្ធាប់តាមព្រះបរម-ពោធិសត្វទៅ ជូនទ្រព្យជាច្រើនដល់ព្រះបរមពោធិសត្វហើយលាត្រឡប់ មកវិញ ។ ចាប់ពីពេលដែលព្រះបរមពោធិសត្វត្រឡប់ទៅវិញហើយនោះ កដាហកៈក្អេងក្អាងយ៉ាងក្រៃលែង ។ ថ្ងៃមួយ កាលសេដ្ឋីធីតានាំភោជន មានរសប្រណីតៗចូលទៅឲ្យ កាន់វែករង់ចាំបម្រើ កដាហកៈក៏តិះដៀល

*អាហារ ។ សេដ្ឋីធីតាក៏សូត្រគាថានោះ តាមទំនងដែលបានរៀនហើយក្នុងសម្នាក់ព្រះបរមពោធិសត្វថា*

**ពហុម្បិ សោ វិកត្ថេយ្យ អញ្ញំ ជនបទំ គតោ**
**អន្វាគន្ត្វាន ទូសេយ្យ ភុញ្ជ ភោគេ កដាហកាតិ ។**

*ទាសៈឈ្មោះកដាហកៈនោះ ទៅកាន់ជនបទដទៃ ពោលអួតនូវពាក្យច្រើន សេដ្ឋីជាម្ចាស់មកតាម (ម្តងទៀត) គប្បីប្រទូស្តមិនខាន ម្នាលកដាហកៈ អ្នកចូរបរិភោគ នូវភោគៈទាំងឡាយទៅ ។*

*បណ្តាបទទាំងនោះ បទថា* **ពហុម្បិ សោ វិកត្ថេយ្យ អញ្ញំ ជនបទំ គតោ** *សេចក្តីថា អ្នកណាទៅកាន់ជនបទដទៃអំពីជាតិភូមិរបស់ខ្លួន ក្នុងទីដែលមិនមានអ្នកដឹងកំណើតរបស់ខ្លួន អ្នកនោះគប្បីអួរទាំ គឺពោលអួតនូវពាក្យច្រើនក៏បាន ។*

*បទថា* **អន្វាគន្ត្វាន ទូសេយ្យ** *សេចក្តីថា ព្រោះបានទៅធ្វើកិច្ចរបស់ទាសៈ តាមផ្លូវឲ្យចៅហ្វាយនាយហើយ ទើបអ្នករួចផុតអំពីការវាយដោយរំពាត់ផ្តៅ ដែលនឹងលាត់ស្បែកខ្នងឡើងថាជាទាសៈ និងការបោះត្រាធ្វើជាគ្រឿងសម្គាល់ ប្រសិនបើអ្នកនៅតែចចេសធ្វើអាក្រក់ទៀត សេដ្ឋីជាម្ចាស់នឹងមកតាមប្រទូស្តមិនខាន គឺតាមមកដល់ផ្ទះនេះ ហើយគប្បីប្រទូស្ត ធ្វើឲ្យដល់នូវសេចក្តីអន្តរាយម្តងទៀត ដោយការវាយនឹងរំពាត់ផ្តៅ ការបោះត្រាធ្វើជាគ្រឿងសម្គាល់ថាជាទាសៈ និងដោយការប្រកាសកំណើត*

*ក៏បាន ហេតុនោះ កដាហកៈអើយ អ្នកចូរលះបង់ការប្រព្រឹត្តិមិនល្អនេះ ហើយបរិភោគនូវភោគៈទាំងឡាយទៅ កុំធ្វើឲ្យភាពជាទាសៈរបស់ខ្លួន ប្រាកដឡើង ហើយត្រូវក្តៅក្រហាយស្តាយក្នុងកាលជាខាងក្រោយឡើយ នេះជាការអត្ថាធិប្បាយរបស់សេដ្ឋី ។*

*ចំណែកសេដ្ឋីធីតាមិនដឹងសេចក្តីនោះ មិនយល់ន័យក្នុងគាថានោះ ពោលបានតាមគន្ធព្យញ្ជនៈតាមការរៀនប៉ុណ្ណោះ ។ កដាហកៈគិតថា សេដ្ឋីប្រាប់រឿងអាក្រក់របស់អញហើយ ពិតជាប្រាប់រឿងទាំងអស់ដល់នាងនេះមិនខាន ចាប់តាំងពីពេលនោះមក ឈប់តិះដៀលអាហារទៀត លះបង់មានះចោល បរិភោគអាហារតាមមានតាមបាន ក្រោយអំពីចុតិក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា កដាហកៈក្នុងកាលនោះ បានមកជាភិក្ខុដែលច្រើនទៅដោយការអួតក្នុងកាលឥឡូវនេះ ចំណែកពារាណសីសេដ្ឋី គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា កដាហកជាតក ទី ៥ ។

# អដ្ឋកថា អសិលក្ខណជាតក ទី ៦

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍អ្នកពិនិត្យលក្ខណៈដាវរបស់ព្រះបាទកោសល ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **តថេវេកាស្ស កល្យាណំ** ដូច្នេះជាដើម ។

បានឮថា ព្រាហ្មណ៍នោះ ពេលដែលពួកជាងដែកនាំដាវមកថ្វាយព្រះរាជា ក៏ហិតក្លិនដាវហើយប្រាប់លក្ខណៈល្អអាក្រក់របស់ដាវ គាត់បានលាភអំពីដៃនៃជាងដាវពួកណា ក៏ពោលសរសើរដាវនៃជាងពួកនោះថាសម្បូរដោយលក្ខណៈ ប្រកបដោយមង្គល មិនបានទទួលលាភអំពីដៃនៃជាងពួកណា ក៏តិះដៀលដាវនៃជាងពួកនោះថា អប្បលក្ខណ៍ ។ គ្រានោះជាងដាវម្នាក់ ធ្វើដាវហើយយកម្ទេសម៉្ទដាក់ទៅក្នុងស្រោមស៊កដាវហើយយកមកថ្វាយព្រះរាជា ។ ព្រះរាជាបញ្ជាឲ្យហៅព្រាហ្មណ៍មក ហើយត្រាស់ថា នែព្រាហ្មណ៍ អ្នកចូរពិនិត្យមើលដាវនេះចុះ ។ កាលព្រាហ្មណ៍ហូតដាវចេញមក ក្លិនម្ទេសម៉្ទក៏ចូលទៅក្នុងច្រមុះ ធ្វើឲ្យកើតកណ្តាស់ឡើង កាលព្រាហ្មណ៍កំពុងកណ្តាស់នោះ ច្រមុះក៏ត្រូវមុខដាវមុតដាច់ជាពីរកំណាត់ ។ ការដែលព្រាហ្មណ៍នោះត្រូវដាច់ច្រមុះ បានដឹងដល់ពួកភិក្ខុ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយលើករឿងឡើងសន្ទនាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ បានឮថា ព្រាហ្មណ៍ដែលពិនិត្យមើលលក្ខណៈដាវរបស់ព្រះរាជាពិនិត្យមើលលក្ខណៈដាវហើយ ធ្វើឲ្យច្រមុះដាច់ ។ ព្រះ-

សាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់-មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំង-ឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលព្រាហ្មណ៍នោះហិតក្លិនដាវ ហើយត្រូវដាច់ច្រមុះនោះ សូម្បីក្នុងកាលមុនក៏ត្រូវដាច់ច្រមុះដែរ ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ទ្រង់មានព្រាហ្មណ៍អ្នកមើលលក្ខណៈដាវដែរ រឿងគ្រប់យ៉ាងក៏ដូចរឿងក្នុងបច្ចុប្បន្ននេះឯង ប្លែកតែថា ព្រះរាជាបានព្រះរាជទានពេទ្យដល់ព្រាហ្មណ៍ ឲ្យព្យាបាលរហូតទាល់តែចុងច្រមុះជាសះស្បើយ ឲ្យធ្វើច្រមុះក្លែងក្លាយដោយក្រមួនដាក់ជំនួស ហើយទ្រង់តែងតាំងព្រាហ្មណ៍ទុកក្នុងតំណែងដើមវិញ ។ ព្រះរាជានគរពារាណសី ទ្រង់មិនមានព្រះ-រាជឱរស មានតែព្រះរាជធីតាមួយព្រះអង្គនិងព្រះរាជភាគិនេយ្យ ( ក្មួយប្រុស ) មួយអង្គប៉ុណ្ណោះ ។ ទ្រង់ចិញ្ចឹមព្រះរាជធីតានិងព្រះរាជភាគិនេយ្យទុកក្នុងសម្នាក់ព្រះអង្គ កាលព្រះរាជធីតានិងព្រះភាគិនេយ្យទ្រង់ចម្រើនវ័យជាមួយគ្នាមក ក្សត្រទាំង ២ អង្គក៏មានព្រះទ័យប្រតិព័ទ្ធគ្នាទៅវិញទៅមក ។ ចំណែកព្រះរាជា ត្រាស់ហៅអាមាត្យទាំងឡាយមកត្រាស់ថា ក្មួយរបស់យើងនឹងបានជាម្ចាស់នៃរាជសម្បត្តិនេះតែម្នាក់ឯង យើងនឹងលើក

ធីតាឲ្យ ហើយអភិសេកឲ្យនោះឯង ហើយទ្រង់ព្រះតម្រិះថ្មីទៀតថា ក្មួយរបស់អញក៏គង់ជាញាតិរបស់អញ ដោយប្រការទាំងពួង អញនឹងនាំរាជធីតាដទៃមកឲ្យ ហើយធ្វើការអភិសេក លើកព្រះរាជធីតារបស់អញឲ្យដល់ព្រះរាជាអង្គដទៃ ដោយឧបាយនេះ ញាតិរបស់អញនឹងជាម្ចាស់នៃសម្បត្តិទាំងពីរនគរ ។ ព្រះរាជាទ្រង់ប្រឹក្សានឹងអាមាត្យទាំងឡាយ ទ្រង់ត្រាស់ថា គួរតែបំបែកមនុស្សទាំងពីរនាក់នោះចេញ ហើយបញ្ជាឲ្យព្រះរាជភាគិនេយ្យគង់នៅក្នុងដំណាក់មួយ ព្រះរាជធីតាគង់នៅក្នុងដំណាក់មួយ ។ ព្រះរាជភាគិនេយ្យនិងព្រះរាជធីតាទាំងពីរអង្គនោះ មានព្រះជន្ម ១៦ ព្រះវស្សាដូចគ្នា ហើយរឹងរឹតតែមានព្រះទ័យប្រតិព័ទ្ធចំពោះគ្នាក្រៃលែងឡើង ។ ព្រះរាជកុមារទ្រង់ព្រះតម្រិះថា ដោយឧបាយណាហ្ន៎ ទើបអញអាចនាំធីតារបស់ស្តេចអំចេញអំពីព្រះរាជវាំងបាន ទ្រង់គិតឃើញថា មានឧបាយមួយ ទើបត្រាស់ហៅស្រីមេមត់ចូលមកគាល់ ប្រទានវត្ថុមានតម្លៃ ១ ពាន់កហាបណៈដល់នាង ។ កាលស្រីមេមត់នោះក្រាបទូលសួរថា បពិត្រព្រះកុមារ ព្រះកុមារនឹងឲ្យខ្ញុំម្ចាស់ធ្វើអ្វី ? ទើបទ្រង់ត្រាស់ថា នែនាងដ៏ចម្រើន កាលនាងធ្វើការក្នុងថ្ងៃនេះ រឿងដែលឈ្មោះថាមិនសម្រេច មិនមានឡើយ នាងចូរអាងហេតុណាមួយក៏បាន ធ្វើឲ្យស្តេចអំរបស់ខ្ញុំនាំព្រះរាជធីតាចេញអំពីព្រះរាជវាំងឲ្យខាងតែបាន ។ ស្រីមេមត់នោះទទួលថា ព្រះមេខ្ញុំម្ចាស់ ខ្ញុំម្ចាស់នឹងចូលគាល់ព្រះរាជា ហើយក្រាបទូលយ៉ាងនេះ

ថា បពិត្រព្រះសម្មតិទេព កាឡកណ្ណីកំពុងចោមរោមចាប់ព្រះរាជធីតាអស់កាលមានប្រមាណប៉ុណ្ណេះ មិនមានផ្លូវដែលវានឹងត្រឡប់ទៅវិញឡើយ ខ្ញុំម្ចាស់នឹងនាំព្រះរាជធីតាឡើងរាជរថចេញទៅក្នុងថ្ងៃឯណោះ ចាត់បុរសឲ្យកាន់អាវុធចំនួនច្រើនតាមទៅជាមួយ ទៅកាន់ព្រៃខ្មោចដោយបរិវារជាច្រើន ឲ្យមនុស្សដែលស្លាប់ហើយដេកលើគ្រែក្នុងព្រៃខ្មោច នៅខាងក្រោមតាំងដែលជាមណ្ឌលវិធីនោះ ឲ្យព្រះរាជធីតាគង់លើគ្រែខាងលើ ហើយឲ្យព្រះរាជធីតាស្រង់ព្រះកាយដោយទឹកក្រអូបប្រមាណ ១៥០ ក្អមធ្វើខ្លួនកាឡកណ្ណីឲ្យអណ្តែតទៅ ។ កាលខ្ញុំម្ចាស់ក្រាបទូលព្រះរាជាយ៉ាងនេះហើយ នឹងនាំព្រះរាជធីតាទៅក្នុងព្រៃស្មសានបាន ។ ក្នុងថ្ងៃដែលខ្ញុំម្ចាស់ទៅកាន់ព្រៃស្មសាននោះ សូមទ្រង់កាន់យកម្ទេសម៉្ដបន្តិចហែហមដោយពួកអ្នកកាន់អាវុធរបស់ទ្រង់ទៅកាន់ព្រៃស្មសានមុន បញ្ឈប់រថនៅក្បែរទ្វារព្រៃស្មសានម្ខាងមុន ឲ្យពួករាជបុរសដែលកាន់អាវុធចូលទៅក្នុងព្រៃស្មសាន ចំណែកទ្រង់យាងទៅកាន់គ្រែពិធីក្នុងព្រៃស្មសាន ហើយទ្រង់ផ្ទំនៅទីនោះធ្វើជាមនុស្សស្លាប់ដែលគេគ្របទុក ខ្ញុំម្ចាស់មកដល់ទីនោះក៏នឹងដាក់គ្រែព័ទ្ធជុំវិញ លើកព្រះរាជធីតាឡើងដាក់លើគ្រែ ពេលនោះសូមទ្រង់យកម្ទេសម៉្ដដាក់ក្នុងព្រះនាសិក ហើយទ្រង់នឹងកណ្ដាស់ពីរ-បីដង ពេលដែលទ្រង់កណ្ដាស់ខ្ញុំម្ចាស់នឹងបោះបង់ព្រះរាជធីតាហើយរត់គេចចេញ ពេលនោះសូមទ្រង់ឲ្យព្រះរាជធីតាទ្រង់កក់ស្រង់ព្រះសិរសា

សូម្បីទ្រង់ក៏កក់ស្រង់ព្រះសិរសាផងដែរ ហើយនាំព្រះរាជធីតាទៅកាន់ដំណាក់របស់ទ្រង់ទៅ ។ ព្រះកុមារត្រាស់ថា ឧបាយនេះល្អពិតមែនហ្ន៎ ។ ចំណែកស្រីមេមត់ក៏ទៅក្រាបទូលរឿងនោះចំពោះព្រះរាជា ។ ព្រះរាជាទ្រង់អនុញ្ញាតហើយ ក៏ទៅទូលរឿងនោះឲ្យព្រះរាជធីតាជ្រាប សូម្បីព្រះរាជធីតាក៏ទ្រង់យល់ព្រម ។ ក្នុងថ្ងៃដែលចេញទៅនោះ ស្រីមេមត់ឲ្យសញ្ញាដល់ព្រះកុមារ ហើយទៅកាន់ព្រៃស្មសានមួយអន្ទើដោយបរិវារជាច្រើន ពោលគំរាមដើម្បីឲ្យកើតការភ័យខ្លាចដល់ពួកមនុស្សដែលរក្សាថា ក្នុងពេលដែលយើងដាក់ព្រះរាជធីតាលើគ្រែ មនុស្សស្លាប់ដែលនៅក្រោមគ្រែនឹងកណ្តាស់ ហើយនឹងក្រោកចេញអំពីក្រោមគ្រែ ឃើញអ្នកណាមុននឹងចាប់អ្នកនោះទៅ ពួកអ្នកគប្បីរក្សាខ្លួនឲ្យល្អ កុំប្រមាទ ។ ព្រះកុមារយាងទៅដល់ទីនោះមុន ហើយទ្រង់ផ្ទំនៅទីនោះដោយន័យដូចពោលហើយ ស្រីមេមត់បីព្រះរាជធីតាដើរទៅកាន់គ្រែក្រាបទូលលួងលោមថា ព្រះនាងកុំខ្លាចឡើយ ឲ្យសញ្ញាហើយដាក់ចុះលើគ្រែ ។ ពេលនោះ ព្រះកុមារក៏យកម្ទេសម៉ដ្ឋដាក់ចូលទៅក្នុងច្រមុះរួចកណ្តាស់ឡើង គ្រាន់តែព្រះកុមារទ្រង់កណ្តាស់ភ្លាម ស្រីមេមត់ក៏ទុកព្រះរាជធីតាដែលស្រែកយំដ៏លាន់ឮនៅទីនោះ រត់គេចចេញទៅមុនមនុស្សទាំងអស់ កាលស្រីមេមត់រត់ចោលព្រះរាជធីតានោះ មិនមានអ្នកណាសូម្បីតែម្នាក់ដែលអាចនៅទីនោះបានម្នាក់ៗបោះបង់អាវុធដែលកាន់មករត់គេចទៅអស់ ព្រះកុមារទ្រង់ធ្វើកិច្ច

គ្រប់យ៉ាងតាមដែលប្រឹក្សាគ្នាទុក ហើយនាំព្រះរាជធីតាទៅកាន់និវេសន៍របស់ទ្រង់ ។ ស្រីមេមត់ក៏ទៅក្រាបទូលរឿងនោះចំពោះព្រះរាជា ។ ព្រះ-រាជាទ្រង់ព្រះតម្រិះថា តាមប្រក្រតីយើងក៏ចិញ្ចឹមនាងទុកលើកឲ្យព្រះកុមារនោះឯង ក៏ដូចដាក់សប្បិទៅក្នុងបាយាសដូច្នោះ ទើបទ្រង់យល់ព្រមក្រោយមកទ្រង់ប្រគល់រាជសម្បត្តិដល់ព្រះភាគិនេយ្យ ទ្រង់តែងតាំងព្រះរាជធីតាឲ្យជាព្រះអគ្គមហេសី ។ ព្រះភាគិនេយ្យក៏បាននៅរួមជាមួយនឹងព្រះរាជធីតានោះគ្រប់គ្រងរាជសម្បត្តិដោយធម៌ ព្រាហ្មណ៍អ្នកពិនិត្យមើលលក្ខណៈដាវក៏បានជាឧបដ្ឋាករបស់ព្រះអង្គ ។ ក្រោយមកថ្ងៃមួយ កាលព្រាហ្មណ៍ចូលគាល់ព្រះរាជា ឈរគាល់បែរមុខទៅរកព្រះអាទិត្យ ក្រមួនដែលបិទច្រមុះនោះក៏រលាយធ្លាក់ទៅលើដី ព្រាហ្មណ៍ត្រូវឈរបាំងមុខដោយការខ្មាសអៀន ។ គ្រានោះ ព្រះរាជាទ្រង់សើចព្រាហ្មណ៍ រួចត្រាស់ថា បពិត្រអាចារ្យ លោកកុំគិតច្រើនឡើយ ធម្មតាការកណ្តាស់ បានផលល្អដល់មនុស្សម្នាក់ បានផលអាក្រក់ដល់មនុស្សម្នាក់ លោកកណ្តាស់ត្រូវដាច់ច្រមុះ ចំណែកខ្ញុំកណ្តាស់បានធីតារបស់ស្តេចអ៊ំនិងបានរាជសម្បត្តិហើយត្រាស់គាថានេះថា

**តថេវេកស្ស កល្យាណំ តថេវេកស្ស ចាបកំ**
**តស្មា សព្វំ ន កល្យាណំ សព្វំ វាបិ ន ចាបកន្តិ ។**

ការកណ្តាស់នោះ របស់បុគ្គលខ្លះល្អ ការកណ្តាស់នោះ

របស់បុគ្គលខ្លះអាក្រក់ ហេតុនោះ ការកណ្តាស់មិនមែនល្អ ទាំងអស់ មិនមែនអាក្រក់ទាំងអស់ទេ ។

បណ្តាបទទាំងនោះ បទថា **តថេវេកស្ស** បានដល់ **តថេវ-កស្ស**ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា សូម្បីបទទីពីរ ក៏មានន័យដូចនេះដែរ ។

ព្រះរាជាទ្រង់នាំហេតុការណ៍នោះមកដោយគាថានេះ យ៉ាងនេះ ទ្រង់បំពេញបុណ្យមានថ្វាយទានជាដើម ក្រោយអំពីសោយទិវង្គត ក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្តា ទ្រង់ប្រកាសផលនៃអំពើល្អអំពើអាក្រក់តាមលោកសន្មតហើយដោយព្រះធម្មទេសនានេះ ហើយទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍អ្នកមើលលក្ខណៈដាវក្នុងកាលនោះ បានមកជាព្រាហ្មណ៍អ្នកមើលលក្ខណៈដាវក្នុងកាលឥឡូវនេះ ចំណែកព្រះរាជាដែលជាព្រះភាគិនេយ្យនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា អសិលក្ខណជាតក ទី ៦ ។

# អដ្ឋកថា កលណ្ឌុកជាតក ទី ៧

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលច្រើនទៅដោយការអួតអាងមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **តេ ទេសា តានិ វត្ថូនិ** *ដូច្នេះជាដើម ។*

*រឿងទាំងពីរក្នុងជាតកនេះក៏ដូច* **កដាហកជាតក** *ដែរ ប៉ុន្តែក្នុងជាតកនេះ ទាសៈរបស់ពារាណសីសេដ្ឋីមានឈ្មោះថា កលណ្ឌុកៈ លួចរត់ចេញទៅគ្រប់គ្រងធីតារបស់បច្ចន្តសេដ្ឋី ហើយរស់នៅដោយបរិវារជាច្រើន សូម្បីពារាណសីសេដ្ឋីចាត់មនុស្សឲ្យដើររក ក៏រកមិនឃើញ មិនដឹងថាទាសៈនោះទៅណា ទើបបញ្ជូនសត្វសេកដែលនៅជាមួយនឹងខ្លួនទៅថា នែសេក អ្នកចូរទៅស៊ើបសួររកកលណ្ឌុកៈឲ្យឃើញចុះ សេកក៏ហើរទៅរហូតដល់នគរនោះ ។ ក្នុងកាលនោះ កលណ្ឌុកៈប្រាថ្នានឹងលេងទឹក ឲ្យអ្នកបម្រើកាន់យកកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ខាទនីយៈនិងភោជ-នាហារជាច្រើនទៅកាន់ស្ទឹង អង្គុយលើទូកជាមួយសេដ្ឋីធីតាលេងទឹកស្ទឹង ។ ក្នុងប្រទេសនោះ កាលអ្នកធំលេងកំសាន្តក្នុងទឹកតែងតែផឹកទឹកដោះស្រស់ជាមួយភេសជ្ជៈដែលមានរសប្រៃ ព្រោះហេតុនោះ កាលពួកនោះលេងទឹករហូតមួយថ្ងៃ ភាពរងាក៏មិនបានបៀតបៀន ប៉ុន្តែកលណ្ឌុកៈនេះកាន់កែវទឹកដោះស្រស់ខ្ពុរមាត់ហើយ ស្តោះទឹកដោះស្រស់នោះចោល សូម្បីកាលនឹងស្តោះចោល ក៏មិនស្តោះចោលទៅក្នុងទឹក ត្រឡប់ជាស្តោះ*

*ដាក់ក្បាលសេដ្ឋីធីតាទៅវិញ ។ ចំណែកកូនសេកហើរទៅដល់ស្ទឹងក៏ទំនៅលើមែកល្វា រកមើលក៏ចំណាំកលណ្ឌុកៈបាន ឃើញកំពុងស្តោះទឹកដោះស្រស់ដែលខ្ពុរមាត់នោះដាក់លើក្បាលសេដ្ឋីធីតា ក៏ពោលថា នែកលណ្ឌុកៈអ្នកមានជាតិអាក្រក់ណាស់ ចូរអ្នកនឹកដល់ជាតិកំណើតដើមរបស់ខ្លួនផង កុំយកទឹកដោះស្រស់មកលាងមាត់ ហើយស្តោះដាក់លើក្បាលសេដ្ឋីធីតាដែលជាអ្នកសម្បូរដោយជាតិកំណើត ចម្រើនដោយសេចក្តីសុខនោះឡើយ អ្នកមិនស្គាល់ប្រមាណខ្លួន ហើយពោលគាថានេះថា*

**តេ ទេសា តានិ វត្ថូនិ អហញ្ច វនគោចរោ**
**អនុវិច្ច ខោ តំ គណ្ហេយ្យុំ បិវ ខីរំ កាលណ្ឌុកាតិ ។**

*នោះជាប្រទេស នោះជាទីកន្លែង ( គឺផ្ទៃនៃទាសី ) សូម្បីខ្ញុំជាសត្វគោចរ ក្នុងព្រៃ ( គង់ដឹងដំណើរនុ៎ះ ម្ចាស់ទាំងឡាយរបស់អ្នក) រកឃើញហើយចាប់អ្នកមិនខាន ម្នាលកលណ្ឌុកៈ អ្នកចូរផឹកនូវទឹកដោះ ។*

*បណ្តាបទទាំងនោះ បទថា* **តេ ទេសា តានិ វត្ថូនិ** *នេះ កូនសេកពោលសំដៅដល់ផ្ទៃនៃមាតា ក្នុងចំណុចនេះ មានការអធិប្បាយដូច្នេះថា អ្នកកើតហើយក្នុងប្រទេសណា ប្រទេសនោះមិនមែនជាផ្ទៃនៃឥស្សរជន មានខត្តិយកញ្ញាជាដើមទេ កន្លែងដែលអ្នកនៅហើយ ចម្រើនធំធាត់ហើយ ក្នុងផ្ទៃនៃទាសីប៉ុណ្ណោះ ។*

បទថា **អហាញ្ច វនគោចរោ** នេះ សេកសម្ដែងសេចក្ដីថា សូម្បីខ្ញុំជាសត្វតិរច្ឆាន ក៏គង់ដឹងដំណើរនេះ ។

បទថា **អនុវិច្ច ខោ តំ គណ្ហេយ្យុំ** សេចក្ដីថា កាលខ្ញុំទៅប្រាប់ការប្រព្រឹត្តិដ៏អាក្រក់របស់អ្នកយ៉ាងនេះហើយ ម្ចាស់ទាំងឡាយរបស់អ្នកដឹងរឿងនេះហើយ គប្បីមកចាប់អ្នកទៅ គឺចាប់អ្នកទៅវាយ ហើយបោះត្រាជាគ្រឿងសម្គាល់ថាជាទាសៈមិនខាន ព្រោះហេតុនោះ អ្នកចូរប្រមាណខ្លួន ផឹកទឹកដោះហើយកុំស្ដោះដាក់ក្បាលសេដ្ឋីធីតាឡើយ កូនសេកហៅឈ្មោះទាសៈនោះថា កលណ្ឌុកៈ ។

ចំណែកកលណ្ឌុកៈក៏ចំណាំកូនសេកបាន ដោយខ្លាចកូនសេកបើករឿងអាថ៌កំបាំងរបស់ខ្លួនក៏ហៅថា នែសេក មកនេះ អ្នកមកអំពីកាលណា ? សូម្បីកូនសេកក៏ដឹងថា បុគ្គលនេះមិនបានហៅអញដោយបំណងល្អទេ មានបំណងនឹងមួលកអញឲ្យស្លាប់ ទើបពោលថា ខ្ញុំមិនមានកិច្ចអ្វីជាមួយអ្នកទេ ដូច្នេះហើយ ហើរអំពីទីនោះទៅកាន់នគរពារាណសី តំណាលរឿងរ៉ាវតាមដែលខ្លួនបានឃើញឲ្យសេដ្ឋីស្ដាប់ដោយពិស្ដារ ។ សេដ្ឋីគិតថា ទាសៈនោះធ្វើអំពើមិនសមគួរឡើយ ទើបដាក់អាជ្ញាដល់កលណ្ឌុកៈនោះ នាំខ្លួនមកកាន់នគរពារាណសីវិញ ហើយប្រើជាទាសៈតទៅ ។

ព្រះបរមសាស្ដាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា កលណ្ឌុកៈក្នុងកាលនោះ បានមកជាភិក្ខុដែលច្រើនទៅដោយ

ការអួតអាងនេះ ចំណែកពារាណសីសេដ្ឋី គឺ **តថាគត** នេះឯង ។

ចប់ អដ្ឋកថា កលណ្ឌុកជាតក ទី ៧ ។

# អដ្ឋកថា មូសិកជាតក ទី ៨

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលនិយាយកុហកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យោ វេ ធម្មទ្ធជំ កត្វា** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ក្នុងគ្រានោះ កាលដែលភិក្ខុទាំងឡាយក្រាប-ទូលរឿងដែលភិក្ខុនោះជាអ្នកកុហកឲ្យទ្រង់ជ្រាបហើយ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលភិក្ខុនេះជាអ្នកកុហកឆបោកនោះ សូម្បីក្នុងកាលមុនភិក្ខុនេះក៏ជាអ្នកកុហកឆបោកដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងកំណើតសត្វកណ្តុរ ធំឡើងមានរូបរាងធាត់ធំស្រដៀងកូនជ្រូក មានកណ្តុរច្រើនរយជាបរិវាររស់នៅក្នុងព្រៃ ។ គ្រានោះ មានចចកមួយដើរទៅតាមទំនើង ឃើញហ្វូងកណ្តុរនោះហើយ គិតថា អញនឹងបោកបញ្ឆោតកណ្តុរទាំងនេះ ហើយចាប់ពួកវាស៊ី ហើយងើបមុខសម្លឹងមើលព្រះអាទិត្យ ឈរជើងម្ខាងក្នុងទី

មិនឆ្ងាយពីកន្ទ្រែងដែលហ្វូងកណ្ដុររស់នៅ ។ ព្រះពោធិសត្វត្រាច់រកអាហារ ឃើញចចកហើយ គិតថា ចចកនេះ គង់ជាអ្នកមានសីល ទើបដើរទៅកាន់សម្នាក់របស់ចចក រួចសួរថា នែលោកដ៏ចម្រើន លោកឈ្មោះអ្វី ?

ចចកឆ្លើយថា យើងឈ្មោះ ធម្មិកៈ ។

ព្រះពោធិសត្វសួរថា ព្រោះហេតុដូចម្ដេច លោកមិនឈរដោយជើងទាំង ៤ ឈរដោយជើងតែម្ខាង ?

ចចកឆ្លើយថា កាលបើយើងជាន់ផែនដីដោយជើងទាំង ៤ ផែនដីមិនអាចទ្រាំទ្របាន ព្រោះហេតុនោះ ទើបយើងត្រូវឈរតែជើងម្ខាងប៉ុណ្ណោះ ។

ព្រះបរមពោធិសត្វសួរថា ហេតុដូចម្ដេចទើបត្រូវឈរហាមាត់ ?

ចចកឆ្លើយថា យើងមិនស៊ីអាហារដទៃ ស៊ីតែខ្យល់ប៉ុណ្ណោះ ។

ព្រះបរមពោធិសត្វសួរថា កាលបើដូច្នោះ ហេតុអ្វីទើបត្រូវសម្លឹងមើលព្រះអាទិត្យ ?

ចចកឆ្លើយថា ព្រោះយើងគោរពព្រះអាទិត្យ ។ ព្រះមហាសត្វស្ដាប់ពាក្យរបស់ចចកហើយ ជឿជាក់ថា ចចកនេះ ពិតជាមានសីលមែន ពេលនោះក៏ទៅកាន់ទីបម្រើចចកនោះ ជាមួយហ្វូងកណ្ដុរទាំងពេលព្រឹកទាំងពេលល្ងាច ។ នៅពេលដែលកណ្ដុរពោធិសត្វធ្វើការបម្រើហើយត្រឡប់ទៅវិញ ចចកនោះក៏ចាប់កណ្ដុរមួយចុងក្រោយ ស៊ីហើយជូតមាត់

យ៉ាងស្អាត ឈរធ្វើមិនដឹង ។ ហ្វូងកណ្ដុរអស់ទៅៗដោយលំដាប់ ។ ហ្វូងកណ្ដុរប្រឹក្សាគ្នាថា ក្នុងកាលមុនពួកយើងត្រូវប្រជ្រៀតគ្នា នៅពេលនេះមើលទៅដូចជានៅទូលាយមិនចង្អៀត លំនៅសូម្បីប៉ុណ្ណោះក៏មិនពេញ តើមានរឿងអ្វីហ្ន៎ ហើយនាំគ្នាប្រាប់រឿងនោះដល់ព្រះពោធិសត្វ ។ ព្រះ-ពោធិសត្វគិតថា មានហេតុអ្វីហ្ន៎ ទើបហ្វូងកណ្ដុរចេះតែរលស់ទៅៗយ៉ាងនេះ ចាប់ផ្ដើមសង្ស័យចំពោះចចក គិតថា ត្រូវសាកល្បងចចក នៅពេលទៅបម្រើឲ្យហ្វូងកណ្ដុរចេញទៅមុន ខ្លួនឯងនៅក្រោយគេ ចចកក៏រត់ទៅចាប់កណ្ដុរពោធិសត្វ ។ កណ្ដុរពោធិសត្វឃើញចចកនោះចាប់ខ្លួន ក៏បែរត្រឡប់ហើយពោលថា នែចចក អ្នកមានកល ការបំពេញវត្តរបស់អ្នកនេះមិនមែនប្រព្រឹត្តទៅដើម្បីការប្រព្រឹត្តិល្អ បដិបត្តិដ៏ប្រពៃទេ ប៉ុន្តែអ្នកបានប្រព្រឹត្តបិទបាំងទោស យកធម៌ធ្វើជាទង់ជ័យ ដើម្បីបៀតបៀនសត្វដទៃហើយពោលគាថានេះថា

**យោ វេ ធម្មទ្ធជំ កត្វា ឆិតុយ្ហោ ចាបមាចរេ**
**វិស្សាសយិត្វា ភូតានិ ពិឡារន្នាម តំ វតន្តិ ។**

បុគ្គលអ្នកបិទបាំងទោសណា ធ្វើនូវធម៌ឲ្យជាទង់ជ័យ ញុំាងសត្វទាំងឡាយឲ្យទុកចិត្ត ហើយប្រព្រឹត្តនូវអំពើអាក្រក់ វត្តរបស់បុគ្គលនោះ ឈ្មោះថា ពិឡារវត្ត (វត្តឆ្មា) ។

បណ្ដាបទទាំងនោះ បទថា **យោ វេ** សេចក្ដីថា ពួកជនមានក្សត្រ

ជាដើម បុគ្គលណាមួយក៏ដោយ ។

បទថា **ធម្មធជំ កត្វា** សេចក្ដីថា លើកស្ទួយកុសលកម្មបថ ១០ ប្រការជាទង់ គឺធម៌ ធ្វើដូចខ្លួនបដិបត្តិធម៌នោះ លើកឡើងសម្ដែង ។

បទថា **វិស្សាសយិត្វា** សេចក្ដីថា ធ្វើឲ្យកណ្ដុរទាំងឡាយទុកចិត្ត ដោយសម្គាល់ខុសថា អ្នកនេះមានសីល ។

បទថា **ពិឡារវ្ឍាម តំ វតំ** សេចក្ដីថា ពិឡារវត្តរបស់អ្នកដែលធ្វើនូវធម៌ឲ្យជាទង់ជ័យយ៉ាងនេះ ហើយបិទបាំងទោស ប្រព្រឹត្តនូវអំពើអាក្រក់នោះ រមែងមានឈ្មោះថា ជាវត្តប្រកបដោយការបោកប្រាស់ ។

ព្រះមហាសត្វពោលបណ្ដើរលោតឡើងតោងកចចកនោះបណ្ដើរ ខាំត្រង់ក ក្រោមចង្កាឲ្យដល់នូវការអស់ជីវិត កណ្ដុរទាំងឡាយមកខាំស៊ីចចកដោយមានសំឡេងដ៏លាន់ឮ ហើយនាំគ្នាទៅ បានឮថា កណ្ដុរដែលមកមុនបានស៊ីសាច់ កណ្ដុរដែលមកក្រោយមិនបានស៊ី ចាប់ពីពេលនោះមក ពួកកណ្ដុរក៏អស់ភ័យបានសេចក្ដីសុខ ។

ព្រះបរមសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះ បានមកជាភិក្ខុដែលកុហកឆបោកក្នុងកាលឥឡូវនេះ ចំណែកស្ដេចកណ្ដុរ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា មូសិកជាតក ទី ៨ ។

# អដ្ឋកថា អគ្គិកជាតក ទី ៩

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលនិយាយកុហកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ជាយំ សិខា បុញ្ញហេតុ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន ដូចរឿងដែលពោលហើយខាងដើមនោះឯង ។

សេចក្តីសង្ខេបថា ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាស្តេចកណ្តុរនៅក្នុងព្រៃ ។ គ្រានោះ កាលភ្លើងឆេះព្រៃ ចចកមួយមិនអាចរត់គេចទៅបាន ក៏ឈរយកក្បាលទល់នឹងដើមឈើមួយដើម រោមរបស់ចចកនោះត្រូវភ្លើងឆេះអស់ សល់តែរោមត្រង់ដែលវាយកក្បាលទល់នឹងដើមឈើបន្តិចដូចកំប៉ោយនៅលើក្បាល ។ ថ្ងៃមួយ ចចកនោះទៅផឹកទឹកក្នុងត្រពាំងសម្ញឹងមើលស្រមោលឃើញកំប៉ោយហើយ គិតថា ពេលនេះវត្ថុដែលជាមូលដ្ឋាននៃកណ្តាកើតដល់អញហើយ ។ កាលនៅក្នុងព្រៃឃើញហ្វូងកណ្តុរនោះ គិតថា អញនឹងបោកបញ្ឆោតស៊ីកណ្តុរទាំងនេះ ហើយបានឈរនៅក្នុងទីមិនឆ្ងាយ តាមន័យដែលបានពោលមកហើយក្នុងកាលមុននោះឯង ។ គ្រានោះ ព្រះមហាសត្វដើររកអាហារឃើញចចកនោះហើយ ក៏ចូលទៅរកដោយសម្គាល់ថា បុគ្គលនេះ ជាអ្នកមានសីល ហើយសួរថា អ្នកឈ្មោះអ្វី ?

ចចកឆ្លើយថា យើងឈ្មោះអគ្គិកភារទ្វាជ ។

កណ្ដុរពោធិសត្វសួរថា អ្នកមកទីនេះ ធ្វើអ្វី ?

ចចកឆ្លើយថា មកដើម្បីជួយគ្រប់គ្រងរក្សាពួកអ្នក ។

កណ្ដុរពោធិសត្វសួរទៀតថា អ្នកនឹងធ្វើយ៉ាងណា ទើបគ្រប់គ្រងមើលថែពួកយើងបាន ?

ចចកឆ្លើយថា យើងដឹងវិធីរាប់ចំនួន ដែលគេហៅថា រាប់ដោយកន្ទុយ ក្នុងពេលដែលពួកអ្នកចេញទៅរកស៊ីពេលព្រឹក យើងក៏រាប់ថាមានចំនួនប៉ុណ្ណោះ ពេលត្រឡប់មកវិញក៏ត្រូវរាប់មើល កាលយើងរាប់មើលទាំងព្រឹកទាំងល្ងាចយ៉ាងនេះ ក៏នឹងគ្រប់គ្រងមើលថែពួកអ្នកបាន ។

ស្ដេចកណ្ដុរពោលថា បើដូច្នោះ ក៏ចូរគ្រប់គ្រងចុះ ។ ចចកទទួលពាក្យហើយ នៅពេលដែលពួកកណ្ដុរចេញទៅរកស៊ី ក៏ចាប់ផ្ដើមរាប់មួយ ពីរ បីជាដើម សូម្បីនៅពេលដែលត្រឡប់មកវិញ ក៏រាប់មួយ ពីរ បី ជាដើមដែរ ហើយសង្គ្រប់ចាប់កណ្ដុរដែលដើរក្រោយគេស៊ី រឿងដ៏សេសដូចរឿងមុននោះឯង ប៉ុន្តែក្នុងជាតកនេះ កណ្ដុរពោធិសត្វបែរត្រឡប់មកឈរហើយពោលថា នែចចកអគ្គិកភារទ្វាជបោកប្រាស់ កំប៉ោយដែលនៅលើក្បាលរបស់អ្នក មិនមែនមានដើម្បីសច្ចៈ សុចរិត និងយុត្តិធម៌ទេ ប៉ុន្តែមានព្រោះហេតុនៃផ្ទៃ ហើយពោលគាថានេះថា

**ឆាយំ សិខា បុញ្ញហេតុ ឃាសហេតុ អយំ សិខា**

**ឧក្កុដ្ឋគណ្ឌំ យាតិ អលង្កេ ហោតុ អគ្គិកាតិ ។**

*កំប៉ោយនេះមិនមែនមាន ព្រោះហេតុនៃបុណ្យទេ កំប៉ោយនេះមាន ព្រោះហេតុតែគ្រឿងបរិភោគ ការរាប់ដោយកន្ទុយរមែងប្រព្រឹត្តទៅ នៃអគ្គិកៈ ការនៅរួមគ្នាគួរដល់អ្នកហើយ ។*

*បណ្ដាបទទាំងនោះ បទថា* **ឧក្កុដ្ឋគណ្ឌំ យាតិ** *លោកពោលសំដៅដល់ការរាប់ដោយកន្ទុយ អធិប្បាយថា ហ្វូងកណ្ដុរនេះមិនដល់ មិនប្រហាក់ប្រហែល មិនគ្រប់ចំនួន បានដល់រលស់ទៅៗ គឺតិចទៅៗ ។*

*បទថា* **អលង្កេ ហោតុ អគ្គិកា** *សេចក្ដីថា ស្ដេចកណ្ដុរ កាលនឹងនិយាយចំពោះចចកហៅដោយឈ្មោះថា អគ្គិកៈ អធិប្បាយថា នៃអគ្គិកៈ អ្នកមានកលល្បិចអើយ សម្រាប់អ្នកល្មមត្រឹមប៉ុណ្ណោះចុះ ខាងមុខអំពីនេះទៅ អ្នកនឹងខាំកណ្ដុរស៊ីទៀតមិនបាន យើងនិងអ្នកឈប់នៅរួមគ្នា អធិប្បាយថា ពេលនេះពួកយើងនឹងមិនអាចនៅរួមជាមួយអ្នកតទៅទៀតបានទេ ពាក្យដ៏សេសដូចរឿងដែលបានពោលហើយនោះឯង ។*

*ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ចចកក្នុងកាលនោះ បានមកជាភិក្ខុដែលនិយាយកុហកក្នុងកាលឥឡូវនេះ ចំណែកស្ដេចកណ្ដុរ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា អគ្គិកជាតក ទី ៩ ។

# អដ្ឋកថា កោសិយជាតក ទី ១០

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមាតុគ្រាមក្នុងនគរសាវត្ថីម្នាក់ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យថា វាចា ច កុញ្ចស្ស** ដូច្នេះជាដើម ។

បានឮថា ព្រាហ្មណីរបស់ព្រាហ្មណ៍ឧបាសកអ្នកមានសទ្ធាជ្រះថ្លាមួយរូប ជាស្ត្រីប្រព្រឹត្តអាក្រក់យ៉ាងខ្លាំងក្លា ថោកទាប លាមក ពេលយប់ប្រព្រឹត្តក្បត់ចិត្តប្តី ពេលថ្ងៃមិនធ្វើការងារអ្វីទាំងអស់ ធ្វើពុតជាឈឺ ដេកដកដង្ហើមធំតូចទៅមក ។ ពេលនោះ ព្រាហ្មណ៍សួរនាងថា នែនាងដ៏ចម្រើន នាងមិនស្រួលខ្លួនឬ ?

នាងឆ្លើយថា ខ្យល់វាចាក់សៀតខ្ញុំ ។

ព្រាហ្មណ៍សួរថា បើដូច្នោះ បានអ្វីទើបសមគួរ ?

នាងឆ្លើយថា ត្រូវបានយាគូ ភត្ត និងប្រេងជាដើម ដ៏ប្រណីតៗ ។ ព្រាហ្មណ៍ក៏ទៅរកវត្ថុដែលនាងត្រូវការនោះមកឲ្យ ធ្វើកិច្ចគ្រប់យ៉ាងដូចជាទាសៈ ។ ចំណែកព្រាហ្មណីពេលព្រាហ្មណ៍ចូលផ្ទះក៏ដេក ពេលព្រាហ្មណ៍ចេញអំពីផ្ទះក៏ប្រឡែងលេងជាមួយសហាយស្មន់ ។ ចំណែកព្រាហ្មណ៍ក៏គិតថា គំនរខ្យល់ដែលចាក់សៀតសរីរៈភរិយារបស់អញនេះ មើលទៅដូចជាមិនមានទីបំផុត ។ ថ្ងៃមួយ បានកាន់គ្រឿងក្រអូបនិងកម្រងផ្កាជាដើមទៅកាន់វត្តជេតពន បូជាព្រះបរមសាស្តាថ្វាយបង្គំហើយអង្គុយក្នុងទីដ៏

សមគួរមួយ កាលមានព្រះតម្រាស់ថា ម្នាលព្រាហ្មណ៍ ព្រោះហេតុអ្វីទើបអ្នកបាត់មុខយូរម្ល៉េះ ?

ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្យល់ចាក់សៀតសរីរៈព្រាហ្មណីរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គត្រូវស្វែងរកទឹកដោះថ្លា ប្រេងជាដើម និងភោជនដ៏ប្រណីតៗឲ្យនាង រាងកាយរបស់នាងចេះតែធំជាត់ឡើងៗ ពណ៌សម្បុរចេះតែស្រស់ថ្លា ប៉ុន្តែរោគខ្យល់ចាក់ដោតនៅតែដដែល មិនចេះស្រាកស្រាន្ត ខ្ញុំព្រះអង្គត្រូវបម្រើនាងរឿយៗ ទើបមិនមានឱកាសមកកាន់វិហារ ។ ព្រះបរមសាស្តាទ្រង់ជ្រាបគំនិតអាក្រក់របស់ព្រាហ្មណីហើយ ទើបទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ មាតុគ្រាមកាលដេកយ៉ាងនេះរោគក៏មិនស្ងប់ ត្រូវផ្សំថ្នាំយ៉ាងនេះឲ្យទើបសមគួរ សូម្បីក្នុងកាលមុនបណ្ឌិតក៏ធ្លាប់ប្រាប់អ្នកហើយដែរ ប៉ុន្តែអ្នកមិនចាំព្រោះមានហេតុដែលភពមកបិទបាំង កាលព្រាហ្មណ៍ក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍មហាសាល រៀនសិល្បៈគ្រប់ប្រការក្នុងនគរតក្កសិលា ហើយបានជាអាចារ្យទិសាបាមោក្ខក្នុងនគរពារាណសី ខត្តិយកុមារក្នុងរាជធានីទាំង ១០១ និងព្រាហ្មណកុមារ នាំគ្នាមករៀនសិល្បៈក្នុងសម្នាក់ព្រះបរមពោធិសត្វយ៉ាង

ច្រើន ។ គ្រានោះ មានព្រាហ្មណ៍អ្នកជនបទមួយរូប រៀនត្រៃវេទនិងវិជ្ជា ឋាន ១៨ ប្រការក្នុងសម្នាក់ព្រះបរមពោធិសត្វ មានភរិយានៅក្នុងនគរ ពារាណសីនោះឯង គាត់មកកាន់សម្នាក់ព្រះបរមពោធិសត្វ ក្នុងមួយថ្ងៃ ពីរ-បីដង រាល់ៗថ្ងៃ ។ ព្រាហ្មណីរបស់ព្រាហ្មណ៍នោះ ជាស្ត្រីមានកល-ល្បិចប្រព្រឹត្តអាក្រក់យ៉ាងខ្លាំងក្លា ថោកទាប លាមក រឿងទាំងពួង តាំងពីនេះទៅ ដូចរឿងក្នុងបច្ចុប្បន្ននោះដែរ ។ ចំណែកព្រះបរមពោធិសត្វកាល ព្រាហ្មណ៍នោះប្រាប់ថា ដោយហេតុនេះ ទើបខ្ញុំមិនមានឱកាសដើម្បីនឹង មកទទួលឱវាទ ដូច្នេះ ក៏ជ្រាបថា មាណវិកានោះ ដេកបោកបញ្ឆោត ព្រាហ្មណ៍នេះ ហើយគិតថា អញត្រូវប្រាប់ថ្នាំដែលសមគួរឲ្យនាង ហើយ ពោលថា នែព្រាហ្មណ៍ ចាប់ពីពេលនេះទៅ អ្នកកុំឲ្យទឹកដោះស្រស់និង ទឹកដោះថ្លាដល់នាងជាដាច់ខាត ប៉ុន្តែចូរបុកស្លឹកឈើ ៥ ប្រភេទ និងផ្លែ ឈើ ៣ ប្រភេទជាដើម ដាក់ក្នុងទឹកនោមគោ ហើយដាក់ត្រាំក្នុងភាជនៈ ស្ពាន់ថ្មីៗ ឲ្យក្លិនលោហៈវាចាប់ ហើយកាន់យកផ្តៅឬរំពាត់ រួចពោលថា នែនាងដ៏ចម្រើន ថ្នាំនេះត្រូវនឹងរោគរបស់នាង នាងចូរផឹកថ្នាំនេះចុះ ឬ មិនដូច្នោះ ក៏ក្រោកឡើងធ្វើការងារឲ្យសមគួរដល់ភត្តដែលនាងបរិភោគ ហើយ ហើយត្រូវពោលគាថានេះ ប្រសិនបើនាងមិនព្រមផឹកថ្នាំ ក៏ត្រូវ យកផ្តៅ ឬរំពាត់វាយនាងដោយមិនចាំបាច់រាប់ឡើយ ហើយចាប់សក់ ទាញមកអុកដោយកែង នាងនឹងក្រោកឡើងធ្វើការងារមិនខាន ។

ព្រាហ្មណ៍ទទួល ថា ប្រពៃណាស់ ហើយផ្សំថ្នាំតាមដែលព្រះបរមពោធិសត្វបានប្រាប់ រួចពោលថា នែនាងដ៏ចម្រើន ក្រោកឡើងផឹកថ្នាំនេះចុះ ។

ព្រាហ្មណីសួរថា ថ្នាំនេះ អ្នកណាប្រាប់ឲ្យលោកផ្សំ ?

ព្រាហ្មណ៍ឆ្លើយថា អាចារ្យប្រាប់ខ្ញុំ ។

ព្រាហ្មណីពោលថា យកទៅវិញចុះ ខ្ញុំមិនផឹកទេ ។

ព្រាហ្មណ៍ពោលថា នាងនឹងផឹកតាមចិត្តរបស់នាងមិនបានទេ ហើយស្រវាចាប់រំពាត់រួចពោលថា នាងចូរផឹកថ្នាំដែលត្រូវនឹងរោគរបស់ខ្លួន បើមិនដូច្នោះទេ ចូរធ្វើការងារឲ្យសមគួរដល់កត្តដែលនាងបរិភោគហើយចុះ ហើយពោលគាថានេះថា

**យថា វាចា ច ភុញ្ជស្សុ យថា ភុត្តញ្ច ព្យាហរ**
**ឧភយន្តេ ន សមេតិ វាចា ភុត្តញ្ច កោសិយេតិ ។**

នាងចូរបរិភោគឲ្យដូចជាសម្ដី ចូរលេប (ថ្នាំ) ឲ្យដូចជាបាយ
ដែលនាងស៊ីហើយ ម្នាលព្រាហ្មណីជាកោសិយគោត្រ
(ព្រោះ) វាចានិងភត្តដែលនាងបរិភោគហើយ ទាំងពីរ
(នេះ) មិនស្មើគ្នាទេ ។

បណ្ដាបទទាំងនោះ បទថា **យថា វាចា ច ភុញ្ជស្សុ** សេចក្ដីថា នាងចូរបរិភោគឲ្យដូចជាសម្ដី អធិប្បាយថា ចូរបរិភោគឲ្យដូចជាវាចាដែលនាងបានពោលថាខ្យល់ចាក់សៀតខ្ញុំដូច្នេះ ។ បាឋថា **យថា វាចំ**

**វា វា** ដូច្នេះក៏គួរ អាចារ្យខ្លះក៏សូត្រថា **យថា វាចាយ** ដូច្នេះក៏មាន បទទាំងនេះក៏មានសេចក្តីដូចគ្នានោះឯង ។

បទថា **យថា កុត្តញ្ច ព្យាហរ** សេចក្តីថា ចូរនិយាយចេញមកឲ្យដូចអាហារដែលនាងបរិភោគហើយ អធិប្បាយថា ចូរប្រាប់មកថា ខ្ញុំគ្មានរោគទេដូច្នេះ ហើយធ្វើការងារដែលត្រូវធ្វើក្នុងផ្ទះ ។ បាឋថា **យថា កុត្តញ្ច** ដូច្នេះក៏មាន ម្យ៉ាងទៀតមានអធិប្បាយថា ចូរនិយាយតាមការពិតថា ខ្ញុំមិនមានរោគទេ ដូច្នេះហើយធ្វើការងារចុះ ។

បទថា **ឧភយន្តេ ន សមេតិ វាចា កុត្តញ្ច កោសិយេ** សេចក្តីថា វាចារបស់នាងដែលពោលថាខ្យល់ចាក់សៀតខ្ញុំដូច្នេះ និងភត្តដ៏ប្រណីតដែលនាងបរិភោគហើយ ទាំងពីរយ៉ាងរបស់នាងមិនសមគ្នាឡើយ ព្រោះហេតុនោះ ចូរក្រោកឡើងធ្វើការងារចុះ ។

កាលព្រាហ្មណ៍ពោលយ៉ាងនេះហើយ ធីតានៃកោសិយព្រាហ្មណ៍គិតថា ចាប់តាំងពីពេលដែលអាចារ្យជួយខ្វល់ខ្វាយមក អញមិនអាចបោកប្រាស់ព្រាហ្មណ៍តទៅទៀតបានទេ ត្រូវតែក្រោកឡើងធ្វើការងារដូច្នេះហើយ ក៏ក្រោកឡើងប្រកបកិច្ចការតាមតួនាទីរបស់ខ្លួន ថែមទាំងជាស្ត្រីមានសីល វៀរចាកការប្រព្រឹត្តិអាក្រក់ ដោយការខ្លាចក្រែងចំពោះអាចារ្យថា ការដែលអញជាស្ត្រីប្រព្រឹត្តអាក្រក់ដ៏ខ្លាំងក្លា អាចារ្យដឹងអស់ហើយ តទៅនេះ អញមិនអាចនឹងធ្វើដូច្នេះបានទៀតទេ ។

*សូម្បីនាងព្រាហ្មណីនោះ ក៏មិនហ៊ានប្រព្រឹត្តអនាចារទៀត ដោយការគោរពព្រះបរមសាស្តាថា បានឮថា ព្រះសម្មាសម្ពុទ្ធទ្រង់ដឹងរឿងរបស់អញហើយ ។*

*ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា គូស្វាមីភរិយាក្នុងកាលនោះ បានមកជាគូស្វាមីភរិយាក្នុងកាលឥឡូវនេះ ចំណែកអាចារ្យ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា កោសិយជាតក ទី ១០ ។

ចប់ អដ្ឋកថា កុសនាឡិវគ្គ ទី ១៣ ។

# រួមជាតកដែលមានក្នុងវគ្គនេះគឺ

*កុសនាឡិជាតក ១ ទុម្មេធជាតក ១ នង្គលីសជាតក ១*
*អម្ពជាតក ១ កដាហកជាតក ១ អសិលក្ខណជាតក ១*
*កលណ្ឌុកជាតក ១ មូសិកជាតក ១ អគ្គិកជាតក ១*
*កោសិយជាតក ១ ៕*

# អសម្បទានវគ្គ ទី ១៤
# អដ្ឋកថា អសម្បទានជាតក ទី ១

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **អសម្បទានេនិតរីតរស្ស** *ដូច្នេះជាដើម ។*

*សេចក្តីសង្ខេបថា ក្នុងកាលនោះ ភិក្ខុទាំងឡាយលើករឿងឡើងសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ភិក្ខុទេវទត្តជាបុគ្គលអកតញ្ញូមិនដឹងគុណព្រះតថាគត ។ ព្រះបរមសាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយ ក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលភិក្ខុទេវទត្តជាបុគ្គលអកតញ្ញូនោះ សូម្បីក្នុងកាលមុនក៏ជាបុគ្គលអកតញ្ញូដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា*

*ក្នុងអតីតកាល ព្រះរាជាមគធៈមួយព្រះអង្គសោយរាជសម្បត្តិនៅក្នុងនគររាជគ្រឹះ ដែនមគធៈ ព្រះបរមពោធិសត្វសោយព្រះជាតិជាសេដ្ឋីនៃព្រះរាជាអង្គនោះ មានសម្បត្តិ៨០កោដិ ឈ្មោះថា សង្ខសេដ្ឋី ។ នៅក្នុងនគរពារាណសីមានសេដ្ឋីមានសម្បត្តិ ៨០ កោដិ ឈ្មោះថា បិលិយសេដ្ឋី ។ សេដ្ឋីទាំងពីរនោះ ជាសម្លាញ់នឹងគ្នា ។ ក្នុងសេដ្ឋីទាំងពីរនោះ បិលិយសេដ្ឋី*

នៅក្នុងនគរពារាណសីជួបប្រសព្វភ័យយ៉ាងមហន្ត ដោយសេដ្ឋីអស់ទ្រព្យសម្បត្តិ ធ្លាក់ខ្លួនក្រ គ្មានទីពឹង បបួលភរិយាធ្វើដំណើរទៅរកសង្ខសេដ្ឋីដើម្បីបានទីពឹង ។ សេដ្ឋីនោះចេញអំពីនគរពារាណសីសំដៅទៅកាន់នគររាជគ្រឹះដោយជើងទទេ រហូតដល់និវេសន៍របស់សង្ខសេដ្ឋី ។ សង្ខសេដ្ឋីឃើញបិលិយសេដ្ឋីហើយពោលថា សម្លាញ់របស់យើងមកហើយ ទទួលយ៉ាងរាក់ទាក់ សម្តែងការគោរពរាប់អាន ឲ្យស្នាក់នៅពីរ-បីថ្ងៃ ។ ថ្ងៃមួយសង្ខសេដ្ឋីបានសួរថា នែសម្លាញ់ អ្នកមកទីនេះមានការអ្វី ?

បិលិយសេដ្ឋីឆ្លើយថា នែសម្លាញ់ភ័យកើតដល់ពួកខ្ញុំ ខ្ញុំអស់ទ្រព្យធ្លាក់ខ្លួនក្រ ជួយឧបត្ថម្ភពួកខ្ញុំផងចុះ ។ ចំណែកសង្ខសេដ្ឋីក៏ពោលថា សាធុសម្លាញ់ កុំខ្លាចឡើយ ហើយបញ្ជាឲ្យបើកឃ្លាំងចែកប្រាក់ឲ្យ ៤០ កោដិហើយនៅបែងចែកសវិញ្ញាណកទ្រព្យ អវិញ្ញាណកទ្រព្យ និងបរិវារពាក់កណ្តាលឲ្យទៀតផង ។ បិលិយសេដ្ឋីក៏ដឹកជញ្ជូនទ្រព្យសម្បត្តិទៅនគរពារាណសីវិញ ។

ក្រោយមកភ័យដូច្នោះ ក៏កើតដល់សង្ខសេដ្ឋីវិញ សង្ខសេដ្ឋីប្រាថ្នានឹងរកទីពឹង បានគិតឃើញថា អញបានធ្វើឧបការៈយ៉ាងធំដល់សម្លាញ់របស់អញ បានបែងចែកទ្រព្យពាក់កណ្តាលឲ្យ បិលិយសេដ្ឋីសម្លាញ់ឃើញអញហើយ គង់មិនបោះបង់អញ អញនឹងទៅរកគេ លុះគិតដូច្នេះហើយ ក៏នាំភរិយាទៅកាន់នគរពារាណសីដោយជើងទទេ ។ សង្ខសេដ្ឋី

ពោលទៅកាន់ភរិយាថា នែនាង៩ចម្រើន កាលបើនាងនឹងដើរទៅតាមផ្លូវជាមួយខ្ញុំ មើលទៅមិនសមគួរឡើយ នាងរង់ចាំឡើងយាននៅពេលដែលខ្ញុំបញ្ជូនមក ហើយទៅជាមួយបរិវារដែលមានចំនួនច្រើនខាងក្រោយចុះ ចូររង់ចាំនៅទីនេះរហូតទាល់តែខ្ញុំបញ្ជូនយានមកទទួល លុះពោលដូច្នេះហើយ ឲ្យភរិយាសម្រាកនៅក្នុងសាលា ខ្លួនឯងចូលកាន់នគរ ទៅកាន់ផ្ទះបិលិយសេដ្ឋី ឲ្យមនុស្សទៅប្រាប់ថា សម្លាញ់របស់លោកឈ្មោះ សង្ខសេដ្ឋីមកអំពីនគររាជគ្រឹះ ។ បិលិយសេដ្ឋីឲ្យមនុស្សទៅអញ្ជើញមក កាលឃើញសង្ខសេដ្ឋីហើយ ក៏មិនបានក្រោកឡើងអំពីអាសនៈ មិនធ្វើបដិសណ្ឋារៈឡើយ ហាមាត់សួរតែម្យ៉ាងថា លោកមកមានការអ្វី ?

សង្ខសេដ្ឋីឆ្លើយថា ខ្ញុំមកដើម្បីជួបលោក ។

បិលិយសេដ្ឋីសួរថា លោកសម្រាកនៅទីណា ?

សង្ខសេដ្ឋីឆ្លើយថា ទីសម្រាករបស់ខ្ញុំមិនទាន់មានទេ ខ្ញុំឲ្យភរិយាឈប់រង់ចាំនៅឯសាលា ហើយមកទីនេះមុន ។

បិលិយសេដ្ឋីពោលថា ទីសម្រាករបស់លោកនៅទីនេះ ក៏មិនមានដែរ លោកចូរទទួលអាហារទៅឲ្យគេចំអិនបរិភោគនៅកន្លែងណាមួយ ហើយនាំគ្នាទៅចុះ កុំមកជួបយើងទៀតឡើយ ហើយប្រើទាសៈថា អ្នកចូរវាល់សម្ពីស្រូវ ៤ នាឡិ វេចនឹងជាយសំពត់សម្លាញ់របស់យើងឲ្យគេទៅចុះ ។ បានឮថា ថ្ងៃនោះ បិលិយសេដ្ឋីឲ្យមនុស្សអុំស្រូវសាលីពណ៌ក្រហមប្រមាណ

១ ពាន់រទេះ លើកឡើងដាក់ពេញជង្រុក ចាប់តាំងពីបានទទួលទ្រព្យ ៤០ កោដិមក នៅរមិលគុណដូចមហាចោរ ប្រាប់ឲ្យវាល់សម្ពីស្រូវ ៤ នាឡិដល់សម្លាញ់ដូច្នេះ បានឲ្យទាសៈវាល់សម្ពីស្រូវ ៤ នាឡិដាក់ក្នុងថង់ ហើយយកទៅឲ្យព្រះពោធិសត្វ ។ ព្រះពោធិសត្វគិតថា បុគ្គលនេះជាអសប្បុរស បានទ្រព្យ ៤០ កោដិអំពីសម្នាក់អញ ពេលនេះប្រាប់ឲ្យទាសៈវាល់សម្ពីស្រូវ ៤ នាឡិឲ្យដល់អញ អញគួរទទួលឬ មិនគួរទទួលហ្ន៎ លុះគិតឃើញថា បុគ្គលនេះជាអ្នកមិនដឹងគុណ ទ្រុស្តមិត្ត ទម្លាយនូវមិត្តភាពចំពោះអញ ជាមនុស្សកាត់ផ្តាច់នូវឧបការៈដែលអញធ្វើទុកហើយ ប្រសិនបើអញមិនទទួលសម្ពីស្រូវ ៤ នាឡិដែលគេឲ្យ ព្រោះជារបស់មិនល្អទេ ក៏នឹងត្រូវទម្លាយមិត្តភាព បុគ្គលអន្ធពាលដែលមិនព្រមទទួលវត្ថុដែលខ្លួនបានតិចតួចទេ រមែងញ៉ាំងមិត្តភាពឲ្យវិនាស ប៉ុន្តែអញទទួលសម្ពីស្រូវដែលគេឲ្យ នឹងតម្កល់មិត្តភាពទុកបានដោយអំណាចអាត្មាអញ ហើយក៏វេចសម្ពីស្រូវ ៤ នាឡិនឹងជាយសំពត់ ចុះអំពីប្រាសាទទៅកាន់សាលា ។ ពេលនោះ ភរិយាសួរថា បពិត្រអ្នកជាម្ចាស់ លោកបានវត្ថុអ្វីខ្លះ ?

សង្ខសេដ្ឋីឆ្លើយថា បិលិយសេដ្ឋីសម្លាញ់ ប្រើគេឲ្យវាល់សម្ពីស្រូវ ៤ នាឡិឲ្យ ហើយកម្ចាត់យើងចោលក្នុងថ្ងៃនេះឯង ។

នាងពោលថា បពិត្រអ្នកជាម្ចាស់ លោកយកមកធ្វើអ្វី ? វាសមនឹងទ្រព្យ ៤០ កោដិដែរឬ ? ហើយផ្តើមស្រែកយំ ។

*ព្រះបរមពោធិសត្វពោលថា នែនាងដ៏ចម្រើន នាងកុំយំឡើយ បង ខ្លាចក្រែងខូចមេត្រីភាពជាមួយគេ ទើបបងទទួលមកដើម្បីញ៉ាំងមិត្តភាព ឲ្យតាំងនៅដោយអំណាចបង នាងយំធ្វើអ្វី ? ដូច្នេះហើយពោលគាថា នេះថា*

**អសម្បទានេនិតរីតរស្ស**
**ពាលស្ស មិត្តានិ កលី ភវន្តិ**
**តស្មា ហរាមិ ភុស្សមឌ្ឍមានំ**
**មា មេ មិត្តិ ភិជ្ជិត្ថ សស្សតាយន្តិ ។**

*ការរាប់អានទាំងឡាយ របស់ជនពាល រមែងទៅជាទោស*
*ព្រោះតែមិនទទួលនូវវត្ថុ តាមមានតាមបាន ព្រោះហេតុ-*
*នោះបានជាយើងខ្ញុំ នាំយកសម្ដីស្រូវកន្ទះមានៈ (៤ នាឡិ)*
*មក កុំឲ្យការមេត្រីរាប់អានរបស់យើង បែកបាក់ទៅឡើយ*
*សូមឲ្យការមេត្រីរាប់អាននេះនៅទៀងទាត់ ។*

*បណ្ដាបទទាំងនោះ បទថា* **អសម្បទានេន** *សេចក្ដីថា ព្រោះតែ មិនព្រមទទួលនូវវត្ថុ ចូលសន្និគ្នាដោយលុបស្រៈ បានសេចក្ដីថា ព្រោះមិន កាន់យកវត្ថុ ។ បទថា* **ឥតរីតរស្ស** *បានដល់ វត្ថុណាមួយ តាមមាន តាមបាន សូម្បីល្អឬមិនល្អក៏ដោយ ។*

*បទថា* **ពាលស្ស មិត្តានិ កលី ភវន្តិ** *សេចក្ដីថា មេត្រីភាព*

របស់ជនពាល ឥតបញ្ញារមែងជាទោស គឺដូចកាឡកណ្ណិ អធិប្បាយថា រមែងបែកបាក់បាន ។

ដោយបទថា **តស្មា ហរាមិ កុស្សមឌ្ឍមានំ** នេះ ព្រះបរម-ពោធិសត្វសម្ដែងថា ព្រោះហេតុនោះ ទើបបងកាន់យក គឺព្រមទទួលសម្ដីស្រូវកន្ទះមានៈ ( ៤ នាឡិ ) ដែលសម្លាញ់របស់បងឲ្យ អធិប្បាយមួយមានៈ ស្មើនឹង ៨ នាឡិ កន្ទះមានៈ ស្មើនឹង ៤ នាឡិ ហើយ ៤ នាឡិ ឈ្មោះថា មួយតុម្ពៈ ព្រោះហេតុនោះ ទើបលោកពោលថា **បលាបតុម្ពំ** ។

បទថា **មា មេ មិត្តិ ភិជ្ជិត្ថ សស្សតាយំ** សេចក្ដីថា មេត្រី-ភាពរបស់យើងនិងសម្លាញ់ កុំបែកបាក់ទៅឡើយ សូមឲ្យមេត្រីភាពនៅទៀងទាត់ទៅចុះ ។

កាលសង្ខសេដ្ឋីពោលយ៉ាងនេះ ភរិយានៅតែស្រែកយំដដែល ពេលនោះ ទាសកម្មករដែលសង្ខសេដ្ឋីប្រគល់ឲ្យបិលិយសេដ្ឋីនោះដើរកាត់សាលា បានឮសំឡេងយំរបស់ភរិយាសេដ្ឋីក៏ចូលទៅកាន់សាលាឃើញចៅហ្វាយចាស់របស់ខ្លួនក៏ក្រាបចុះទៀបជើង យំបណ្ដើរ សួរបណ្ដើរថា បពិត្រលោកម្ចាស់ លោកមកទីនេះធ្វើអ្វី ? សេដ្ឋីក៏តំណាលរឿងរ៉ាវទាំង-អស់ឲ្យស្ដាប់ ។ ទាសៈនោះក៏លួងលោមអ្នកទាំងពីរនោះថា បពិត្រលោក-ម្ចាស់ លោកទាំងពីរកុំព្រួយ កុំគិតច្រើន ហើយនាំទៅផ្ទះរបស់ខ្លួន ឲ្យងូតទឹកក្រអូប ឲ្យបរិភោគអាហារ ហៅទាសៈទាំងឡាយមកប្រជុំគ្នា បង្ហាញឲ្យ

ដឹងថាចៅហ្វាយនាយរបស់ពួកអ្នកមកពីរ-បីថ្ងៃហើយ នាំទាសៈទាំងអស់ទៅកាន់លានព្រះរាជវាំង ហើយស្រែកបង្ហូកប្រកាសឡើង ។ ព្រះរាជាបញ្ជាឲ្យហៅមកហើយត្រាស់សួរថា នែអ្នកដ៏ចម្រើនទាំងឡាយ តើមានរឿងអ្វី ? ទាសៈទាំងនោះក្រាបទូលរឿងទាំងអស់ឲ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវពាក្យរបស់ទាសៈទាំងនោះហើយ បញ្ជាឲ្យហៅសេដ្ឋីទាំងពីរចូលគាល់ ហើយត្រាស់សួរសង្ខសេដ្ឋីថា នែមហាសេដ្ឋី បានឮថាលោកឲ្យទ្រព្យ ៤០ កោដិ ដល់បិលិយសេដ្ឋី ពិតមែនឬ ?

ព្រះមហាសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព មិនមែនតែទ្រព្យម្យ៉ាងប៉ុណ្ណោះទេ ដែលទូលបង្គំឲ្យដល់សម្លាញ់ដែលនឹកដល់ទូលបង្គំហើយបែរមុខទៅកាន់នគររាជគ្រឹះ ទូលបង្គំបានចែកសវិញ្ញាណកទ្រព្យនិងអវិញ្ញាណកទ្រព្យដែលជាសម្បត្តិគ្រប់យ៉ាង ចេញជាពីរចំណែក ហើយចែកស្មើៗ គ្នា ។

ព្រះរាជាត្រាស់សួរបិលិយសេដ្ឋីថា នែសេដ្ឋី រឿងនោះពិតមែនឬ ?

បិលិយសេដ្ឋីក្រាបទូលថា បពិត្រព្រះសម្មតិទេព រឿងនោះពិតមែន ។

ព្រះរាជាត្រាស់សួរតទៅទៀតថា កាលសង្ខសេដ្ឋីនឹកដល់អ្នក មកដល់ទីនេះហើយ អ្នកបានតបស្នងដោយវត្ថុអ្វីខ្លះ ? បិលិយសេដ្ឋីនៅស្ងៀម ។ ព្រះរាជាត្រាស់សួរតទៅទៀតថា ម្យ៉ាងទៀត អ្នកបានឲ្យទាសៈវាល់សម្លីស្រូវ ៤ នាឡិវេចនឹងជាយសំពត់ឲ្យគេ ហើយដេញគេឲ្យទៅ

*ពិតមែនឬ? បិលិយសេដ្ឋី សូម្បីបានស្ដាប់ព្រះតម្រាស់នោះហើយក៏ដោយ ក៏អង្គុយនៅស្ងៀមដដែល ព្រះរាជាទ្រង់ប្រឹក្សានឹងពួកអាមាត្យថា គួរធ្វើដូចម្ដេច? ទ្រង់បរិភាសបិលិយសេដ្ឋីហើយត្រាស់ថា អ្នកទាំងឡាយទៅយកទ្រព្យក្នុងផ្ទះបិលិយសេដ្ឋីឲ្យដល់សង្ខសេដ្ឋីចុះ ។*

*ព្រះបរមពោធិសត្វក្រាបទូលថា បពិត្រមហារាជ ទូលបង្គំមិនត្រូវការទ្រព្យរបស់អ្នកដទៃទេ សូមទ្រង់ព្រះករុណាព្រះរាជទានចំណែកដែលទូលបង្គំឲ្យគេប៉ុណ្ណោះចុះ ។ ព្រះរាជាបញ្ជាឲ្យព្រះរាជទានសម្បត្តិដែលជាចំណែករបស់ព្រះពោធិសត្វ ។ ព្រះមហាសត្វបានសម្បត្តិដែលខ្លួនឲ្យដល់បិលិយសេដ្ឋីទាំងអស់មកហើយ ចោមរោមដោយទាសៈត្រឡប់ទៅកាន់នគររាជគ្រឹះវិញ តម្កល់ជាដើមទុនបានហើយ ធ្វើបុណ្យទាំងឡាយមានឲ្យទានជាដើម ក្រោយអំពីចុតិក៏បានទៅតាមយថាកម្ម ។*

*ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា បិលិយសេដ្ឋីក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ចំណែកសង្ខសេដ្ឋី គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា អសម្បទានជាតក ទី ១ ។

# អដ្ឋកថា បញ្ចភិរុកជាតក ទី ២

*ព្រះបរមសាស្តា កាលទ្រង់គង់នៅវត្តក្នុងជេតពន ទ្រង់ប្រារព្ធព្រះសូត្រដែលពោលដោយការលួងលោមរបស់មារធីតា នៅក្នុងអជបាលនិគ្រោធ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **កុសលូបទេសេ ធិតិយា ទឡ្ហាយ ច** *ដូច្នេះជាដើម ។*

*សេចក្តីពិស្តារថា ក្នុងកាលដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ព្រះសូត្រនោះ តាំងពីដើមរហូតដល់ចប់បរិបូណ៌យ៉ាងនេះថា*

*នាងតណ្ហា អរតី និងនាងរាគា សុទ្ធតែស្រស់ព្រាយ*
*នាំគ្នាមក ព្រះសាស្តាទ្រង់កម្ចាត់នាងទាំងនោះទៅ ដូច*
*ខ្យល់បក់បំបើុងសំឡី ឲ្យធ្លាក់រប៉ាយទៅដូច្នោះ ។*

*ពួកភិក្ខុប្រជុំគ្នាក្នុងធម្មសភាយករឿងមកសន្ទនាថា អ្នកមានអាយុទាំងឡាយ ព្រះសម្មាសម្ពុទ្ធ ទ្រង់មិនបានបើកព្រះនេត្រទតពួកមារធីតាដែលក្លែងរូបទិព្វច្រើនរយប្រភេទ ហើយចូលទៅរកដើម្បីប្រលោមលួងលោម ឱ ដែលឈ្មោះថាកម្លាំងរបស់ព្រះសម្ពុទ្ធ គួរអស្ចារ្យហ្ន៎ ។ ព្រះបរមសាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការមិនសម្លឹងមើលពួកមារធីតារបស់តថាគតដែលធ្វើឲ្យអាសវៈ*

*អស់ទៅហើយ បានសម្រេចភាពជាព្រះសព្វញ្ញុតញ្ញាណនៅពេលនេះ មិនគួរឲ្យអស្ចារ្យឡើយ ពិតណាស់ក្នុងកាលមុន តថាគតកំពុងស្វែងរកពោធិញ្ញាណ មិនបានទម្លាយឥន្ទ្រីយ៍ទាំងឡាយសម្លឹងមើលរូប សូម្បីជាទិព្វដែលពួកយក្ខិនីនិម្មិតដោយអំណាចកិលេស ទាំងដែលតថាគតនៅមានកិលេស ធ្វើដំណើរទៅរហូតបានសម្រេចភាពជាមហារាជបាន ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាព្រះរាជបុត្រពៅនៃព្រះរាជបុត្រ ១០០ អង្គ រឿងរ៉ាវទាំងអស់បណ្ឌិតគប្បីឲ្យពិស្តារដោយន័យដូចពោលហើយនៅក្នុង* **តក្កសិលាជាតក** (១) *នោះឯង (ប្លែក) តែថា ក្នុងកាលនោះ កាលអ្នកក្រុងតក្កសិលាចូលទៅអញ្ជើញព្រះបរម-ពោធិសត្វនៅក្នុងសាលាខាងក្រៅនគរ ប្រគល់រាជសម្បត្តិធ្វើការអភិសេកអ្នកនគរតក្កសិលានាំគ្នាតាក់តែងនគរដូចទេវនគរ តាក់តែងព្រះរាជនិវេសន៍ដូចវិមានរបស់ព្រះឥន្ទ ។ កាលព្រះបរមពោធិសត្វយាងចូលនគរហើយស្តេចឡើងកាន់បល្ល័ង្ករតន៍ខាងក្រោមស្វេតច្ឆត្រក្នុងលានព្រះរាជវាំង ក្នុង*

---

*១- តេលបត្តជាតក ។*

ប្រាសាទដែលជាព្រះរាជដ្ឋាន ទ្រង់គង់ដោយលីលាដូចសក្កទេវរាជ ពួកអាមាត្យ ព្រាហ្មណ៍ គហបតី និង ខត្តិយកុមារម្នាក់ៗ តាក់តែងខ្លួន ទ្រង់គ្រឿងព្រម ហែហមណែនណាន់តាន់តាប់ ស្ត្រីរបាំប្រមាណ ១៦.០០០ នាក់ សុទ្ធតែមានរាងស្តើងតូច ប្រៀបដូចទេពអប្សរ ម្នាក់ៗស្ទាត់ជំនាញក្នុងការរាំ ការច្រៀង និងការលេងភ្លេង ព្រះរាជវាំងក៏គគ្រឹកគគ្រេងដោយសំឡេងច្រៀងនិងសំឡេងតូរ្យតន្ត្រីដែលប្រគំឡើង ប្រៀបដូចមហាសមុទ្រដែលកំពុងសម្តែងអាការរីករាយនឹងរលកខាងមុខ ដែលភ្លៀងបានបង្អុរចុះមក ។ ព្រះបរមពោធិសត្វ ទ្រង់ទតសិរីដ៏ស្រស់ត្រកាលដែលសម្រេចដល់ព្រះអង្គនោះ ទ្រង់ព្រះតម្រិះថា ប្រសិនបើអញបានខ្វល់ខ្វាយសម្លឹងមើលរូបទិព្វដែលពួកយក្ខិនីនិម្មិតនោះ គង់នឹងអស់ជីវិតមិនខាន ហើយអញក៏មិនបានសម្លឹងមើលសិរីដ៏ស្រស់ត្រកាលនេះ ប៉ុន្តែព្រោះអញតាំងនៅក្នុងឱវាទរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ សិរីដ៏ស្រស់ត្រកាលនេះទើបសម្រេចដល់អាត្មាអញ លុះទ្រង់ព្រះតម្រិះដូច្នេះហើយ កាលទ្រង់បន្លឺព្រះឧទាន បានត្រាស់គាថានេះថា

កុសលូបទេសេ ធិតិយា ទឡ្ហាយ ច
អនិវត្តិតត្តា ភយភីរុតាយ ច
ន រក្ខសីនំ វសមាគមិម្ហ
ស សោត្ថិភាវោ មហតា ភយេន មេតំ ។

យើងមិនបានលុះក្នុងអំណាចនៃពួកយក្ខិនីឡើយ ព្រោះមានសេចក្ដីព្យាយាមដ៏មាំ ក្នុងឧបាយគ្រឿងណែនាំរបស់ព្រះបច្ចេកពុទ្ធ ជាអ្នកឈ្លាសផង ព្រោះភាពជាអ្នកគ្របសង្កត់សេចក្ដីខ្លាច និងសេចក្ដីតក់ស្លុតផង សុវត្ថិភាពចាកភ័យដ៏ធំនោះមានដល់ខ្ញុំ ។

បណ្ដាបទទាំងនោះ បទថា **កុសលូបទេសេ** សេចក្ដីថា ក្នុងពាក្យណែនាំរបស់អ្នកឈ្លាសទាំងឡាយ អធិប្បាយថា ក្នុងឱវាទរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ។

បទថា **ធិតិយា ទឡ្ហាយ ច** សេចក្ដីថា ព្រោះសេចក្ដីព្យាយាមដ៏តឹងរ៉ឹងមាំទាំ ។

បទថា **អវត្ថិតត្តា ភយភីរុតាយ ច** សេចក្ដីថា និងព្រោះភាពជាអ្នកមិនញាប់ញ័រក្នុងភ័យដ៏ធំដែលធ្វើឲ្យកាយញាប់ញ័រតក់ស្លុត បណ្ដាភ័យទាំងពីរនោះ ភ័យបន្តិចបន្តួចដែលធ្វើឲ្យចិត្តតក់ស្លុត ឈ្មោះថា “ខ្លាច” ភ័យដ៏ធំដែលធ្វើឲ្យរាងកាយញាប់ញ័រ ឈ្មោះថា “ តក់ស្លុត ” ភ័យទាំងពីរប្រការនេះក្ដី អារម្មណ៍ដែលគួរឲ្យស្លុតរន្ធត់ថា យក្ខិនីទាំងនេះវាស៊ីមនុស្សទាំងនោះដូច្នេះក្ដី មិនមានដល់ព្រះមហាសត្វឡើយ ព្រោះហេតុនោះ ទើបលោកពោលថា **អវត្ថិតត្តា ភយភីរុតាយ ច** ព្រោះភាពជា

*អ្នកគ្រប់សង្កត់ការភ័យខ្លាចនិងសេចក្តីតក់ស្លុតផង អធិប្បាយថា ព្រោះមិនមានការញាប់ញ័រ ភ័យខ្លាច តក់ស្លុត គឺសូម្បីឃើញ ឬជួបប្រសព្វនឹងអារម្មណ៍ដែលគួរឲ្យតក់ស្លុត ភ័យខ្លាច ក៏មិនព្រមរាថយ ។*

*បទថា* **ន រក្ខសីនំ វសមាគមិម្ហសេ** *សេចក្តីថា មិនត្រូវលុះក្នុងអំណាចនៃពួកយក្ខិនីទាំងនោះ ក្នុងអមនុស្សកន្តារៈ លោកអធិប្បាយថា ព្រោះហេតុតែអញមានការបួរផ្តាច់ចំពោះឧបាយគ្រឿងណែនាំរបស់អ្នកឈ្លាសវៃ ហើយអញមានការមិនរួញរាជាសភាព ព្រោះមិនមានការភ័យខ្លាចនិងការតក់ស្លុត ព្រោះហេតុនោះ ទើបអញមិនមកកាន់អំណាចនៃពួកយក្ខិនី ដូច្នេះសុវត្ថិភាពគឺការក្សេមចាកភ័យដ៏ធំ គឺចាកទុក្ខទោមនស្សដែលអញត្រូវជួបប្រសព្វក្នុងសម្នាក់នៃពួកយក្ខិនីរបស់អញនោះ គឺមានតែបីតិសោមនស្សតែម្យ៉ាងកើតដល់អាត្មាអញក្នុងថ្ងៃនេះ ។*

*ព្រះបរមពោធិសត្វទ្រង់សម្តែងធម៌ដោយគាថានេះ ដោយប្រការដូច្នេះ ទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ ទ្រង់បំពេញបុណ្យមានឲ្យទានជាដើម ក្រោយអំពីសោយទិវង្គតក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា* **តថាគត** *កាលនោះជាព្រះរាជកុមារដែលគ្រប់គ្រងរាជ-សម្បត្តិនៅក្នុងនគរតក្កសិលា ៕*

ចប់ អដ្ឋកថា បញ្ចភិរុកជាតក ទី ២ ។

# អដ្ឋកថា ឃតាសនជាតក ទី ៣

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ខេមំ យហឹ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ភិក្ខុនោះ រៀនកម្មដ្ឋានអំពីសម្នាក់ព្រះបរមសាស្តា ហើយទៅកាន់ស្រុកជាយដែនមួយ នៅក្នុងភូមិមួយចាំវស្សាក្នុងសេនាសនៈព្រៃ ។ ក្នុងខែដំបូងនោះ កាលលោកចូលទៅបិណ្ឌបាត បណ្ណសាលាត្រូវភ្លើងឆេះ លោកត្រូវលំបាកដោយមិនមានទីលំនៅ ទើបប្រាប់ពួកឧបដ្ឋាកមនុស្សទាំងនោះពោលថា មិនជាអ្វីទេលោកម្ចាស់ ពួកខ្ញុំនឹងសាងបណ្ណ-សាលាប្រគេន រង់ចាំឲ្យពួកខ្ញុំភ្ជួរ ព្រោះ ហើយសិន ។ រហូតពេលវេលា ៣ ខែបានកន្លងទៅ លោកមិនអាចបំពេញកម្មដ្ឋានឲ្យដល់ទីបំផុតបាន ព្រោះមិនមានសេនាសនៈជាទីសប្បាយ សូម្បីត្រឹមតែនិមិត្តក៏ឲ្យកើតឡើងមិនបាន ។ លុះចេញវស្សាលោកក៏ទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះបរម-សាស្តាហើយគង់ក្នុងទីដ៏សមគួរ ។ ព្រះបរមសាស្តាទ្រង់ធ្វើបដិសណ្ឋារៈនឹងលោកហើយទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ កម្មដ្ឋានរបស់អ្នកជាទីសប្បាយឬទេ ? លោកក៏ក្រាបទូលការមិនសប្បាយតាំងអំពីដើមដល់ចប់ ។ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុនសូម្បីសត្វតិរច្ឆានទាំងឡាយក៏គង់ដឹងសប្បាយឬអសប្បាយរបស់ខ្លួន នាំគ្នារស់នៅក្នុងវេលា

សប្បាយ ក្នុងវេលាមិនសប្បាយក៏នាំគ្នាបោះបង់ចោលទីនោះទៅកាន់ទីដទៃ ហេតុអ្វីទើបអ្នកមិនដឹងសប្បាយ ឬអសប្បាយរបស់ខ្លួន ? កាលភិក្ខុនោះក្រាបទូលអារាធនា ទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វកើតជាបក្សី ធំឡើងដល់នូវភាពដ៏ល្អលើស បានជាស្តេចបក្សីនៅនឹងដើមឈើមួយដើមធំ សម្បូរដោយមែកសាខានិងប្រគាបមានស្លឹកក្រាស់ នៅជិតស្រះដែលកើតឯង មួយអន្ទើដោយបរិវារ ។ បក្សីជាច្រើន កាលនៅលើមែកដែលបែកទៅលើទឹក ក៏ជុះអាចម៍ដាក់ទឹក ។ ក្នុងជាតិស្រះនោះ មាននាគរាជដ៏កាចសាហាវរស់នៅ នាគ-រាជនោះគិតថា បក្សីទាំងនេះ ជុះអាចម៍ដាក់ជាតិស្រះដែលកើតឯង ដែលជាលំនៅរបស់អញ អញត្រូវធ្វើឲ្យភ្លើងឆេះឡើងអំពីទឹកដុតដើមឈើ ឲ្យពួកវាចៀសចេញទៅ ។ ស្តេចនាគនោះមានចិត្តក្រោធ កណ្តាលអធ្រាត្រពេលដែលពួកបក្សីមកជួបជុំគ្នាដេកនៅលើមែកឈើទាំងឡាយ ក៏ផ្តើមធ្វើឲ្យទឹកក្តៅខ្លាំង ដូចលើកយកស្រះឡើងដាក់លើជើងក្រានដូច្នោះ នេះលើកដំបូង លើកទីពីរក៏ធ្វើឲ្យផ្សែងហុយឡើង លើកទីបីធ្វើឲ្យមានអណ្តាតភ្លើងឆេះឡើងកំពស់មួយដើមត្នោត ។ ព្រះពោធិសត្វឃើញអណ្តាតភ្លើងឆេះអំពីទឹកក៏ពោលថា នៃបក្សីទាំងឡាយ ធម្មតាភ្លើងឆេះឡើងគេក៏នាំគ្នាយក

ទឹកពន្ធត់ ប៉ុន្តែពេលនេះ ទឹកនោះឯងត្រឡប់ឆេះជាភ្លើងឡើង ពួកយើងមិនអាចនៅទីនេះបានទៀតទេ ត្រូវនាំគ្នាទៅកាន់ទីដទៃ ហើយពោលគាថានេះថា

**ខេមំ យហឹ តត្ថ អរី ឧទីរិតោ**

**ទកស្ស មជ្ឈេ ជលតេ ឃតាសនោ**

**ន អជ្ជ វាសោ មហិយា មហីរុហោ**

**ទិសា ភជវ្ហោ សរណាជ្ជ នោ ភយន្តិ ។**

*សេចក្តីក្សេមក្សាន្តមាននៅលើខ្នងទឹកណា លើខ្នងទឹកនោះមានសត្រូវកើតហើយ ព្រោះភ្លើងឆេះត្រង់ពាក់កណ្តាលនៃទឹក ទីអាស្រ័យនៅ (នៃពួកយើង) លើដើមឈើ (ដែលដុះ) លើផែនដីធំ ក្នុងថ្ងៃនេះគ្មានទេ អ្នកទាំងឡាយ ចូរទៅកាន់ទិសឯទៀតទៅ ថ្ងៃនេះភ័យកើតឡើងដល់យើងទាំងឡាយ អំពីឈើជាទីពឹងហើយ ។*

បណ្តាបទទាំងនោះ បទថា **ខេមំ យហឹ តត្ថ អរី ឧទីរិតោ** សេចក្តីថា សេចក្តីក្សេមក្សាន្ត គឺការមិនមានភ័យ មាននៅលើទឹកណា លើទឹកនោះ មានសត្រូវកើតឡើងចំពោះមុខហើយ ។

បទថា **ទកស្ស** ស្មើនឹង **ឧទកស្ស** ប្រែថា នៃទឹក ។

ភ្លើងឈ្មោះថា **ឃតាសន** អធិប្បាយថា ភ្លើងនោះរមែងស៊ីសូម្បី

តក្កៈ គឺទឹកដោះជូរ ព្រោះហេតុនោះ ទើបលោកហៅថា **យតាសន** ។

បទថា **ន អជ្ជ ភាសោ** សេចក្ដីថា ថ្ងៃនេះ លំនៅរបស់ពួកយើងគ្មានទេ ។

ក្នុងបទថា **មហិយា មហីរុហោ** នេះ ដើមឈើលោកហៅថា **មហីរុក្ខោ** លើដើមឈើនោះ អធិប្បាយថា បានដល់ដើមឈើដែលដុះនៅលើផែនដីនេះ ។

បទថា **ទិសា ភជថ្ហ** សេចក្ដីថា អ្នកទាំងឡាយចូរគប់ គឺនាំគ្នាហើរទៅកាន់ទិសផ្សេងៗ ។

បទថា **សរណាជ្ជ នោ ភយំ** សេចក្ដីថា ថ្ងៃនេះ ភ័យកើតអំពីឈើជាទីពឹង គឺទីពំនាក់អាស្រ័យរបស់ពួកយើងកើតភ័យឡើងហើយ ។

ព្រះមហាសត្វ លុះពោលយ៉ាងនេះហើយក៏នាំហ្វូងបក្សីដែលជឿស្ដាប់ពាក្យហើរទៅកាន់ទីដទៃ បក្សីដែលមិនជឿ មិនស្ដាប់ពាក្យរបស់ព្រះ-មហាសត្វ ទំនៅទីនោះ ក៏អស់ជីវិតទៅ ។

ព្រះបរមសាស្ដា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈ លុះចប់សច្ចៈ ភិក្ខុនោះបានសម្រេចជាព្រះអរហន្ត ហើយទ្រង់ប្រជុំជាតកថា ហ្វូងបក្សីដែលធ្វើតាមពាក្យរបស់ស្ដេចបក្សីក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទ ចំណែកស្ដេចបក្សី គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា យតាសនជាតក ទី ៣ ។

# អដ្ឋកថា ឈានសោធនជាតក ទី ៤

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការដែលព្រះធម្មសេនាបតីព្យាករបញ្ហា ដែលទ្រង់ត្រាស់សួរដោយសង្ខេបបានយ៉ាងពិស្ដារនៅទីងខ្លោងទ្វារសង្កស្សនគរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **យេ សញ្ញិនោ** ដូច្នេះជាដើម ។

តទៅនេះ ជារឿងអតីត ក្នុងការព្យាករណ៍បញ្ហានោះ។

បានឮថា ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វកំពុងធ្វើមរណកាលនៅឯជាយព្រៃ ត្រូវពួកអន្តេវាសិកសួរ ក៏ពោលថា **នេវសញ្ញីនាសញ្ញី** មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។ ល ។ (ដូចរឿង **បរោសហស្សជាតក** ) ពួកតាបសមិនព្រមជឿពាក្យរបស់អន្តេវាសិកដែលជាប្រធាន ព្រះបរមពោធិសត្វក៏មកអំពីព្រហ្មលោកជាន់អាភស្សរៈ ឈរនៅក្នុងអាកាសពោលគាថានេះថា

**យេ សញ្ញិនោ តេបិ ទុគ្គតា**
**យេបិ អសញ្ញិនោ តេបិ ទុគ្គតា**
**ឯតំ ឧភយំ វិវជ្ជយ**
**តំ សមាបត្តិ សុខំ អនង្គណាន្តិ ។**

ពួកសត្វណា មានសញ្ញា ពួកសត្វនោះ ក៏ទុគ៌ត

( មិនបានសមាបត្តិ ) ពួកសត្វណា មិនមានសញ្ញា
ពួកសត្វនោះក៏ទុគ៌ត អ្នកចូរវៀរនូវសត្វទាំងពីរ
ពួកនោះចេញ សុខដែលកើតអំពីសមាបត្តិនោះ
ឈ្មោះថា មិនមានទីទួល គឺកិលេសឡើយ ។

បណ្ដាបទទាំងនោះ ដោយបទថា **យេ សញ្ញិនោ** នេះ លោកសម្ដែងដល់សត្វដែលមានចិត្តដ៏សេស វៀរលោកអ្នកដែលបាននេវសញ្ញា-នាសញ្ញាយតនឈាន ។

បទថា **តេបិ ទុគ្គតា** សេចក្ដីថា ព្រោះមិនបានសមាបត្តិនោះ សូម្បីពួកសត្វនោះ ក៏នៅមានឈ្មោះថា ទុគ្គតៈ ។

ដោយបទថា **យេបិ អសញ្ញិនោ** នេះ លោកសម្ដែងដល់អចិត្តក-សត្វដែលកើតក្នុងអសញ្ញីភព ។

បទថា **តេបិ ទុគ្គតា** សេចក្ដីថា សូម្បីសត្វទាំងនោះ ក៏ទុគ្គតដែរ ព្រោះមិនទាន់បានសមាបត្តិ ។

បទថា **ឯតំ ឧភយំ វិវជ្ជយ** សេចក្ដីថា ព្រះបរមពោធិសត្វឲ្យឱវាទដល់អន្តេវាសិកតទៅថា អ្នកទាំងឡាយចូរវៀរ ចូរលះបង់នូវពួកសត្វទាំងពីរពួកនោះគឺ សញ្ញីភាវៈនិងអសញ្ញីភាវៈ ។

បទថា **តំ សមាបត្តិ សុខំ អនង្គណំ** សេចក្ដីថា សេចក្ដីសុខក្នុងឈាននោះ គឺដែលដល់ការរាប់ថាជាសុខ ព្រោះជាធម្មជាតិស្ងប់របស់

*លោកអ្នកបាននេវសញ្ញានាសញ្ញាយតនសមាបត្តិ ជាអនង្គណៈ គឺ ប្រាស-ចាកទោស ព្រោះភាវៈនៃចិត្តមានឯកគ្គតា មានកម្លាំងជាលក្ខណៈ សេចក្តីសុខនោះ ក៏ឈ្មោះថាជាវត្ថុមិនមានទីទួលគឺកិលេស ។*

*ព្រះបរមពោធិសត្វសម្តែងធម៌សរសើរគុណរបស់អន្តេវាសិក ដោយប្រការដូច្នេះហើយ ក៏បានត្រឡប់ទៅកាន់ព្រហ្មលោកវិញ ។ គ្រានោះតាបសដ៏សេសនាំគ្នាជឿអន្តេវាសិកដែលជាប្រធាន ។*

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ត្រាស់ប្រជុំជាតកថា អន្តេវាសិកដែលជាប្រធានក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកមហាព្រហ្ម គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា ឈានសោធនជាតក ទី ៤ ។

# អដ្ឋកថា ចន្ទាភជាតក ទី ៥

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការព្យាករណ៍បញ្ហារបស់ព្រះថេរៈ ដែលនៅក្បែរខ្លោងទ្វារនគរសង្កស្សៈនោះ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **ចន្ទាភំ** *ដូច្នេះជាដើម ។*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វកំពុងធ្វើមរណកាលនៅក្នុងដាយព្រៃ ត្រូវពួកអន្តេវាសិកសាកសួរ ក៏ពោលថា* **ចន្ទាភំ សុរិយាភំ** *បុគ្គលណា*

បានកសិណមានពន្លឺដូចព្រះចន្ទ មានពន្លឺដូចព្រះអាទិត្យ ដូច្នេះហើយ (ក៏ធ្វើមរណកាល) ទៅកើតក្នុងព្រហ្មលោកជាន់អាភស្សរៈ ។ ពួកតាបសមិនជឿអន្តេវាសិកដែលជាប្រធាន ព្រះបរមពោធិសត្វមកឋិតនៅលើអាកាសពោលគាថានេះថា

**ចន្ទាភំ សុរិយាភញ្ច យោធ បញ្ញាយ គាធតិ**
**អវិតក្កេន ឈានេន ហោតិ អាភស្សរូបគោតិ។**

បុគ្គលណា ក្នុងលោកនេះ បាននូវកសិណ មានពន្លឺ
ដូចព្រះចន្ទ (ឱទាតកសិណ) មានពន្លឺដូចព្រះអាទិត្យ
(បីតកសិណ) ដោយបញ្ញា បុគ្គលនោះ រមែងទៅកើត
ក្នុងអាភស្សរព្រហ្មលោក ដោយឈានមិនមានវិតក្កៈ
(ទុតិយជ្ឈាន) ។

បណ្តាបទទាំងនោះ ព្រះបរមពោធិសត្វសម្តែង **ឱទាតកសិណ** ដោយបទថា **ចន្ទាភំ** សម្តែង **បីតកសិណ** ដោយបទថា **សុរិយាភំ**។

បទថា **យោធ បញ្ញាយ គាធតិ** សេចក្តីថា បុគ្គលណាក្នុងសត្វលោកនេះ ចុះស៊ប់បានដោយបញ្ញានូវកសិណទាំងពីរយ៉ាងនេះ គឺធ្វើឲ្យជាអារម្មណ៍ បញ្ជូនចិត្តទៅ ឬតាំងចិត្តទុកបានក្នុងកសិណទាំងពីរយ៉ាងនោះ បរិយាយមួយទៀត បទថា **ចន្ទាភំ សុរិយាភញ្ច យោធ បញ្ញាយ គាធតិ** សេចក្តីថា ពន្លឺព្រះចន្ទនិងពន្លឺព្រះអាទិត្យផ្សាយទៅកាន់ទីមាន

ប្រមាណប៉ុណ្ណា ចម្រើនបដិភាគកសិណក្នុងទីមានប្រមាណប៉ុណ្ណោះ ធ្វើបដិភាគកសិណនោះឲ្យជាអារម្មណ៍ ញុំាងឈានឲ្យកើតឡើងក៏មានឈ្មោះថា ឈមចុះកាន់ពន្ទីទាំងពីរនោះបានដោយបញ្ញា ព្រោះហេតុនោះ ចំណុចនេះក៏ជាការអធិប្បាយក្នុងបទនោះបានដែរ បុគ្គលនោះ រមែងទៅកើតក្នុងអាភស្សរព្រហ្មលោកបានដោយឈានទីពីរ ដែលខ្លួនបានហើយព្រោះធ្វើយ៉ាងនោះ ។

ព្រះពោធិសត្វឲ្យពួកតាបសដឹងច្បាស់ដោយប្រការដូច្នេះហើយ ពោលសរសើរគុណអន្តេវាសិកដែលជាប្រធាន ហើយក៏ត្រឡប់ទៅកាន់ព្រហ្មលោកភ្លាម ។

ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា អន្តេវាសិកដែលជាធំក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកមហាព្រហ្ម គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ចន្ទាភជាតក ទី ៥ ។

# អដ្ឋកថា សុវណ្ណហំសជាតក ទី ៦

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុនីឈ្មោះ ថុល្លនន្ទា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **យំ លទ្ធំ តេន តុដ្ឋព្វំ** *ដូច្នេះជាដើម ។*

*សេចក្តីពិស្តារថា ឧបាសកម្នាក់នៅក្នុងនគរសាវត្ថី បវារណាខ្ទឹមចំពោះភិក្ខុនីសង្ឃហើយផ្តាំអ្នកចាំចម្ការថា ប្រសិនបើអ្នកនាងម្ចាស់ទាំង-ឡាយមកយកខ្ទឹម ចូរប្រគេនមួយអង្គ ពីរ-បីកញ្ចប់ចុះ ។ ចាប់ពីពេលនោះមក ភិក្ខុនីទាំងឡាយត្រូវការខ្ទឹម ក៏នាំគ្នាទៅកាន់ផ្ទះឧបាសកនោះខ្លះទៅកាន់ចម្ការខ្លះ លុះដល់ថ្ងៃមហោស្រពមួយ ខ្ទឹមក្នុងផ្ទះរបស់ឧបាសកនោះអស់ ។ ភិក្ខុនីឈ្មោះ ថុល្លនន្ទា មួយអន្លើដោយបរិវារទៅកាន់ផ្ទះឧបាសកនោះហើយពោលថា នែអ្នកមានអាយុ អាត្មាត្រូវការខ្ទឹម ។ អ្នកបម្រើពោលថា បពិត្រអ្នកនាងម្ចាស់ ខ្ទឹមនៅផ្ទះមិនមានទេ អស់ហើយ និមន្តទៅចម្ការចុះ ទើបនាំគ្នាទៅចម្ការ ជញ្ជូនខ្ទឹមទៅដោយមិនស្គាល់ប្រមាណ ។ អ្នកចាំចម្ការពោលទោសថា ព្រោះហេតុអ្វីទើបភិក្ខុនីទាំងឡាយ នាំគ្នាជញ្ជូនខ្ទឹមយកទៅដោយមិនស្គាល់ប្រមាណយ៉ាងនេះ ពួកភិក្ខុនីដែលមានសេចក្តីប្រាថ្នាតិច បានស្តាប់ពាក្យរបស់អ្នកចាំចម្ការហើយពោលទោសភិក្ខុនីទាំងនោះ ។ ពួកភិក្ខុ លុះបានឮអំពីភិក្ខុនីទាំងនោះក៏នាំគ្នាពោលទោស ហើយក៏ក្រាបទូលរឿងនោះចំពោះព្រះដ៏មានព្រះភាគ ។*

ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលភិក្ខុនីឈ្មោះថុល្លនន្ទាហើយ ទ្រង់សម្ដែងធម៌ដ៏សមគួរដល់រឿងនោះ ដល់ភិក្ខុនីទាំងឡាយដោយន័យមានជាអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាបុគ្គលអ្នកមានសេចក្ដីប្រាថ្នាច្រើន មិនជាទីស្រឡាញ់ មិនជាទីត្រេកអរ មិនជាទីចម្រើនចិត្ត សូម្បីដល់មាតាបិតាបង្កើត មិនអាចនឹងញុំាងអ្នកដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាបាន មិនអាចញុំាងអ្នកដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាបានឡើងទេ មិនអាចញុំាងលាភដែលមិនទាន់កើត ឲ្យកើត ឬលាភដែលកើតហើយ ក៏មិនអាចធ្វើឲ្យឋិតថេរគង់វង្សបាន ចំណែកអ្នកដែលប្រាថ្នាតិច រមែងញុំាងលាភដែលមិនទាន់កើតឲ្យកើត លាភដែលកើតហើយក៏ធ្វើឲ្យឋិតថេរគង់វង្សបាន ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលភិក្ខុនីឈ្មោះថុល្លនន្ទាមានសេចក្ដីប្រាថ្នាច្រើននោះ សូម្បីក្នុងកាលមុនក៏ធ្លាប់មានសេចក្ដីប្រាថ្នាច្រើនដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ កាលចម្រើនវ័យហើយ មាតាបិតារៀបចំឲ្យមានភរិយាដែលមានជាតិត្រកូលស្មើគ្នា មានធីតាបីនាក់ ឈ្មោះនន្ទា នន្ទវតី សុនន្ទា កាលធីតាទាំងនោះមានស្វាមីគ្រប់គ្នាហើយ ព្រះពោធិសត្វក៏ធ្វើកាលកិរិយាទៅកើតជាសត្វហង្ស

មាស ហើយមានញាណរលឹកជាតិបានទៀតផង ហង្សមាសនោះធំឡើង ហើយ ឃើញអត្តភាពដែលពេញបរិបូណ៌ដោយរោមដែលជាមាស ក៏គិតថា អញចុតិមកអំពីទីណាហ្ន៎ ទើបមកកើតក្នុងទីនេះ ក៏ដឹងថា មកអំពីមនុស្សលោក ពិចារណាតទៅទៀតថា ព្រាហ្មណីនិងពួកធីតារបស់អញនៅមានជីវិតឬហ្ន៎ ? ក៏បានដឹងថា ទីទ័លក្រ ត្រូវស៊ីឈ្នួលគេចិញ្ចឹមជីវិតយ៉ាងលំបាក ទើបគិតថា រោមទាំងឡាយក្នុងសរីរៈរបស់អញជាមាសទាំងអស់ អញនឹងឲ្យរោមអំពីសរីរៈនេះដល់នាងទាំងនោះ ម្តងមួយៗ ដោយហេតុនោះ ភរិយានិងធីតាទាំងបីរបស់អញនឹងរស់នៅដោយមិនលំបាក គឺរស់នៅដោយសុខសប្បាយ ។ ស្តេចហង្សមាសក៏ហើរទៅកាន់ទីនោះ ទំលើត្បាល់ជាន់ ព្រាហ្មណីនិងធីតាឃើញព្រះមហាសត្វហើយក៏សួរថា បពិត្រអ្នកដ៏ចម្រើន តើអ្នកមកអំពីទីណា ?

ហង្សមាសពោធិសត្វឆ្លើយថា យើងជាបិតារបស់អ្នកទាំងឡាយស្លាប់ទៅកើតជាហង្សមាសមកដើម្បីជួបអ្នកទាំងឡាយ តាំងពីពេលនេះទៅអ្នកទាំងឡាយមិនបាច់ទៅស៊ីឈ្នួលអ្នកដទៃ ដើម្បីចិញ្ចឹមជីវិតដោយលំបាកទៀតទេ យើងនឹងឲ្យរោមដល់អ្នកទាំងឡាយ ម្តងមួយៗ ចូរយកទៅលក់ចិញ្ចឹមជីវិតតាមសប្បាយចុះ ជម្រុះរោមទុកឲ្យមួយ ហើយទើបហើរទៅ ។ ហង្សមាសនោះមកជាចន្លោះៗ រលាស់ជម្រុះរោមឲ្យម្តងមួយដោយទំនងនេះ ព្រាហ្មណីនិងកូនៗ បានធូរធារឡើងៗ ចិញ្ចឹមជីវិត

ដោយសុខស្រួល មានសេចក្ដីសុខសប្បាយគ្រប់គ្នា ។ ថ្ងៃមួយព្រាហ្មណី ប្រឹក្សាជាមួយកូនៗថា នែនាងទាំងឡាយ ធម្មតាសត្វតិរច្ឆានស្គាល់ចិត្ត បានដោយលំបាក ពេលខ្លះ បិតារបស់កូនមិនមកទីនេះ ពួកយើងនឹងធ្វើ ដូចម្ដេច ឥឡូវនេះ ពេលដែលបិតារបស់កូនឯងមក ពួកយើងនាំគ្នាចាប់ ដករោមឲ្យអស់ចុះ ។ ពួកកូនស្រីនាំគ្នានិយាយថា ធ្វើយ៉ាងនោះ បិតា របស់ពួកខ្ញុំនឹងលំបាក ម្នាក់ៗក៏មិនយល់ព្រម ប៉ុន្តែនាងព្រាហ្មណីព្រោះ តែមានសេចក្ដីប្រាថ្នាធំ ថ្ងៃមួយ ពេលដែលស្ដេចហង្សមាសមកក៏និយាយ ថា បពិត្រអ្នកជាម្ចាស់ មកនេះសិន លុះស្ដេចហង្សមាសចូលទៅជិតក៏ចាប់ ដោយដៃទាំងពីរ ដករោមអស់ ប៉ុន្តែព្រោះចាប់ដកយកដោយកម្លាំងឈ្មោក ព្រះពោធិសត្វមិនបានឲ្យដោយសុទ្ធចិត្ត រោមទាំងនោះទើបដូចជារោមកុក ទាំងអស់ ។ ព្រះមហាសត្វមិនអាចនឹងត្រដាងស្លាបហើរទៅបាន ព្រាហ្មណី ក៏ចាប់ហង្សមាសយកទៅដាក់ក្នុងពាងធំដើម្បីចិញ្ចឹមថែទាំ រោមដែលដុះ ឡើងថ្មីរបស់ហង្សមាសនោះ ក្លាយជាពណ៌សទាំងអស់ ។ ស្ដេចហង្សនោះ លុះរោមដុះឡើងគ្រប់គ្រាន់ហើយ ក៏លោតឡើងហើរទៅលំនៅរបស់ខ្លួន ភ្លាម ហើយក៏មិនបានមកទៀតឡើយ ។

ព្រះបរមសាស្ដា ទ្រង់នាំយករឿងក្នុងអតីតនេះមកសម្ដែងហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលថុល្លនន្ទាមានសេចក្ដីប្រាថ្នាច្រើន សូម្បីក្នុងកាលមុនក៏មានសេចក្ដី

ប្រាថ្នាច្រើនដែរ ហើយព្រោះតែមានការប្រាថ្នាច្រើន ទើបត្រូវវិនាសចាកមាស ពេលនេះ ព្រោះហេតុតែខ្លួនមានសេចក្ដីប្រាថ្នាច្រើននោះឯង នឹងត្រូវសាបសូន្យសូម្បីតែខ្ទឹម ព្រោះហេតុនោះ តាំងពីពេលនេះទៅនឹងមិនបានសូម្បីតែឆាន់ខ្ទឹម សូម្បីភិក្ខុនីដ៏សេសទាំងឡាយ ព្រោះអាស្រ័យថុល្លនន្ទានោះ ក៏នឹងមិនបានឆាន់ខ្ទឹមដូចថុល្លនន្ទាដែរ ហេតុនោះ សូម្បីនឹងបានច្រើនក៏ត្រូវស្គាល់ប្រមាណ ប៉ុន្តែបើបានតិចក៏គប្បីត្រេកអរពេញចិត្តតាមដែលបានប៉ុណ្ណោះ មិនគួរប្រាថ្នាឲ្យក្រៃលែងឡើងឡើយ ហើយទ្រង់ត្រាស់ព្រះគាថានេះថា

**យំ លទ្ធំ តេន តុដ្ឋព្វំ អតិលោភោ ហិ បាបកោ**

**ហំសរាជំ គហេត្វាន សុវណ្ណា បរិហាយតីតិ ។**

ទ្រព្យណា ដែលបុគ្គលបានមកហើយ បុគ្គលគប្បីត្រេកអរដោយទ្រព្យនោះ ព្រោះថាសេចក្ដីល្មោភហួសជារបស់លាមក (ដូចនាងព្រាហ្មណី) ក៏សាបសូន្យ ចាកមាស ព្រោះចាប់ស្ដេចហង្ស ។

បណ្ដាបទទាំងនោះ បទថា **តុដ្ឋព្វំ** ប្រែថា គប្បីត្រេកអរ ។

ព្រះបរមសាស្ដា លុះទ្រង់ត្រាស់ព្រះធម្មទេសនានេះហើយ ទ្រង់តិះដៀលដោយអនេកបរិយាយ ហើយទ្រង់បញ្ញត្តិសិក្ខាបទថា ភិក្ខុនីណាឆាន់ខ្ទឹមត្រូវអាបត្តិបាចិត្តិយៈ ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ព្រាហ្មណីក្នុងកាលនោះ បានមកជាថុល្លនន្ទាភិក្ខុនីក្នុងកាលឥឡូវនេះ ធីតាទាំងបី

*បានមកជាបងប្អូនស្រីរបស់ភិក្ខុនីថុល្លនន្ទា ចំណែកស្តេចហង្សមាស គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា សុវណ្ណហំសជាតក ទី ៦ ។

# អដ្ឋកថា ពព្វុជាតក ទី ៧

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសិក្ខាបទ ដែលទ្រង់បញ្ញត្តិ ដោយមានឧបាសិកាជាមាតារបស់នាងកាណាជាហេតុ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **យត្ថេកោ លភតេ ពព្វុ** *ដូច្នេះជាដើម ។*

*សេចក្តីពិស្តារថា ឧបាសិកាក្នុងនគរសាវត្ថី មាននាមតាមធីតាថា កាណាមាតា បានជាអរិយសាវិកា ជាសោតាបន្ន នាងបានលើកកូនក្រមុំឈ្មោះកាណាឲ្យដល់បុរសអ្នកមានជាតិត្រកូលស្មើគ្នា ក្នុងភូមិមួយ ។ នាងកាណាត្រឡប់មកផ្ទះមាតាដោយកិច្ចឯណាមួយ តមកស្វាមីរបស់នាងបញ្ជូនទូតទៅថា នាងកាណាចូរត្រឡប់មក យើងត្រូវការឲ្យនាងកាណាត្រឡប់ នាងកាណាស្តាប់ពាក្យរបស់ទូតហើយ លាមាតាថា ម៉ែកូនត្រូវទៅហើយ មាតាពោលថា ឯងនៅយូរប៉ុណ្ណេះ នឹងទៅដៃទទេម្តេចបាន ហើយក៏ចៀននំ ខណៈនោះឯង ភិក្ខុមួយអង្គដែលប្រព្រឹត្តបិណ្ឌបាតជាវត្តបានទៅដល់លំនៅរបស់នាង ឧបាសិកានិមន្តលោកឲ្យគង់ហើយប្រគេននំ*

ពេញបាត្រ ភិក្ខុនោះចេញទៅហើយក៏ប្រាប់ដល់ភិក្ខុដទៃ ឧបាសិកាក៏ប្រគេនដល់ភិក្ខុនោះ ដោយទំនងដូចគ្នានេះឯង សូម្បីភិក្ខុនោះក៏ត្រឡប់ចេញទៅ ហើយប្រាប់បន្តដល់ភិក្ខុដទៃ ឧបាសិកាក៏ប្រគេនដល់ភិក្ខុនោះដែរ ត្រូវប្រគេនដល់ភិក្ខុតៗគ្នាយ៉ាងនេះដល់បួនអង្គ នំតាមដែលត្រៀមទុកក៏អស់ទៅ នាងកាណាក៏នៅមិនទាន់អាចទៅបាន ។ គ្រានោះ ស្វាមីរបស់នាងកាណាក៏បញ្ជូនទូតទៅដដែលទៀតជាលើកទី ២ លុះលើកទី ៣ ក៏បញ្ជូនទូតទៅព្រមនឹងពាក្យលែងលះគ្នាថា បើនាងកាណានៅតែមិនព្រមមក យើងនឹងនាំស្ត្រីដទៃមកជាភរិយា សូម្បីរហូតដល់ទាំង ៣ លើក នាង-កាណាក៏មិនទាន់អាចទៅបាន ដោយការខកខានទុំះឯង ស្វាមីរបស់នាងក៏នាំស្ត្រីដទៃមកជាភរិយា នាងកាណាបានស្តាប់ដំណឹងនោះហើយក៏ស្រែកយំ ។

ព្រះបរមសាស្តាទ្រង់ជ្រាបរឿងនោះហើយ ទ្រង់ស្លៀកស្បង់ហើយប្រដាប់ដោយបាត្រនិងចីវរអំពីព្រឹក យាងទៅកាន់លំនៅរបស់ឧបាសិកាជាមាតានាងកាណា លុះទ្រង់យាងទៅដល់ហើយក៏គង់លើអាសនៈដែលគេបានចាត់ចែងថ្វាយ ទើបឧបាសិកាជាមាតារបស់នាងកាណាចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ លុះចូលទៅដល់ក៏ថ្វាយបង្គំព្រះដ៏មានព្រះ-ភាគហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះ-ពុទ្ធដីកានេះ នឹងឧបាសិកាជាមាតារបស់នាងកាណាដែលបានអង្គុយក្នុងទី

ដ៏សមគួរថា នាងកាណានេះ ហេតុអ្វីបានជាយំ ។ កាលទ្រង់ស្តាប់ថា ដោយហេតុយ៉ាងនេះ ទើបទ្រង់ពន្យល់កាណមាតា សម្តែងធម្មីកថា ហើយក្រោកចាកអាសនៈយាងត្រឡប់ទៅកាន់ព្រះវិហារ ។ គ្រានោះ សភាពដែលភិក្ខុទាំងបួនរូបនោះទទួលយកនំដែលត្រៀមទុក រហូតជាហេតុធ្វើឲ្យខកខានដល់ការទៅរបស់នាងកាណា ក៏ល្បីក្នុងពួកភិក្ខុ ។ ថ្ងៃមួយ ពួកភិក្ខុទាំង-ឡាយ លើកយករឿងនោះឡើងសន្ទនាគ្នាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ ភិក្ខុបួនរូបនោះ ឆាន់នំដែលមាតានាងកាណាបានប្រគេនបីដង ធ្វើឲ្យនាងកាណាទៅផ្ទះស្វាមីមិនបាន រហូតត្រូវស្វាមីបោះបង់ចោល នាំឲ្យកើតសេចក្តីទោមនស្សដល់មហាឧបាសិកា ។ ព្រះបរមសាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលភិក្ខុទាំងបួនរូបនោះ ឆាន់នំរបស់នាងកាណមាតាហើយ ធ្វើឲ្យកើតទោមនស្សដល់នាង សូម្បីក្នុងកាលមុនក៏ធ្លាប់ធ្វើឲ្យកើតទោមនស្សមកហើយដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលជាងថ្មាក់ថ្ម ចម្រើន

រ័យ សិក្សាសិល្បៈចប់ហើយ ។ នៅក្នុងនិគមមួយនាដែនកាសី មានសេដ្ឋីដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភម្នាក់ កប់ទ្រព្យទុក ៤០ កោដិ ភរិយារបស់គាត់ស្លាប់ទៅ ព្រោះការហួងហែងទ្រព្យ ទើបកើតជាសត្វកណ្ដុរនៅលើកំណប់ទ្រព្យនោះ ត្រកូលនោះដល់នូវការវិនាសទៅដោយលំដាប់ ដោយប្រការយ៉ាងនេះ អ្នកបន្តវង្សត្រកូលក៏ត្រូវដាច់ សូម្បីផ្ទះនោះក៏ត្រូវបោះបង់ចោល ។ គ្រានោះ ព្រះបរមពោធិសត្វគាស់យកថ្មក្នុងផ្ទះចាស់នោះ មកធ្វាក់ ចំណែកមេកណ្ដុរនោះទៅរកស៊ីឃើញព្រះបរមពោធិសត្វញយៗ ក៏កើតចិត្តស្រឡាញ់ គិតថា ទ្រព្យរបស់អញមានច្រើននឹងវិនាសទៅដោយឥតហេតុ អញនឹងរួមជាមួយបុរសនេះប្រើប្រាស់ទ្រព្យនេះ ។ ថ្ងៃមួយ មេកណ្ដុរនោះក៏ពាំទ្រព្យ ១ កហាបណៈទៅកាន់សម្នាក់ព្រះបរមពោធិសត្វ ។ ព្រះបរមពោធិសត្វឃើញមេកណ្ដុរនោះហើយ ក៏ប្រាស្រ័យជាមួយដោយវាចាជាទីស្រឡាញ់ សួរថា នែកណ្ដុរ អ្នកពាំកហាបណៈមកធ្វើអ្វី ? មេកណ្ដុរឆ្លើយថា បពិត្រលោកដ៏ចម្រើន សូមលោកទទួលយកកហាបណៈនេះទៅប្រើប្រាស់សម្រាប់ខ្លួនខ្លះនាំសាច់មកឲ្យខ្ញុំខ្លះចុះ ។ ព្រះពោធិសត្វទទួលពាក្យហើយយកកហាបណៈទៅកាន់នគរ ទិញសាច់មួយមាសកៈហើយយកមកឲ្យមេកណ្ដុរនោះ ។ មេកណ្ដុរនោះទទួលសាច់យកទៅកាន់លំនៅរបស់ខ្លួន ស៊ីសាច់តាមការពេញចិត្ត ។ ចាប់ពីពេលនោះមក កណ្ដុរនោះក៏ឲ្យកហាបណៈដល់ព្រះបរមពោធិសត្វរាល់ថ្ងៃដោយទំនងនេះឯង ។

ថ្ងៃមួយ ឆ្មាចាប់កណ្តុរនោះបាន ពេលនោះ កណ្តុរនិយាយនឹងឆ្មា យ៉ាងនេះថា នែសម្លាញ់ អ្នកកុំសម្លាប់ខ្ញុំឡើយ ។ ឆ្មាពោលថា រឿងអ្វី យើងនឹងមិនសម្លាប់អ្នក យើងឃ្លានចង់ស៊ីសាច់ មិនអាចនឹងទុកជីវិតឲ្យ អ្នកបានទេ ។ កណ្តុរសួរថា អ្នកចង់ស៊ីសាច់តែមួយថ្ងៃប៉ុណ្ណោះ ឬក៏ចង់ បានស៊ីរហូត? ឆ្មាឆ្លើយថា ប្រសិនបើបានដូច្នោះ យើងក៏ចង់បានស៊ីរហូត ដែរ កណ្តុរពោលថា បើដូច្នោះ ខ្ញុំនឹងឲ្យសាច់ដល់អ្នកជានិច្ច អ្នកចូរដោះ លែងខ្ញុំទៅ ពេលនោះ ឆ្មាក៏បញ្ជាក់កណ្តុរថា បើដូច្នោះ អ្នកកុំភ្លេចពាក្យ សន្យា ហើយក៏ដោះលែងកណ្តុរទៅ ។ តាំងពីនោះមក កណ្តុរក៏បែងសាច់ ដែលព្រះបរមពោធិសត្វនាំមកឲ្យខ្លួនជា ២ ចំណែក ឲ្យឆ្មាមួយចំណែក ស៊ីខ្លួនឯងមួយចំណែក ។ ថ្ងៃមួយ កណ្តុរត្រូវឆ្មាដទៃចាប់បានទៀត កណ្តុរ ក៏ត្រូវអង្វរឲ្យឆ្មាយល់ព្រម ដូចលើកមុនទៀត ហើយឲ្យដោះលែងខ្លួន តាំងពីពេលនោះក៏បែងសាច់ចេញជា ៣ ចំណែក កាលត្រូវឆ្មាចាប់បាន ទៀត ក៏សូមឲ្យឆ្មាដោះលែងខ្លួនដោយវិធីនោះឯង ចាប់ពីពេលនោះមក ក៏ត្រូវបែងសាច់ចេញជា ៤ ចំណែក ក្រោយមកត្រូវឆ្មាដទៃចាប់បានទៀត ក៏សូមអង្វរឲ្យដោះលែងខ្លួនដោយវិធីនោះទៀត តាំងពីពេលនោះមក ក៏ ត្រូវបែងសាច់ចេញដល់ទៅ ៥ ចំណែក កណ្តុរស៊ីចំណែកទី ៥ ព្រោះ មានអាហារតិច ទើបលំបាក ស្គមស្លេកស្លាំង មានសាច់និងឈាមតិច ។

ព្រះពោធិសត្វឃើញកណ្តុរនោះហើយ ក៏សួរថា នែ កណ្តុរ ហេតុ-

ដូចម្ដេច ទើបអ្នកស្គមស្ញេកស្លាំងយ៉ាងនេះ ? កាលកណ្ដុរប្រាប់រឿងរ៉ាវ ព្រះមហាសត្វពោលថា ហេតុអ្វីមិនប្រាប់យើងរហូតបែបនេះ យើងនឹងជួយធ្វើកិច្ចក្នុងរឿងនេះ ធ្វើឲ្យកណ្ដុរធូរស្បើយចិត្តហើយ ធ្វើរន្ធដោយកែវផលិកថ្លាយកមកប្រគល់ឲ្យដោយផ្ដាំថា នែកណ្ដុរ អ្នកចូលទៅដេកក្នុងរន្ធនេះចុះ ហើយស្ដីបន្ទោសឆ្មាដែលនាំគ្នាមកដោយវាចាដ៏អាក្រក់ ។ កណ្ដុរក៏ចូលដេកក្នុងរន្ធ កាលឆ្មាទី ១ មករកខ្លួនថា អ្នកចូរឲ្យសាច់ដល់យើង កណ្ដុរក៏ស្ដីបន្ទោសឆ្មាថា នែសត្វឆ្មាអាក្រក់ អញជាខ្ញុំកញ្ជះរកសាច់ឲ្យឯងឬ? ចូរទៅស៊ីសាច់កូនៗរបស់ឯងទៅ ឆ្មាមិនដឹងថាកណ្ដុរដេកក្នុងរន្ធកែវផលិកឡើយ ដោយអំណាចនៃសេចក្ដីក្រោធក៏លោតទៅដោយរហ័ស ដោយសំដៅទៅចាប់កណ្ដុរឲ្យបាន ក៏ជ្រុលបុកកែវផលិក បែកបេះដូងភ្លាម ភ្នែកទាំងពីរលៀនចេញមក ក៏ស្លាប់នៅទីនោះឯង ឆ្មាទាំង ៤ នោះត្រូវស្លាប់ទាំងអស់ ។ តាំងពីនោះមក កណ្ដុរក៏ផុតអំពីភ័យ ឲ្យកហាបណៈពីរឬបីដល់ព្រះបរមពោធិសត្វរាល់ៗថ្ងៃ ក្រោយមកបានប្រគល់ទ្រព្យទាំងអស់ដល់ព្រះបរមពោធិសត្វ ដោយឧបាយយ៉ាងនេះ អ្នកទាំងពីរមិនបានទម្លាយមិត្តភាពរហូតដល់អស់ជីវិត ក្រោយអំពីចុតិ ជនទាំងពីរក៏បានទៅតាមយថាកម្ម ។

ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ លុះព្រះអង្គបានត្រាស់ដឹងហើយ ទ្រង់បានត្រាស់ព្រះគាថានេះថា

**យត្ថេកោ លភតេ ពព្ពុ ទុតិយោ តត្ថ ជាយតិ**
**តតិយោ ច ចតុត្ថោ ច ឥទន្តេ ពព្ពុកា ពិលន្តិ ។**

*ឆ្មា ១ បានកណ្ដុរ ក្នុងទីណា ឆ្មាជាគម្រប់ពីរគម្រប់បី គម្រប់បួន រមែងកើតក្នុងទីនោះ ឆ្មាទាំងនោះ (ប្រហារ) នូវរន្ធនេះ ហើយដល់នូវសេចក្ដីស្លាប់។*

*បណ្ដាបទទាំងនោះ បទថា* **យត្ថ** *ប្រែថា ក្នុងទីណា ។*

*បទថា* **ពព្ពុ** *ប្រែថា ឆ្មា ។*

*បទថា* **ទុតិយោ តត្ថ ជាយតិ** *សេចក្ដីថា ឆ្មាមួយបានកណ្ដុរឬសាច់ក្នុងទីណា សូម្បីឆ្មាជាគម្រប់ពីរក៏កើតក្នុងទីនោះដែរ គម្រប់បី គម្រប់បួន រមែងកើតក្នុងទីនោះដែរ ដោយអាការយ៉ាងនេះ ឆ្មាទាំង ៤ នោះរួមគ្នាហើយក៏ស៊ីសាច់រាល់ថ្ងៃ ឆ្មាទាំងនោះប្រហាររន្ធដែលធ្វើអំពីកែវផលិកដោយទ្រូង ក៏ដល់នូវការអស់ជីវិតទាំងអស់ ។*

*ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ឆ្មាទាំង ៤ ក្នុងកាលនោះ បានមកជាភិក្ខុទាំង ៤ រូបនេះក្នុងកាលឥឡូវនេះ មេកណ្ដុរ បានមកជាមាតានាងកាណា ចំណែកជាងថ្វាក់ឬ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា ពព្ពុជាតក ទី ៧ ។

# អដ្ឋកថា គោធជាតក ទី ៨

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលនិយាយកុហកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កិំ តេ ជដាហិ ទុម្មេធ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ន ដូចរឿងដែលបានពោលហើយក្នុងកាលមុននោះឯង ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងកំណើតទន្សង ។ កាលនោះ តាបសមួយរូបបានអភិញ្ញា ៥ មានតបៈដ៏ខ្លាំងក្លា អាស្រ័យបច្ចន្តគ្រាមមួយនៅក្នុងបណ្ណសាលាជាយព្រៃ ។ ពួកអ្នកស្រុកនាំគ្នាទំនុកបម្រុងតាបសដោយសេចក្តីគោរព ។ ព្រះមហាបុរសក៏នៅក្នុងដំបូកមួយដែលនៅក្នុងទីបំផុតនៃទីចង្រ្កមរបស់តាបសនោះ ។ ក្នុងកាលនោះ ព្រះមហាបុរសបានទៅរកតាបសនោះ ក្នុងមួយថ្ងៃពី-បីដង រាល់ៗ ថ្ងៃ ស្តាប់ពាក្យដែលប្រកបដោយហេតុប្រកបដោយផល ហើយថ្វាយបង្គំតាបសត្រឡប់ទៅកាន់ទីលំនៅរបស់ខ្លួនវិញ ។ ក្រោយមក តាបសក៏លាពួកអ្នកស្រុកចៀសចេញទៅកាន់ទិស ។ កាលតាបសអ្នកសម្បូរដោយសីលនិងវត្តចៀសចេញទៅហើយ មានតាបសកោងដទៃមកស្នាក់នៅក្នុងអាស្រមនោះ ។ ព្រះមហាសត្វសម្គាល់ថា សូម្បីតាបសនេះ ក៏ជាអ្នកមានសីលដែរ ទើបទៅកាន់សម្នាក់តាបសនោះ ដោយន័យដូចមុននោះឯង ។ ថ្ងៃមួយ មហាមេឃ តាំង

ឡើងពុំជួកាល ញ៉ាំងភ្លៀងឲ្យធ្លាក់ចុះមកក្នុងរដូវប្រាំងហួតហែង មេភ្លៀងជាច្រើននាំគ្នាចេញអំពីដំបូកទាំងឡាយ ពួកទន្សងក៏ចេញមកស៊ីមេភ្លៀងទាំងនោះ ពួកអ្នកស្រុកក៏ចេញមកចាប់ទន្សងដែលចេញមកស៊ីមេភ្លៀងបានយ៉ាងច្រើន ហើយចាត់ចែងធ្វើជាសម្ល ផ្សំដោយគ្រឿងផ្សំដែលមានរសជាតឆ្ងាញ់ប្រគេនតាបស ។ តាបសឆាន់សម្លគ្រឿងសាច់ទន្សងជាប់ចិត្តក្នុងរសក៏សួរថា សាច់នេះឆ្ងាញ់ខ្លាំងណាស់ សាច់នេះជាសាច់សត្វប្រភេទណា? លុះបានឮគេប្រាប់ថា សាច់ទន្សង ក៏គិតថា ទន្សងមួយធំមកកាន់សម្នាក់អញរាល់ថ្ងៃ អញនឹងសម្លាប់វាយកសាច់ស៊ី ។ លុះគិតដូច្នេះហើយ ក៏ឲ្យអ្នកស្រុកយកភាជនៈសម្រាប់ដាំស្ល និងវត្ថុទាំងឡាយមានទឹកដោះថ្លានិងអំបិលជាដើម មកទុកកន្លែងមួយ កាន់កំណាត់ឈើលាក់ក្នុងសំពត់ដណ្ដប់ រង់ចាំការមករបស់ទន្សងពោធិសត្វនៅក្បែរមាត់ទ្វារបណ្ណសាលា អង្គុយធ្វើអាកប្បកិរិយាដូចជាមនុស្សស្ងប់ស្ងៀម ។

ក្នុងវេលារសៀល ព្រះបរមពោធិសត្វគិតថា អញនឹងទៅរកតាបសហើយចេញទៅ ខណៈដែលកំពុងចូលទៅជិតនោះឯង បានឃើញចំណុចខុសប្លែកនៃឥន្ទ្រីយ៍របស់តាបស ក៏គិតថា តាបសនេះ មិនបានអង្គុយដោយអាកប្បកិរិយាដែលធ្លាប់អង្គុយក្នុងថ្ងៃដទៃៗឡើយ សូម្បីសម្លឹងមើលអញក្នុងថ្ងៃនេះ ក៏សម្លឹងមើលដោយកន្ទុយភ្នែកដែលគួរឲ្យសង្ស័យដូច្នេះ អញត្រូវរង់ចាំមើលឲ្យបានជាក់ច្បាស់ លុះគិតដូច្នេះហើយ ទន្សងពោធិសត្វក៏

ទៅឈរនៅខាងក្រោមខ្យល់នៃតាបស បានធុំក្លិនសាច់ទន្សងទើបគិតថា ថ្ងៃនេះ តាបសអាក្រក់នេះ ប្រាកដជាឆាន់សាច់ទន្សងជាប់ចិត្តក្នុងរសហើយ ពេលនេះ រង់ចាំវាយអញដែលចូលទៅរកដោយកំណាត់ឈើ ហើយយក សាច់ទៅស្ងោរគ្រឿងស៊ីដោយពិតឥតសង្ស័យ ព្រះពោធិសត្វមិនព្រមចូល ទៅជិតតាបស ថយត្រឡប់ក្រោយរត់ទៅ ។ តាបសឃើញទន្សងពោធិសត្វ មិនព្រមចូលមក ក៏គិតថា ទន្សងនេះប្រាកដជាដឹងថាអញប្រាថ្នាសម្លាប់ វា ដោយហេតុនោះ ទើបមិនចូលមក សូម្បីវាមិនចូលមក ក៏មិនរួចផុតអំពី កណ្តាប់ដៃអញដែរ តាបសអាក្រក់នោះក៏យកកំណាត់ឈើចេញគ្រវែង ព្រះពោធិសត្វ កំណាត់ឈើនោះប៉ះតែចុងកន្ទុយរបស់ទន្សងពោធិសត្វ ប៉ុណ្ណោះ ។ ព្រះមហាសត្វចូលដំបូកយ៉ាងលឿន អើតក្បាលតាមរន្ធដទៃ រួចពោលថា នៃជដិលបោកប្រាស់ កាលយើងចូលទៅរកអ្នក ក៏ចូលទៅ ដោយសម្គាល់ថាជាបុគ្គលមានសីល ប៉ុន្តែពេលនេះ អំពើអាក្រក់ អំពើ បោកប្រាស់របស់អ្នក យើងបានដឹងអស់ហើយ មហាចោរដូចអ្នក បួសធ្វើ អ្វី ? កាលនឹងតិះដៀលតាបស ក៏បានពោលគាថានេះថា

**កិន្តេ ជដាហិ ទុម្មេធ កិន្តេ អជិនសាដិយា**
**អព្ភន្តរន្តេ គហនំ ពាហិរំ បរិមជ្ជសីតិ ។**

ម្នាលតាបស ឥតបញ្ញា ប្រយោជន៍អ្វីដោយជដារបស់
អ្នក ប្រយោជន៍អ្វីដោយស្បែកខ្លាឃ្មុំរបស់អ្នក ព្រោះ

គ្រឿងសំញុាំដោយ (រាគាទិក្កិលេស) មានខាងក្នុង
របស់អ្នក អ្នកខំដុសខាត់តែខាងក្រៅទេ ។

បណ្តាបទទាំងនោះ បទថា **កិន្តេ ជដាហិ ទុម្មេធ** សេចក្តីថា នៃតាបស ឥតបញ្ញា មិនមានការចេះដឹងដោយជុំវិញ ការបួងជដានេះ អ្នកដែលវៀរចាកការបៀតបៀន ទើបគួររក្សាទុក អធិប្បាយថា អ្នកប្រាសចាកគុណ គឺការវៀរចាកការបៀតបៀនចេញហើយ នឹងរក្សាជដានោះទុកធ្វើអ្វី ?

បទថា **កិន្តេ អជិនសាដិយា** សេចក្តីថា ចាប់ពីពេលដែលអ្នកមិនមានសំវរគុណដែលជាគូនឹងគ្នា អ្នកស្លៀកដណ្តប់ស្បែកខ្លាធ្វើអ្វី ?

បទថា **អព្ភន្តរន្តេ គហនំ** សេចក្តីថា ខាងក្នុងគឺហទយរបស់អ្នកសំញុាំ ណែនណាន់ដោយគ្រឿងសំញុាំគឺ រាគៈ ទោសៈ មោហៈ ។

បទថា **ពាហិរំ បរិមជ្ជសិ** សេចក្តីថា អ្នកនោះ កាលខាងក្នុងនៅសំញុាំដោយរាគាទិក្កិលេស ខំដុសខាត់ខាងក្រៅដោយការងូតទឹកជាដើម និងដោយការកាន់យកភេទ កាលខំដុសខាត់តែខាងក្រៅ អ្នកនោះក៏ដូចជាសម្បកឃ្លោកដែលពេញដោយសម្បុក ដូចពាងពេញដោយថ្នាំពុល ដូចដំបូកដែលពេញដោយអាសិរ្ពិស និងដូចផ្ទាំងដ៏វិចិត្រពេញដោយលាមកដែលរលើបរលោងតែខាងក្រៅប៉ុណ្ណោះ អ្នកជាចោរ នឹងនៅទីនេះធ្វើអ្វី ? ប្រញាប់ចៀសចេញទៅឲ្យឆាប់ ប្រសិនបើអ្នកមិនចៀសចេញទៅទេ យើង

*នឹងប្រាប់អ្នកស្រុកឲ្យបណ្តេញអ្នក ។*

*ព្រះបរមពោធិសត្វគំរាមតាបសអាក្រក់នោះយ៉ាងនេះហើយ ក៏ចូលទៅកាន់ដំបូក ចំណែកតាបសអាក្រក់នោះ ក៏បាត់អំពីទីនោះ ។*

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា តាបសអាក្រក់ក្នុងកាលនោះ បានមកជាភិក្ខុបោកប្រាស់ក្នុងកាលឥឡូវនេះ តាបសអ្នកមានសីលអង្គនោះ បានមកជាសារីបុត្ត ចំណែកគោធបណ្ឌិត គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា គោធជាតក ទី ៨ ។

# អដ្ឋកថា ឧភតោភដ្ឋជាតក ទី ៩

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **អក្ខី ភិន្នា បដោ ឆដ្ឋោ** *ដូច្នេះជាដើម ។*

*បានឮថា ក្នុងកាលនោះ ភិក្ខុទាំងឡាយនាំគ្នាលើកយករឿងឡើងសន្ទនាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ កំណាត់ឈើត្រូវភ្លើងឆេះទាំងសងខាង ត្រង់កណ្តាលប្រឡាក់លាមក មិនអាចញុំាងប្រយោជន៍ឲ្យសមគួរជាឈើក្នុងព្រៃ មិនអាចញុំាងប្រយោជន៍ជាឈើក្នុងស្រុកបានយ៉ាងណា ភិក្ខុទេវទត្តក៏ដូច្នោះដែរ បួសហើយក្នុងសាសនាដែលប្រកបដោយធម៌*

ជាគ្រឿងនាំសត្វចេញចាកទុក្ខបែបនេះ នៅភ្លាំងភ្លាត់សូន្យចាកប្រយោជន៍ទាំងពីរបាន គឺសាបសូន្យចាកភោគៈរបស់គ្រហស្ថ ទាំងមិនអាចញ៉ាំងប្រយោជន៍នៃភាពជាសមណៈឲ្យបរិបូណ៌បាន ។ ព្រះបរមសាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលទេវទត្តភ្លាំងភ្លាត់ចាកប្រយោជន៍ទាំងពីរនោះ សូម្បីក្នុងអតីតកាល ក៏ធ្លាប់វិនាសចាកប្រយោជន៍ទាំងពីរមកហើយដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជារុក្ខទេវតា ក្នុងកាលនោះ ពួកអ្នកនេសាទរស់នៅជាមួយគ្នាក្នុងស្រុកមួយ ។ គ្រានោះ អ្នកនេសាទម្នាក់កាន់សន្ទូចជាមួយកូនប្រុស ទៅកាន់បឹងដែលពួកអ្នកនេសាទតែងតែចាប់ត្រីជាប្រក្រតី ហើយចុះទៅស្ទូច គាត់ស្ទូចជាប់គល់ឈើមួយនៅក្នុងទឹក ព្រានសន្ទូចនោះមិនអាចនឹងទាញឡើងមកបាន ក៏គិតថាសន្ទូចប្រាកដជាជាប់ត្រីធំមិនខាន អញត្រូវបញ្ជូនកូនប្រុសទៅរកម៉ែវា ឲ្យបង្កជម្លោះនឹងពួកអ្នកជិតខាង កាលបើដូច្នោះ បុគ្គលណាម្នាក់ក៏នឹងមិនរង់ចាំយកចំណែកចែកអំពីត្រីនេះ ហើយប្រាប់កូនប្រុសថា នែកូនប្រុស

កូនឯងទៅចុះ ចូរទៅប្រាប់ម៉ែកូនឯងអំពីរឿងដែលយើងបានត្រីធំ ឲ្យម៉ែកូនឯងដើរឈ្លោះនឹងអ្នកជិតខាងចុះ ។ លុះព្រាហ្មណ៍នោះប្រើកូនឲ្យទៅហើយ កាលមិនអាចទាញសន្ទូចឡើងមកបានខ្លាចដាច់ខ្សែសន្ទូច ទើបដោះសំពត់ដាក់លើគោក លោតចុះទឹកព្រោះចង់បានត្រីធំ មិនបានពិចារណាថា ត្រីមែនឬក៏មិនមែនទេ ទើបទៅប៉ះនឹងគល់ឈើបែកភ្នែកទាំងពីរ សំពត់ស្លៀកដែលស្រាតដាក់លើគោកនោះ ត្រូវចោរលួចយកទៅ ព្រាហ្មណ៍នោះឈឺក្រៃលែងណាស់ យកដៃទាំងពីរក្តោបភ្នែកទាំងពីរ ឡើងអំពីទឹកពាវរកសំពត់ស្លៀក ។ ចំណែកភរិយារបស់គាត់គិតថា អញនឹងបង្កជម្លោះ ធ្វើមិនឲ្យអ្នកណាម្នាក់រង់ចាំសូមចំណែកដែលចែក ដូច្នេះហើយ យកស្លឹកត្នោតធ្វើកុណ្ឌលប្រដាប់ត្រចៀកម្ខាងប៉ុណ្ណោះ ភ្នែកម្ខាងក៏ក្រហម ពកូនថ្លៃនឹងចង្កេះ ដើរទៅអង្គុយពីដើមភូមិរហូតដល់ចុងភូមិ ។ គ្រានោះ មានស្ត្រីដែលជាសម្លាញ់ម្នាក់ និយាយដោយគ្មានក្រែងរអែងយ៉ាងនេះថា ហងយកស្លឹកត្នោតមកប្រដាប់ឰដ៏ត្រចៀកតែម្ខាងប៉ុណ្ណោះ ភ្នែកម្ខាងក៏ក្រហម ពកូនថ្លៃនឹងចង្កេះដូចកូនជាទីស្រឡាញ់ ដើរទៅអង្គុយតាំងពីដើមភូមិរហូតដល់ចុងភូមិ ហងឆ្កួតហើយឬ?

នាងពោលថា អញមិនបានឆ្កួតទេ ហងមកជេរអញដោយឥតហេតុយ៉ាងនេះ ពេលនេះ អញនឹងនាំហងទៅរកមេស្រុកឲ្យពិន័យហង ៨ កហាបណៈ លុះឈ្លោះគ្នាយ៉ាងនេះហើយ អ្នកទាំងពីរនោះនាំគ្នាទៅ

ប្ដីនៃមេស្រុក ។ កាលមេស្រុកកាត់ក្ដី ការឈ្លោះទាស់ទែងគ្នានៃស្ត្រីទាំងពីរនាក់នោះ ក៏ពិន័យស្ត្រីដែលជាភរិយាព្រានសន្ទូចនោះទៀត មនុស្សទាំង-ឡាយក៏ចាប់ចងនាងបង្ខំថា ចូរឲ្យថ្លៃពិន័យ ហើយចាប់ផ្ដើមវាយ រុក្ខ-ទេវតាឃើញអំពើនេះរបស់នាងក្នុងស្រុក និងការវិនាសរបស់ប្ដីនោះក្នុងព្រៃ ក៏ឈរនៅនឹងប្រគាបឈើពោលថា នៃមនុស្សថោកទាប ការងាររបស់ឯងវិនាសសាបសូន្យឥតប្រយោជន៍អស់ហើយ ទាំងក្នុងទឹក ទាំងលើគោក ឯងសាបសូន្យចាកប្រយោជន៍ទាំងពីរស្ថាន ហើយពោលគាថានេះថា

**អក្ខី ភិន្នា បដោ នដ្ឋោ សខីគេហេ ច ភណ្ឌនំ**
**ឧភតោ បទុដ្ឋកម្មន្តា ឧទកម្ហិ ថលម្ហិ ចាតិ ។**

ភ្នែកទាំងឡាយបែកធ្លាយហើយ សំពត់បាត់ហើយ ការឈ្លោះក៏មានក្នុងផ្ទះនៃស្ត្រីជាសម្លាញ់ ការងារទាំងឡាយខូចទាំងសងខាង គឺក្នុងទឹកផង លើគោកផង ។

បណ្ដាបទទាំងនោះ បទថា **សខីគេហេ ច ភណ្ឌនំ** សេចក្ដីថា ស្ត្រីដែលជាសម្លាញ់ឈ្មោះថា មិត្ត អធិប្បាយថា ប្រពន្ធរបស់អ្នក ធ្វើការប្រេះធានឹងស្ត្រីដែលជាសម្លាញ់នោះ ត្រូវចាប់ចងវាយធ្វើទារុណកម្ម ។

បទថា **ឧភតោ បទុដ្ឋកម្មន្តា** សេចក្ដីថា ការងារទាំងពីរឋានៈរបស់អ្នកខូចខាតវិនាសយ៉ាងនេះ ។

សួរថា ក្នុងឋានៈទាំងពីរនោះខូចខាតដូចម្ដេច ?

ឆ្លើយថា ក្នុងទឹកផង លើគោកផង បានដល់ ការងារក្នុងទឹកវិនាស ព្រោះបែកភ្នែកទាំងពីរ និងសំពត់ស្លៀកត្រូវចោរលួច ការងារលើគោកវិនាស ព្រោះប្រពន្ធធ្វើការប្រេះឆានឹងស្រ្តីជាដែលជាសម្លាញ់ ត្រូវចាប់ចងវាយធ្វើទារុណកម្ម ។

ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រានសន្ទូចក្នុងកាលនោះ បានមកជាទេវទត្ត ចំណែករុក្ខទេវតា គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ឧភតោភដ្ឋជាតក ទី ៩ ។

# អដ្ឋកថា កាកជាតក ទី ១០

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ **ញាតត្ថចរិយា** គឺការប្រព្រឹត្តជាប្រយោជន៍ដល់ព្រះញាតិ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **និច្ចំ ឧព្វិគ្គហាទយា** ដូច្នេះជាដើម។

រឿងក្នុងបច្ចុប្បន្ន នឹងមានជាក់ច្បាស់នៅក្នុង **ភទ្ទសាលជាតក ទ្វាទសកនិបាត** ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងកំណើតក្អែក ។ ថ្ងៃមួយបុរោហិតរបស់ព្រះរាជាងូតទឹកក្នុងស្ទឹងក្រៅនគរ ផាត់ម្សៅ តែងកាយ

ប្រដាប់កម្រងផ្កា ស្លៀកសំពត់សមនឹងយសសក្តិ កំពុងធ្វើដំណើរចូលនគរ ។ នៅលើចុងសសរបន្ទាយជិតនគរមានក្អែកពីរទំនៅទីនោះ បណ្តាក្អែកទាំងពីរនោះ ក្អែកមួយនិយាយនឹងក្អែកមួយទៀតថា នែសម្លាញ់ ខ្ញុំនឹងជុះអាចម៍ដាក់ក្បាលព្រាហ្មណ៍នេះ ។

ក្អែកមួយទៀតជំទាស់ថា អ្នកកុំនឹកចង់សប្បាយយ៉ាងនេះឡើយ ព្រាហ្មណ៍នេះជាអ្នកធំ ធម្មតាការបង្កពៀរវេរានឹងឥស្សរជន អ្នកនឹងជួបប្រសព្វនឹងផលអាក្រក់ក្រៃលែងណាស់ ព្រោះថា កាលបើព្រាហ្មណ៍នោះក្រោធហើយ នឹងធ្វើក្អែកទាំងអស់ឲ្យវិនាសបាន ។

ក្អែកមួយនោះពោលថា ខ្ញុំមិនអាចផ្លាស់ប្តូរចិត្តបាន ។

ក្អែកមួយទៀតពោលថា បើយ៉ាងនោះ អ្នកនឹងបានដឹងខ្លួនឯងហើយក៏ហើរចៀសចេញទៅ ។ ក្អែកមួយនោះ ពេលព្រាហ្មណ៍មកដល់ខាងក្រោមសសរបន្ទាយ ក៏ធ្វើជាបន្ទន់ខ្លួនចុះ ហើយជុះអាចម៍ដាក់ក្បាលព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍ក្រោធ ចងពៀរនឹងហ្វូងក្អែក ។

គ្រានោះ ទាសីបម្រើខាងបុកអង្ករម្នាក់ យកស្រូវហាលនៅក្បែរផ្ទះអង្គុយយាមរួចក៏ដេកលក់ទៅ ពពែរោមវែងមួយដឹងថាទាសីនោះធ្វេស-ប្រហែសក៏មកស៊ីស្រូវ ទាសីនោះភ្ញាក់ឡើងឃើញពពែក៏ដេញទៅ ពពែលួចមកស៊ីស្រូវពេលដែលទាសីនោះដេកលក់យ៉ាងនោះឯង អស់វារៈពីរ-បីដង ទាសីនោះក៏ដេញពពែនោះទៅទាំងបីដង ហើយគិតថា កាលពពែ

ស៊ីរឿយៗ នឹងស៊ីស្រូវអស់ពាក់កណ្ដាល អញនឹងខាតប្រយោជន៍ជាច្រើន ពេលនេះ ត្រូវធ្វើយ៉ាងណាកុំឲ្យពពែមកបានទៀត ។ នាងក៏កាន់ចន្លុះ អង្គុយធ្វើដូចជាដេកលក់ កាលពពែចូលមកស៊ីស្រូវក៏ក្រោកឡើងគប់ពពែ ដោយចន្លុះ ពពែក៏ត្រូវភ្លើងឆេះ កាលរាងកាយត្រូវភ្លើងឆេះ ពពែគិតឲ្យ ភ្លើងរលត់ ទើបរត់ទៅយ៉ាងលឿន យកខ្លួនត្រដុសនឹងខ្ទមស្មៅមួយដែល នៅជិតរោងដំរី ខ្ទមនោះក៏ឆេះសន្ធោសន្ធៅ អណ្ដាតភ្លើងដែលកើតអំពីខ្ទម នោះ រាលទៅឆេះរោងដំរី កាលរោងដំរីឆេះ ខ្នងដំរីក៏ឆេះដែរ ដំរីនីមួយៗ មានខ្លួនរបួសយ៉ាងដំណំ ។ ពួកហ្មដំរីមិនអាចនឹងព្យាបាលឲ្យជាបាន ក៏ ក្រាបទូលព្រះរាជា ។ ព្រះរាជាក៏ត្រាស់នឹងបុរោហិតថា លោកអាចារ្យ ហ្មដំរីអស់ថ្វីដៃដែលនឹងរក្សាហ្វូងដំរីហើយ លោកល្មមនឹងស្គាល់ថ្នាំអ្វីៗ ខ្លះឬ?

បុរោហិតទទួលព្រះរាជតម្រាស់ថា ព្រះករុណាថ្លៃវិសេស ។

ព្រះរាជាត្រាស់សួរថា បានអ្វីទើបគួរ?

បុរោហិតក្រាបទូលថា បពិត្រមហារាជ ទាល់តែបានខ្លាញ់ក្អែក ទើបអាចព្យាបាលបាន ។

ព្រះរាជាត្រាស់ថា បើដូច្នោះអ្នកទាំងឡាយ ចូរប្រើមនុស្សឲ្យទៅ សម្លាប់ក្អែកយកខ្លាញ់មកចុះ ។ ចាប់តាំងពីពេលនោះមក មនុស្សទាំង- ឡាយក៏នាំគ្នាទៅសម្លាប់ក្អែក មិនបានខ្លាញ់ក៏បោះចោលជាគំនរ ៗ ក្នុងទី

នោះៗ មហាភ័យបានកើតឡើងដល់ហ្វូងក្អែក ។

គ្រានោះ ព្រះមហាបុរសមានហ្វូងក្អែក ៨ ម៉ឺនជាបរិវារនៅក្នុងព្រៃខ្មោច ។ មានក្អែកមួយមកប្រាប់ព្រះពោធិសត្វអំពីភ័យដែលកើតឡើងដល់ហ្វូងក្អែក ។ ព្រះមហាសត្វត្រិះរិះថា វៀរអាត្មាអញចេញហើយ អ្នកដទៃដែលអាចបំបាត់ភ័យ ដែលកំពុងកើតឡើងដល់ពួកញាតិរបស់អញ មិនមានឡើយ អញត្រូវកម្ចាត់ភ័យនោះ ហើយរំពឹងនឹកដល់បារមី ១០ប្រការធ្វើមេត្តាបារមីឲ្យជាបុរេចារិកហើយ ហើរទៅម្នាក់ឯងប៉ុណ្ណោះ ចូលទៅតាមប្រហោងបង្អួចដែលគេបើកទុក ចូលទៅលាក់ខ្លួននៅខាងក្រោមព្រះរាជ-អាសនៈ ។ ពេលនោះ អាមាត្យម្នាក់ធ្វើអាកប្បកិរិយានឹងចាប់ស្តេចក្អែកពោធិសត្វ ព្រះរាជាត្រាស់ហាមឃាត់ថា ក្អែកចូលមករកទីពឹង កុំចាប់ក្អែកនោះឡើយ ។ ស្តេចក្អែក សម្រាកនៅទីនោះបន្តិច ហើយរំពឹងនឹកដល់ព្រះបារមី ចេញអំពីអាសនៈ ក្រាបទូលព្រះរាជាថា បពិត្រមហារាជធម្មតាព្រះរាជាមិនត្រូវលុះក្នុងអំណាចអគតិ មានឆន្ទាគតិជាដើម ទើបប្រពៃ កម្មណាៗដែលនឹងត្រូវធ្វើ កម្មនោះៗ ត្រូវពិចារណាឲ្យល្អិតល្អន់ហើយសឹមធ្វើ ទើបប្រសើរ ម្យ៉ាងទៀត កម្មណាដែលនឹងធ្វើត្រូវបានផលកម្មនោះប៉ុណ្ណោះទើបគួរធ្វើ កម្មក្រៅអំពីនេះមិនគួរធ្វើ ប្រសិនបើព្រះ-រាជាទាំងឡាយ ទ្រង់ធ្វើកម្មដែលធ្វើទៅមិនសម្រេចផលនោះ មហាភ័យមានមរណភ័យជាទីបំផុត រមែងកើតឡើងដល់មហាជន ដ្បិតបុរោហិត

*ឋិតនៅក្នុងអំណាចនៃការចងពៀរ បានក្រាបទូលកុហក ធម្មតាខ្ញាញ់រាវរបស់ក្អែកទាំងឡាយមិនមានឡើយ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ មានព្រះទ័យជ្រះថ្លា ឲ្យព្រះបរមពោធិសត្វទំនៅលើតាំង ឲ្យរាជបុរសលាបស្លាបដោយប្រេងដែលរម្ងាស់ហើយ ១ សែនដង ឲ្យបរិភោគអាហារដ៏ស្អាតដូចជាព្រះក្រយាហារ ឲ្យផឹកទឹក លុះស្ដេចក្អែកសប្បាយចិត្តបាត់ការហត់នឿយហើយ ទើបត្រាស់ពាក្យនេះថា នែបណ្ឌិត អ្នកពោលថា ធម្មតាខ្ញាញ់រាវរបស់ក្អែកទាំងឡាយ មិនមានឡើយ ព្រោះហេតុដូចម្ដេច ទើបក្អែកទាំងឡាយមិនមានខ្ញាញ់រាវ ? ព្រះមហាសត្វកាលនឹងក្រាបទូលក៏ពន្យល់ថា បពិត្រមហារាជ ដោយហេតុឈ្មោះនេះ ដោយហេតុឈ្មោះនេះ ធ្វើព្រះរាជវាំងទាំងមូលឲ្យមានសំឡេងតែមួយ សម្ដែងធម៌ពោលគាថានេះថា*

**និច្ចំ ឧព្វិគ្គហទយា សព្វលោកវិហេសកា**
**តស្មា នេសំ វសា នត្ថិ កាកានម្ហាក ញាតិនន្តិ ។**

*ក្អែកទាំងឡាយ ជាសត្វមានហឫទ័យភ្ញាក់ផ្អើលជានិច្ច*
*ជាសត្វបៀតបៀនមនុស្សលោកទាំងពួង ព្រោះហេតុនោះ*
*បានជាខ្ញាញ់រាវនៃពួកក្អែក ជាញាតិរបស់យើងទាំងនោះ*
*មិនចេះមានឡើយ។*

*ក្នុងគាថានោះ មានសេចក្ដីសង្ខេបដូច្នេះ បពិត្រមហារាជ ធម្មតា*

ហ្វូងក្អែកមានចិត្តភ្ញាក់ផ្អើល គឺធ្លាប់តែតក់ស្លុតជានិច្ច ។

បទថា **សព្វលោកាវិហេសកា** សេចក្តីថា ក្អែកទាំងឡាយជាសត្វចូលចិត្តបៀតបៀន គំរាមកំហែងមនុស្សដែលជាធំ មានក្សត្រជាដើមខ្លះ ស្ត្រីបុរសទូទៅខ្លះ ក្មេងប្រុសក្មេងស្រីជាដើមខ្លះ ហេតុនោះគឺដោយហេតុពីរប្រការនេះ ខ្លាញ់រាវរបស់ក្អែកទាំងឡាយដែលជាញាតិរបស់ទូលបង្គំទាំងនោះ ទើបមិនមាន សូម្បីក្នុងអតីតក៏មិនធ្លាប់មាន សូម្បីក្នុងអនាគតក៏នឹងមិនមាន ។

ស្តេចក្អែកពោធិសត្វចង្អុលបង្ហាញហេតុនេះ ដោយប្រការដូច្នេះហើយ ទូលដាស់តឿនព្រះរាជាថា បពិត្រមហារាជ ធម្មតាព្រះរាជាមិនបានពិចារណាហើយ មិនគប្បីបដិបត្តិព្រះរាជកិច្ច ។ ព្រះរាជាទ្រង់ពេញព្រះទ័យបូជាព្រះបរមពោធិសត្វដោយរាជសម្បត្តិ ។ ព្រះមហាសត្វថ្វាយរាជសម្បត្តិចំពោះព្រះរាជាវិញ ឲ្យព្រះរាជាតាំងនៅក្នុងបញ្ចសីល ទូលសូមព្រះរាជទានអភ័យដល់សត្វទាំងពួង ។ ព្រះរាជាទ្រង់ព្រះសណ្តាប់នូវព្រះធម្មទេសនាហើយ ទ្រង់ព្រះរាជទានអភ័យដល់សត្វទាំងពួង ទ្រង់តម្កល់និពទ្ធទាន គឺទានដែលឲ្យជាប្រចាំដល់ហ្វូងក្អែក ហើយបញ្ជាឲ្យដាំបាយប្រមាណមួយថាំង លាយដោយវត្ថុដែលមានរសដ៏ប្រណីតផ្សេងៗ ព្រះរាជទានដល់ហ្វូងក្អែករាល់ៗថ្ងៃ ចំណែកព្រះបរមពោធិសត្វបានទទួលព្រះរាជទានព្រះក្រយាហារនោះឯង ។

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ព្រះរាជានគរពារាណសីក្នុងកាលនោះ បានមកជាអានន្ទ ចំណែកស្តេចក្អែក គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា កាកជាតក ទី ១០ ។

ចប់ អដ្ឋកថា អសម្បទានវគ្គ ទី ១៤ ។

## រួមជាតកដែលមានក្នុងវគ្គនេះគឺ

*អសម្បទានជាតក ១ បញ្ចភិរុកជាតក ១ ឃតាសនជាតក ១ ឈានសោធនជាតក ១ ចន្ទាភជាតក ១ សុវណ្ណហំសជាតក ១ ពព្វុជាតក ១ គោធជាតក ១ ឧភតោភដ្ឋជាតក ១ កាកជាតក ១ ។*

# កកណ្ដកវគ្គ ទី ១៥

## អដ្ឋកថា គោធជាតក ទី ១

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុដែលសេពគប់អ្នកយល់ខុសមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **ន ចាបជនសំសេវី** *ដូច្នេះជាដើម ។*

*រឿងបច្ចុប្បន្នក៏ដូចរឿងដែលពោលហើយក្នុង* **មហិឡាមុខជាតក** *នោះឯង ។*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងកំណើតទន្សង ធំពេញវ័យហើយមានទន្សងច្រើនរយជាបរិវារ រស់នៅក្នុងប្រហោងឈើធំមួយដែលនៅនឹងឆ្នេរស្ទឹង ។ កូនរបស់ព្រះបរមពោធិសត្វនោះ មានឈ្មោះថា គោធបិល្វកៈ ធ្វើសេចក្ដីស្និទ្ធស្នាលនឹងបង្កួយមួយ ប្រឡែងលេងជាមួយនឹងបង្កួយនោះ ឡើងជាន់បង្កួយដោយគិតថា អញនឹងឱបបង្កួយ ។ ពួកទន្សងប្រាប់សេចក្ដីស្និទ្ធស្នាលរវាងគោធបិល្វកៈនឹងបង្កួយនោះ ឲ្យស្ដេចទន្សងជ្រាប ។ ស្ដេចទន្សងក៏ហៅបុត្តមករួចពោលថា កូនសម្លាញ់ កូនឯងធ្វើសេចក្ដីស្និទ្ធស្នាលក្នុងទីដែលមិនសមគួរឡើយ ធម្មតាបង្កួយទាំងឡាយមានកំណើតថោកទាប មិនគួរធ្វើសេចក្ដីស្និទ្ធស្នាលនឹងវាឡើយ ប្រសិនបើកូនឯងនៅតែរឹងធ្វើសេចក្ដីស្និទ្ធស្នាលនឹងវា ត្រកូលទន្សងទាំងអស់នឹងត្រូវ*

វិនាសព្រោះអាស្រ័យវាជាពិតប្រាកដ ចាប់ពីពេលនេះទៅ កូនឯងកុំធ្វើសេចក្ដីស្និទ្ធស្នាលនឹងវាទៀត ។ គោធបិល្លក:នៅតែធ្វើសេចក្ដីស្និទ្ធស្នាលនឹងបង្គួយនោះដដែល សូម្បីព្រះបរមពោធិសត្វនិយាយជារឿយៗ ក៏មិនអាចហាមឃាត់សេចក្ដីស្និទ្ធស្នាលរវាងកូនទន្សងនឹងបង្គួយបាន ទើបត្រិះរិះថា អាស្រ័យបង្គួយមួយ ភ័យត្រូវកើតឡើងដល់ពួកយើងជាពិតប្រាកដ គួររៀបចំផ្លូវសម្រាប់រត់គេចទុកជាមុន លុះគិតដូច្នោះហើយក៏ឲ្យធ្វើរន្ធបន្ទំម្ខាង ។ ចំណែកកូនរបស់ស្ដេចទន្សងនោះ មានកាយធំឡើងដោយលំដាប់ គិតថា នឹងឱបបង្គួយ ( ពេលណា ) ក៏លោតឱបរឿយៗ ( ពេលនោះ ) ពេលដែលគោធបិល្លិក:លោតឱបបង្គួយ ដូចត្រូវភ្នំសង្កត់ដូច្នោះ ។ កាលបង្គួយបានទទួលការលំបាកទើបគិតថា ប្រសិនបើទន្សងនេះលោតឱបអញយ៉ាងនេះ ត្រឹមតែពីរ-បីថ្ងៃជាប់គ្នា អញពិតជាស្លាប់មិនខាន អញនឹងរួមដៃជាមួយព្រានម្នាក់បោសសម្អាតត្រកូលទន្សងនេះ ឲ្យទាល់តែអស់ ។

ថ្ងៃមួយ ក្នុងរដូវប្រាំង កាលភ្លៀងធ្លាក់ហើយ ហ្វូងមេភ្លៀងនាំគ្នាហើរចេញអំពីដំបូក ហ្វូងទន្សងចេញអំពីទីនោះៗមកស៊ីមេភ្លៀង ។ ព្រានទន្សងម្នាក់កាន់ចបទៅព្រៃជាមួយហ្វូងឆ្កែដើម្បីជីករូងទន្សង បង្គួយឃើញព្រាននោះហើយគិតថា ថ្ងៃនេះសេចក្ដីប្រាថ្នារបស់អញសម្រេចពិតប្រាកដហើយ លុះគិតដូច្នេះហើយក៏ចូលទៅរកព្រានក្រាបចុះក្នុងទីមិនឆ្ងាយ សួរថា បពិត្រលោកដ៏ចម្រើន លោកត្រាច់ទៅក្នុងព្រៃធ្វើអ្វី ? ព្រានឆ្លើយថា

យើងដើររកចាប់ទន្សង ។ បង្គួយពោលថា ខ្ញុំដឹងទីនៅនៃទន្សងច្រើនរយក្បាល លោកចូរទៅរកភ្លើងនិងចំបើងមកចុះ បង្គួយនាំព្រានទៅកាន់ទីនោះ ហើយប្រាប់ថា លោកចូរដាក់ភ្លើងត្រង់នេះ ហើយដុតធ្វើឲ្យមានផ្សែង ដាក់ឆ្កែព័ទ្ធជុំវិញ ហើយលោកខ្លួនឯងចេញទៅរង់ចាំវាយទន្សងឲ្យស្លាប់ ហើយយកទៅគរទុក ។ លុះប្រាប់យ៉ាងនេះហើយ ក៏គិតថា ថ្ងៃនេះ អញបានសង-សឹកសត្រូវហើយ ហើយក៏ទៅដេកងក់ក្បាលផ្ងក់ៗ នៅក្នុងកន្លែងមួយ ។ ចំណែកព្រានទន្សងចាត់ចែងដុតគំនរចំបើង ផ្សែងចូលទៅក្នុងប្រហោងឈើ ទន្សងទាំងឡាយថប់នឹងផ្សែង ត្រូវមរណភ័យគំរាម ទន្សងនីមួយៗប្រញាប់ចេញមក ព្រានក៏ចាំវាយទន្សងទាំងឡាយដែលចេញមកឲ្យស្លាប់ ទន្សងដែលរួចផុតអំពីដៃព្រានក៏ត្រូវហ្វូងឆ្កែខាំ មហាវិនាសកើតឡើងដល់ហ្វូងទន្សង ។ ស្តេចទន្សងដឹងថា ព្រោះអាស្រ័យបង្គួយមួយនេះទើបភ័យកើតឡើង ក៏ពោលថា ធម្មតាការសេពគប់បុគ្គលអាក្រក់ ជាអំពើមិនគប្បីធ្វើ ធម្មតាប្រយោជន៍រមែងមិនមានព្រោះអាស្រ័យជនអាក្រក់ ដោយអំណាចនៃបង្គួយអាក្រក់តែមួយ ទើបសេចក្តីវិនាសកើតដល់ទន្សងទាំង-ឡាយមានប្រមាណប៉ុណ្ណោះ កាលនឹងរត់គេចទៅតាមរន្ធខ្យល់បានពោលគាថានេះថា

ន ចាបជនសំសេវី អច្ចន្តសុខមេធតិ
គោធា កុលំ កកណ្តាវ កលី ចាបេតិ អត្តនន្តិ ។

បុគ្គលអ្នកសេពគប់នូវជនបាប រមែងមិនដល់ នូវសេចក្តី
សុខពិតទេ ដូចជាត្រកូលទន្សងមិនបានសេចក្តីសុខ ព្រោះ
បង្កួយ(១) រមែងញុំាងខ្លួនឲ្យដល់ នូវសេចក្តីវិនាស ។

ក្នុងគាថានោះ មានសេចក្តីសង្ខេបដូច្នេះ បុគ្គលដែលសេពគប់នូវបាបជន រមែងមិនដល់ គឺមិនជួបប្រសព្វ មិនបានទទួលសេចក្តីសុខដ៏យូរអង្វែងទេ គឺសេចក្តីសុខដែលមានឈ្មោះថា សុខមួយខណៈ ដូចអ្វី ? ដូចត្រកូលទន្សងមិនបានសេចក្តីសុខ ព្រោះសត្វបង្កួយយ៉ាងណា បុគ្គលដែលសេពគប់បុគ្គលអាក្រក់ រមែងមិនបានសេចក្តីសុខដូច្នោះដែរ មានតែនាំខ្លួនឲ្យដល់នូវសេចក្តីវិកវរជាមួយនឹងបុគ្គលអាក្រក់នោះ រមែងនាំខ្លួននិងអ្នកដទៃដែលនៅជាមួយខ្លួន ឲ្យដល់នូវសេចក្តីវិនាសតែម្យ៉ាងប៉ុណ្ណោះ ប៉ុន្តែក្នុងបាលីលោកសរសេរទុកថា **កលឹ ចាបេយ្យ** ប្រែថា គប្បីនាំខ្លួនឲ្យដល់នូវសេចក្តីវិកវរ ព្យញ្ជនៈ( គឺសេចក្តី )យ៉ាងនោះ មិនមានក្នុងអដ្ឋកថា

---

១-កកណ្តកសព្ទ បិដកខ្មែរប្រែថា សត្វត្រកួត តែក្នុងទីនេះ យើងប្រែថា សត្វបង្កួយ ព្រោះសព្ទត្រូវគ្នានឹងកកណ្តកបញ្ហា គឺប្រស្នាពោលអំពីសត្វបង្កួយ ដែលនៅលើខ្លោងទ្វាររបស់ព្រះបាទវិទេហៈ ក្នុងអដ្ឋកថា មហោសថជាតក ។ សេចក្តីនេះ បណ្ឌិតគប្បីពិចារណា ។

ទាំងអត្ថន័យនៃព្យញ្ជនៈនោះក៏មិនត្រឹមត្រូវ ហេតុនោះ គប្បីកាន់យកពាក្យតាមដែលបានពោលហើយនោះឯង ។

ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ប្រជុំជាតកថា បង្គួយក្នុងកាលនោះ បានមកជាទេវទត្ត បុត្តរបស់ព្រះបរមពោធិសត្វឈ្មោះ គោធបិល្លកៈ ដែលមិនជឿឱវាទ បានមកជាភិក្ខុដែលសេពគប់អ្នកយល់ខុស ចំណែកស្តេចទន្សង៍ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា គោធជាតក ទី ១ ។

# អដ្ឋកថា សិង្គាលជាតក ទី ២

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការព្យាយាមផ្តាច់ព្រះជន្មទ្រង់របស់ភិក្ខុទេវទត្ត ត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **ឯតំ ហិ តេ ទុរាជានំ** ដូច្នេះជាដើម ។

សេចក្តីសង្ខេបថា ព្រះបរមសាស្តាទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ភិក្ខុទាំងឡាយក្នុងធម្មសភាហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលទេវទត្តព្យាយាមសម្លាប់តថាគតនោះ សូម្បីក្នុងកាលមុនក៏ធ្លាប់ព្យាយាមសម្លាប់តថាគតហើយដែរ ប៉ុន្តែមិនអាចនឹងសម្លាប់តថាគតបាន ហើយត្រូវលំបាកម្នាក់ឯងប៉ុណ្ណោះ កាលទ្រង់ត្រាស់ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅ

នេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងកំណើតចចក បានជាស្តេចសិង្គាលហែហមដោយហ្វូងចចករស់នៅក្នុងព្រៃ ។ ក្នុងសម័យនោះ នគរពារាណសីមានមហោស្រព មនុស្សទាំងឡាយនាំគ្នាផឹកសុរាយ៉ាងច្រើន បានឮថា មហោស្រពនោះ គឺមហោស្រពដែលចាត់ចែងឡើងដើម្បីការផឹកសុរានោះឯង ។ គ្រានោះ ពួកអ្នកលេងសុរាជាច្រើន បបួលគ្នារកសុរានិងសាច់មកជាច្រើន ហើយប្រដាប់តាក់តែងរាងកាយ នាំគ្នាច្រៀងរាំផង ផឹកសុរាផង ស៊ីសាច់ក្លែមសុរាផង លុះអស់យាមដំបូង សាច់របស់ពួកគេក៏អស់ ប៉ុន្តែសុរានៅសល់ច្រើន ពេលនោះ អ្នកលេងសុរាម្នាក់ពោលថា ឲ្យសាច់យើងមួយចំណិត កាលបានទទួលពាក្យតបថា សាច់អស់ហើយ ក៏និយាយថា កាលខ្ញុំនៅ មិនត្រូវមានពាក្យថាសាច់អស់ហើយ ពោលបន្តទៀតថា ខ្ញុំនឹងសម្លាប់ចចកដែលមកស៊ីសាកសពមនុស្សក្នុងព្រៃខ្មោច យកសាច់មក ហើយស្រវាចាប់ដំបងចេញអំពីនគរតាមផ្លូវបង្ហូរទឹកទៅកាន់ព្រៃខ្មោច ដេកផ្ងារដៃកាន់ដំបងធ្វើដូចមនុស្សស្លាប់ ។ គ្រានោះ ស្តេចចចកពោធិសត្វចោមរោមដោយចចកទៅកាន់ទីនោះ ឃើញអ្នកលេងនោះហើយ សូម្បីដឹងថាអ្នកនេះមិនមែនស្លាប់ទេ គិតថា ត្រូវពិនិត្យមើលឲ្យបានល្អិតល្អន់សិន ទើបទៅឈរខាងក្រោមខ្យល់នៃបុរសនោះហិតក្លិន

ខ្លួន ក៏ដឹងថាបុរសនេះមិនទាន់ស្លាប់ពិតប្រាកដ គិតថា ត្រូវធ្វើឲ្យបុរសនោះខ្មាសហើយសឹមឲ្យទៅ ទើបដើរទៅខាំត្រង់ចុងដំបងទាញមក អ្នកលេងនោះមិនព្រមលែង សូម្បីមិនសម្លឹងមើលស្តេចចចកដែលចូលមកជិត ក៏នៅតែចាប់កាន់ដំបងនោះយ៉ាងមាំ ។ ព្រះបរមពោធិសត្វត្រឡប់ទៅវិញ ហើយពោលថា នៃអ្នកដ៏ចម្រើន ប្រសិនបើអ្នកជាមនុស្សស្លាប់ហើយពិតមែននោះ កាលយើងទាញដំបងមក ក៏មិនគួរចាប់កាន់ដំបងយ៉ាងមាំដែរ ដោយហេតុណា ហេតុរបស់អ្នកនោះ ទើបដឹងបានដោយលំបាក ដូច្នេះហើយ ពោលគាថានេះថា

**ឯតំ ហិ តេ ទុរាជានំ យំ សេសិ មតសាយិតំ**

**យស្ស តេ កឌ្ឍមានស្ស ហត្ថា ទណ្ឌោ ឧមុច្ចតីតិ ។**

អ្នកដេកធ្វើពុតជាស្លាប់ ដោយហេតុណា ហេតុរបស់អ្នកនុ៎ះ

ដឹងបានដោយក្រ តែដំបងមិនរបូតអំពីដៃរបស់អ្នក កំពុង

ចាប់កាន់នោះ ។

បណ្តាបទទាំងនោះ បទថា **ឯតំ ហិ តេ ទុរាជានំ** សេចក្តីថា ហេតុនុ៎ះរបស់អ្នក ដឹងបានដោយក្រ ។

បទថា **យំ សេសិ មតសាយិតំ** សេចក្តីថា ហេតុដែលអ្នកដេកដូចមនុស្សស្លាប់នោះ (ដឹងបានដោយលំបាកពិតៗ) ។

បទថា **យស្ស តេ កឌ្ឍមានស្ស** សេចក្តីថា អ្នកណា កាល

យើងខាំចុងដំបងទាញមក ដំបងមិនរបូតអំពីដៃ អ្នកនោះនឹងហៅថា មនុស្សស្លាប់ហើយ មិនបានសោះឡើយ ។

កាលព្រះបរមពោធិសត្វពោលយ៉ាងនេះហើយ អ្នកលេងនោះគិតថា ស្តេចចចកនេះ ដឹងថាអញមិនទាន់ស្លាប់ ក៏ក្រោកឡើងព្រួយដំបងទៅ ដំបងរត់ទៅខុសទិសដៅ អ្នកលេងពោលថា អាទៅចុះ ពេលនេះអារួចអំពីកណ្តាប់ដៃអញ ពេលក្រោយមិនប្រាកដទេ ។ ព្រះបរមពោធិសត្វបែរមកពោលថា នៃបុរសដ៏ចម្រើន សូម្បីអ្នកភ្ញាត់យើងទៅ ប៉ុន្តែអ្នកមិនរួចផុតអំពីមហានរក ៨ រណ្តៅ ឧស្សទនរក ១៦ រណ្តៅឡើយ ( ព្រះបរមពោធិសត្វពោលដូច្នេះ ) ហើយគេចទៅ ។ អ្នកលេងមិនបានអ្វី ចេញអំពីព្រៃខ្មោចងូតទឹកក្នុងប្រឡាយ ចូលកាន់នគរវិញ ។

ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា អ្នកលេងក្នុងកាលនោះ បានមកជាទេវទត្ត ចំណែកស្តេចចចក គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា សិង្គាលជាតក ទី ២ ។

# អដ្ឋកថា ទិរោចនជាតក ទី ៣

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភាព ដែលភិក្ខុទេវទត្តសម្តែងអាកប្បកិរិយាដូចព្រះសុគត នៅក្នុងគយាសីស-ប្រទេស ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្តើមថា **លសី ច តេ និប្ផលិតា** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ភិក្ខុទេវទត្តមានឈានសាបសូន្យហើយ ក៏សាប-សូន្យចាកលាភសក្ការៈផងដែរ ក៏គិតថា នៅមានឧបាយម្យ៉ាង លុះគិតដូច្នេះហើយ ក្រាបទូលសូមវត្ថុ ៥ ប្រការអំពីព្រះបរមសាស្តា កាលមិនបាន ក៏បបួលភិក្ខុ ៥០០ រូបដែលជាសទ្ធិវិហារិករបស់ព្រះអគ្គសាវកទាំងពីរ ដែលទើបបួសថ្មី មិនទាន់ឈ្លាសក្នុងព្រះធម្មវិន័យ ទៅកាន់គយាសីសប្រទេស[១] បំបែកសង្ឃ ធ្វើសង្ឃកម្មមួយពួកផ្សេងក្នុងសីមាមួយជាមួយគ្នា ។ ព្រះ-បរមសាស្តាទ្រង់ជ្រាបវេលានៃបញ្ញារបស់ភិក្ខុទាំងនោះចាស់ក្លា ទ្រង់បញ្ជូនព្រះអគ្គសាវកទាំងពីរអង្គទៅកាន់ទីនោះ ។ ទេវទត្តឃើញព្រះអគ្គសាវកទាំងពីរភ្លាមក៏សប្បាយចិត្ត គិតថា កាលអញសម្តែងធម៌មួយយប់ទល់ភ្លឺ នឹងធ្វើអាកប្បកិរិយាដូចព្រះពុទ្ធ លុះគិតដូច្នោះហើយ កាលនឹងសម្តែង

---

១-តំបន់មួយដែលមានភ្នំរាងដូចក្បាលដំរី ទើបឈ្មោះថា គយាសីសប្រទេស ។

អាកប្បកិរិយាដូចព្រះសុគត ទើបពោលថា នៃសារីបុត្ត ភិក្ខុសង្ឃមិនទាន់ងោកងុយនៅឡើយ ចូរអ្នកសម្តែងធម្មីកថាដល់ភិក្ខុទាំងឡាយចុះ ខ្ញុំរោយខ្នងខ្លាំងណាស់ នឹងសូមតម្រង់ខ្នងបន្តិច ហើយក៏ចូលទៅដេក ។ ព្រះ-អគ្គសាវកទាំងពីរអង្គសម្តែងធម៌ដល់ភិក្ខុទាំងឡាយនោះ ឲ្យភ្ញាក់ដោយមគ្គផលទាំងឡាយហើយ នាំត្រឡប់មកកាន់វត្តវេឡុវ័នទាំងអស់ ។ ភិក្ខុកោ-កាលិកៈឃើញវិហារសូន្យចាកភិក្ខុក៏ទៅកាន់សម្នាក់ទេវទត្ត ហើយពោលថា អាវុសោទេវទត្ត អគ្គសាវកទាំងពីររបស់លោក ទម្លាយបរិស័ទរបស់លោកហើយ នាំភិក្ខុទាំងនោះទៅអស់ នៅសល់តែវិហារទទេ ចំណែកលោករវល់ដេកលក់ដល់កាលណាទៀត ហើយកន្ត្រាក់សំពត់ដណ្តប់របស់ទេវទត្តចេញ យកកែងជើងជាក់កណ្តាលដើមទ្រូង ដូចដំដែកគោលនឹងជញ្ជាំងផ្ទះ ភ្លាមនោះឯងឈាមក៏ហូរចេញអំពីមាត់របស់ទេវទត្ត តាំងអំពីពេលនោះមក ទេវទត្តក៏ធ្លាក់ខ្លួនឈឺ ។

ព្រះបរមសាស្តាត្រាស់សួរព្រះសារីបុត្តថា ម្នាលសារីបុត្ត វេលាដែលអ្នកនាំគ្នាទៅ ទេវទត្តកំពុងធ្វើអ្វី?

ព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទេវទត្តឃើញខ្ញុំព្រះអង្គទាំងពីរហើយ គិតនឹងធ្វើលំនាំដូចព្រះអង្គ កាលសម្តែងអាកប្ប-កិរិយាដូចព្រះសុគត ក៏ដល់នូវការវិនាសធំ ។ ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលទេវទត្តធ្វើតាម

តថាគតហើយដល់នូវសេចក្ដីវិនាសនោះ សូម្បីក្នុងកាលមុនក៏ធ្លាប់ដល់នូវសេចក្ដីវិនាសហើយដែរ កាលព្រះថេរៈក្រាបទូលអារាធនា ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាកេសរសីហរាជ នៅក្នុងគុហាមាស ក្នុងព្រៃហិមពាន្ត ។ ថ្ងៃមួយ ចេញអំពីគុហារលាស់កាយសម្លឹងមើលទិសទាំង ៤ បន្លឺសីហនាទ ហើយចេញទៅរកអាហារ សម្លាប់ក្របីធំមួយស៊ីសាច់ ហើយចុះកាន់ស្រះផឹកទឹកដែលមានពណ៌ដូចកែវមណីពេញពោះហើយដើរសំដៅទៅគុហាវិញ ។ គ្រានោះ ចចកមួយខ្វាយខ្វល់ដើររកចំណី ពើបនឹងរាជសីហ៍ភ្លាមមិនអាចនឹងគេចចេញទៅបាន ក៏ដេកក្រាបចុះជិតជើងខាងមុខរាជសីហ៍ កាលរាជសីហ៍សួរថា នែចចកមានការអ្វី ? ក៏ប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំមកទីនេះ ដោយមានបំណងថានឹងបម្រើលោក ។ រាជសីហ៍ពោលថា ប្រពៃហើយ ចូរបម្រើយើងចុះ យើងនឹងឲ្យអ្នកបានស៊ីសាច់ឆ្ងាញ់ៗ ហើយនាំចចកទៅកាន់គុហាមាស ។ ចាប់ពីពេលនោះមកចចកក៏ស៊ីដែលរាជសីហ៍ កន្ទ្រងមកបានពីរ-បីថ្ងៃ ក៏ធាត់ធំឡើង ។ ក្រោយមករាជសីហ៍ដេកនៅក្នុងគុហាប្រាប់វាថា ទៅចុះចចក អ្នកឡើងទៅឈរលើកំពូលភ្នំ ចង់ស៊ីសាច់នៃសត្វណា មានដំរី សេះក្របីជាដើម ដែលត្រាច់ទៅមកនៅជើងភ្នំនេះ ចូរចំណាំសត្វនោះទុក

ហើយមកប្រាប់យើងថា ខ្ញុំចង់ស៊ីសាច់សត្វឯណោះ ហើយចូរប្រាប់ថា លោកចូរបន្ទឺសំឡេងចុះ ដូច្នេះហើយ យើងនឹងសម្លាប់សត្វនោះ ស៊ីសាច់ឆ្ងាញ់ៗ ហើយចែកឲ្យអ្នកខ្លះ ។ ចចកក៏ឡើងទៅកាន់កំពូលភ្នំរកមើលហ្វូងម្រឹគនានា លុះនឹកចង់ស៊ីសាច់សត្វប្រភេទណា ក៏ចូលទៅកាន់គុហាមាសប្រាប់សត្វនោះដល់រាជសីហ៍ ហើយក្រាបចុះជិតជើងរាជសីហ៍ពោលថា បពិត្រលោកម្ចាស់ សូមលោកបន្ទឺសំឡេងចុះ ។ រាជសីហ៍រត់ទៅយ៉ាងលឿន ប្រសិនបើឃើញដំរីចុះប្រេង ក៏សម្លាប់ឲ្យស្លាប់នៅទីនោះតែម្តង ហើយខ្លួនឯងស៊ីសាច់ល្អៗខ្លះ ឲ្យចចកខ្លះ ចចកស៊ីសាច់ឆ្អែតហើយចូលគុហាដេកលក់យ៉ាងស្រួល ។

លុះវេលាកន្លងយូរទៅ ចចកក៏កើតមានះថា សូម្បីខ្លួនអញក៏ជាសត្វជើង ៤ ដែរ ហេតុអ្វីចាំបាច់ឲ្យអ្នកដទៃជួយចិញ្ចឹមរាល់ៗ ថ្ងៃ ចាប់ពីថ្ងៃនេះទៅ អញនឹងសម្លាប់ដំរីជាដើមស៊ីសាច់ សូម្បីតែរាជសីហ៍ដែលជាស្តេចម្រឹគ ក៏អាស្រ័យអញជួយពោលថា បពិត្រលោកម្ចាស់ សូមលោកបន្ទឺសំឡេងចុះ ដូច្នេះប៉ុណ្ណោះ ក៏សម្លាប់ដំរីទាំងឡាយបាន អញត្រូវឲ្យរាជសីហ៍និយាយនឹងអញខ្លះថា នែចចកដ៏ចម្រើន អ្នកចូរបន្ទឺសំឡេងចុះ ដូច្នេះក៏នឹងសម្លាប់ដំរីមួយស៊ីសាច់បាន ។ ចចកនោះ លុះគិតដូច្នោះហើយ ក៏ចូលទៅរករាជសីហ៍ ហើយពោលថា បពិត្រលោកម្ចាស់ ខ្ញុំស៊ីសាច់ដំរីដែលលោកសម្លាប់មកយូរហើយ ខ្ញុំចង់សម្លាប់ដំរីមួយស៊ីសាច់ដែរ ហេតុ

នោះ ខ្ញុំសូមដេកក្នុងគុហាមាសលើទីដេករបស់លោក សូមលោកជួយមើលដំរីឈ្មោលដែលត្រាច់ទៅមកនៅតាមជើងភ្នំ ហើយមកកាន់សម្នាក់ខ្ញុំប្រាប់ថា នែចចក អ្នកចូរបន្លឺសំឡេងចុះ សូមត្រឹមតែប៉ុណ្ណោះឯង លោកកុំកំណាញ់ឡើយ ។ ពេលនោះ រាជសីហ៍ក៏ប្រាប់ចចកនោះថា នែចចក អ្នកមិនអាចនឹងសម្លាប់ដំរីបានទេ ធម្មតាចចកដែលកើតក្នុងត្រកូលសីហៈអាចសម្លាប់ដំរីស៊ីសាច់បាន មិនមានក្នុងលោកឡើយ អ្នកកុំពេញចិត្តយ៉ាងនេះឡើយ រង់ចាំស៊ីសាច់ដំរីដែលយើងសម្លាប់បានហើយ សូម្បីរាជសីហ៍ប្រាប់យ៉ាងនេះក៏ដោយ ក៏ចចកនោះមិនលះបង់ការតាំងចិត្ត នៅតែរំអុកដដែល ។ រាជសីហ៍ កាលមិនអាចហាមចចកបានក៏ទទួលពាក្យ ហើយពោលថា បើដូច្នោះ អ្នកចូរទៅកាន់លំនៅរបស់យើង ដេករង់ចាំចុះ ឲ្យចចកដេកក្នុងគុហាមាស ខ្លួនឯងរង់ចាំមើលដំរីចុះប្រេងដែលដើរនៅតាមជើងភ្នំ ហើយទៅកាន់មាត់ទ្វារគុហាប្រាប់ថា នែចចក អ្នកចូរបន្លឺសំឡេងចុះ ។ ចចកចេញអំពីគុហារលាស់កាយ សម្លឹងមើលទិសទាំងបួន លូបីដង រួចគិតថា អញត្រូវលោតចុះឲ្យចំត្រង់ក្បាលដំរីចុះប្រេង ក៏ភ្លាត់ធ្លាក់ទៅក្បែរជើងដំរី ដំរីលើកជើងស្តាំជាន់ក្បាល លលាដ៍ក្បាលបែកជាលម្អិតតូចធំ ពេលនោះ ដំរីយកជើងលញ់រាងកាយរបស់ចចកនោះធ្វើជាដុំៗ ជុះអាចម៍ដាក់ចចកហើយបន្លឺកោញ្ចនាទ រួចចូលព្រៃទៅ ។ ព្រះបរម-ពោធិសត្វឃើញការប្រព្រឹត្តិទៅដូច្នោះ ក៏ពោលថា នែចចក ពេលនេះអ្នក

*ចូរបន្ទឺសំឡេងចុះ ដូច្នេះហើយ ពោលគាថានេះថា*

**លសី ច តេ និប្ផលិតា មត្ថកោ ច បទាលិតោ**

**សព្វា តេ ផាសុកា ភគ្គា អជ្ជ ខោ ត្វំ វិរោចសីតិ ។**

*ខួរក្បាលរបស់អ្នកធ្លាយចេញផង រលាក្បាលរបស់អ្នកបែក ផង ឆ្អឹងជំនីរទាំងអស់របស់អ្នកដំរីបំបាក់ហើយផង ក្នុងថ្ងៃ នេះ អ្នកនៅរុងរឿងអ្វីទៀត ។*

*បណ្ដាបទទាំងនេះ បទថា* **លសី** *ប្រែថា ខួរក្បាល ។*

*បទថា* **និប្ផលិតា** *ប្រែថា ហូរចេញហើយ ។*

*ព្រះបរមពោធិសត្វពោលគាថានេះហើយ បិតនៅរហូតអស់អាយុ ហើយក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំ ជាតកថា ចចកក្នុងកាលនោះ បានមកជាទេវទត្ត ចំណែករាជសីហ៍ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា វិរោចនជាតក ទី ៣ ។

# អដ្ឋកថា នង្គុដ្ឋជាតក ទី ៤

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធតបៈខុសរបស់ពួកអាជីវក ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ពហុម្បេតំ អសព្ភិ ជាតវេទ** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលនោះ ពួកអាជីវកនាំគ្នាប្រព្រឹត្តតបៈខុសមានប្រការផ្សេងៗ នៅខាងក្រោយវត្តជេតពន ភិក្ខុទាំងឡាយចំនួនច្រើនឃើញតបៈខុសមានដូចជា **ឧក្កុដិកប្បធាន** (តាំងចិត្តអង្គុយច្រហោង) **វគ្គុលិវត្ត** ( ធ្វើដូចសត្វប្រចៀវ ) **កណ្ដកាបស្សយ** ( ដេកលើបន្លា) **បញ្ចតបម** ( ឆ្អើរភ្លើង៥គំនរ ) ជាដើម របស់ពួកនោះ នាំគ្នាទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កុសល ឬសេចក្ដីចម្រើនអាស្រ័យតបៈដែលខុសទាំងនេះ នឹងអាចប្រព្រឹត្តទៅបានឬ ?

ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុសលឬសេចក្ដីចម្រើន អាស្រ័យតបៈដែលខុសយ៉ាងនេះមិនមានឡើយ ក្នុងកាលមុន បណ្ឌិតសម្គាល់ថា អាស្រ័យតបៈយ៉ាងនេះ កុសលឬសេចក្ដីចម្រើនគង់មាន បានកាន់យកភ្លើងប្រចាំកំណើតចូលព្រៃ មិនជួបប្រសព្វសេចក្ដីចម្រើនអ្វីឡើយ ដោយអំណាចការបូជាភ្លើងជាដើម ទើបយកទឹកពន្លត់ភ្លើង បំពេញកសិណបរិកម្ម ញុំាំងអភិញ្ញាសមាបត្តិឲ្យកើតឡើង ក្រោយអំពីចុតិបានទៅកាន់ព្រហ្មលោក ហើយទ្រង់ក៏នាំយករឿងក្នុងអតីតមក

សម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ ក្នុងថ្ងៃដែលលោកប្រសូតនោះ មាតាបិតាក៏ដុតភ្លើងប្រចាំកំណើតតម្កល់ទុកឲ្យ ។ លុះកុមារអាយុបាន ១៦ ឆ្នាំ មាតាបិតាប្រាប់ថា នែកូន ក្នុងថ្ងៃដែលកូនកើតនោះ មាតាបិតាបានដុតភ្លើងទុកឲ្យ ប្រសិនបើកូនប្រាថ្នានឹងគ្រប់គ្រងផ្ទះ ចូររៀនវេទទាំង ៣ ឬមិនដូច្នោះ បើប្រាថ្នានឹងទៅកាន់ព្រហ្មលោកក៏ចូរកាន់យកភ្លើងចូលព្រៃបម្រើភ្លើង ធ្វើឲ្យមហាព្រហ្មប្រោសប្រាណ ហើយក៏នឹងជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខបាន ។

ព្រះមហាសត្វពោលថា ខ្ញុំមិនត្រូវការនៅគ្រប់គ្រងផ្ទះទេ ។ ពោលហើយក៏កាន់ភ្លើងចូលព្រៃសាងអាស្រម បម្រើភ្លើងនៅក្នុងព្រៃ ។ ថ្ងៃមួយបានទទួលជំនូនគឺគោក្នុងស្រុកជាយដែន ទើបដឹកគោទៅកាន់អាស្រម គិតថា អញនឹងឲ្យព្រះអគ្គីអ្នកមានជោគឆាន់សាច់គោ ។ ពេលនោះព្រះមហាសត្វមានសេចក្តីត្រិះរិះដូច្នេះថា ទីនេះមិនមានអំបិល ព្រះអគ្គីអ្នកមានជោគនឹងមិនអាចឆាន់សាច់ដែលមិនមានរសប្រៃបាន អញនឹងទៅរកអំបិលមកអំពីភូមិ ឲ្យព្រះអគ្គីអ្នកមានជោគឆាន់សាច់ដែលមានរសប្រៃ ព្រះមហាសត្វក៏ចងគោទុកនៅទីនោះ ហើយទៅភូមិដើម្បីរកអំបិល ។ ពេលដែលព្រះពោធិសត្វទៅនោះ មានព្រានព្រៃច្រើននាក់មកដល់ទីនោះ

ឃើញគោហើយសម្លាប់អាំងសាច់ស៊ី ចោលកន្ទុយ កែងជើងនិងស្បែកនៅទីនោះឯង ហើយយកសាច់ដែលសល់ទៅជាមួយផង ។ ព្រះពោធិសត្វមកវិញហើយ ឃើញគោនៅសល់តែស្បែកជាដើម ក៏គិតថា ព្រះអគ្គីអ្នកមានជោគនេះ សូម្បីតែវត្ថុរបស់ខ្លួនក៏រក្សាមិនបាន នឹងរក្សាអញបានដូចម្តេច ការបម្រើភ្លើងនេះឥតប្រយោជន៍ កុសលឬសេចក្តីចម្រើនមានការបូជាភ្លើងជាហេតុគង់មិនមានដោយពិត ព្រះមហាសត្វក៏អស់ការពេញចិត្តក្នុងការបម្រើភ្លើង ទើបពោលថា បពិត្រព្រះអគ្គីដ៏ចម្រើន សូម្បីតែវត្ថុរបស់ខ្លួនលោកក៏មិនអាចរក្សាទុកបាន តើរក្សាខ្ញុំបានដូចម្តេចទៅ សាច់មិនមានចូរត្រេកអរត្រឹមតែប៉ុណ្ណោះចុះ កាលនឹងបោះកន្ទុយ (គោ) ជាដើមចូលទៅក្នុងគំនរភ្លើង បានពោលគាថានេះថា

**ពហុម្បេតំ អសព្ភិ ជាតវេទ**
**យន្តំ វាលធិនាភិបូជយាម**
**មំសារហស្ស នត្ថជ្ជ មំសំ**
**នង្គុដ្ឋម្បិ ភវំ បដិគ្គហាតុ្វតិ ។**

ម្នាលភ្លើង ជាអសប្បុរស យើងនឹងបូជាអ្នកដោយកន្ទុយណា កន្ទុយប៉ុណ្ណោះច្រើនហើយ ក្នុងថ្ងៃនេះ សាច់មិនមានដល់អ្នកដ៏គួរដល់សាច់ទេ អ្នកដ៏ចម្រើន ចូរទទួលយកតែកន្ទុយចុះ ។

*បណ្ដាបទទាំងនោះ បទថា* **ពហុម្បេតំ** *សេចក្ដីថា សូម្បីវត្ថុត្រឹមតែប៉ុណ្ណេះ ក៏ឈ្មោះថាច្រើនទៅហើយ ។*

*បទថា* **អសត្ថិ** *សេចក្ដីថា ភ្លើងជាអសប្បុរស គឺមិនមែនវត្ថុល្អ ។ ព្រាហ្មណ៍ហៅភ្លើងថា ជាតវេទ អធិប្បាយថា ភ្លើងគ្រាន់តែឆេះឡើង ក៏អាចដឹងបាន គឺប្រាកដឲ្យឃើញទូទៅ ព្រោះហេតុដូច្នោះ ទើបលោកហៅថា ជាតវេទ ។*

*ដោយបទថា* **យដ្តំ វាលជិជាកិបូជយាម** *សេចក្ដីថា សូម្បីការដែលយើងបូជាអ្នកដែលមានដោគ ដែលមិនអាចនឹងរក្សាវត្ថុរបស់ខ្លួនទុកបានក្នុងថ្ងៃនេះ ដោយកន្ទុយត្រឹមតែប៉ុណ្ណេះ ក៏ច្រើនទៅហើយសម្រាប់អ្នក ។*

*បទថា* **មំសារហស្ស** *សេចក្ដីថា ថ្ងៃនេះសាច់មិនមានសម្រាប់អ្នកដែលពេញចិត្តសាច់ ។*

*បទថា* **ឯង្គុដ្ឋម្បិ ភវំ បដិគ្គហាតុ** *សេចក្ដីថា កាលអ្នកមិនអាចនឹងរក្សាវត្ថុរបស់ខ្លួនបាន ក៏អញ្ជើញអ្នកដ៏ចម្រើនទទួលត្រឹមតែកន្ទុយព្រមទាំងឆ្អឹងនិងស្បែកនេះចុះ ។*

*ព្រះមហាសត្វ លុះពោលយ៉ាងនេះហើយ ក៏យកទឹកពន្លត់ភ្លើងហើយបួសជាតាបស ញ៉ាំងអភិញ្ញានិងសមាបត្តិឲ្យកើតឡើង ជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។*

ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា តាបសអ្នកពន្លត់ភ្លើងក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា នង្គុដ្ឋជាតក ទី ៤ ។

# អដ្ឋកថា រាធជាតក ទី ៥

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមនៃបុរាណទុតិយិកា គឺភរិយាអំពីដើមរបស់ភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន ត្វំ រាធ វិជានាសិ** ដូច្នេះជាដើម ។

រឿងក្នុងបច្ចុប្បន្ន នឹងមានជាក់ច្បាស់នៅក្នុង **ឥន្ទ្រិយជាតក** ចំណុចដែលប្លែកគឺ ព្រះបរមសាស្តាហៅភិក្ខុនោះមក ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ធម្មតាមាតុគ្រាមជាបុគ្គលដែលមិនមានអ្នកណារក្សាបាន សូម្បីនឹងរក្សាការពារយ៉ាងណាក៏ដោយ ក៏មិនអាចរក្សាការពារបាន ម្នាលភិក្ខុ ក្នុងកាលមុន សូម្បីអ្នកដាក់ការការពារចាំមើលថែមាតុគ្រាម ប៉ុន្តែមិនអាចរក្សាបានឡើយ ពេលនេះ អ្នកនឹងរក្សាបានដូចម្តេច ? ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងកំណើតសត្វសេក ។

ព្រាហ្មណ៍ម្នាក់ដែលនៅក្នុងដែនកាសី ចិញ្ចឹមព្រះពោធិសត្វនិងប្អូនប្រុសរបស់ព្រះពោធិសត្វទុកដូចកូន ។ បក្សីទាំងពីរនោះ ព្រះពោធិសត្វមានឈ្មោះថា បោដ្ឋបាទៈ ប្អូនប្រុសមានឈ្មោះថា រាធៈ ។ ភរិយារបស់ព្រាហ្មណ៍នោះ ជាស្ត្រីមិនមានមារយាទ ទ្រុស្តសីល កាលព្រាហ្មណ៍ចេញទៅជួញ ក៏ផ្ដាំសេកទាំងពីរនាក់បងប្អូនថា នៃអ្នកទាំងពីរ ប្រសិនបើព្រាហ្មណីម្ដាយរបស់អ្នកប្រព្រឹត្តមិនល្អ ម្ទិកម្ទ៉ក់ដាក់ប្រុសដទៃ អ្នកចាំហាមប្រាមឲ្យផង ។ សេកពោធិសត្វពោលថា បាទលោកឪពុក ប្រសិនបើអាចហាមបាន ខ្ញុំជួយហាមឃាត់ជូន បើហាមមិនបានក៏ត្រូវនៅស្ងៀម ។ ព្រាហ្មណ៍ប្រគល់ព្រាហ្មណីឲ្យដល់សេកទាំងពីរយ៉ាងនេះហើយ ក៏ចេញទៅជួញ ។ តាំងពីថ្ងៃដែលព្រាហ្មណ៍ចេញទៅនោះ ព្រាហ្មណីក៏ផ្ដើមប្រព្រឹត្តក្បត់ចិត្តស្វាមីខ្លួន ទាំងមនុស្សដែលចូលទៅនិងមនុស្សដែលចេញមក ប្រមាណមិនបាន រាធៈឃើញការប្រព្រឹត្តិរបស់នាងក៏ពោលនឹងព្រះមហាសត្វថា បពិត្របង ឪពុករបស់យើងបានផ្ដាំមុនចេញទៅថា ប្រសិន-បើម្ដាយរបស់អ្នកទាំងពីរប្រព្រឹត្តមិនល្អ ប្រព្រឹត្តមិនប្រពៃ អ្នកទាំងពីរជួយហាមផង ផ្ដាំដូច្នេះហើយទើបទៅ ពេលនេះម្ដាយរបស់យើងកំពុងប្រព្រឹត្តមិនល្អ ប្រព្រឹត្តមិនប្រពៃ យើងនាំគ្នាហាមគាត់ចុះ ។ ព្រះបរមពោធិសត្វពោលដាស់តឿនថា នៃរាធៈ អ្នកនិយាយដោយការល្ងង់ខ្លៅ ព្រោះការមិនឈ្លាសវៃរបស់ខ្លួនពិតៗ ធម្មតាមាតុគ្រាម សូម្បីបុគ្គលពនាំទៅក៏មិន

អាចរក្សាទុកបានដែរ មិនសមគួរនឹងយើងធ្វើអំពើដែលមិនអាចធ្វើបាន ហើយពោលគាថានេះថា

**ន ត្វំ រាធ វិជានាសិ អឌ្ឍរត្តេ អនាគតេ**
**អព្យាយតំ វិលបសិ វិរត្តេ កោសិយាយនេតិ ។**

ម្នាលរាធៈ អ្នករមែងមិនដឹងច្បាស់ថា ពួកមនុស្សប៉ុណ្ណោះ ក្នុងពេលពាក់កណ្ដាលអធ្រាត្រមិនទាន់មកដល់ ពោលចរចានូវពាក្យមិនប្រាកដ នឹងនាងព្រាហ្មណីជាកោសិយគោត្រ អ្នកមិនមានតម្រេក ( នឹងស្វាមីខ្លួន ) ។

បណ្ដាបទទាំងនោះ បទថា **ន ត្វំ រាធ វិជានាសិ អឌ្ឍរត្តេ អនាគតេ** សេចក្ដីថា នែរាធៈ អ្នកមិនដឹងអ្វីឬ ក្នុងបឋមយាម ប៉ុណ្ណោះមនុស្សដែលមកដល់ មានដល់ម្ល៉េះទៅហើយ តើក្នុងយាមខាងមុខ អ្នកណានឹងដឹងថា មនុស្សប៉ុន្មាននាក់ទៀត នឹងនាំគ្នាមក ។

បទថា **អព្យាយតំ វិលបសិ** សេចក្ដីថា អ្នកកុំនិយាយផ្ដេសផ្ដាស ព្រោះការល្ងង់ខ្លៅ ។

បទថា **វិរត្តេ កោសិយាយ** សេចក្ដីថា ព្រាហ្មណីកោសិយានីមាតារបស់យើង អស់សេចក្ដីស្រឡាញ់ហើយ គឺមិនមានសេចក្ដីស្រឡាញ់ក្នុងបិតារបស់យើង បើគាត់នៅមានសេចក្ដីអាឡោះអាល័យ ឬសេចក្ដីស្រឡាញ់ក្នុងបិតា ក៏មិនគួរនឹងប្រព្រឹត្តមិនល្អ មិនប្រពៃយ៉ាងនេះឡើយ

*ដោយព្យញ្ជនៈ ( ក្នុងគាថា ) ទាំងនេះ ព្រះបរមពោធិសត្វប្រកាសសេចក្ដីដូចពណ៌នាមកនេះ ។*

*លុះព្រះមហាសត្វប្រកាសយ៉ាងនេះហើយ មិនព្រមឲ្យប្អូនប្រុសនិយាយហាមព្រាហ្មណី នាងក៏ប្រព្រឹត្តក្បត់ស្វាមីតាមអំពើចិត្ត ដរាបណាដែលព្រាហ្មណ៍មិនទាន់ត្រឡប់មក ។ ព្រាហ្មណ៍មកវិញហើយ សួរសេកឈ្មោះពោដ្ឋបាទៈថា នែកូន ម្ដាយរបស់អ្នកទាំងពីរដូចម្ដេចដែរ ? ព្រះ-ពោធិសត្វប្រាប់រឿងពិតទាំងអស់ដល់ព្រាហ្មណ៍ ហើយពោលថា បពិត្រលោកឪពុក ស្ត្រីប្រព្រឹត្តអាក្រក់យ៉ាងនេះ ពុកចិញ្ចឹមទុកធ្វើអ្វី ? ហើយពោលតទៅថា បពិត្រពុក ចាប់ពីពេលដែលខ្ញុំទាំងពីរពោលទោសម្ដាយហើយ ក៏មិនអាចនៅទីនេះបាន ក្រាបចុះជិតជើងព្រាហ្មណ៍ហើយ ក៏ហើរចូលព្រៃ ។*

*ព្រះបរមសាស្ដា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈ លុះចប់សច្ចៈ ភិក្ខុអ្នកអផ្សុកចង់សឹកនោះបានសម្រេចសោតាបត្តិផល ។ ទ្រង់ប្រជុំជាតកថា ព្រាហ្មណ៍និងព្រាហ្មណីក្នុងកាលនោះ បានមកជាគូស្វាមីភរិយាមួយគូនេះឯង សេកឈ្មោះ រាធៈបានមកជាអានន្ទ ចំណែកសេកឈ្មោះពោដ្ឋបាទៈ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា រាធជាតក ទី ៥ ។

# អដ្ឋកថា ភាកជាតក ទី ៦

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចាស់ៗ ច្រើនរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **អបិ ធុហាធុកា សន្តា** *ដូច្នេះជាដើម ។*

*បានឮថា ភិក្ខុទាំងនោះ កាលនៅជាគ្រហស្ថ ជាកុដុម្ពិកៈនៅក្រុងសាវត្ថីមានទ្រព្យច្រើន ជាសម្លាញ់នឹងគ្នា ធ្វើបុណ្យរួមគ្នា ស្តាប់ព្រះធម្មទេសនារបស់ព្រះបរមសាស្តាហើយត្រិះរិះថា ពួកយើងជាមនុស្សចាស់ នឹងមានប្រយោជន៍អ្វីដល់ពួកយើងដោយការនៅគ្រប់គ្រងផ្ទះ ពួកយើងនឹងបួសក្នុងព្រះពុទ្ធសាសនាដែលគួរជាទីត្រេកអរ ក្នុងសម្នាក់ព្រះបរមសាស្តានឹងធ្វើទីបំផុតនៃសេចក្តីទុក្ខ ។ លុះគិតដូច្នេះហើយ ម្នាក់ៗលើកសម្បត្តិទាំងពួងឲ្យដល់កូនចៅជាដើម លះបង់ពួកញាតិដែលមានមុខជោកដោយទឹកភ្នែក ទូលសូមបព្វជ្ជាអំពីព្រះសម្មាសម្ពុទ្ធ លុះបួសហើយមិនបានបបួលគ្នាបំពេញសមណធម៌ដែលសមគួរដល់បព្វជ្ជាទេ សូម្បីព្រះធម៌ក៏មិនសិក្សាព្រោះភាពជាមនុស្សចាស់ សូម្បីបួសហើយក៏ដោយ ក៏ដូចកាលដែលនៅជាគ្រហស្ថដែរ ឲ្យមនុស្សសាងបណ្ណសាលានៅខាងចុងវិហារគង់នៅរួមគ្នា សូម្បីកាលត្រាច់ទៅបិណ្ឌបាតក៏មិនទៅកាន់ទីដទៃ ដោយច្រើនបបួលគ្នាទៅឆាន់នៅផ្ទះបុត្តភរិយារបស់ខ្លួននោះឯង បណ្តាភរិយាទាំងនោះ ភរិយាចាស់របស់ព្រះថេរៈចាស់មួយរូប មានឧបការៈដល់ព្រះ-*

ថេរៈចាស់ៗ ទាំងអស់ ហេតុនោះ សូម្បីព្រះថេរៈដ៏សេស ក៏យកអាហារ ដែលខ្លួនបានមកឆាន់ក្នុងផ្ទះរបស់នាងតែម្នាក់ ចំណែកនាងដទៃក៏ប្រគេន ម្ហូបសម្ងួតតាមដែលខ្លួនធ្វើដល់ព្រះថេរៈទាំងនោះ ក្រោយមកនាងនោះធ្វើ កាលកិរិយាដោយរោគាពាធណាមួយ ។ គ្រានោះ ព្រះថេរៈចាស់ៗទាំង- នោះ នាំគ្នាទៅកាន់វិហារ ឱបគ្នាយំរៀបរាប់នៅខាងចុងវិហារថា ឧបាសិកា អ្នកមានថ្វីដៃដ៏ពិសេសស្លាប់ហើយ ។ ចំណែកភិក្ខុទាំងឡាយស្តាប់សំឡេង ភិក្ខុចាស់ទាំងនោះហើយ ក៏មកប្រជុំគ្នាអំពីទីផ្សេងៗ សួរថា អាវុសោ ហេតុ អ្វីលោកទាំងឡាយមកយំរៀបរាប់យ៉ាងនេះ? ភិក្ខុចាស់ទាំងនោះឆ្លើយថា ភរិយាចាស់នៃសម្លាញ់របស់ពួកយើង អ្នកមានថ្វីដៃខាងធ្វើម្ហូបឆ្ងាញ់ស្លាប់ ហើយ នាងមានឧបការៈដល់ពួកយើងច្រើនណាស់ ទីនេះនឹងរកអ្នកណា បានដូចនាងទៅ ហេតុនេះទើបពួកខ្ញុំនាំគ្នាយំ ។ ភិក្ខុទាំងឡាយឃើញ ការវិបរិតរបស់ភិក្ខុចាស់ទាំងនោះហើយ នាំគ្នាលើករឿងឡើងសន្ទនាក្នុង ធម្មសភាថា អ្នកមានអាយុទាំងឡាយ ដោយហេតុនេះ ព្រះថេរៈចាស់ៗ ទាំងឡាយឱបគ្នាយំនៅខាងចុងវិហារ ។ ព្រះបរមសាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយ អង្គុយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះ ក្រាបទូលឲ្យទ្រង់ ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេល នេះប៉ុណ្ណោះទេ ដែលភិក្ខុទាំងនោះយំកន្ទក់កន្ទេញព្រោះស្ត្រីនោះស្លាប់

សូម្បីក្នុងកាលមុន ភិក្ខុទាំងនេះ អាស្រ័យស្ត្រីនេះ ដែលកើតក្នុងកំណើតក្អែកហើយស្លាប់ក្នុងសមុទ្រ ក៏រួមប្រជុំគ្នាគិតថា ពួកយើងនឹងបាចទឹកសមុទ្រ នាំមេក្អែកឡើងមកឲ្យទាល់តែបាន លុះគិតដូច្នេះហើយ នាំគ្នាព្យាយាមបាចទឹកសមុទ្រ ព្រោះបានបណ្ឌិតជាទីអាស្រ័យ ទើបមានជីវិតដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាទេវតារក្សាសមុទ្រ ។ គ្រានោះ មានក្អែកមួយនាំមេក្អែកដែលជាប្រពន្ធរបស់ខ្លួនស្វែងរកចំណីបានទៅដល់ឆ្នេរសមុទ្រ ។ កាលនោះ ពួកជននាំគ្នាធ្វើពលិកម្មដល់ស្ដេចនាគដោយទឹកដោះ បាយាស ត្រី សាច់ និងសុរាជាដើម ហើយនាំគ្នាចៀសចេញទៅ ។ ពេលនោះ ក្អែកមួយហើរទៅដល់កន្លែងធ្វើពលិកម្មនោះ ឃើញទឹកដោះជាដើម ក៏នាំក្អែកញីផឹកទឹកដោះ ស៊ីបាយាស ត្រី សាច់ជាដើម ហើយផឹកសុរាយ៉ាងច្រើន កាលស្រវឹង គិតនឹងលេងទឹកសមុទ្រ ទំលើឆ្នេរខ្សាច់ប្រាថ្នានឹងងូតទឹកសមុទ្រ ពេលនោះ រលកមួយបោកមក នាំយកមេក្អែកនោះចូលទៅក្នុងសមុទ្រ ត្រីមួយក៏ត្របាក់មេក្អែកនោះលេបចូលទៅក្នុងពោះ ក្អែកឈ្មោលយំរៀបរាប់ថា ប្រពន្ធរបស់ខ្ញុំស្លាប់ហើយ ។ ក្អែកទាំងឡាយដែលជាសម្លាញ់ បានឮសំឡេងយំរៀបរាប់របស់ក្អែកនោះក៏មកប្រជុំគ្នាសួរថា ហេតុអ្វីទើបអ្នកយំ ? ក្អែកនោះប្រាប់ថា ស្ត្រីដែលជាទី

ស្រឡាញ់របស់អ្នកទាំងឡាយកំពុងផ្លូតទឹកនៅមាត់សមុទ្រ រលកក៏នាំយកទៅ ក្អែកទាំងនោះគ្រប់គ្នាក៏យំរៀបរាប់ដោយមានសំឡេងតែមួយ ។ គ្រានោះ ហ្វូងក្អែកទាំងនោះមានគំនិតដូច្នេះថា ជម្មតាទឹកសមុទ្រនេះ នឹងសំខាន់ជាងពួកយើងឬ ពួកយើងត្រូវនាំគ្នាបាចទឹកសមុទ្រនេះឲ្យរីង នាំយកស្ត្រីដែលជាសម្លាញ់ចេញមកឲ្យបាន ក្អែកទាំងនោះនាំគ្នាបៀមទឹកពេញមាត់យកទៅខ្ជាក់ចោលខាងក្រៅសមុទ្រ ហើយកាលកស្ងួតព្រោះទឹកប្រៃក៏នាំគ្នាឡើងទៅលើគោក ក្អែកទាំងនោះ កាលចង្កាពោយ ចំពុះស្ងួតស្វាំង ភ្នែកក្រហម ក៏ហត់នឿយអស់កម្លាំងទាំងអស់គ្នា ទើបហៅគ្នាមកប្រាប់អំពីសេចក្ដីទុក្ខថា នែគ្នាយើង ពួកយើងនាំគ្នាបៀមទឹកអំពីសមុទ្រទៅចោលខាងក្រៅ យើងបៀមទឹកទៅហើយ មហាសមុទ្រនៅតែពេញដដែល ពួកយើងមិនអាចធ្វើឲ្យសមុទ្ររីងបានទេ ដូច្នេះហើយ ពោលគាថានេះថា

**អបិ នុ ហនុកា សន្តា មុខញ្ច បរិសុស្សតិ**
**ឱរមាម ន ចារេម បូរតេវ មហោទធីតិ ។**

*អើ ចង្កាយើងក៏ពោយ ទាំងមាត់ក៏ស្ងួតក្រៀមក្រោះ*
*យើងមិនអាចបាចទឹក ក្នុងសមុទ្រឲ្យរីងបានទេ ព្រោះ*
*មហាសមុទ្រនៅតែពេញដដែល ។*

បណ្ដាបទទាំងនោះ បទថា **អបិ នុ ហនុកា សន្តា** សេចក្ដី

ថា អើ ចង្ការរបស់យើងរោយខ្លាំងណាស់ ។

បទថា **ឱរមាម ន ចារេម** សេចក្តីថា ពួកយើងនាំគ្នាបៀមទឹកអំពីមហាសមុទ្រ ទៅចោលតាមកម្លាំងរបស់ខ្លួន ក៏មិនអាចធ្វើឲ្យរីងបាន ព្រោះអន្លង់ទឹកធំនៅតែពេញដដែល ។

លុះពោលយ៉ាងនេះហើយ ក្អែកទាំងអស់នោះ មួយៗ ក៏និយាយប៉ប៉ាច់ប៉ប៉ោចថា ចំពុះនៃមេក្អែកនោះ ល្អបែបនេះ ភ្នែកមូលយ៉ាងនេះ ពណ៌សម្បុរសណ្ឋានស្រស់ស្អាតយ៉ាងនេះ សំឡេងពីរោះយ៉ាងនេះ ព្រោះអាស្រ័យសមុទ្រដែលជាចោរនេះ មេក្អែករបស់ពួកយើងបានបាត់ទៅហើយ ។ ទេវតាប្រចាំសមុទ្រសម្តែងរូបគួរខ្លាច ដេញហ្វូងក្អែកដែលកំពុងយំរៀបរាប់កន្ទក់កន្ទេញយ៉ាងនេះ ឲ្យចៀសចេញទៅ សួស្តីបានកើតមានដល់ហ្វូងក្អែកដោយប្រការដូច្នេះ ។

ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា មេក្អែកក្នុងកាលនោះ បានមកជាភរិយាចាស់នេះ ក្អែកឈ្មោលបានមកជាភិក្ខុចាស់ ហ្វូងក្អែកដ៏សេស បានមកជាភិក្ខុចាស់ៗដ៏សេស ចំណែកទេវតារក្សាសមុទ្រ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា កាកជាតក ទី ៦ ។

# អដ្ឋកថា បុប្ផរត្តជាតក ទី ៧

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកអផ្សុកមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **ឩយិធំ ទុក្ខំ អធុំ ទុក្ខំ** *ដូច្នេះជាដើម ។*

*សេចក្តីសង្ខេបថា ភិក្ខុនោះ កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកចង់សឹកពិតមែនឬ ? ក៏ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គអផ្សុកចង់សឹកពិតមែន ទ្រង់ត្រាស់សួរទៀតថា អ្នកអផ្សុកព្រោះហេតុអ្វី ? ភិក្ខុនោះក្រាបទូលថា ព្រោះភរិយាចាស់របស់ខ្ញុំព្រះអង្គ ហើយក្រាបទូលតទៅថា បពិត្រព្រះអង្គដ៏-ចម្រើន ស្ត្រីនោះមានថ្ងៃដៃខាងឆ្វេងម្ហូបឆ្ងាញ់ ខ្ញុំព្រះអង្គមិនអាចអត់នាងបានទេ ។ គ្រានោះ ព្រះបរមសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ ស្ត្រីនេះ ធ្វើសេចក្តីវិនាសឲ្យដល់អ្នកតែក្នុងពេលនេះប៉ុណ្ណោះក៏ទេ សូម្បីកាលមុន ព្រោះស្ត្រីនេះជាហេតុ អ្នកក៏ត្រូវដោតដោយឈើអណ្តោត សោក-សៅ ស្រែកយំរកតែនាងប៉ុណ្ណោះ លុះស្លាប់ហើយទៅកើតក្នុងនរក ពេលនេះ ព្រោះហេតុអ្វី អ្នកនៅប្រាថ្នាចង់បានស្រីនោះទៀត លុះត្រាស់ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វសោយព្រះជាតិជាអាកាសដ្ឋទេវតា ។*

គ្រានោះ ក្នុងនគរពារាណសីមានមហោស្រពពាក់កណ្ដាលខែកត្តិក មនុស្សម្នានាំគ្នាតាក់តែងព្រះនគរយ៉ាងស្អាតដូចទេវនគរ មនុស្សទាំងឡាយប្រាថ្នានឹងលេងមហោស្រព ប៉ុន្តែអ្នកក្រម្នាក់ មានសំពត់សាច់ជិតតែមួយគូប៉ុណ្ណោះ បុរសនោះយកមកបោកគក់ឲ្យស្អាត បោកខ្ទាំងពេកទៅ ដាច់ជាចម្រៀកៗ រាប់រយពាន់បំណះ ។ ពេលនោះ ភរិយារបស់បុរសនោះនិយាយនឹងបុរសនោះថា បពិត្រអ្នកជាម្ចាស់ ខ្ញុំចង់ស្លៀកសំពត់ដែលជ្រលក់ដោយទឹកផ្កាដកគាំមួយផ្ទាំង ដណ្ដាប់មួយផ្ទាំង កៀក-កលោកដើរលេងរហូតមួយយប់ទល់ភ្លឺ ។

បុរសនោះពោលថា នែនាងដ៏ចម្រើន យើងក្រនឹងមានសំពត់ជ្រលក់ដោយផ្កាដកគាំពីណាមក នាងចូរស្លៀកដណ្ដាប់សំពត់មួយផ្ទាំងនេះ ហើយទៅដើរលេងចុះ ។

នាងពោលថា កាលបើមិនបានសំពត់ជ្រលក់ដោយទឹកផ្កាដកគាំទេ ខ្ញុំនឹងមិនទៅលេងបុណ្យមហោស្រពទេ អ្នកនាំស្ត្រីដទៃទៅលេងជាមួយចុះ ។

បុរសនោះពោលថា នែនាងដ៏ចម្រើន ហេតុអ្វីក៏នាងបង្ខំខ្ញុំខ្លាំងម៉្លេះ យើងនឹងបានសំពត់នោះ អំពីទីណា ?

នាងពោលថា កាលសេចក្ដីប្រាថ្នារបស់កូនប្រុសមាន ការប្រាថ្នានោះ មិនសម្រេច មិនមានឡើយ ផ្កាដកគាំក្នុងចម្ការរបស់ព្រះរាជាមាន

ច្រើន មិនមែនឬ ?

បុរសនោះពោលថា នែនាងដ៏ចម្រើន ទីនោះមានការការពារតឹងរ៉ឹង ខ្លាំងណាស់ ដូចស្រះបោក្ខរណីដែលអារក្សទឹករក្សាដូច្នោះ យើងមិនអាច ចូលទៅជិតបានទេ នាងកុំពេញចិត្តនឹងសំពត់នោះអី ចូរត្រេកអរតាម មានតាមបានប៉ុណ្ណោះចុះ ។

នាងពោលថា បពិត្រអ្នកជាម្ចាស់ កាលភាពងងឹតមានក្នុងយាម រត្តិកាល ធម្មតាទីដែលកូនប្រុសប្រាថ្នានឹងទៅមិនបាន មិនមានឡើយ ។ ទេវតាអ្នកត្រាច់ទៅក្នុងអាកាសមួយអង្គ ឃើញភ័យក្នុងអនាគតរបស់ ទុគ្គតបុរស ក៏ជួយហាមឃាត់ ។

កាលនាងនិយាយរំអុករឿយៗយ៉ាងនេះ ទុគ្គតបុរសនោះក៏ជឿសម្ដី របស់នាងដោយអំណាចកិលេស លួងលោមនាងថា នែនាងដ៏ចម្រើន នាង នៅជាសុខចុះ កុំគិតថ្វីឡើយ ។ លុះដល់ពេលយប់អធ្រាត្រ ក៏ប្ដូរជីវិត ចេញចាកនគរទៅកាន់ចម្ការផ្កាដកគាំរបស់ព្រះរាជា ឡើងរបងចូលទៅ ក្នុងចម្ការ ។ ពួកអ្នកចាំចម្ការឮសូរសំឡេងឡើងរបង ម្នាក់ៗ ក៏ស្រែកថា ចោរ ចោរ ហើយព័ទ្ធចាប់បាន នាំគ្នាជេរស្ដី រួចចងទុកមួយកន្ទែង លុះភ្លឺ ឡើងក៏នាំទៅថ្វាយព្រះរាជា ។ ព្រះរាជាត្រាស់ថា អ្នកទាំងឡាយ ចូរនាំ បុរសនេះទៅដោតនឹងឈើអណ្ដោតចុះ ។ រាជបុរសក៏ចងស្លាបសេកបុរស នោះរួចនាំចេញចាកក្រុង ដោយមានអ្នកវាយស្គរប្រកាសទោសប្រហារ

ជីវិតតាមទៅជាមួយ ហើយយកទៅដោតនៅលើឈើអណ្ដោត ។ បុរសនោះសោយទុក្ខវេទនាយ៉ាងខ្លាំង ហ្វូងក្អែកនាំគ្នាទៅទំលើក្បាល ចឹកភ្នែកដោយចំពុះដ៏មុតដូចចុងដង្កាប់ ។ បុរសនោះមិនបានយកចិត្តទុកដាក់ចំពោះមហាទុក្ខដល់ម៉្លេះ គិតតែដល់ស្ត្រីនោះប៉ុណ្ណោះ បុរសនោះគិតថាអញខាតបានឱកាសដើរមើលមហោស្រពប្រចាំខែកត្តិក ជាមួយនឹងនាងដែលស្លៀកដណ្ដប់សំពត់ជ្រលក់ដោយផ្កាដកគាំ ប្រើដៃទាំងពីរឱបក្រសោបកៀក-កគ្នាដើរកំសាន្តលេង ហើយពោលគាថានេះថា

**ន យិទំ ទុក្ខំ អទុំ ទុក្ខំ យំ មំ តុទតិ វាយសោ**
**យំ សាមា បុប្ផរត្តេន កត្តិកំ នានុភោសតីតិ ។**

*ក្អែកចោះអញ ដោយហេតុណា ហេតុនេះ មិនជាទុក្ខទេ*
*សេចក្ដីទុក្ខនោះ ក៏មិនមានដល់យើងឡើយ ទុក្ខមានដល់*
*យើងនោះ ត្រង់កិរិយាឈ្មោះសាមា មិនស្លៀកដណ្ដប់*
*សំពត់ ដែលជ្រលក់ដោយទឹកដកគាំ ដើរមើលមហោស្រព*
*ក្នុងខែកត្តិក ។*

បណ្ដាបទទាំងនោះ បទថា **នយិទំ ទុក្ខំ អទុំ ទុក្ខំ យំ មំ តុទតិ វាយសោ** មានអធិប្បាយថា ទុក្ខផ្លូវកាយ ផ្លូវចិត្តដែលត្រូវចាក់ដោយដែកស្រួចជាបច្ច័យនេះក្ដី ទុក្ខដែលត្រូវក្អែកចឹកដោយចំពុះស្រួចដូចធ្វើដោយលោហៈក្ដី សូម្បីទាំងអស់នេះ ក៏មិនមែនជាសេចក្ដីទុក្ខរបស់

*អញទេ ទុក្ខនោះផ្សេងអំពីទុក្ខរបស់អញ ។*

*សួរថា ទុក្ខប្រភេទណា ?*

*ឆ្លើយថា គឺទុក្ខមានដល់អញនោះ ត្រង់ដែលភរិយាមានពណ៌សម្បុរដូចមាស មិនបានស្លៀកដណ្តប់សំពត់ដែលជ្រលក់ដោយទឹកផ្កាដកគាំ ដើរមើលមហោស្រពប្រចាំខែកត្តិក អធិប្បាយថា ការដែលស្ត្រីឈ្មោះសាមា ជាភរិយារបស់អញនោះ នឹងមិនបានស្លៀកដណ្តប់សំពត់ដែលជ្រលក់ដោយទឹកដកគាំ បិទបាំងរាងកាយដោយគូនៃសំពត់សាច់-ម៉ដ្ឋដែលជ្រលក់ដោយផ្កាឈើ កៀក-កអញដើរមើលមហោស្រពប្រចាំខែកត្តិក នេះជាសេចក្តីទុក្ខរបស់អញ ទុក្ខនេះប៉ុណ្ណោះ ដែលបៀតបៀនអញក្រៃលែងណាស់ ។*

*បុរសនោះ គិតតែពីសោកកន្ទក់កន្ទេញ នឹកដល់មាតុគ្រាមនោះយ៉ាងនេះ ប៉ុណ្ណោះ រហូតស្លាប់ទៅកើតក្នុងនរក ។*

*ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា គូស្វាមីភរិយាក្នុងកាលនោះ បានមកជាគូស្វាមីភរិយាក្នុងកាលឥឡូវនេះ ចំណែកអាកាសដ្ឋទេវតាអ្នកឈរប្រកាសធ្វើហេតុនោះឲ្យប្រែចក្ស គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា បុប្ផរត្តជាតក ទី ៧ ។

# អដ្ឋកថា សិង្គាលជាតក ទី ៨

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការគ្របសង្កត់កិលេស ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **ជាហំ បុនំ ន ច បុនំ** *ដូច្នេះជាដើម ។*

*បានឮថា សេដ្ឋីបុត្តក្រុងសាវត្ថីប្រមាណ ៥០០ នាក់ ជាសម្លាញ់នឹងគ្នា ម្នាក់ៗមានសម្បត្តិយ៉ាងសន្ធឹកសន្ធាប់ ស្តាប់ព្រះធម្មទេសនារបស់ព្រះបរមសាស្តាហើយ បួសឧទ្ទិសជីវិតចំពោះព្រះសាសនា នៅកុដិខាងចុងក្នុងវត្តជេតពន ។ ថ្ងៃមួយ ក្នុងវេលារាត្រី សេចក្តីត្រិះរិះអាស្រ័យកិលេសដែលទាក់ទងនឹងការគ្រប់គ្រងផ្ទះកើតឡើងដល់ភិក្ខុទាំងនោះ ភិក្ខុទាំង-នោះ មួយអង្គៗកើតការអផ្សុក បន្ទាប់មកភិក្ខុទាំងនោះ កើតចិត្តប្បាទដើម្បីនឹងគ្រប់គ្រងកិលេសដែលខ្លួនបានលះហើយ ។ គ្រានោះ ព្រះបរមសាស្តាទ្រង់លើកប្រទីបដែលមានព្រះសព្វញ្ញុតញ្ញាណជាដង ក្នុងកណ្តាលរាត្រីទ្រង់ត្រួតមើលអធ្យាស្រ័យរបស់ភិក្ខុទាំងនោះថា ភិក្ខុទាំងនោះស្នាក់នៅក្នុងវត្តជេតពនដោយសេចក្តីត្រេកអរដូចម្តេចទៅហ្ន៎ ទ្រង់ជ្រាបសភាពដែលភិក្ខុទាំងនោះមានសេចក្តីត្រិះរិះក្នុងកាមរាគៈ កើតឡើងខាងក្នុងសន្តានធម្មតាព្រះបរមសាស្តារមែងរក្សាសាវករបស់ព្រះអង្គ ដូចស្ត្រីមានកូនតែមួយ ថ្នាក់ថ្នមកូនរបស់ខ្លួន ដូចបុគ្គលមានភ្នែកតែម្ខាង រមែងរក្សាភ្នែករបស់ខ្លួនដូច្នោះ ។ ក្នុងសម័យណា មានវេលាព្រឹកជាដើម កិលេសទាំងឡាយ*

កើតដល់ពួកសាវកនោះ ទ្រង់មិនព្រមឲ្យកិលេសទាំងនោះ របស់សាវកទាំងនោះ កព្វនឲ្យច្រើនជាងនោះឡើយ ទ្រង់គ្របសង្កត់ក្នុងសម័យនោះ ដោយហេតុនោះ ទើបទ្រង់មានព្រះតម្រិះថា កាលនេះ ដូចជាកាលកើតនៃពួកចោរខាងក្នុងនគររបស់ស្តេចចក្រពត្តិដូច្នោះ តថាគតត្រូវសម្តែងព្រះ-ធម្មទេសនាគ្របសង្កត់កិលេសហើយ ឲ្យអរហត្តផលដល់ភិក្ខុទាំងនោះក្នុងកាលឥឡូវនេះឯង ។ លុះទ្រង់ព្រះតម្រិះយ៉ាងនេះហើយស្តេចយាងចេញអំពីព្រះគន្ធកុដិដែលមានក្លិនក្រអូប មានព្រះតម្រាស់ដោយព្រះសូរសៀងដ៏ពីរោះហៅព្រះអានន្ទដែលជាឃ្លាំងធម៌ថា ម្នាលអានន្ទ ។ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ថា ព្រះករុណាព្រះអង្គ ។ ព្រះអានន្ទមកថ្វាយបង្គំ ទ្រង់ប្រថាប់ឈរត្រាស់ថា ម្នាលអានន្ទ ភិក្ខុប៉ុន្មានអង្គដែលនៅក្នុងកុដិខាងចុងវិហារ ចូរអ្នកទៅប្រាប់ឲ្យភិក្ខុទាំងនោះ ប្រជុំគ្នាក្នុងបរិវេណព្រះគន្ធកុដិទាំងអស់ ។ បានឮថា ព្រះបរមសាស្តា ទ្រង់ព្រះតម្រិះដូច្នេះថា ប្រសិនបើតថាគតឲ្យហៅភិក្ខុ ៥០០ អង្គនោះប៉ុណ្ណោះមកប្រជុំ ភិក្ខុទាំងនោះនឹងតក់ស្លុតចិត្តថា ព្រះបរមសាស្តាទ្រង់ជ្រាប ការដែលគំនរកិលេសកើតឡើងខាងក្នុងសន្តានពួកយើងហើយ នឹងមិនអាចទទួលព្រះធម្មទេសនាបាន ហេតុនោះទើបទ្រង់ត្រាស់ថា ឲ្យមកប្រជុំទាំងអស់ ។ ព្រះអានន្ទទទួលព្រះពុទ្ធតម្រាស់ថា ព្រះករុណាព្រះអង្គ ហើយកាន់កូនសោរនិមន្តទៅគ្រប់បរិវេណ ប្រាប់ឲ្យភិក្ខុទាំងអស់ប្រជុំគ្នានៅក្នុងបរិវេណព្រះគន្ធកុដិ ហើយ

ចាត់ចែងក្រាលពុទ្ធាសនៈទុក ។

ព្រះបរមសាស្តា ទ្រង់គង់ពត់ភ្នែន តាំងព្រះកាយត្រង់ ប្រថាប់លើពុទ្ធាសនៈដែលក្រាលទុក ដូចភ្នំសិនេរុដែលឋិតនៅលើបបរីសិលា ទ្រង់ផ្សាយព្រះរស្មីដែលមានពណ៌ ៦ ធ្មៀលធ្វាត់ចុះឡើង ប្រទាក់ពណ៌គ្នាជាគូៗ ព្រះរស្មីទាំងនោះ មានប្រមាណប៉ុនថាស ប៉ុនឆ័ត្រនិងប៉ុនគោមនៃផ្ទះកំពូលដាច់ជាចន្លោះៗ វិលជុំវិញព្រះវរកាយ ដូចផ្លេកបន្ទោរឮដ៏នភាកាសកាលនោះ ដូចជាកាលដែលព្រះអាទិត្យកំពុងបញ្ចេញពន្លឺដ៏ស្រទន់ៗ ធ្វើឲ្យផ្ទៃសមុទ្រធំមានពន្លឺព្រិចៗ ដូច្នោះ ។ ភិក្ខុទាំងនោះឱនសិរសាថ្វាយ-បង្គំព្រះបរមសាស្តា ដោយតាំងចិត្តគោរពយ៉ាងមាំ អង្គុយចោមរោមជុំវិញព្រះសម្មាសម្ពុទ្ធ ដូចព័ទ្ធព័ទ្ធដោយវាំងននកម្ពលក្រហមដូច្នោះ ។ ព្រះបរមសាស្តាទ្រង់បន្លឺព្រះសូរសៀងដូចសំឡេងព្រហ្ម ទ្រង់តឿនភិក្ខុទាំងឡាយដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុមិនគួរត្រិះរិះដល់អកុសលវិតក្កទាំង ៣ នេះគឺ **កាមវិតក្ក** សេចក្តីត្រិះរិះក្នុងកាម ១ **ព្យាបាទវិតក្ក** សេចក្តីត្រិះរិះក្នុងព្យាបាទ ១ **វិហឹសាវិតក្ក** សេចក្តីត្រិះរិះក្នុងការបៀតបៀន ១ ធម្មតាកិលេសដូចជាបច្ចាមិត្ត ហើយបច្ចាមិត្តនោះនឹងឈ្មោះថា តិចតួចមិនមានឡើយ បានឱកាសពេលណាហើយ រមែងធ្វើឲ្យដល់នូវសេចក្តីវិនាសតែម្យ៉ាង កិលេសសូម្បីមានប្រមាណតិច កើតឡើងហើយ បានឱកាសដើម្បីនឹងកពូន រមែងញ៉ាំង

មហាវិនាសឲ្យកើតឡើងបានយ៉ាងនោះ ធម្មតាកិលេសនេះ ប្រៀបដូចជាថ្នាំពុលដ៏កាចសាហាវ នឹងប្រៀបដូចជាបួសដែលមានស្បែករបកហើយ (តែងហូរមកនូវខ្ទុះ) ប្រៀបបាននឹងអាសិរពិស ប្រហែលនឹងភ្លើងដែលកើតអំពីអសនីបាត មិនគួរឡើយនិយមត្រេកអរ គួរតែរង្កៀសដោយកម្លាំងនៃការពិចារណា ដោយកម្លាំងនៃភាវនា ក្នុងខណៈដែលកើតគួរលះបង់ចោលដោយការដែលកិលេសទាំងនោះ នឹងស្ទុះទៅមិនទាន់តាំងនៅក្នុងហឫទ័យត្រឹមតែបន្តិច ដូចដំណក់ទឹករមៀលធ្លាក់អំពីស្លឹកឈូកយ៉ាងណា សេចក្តីនោះក៏ដូច្នោះដែរ សូម្បីបណ្ឌិតក្នុងកាលមុនក៏តិះដៀលកិលេស សូម្បីមានប្រមាណតិច គ្របសង្កត់កិលេសនោះមិនឲ្យកើតឡើងខាងក្នុងសន្តានបានទៀត ដូច្នេះ ។ លុះទ្រង់សម្តែងដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងកំណើតចចក រស់នៅលើឆ្នេរស្ទឹងជិតព្រៃ ។ គ្រានោះ មានដំរីចាស់មួយដួលស្លាប់នៅលើមាត់ទន្លេគង្គា ចចកចេញរកចំណីជួបសាកសពដំរីនោះ គិតថា ចំណីធំកើតឡើងដល់អញហើយ ទើបទៅជិតសាកសពដំរីនោះ ខាំប្រមោយក៏ដូចជាខាំដងនង្គ័ល គិតថា ត្រង់នេះមិនគួរស៊ី ទើបខាំភ្លុកទាំងពីរក៏ដូចជាខាំសសរ ខាំត្រចៀកក៏ដូចជាខាំចំកណ្តាប់ចង្អេរ ខាំពោះក៏ដូចជាខាំចំជង្រុកស្រូវ

ខាំដើងដូចជាខាំចំត្បាល់ ខាំកន្ទុយដូចជាខាំចំអង្រែ ចចកក៏គិតថា សូម្បីត្រង់នេះក៏មិនគួរស៊ីដែរ កាលមិនបានទទួលការពេញចិត្តក្នុងអវយវៈទាំង-ពួងក៏ខាំត្រង់វច្ចមគ្គ ក៏ដូចជាខាំនំទន់ ។ ចចកគិតថា ពេលនេះ អញបានទីដែលគួរស៊ីក្នុងសរីរៈនេះហើយ ទើបខាំតែវច្ចមគ្គនោះ ចូលទៅដល់ក្នុងពោះ ស៊ីថ្លើមនិងបេះដូងជាដើម ពេលស្រេកទឹកក៏ផឹកឈាម ពេលចង់ដេកក៏យកផ្ទៃពោះទ្រោបដេក ។ ពេលនោះ ចចកក៏មានបរិវិតក្កថា សាក-សពដំរីនេះដូចជាផ្ទះរបស់អញ ព្រោះជាទីនៅយ៉ាងសប្បាយ ពេលចង់ស៊ីក៏មានសាច់ស៊ីគ្រប់គ្រាន់ ពេលនេះ អញនឹងទៅទីដទៃធ្វើអ្វី ទើបមិនព្រមទៅកាន់ទីដទៃទៀត នៅស៊ីតែសាច់ក្នុងពោះដំរីតែមួយកន្លែង ។

លុះវេលាកន្លងទៅ រហូតដល់រដូវប្រាំង សាកសពដំរីនោះក៏រួញខ្លួនស្វិតស្ងួត ដោយត្រូវខ្យល់និងត្រូវពន្លឺព្រះអាទិត្យដុតកោល ប្រហោងដែលចចកចេញចូលក៏បិទអស់ ខាងក្នុងពោះក៏ងងឹត ប្រាកដដល់ចចកនោះដូចនៅក្នុងលោកន្តរនរកដូច្នោះ សាកសពដំរីស្ងួត សូម្បីសាច់ជាដើម ក៏ស្ងួតអស់ដែរ ហើយឈាមក៏ស្ងួតអស់ ចចកមិនមានផ្លូវចេញក៏កើតការខ្លាច ជជ្រុលជជ្រកទៅខាំខាងនោះខាងនេះ ខ្វល់ខ្វាយរកផ្លូវចេញ កាលចចកនោះជាប់នៅក្នុងពោះដំរីយ៉ាងនេះ ក៏ដូចជាដុំម្សៅនៅក្នុងឆ្នាំងបាយដូច្នោះ ។ កន្លងមកពីរ-បីថ្ងៃ ភ្លៀងធ្លាក់មួយមេធំ កាលសាកសពដំរីនោះជោកទៅដោយទឹកភ្លៀង ក៏ហើមប៉ោងឡើង រហូតមានសណ្ឋានដូចដើម

ទ្វារលាមកក៏បើកប្រាកដដូចដួងតារា ចចកឃើញប្រហោងនោះក៏គិតថា ពេលនេះអញបានរួចខ្លួនហើយ ដើរថយក្រោយរហូតដល់ក្បាលដំរី រត់ចេញយ៉ាងលឿន យកក្បាលរុញទ្វារលាមកចេញទៅបាន ព្រោះថារាង កាយរបស់ចចកនោះស្គមស្គាំង រោមទាំងអស់ក៏ជាប់នៅក្នុងទ្វារលាមកនោះឯង ។ ចចកមានចិត្តសង្វេគដោយរាងកាយដែលអត់មានរោម ដូចដើមត្នោត រត់ទៅបានបន្តិច ត្រឡប់មកអង្គុយសម្លឹងមើលសរីរៈដោយសង្វេគ ហើយគិតថា ទុក្ខរបស់អញនេះ វត្ថុដទៃមិនបានធ្វើឲ្យឡើយ ប៉ុន្តែព្រោះ សេចក្តីលោភជាហេតុ ព្រោះសេចក្តីលោភជាបច្ច័យ អញអាស្រ័យសេចក្តីលោភ បង្កទុក្ខនេះដោយខ្លួនឯង ចាប់ពីពេលនេះតទៅ អញនឹងមិនព្រមលុះក្នុងអំណាចនៃសេចក្តីលោភទៀតទេ ដែលឈ្មោះ ថាសាកសពដំរីអញនឹងមិនចូលទៅទៀតឡើយ ដូច្នេះហើយ ពោលគាថានេះថា

**ណាហំ បុនំ ន ច បុនំ ន ចាបិ អបុនប្បុនំ**
**ហត្ថិពោន្ទឹ បវេក្ខាមិ តថា ហិ ភយតជ្ជិតោតិ ។**

យើងនឹងមិនចូលកាន់ពោះដំរីទៀត យើងនឹងមិនចូល
កាន់ពោះដំរីទៀត យើងនឹងមិនចូលកាន់ពោះដំរីញយ ៗ
ទេ ព្រោះយើងត្រូវភ័យគំរាមហើយ ដូច្នោះ ។

ក្នុងគាថានោះ អ អក្សរ ក្នុងបាទគាថាថា **ន ចាបិ អបុនប្បុនំ** ត្រឹមតែជានិបាត ក្នុងគាថាទាំងអស់នេះមានអត្ថាធិប្បាយដូច្នេះថា តទៅ

នេះ អញនឹងមិនចូលទៅទៀតទេ បានដល់ អញនឹងមិនចូលទៅកាន់ពោះដំរីទេ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះថា ពេលនៅក្នុងពោះដំរី ត្រូវភ័យគំរាមស្ទើរស្លាប់ អធិប្បាយថា ព្រោះអញត្រូវភ័យក្នុងការចូលទៅក្នុងពោះដំរីគំរាមស្ទើរស្លាប់ គឺត្រូវដល់នូវការតក់ស្លុត តក់ស្លុតព្រោះខ្លាចស្លាប់ ។

ចចកនោះ លុះពោលយ៉ាងនេះហើយ ក៏ចៀសចេញអំពីទីនោះមួយរំពេច សរីរៈដំរីនោះក្តី សរីរៈដទៃក្តី ចចកនោះមិនងាកក្រោយសម្លឹងមើលឡើយ ។ បន្ទាប់ពីនោះ ចចកនោះក៏មិនលុះក្នុងអំណាចនៃសេចក្តីលោភទៀតឡើយ ។

ព្រះបរមសាស្តា លុះទ្រង់នាំយកព្រះធម្មទេសនានេះមកហើយទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាកិលេសដែលកើតឡើងខាងក្នុងមិនត្រូវឲ្យរកពូនបាន គួរគ្របសង្កត់នៅពេលនោះភ្លាម ហើយទ្រង់ប្រកាសសច្ចៈទាំងឡាយ ពេលចប់សច្ចៈ ភិក្ខុទាំង ៥០០ រូបនោះ បានសម្រេចព្រះអរហត្តផល ភិក្ខុដ៏សេសពួកខ្លះបានជាព្រះសោតាបន្ន ពួកខ្លះបានជាព្រះសកទាគាមី ពួកខ្លះបានជាព្រះអនាគាមី ។ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ក្នុងកាលនោះ សិង្គាល ( ចចក ) គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា សិង្គាលជាតក ទី ៨ ។

# អដ្ឋកថា ឯកបណ្ណជាតក ទី ៩

ព្រះបរមសាស្ដា កាលទ្រង់អាស្រ័យនៅក្នុងនគរវេសាលី ទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យផ្ដើមថា **ឯកបណ្ណោ អយំ រុក្ខោ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ក្នុងកាលនោះ នគរវេសាលីមានកំពែងព័ទ្ធជុំវិញ ៣ ជាន់ រហូតបរិវេណ ១ គាវុត មានបន្ទាយទាហាននិងប៉មក្នុងកំពែងទាំង ៣ ដល់នូវភាពជាក្រុងល្អឥតខ្ចោះ ចំនួនព្រះរាជាសោយរាជសម្បត្តិជានិច្ចជាកាល ក្នុងនគរនោះមានដល់ទៅ ៧៧០៧ អង្គ ចំនួនឧបរាជក៏ប៉ុណ្ណោះដែរ សេនាបតីនិងនាយឃ្លាំងក៏មានចំនួនប៉ុណ្ណោះដែរ ។ បណ្ដាក្រុមនៃឱរសរបស់ព្រះរាជាទាំងនោះ មានរាជកុមារមួយអង្គព្រះនាមថា ទុដ្ឋលិច្ឆវី ជាអ្នកច្រើនទៅដោយសេចក្ដីក្រោធនិងភាពកាចសាហាវ ជាអ្នកមានវាចាគ្រោតគ្រាត ដូចអសិរពិសដែលត្រូវគេវាយនឹងដំបង កើតការក្ដៅក្រហាយជានិច្ច អ្នកដែលអាចពោលពាក្យពីរ-បីម៉ាត់ចំពោះព្រះភក្ត្រព្រះ-រាជកុមារ ដោយអំណាចសេចក្ដីក្រោធមិនមានឡើយ ព្រះមាតាព្រះបិតាព្រះញាតិនិងសម្លាញ់ គ្មានអ្នកណាអាចនឹងអប់រំព្រះរាជកុមារនោះបានឡើយ ។

គ្រានោះ ព្រះមាតាព្រះបិតារបស់ព្រះរាជកុមារនោះ ទ្រង់មានបរិវិតក្កថា កុមារនេះកាចសាហាវយង់ឃ្នងណាស់ វៀរព្រះសម្មាសម្ពុទ្ធ

ចេញហើយ អ្នកដទៃដែលអាចអប់រំកុមារនេះបាន មិនមានឡើយ កុមារនេះគួរជាបុគ្គលដែលព្រះសម្ពុទ្ធទ្រង់ណែនាំ លុះទ្រង់មានបរិវិតក្កដូច្នេះហើយ នាំព្រះរាជកុមារទៅកាន់សម្នាក់ព្រះសម្មាសម្ពុទ្ធ ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កុមារនេះកាចសាហាវយង់ឃ្នងពោរពេញដោយសេចក្ដីក្រោធ សូមព្រះអង្គទ្រង់ប្រទានឱវាទដល់កុមារនេះផង ។ ព្រះបរមសាស្ដាទ្រង់ប្រទានឱវាទដល់ព្រះរាជកុមារថា ម្នាលកុមារ អ្នកមិនគួរជាមនុស្សកាចសាហាវយង់ឃ្នងទេ មិនគួរពេញចិត្តសង្កត់សង្កិនគំរាមកំហែងពួកសត្វទាំងនេះឡើយ ធម្មតាអ្នកមានវាចាគ្រោតគ្រាត រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តនៃមាតាបង្កើត នៃបិតា នៃបុត្តភរិយា នៃបងប្អូនប្រុសស្រី សូម្បីនៃពួកញាតិ ជាទីតាំងនៃការភ័យខ្លាច ដូចអសិរពិសកំពុងលូនមកខាំ ដូចចោរដែលឡោមព័ទ្ធនៅក្នុងព្រៃ ដូចយក្សដែលកំពុងដើរមកចាប់ស៊ី រមែងកើតក្នុងនរកជាដើមបានក្នុងបច្ចុប្បន្ននេះអ្នកដែលច្រើនទៅដោយសេចក្ដីក្រោធ សូម្បីប្រដាប់តាក់តែងទៅដោយសម្លៀកបំពាក់ល្អៗ យ៉ាងណាក៏ដោយ ក៏នៅតែមានពណ៌សម្បុរសៅហ្មងមិនល្អដដែល មុខមាត់របស់បុគ្គលនោះ សូម្បីមានសិរីដូចព្រះចន្ទពេញវង់ក៏ដោយ ក៏គង់ដូចផ្កាឈូកដែលត្រូវរោលដោយភ្លើង ដូចកញ្ចក់ដែលប្រកបដោយមន្ទិល រមែងខុសរូបខុសរាងមិនគួរមើល ដ្បិតថា ពួកសត្វអាស្រ័យសេចក្ដីក្រោធ រមែងចាប់អាវុធប្រហារខ្លួនឯងស្លាប់

ផឹកថ្នាំពុលសម្លាប់ខ្លួន ចងកសម្លាប់ខ្លួន លោតទឹកសម្លាប់ខ្លួន លុះស្លាប់ដោយអំណាចសេចក្តីក្រោធយ៉ាងនេះហើយ ក៏រមែងកើតក្នុងអបាយភូមិមាននរកជាដើម ចំណែកអ្នកដែលពេញចិត្តបៀតបៀនអ្នកដទៃ ក៏ត្រូវតិះ-ដៀលក្នុងបច្ចុប្បន្ន កាលបែកធ្លាយរាងកាយទៅ ក៏បដិសន្ធិក្នុងនរកជាដើម សូម្បីបានត្រឡប់មកកើតជាមនុស្ស ក៏ជាមនុស្សមានរោគច្រើនតាំងអំពីកើតមកនោះឯង បណ្តារោគទាំងឡាយ មានរោគភ្នែក រោគត្រចៀកជាដើម នឹងចោមរោមបៀតបៀនមនុស្សប្រភេទនេះ ជនទាំងនោះនឹងមិនផុតអំពីរោគបៀតបៀន នឹងជាអ្នកមានទុក្ខជាប្រចាំ ព្រោះហេតុនោះ អ្នកគប្បីជាមនុស្សមានចិត្តមេត្តា មានចិត្តទន់ភ្លន់ចំពោះសព្វសត្វ ព្រោះបុគ្គលដូច្នេះ រមែងរួចផុតអំពីភ័យមាននរកជាដើមបាន ដូច្នេះ ។ កុមារនោះស្តាប់ឱវាទរបស់ព្រះបរមសាស្តាហើយ លះបង់មានះបានដោយព្រះឱវាទតែម្តងប៉ុណ្ណោះ ជាអ្នកទូន្មានបាន ជាអ្នកមានចិត្តទន់ភ្លន់ សូម្បីអ្នកដទៃជេរវាយក៏មិនបានយកចិត្តទុកដាក់ឡើយ ដូចពស់ដែលត្រូវគេដកចង្កូម ដូចក្តាមដែលត្រូវគេកាច់តង្កៀប និងដូចគោឈ្មោលដែលត្រូវគេកាត់ស្នែង ដូច្នោះ ។

ភិក្ខុទាំងឡាយក្រាបទូលព្រឹត្តការណ៍របស់កុមារនោះហើយ ទើបលើករឿងឡើងសន្ទនាគ្នាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ ព្រះ-មាតាបិតា ព្រះញាតិនិងសម្លាញ់ជាដើម មិនអាចទូន្មានលិច្ឆវីកុមារ ដែល

កាចសាហាវយង់ឃ្នងបាន អស់កាលយូរអង្វែង ប៉ុន្តែព្រះសម្មាសម្ពុទ្ធទ្រង់ទូន្មានព្រះរាជកុមារនោះ ដោយព្រះឱវាទតែម្តងប៉ុណ្ណោះ ទ្រង់ធ្វើហេតុគឺការឲ្យនៅក្នុងព្រំដែនដែលគួរសរសើរបាន ដូចហត្ថាចារ្យទូន្មានដំរីដែលចុះប្រេងឲ្យអស់ភាពចចេសដូច្នោះ ដូចព្រះពុទ្ធភាសិតសម្តែងថា ម្នាលភិក្ខុទាំងឡាយ ដំរីគួរទូន្មាន ដែលទម័កដំរី បានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសតែមួយៗ គឺទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ សេះគួរទូន្មាន ដែលទម័កសេះបានទូន្មានហើយ រមែងស្ទុះទៅកាន់កាន់ទិសតែមួយៗ គឺទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ គោគួរទូន្មាន ដែលទម័កគោបានទូន្មានហើយ រមែងស្ទុះទៅកាន់កាន់ទិសតែមួយៗ គឺទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ ឯបុរសគួរទូន្មាន ដែលព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធបានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសទាំង ៨ បាន គឺបុគ្គលបាននូវរូបជ្ឈានតែងមើលឃើញនូវរូបទាំងឡាយ នេះជាទិសទី ១ [១] ។ ព្រះតថាគតអង្គនោះ បណ្ឌិតរមែងពោលថា ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ក្រៃលែងជាងអាចារ្យ

---

[១]-បណ្ឌិតត្រូវការសេចក្តីពិស្តារ អានក្នុងបិដកខ្មែរលេខ ២៨ ទំព័រ ១១៤ ចុះ ។

អ្នកហ្វឹកហាត់ទាំងឡាយ អ្នកមានអាយុទាំងឡាយ ធម្មតាអ្នកទូន្មានទូន្មានទូវបុរសដែលគួរទូន្មានបាន ដូចព្រះសម្មាសម្ពុទ្ធនោះមិនមានសោះឡើយ ។ ព្រះបរមសាស្តា ស្តេចយាងមក ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាប-ទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលតថាគតទូន្មានកុមារនេះបានដោយឱវាទតែម្តងនោះ សូម្បីកាលពីមុនតថាគតក៏ធ្លាប់បានទូន្មានកុមារនេះ ដោយឱវាទតែម្តងដែរ ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឧទិច្ចព្រាហ្មណ៍ចម្រើនវ័យហើយ រៀនត្រៃវេទនិងសព្វសិល្បវិទ្យានៅក្នុងនគរតក្កសិលានៅគ្រប់គ្រងផ្ទះអស់កាលតិចតួច កាលមាតាបិតាស្លាប់ទៅក៏បួសជាឥសីញុំាងអភិញ្ញាសមាបត្តិឲ្យកើតឡើងហើយ រស់នៅក្នុងព្រៃហិមពាន្ត ។ កាលនៅក្នុងព្រៃនោះយូរៗ ក៏ទៅកាន់ជនបទដើម្បីឆាន់រសជូរ ប្រៃ និមន្តទៅដល់នគរពារាណសី ស្នាក់នៅក្នុងព្រះរាជឧទ្យាន ។ ភ្លឺឡើង ស្លៀកដណ្តប់ហើយ បរិបូណ៌ដោយមារយាទរបស់តាបស ចូលកាន់នគរដើម្បីភិក្ខានិមន្តទៅដល់លានព្រះរាជវាំង ។

ព្រះរាជាកំពុងទតទៅតាមសីហបញ្ជរ ទ្រង់ឃើញតាបសហើយ ទ្រង់ជ្រះថ្លាក្នុងឥរិយាបថ ទ្រង់ព្រះតម្រិះថា តាបសនេះមានឥន្ទ្រីយ៍សង្រួម មានចិត្តស្ងប់ មានភ្នែកដាក់ចុះមួយជួរនឹម ដូចដាក់ថង់ទ្រព្យមួយពាន់កហាបណៈគ្រប់ៗជំហាន និមន្តមកដោយលីលាអង់អាចដូចរាជសីហ៍ ប្រសិនបើមានសភាវៈដែលឈ្មោះថា សន្តធម៌ សន្តធម៌នោះ ត្រូវមានខាងក្នុងនៃតាបសនេះឯង ហើយទ្រង់ទតមើលអាមាត្យម្នាក់ អាមាត្យនោះក្រាបទូលថា បពិត្រមហារាជ ទូលព្រះបង្គំនឹងត្រូវធ្វើអ្វីឬ ?

ទ្រង់ត្រាស់ថា អ្នកចូរទៅនិមន្តតាបសនោះមក ។ អាមាត្យនោះទទួលព្រះរាជឱង្ការថា ព្រះករុណាថ្លៃវិសេស រួចចូលទៅរកព្រះពោធិសត្វ ថ្វាយបង្គំហើយទទួលភាជនៈដាក់ភិក្ខាអំពីដៃតាបសពោធិសត្វ កាលតាបសពោធិសត្វពោលថា មានការអ្វីឬ អ្នកមានបុណ្យច្រើន ?

អាមាត្យនោះក្រាបទូលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះរាជាឲ្យនិមន្តលោកម្ចាស់ ។

ព្រះពោធិសត្វពោលថា យើងមិនមែនអ្នកបួសប្រចាំរាជដំណាក់ទេ យើងជាអ្នកបួសនៅក្នុងព្រៃហិមពាន្ត ។ អាមាត្យទៅក្រាបទូលពាក្យនោះចំពោះព្រះរាជា ។ ព្រះរាជាត្រាស់ថា តាបសដទៃដែលស្និទ្ធស្នាលនឹងយើងមិនមានទេ ចូរនិមន្តលោកមកចុះ ។ អាមាត្យក៏ទៅថ្វាយបង្គំតាបសអារាធនានិមន្តលោកចូលកាន់ព្រះរាជវាំង ។ ព្រះរាជាថ្វាយបង្គំព្រះបរម-

ពោធិសត្វអារាធនាឲ្យគង់លើបល្ល័ង្កមាសខាងក្រោមស្វេតច្ឆត្រ ឲ្យឆាន់ភោជនដែលមានរសប្រណីតៗ ដែលគេតាក់តែងទុកសម្រាប់ទ្រង់ ហើយត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់នៅទីណា ?

ព្រះបរមពោធិសត្វថ្វាយព្រះពរថា មហាបពិត្រ អាត្មាភាពនៅក្នុងព្រៃហិមពាន្ត ។

ព្រះរាជាសួរថា ពេលនេះលោកម្ចាស់សម្រាកនៅឯណា ?

ព្រះបរមពោធិសត្វថ្វាយព្រះពរថា មហាបពិត្រ អាត្មាភាពកំពុងរកមើលសេនាសនៈ ដែលសមគួរដល់រដូវភ្លៀង ។

ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះសូមនិមន្តនៅក្នុងឧទ្យានរបស់ពួកញោមចុះ ។ ទ្រង់កាន់យកបដិញ្ញាហើយ សូម្បីព្រះអង្គខ្លួនឯងក៏សោយស្រេច ទ្រង់នាំព្រះបរមពោធិសត្វទៅកាន់ឧទ្យានបញ្ជាឲ្យសាងបណ្ណសាលា ឲ្យធ្វើទីសម្រាកពេលថ្ងៃនិងពេលយប់ ទ្រង់ថ្វាយបរិក្ខារសម្រាប់បព្វជិត ទ្រង់ប្រគល់អ្នកយាមសួនឲ្យមើលថែ ហើយស្ដេចចូលកាន់នគរ ។

ចាប់ពីពេលនោះមក ព្រះបរមពោធិសត្វក៏នៅក្នុងឧទ្យាន ចំណែកព្រះរាជាក៏យាងទៅរកព្រះពោធិសត្វ ក្នុងមួយថ្ងៃពីរ-បីដង រាល់ៗ ថ្ងៃ ។ ព្រះរាជាអង្គនោះ ទ្រង់មានព្រះឱរសព្រះនាមថា ទុដ្ឋកុមារ ជាអ្នកមានសន្ដានអាក្រក់ កាចសាហាវយង់ឃ្នង ព្រះរាជានិងពួកព្រះញាតិមិនអាច

ទូន្មានអប់រំបាន ពួកអាមាត្យក្តី ពួកព្រាហ្មណ៍ក្តី និងពួកគហបតីក្តី សូម្បីរួមគ្នាពោលដោយទោមនស្សថា បពិត្រព្រះរាជកុមារ សូមទ្រង់កុំធ្វើយ៉ាងនេះឡើយ ទ្រង់មិនគួរធ្វើយ៉ាងនេះទេ ក៏មិនអាចញ៉ាំងព្រះរាជកុមារនោះឲ្យស្តាប់ពាក្យសម្តីបាន ។ ព្រះរាជាទ្រង់ព្រះតម្រិះថា វៀរតាបស អ្នកទ្រទ្រង់សីលរបស់យើងចេញហើយ គង់មិនមានអ្នកដទៃទូន្មានកុមារនេះបាន ។ ព្រះរាជាទ្រង់នាំព្រះរាជកុមារទៅកាន់សម្នាក់ព្រះបរមពោធិសត្វ ហើយត្រាស់ប្រាប់ថា បពិត្រលោកម្ចាស់ កុមារនេះមានសន្តានអាក្រក់កាចសាហាវយង់ឃ្នង ពួកខ្ញុំមិនអាចទូន្មានអប់រំកុមារនេះបាន សូមលោកម្ចាស់មេត្តារកឧបាយម្យ៉ាង ទូន្មានគេផងចុះ ។ ព្រះរាជាទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់ប្រគល់ព្រះរាជកុមារដល់ព្រះបរមពោធិសត្វ ហើយទ្រង់ចៀសចេញទៅ ។ ព្រះបរមពោធិសត្វក៏បបួលព្រះរាជកុមារត្រាច់ទៅក្នុងឧទ្យានឃើញដើមស្តៅទើបតែដុះមិនទាន់បាន ៤ ធ្នាប់ ទើបតែមានស្លឹកពីរប៉ុណ្ណោះ គឺស្លឹកចេញម្ខាងមួយសន្លឹក ទើបពោលនឹងព្រះរាជកុមារថា នែកុមារ សូមទ្រង់ទំពាស្លឹកស្តៅនេះ ហើយជ្រាបរសរបស់វាចុះ ។ ព្រះរាជកុមារទ្រង់ទំពាស្លឹកមួយសន្លឹក ដឹងរសហើយត្រាស់ថា ថ្វីយ ថ្វីយ ស្តោះចោលលើផែនដី មួយអន្ទើទាំងទឹកមាត់ កាលតាបសពោលថា យ៉ាងណាដែរកុមារ ក៏ប្រាប់ថា បពិត្រលោកម្ចាស់ ដើមឈើនេះប្រៀបដូចថ្នាំពិសដ៏កាចសាហាវ ប្រសិនបើដើមឈើនេះធំឡើង គង់សម្លាប់មនុស្សយ៉ាងច្រើន ទ្រង់ពោល

ដូច្នេះហើយ ទ្រង់ដកដើមស្តៅនោះ ហើយញីរហូតទាល់តែខ្ទេចដោយព្រះហស្ត ទើបត្រាស់ព្រះគាថានេះថា

**ឯកបណ្ណោ អយំ រុក្ខោ ន ភុម្យា ចតុរង្គុលោ**
**ផលេន វិសកប្បេន មហាយំ កឹ ភវិស្សតីតិ ។**

ឈើនេះទើបតែនឹងមានស្លឹកតែមួយ ៗ ដុះអំពីផែនដីមិនទាន់ដល់ ៤ ធ្នាប់ មានផលដូចជាថ្នាំពិសទៅហើយ ចំណង់ឈើនេះធំឡើង នឹងដូចម្តេចទៅ ។

បណ្តាបទទាំងនោះ បទថា **ឯកបណ្ណោ** សេចក្តីថា ទើបតែមានស្លឹកមួយៗ ។

បទថា **ន ភុម្យា ចតុរង្គុលោ** សេចក្តីថា ( ដើមឈើនេះ ) ដុះអំពីផែនដីមិនទាន់ដល់ ៤ ធ្នាប់ផង ។

បទថា **ផលេន** បានដល់ រសដែលកើតអំពីផ្លែ ។

បទថា **វិសកប្បេន** បានដល់ មានផ្លែដូចជាថ្នាំពិស អធិប្បាយថា ឈើនេះទើបតែនឹងមានស្លឹកតែមួយៗ ដុះអំពីផែនដី មិនទាន់ដល់ ៤ ធ្នាប់ផង មានផលដូចជាថ្នាំពិសទៅហើយ ។

បទថា **មហាយំ កឹ ភវិស្សតិ** សេចក្តីថា ប្រសិនបើឈើនេះធំឡើង គឺធំឡើងកាលណា កាលនោះនឹងដូចម្តេចទៅ វាពិតជាសម្លាប់មនុស្សបានមិនខាន ព្រះរាជកុមារត្រាស់ថា ដោយហេតុដូចពោលមក

នេះ យើងត្រូវដកវាចោល ។

គ្រានោះ ព្រះបរមពោធិសត្វក៏ពោលពាក្យនេះនឹងព្រះរាជកុមារថា បពិត្រព្រះរាជកុមារ ទ្រង់មានរាជឱង្ការអំពីពន្លកស្ដៅនេះថា ពេលនេះ វាមានជាតល្វីងយ៉ាងហ្នឹងទៅហើយ កាលវាធំឡើងនឹងដូចម្ដេចទៅ អាស្រ័យវាហើយនឹងមានសេចក្ដីចម្រើនអំពីទីណា ដូច្នេះត្រូវដកចោល ព្រះរាជ-កុមារបដិបត្តិចំពោះដើមស្ដៅនេះ យ៉ាងណា សូម្បីអ្នកដែនរបស់ព្រះរាជ-កុមារ ក៏គង់ដូច្នោះដែរ នឹងនាំគ្នាពោលថា ព្រះរាជកុមារនេះនៅក្មេងកាចសាហាវយង់ឃ្នងយ៉ាងនេះទៅហើយ កាលចម្រើនព្រះជន្មធំឡើងបានគ្រប់គ្រងរាជសម្បត្តិ នឹងដូចម្ដេចទៅ ពួកយើងអាស្រ័យព្រះរាជកុមារនេះ នឹងមានសេចក្ដីសុខចម្រើនដូចម្ដេចបាន ហើយមិនព្រមថ្វាយរាជ-សម្បត្តិដែលជារបស់នៃត្រកូលរបស់ព្រះរាជកុមារ នឹងដកព្រះរាជកុមារដូចដកដើមស្ដៅនេះ ហើយបណ្ដេញព្រះរាជកុមារចេញអំពីដែន ព្រោះហេតុនោះ ចូរទ្រង់លះបង់ភាពជាអ្នកមានខ្លួនដូចជាដើមស្ដៅ ហើយដល់ព្រមដោយការអត់ធន់ មានមេត្តានិងករុណា ចាប់ពីពេលនេះតទៅចុះ ។ ចាប់ពីពេលនោះមក ព្រះរាជកុមារនោះក៏អស់មានះ មិនចចេសរឹងរូសសម្បូរដោយការអត់ធន់ មានមេត្តានិងករុណា តាំងនៅក្នុងឱវាទរបស់ព្រះបរមពោធិសត្វ កាលព្រះបិតាសោយព្រះទិវង្គតទៅក៏បានគ្រប់គ្រងរាជ-សម្បត្តិ ទ្រង់បំពេញបុណ្យមានឲ្យទានជាដើម ក្រោយអំពីសោយទិវង្គត

ស្តេចទៅតាមយថាកម្ម ។

ព្រះបរមសាស្តា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ត្រាស់បញ្ជាក់ទៀតថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលតថាគតទូន្មានលិច្ឆវីកុមារដែលអាក្រក់ឃោរឃៅបាននោះ សូម្បីក្នុងកាលមុនតថាគតក៏ធ្លាប់ទូន្មានលិច្ឆវីកុមារដែរ លុះទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ទុដ្ឋកុមារក្នុងកាលនោះ បានមកជាលិច្ឆវីកុមារក្នុងកាលឥឡូវនេះ ព្រះរាជាបានមកជាអានន្ទ ចំណែកតាបសអ្នកឲ្យឱវាទ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ឯកបណ្ណជាតក ទី ៩ ។

# អដ្ឋកថា សញ្ជីវជាតក ទី ១០

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការលើកតម្កើងអសប្បុរសរបស់ព្រះបាទអជាតសត្រូវ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អសន្តំ យោ បគ្គណ្ហាតិ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ព្រះបាទអជាតសត្រូវនោះ ទ្រង់ជ្រះថ្លានឹងភិក្ខុទេវទត្ត អ្នកទ្រុស្តសីល មានបាបធម៌ ជាសត្រូវចំពោះព្រះពុទ្ធអង្គនិងពុទ្ធសាវក ទ្រង់សរសើរភិក្ខុទេវទត្តអ្នកមិនស្ងប់ជាអសប្បុរស ទ្រង់ព្រះតម្រិះថា ទ្រង់នឹងធ្វើសក្ការបូជាភិក្ខុទេវទត្ត ដូច្នេះហើយ ទ្រង់បរិច្ចាគទ្រព្យជាច្រើន

ឲ្យសាងវិហារឯគយាសីសប្រទេស ទ្រង់ជឿតាមភិក្ខុទេវទត្ត សម្រេចទោសព្រះរាជបិតាដែលជាព្រះរាជាតាំងនៅក្នុងធម៌ ជាព្រះអរិយសាវកថ្នាក់សោតាបន្ន កាត់ផ្តាច់ឧបនិស្ស័យសោតាបត្តិមគ្គរបស់ព្រះអង្គ (ខ្លួនឯង) ដល់នូវមហាវិនាស ទ្រង់ព្រះសណ្តាប់ថា ទេវទត្តត្រូវផែនដីស្រូប ក៏សង្ស័យថា ខ្លួនអញនឹងត្រូវផែនដីស្រូបដែរឬហ្ន៎ មិនបានទទួលសេចក្តីសុខក្នុងរាជសម្បត្តិ មិនបានប្រសព្វសេចក្តីត្រេកអរលើព្រះក្រឡាបន្ទំ ទ្រង់ញាប់-ញ័រជានិច្ច ដូចប្រេតដែលត្រូវទារុណកម្មដ៏សាហាវ ព្រះរាជាទ្រង់នឹកឃើញថា ព្រះអង្គដូចជាកំពុងត្រូវផែនដីស្រូប ដូចអណ្តាតភ្លើងក្នុងអវិចីកំពុងលៀនចេញមក ហើយដូចព្រះអង្គត្រូវគេបញ្ជាឲ្យផ្ទំផ្ងារលើផ្ទាំងដែកដ៏ក្តៅ ហើយត្រូវចាក់ដោយលំពែងដែកស្រួចដូច្នោះ ដោយហេតុនោះការស្ងប់ព្រះទ័យសូម្បីតែបន្តិច ក៏មិនមានដល់ព្រះអង្គដែលញាប់ញ័រដូចមាន់ដែលត្រូវអារក ។ ព្រះរាជាមានព្រះរាជបំណងចូលគាល់ព្រះសម្មា-សម្ពុទ្ធ ទ្រង់មានព្រះរាជបំណងនឹងសូមឲ្យព្រះពុទ្ធអង្គអត់ទោសឲ្យ ទាំងមានព្រះរាជបំណងនឹងទូលសួរបញ្ហា ប៉ុន្តែព្រោះព្រះអង្គមានកំហុសធំទើបមិនអាចនឹងចូលគាល់បាន ។

គ្រានោះ ជួននឹងនគររាជគ្រឹះមានបុណ្យនក្ខត្តឫក្សប្រចាំខែកត្តិក មហាជននាំគ្នាតាក់តែងក្រុងដូចជាទេវនគរ ព្រះបាទអជាតសត្រូវចោម-រោមដោយពួកអាមាត្យ ទ្រង់គង់លើព្រះរាជអាសនៈមាសក្នុងលានព្រះ-

រាជវាំង ទ្រង់ទតឃើញពេទ្យជីវកោមារភច្ចអង្គុយគាល់ក្នុងទីមិនឆ្ងាយ ទ្រង់មានបរិវិតក្កថា អញនឹងបបួលពេទ្យជីវកោមារភច្ចទៅគាល់ព្រះសម្មាសម្ពុទ្ធ ប៉ុន្តែអញមិនអាចនឹងបបួលត្រង់ៗថា ជីវកសម្លាញ់ យើងមិនអាចនឹងទៅតែម្នាក់ឯងបាន មកចុះ នាំយើងទៅគាល់ព្រះបរមសាស្តាផងចុះ ដូច្នេះ ត្រូវពណ៌នាអំពីលំអនៃរាត្រីដល់ជីវកនោះដោយបរិយាយជាច្រើន ហើយសឹមពោលថា ថ្ងៃនេះ ពួកយើងគួរតែចូលទៅរកសមណៈឬព្រាហ្មណ៍ណាមួយ កាលពួកយើងចូលទៅរកលោកហើយ នឹងគប្បីញ៉ាំងចិត្តរបស់យើងឲ្យផ្លូវផង់បាន ស្តាប់ពាក្យនោះហើយ ពួកអាមាត្យនឹងនាំគ្នាពណ៌នាគុណនៃសាស្តាទាំងឡាយរបស់ខ្លួន សូម្បីពេទ្យជីវកក៏គង់នឹងពោលពណ៌នាគុណរបស់ព្រះសម្មាសម្ពុទ្ធដែរ កាលបើដូច្នោះ អញនឹងបបួលពេទ្យជីវកទៅកាន់សម្នាក់ព្រះបរមសាស្តា លុះគិតដូច្នោះហើយ ព្រះរាជាក៏ពណ៌នាភាពល្អស្អាតនៃរាត្រីដោយបទទាំង ៥ ដូច្នេះថា

រាត្រីប្រាសចាកទោស (ស្វាងរុងរឿង) គួរជាទីត្រេកអរ អ្វីម៉្ល៉េះហ្ន៎
រាត្រីប្រាសចាកទោស មានភាពល្អ អ្វីម៉្ល៉េះហ្ន៎
រាត្រីប្រាសចាកទោស គួរជាទីរមិលមើល អ្វីម៉្ល៉េះហ្ន៎
រាត្រីប្រាសចាកទោស ជាទីនាំមកនូវសេចក្តីជ្រះថ្លា អ្វីម៉្ល៉េះហ្ន៎
រាត្រីប្រាសចាកទោស គួរជាទីកំណត់ដឹង អ្វីម៉្ល៉េះហ្ន៎

ក្នុងថ្ងៃនេះ អ្នកណាទៅហ្ន៎ ពួកយើងគួរចូលទៅរក បុគ្គលណា

ដែលពួកយើងគួរចូលទៅរក ដើម្បីញុំាងចិត្តឲ្យស្រស់ថ្លាបាន ។ គ្រានោះ អាមាត្យម្នាក់ពោលគុណរបស់បូរណកស្សប ម្នាក់ពោលគុណរបស់មក្ខលិគោសាល ម្នាក់ពោលគុណរបស់អជិតកេសកម្ពល ម្នាក់ពោលគុណរបស់បកុធកច្ចាយន ម្នាក់ពោលគុណរបស់សញ្ជយវេលដ្ឋបុត្ត ម្នាក់ពោលគុណរបស់និគណ្ឋនាថបុត្ត ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវពាក្យសរសើររបស់អាមាត្យទាំងនោះហើយទ្រង់តុណ្ហីភាព ព្រះរាជាទ្រង់ប្រាថ្នាពាក្យរបស់មហាមាត្យជីវកប៉ុណ្ណោះ ។ ចំណែកពេទ្យជីវកត្រិះរិះថា កាលព្រះរាជាត្រាស់នឹងអញ ទើបអញក្រាបទូល លុះគិតដូច្នេះហើយ អង្គុយស្ងៀមមិនឆ្ងាយអំពីព្រះរាជា ។ គ្រានោះ ព្រះរាជាក៏ត្រាស់សួរពេទ្យជីវកថា នែសម្លាញ់ជីវក ហេតុដូចម្ដេចទើបអ្នកនៅស្ងៀម ។ ខណៈនោះពេទ្យជីវកក៏ក្រោកចាកអាសនៈ ប្រណមអញ្ជលីបែរមុខទៅរកព្រះដ៏មានព្រះភាគហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះដ៏មានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ឥឡូវនេះ ទ្រង់កំពុងគង់នៅក្នុងចម្ការស្វាយរបស់ទូលបង្គំ មួយអន្លើដោយភិក្ខុសង្ឃច្រើន ចំនួន ១២៥០ រូប ឯកិត្តិស័ព្ទដ៏ពីរោះរបស់ព្រះដ៏មានព្រះភាគអង្គនោះ បានល្បីខ្ចរខ្ចាយសុះសាយទៅយ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាងហើយ ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ចំពោះព្រះអង្គដោយប្រពៃ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ គឺសេចក្ដីចេះ

ដឹងនិងក្រឹត្យដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អទៅកាន់ព្រះ-និព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិ-គុណ មិនមានបុគ្គលណាមួយស្មើ ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត (កាលប្រកាសព្រះពុទ្ធគុណហើយ) ក៏ប្រកាសបាដិហារិយ៍ ៩០០ ប្រការ អានុភាពរបស់ព្រះដ៏មានព្រះភាគ មានបុព្វនិមិត្តតាំងពីប្រសូតជាដើម ជាប្រភេទហើយ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមស្ដេចយាងចូលទៅគាល់ព្រះដ៏មានព្រះភាគអង្គនោះ ហើយទ្រង់ស្តាប់ធម៌ ត្រាស់សួរបញ្ហាចុះ ។ ព្រះរាជាទ្រង់មានមនោរថពេញបរិបូណ៌ត្រាស់ថា សម្លាញ់ជីវក បើដូច្នោះ អ្នកចូរប្រើឲ្យគេចាត់ចែងដំរីចុះ ។ លុះបញ្ជាឲ្យចាត់ចែងយានពាហនៈហើយ ព្រះរាជាស្ដេចយាងទៅកាន់ជីវកម្ពវ័នដោយអានុភាពដ៏ធំ ទ្រង់ទតឃើញព្រះតថាគតចោមរោមដោយពួកភិក្ខុក្នុងរោងធំ ក្នុងជីវកម្ពវ័ននោះ ទ្រង់ឆ្មៀងមើលពួកភិក្ខុ អ្នកប្រាសចាកការកម្រើកដូចទូកធំនៅក្នុងកណ្ដាលសមុទ្រ ពេលស្ងប់រលកហើយដូច្នោះ ដោយទូទៅទ្រង់ជ្រះថ្លាក្នុងឥរិយាបថនោះឯង ដោយទ្រង់ព្រះតម្រិះថា បរិស័ទដូច្នេះ អញមិនដែលឃើញឡើយ ទ្រង់ត្រាស់ផង ទ្រង់ផ្គងអញ្ជលីចំពោះព្រះអង្គផងរួចត្រាស់សរសើរ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ទ្រង់គង់នៅក្នុងទីដ៏

*សមគួរ ហើយក្រាបទូលសួរបញ្ហាក្នុង* **សាមញ្ញផលសូត្រ** *។ គ្រានោះព្រះដ៏មានព្រះភាគទ្រង់សម្តែង* **សាមញ្ញផលសូត្រ** *កាលចប់ព្រះធម្មទេសនា ព្រះរាជាទ្រង់សប្បាយព្រះទ័យ ទូលសូមឲ្យព្រះដ៏មានព្រះភាគទ្រង់អត់ទោស ហើយស្តេចក្រោកចាកអាសនៈ ទ្រង់ធ្វើប្រទក្សិណព្រះបរមសាស្តាហើយ ស្តេចចៀសចេញទៅ ។ កាលព្រះរាជាយាងទៅហើយមិនយូរប៉ុន្មាន ព្រះបរមសាស្តាទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនេះ ជីករំលើងគុណធម៌របស់ខ្លួនចេញអស់ហើយ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនេះ ផ្តាច់បង់គុណធម៌ខ្លួនចេញអស់ហើយ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើព្រះរាជាអង្គនេះមិនបានផ្តាច់បង់ព្រះជន្មាយុនៃព្រះបិតាដែលជាព្រះធម្មរាជ អ្នកប្រកបដោយធម៌ ព្រោះប្រាថ្នាភាពជាធំទេ ធម្មចក្ខុ គឺសោតាបត្តិមគ្គដែលប្រាសចាកធូលី ប្រាសចាកមន្ទិលនឹងកើតឡើងដល់ព្រះរាជាអង្គនោះ លើអាសនៈនេះមិនខានឡើយ ប៉ុន្តែព្រះអង្គអាស្រ័យទេវទត្ត លើកតម្កើងអសប្បុរសទើបវិនាសសាបសូន្យចាកសោតាបត្តិផល ។ ថ្ងៃស្អែកឡើង ភិក្ខុទាំងឡាយលើករឿងឡើងសន្ទនាគ្នាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ បានឮថា ព្រះបាទអជាតសត្រូវសាបសូន្យចាកសោតាបត្តិផល ព្រោះលើកតម្កើងអសប្បុរស អាស្រ័យភិក្ខុទេវទត្តដែលទ្រុស្តសីល មានបាបធម៌ ទ្រង់ធ្វើបិតុឃាតកម្ម ទ្រង់ជាព្រះរាជាដែលភិក្ខុទេវទត្តឲ្យវិនាសហើយ ។*

ព្រះបរមសាស្ដា ស្ដេចយាងមកហើយ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំង-ឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាអំពីរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែពេលនេះប៉ុណ្ណោះទេ ដែលព្រះបាទអជាត-សត្រូវលើកតម្កើងអសប្បុរស ដល់នូវសេចក្ដីវិនាសដ៏ធំនេះ សូម្បីកាលពីមុន ព្រះរាជាអង្គនេះ ក៏ទម្លាយខ្លួនឯងដោយការលើកតម្កើងអសប្បុរសដែរ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍មានសម្បត្តិច្រើន ចម្រើនវ័យទៅកាន់នគរតក្កសិលារៀនសព្វសិល្បវិទ្យា បានជាអាចារ្យទិសាបាមោក្ខក្នុងនគរពារាណសី បង្រៀនសិល្បៈដល់មាណព ៥០០ នាក់ ។ បណ្ដាមាណពទាំងនោះ មានមាណពម្នាក់ឈ្មោះ សញ្ជីវៈ ព្រះបរមពោធិសត្វបានឲ្យមន្តធ្វើមនុស្សស្លាប់ឲ្យរស់ឡើងវិញ ដល់មាណពនោះ មាណពនោះរៀនមន្តដែលធ្វើមនុស្សស្លាប់ឲ្យរស់ឡើងវិញ តែម្យ៉ាងមិនបានរៀនមន្តសម្រាប់ការពារ ។ ថ្ងៃមួយ ទៅព្រៃរកឧសនឹងសម្លាញ់ឃើញខ្លាធំស្លាប់មួយក៏និយាយនឹងពួកមាណពថា អ្នកមានអាយុទាំងឡាយខ្ញុំនឹងធ្វើខ្លាធំស្លាប់មួយនេះ ឲ្យរស់ឡើងវិញ ។ មាណពទាំងឡាយពោលជំទាស់ថា អ្នកនឹងមិនអាចទេ ។ មាណពនោះពោលថា ខ្ញុំនឹងធ្វើវាឲ្យ

រស់ឡើងវិញ ឲ្យអ្នកទាំងឡាយឃើញគ្រប់គ្នា ។ មាណពទាំងនោះ ក៏ពោលថា ប្រសិនបើអ្នកអាចក៏ចូរដាស់វាឲ្យភ្ញាក់ឡើងចុះ លុះពោលហើយម្នាក់ៗក៏ប្រញាប់ឡើងដើមឈើ ។ សញ្ជីវមាណពរាយមន្តហើយ គ្រវែងខ្លាដែលស្លាប់ដោយដុំក្រួស ខ្លាក្រោកឡើងលោតខាំសញ្ជីវមាណពត្រង់កធ្វើឲ្យអស់ជីវិត ដួលដេកក្នុងទីនោះឯង ទាំងមាណពទាំងខ្លាដេកស្លាប់នៅទីនោះ ។ ពួកមាណពជញ្ជូនឧសទៅហើយប្រាប់រឿងនោះដល់អាចារ្យ ។ ព្រះបរមពោធិសត្វក៏ហៅមាណពទាំងឡាយមកពោលថា នៃអ្នកទាំង-ឡាយ ធម្មតាអ្នកដែលលើកតម្កើងអសប្បុរស ធ្វើសក្ការៈនិងសេចក្តីស្និទ្ធ-ស្នាល ក្នុងទីដែលមិនសមគួរ រមែងបានទទួលទុក្ខបែបនេះ លុះពោលដូច្នេះហើយ ពោលគាថានេះថា

**អសន្តំ យោ បគ្គណ្ហាតិ អសន្តំ ចូបសេវតិ**
**តមេវ ឃាសំ កុរុតេ ព្យគ្ឃោ សញ្ជីវកោ យថាតិ ។**

បុគ្គលណាលើកតម្កើងនូវជន ជាអសប្បុរសផង ចូលទៅសេពគប់នូវជន ជាអសប្បុរសផង ជនជាអសប្បុរសនោះ រមែងធ្វើនូវបុគ្គលនោះឯង ឲ្យទៅជាអាហារដូចខ្លានឹងសញ្ជីវមាណព ។

បណ្តាបទទាំងនោះ បទថា **អសន្តំ** បានដល់ អ្នកទ្រុស្តសីលមានបាបធម៌ ប្រកបដោយទុច្ចរិត ៣ ប្រការ ។

*បទថា* **យោ បគ្គណ្ហាតិ** *សេចក្ដីថា បណ្ដាជនមានក្សត្រជាដើម បុគ្គលណាលើកតម្កើង គឺធ្វើសក្ការៈ ធ្វើសេចក្ដីស្និទ្ធស្នាលនឹងអសប្បុរស អ្នកទ្រុស្ដសីលបែបនេះ ចំពោះបព្វជិតដោយប្រគេនបច្ច័យមានចីវរជាដើម ជាមួយគ្រហស្ថដោយការឲ្យគ្រប់គ្រងតំណែង ជាឧបរាជ ជាសេនាបតី ជាដើម ។*

*បទថា* **អសន្តំ ចូបសេវតិ** *សេចក្ដីថា ម្យ៉ាងទៀតបុគ្គលណា រមែងចូលទៅសេពគប់ ស្និទ្ធស្នាលនឹងអសប្បុរសទ្រុស្ដសីលបែបនេះ ។*

*បទថា* **តមេវ ឃាសំ កុរុតេ** *សេចក្ដីថា បុគ្គលអាក្រក់ទ្រុស្ដសីលនោះ រមែងខាំបុគ្គលនោះ គឺអ្នកដែលលើកតម្កើងអសប្បុរសនោះស៊ីបានដល់ធ្វើអ្នកនោះ ឲ្យដល់នូវការអស់ជីវិត ។*

*សួរថា ដូចអ្វី?*

*ឆ្លើយថា ដូចខ្លាដែលរស់ឡើងវិញ ព្រោះមាណពជប់ឡើង អធិប្បាយថា ខ្លាងាប់ហើយមានជីវិតឡើងវិញ ដោយអាស្រ័យសញ្ជីវមាណពរាយមន្តលើកតម្កើង ដោយការប្រគល់ជីវិតឲ្យ ត្រឡប់ផ្ដាច់ជីវិតសញ្ជីវមាណពអ្នកឲ្យជីវិតដល់វា ឲ្យដួលដេកនៅទីនោះឯង យ៉ាងណា សូម្បីអ្នកដទៃក៏ដូច្នេះដែរ គឺបុគ្គលណាលើកតម្កើងអសប្បុរស អសប្បុរសទ្រុស្ដសីលនោះ រមែងទម្លាយបុគ្គលអ្នកលើកតម្កើងនោះ អ្នកដែលលើកតម្កើងពួកជនជាអសប្បុរស រមែងដល់នូវការវិនាស ដោយប្រការដូច្នេះ ។*

*ព្រះបរមពោធិសត្វសម្ដែងធម៌ដល់មាណពទាំងឡាយ ដោយគាថានេះ ធ្វើបុណ្យមានឲ្យទានជាដើម លុះអស់ជីវិតហើយក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្ដា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់សមោធានជាតកថា* **តទា មតព្យគ្ឃុដ្ឋាបកោ មាណវោ អជាតសត្តុ អហោសិ ទិសាចាមោក្ខោ អាចរិយោ បន អហមេវ អហោសិន្តិ** *មាណពអ្នកធ្វើខ្លាដែលស្លាប់ឲ្យរស់ឡើងវិញក្នុងកាលនោះ បានមកជាព្រះបាទ-អជាតសត្រូវ ចំណែកអាចារ្យទិសាបាមោក្ខ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា សញ្ជីវជាតក ទី ១០ ។

ចប់ អដ្ឋកថា កកណ្ដកវគ្គ ទី ១៥ ។

ចប់ ឯកនិបាត ។

# រួមជាតកដែលមាននៅក្នុងវគ្គនេះគឺ

*គោធជាតក ១ សិង្គាលជាតក ១ វិរោចនជាតក ១ នង្គុដ្ឋជាតក ១ រាធជាតក ១ កាកជាតក ១ បុប្ផរត្តជាតក ១ សិង្គាលជាតក ១ ឯកបណ្ណជាតក ១ សញ្ជីវជាតក ១ ។*

# រួមវគ្គដែលមាននៅក្នុង ឯកនិបាតភាគ ទី ២ នេះគឺ

*អត្ថកាមវគ្គ ១ អាសីសវគ្គ ១ ឥត្ថីវគ្គ ១ វរុណវគ្គ ១ អបាយិម្ហវគ្គ ១ លិត្តវគ្គ ១ បរោសតវគ្គ ១ ហំសិវគ្គ ១ កុសនាឡិវគ្គ ១ អសម្បទានវគ្គ ១ កកណ្ដកវគ្គ ១ ។*

## នាមពុទ្ធបរិស័ទជួយពិនិត្យអក្ខរាវិរុទ្ធ

លោកម្ចាស់ គង់ សុមិត្ត　　លោកម្ចាស់ សួន ចាន់ផល្លី

លោកម្ចាស់ កែន សុធន

លោកគ្រូ អ៊ឹម វ៉ែយ៉ា　　ឧ.ស.ឡាន សុខុម

ឧ.សិ.ហេង ចន្ទបុញ្ញវត្តី　　ឧ.សិ. ទី សុធី

ឧ.សិ.ពាម សាយឿន　　ឧ.សិ. ស៊ីម យ៉េកហួយ ។

## នាមពុទ្ធបរិស័ទជួយវាយអត្ថបទ

១- លោកម្ចាស់ ប៉ាន់ ឈា

២-ឧ.សិ. ហេង ចន្ទបុញ្ញវត្តី　　៣-យុវជន អន ធីម ។

## នាមពុទ្ធបរិស័ទជួយឧបត្ថម្ភសម្ភារៈ និងប្រាក់សម្រាប់ការងារធម្មទាន

ឧ.ស. ហេង វិរិន្ទ　ឧ.សិ. ហេង ចន្ទរចនា　ឧ.ស.ហេង វណ្ណៈ

ឧ.ស.ហេង វណ្ណា　ឧ.សិ.ហេង ចន្ទកុលសុកៈ　ឧ.ស.ហេង រស្មី

និងក្រុមគ្រួសារ　　ឧ.សិ.ប៉ាល់ធីតា + ស្វាមី និងកូនចៅ ។

# ពុទ្ធបរិស័ទអ្នកមានឧបការៈក្នុងការខាររធម្មទាន

| | |
|---|---|
| លោកម្ចាស់ មាស សាពួន | លោកម្ចាស់ កន ជឿន |
| លោកម្ចាស់ ហ៊ី ហេង | លោកម្ចាស់ លឹម ឈាងលី |
| លោកម្ចាស់ ង៉ែត ប៊ុននឿន | លោកម្ចាស់ ប៉ាន់ ឈា |
| លោកម្ចាស់ ជា ចាន់ | លោកម្ចាស់ ផល ផានិត |
| លោកម្ចាស់ មិត្ត កំសាន្ត | លោកម្ចាស់ កែវ វុទ្ធី |
| លោកម្ចាស់ សំ សាន | លោកម្ចាស់ ឈីវ ហៀក ។ |

| | | |
|---|---|---|
| ឧ.សិ.ជុន ស៊ូគី | ឧ.សិ.ឈឹម សុខែម | ឧ.សិ.ស៊ីម យ៉េកហួយ |
| ឧ.សិ.រស់ គឹមថាន | ឧ.សិ.ទីសុធី | ឧ.សិ.ប៉ែន រម្មណីយ៍ |
| ឧ.សិ.ទេព ផលម៉ាឡា | ឧ.ស.យិច ឈីន | ឧ.សិ.តែ សុមាលី (បួយ) |
| ឧ.សិ.ជួន ស៊ីមជាង | ឧ.សិ.អៀង ប៊ុក | ឧ.សិ.ហាវ សារុធ |
| ឧ.សិ.សរ យ៉ាត | ឧ.សិ.សូ យឿន | ឧ.សិ.ហេង ចន្ទកុលសុកៈ |
| ឧ.សិ.សុខ ភួង | ឧ.សិ.បានរ៉ូ | ឧ.សិ.គង់ វណ្ណា |
| ឧ.សិ.គឹម អា | ឧ.សិ.ប៉ាល់ ធីតា | ឧ.សិ.ស្រី វណ្ណនី |
| ឧ.សិ. យឹម វ៉ន | ឧ.សិ.យ៉ា សុខគីម | ឧ.សិ.ខាំ នាងសុខី |
| ឧ.សិ.សាធ ណាគ្រី | ឧ.សិ.អឿសុខុន | ឧ.សិ.រៀល សុខា |
| ឧ.សិ.មុត សុជាតា | ឧ.សិ.ឈិតសាម៉េន | ឧ.សិ.ឆោម ពុទ្ធរ័ត្ន |
| ឧ.សិ.ប៊ិន ប៊ុនធី ។ | | |

# នាមពុទ្ធបរិស័ទដែលមានសទ្ធា
# បរិច្ចាគប្រាក់បោះពុម្ពសៀវភៅនេះ

១- ភិក្ខុមង្គលជោតិប្បញ្ញោ អ៊ឹម ឌុន ............................... ១០ $

២-ភិក្ខុគន្ធសីលោ មុិល សុភា ................................. ២០.០០០៛

៣-សាមណេរ ភារៈ,សា. សីលា ,សា. អ៊ុិល អុល ............. ២.០០០០ ៛

៤-សាមណេរ អន ថៃ ............................................... ២០.០០០៛

៥- ឧ.សិ.ស៊ី ឈុនហ៊ាង ព្រមទាំងកូនចៅ .............................. ២០០ $

៦- ឧ.សិ.ប៉ែន រម្មណីយ៍ និង ស្វាមី ព្រមទាំងបុត្រ ................. ១០០ $

៧- ឧ.សិ.ដួង លី និង ស្វាមី ព្រមទាំងបុត្រ .............................. ១០០ $

៨-ឧ.សិ.តឹក អេងគី ព្រមទាំងកូនចៅ ..................................... ៥០ $

៩-ឧ.សិ.កាំង ប៉ោទៀង+ស្វាមី ព្រមទាំងកូនចៅ .................... ៥០ $

១០-ឧ.សិ.ស៊ុន ដា (ហៅ កៅ ដា ) និងកូនចៅ ......... ១៥.០០០៛+ ៣០ $

១១-ឧ.ស.ជួន ហុី ឧ.សិ.ខ្វាន់ ទឹម+ កូនចៅ ................................ ២០$

១២-ឧ.ស.ហុក ហេង ឧ.សិ.ស៊ុយ ឡៃ+ ឧ.ស.ហេងវិរិទ្ធ+ កូនចៅ .... ២០ $

១៣- ឧ.ស.ម៉ម សេង ឧ.សិ.ខាត់ រតនា ព្រមទាំងបុត្រ .................. ២០ $

១៤-ឧ.សិ.ម៉ម មុន្នីរ័ត្ន + ឧ.សិ.ម៉ម នរម ............................ ២០ $

១៥-ឧ.ស.ហាង់ ច័ន្ទរិទ្ធនិង ឧ.សិ. ដួង រ៉ាវី ព្រមទាំងកូនចៅ ............ ២០ $

១៦-ឧ.សិ.អុឹង គីមរស់ ព្រមទាំងកូនចៅ .................................... ២០ $

១៧-ឧ.ស.តាំង សុផល ឧ.សិ.ឡុង កេង ព្រមទាំងកូនចៅ ... ២០ $

១៨-ឧ.សិ.ម៉ី សារ៉ែន ឧ.សិ.ឡាំង គឹមជាង ព្រមទាំងកូនចៅ ........ ១៥ $

១៩-ឧ.សិ.ម៉ម សុខហេង+ កូន សុវណ្ណឌី +ស្វាមី ........ ៤០.០០០៛ + ១០ $

២០-ឧ.សិ.ឃឹម វ៉ែនព្រមទាំងមិត្តព្រះធម៌ ................ ៦៣.០០០៛ + ១០ $

២១-ឧ.សិ.ផន ចន្ថា និង ស្វាមី ព្រមទាំងបុត្រ ............ ១២.០០០៛ + ១០ $

២២-ឧ.សិ.ហាស់ សុខុម ព្រមទាំងកូនចៅ ............. ១០.០០០៛ + ១០ $

២៣-ឧ.សិ.ហាក់ គៀនសុខ ព្រមទាំងកូនចៅ .......................... ១០ $

២៤-ឧ.សិ.គឹម.យុន ព្រមទាំងកូនចៅ ........................................ ១០ $

២៥-ឧ.សិ.ប៊ុន រ៉ាវី ព្រមទាំងកូនចៅ ...................................... ១០ $

២៦-ឧ.ស.ស្រេង មួយឈាង ឧ.សិ.ហៀប រួចគាវ ................. ១០ $

២៧-ឧ.ស.គ្រី ឈាងលឹម ឧ.សិ.ឃួន សៀកលាង + កូនចៅ ........ ១០ $

២៨-ឧ.សិ.សំ ចន្ថា និង ស្វាមី ព្រមទាំងបុត្រ .............................. ៩ $

២៩-ឧ.សិ.ហ៊ឺ អ៊ុនសេង ឧ.សិ. ហ៊ឹង ស៊ីមណៃ + កូនចៅ .............. ៨ $

៣០-ឧ.សិ.នាង សេង និង ឧ.សិ. មាន ហរិតា .......................... ៨ $

៣១-ឧ.ស.យិន ប៊ុន ព្រមទាំកូនចៅ ..................................... ៥ $

៣២-ឧ.សិ.សោម យ៉ាន ព្រមទាំងកូនចៅ ................................. ៥ $

៣៣-ឧ.សិ.រស់ វណ្ណា ព្រមទាំងកូនចៅ .................................... ៥ $

៣៤-ឧ.សិ គ្រុយ លាងចាយ ព្រមទាំងកូនចៅ ....................... ៥ $

៣៥-ឧ.ស.ហុង ហ៊ាន ឧ.សិ.ហ៊ឹង សៅ ព្រមទាំងកូនចៅ .............. ៥ $

៣៦-ឧ.ស.អេង វណ្ណាឧ.សិ សៅ ណារី ព្រមទាំកូនចៅ .......... ៥ $

៣៧- ឧ.សិ.សំ ម៉ិចព្រមទាំងបុត្រ ............................ ៤ $ + ១០.០០០៛

៣៨- លោក គីម ឡុង និងភរិយា ព្រមទាំងបុត្រ ................................ ៤ $

៣៩-ឧ.សិ តាំង ស៊ីម លោកយាយ ( ចន្ទ្រី ) ព្រមទាំងកូនចៅ ......... ៤ $

៤០-ឧ.សិ ទិន សន ព្រមទាំងកូនចៅ ............................................ ៤ $

៤១-ឧ.សិ ហាំង គិន ព្រមទាំងកូនចៅ ............................................ ៤ $

៤២-ឧ.សិ.នៅ សុជាទី និង ស្វាមី ព្រមទាំងបុត្រ ........................ ៤ $

៤៣-ឧ.ស.សំ ចេង ព្រមទាំងកូនចៅ .............. .. ៤ $

៤៤-ឧ.ស.តែ ណៃ ឧ.សិ. ប៊ុន ទូច ព្រមទាំងកូនចៅ ........................ ៤ $

៤៥-ឧ.សិ. ទូច សាម៉ែ ព្រមទាំងកូនចៅ ................................ ៤ $

៤៦-ឧ.សិ. ជន បុប្ផាក្លូង ព្រមទាំងកូនចៅ .................................... ៤ $

៤៧-ឧ.សិ. គឹម អ៊ុ ព្រមទាំងកូនចៅ ..................................... ៤ $

៤៨-ឧ.សិ.យូ ស៊ីយ៉ាន និង ស្វាមី ព្រមទាំងបុត្រ ........................ ៤ $

៤៩-ឧ.សិ. លឹម មួយហេង ព្រមទាំងកូនចៅ ............................ ៤ $

៥០- បុត្តធីតា និងកូនចៅ ឧ.សិ.ណុប យ៉េត ............................ ៤ $

៥១-ឧ.សិ. ធីន ម៉ៅព្រមទាំងកូនចៅ ....................................... ៤ $

៥២-ឧ.សិ. ឡាច ធុំព្រមទាំងកូនចៅ ....................................... ៤ $

៥៣-ឧ.ស.លីម ឈុងសុង ឧ.សិ. តាំង មួយខេង + កូនចៅ ............ ៤ $

៥៤-ឧ.សិ.ឡាំង គឹមជាង ព្រមទាំងកូនចៅ .............................. ៤ $

៥៥-លោក វេជ្ជ បណ្ឌិត ម៉ី សំបូរ ភរិយា ឌួង ធរីវណ្ណ និង បុត្រ ....... ៤ $

៥៧-ឧ.សិ.ព្រុំ ស្រីអួន និង ស្វាមី ព្រមទាំងបុត្រ .............. ១០០.០០០៛

៥៨-ញោម ផុស ............................................................. ៨០.០០០៛

៥៩-ឧ.សិ. នូ យ៉ឹម + ពុទ្ធបរិស័ទពោធិចិនតុង ............... ៦២.២០០៛

៦០-ឧ.សិ.មូល វណ្ណថេត + ក្រុមគ្រួសារ ..................... ៦០.០០០៛

៦១-ឧ.សិ.សាធ ណាគ្រី +ឧ.សិ.វូ ណារី + ឧ.សិ. ហេង ភិរម្យ .... ៦០.០០០៛

៦២-ឧ.សិ.លី ឡៃហ៊ាង ព្រមទាំងកូនចៅ ................. ៥៥.០០០៛

៦៣-ឧ.សិ.ជាម ធុច និង ក្រុមគ្រួសារ ....................... ៤៥.០០០៛

៦៤-ឧ.សិ.តាំង ប៉ោជឹង (ហៅឧ.សិទន់)ព្រមទាំងកូនចៅ .... .... ៤០.០០០៛

៦៥-ឧ.សិ.យូ ប៉ូលីន និងស្វាមី ព្រមទាំងបុត្រ ............... .. ៤០.០០០៛

៦៦-ឧ.សិ.សួន គីមផល និងស្វាមី +កូនចៅ .................. ៤០.០០០៛

៦៧-ឧ.សិ.ឡាំងពិដោរ +ស្វាមី ឡុង ម៉េងលី និងបុត្រ ............ ៤០.០០០៛

៦៨-ឧ.សិ.ម៉េង លាក ព្រមទាំងបុត្រនិងចៅ .............. .. ៣២.០០០៛

៦៩-ឧ.សិ.ឃុត វ៉ាន់ថា ព្រមទាំងកូនចៅ ...................... ៣០.០០០៛

៧០-ឧ.ស.ឈឹម ហុក អ៊ាន ព្រមទាំងកូនចៅ ................. ៣០.០០០៛

៧១-ឧ.ស.សយ ពុទ្ធនិងភរិយា ព្រមទាំងបុត្រ .................. ៣០.០០០៛

៧២-ឧ.សិ.គូ ឱជី + ឧ.សិ.គូ ឆេងគុយ ....................... ២៦.០០០៛

៧៣- ឧ.សិ.ឈាវ សៀកឡោ ព្រមទាំងកូនចៅ ............ ២៦.០០០៛

៧៤-ឧ.សិ.ហ៊ិន ដារុង និង ឧ.សិ. យុន គីមជី .................. ២៦.០០០៛

៧៥-ឧ.សិ.អ៊ូ សុខសាន្ត .................................................... ២៥.០០០៛

៧៦-ឧ.សិ.អឿ សុខុន និង ស្វាមី ព្រមទាំងកូនចៅ ........... ២៥.០០០៛

៧៧-ឧ.ស.ម៉ៅ សុវណ្ណឌ៍ + ភរិយា + បុត្រ .............................. ២៥.០០០៛

៧៨-លោក សោម សុភាព លោកស្រី ស៊ាង សូលីលីន +បុត្រ .... ២៤.០០០៛

៧៩-ឧ.សិ.ហួត ជី ព្រមទាំងកូនចៅ ........................... ២២.០០០៛

៨០-ឧ.សិ.សុខ សារឿន ឧ.សិ. សុខ សាអ៊ុក+កូនចៅ ...... ២១.០០០៛

៨១-ឧ.ស.ជា ណានី ឧ.សិ.លឹម សុភ័ណ ព្រមទាំងបុត្រ ...... ... ២០.០០០៛

៨២-ឧ.ស. ហៃ ធន ឧ.សិ.ហ៊ាង ហ៊ាប + កូនចៅ (ព្រៃវែង) . ...... ២០.០០០៛

៨៣-ឧ.សិ.ស្វាយ សុខនព្រមទាំងកូនចៅ ................... ២០.០០០៛

៨៤-ឧ.ស.ប្រាក់ គឹមសុន និង ភរិយាព្រមទាំងបុត្រ .......... ២០.០០០៛

៨៥-ឧ.សិ.គង់ ហៀក ព្រមទាំងកូនចៅ ........................ ២០.០០០៛

៨៦-ឧ.សិ.ឡាំ ហេង ព្រមទាំងកូនចៅ .......................... ២០.០០០៛

៨៧-ឧ.សិ.យឹម ម៉ារី ព្រមទាំងកូនចៅ ......................... ២០.០០០៛

៨៨-ឧ.សិ.អ៊ួង ឈុនហួង និងស្វាមី ព្រមទាំងបុត្រ ............ ២០.០០០៛

៨៩-ឧ.សិ.ម៉ែន ថាប់ ព្រមទាំងកូនចៅ ........................... ២០.០០០៛

៩០-ឧ.សិ.ឈួន សុ ព្រមទាំងកូនចៅ .......................... ២០.០០០៛

៩១-ឧ.សិ.ប៉ុល ណាវ៉ែន ព្រមទាំងកូនចៅ ....................... ២០.០០០៛

៩២-ឧ.សិ.វណ្ណមុនី ព្រមទាំងកូនចៅ ............................ ២០.០០០៛

៩៣-ឧ.សិ.យស នឹម ព្រមទាំងកូនចៅ .......................... ២០.០០០៛

៩៤-ឧ.សិ.ណុប សាគុណ និងស្វាមីព្រមទាំងបុត្រ .......... .. ២០.០០០៛

៩៥-ឧ.សិ.ហុង ទូច ព្រមទាំងកូនចៅ ............................. ២០.០០០៛

៩៦-ឧ.សិ.ម៉ន ចិន្តា ព្រមទាំងកូនចៅ .............................. ២០.០០០៛

៩៧-ឧ.សិ. ខៀវ បុណ្យថា + ស្វាមី ព្រមទាំងបុត្រ ............ ២០.០០០៛

៩៨-ឧ.សិ.ឌួង គុយអេង ឧ.ស.នរៈ មេត្តា + កូនចៅ .......... .... ២០.០០០៛

៩៩-ឧ.សិ.អាយ ស្រី និង ស្វាមី ព្រមទាំងបុត្រ ............... ២០.០០០៛

១០០-ឧ.សិ.លីវ ណយ ព្រមទាំងកូនចៅ ........................... ២០.០០០៛

១០១-ឧ.សិ.ស្រី ស៊ីវុឌ្ឍថា ព្រមទាំងបុត្រ ........................... ២០.០០០៛

១០២-ឧ.សិ.ម៉ែន អូន ព្រមទាំងកូនចៅ ............................ ២០.០០០៛

១០៣-ឧ.សិ.ពិន ណារិន ព្រមទាំងកូនចៅ ............................ ២០.០០០៛

១០៤- ឧ.សិ.ឡុង ម៉េងអ៊ា និងស្វាមី +បុត្រ .......................... ២០.០០០៛

១០៥-ឧ.សិ.ជួរ ចាន់ថុល ព្រមទាំងកូនចៅ .......................... ២០.០០០៛

១០៦-ឧ.សិ.សៀក ថារី និងក្រុមគ្រួសារ .......................... ២០.០០០៛

១០៧-ឧ.សិ.ឈាវ សុភី ព្រមទាំងកូនចៅ ................... ១៨.០០០៛

១០៨-ឧ.សិ.តួច ហ៊ា ព្រមទាំងកូនចៅ ............................ ១៨.០០០៛

១១០-ឧ.សិ.អ៊ុន វីណា + អ្នកម្ដាយ ម៉ី ថន ...................... ១៨.០០០៛

១១១-ឧ.សិ.ស៊ីន ជីម .................................................. ១៨.០០០៛

១១២-ឧ.សិ.ឌី សុភី + ព្រមទាំងកូនចៅ .......................... ១៧.០០០៛

១១៣-ឧ.សិ.អ៊ុក ផាសុកាន ព្រមទាំងកូនចៅ ................. ១៧.០០០៛

១១៤-ឧ.សិ.សាយ សុផា .......................................... ១៦.៥០០៛

១១៥-ឧ.សិ.ហ៊ុំ សាម៉េន ព្រមទាំងកូនចៅ ...................... ១៦.១០០៛

១១៦-ឧ.សិ.សំ សង់វីន ព្រមទាំងបុត្រ .......................... ១៦.០០០៛

១១៧-ញឹបសុខលី +ហេន ឌី +ម៉ៅ+ គាង+ ម៉ាក+ នី+ មនាថ ... ១៦.០០០៛

១១៨-ឧ.សិ.សាន ស៊ាន ព្រមទាំងកូនចៅ ................... ១៦.០០០៛

១១៩-ឧ.សិ.នាង សាម៉ិច ព្រមទាំងកូនចៅ ................... ១៦.០០០៛

១២០-ឧ.សិ.ពេជ្រ សុឃិត ព្រមទាំងកូនចៅ ................. ... ១៦.០០០៛

១២១-ឧ.សិ.ចាន់ យ័ន្ត ព្រមទាំងកូនចៅ ..................... ១៦.០០០៛

១២២- ឧ.សិ.ហឿន ហ៊ិន ព្រមទាំងកូនចៅ .......................... ១៦.០០០៛

១២៣- ឧ.សិ.ឌួង ឡាថៃ និង បុត្រ ឡារាជ ........................... ១៦.០០០៛

១២៤-ឧ.សិ. ព្រំ សុខា + ក្រុមគ្រួសារ ព្រមទាំងកូនចៅ .... . ១៦.០០០៛

១២៥-ឧ.សិ.ប៉ុក សុខ ព្រមទាំងកូនចៅ ........................ ១៦.០០០៛

១២៦-ឧ.សិ.ឃី សំណាង ព្រមទាំងកូនចៅ ...................... ១៦.០០០៛

១២៧-ឧ.សិ.កាន់ គិរីសុខា ព្រមទាំងកូនចៅ .................... ១៦.០០០៛

១២៨-ឧ.សិ.កាន់ ឃុន ឃិន ព្រមទាំងកូនចៅ ................... ១៦.០០០៛

១២៩-ឧ.សិ.ប៉ែន សិរីសុខុម និងស្វាមី សុខ សាមឿន .......... ១៥.៥០០៛

១៣០-ឧ.សិ.តុប សៀកមួយ ព្រមទាំងកូនចៅ .................... ១៥.០០០៛

១៣១-ឧ.សិ.ម៉ម សេងលាង ព្រមទាំងកូនចៅ .................... ១៥.០០០៛

១៣២-ឧ.សិ.វេង ឆេងលាង ព្រមទាំងកូនចៅ ................... ១៥.០០០៛

១៣៣-ឧ.សិ.ឈៀង ប៉ិច ព្រមទាំងកូនចៅ ...................... ១៥.០០០៛

១៣៤-ឧ.សិ.ដួង វណ្ណាថន ឧ.សិ.ដួង វណ្ណាធឿន +កូនចៅ . ... ១៥.០០០៛

១៣៥- ឧ.សិ.សួន រ៉ាវី និង ស្វាមី ព្រមទាំងបុត្រ ................ ១៥.០០០៛

១៣៦-ឧ.សិ.គង់ ពៅ ព្រមទាំងកូនចៅ ............................... ១៥.០០០៛

១៣៧-ឧ.សិ.គង់ គឹមស្រួយ ព្រមទាំងកូនចៅ ...................... ១៥.០០០៛

១៣៨-ឧ.ស.ហង្ស វណ្ណៈ និង ភរិយា ព្រមទាំងបុត្រ ........... . ១៥.០០០៛

១៣៩-ឧ.សិ.កែវ ជីន ព្រមទាំងកូនចៅ ........................ ១៥.០០០៛

១៤០-ឧ.សិ. ជួរ ឡេង + ឧ.សិ. ហ៊ា សុខគៀង .................... ១៥.០០០៛

១៤១-ឧ.សិ. សៃ ទៀង ព្រមទាំងកូនចៅ ........................ ១៥.០០០៛

១៤២-ឧ.សិ.បាក់ ចិន្តា ព្រមទាំងកូនចៅ ........................ ១៤.០០០៛

១៤៣-ឧ.សិ.គឹម សុខេន + ឧសិ.សួន សារឿន .............. ១៤.០០០៛

១៤៤- ឧ.សិ.ផាន់ សួគ៌ ព្រមទាំងកូនចៅ ........................ ១៤.០០០៛

១៤៥-ឧ.សិ.ស៊ាម ហ្គេក + ឡាវ ស៊ាវហួង + សូគុណាវាលី ... ១៣.០០០ ៛

១៤៦-ឧ.សិ.ម៉ម លាំងសាត ព្រមទាំងកូនចៅ ................ ១៣.០០០៛

១៤៧-ឧ.សិ.គីង ផេន .................................................. ១៣.០០០៛

១៤៨-ឧ.សិ.ឮ យក់ឃាន ( ហៅចាប )និងស្វាមី + បុត្រ ........ ១២.០០០៛

១៤៩-ឧ.សិ.ឱក ប៊ុន ព្រមទាំងកូនចៅ .......................... ១២.០០០៛

១៥០-ឧ.សិ.ហាម មៀត ...................................... ១២.០០០៛

១៥១-ឧ.សិ.អ៊ុក ប៊ុនបុល ព្រមទាំងកូនចៅ ..................... ១២.០០០៛

១៥២-ឧ.សិ.ជា សុខ ព្រមទាំងកូនចៅ .................... ១២.០០០៛

១៥៣- ឧ.ស.វង្ស វេត ............................................ ១១.០០០៛

-នាមពុទ្ធបរិស័ទដែលចូលម្នាក់ៗ ១០.០០០៛

-ឧ.ស.តុង ណោង -ឧ.សិ.អ៊ុក សារុន -ឧ.សិ.តូ រិទ្ធ - ឧ.សិ.អ៊ុក ទិព្វ -ឧ.ស.សូ អំ

-ឧ.សិ.សាយ សាអ៊ីម -ឧ.សិ.ហួយ សុខេង -ឧ.សិ.រ័ត្ន គឹមធុន -ឧ.សិ.អ៊ឹម ប៉េងជូ

-ឧ.សិ.អ៊ិត គឹមអឿន -ឧ.ស.ឈឹម ប៉េងយាង - ឧ.សិ.ស្រ៊ុន កែវ -ឧ.ស.ស៊ិន នៅ

-ឧ.សិ.ឃុន យិន -ឧ.ស.ហង្ស ជិន -ឧ.សិ.សៀង ទាវគី -ឧ.សិ.វណ្ណាស៊ីមម៉េង

-ឧ.សិ.គង់ ចំរើន -ឧ.ស.ឡាយ អ៊ាងម៉េង+ឧ.សិ.មាន ផល -ឧ.សិ.ហួយ ជន
-ឧ.ស.ស៊ីវ ពុំ+ ឧ.សិ.ប៊ុល សម្បត្តិ -ឧ.សិ.ឡាច ខាំធន -ឧ.សិ.ឈុន ណារី
- ឧ.សិ.ជិន ហូ -ឧ.សិ.ព្រំ យាន -ឧ.ស.តាក គីអ៊ាង + ឧ.សិ.ឱម លាងគ្រី
-ឧ.ស.ប៊ុន សេង +តាយ៉ិន -ឧ.សិ.អ៊ុក លន់ -ឧ.សិ.ម៉ក់ គឹមអូន -ឧ.សិ.តាំង ហ្គិច
-ឧ.សិ.អៀន នារី -ឧ.សិ.ហេង សានណារី - ឧ.សិ.ថ្វាង តាំងគាន -ឧ.សិ.ម៉ៅ ថេង
-ឧ.សិ. ហ៊ិន សុផល -ឧ.សិ.ឡេង នី -លោក ទីង សារឿន -ឧ.សិ.ច័ន្ទ រស្មី
-ឧ.សិ.ពៅ ចាន់សេនា -ឧ.សិ.ជ័យ សារី -ឧ.សិ.ម៉ិល មម -ឧ.សិ.ប្រាក់ សុខែម
-ឧ.សិ.កែវ ស៊ីផា -ឧ.សិ.ស៊ូ អ៊ឹង -ឧ.សិ.យ៉ាវ អាត់ -ឧ.សិ.ញ៉ែម ទេពបូរី សួរសឿន
-ឧ.សិ.អ៊ូ ប៉ោ +ឧ.ស.ថៃ អៀង- ឧ.សិ.គឹម លិន - ឧ.សិ.អិន សុម - ឧ.សិ.កង កញ្ញា
-ឧ.សិ.តាន់ គឹមលាង -ឧ.សិ.លឹម សារ៉េន -ឧ.សិ.ហែម សុភាព +ឧ.ស លឹម អ៊ាត
-ឧ.សិ.យូ គឹមស្រ៊ុន ឧ.សិ.ជា គឹមហុង - ឧ.ស.ពិ ណាមី +ឧ.សិ ជ្រី មួយស្រ៊ាន
-ឧ.សិ.ទុយ សាន -ឧ.សិ.គឹម សុផល - ឧ.សិ.ម៉ី ម៉ារិន -ឧ.ស.ឈុន ប៊ុនអ៊ាង
-ឧ.ស.ស៊ុន គ្រុយ +ឧ.សិ.ង៉ែត នួន -ឧ.សិ.នៅ រ៉ែន -ឧ.សិ.គឹម ឡេង-ឧ.សិ.នាង ម៉ៅ
-ឧ.សិ.ហ៊ិន សាម៉ុន -លោក ហ៊ុំ ទិតជេដ្ឋា +ល.ស. វ៉ាន់ ចរិយា -ឧ.សិ.អ៊ូ តាំងគិត +
ឧ.សិ.អ៊ូ តាំងណាយ - ឧ.សិ.ឡាច ខាំធន - ឧ.ស.គឹម ហុង+ ឧ.សិ.អ៊ឹង ហេង
-ឧ.សិ.ជុំ ប៊ុន- -ឧ.សិ.វួច ង៉ោ- ឧ.សិ.កែវ ណាគ្រី-ឧ.សិ.ជង វេន-ឧ.សិ. ម៉ុក គឹមលី
-ឧ. សិ. ជា សុផានី - ឧ.សិ. ដួងសាមឿន + ឧ.សិ. គុប ជួក -ឧ.សិ. យុន បូរី
- ឧ.សិ.ហ៊ិន សុផល - ឧ.សិ.ម៉ៅ គឹមស្រ៊ុន -ឧ.សិ.វ៉ាយ វុទ្ធា - ឧ.សិ.ទូច ណាយ
-ឧ.សិ. នៅ យី -ឧ.សិ.ជាវ ឡាយ -ឧ.សិ.គឹម ស៊ីម ព្រមទាំងក្រុមគ្រួសារ ។
-ពុទ្ធបរិស័ទដែលចូល ៩.០០០ ៛ មានចំនួន ២ នាក់

-ពុទ្ធបរិស័ទដែលចូល ៨.០០០ ៛ ឬមានចំនួន ១៥ នាក់

-ពុទ្ធបរិស័ទដែលចូល ៦.០០០ ៛ មានចំនួន ២នាក់

-ពុទ្ធបរិស័ទដែលចូល ៥០០០ ៛មានចំនួន៧៩នាក់

-ពុទ្ធបរិស័ទដែលចូល ៤.០០០ ៛ មានចំនួន ៣ នាក់

-ពុទ្ធបរិស័ទដែលចូល ៣.០០០ ៛ មានចំនួន ៥ នាក់

-ពុទ្ធបរិស័ទដែលចូល ២.៥០០ ៛ មានចំនួន ២ នាក់

-ពុទ្ធបរិស័ទដែលចូល ២.០០០ ៛ មានចំនួន ៨ នាក់

-ពុទ្ធបរិស័ទដែលចូល ១.០០០ ៛ មានចំនួន ៦ នាក់

## តាមរយៈ ឧ.សិ. ហេង ចន្ទកុលសុភៈ

១- ឧ.សិ.ជួន ស៊ីមហ៊ិន ព្រមទាំងកូនចៅ ............................ ២១៥ $

២- ឧ.សិ.ជួន ស្រី ព្រមទាំងកូនចៅ ..................................... ១១០ $

៣- ឧ.សិ.ប៉ុង ណារី ព្រមទាំងកូនចៅ ................................ ១០០ $

៤- កុមារា ផល អម្រឹត និង អ្នកម្តាយ ................................ ២០ $

៥-អ្នកម្តាយ ទូន បុប្ផាធារី និងបងប្រុស ហេង មរកត .................. ១៥ $

៦-ឧ.សិ.ជួន ចន្ថា ព្រមទាំងបុត្រ ...................................... ១២ $

៧- កញ្ញា អេលីស និងក្រុមគ្រួសារ ........................................ ១០ $

៨- កុមារា ផល បញ្ញានិងអ្នកម្តាយ ...................................... ១០ $

៩- លោកស្រី.ហួរ សំណាង (ស៊ីណោត) និងក្រុមគ្រួសារ .......... ១០ $

១០- ឧ.ស.គឹម វុទ្ធីកា និង ភរិយា ព្រមទាំងបុត្រ ................... ៥ $

១១- ឧ.ស.ហោ សុផាន ឧ.សិ អៀង ណាយ បុត្រ .................... ៥ $

១២- ឧ.សិ. តឹក សុខសួរ ព្រមទាំងកូនចៅ .......................... ៣ $

១៣- លោកស្រី.ហួរ សុបុណ្យ +ស្វាមី ព្រមទាំងបុត្រ ........ ១០០.០០០៛

១៤- ឧ.សិ. ម៉ាញ់ ជា ព្រមទាំងកូនចៅ ........................ ១២.០០០៛

១៥- ឧ.សិ.ជួន ស៊ីមជាង និងស្វាមី ព្រមទាំងកូនចៅ ......... ១១.០០០៛

១៦- ឧ.សិ.មាន យ៉េកហ៊ីម ឧ.ស លី សុខហៃ+កូនចៅ ........ ១១.០០០៛

១៧- លោកស្រី.ហួរ យុឡេង និងក្រុមគ្រួសារ .................. ១១.០០០៛

១៨- ឧ.សិ.ជឹម សុខា និងក្រុមគ្រួសារ .......................... ១១.០០០៛

## តាមរយៈ ឧ.សិ. ជុន ស៊ូគី

១- ឧ.សិ.ស្រង់ លេង ព្រមទាំងកូនចៅ ................................... ៥០ $

២- ឧ.សិ.កាំង ហ៊្គិចណៃ និង ស្វាមី ព្រមទាំងកូនចៅ ................. ៣០ $

៣- ឧ.ស.ប៉ុល នាង ឧ.សិ.គ្រៀល ស៊ីយ៉ា ព្រមទាំងកូនចៅ .......... ២០ $

៤- ឧ.សិ.គ្រី ស៊ីម ព្រមទាំងកូនចៅ ......................................... ១៥ $

៥- ឧ.សិ. ប៉ាល់ ស្រីនាង ............................................................... ១៥ $

៦- ឧ.សិ.ថាប់ ជុំថន ( ហៅឡឹង ) និង អ្នកម្តាយ ....................... ១០ $

៧- ឧ.សិ.ជា សុណារី និងក្មួយស្រី ជា សុមេធាធីតា .................. ១០ $

៨- ឧ.សិ.ជុន ស៊ូគី និង ក្មួយ ៗ ............................................ ១០ $

៩- លោក ហុង លាងអ៊ី លោកស្រី នង រតនា + បុត្រ ............ ៥ $

១០-ឧ.ស.នងសុគន្ធី ឧ.សិ.ហ៊ាន ហ៊ង + កូនចៅ + កញ្ញានងសុភារី ...... ៥ $

១១-លោក នង មានទ្ធ និង លោក នង រតនៈ .................... ៥$

១២- ឧ.ស.សោម រតនៈ ឧ.សិ.ស៊ិប វណ្ណា ព្រមទាំងបុត្រ ........... ១២០.០០០៛

១៣- កញ្ញា ស៊ីថា ( ស្តង់ផ្ទៃឈើនាគមាស ) ...................... ៤៥.០០០៛

១៤- ឧ.សិ.ហុក គឹមស្រ៊ាង និងស្វាមី ព្រមទាំងបុត្រ ............. ៤៥.០០០៛

១៥- កញ្ញា ផាន់ ហ៊ុយផេង ....................................... ៣២.០០០៛

១៦- ឧ.សិ.ឃឹម ទូច ព្រមទាំងកូនចៅ ......................... ២៧.០០០៛

១៧- ឧ.សិ.ម៉េង សេងលាង និងស្វាមី ជីវ អ៊ុយម៉េង
-បុត្រ ជីវ ឆាយហេង + បុត្រជីវ ឆាយលី } ២៤.០០០៛

១៨- ឧ.សិ.ប្រាក់ សុខុម ព្រមទាំងកូនចៅ ......................... ២០.០០០៛

១៩- ឧ.ស.ឈា ស្រ៊ុន ឧ.សិ ថយ សុទិព្វ + កូនចៅ ............ ២០.០០០៛

២០-ឧ.សិ.ឡេា គឹមលាង និង ស្វាមី ព្រមទាំងបុត្រ ............. ១៦.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ១០.០០០៛

-ឧ.សិ.សៀង ទាវគី -ឧ.សិ.លីប សុវណ្ណា -ឧ.សិ.ទិត្យ ស៊ុន -ឧ.សិ.ណោនស៊ីថា
-ឧ.សិ.ឈឹម ញឹម -ឧ.សិ.ឈុន ចំណាន - ឧ.សិ.ផាង ស្រួយ - ឧ.សិ.សេង សីហា
-ឧ.សិ.តុប គឹមឡេង +ឧ.សិ.ឈាង ហួតសួរ -ឧ.សិ.អ៊ិន សុថានី - ឧ.សិ.ម៉ៃ អាតូ
-ឧ.សិ.ស្រី អូន -ឧ.សិ.នេត ថន -ឧ.សិ.រស់ វណ្ណា -ឧ.សិ. សូ ថៃន +ចាន់ អ៊ាន
-ឧ.សិ.ឈិត សាម៉េន -ឧ.សិ.ហួត អេងហៀង -ឧ.សិ.ទិន សែម -ឧ.សិ.គឹម ឡេង
-ឧ.សិ.លីម ហេ្គចសាង -ឧ.សិ.សោ ប៊ុនស៊ាន -ឧ.សិ.វេង ឆេងលាង
-ឧ.សិ.សៅ លាង ព្រមទាំងក្រុមគ្រួសារ ។

ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៨.០០០៛ មានចំនួន ២១ នាក់

ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៥.០០០៛ មានចំនួន ១១ នាក់ ។

## តាមរយៈឧ.សិ. រស់ គឹមថាន

១-លោករឹម លឹមសេង និង លោកស្រី ច័ន្ទ សុវត្ថី + បុត្រ ......... ១០០.០០០៛

២-ឧ.សិ.រស់ គឹមថាន និង ស្វាមី ព្រមទាំងបុត្រ ................ ៧០.០០០៛

៣- លោក យ៉ិល សុធី និង លោកស្រី ហ៊ូ ស្រីពេជ្រ +បុត្រ .......... ៧០.០០០៛

៤- ឧ.សិ. នៅ សេងអាន និង ស្វាមី ព្រមទាំងបុត្រ ................ ៥០.០០០៛

៥- លោក អ៊ី សំណាង និង អ្នកស្រី ប៊ុង ច័ន្ទឡៀប + បុត្រ ....... ៥០.០០០៛

៦-អ្នកស្រី អាំង គីណូ និង លោកកែវ សាម៉ីឌី +បុត្រ ........... ៥០.០០០៛

៧- កញ្ញា ពៅ លក្ខិណា ..................................................... ៥០.០០០៛

៨- អ្នកស្រី ប្រាង នី និង ស្វាមី ព្រមទាំងបុត្រ ...................... ២០.០០០៛

៩- ឧ.សិ.ទូច ដានី និង ស្វាមី ព្រមទាំងបុត្រ ....................... ២០.០០០៛

១០- ឧ.ស.ប៊ុង ធីម និង ភរិយា ........................................ ២០.០០០៛

១១-លោក អ៊ី សុផាណារ៉ា និង អ្នកស្រី ជា ធី .................. ២០.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ១០.០០០៛

លោក យ៉ិល សាគី -លោក ម៉េង ស្រ៊ាង - កញ្ញា ទូច សុគី -លោក ប៊ុង សុគីយ៉ា

-យុវជន យ៉ិល យ៉ាការ៉ា -កញ្ញា យ៉ិល យ៉ាលីតា -កញ្ញា យោន មុំសុជាតា

-កញ្ញា រ៉ា នីដា -កុមារី កាន សុវណ្ណនា ព្រមទាំងក្រុមគ្រួសារ ។

## តាមរយៈ ឧ.ស.យិច ឈីន ឧ.សិ. តែ សុមាលី ( បួយ )

១- លោក ស៊ិន ផល្គុណ អ្នកស្រី សេក សារ៉ាត កូនចៅ ............ ១០ $

២- ឧ.ស.រ៉ា ដេន ឧ.សិ.រ៉ា គឹមហោ ព្រមទាំងកូនចៅ .................. ៥ $

៣- លោក ជា ស៊ីថា អ្នកស្រី ម៉ក់ ច័ន្ទណា ព្រមទាំងបុត្រ .......... ៥ $

៤- ឧ.ស. យិច ឈីន ឧ.សិ. តែ សុមាលី (បួយ) +កូនចៅ .......... ២២.០០០៛

៥- លោកស្រី ប្រាក់ ច័ន្ទថន ព្រមទាំងកូនចៅ ...................... ២០.០០០៛

៦- លោក ភិន បូផាន់ និងភរិយាព្រមទាំងកូនចៅ ............. ២០.០០០៛

៧- ឧ.ស.តែ ហៅ ឧ.សិ.ជុន ណៃអ៊ីម ព្រមទាំងបុត្រ ........... ១២.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ១០.០០០៛

-ឧ.ស.អ៊ូច ង៉ួន+ ឧ.សិ.ជី នុក-ឧ.សិ.ស្រេង គ្រឹង- ឧ.សិ.អ៊ឹង យឹមស្រ៊ាន

-ឧ.សិ.យឹម សយ -ឧ.ស.ឃុត ជេដ្ឋា +ឧ.សិ.អ៊ា គឹមហេង-កញ្ញា ស្រី លក្ខ្មីវត្តី

-អ្នកស្រី ដួង សុភា -ឧ.សិ.ហាស់ សំជិន -ឧ.ស.យុង សុង +ឧ.សិ.សៀ សៀកលីម

-ឧ.ស.ឈឹម ពេជ្រសូ +ឧ.សិ.មូល សុខលី -លោក អន សារិន +ឧ.សិ.ទិត្យ ស៊ីថា

-អោ គន្ធា -ឧ.ស. អ៊ុន ញៀន+ ឧ.សិ.អ៊ីញ ញ៉ -លោក គង់ ដួន+ ឧ.សិ លឹម គា

-ឧ.ស.ជា ធឿន +ឧ.សិ.សៀង គឹមហ៊ុន -ឧ.ស.ជា ខេង +ឧ.សិ.សៀង យូលាក

-ឧ.ស.លឹម មុនី + ឧ.សិ.ចាប រុន -ឧ.ស.ឡាច ស្រេង + ឧ.សិ.ស៊ុន ស៊ិន

-ឧ.សិ.ចេង ថូ -ឧ.សិ.ផាន់ សុវណ្ណ -អ្នកស្រី ផាត វ៉ាន់ណេន -ឧ.សិ.ឌឹម សុខហេង

-លោក យិន សុភ័ក្ត្រ + អ្នកស្រី កែវ ស្រីមុំ -ឧ.ស.គឹម ហួត +ឧ.សិ.ផាន់ សារ៉ុន

-ឧ.ស.រ៉ិត សំ + ឧ.សិ.ចាប សារឿន -ឧ.ស.លឹម ឈុន ថៃ + ឧ.សិ.ឡុក សុខអ៊ីម

-លោក សួន សារ៉េត + អ្នកស្រី ហង់ ដានី -ឧ.ស.ឈឹម សារិន+ ឧ.សិ.ចាន់ ថា ឧ.ស.អ៊ុយ ស្តើង + ឧ.សិ.កុក លាងស៊ីម -ឧ.សិ.យាង មួយ -ឧ.សិ.ជិត ស៊ិន -ឧ.ស.ស ជឹម + ឧ.សិ.រស់ សារ៉ូ -ឧ.សិ.គឹម សុផល -ឧ.សិ.ជ័យ ជួនសុផល -ឧ.សិ.សាធ ណាត្រី -ឧ.សិ.សម សុខន -ឧ.សិ.ហង ហ៊ាង -ឧ.សិ.នាង នៅ -លោក ម៉ី សុខន + អ្នកស្រី តាំង ហួយ -ឧ.ស.ស៊ឹម ប៉ោអ៊ាក+ ឧ.សិ.តាំង វួចចេង -ឧ.ស.ចាន់ សូនី + ឧ.សិ អ៊ុក សុផល -ឧ.សិ.អូយ មិនា + លោក អ៊ឹម ពុធសីលៈ -ឧ.ស.វ៉ាល់ វឿន + ឧ.សិ.កែវ វង្ស -ឧ.ស.រស់ ស្រេង + ឧ.សិ.ឡា.ហ៊ុយឡេង -លោកតា លឹម ចាយ + លោកយាយ ខូវ ខាហៀង -ឧ.សិ.តួន ស៊ុនណារី -ឧ.សិ.ឌី បុប្ផា -ឧ.សិ.ផេង យូសេង - ឧ.សិ.សំ ពៅ ព្រមទាំងក្រុមគ្រួសារ ។

## តាមរយៈ ឧ.សិ.ទី សុធី+ឧ.សិ.សុខ ត្នួច

១-ឧ.សិ.ទី សុធី + បុត្រហែម តុលា ............................ ៤០.០០០៛

២-ឧ.សិ.ឧ.សិ.ប៊ុង គីរីកា និង ស្វាមី +បុត្រ ...................... ២០.០០០៛

៣-ឧ.សិ.គឹម សំភីលី ព្រមទាំងកូនចៅ ...................... ២០.០០០៛

៤-ឧ.សិ.ម៉ែន អូន ព្រមទាំងកូនចៅ .......................... ២០.០០០ ៛

៥-ឧ.សិ.សោម សុវណ្ណារ៉េត និងអ្នកម្តាយ ...................... ១៥.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ១០.០០០៛

-ឧ.សិ.សុខ ភួង +ឧ.សិ.សុខ ផៃ -ឧ.សិ.វ៉ន ស៊ីណាត - ឧ.ស.ប៉ែន ផាំ + ឧ.សិ.ហ៊ុម រុំ -ឧ.សិ.ស្រេង គីម -ឧ.សិ.មាស រស់ -ឧ.ស.វ៉ា ហុង+ឧ.សិ.លូ ឡាយ -ឧ.សិ.លាង ហ៊ាន់ -ឧ.សិ.ម៉ក់ គឹមអូន - ឧ.សិ.សុខ ជិនថនព្រមទាំងក្រុមគ្រួសារ ។

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៨.០០០៛ មានចំនួន៦ នាក់ ។

## តាមរយៈ ឧ.សិ.បាន រ៉ូ និង ឧ.សិ.គឹម អា

១-ឧ.សិ.បាន រ៉ូ និងអ្នកម្ដាយ អឹម យ៉ម .......................... ២០.០០០៛

២-ឧ.សិ.បាន ឌី ........................................................... ១៨.០០០៛

៣-ឧ.សិ.គឹម អា+បុត្រ +ឧ.សិ.ណុប អ៊ី+ស្វាមី +បុត្រ ........... ១៥.៥០០៛

៤-កុមារា.ស៊ីម លីមសួង+ កុ.ស៊ីម លីមសួ + កុ.ស៊ីម លីមសា ..... ១៥.០០០៛

៥-ឧ.ស.ស៊ីម លីម និងភរិយា ព្រមទាំងបុត្រ ...................... ១០.០០០៛

## តាមរយៈ ឧ.សិ.ប៉ាល់ ធីតា

១-ឧ.ស.អ៊ុក សំណាង ឧ.សិ.ប៉ាល់ ធីតា +កូនចៅ ....................... ១០ $

២-ឧ.ស.អេង វណ្ណា ឧ.សិ.សៅ ណារី ព្រមទាំងកូនចៅ ............... ៥ $

៤-ឧ.សិ.អ៊ុក ប៊ុនថុល ព្រមទាំងកូនចៅ ............................ ១៨.០០០៛

៥-ឧ.សិ.សូ សុខ និងស្វាមីព្រមទាំងកូនចៅ .................... ១៥.០០០៛

៣-ឧ.សិ.អ៊ុក សារុន + ឧ.សិ.អ៊ូច សុខម៉េង+ ស្វាមី +បុត្រ ...... ២ $ + ៦.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ១០.០០០៛

-ឧ.សិ.លីម ណាលី -ឧ.សិ.ឈឹម ហាន -ឧ.សិ.ប៊ុន រិទ្ធសិតា -ឧ.សិ.គុយ ហ៊ុន + ឧ.សិ.តាំង ស៊ីវហួ -ឧ.សិ.ប្រាក់ ចន្ធី +ឧ.សិ.ឃឹម ផូ ព្រមទាំងក្រុមគ្រួសារ ។

## តាមរយៈ ឧ.សិ.ស្រី វណ្ណី និង ឧ.សិ.យ៉ា សុខគីម

១-ឧ.សិ.យ៉ា សុខគីម +កូនចៅ + ឧ.សិ. រ៉ា សុគន្ធា ......... ៥ $ + ៤៥.០០០៛

១-ឧ.ស.គង់ សំអុល និងភរិយា ព្រមទាំងក្រុមគ្រួសារ ............ ៤០.០០០៛

២-ឧ.សិ.ស្រី វណ្ណី ឧ.ស.នុត ឈា + កូនចៅ ...................... ១៨.០០០៛

៣-ឧ.សិ.អ៊ឹង ហ៊ុយប៉ូ អ៊ឹង ហ៊ុយឡាន បុត្រ ...................... ១២.០០០៛

៤-ឧ.សិ.លីម សុខហៀង ឧ.សិ.លីម សុខអេង ................ ១២.០០០៛

៥-ឧ.សិ.ពាង ថាវរី និងស្វាមី ព្រមទាំងបុត្រ .................... ១២.០០០៛

២-ឧ.សិ.គុជ លាង និងស្វាមី ព្រមទាំងកូនចៅ .................. ៣ $

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ១០.០០០៛

-យាយលក់ធ្យូង -ឧ.សិ.ស៊ីវ ហៀង -ឧ.សិ.ស៊ឹម ស៊ាមលី + ឧ.សិ.ស៊ឹម ឡាំងគ្រី

-ឧ.សិ.យ៉ែម -ឧ.សិ.អិត តំអៀន ព្រមទាំងក្រុមគ្រួសារ ។

## តាមរយៈ ព្រះតេជគុណ កែវ វុទ្ធី

១-ភិក្ខុវិបស្សនាចារ្យធន្ទបាលោ ផែម ល័ក្ខ ( ខេត្តបាត់ដំបង ) .... ៤០.០០០៛

២-ភិក្ខុបញ្ញាបទីបោ វ៉ុន ភារុន ( វត្ត ឧត្តរាវត្តី ) ................. ៤០.០០០៛

៣-ភិក្ខុមហាសិរីបុត្តោ នាង ស៊ីណេន ................................. ៥ $

៤-ភិក្ខុ ធុច សិរីមុនី ............................................................ ១៥.០០០៛

៥-សាមណេរ កែវ វុទ្ធី ...................................... ១០.០០០៛ + ៥ $

៦-សាមណេរ ឌីណា ...................................................... ១១.០០០៛

៧-ឧ.សិ.អ៊ុំ កាក់ និង អែប ណាន .................................... ១១.០០០៛

៨-ឧ.សិ.ស្រី ព្រមទាំងកូនចៅ ............................................ ១១.០០០៛

៩-កែវ អួន + សែមណឺន ព្រមទាំងបុត្រ ........................... ១១.០០០៛

១០-ឧ.សិ. ងីម ព្រមទាំងកូនចៅ ...................................... ១១.០០០៛

# តាមរយៈ ភិក្ខុ មាស សាពួន ( សៀមរាប )

១-ភិក្ខុ មាស សាពួន .................................................. ៥០.០០០៛

២- ភិក្ខុ វ៉ាត ជំនាញ ..................................................... ១២.០០០៛

៣-សាមណេរ គ្រូច ណាត់ .............................................. ១២.០០០ ៛

៤-សាមណេរ គ្រូច ណាត ............................................... ១២.០០០ ៛

៥-ឧ.ស. ស ប៊ុនឡេង ឧ.សិ.ប៊ី ឆេងហួរ

៦-លោកវេជ្ជបណ្ឌិត ស ប៉េងអ៊ាន +ភរិយា អេង ឈុនស៊ី + បុត្រ ... ៥១ $

៧-លោកវេជ្ជបណ្ឌិត លាង វន្នី + ភរិយា ស អឹមអៀក +បុត្រ

៨-ឧ.សិ.ថេង ឆេងគីម + ទាយិកា ឈាងស៊ាងលី +បុត្រ ............. ៣០ $

៩-ឧ.សិ.ឈុន សោភ័ណ្ឌ ព្រមទាំងបុត្រ .................................. ៣០ $

៩-ឧ.សិ.សៀវ ម៉ី ព្រមទាំងក្រុមគ្រួសារ ................................. ៦ $

១០-ឧ.សិ.រឹម ស្រេង ................................................................. ៥ $

១១-ឧ.សិ.លឹម ណាជី ........................................................... ៥ $

១២-ឧ.សិ. លឹម សុខុម .................................................. ៣៦.០០០៛

១៣-ឧ.សិ.អ៊ិម រុំ ........................................................... ៣៦.០០០៛

១៤-ឧ.សិ. ហ៊ុល ង៉ាវ ................................................... ២៤.០០០៛

១៥-ឧ.សិ.ណៃ សូវៀត .................................................. ២៤.០០០៛

១៦-ឧ.សិ.ណុប សឿម ................................................... ១២.០០០៛

១៧-ឧ.សិ.ឯម ស៊ីណា .................................................. ១២.០០០៛

១៨-ឧ.សិ.ឡុង គាវ .................................................... ១២.០០០៛

១៩-ឧ.សិ.នីវ + ម៉ា ហួន .................................................... ១២.០០០៛

២០-ឧ.សិ.ហី ធិបត៍ .................................................... ១២.០០០៛

២១-ឧ.សិ.សរ យ៉ាត .................................................... ១២.០០០៛

២២-ឧ.សិ.ស៊ាប .................................................... ១២.០០០៛

២៣-ឧ.សិ. ស៊ិន់ .................................................... ១២.០០០៛

២៤-ឧ.សិ. អ៊ិត ចន្ថា ............................................. ១២.០០០៛

## តាមរយៈ ភិក្ខុ កន ជឿន

១-ភិក្ខុ កន ជឿន .................................................... ១៨.០០០៛

២-ភិក្ខុ វិរិយបណ្ឌិតោ ននួ សាប្ញទ្ធិ ............................ ១១.០០០៛

៣-ក្រុមពុទ្ធបរិស័ទ ភូមិព្រៃរន្ធ ......................................... ២៩.០០០៛

៤-ឧ.ស.លួន រិន ឧ.សិ.ហ៊ីង៍ គា ...................................... ១៦.០០០៛

៥-ទីង៍ សុខលាង៍ ........................................................... ១១.០០០៛

៦-ឧ.សិ.លឹម សំនៀង៍ ព្រមទាំង៍កូនចៅ ( ភ្នំពេញ ) ........... ១១.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៨.០០០៛ មានចំនួន ១៤ នាក់

## តាមរយៈ ភិក្ខុ ឈានវរោ ប៉ាន់ ឈា

១- ភិក្ខុ ឈាន វរោ ប៉ាន់ ឈា និង៍បង៍ស្រី ធន ................... ១០ $

២-ភិក្ខុ សុខ សុវណ្ណោ +សាមណេរ វឿន សារីន ................ ២០.០០០៛

៣-ព្រះមហា នៅ កុសល .................................................... ២០.០០០៛

៤-ព្រះមហា ប្រាក់ កង៍ ហៅ រ៉េ ............................................ ២០.០០០៛

៥-សាមណេរ ធៀង មករា .................................................. ១០.០០០៛

៦-អ្នកស្រី អ៊ុន ណារី និងកូនស្រី រ័ត្ន .................................. ៣០.០០០៛

៧-សុភ័ក្រ្ត - សាន់តារា ...................................................... ១៥.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ១០.០០០៛

-និស្សិត ធន ស៊ីថាត -អ្នកស្រី អ៊ុក លីដា +ស្វាមី -ឧ.សិ.ហ៊ាន ស្រី -មុន្នី - សារ៉េន។

## នាមរយៈ ព្រះធម្មវិនយរក្ខិតោ ផល ផានិត

១-ភិក្ខុ ហ៊ី ហេង និង ញោមស្រីព្រាប ស៊ីង ............................ ២២.០០០៛

២-ឧ.សិ.នួន មុំ ព្រមទាំងកូនចៅ ..................................... ២០.០០០៛

៣-ឧ.ស.ឃួន ជីន និងភរិយា ព្រមទាំងកូនចៅ ................... ២០.០០០៛

៤-សៀន សុជារី + រ៉ាឌីន ................................................ ២០.០០០៛

៥- និស្សិត ហ៊ី វណ្ណៈ+ឧ.សិ.ហ៊ី ហាម ...................... ១៦.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ១០.០០០៛

-ឧ.សិ.គង់ ម៉េងហ៊ាង +កូន ប្រាក់ សុខអេង -ឧ.ស.ឈួន ទន់ + ឧ.សិ.នៅ សុខុម

-ឧ.ស.ភិន សុភេទ + ឧ.សិ ម៉េង ចាន់ណា -ឧ.ស.គង់ ហ៊ុន + ឧ.សិ.ចេវ សោភា

-ឧ.សិ.ដាំ អូន -ឧ.សិ.បៃ មួយ -ឧ.សិ.វិរៈ ម៉ាឡា -ឧ.សិ.ញឹង សារ៉ន - ហុង វ៉ាន់ស៊ី

-ឧ.សិ.លន់ ឡុងឌី -ឧ.សិ.លាង សុជាវី +ឧ.សិ.ចាន់ ណារុន និងក្រុមគ្រួសារ ។

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៨.០០០៛ មានចំនួន ៦ នាក់ ។

## តាមរយៈ  ភិក្ខុ ង៉ែត ប៊ុនឡឿន

១-ឧ.សិ.បិន សឹម ព្រមទាំងកូនចៅ ................................ ២០.០០០៛

២-ឧ.សិ.លឹម ហ៊ាង ឧ.សិ យាយ ស ព្រមទាំងកូនចៅ .......... ១៦.០០០៛

៣-ឧ.សិ អ៊ឹម ទឹម ព្រមទាំងកូនចៅ .............................. ១៣.០០០៛

៤-ឧ.សិ.ទេព ណាក់ និងក្រុមគ្រួសារ ............................. ១១.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៨.០០០៛ មានចំនួន ៧ នាក់ ។

## តាមរយៈ ភិក្ខុ ជា ចាន់

១-ព្រះតេជគុណ ឃិត គួ (វត្ត ភ្នំទ័ពមានជ័យ) .................... ៥ $

២-ព្រះតេជគុណ យស ច័ន្ទដានី (វត្តទួលគគី ) ..................... ៥ $

៣-ឧ.សិ.ស្រី មុំ .............................................................. ៣ $

៤-ឧ.សិ.ម៉ៃ គីមទីន និងស្វាមី ព្រមទាំងបុត្រ ................... ២៤.០០០៛

៥-ឧ.សិ.ប៉ៃ គីមហ៊ាន់ ព្រមទាំងបុត្រ ............................ ១១.០០០៛

៦-ឧ.សិ.ល័ក្ខ រ៉ារី   (ហៅបងញ៉ាញ់) ........................... ១១.០០០៛

៧-ឧ.សិ. ម៉ក់ ឃន ( កំពង់ឆ្នាំង ) ................................. ១១.០០០៛

## តាមរយៈ ព្រះតេជគុណ សំ  សាន

១-ឧ.ស.គីម ប៉ោស៊ីម ឧ.សិ.សាម យ៉េកឡាង + បុត្រ ........ ៥០.០០០៛

២-ឧ.ស.សំ សាន ឧ.សិ.ឡៅ ស្រួយ +កូនចៅ ................. ២៨.០០០៛

៣-លោក នួវ សារិទ្ធិ និងភរិយា ព្រមទាំងបុត្រ ............... ២០.០០០៛

៤-ឧ.ស.យ៉ុាំ ស្រេន ឧ.សិ.អ៊ុល សេងលាង +កូនចៅ ......... ២០.០០០៛

៥-ឧ.សិ.ជា ចាន់សារី និងស្វាមី ព្រមទាំងបុត្រ ............... ១៦.០០០៛

៦-ឧ.សិ.ជួ ប៉ូង ឧ.សិ.ជី គីម ......................................... ១៦.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ១០.០០០៛

-ឧ.ស.នៅ យី - ឧ.ស.ឡាយ ច្រឹង + ឧ.សិ.គង់ សមឿន - ឧ.ស.កែវ សារ៉ន

-ឧ.ស.ឡឹក សំហៀង + ឧ.សិ.សោម សាន ព្រមទាំងក្រុមគ្រួសារ ។

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៨.០០០៛ មានចំនួន ៩ នាក់ ។

## តាមរយៈ ឧ.សិ.អៀង ប៉ុក

១-ឧ.សិ.អៀង ប៉ុក ព្រមទាំងកូនចៅ + មិត្តព្រះធម៌ ............ ៥២.០០០៛

២-ឧ.ស.សាំង សារុន +ឧ.សិ.សន ទូច +ឧ.សិ.យស ហឿន
ឧ.សិ.កែវ សុវណ្ណី ព្រមទាំងកូនចៅ ............................. } ....... ២៤.០០០៛

៣-ឧ.សិ.ឡេង ចាន់ហួរ និងស្វាមី ព្រមទាំងបុត្រ .............. ២០.០០០៛

៤-ឧ.ស.សេង តុង ឧ.សិ.ស៊ុន ចន្ថា ព្រមទាំងកូនចៅ ........................ ៤ $

៥-តា ប៉ុក ម៉េង និង យាយ សៀ + កូនចៅ ................ ៣ $ + ៥.០០០៛

៦-ឧ.សិ.អ៊ុក ស្រីមុំ +ឧ.សិ.មិនចាន់ណារី +ក្រុមគ្រួសារ .... ៣ $ + ៤.០០០៛

៧-ឧ.សិ.ជាម ញ៉ៃ និងស្វាមីព្រមទាំងកូនចៅ .................... ១៦.០០០៛

៨-លោក ប្រាក់ ណារ៉ាន់ លោកស្រី ឯក វណ្ណមុនី ............... ១៦.០០០៛

៩-ឧ.ស. នង បូណា ឧ.សិ. ប្រាក់ ចន្ទី + កូនចៅ + ក្មួយ ......... ១៦.០០០ ៛

១០- លោក មុី សំបូរ និង ភរិយា ឌួង ធវីវណ្ណ + បុត្រ ............. ១៦.០០០ ៛

១១-ឧ.សិ.ស្រ៊ីម កែវ +ឧ.សិ. អ៊ុក សម្បត្តិ + ឧ.សិ.អ៊ឹង មួយ ....... ១៥.០០០៛

១២-ឧ.សិ. ឡុង គុនហ៊ុន ....................................... ១៥.០០០៛

១៣-ឧ.សិ.ឈួន ឡាយ ....................................... ១៥.០០០៛

១៤-ឧ.សិ.កាំង អេងឡាំង ឧ.សិ.ហ៊ុន ស៊ាមហេង .............. ១២.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ១០.០០០៛

-ឧ.សិ.យូ អេង -ឧ.សិ.លី ស៊ីណា -ឧ.សិ.ស្រី គីម +ឧ.សិ.ជា ស្រី -ឧ.សិ.តាំង អ៊ឹម

-ឧ.សិ.លីវ ណាយ -ឧ.សិ.ហេង សុផារី -ឧ.សិ.ទេព អូន -ឧ.សិ.ម៉ី.វណ្ណធា

-ឧ.សិ.ជា សុខឃីម -ឧ.សិ.អ៊ឹង ឈីវអ៊ាន -ឧ.សិ.បងសី -ឧ.សិ.អា ណាំ

-ឧ.សិ.សាំង សារុន + ឧ.សិ យស នឹម -ឧ.សិ.ហ៊ិន សុខេង + ឧ.សិ. អ៊ុក សារុន

ឧ.សិ. ស៊ុយ +ឧ.សិ. បាក់ ចិន្តា + ឧ.សិ. សៀក ហ៊ាង - ឧ.សិ.ប៊ុន ចាន់សេរី

- ឧ.សិ.ស៊ន់ ចន្ទី ព្រមទាំងក្រុមគ្រួសារ ។

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៨.០០០៛ មានចំនួន ៦ នាក់ ។

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៤.០០០៛ មានចំនួន ២ នាក់ ។

## តាមរយៈ ឧ.សិ.គង់ វណ្ណា

១-ឈឹម លាង + អ្នកស្រី ត្រាច ប៉ុណ្ណា + អ្នកស្រី ត្រាច សារ៉េន
អ្នកស្រី ភោគ លាន + ថៃត លន់ + ក. សួន សុធារី } ១៦ $

២-អ៊ូច សារុំ + ឧ.សិ.ហៀក + មុំ + ឧ.សិ.ប៉ែន សុក
ឧ.សិ.ស៊ុំ + ឧ.សិ.តោង ពួយ ព្រមទាំងកូនចៅ } ........ ២៥.០០០៛

៣-ឧ.ស.ទុំ គឹមសុន ....................................................... ២០.០០០៛

៤-ឧ.សិ.គង់ វណ្ណា ព្រមទាំងកូនចៅ ................................ ១៨.០០០៛

៥-ឧ.ស.ហែន យ៉េន ឧ.សិ.ញ៉ឹក សួងសាន +កូនចៅ ........... ១៥.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ១០.០០០៛

-ឧ.សិ.ប៊ិន ចន្ថា ( ហៅ ពៅ ) -ឧ.ស.ស៊ា មានវិសាល + ឧ.សិ.សារិទ្ធ រតនា

-យុវជន ឈឿន -ឧ.សិ.សួស យ៉ាវ ព្រមទាំងក្រុមគ្រួសារ ។

ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៨.០០០៛ មានចំនួន ៨ នាក់ ។

## តាមរយៈ ឧ.សិ.សូ យឿន

១-ឧ.ស.ប៊ួន ចយ ឧ.សិ.លឹម ហ៊ុយចេង ......................... ៤០.០០០៛

២-ឧ.សិ.សូ យឿន ព្រមទាំងកូនចៅ ............................... ២០.០០០៛

៣-ឧ.សិ.អ៊ឹម ហង់ ព្រមទាំងកូនចៅ ............................... ១៨.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ១០.០០០៛

-ឧ.សិ.ឃ្លោក កញ្ញា -ឧ.ស.ឃ្លោក យ៉ិត -ឧ.សិ.សុខ ស៊ីផុន-ឧ.សិ.តាំង គឹមណៃ

-លោក ដារីត -ឧ.ស.វ៉ា ពិសី -ឧ.ស.ហម សុខវ៉េង -ឧ.សិ.យន់ ស្រី +ក្រុមគ្រួសារ ។

ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៨.០០០៛ ឬ ២ $ មានចំនួន ១០នាក់ ។

## តាមរយៈ ឧ.សិ.ខាំ នាងសុខី

១-ឧ.សិ.ខាំ នាងសុខី .......................................... ២០.០០០៛

២-ឧ.សិ.ម៉ឹង យ៉ុម ព្រមទាំងកូនចៅ .......................... ១៥.០០០៛

៣-ឧ.សិ.ស៊ុំ គឹមមុច + កូនចៅ ............................... ១២.០០០៛

៤-ឧ.សិ.ម៉ី យន + កូនចៅ ................................. ១២.០០០៛

៥-លោកជំទាវ លន់ រតនា + កូនចៅ ................... ១២.០០០៛

៦- លោកស្រី ចន្ធូរ + កូនចៅ .............................. ១២.០០០៛

## តាមរយៈ ឧ.ស.ឈីវ ហៀក

១-ក្រុមឧ.សិ.ជុន អ៊ីខេង និងស្វាមី ព្រមទាំងបុត្រ ........... ១៧.០០០៛

២-ឧ.សិ.តាំង គីមលៃ ព្រមទាំងបុត្រ ............................. ១៦.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ១០.០០០៛

-ឧ.សិ.សូ យឿន -ឧ.សិ.លឹម សៀវង៉ោ -ឧ.សិ.ប៊ុន សុខ -ឧ.សិ.យន់ ស្រី -លឹម ស៊ិន -ឧ.ស.ចាន់ ឆៃហួត -អ្នកស្រី វ៉េត អ៊ាង -ឧ.សិ.ឃឹម សឹង + ឧ.សិ អ៊ឹម ហង់ -ជា គឹមហ៊ាប -ឧ.សិ.សៅ វ៉េត + ឧ.សិ.ខេង ធីតា -ឧ.សិ.ហែម ណារី ព្រមទាំងក្រុមគ្រួសារ ។

## តាមរយៈ ឧ.សិ.វៀល សុខា

១-ឧ.សិ.វៀល សុខា +ឧ.សិ.វៀល សួន + កូនចៅ ............... ១៣.០០០៛

២-ឧ.សិ.ឆោម ពុធរ័ត្ន+ឧ.ស.ស៊ូ គង់ +យាយ យ៉េង ............... ១២.០០០៛

៣-ឧ.ស.ប៉ុង +យាយ ជូ -ឧ.ស.ហម វណ្ណា ..................... ១១.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ៨.០០០៛ មានចំនួន ៤នាក់ ។

## តាមរយៈ ឧ.សិ. មុត សុជាតា

១-ភិក្ខុ អ៊ុន សំអាត ..................................... ១៦.០០០៛

២-បង់តី និង រចនា .......................................... ២០.០០០៛

៣-ឧ.សិ.មុត សុជាតា ......................................... ១៦.០០០៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៨.០០០៛ មានចំនួន ២នាក់ ។

# តាមរយៈ ឧ.សិ.ទេព ផលម៉ាឡា

១- ឧ.ស.ឡុង សត្ថា ឧ.សិ.ទេព ផលម៉ាឡា + បុត្រ ........ ៣០.០០០` + ៥ $

២-ឧ.សិ.សែម សុភា + កូនចៅ ............................................. ៥ $

៣-ឧ.សិ.អុំ ស៊ីថា និង ស្វាមី+ កូនចៅ .................................... ៥ $

៤-ឧ.សិ.ហែម ជ្រឿន និង ស្វាមី + កូនចៅ ........................... ៥ $

៥-លោក ទេព ឫទ្ធី + កូនចៅ .............................................. ៥ $

៦-ឧ.សិ. សុខ ពិសី + វាសនា -សេក .................................... ៥ $

៧-កញ្ញា ស្រី ម៉ុច + ស្រីលុច ............................................. ៥ $

៨-កញ្ញា ស្រី អូន ........................................................ ៥ $

៩- ឧ.សិ. ជុន អ៊ីខេង និង ស្វាមី ព្រមទាំងបុត្រ ................... ៥ $

១០-ឯក ឧត្តម វ៉ាន់ ពុទ្ធិល លោកជំទាវ អ៊ូច ផល្លី +បុត្រ ............... ៤ $

១១- ឧ.ស. វ៉ាន់ សេរី និង ភរិយា ព្រមទាំងបុត្រ .................. ៤ $

១២- ឧ.សិ. ខាំ សារួម និង ស្វាមី ព្រមទាំងបុត្រ .................. ២២.០០០៛

១៣-ឧ.សិ. ប៉ូល ច័ន្ទនារី និង ស្វាមី ព្រមទាំងបុត្រ ....... ២០.០០០៛

១៤- ឧ.ស. តុប គីមឡុង ឧ.សិ. ឈាង ហ៊ិតស៊ួរ +កូនចៅ ...... ២០.០០០៛

១៥- ឧ.សិ. សិទ្ធិ ប៊ុនធឿន ព្រមទាំងកូនចៅ ....................... ១៦.០០០៛

១៦- ម៉ៅ សាឡួន + ជា យ៉ុន + សោ ភ័ណ្ឌ ..................... ១៦.០០០៛

១៧-ឧ.សិ. មិនស្គាល់ឈ្មោះ ....................................... ១៥.០០០៛

១៨- ទូច សុភី +សំ វណ្ណលីស ..................................... ១១.០០០៛

១៩- សួង ភីនី + ប៊ុន គេងលី ........................................ ១១.០០០៛

២០-ឱ.សិ. ពេជ្រ សុផា +សួន ភីរ៉ាត់ .................................. ១១.០០០៛

## តាមរយៈ ឱ.សិ.ហាវ សាវុធ

១- ឱ.ស. គីម ប៉ោស៊ីម ឱ.សិ.សាម យ៉េកឡាង+កូនចៅ ............. ២០ $

២- ឱ.សិ.ហាវ សាវុធ ព្រមទាំងកូនចៅ .......................... ៣០.០០០៛

៣- ទុំ ស្រឿន (ស្អាតចាស់ ) ...................................... ២៤.០០០ ៛

៤- ឱ.សិ.គឹម នាង ព្រមទាំងបុត្រ ..................................... ២០.០០០ ៛

៥- ឱ.សិ.រស់ តីផល និង ស្វាមី ព្រមទាំងបុត្រ .................. ១៨.០០០ ៛

៦- ឱ.ស.ព្រុំ ស៊ុន ឱ.សិ.ឃិន តាំងអ៊ីន ............................ ១៦.០០០ ៛

៧-ឃឹម គឹម ,ឈឹម សុភាព , មុំ វណ្ណន ............................ ១២.០០០ ៛

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ១០.០០០៛

-ឱ.សិ.អ៊ុយ សុភាព -ឱ.ស.ស្រី ផូ +ឱ.សិ.វង់ ណុន -ឱ.សិ. គាត គា -ជ័យ ស៊ាន+

ង៉ួន សែត + អ៊ៅ លាន + ជ័យ សុខុម -ឱ.សិ.អ៊ុង វុធ + សុខ រម្មទី

-ឱ.សិ. គៀត សុផល, ឱ.សិ.ទេព សំអឿន ព្រមទាំងក្រុមគ្រួសារ ។

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៨.០០០៛ មានចំនួន ១៣នាក់ ។

-ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ៥.០០០៛ មានចំនួន ២២នាក់ ។

-ពុទ្ធបរិស័ទដែលចូល ៤.០០០៛ ឬ ១ $ មានចំនួន ៦ នាក់។

-ពុទ្ធបរិស័ទដែលចូល ៣.៥០០៛ មានចំនួន ១ នាក់។

-ពុទ្ធបរិស័ទដែលចូល ៣.០០០៛ មានចំនួន ៨ នាក់។

-ពុទ្ធបរិស័ទដែលចូល ២.០០០៛ មានចំនួន ១៤ នាក់។

# តាមរយៈ ឧ.សិ. ឈឹម សុខែម

១-ឧ.សិ.អ៊ួង ឈុនហួង និងស្វាមី ព្រមទាំងបុត្រ .............................. ២០ $

២-ឧ.សិ.សាយ សុផា និងស្វាមី ព្រមទាំងបុត្រ .............................. ១០ $

៣-ឧ.សិ. នៅ សុជានី និង ស្វាមី ព្រមទាំងបុត្រ ........................ ៨ $

៤-ឧ.សិ. អ៊ិត សោភ័ណ និងស្វាមី ព្រមទាំងបុត្រ ...................... ៨ $

៥-ឧ.សិ.ឈឹម សុខែម ព្រមទាំងកូនចៅ ............................ ៥ $

៦-ឧ.សិ. អ៊ុំ សរ ( ស៊ុន គ្រុយ ) ..................................................... ៤ $

៧- ឧ.ស. ង៉ែត ផេង ឧ.សិ. ហៅ ហេង +បុត្រា ផេង បូរ៉ា ................ ៤ $

៨-ឧ.សិ. ប៉ូអាន ស៊ីវុត្ថា ..................................................... ៤ $

៩-ឧ.សិ.ជិង គឹមស្រ៊ី ..................................................... ៣២.០០០៛

១០-ឧ.សិ. វណ្ណ សូភី ............................................... ២ $ + ១០.០០០ ៛

១១-ឧ.សិ.សាយ សាអ៊ីម ព្រមទាំងកូនចៅ ........................... ២០.០០០៛

១២- ឧ.សិ.ពេជ្រ ច័ន្ទតារា ..................................................... ២០.០០០៛

១៣-ឧ.សិ.លឹម ណៃហួយ ព្រមទាំងកូនចៅ .......................... ២០.០០០៛

១៤-ឧ.សិ.ឰ យក់ឃាន ( ហៅចាប ) ព្រមទាំងកូនចៅ ...................... ២០.០០០៛

១៥-ឧ.សិ.ឡាយ មួយ + ឧ.សិ.សុខ នាង ព្រមទាំងកូនចៅ ......... ២០.០០០៛

១៦-ឧ.សិ.ឡូ សៃហៀង ..................................................... ១៧.០០០៛

១៧-ឧ.សិ. ហ៊ុយ ស៊ីម ..................................................... ១៦.៥០០៛

១៨- ឧ.សិ.ហ៊ុល បូលី + សួន កូលាប + អ៊ូ សំណាង .......... ១៦.០០០៛

១៩- ឧ.សិ.ម៉ារី ប្រេច ............................................... ១៦.០០០៛

២០- ឧ.សិ. ហុង គឹម ហ៊ន ............................................. ១៦.០០០៛

២១-ឧ.សិ.សិត ប៊ុនធឿន + ឧ.សិ.លី យ៉េក ព្រមទាំងកូនចៅ ......... ១៥.០០០៛

២២-ធូ បូរិន + ឧ.សិ.ហែម យ៉ានី + មិត្តព្រះធម៌ +ព្រមទាំងកូនចៅ .... ១៥.០០០៛

២៣-ប៊ុន សុវណ្ណ + អ៊ឹម វាសនា ព្រមទាំងកូនចៅ ......... ១៤.០០០៛

២៤- ឧ.សិ.ហេង ស៊ីថា ............................................. ១១.០០០៛

២៥- ឧ.សិ.សុខ ស៊ីវហ៊ុន ............................................ ១១.០០០៛

២៦- ឧ.ស. អ៊ី ហៀន +ឧ.សិ.សោម ផន + ឧ.សិ. មាស សោភា ៥.០០០៛+ ២ $

## តាមរយៈ ឧ.សិ. ស៊ីម យ៉េកហ្វួយ ( កំពង់ចាម )

១-ឧ.សិ. ស៊ីម យ៉េកហ៊្វួយ និង អ្នកម្តាយ វ៉ា គីមស៊ី ...................... ១០ $

២-លោកស្រី ជា ប៉េងហៀក និងស្វាមី ព្រមទាំងបុត្រ ................ ១០ $

៣-ឧ.សិ. សំណាង ស្រីពៅ និងស្វាមី ព្រមទាំងបុត្រ ............... ៨ $

៤- ឧ.សិ. ស៊ុយ សេងឈាង ព្រមទាំងកូនចៅ ............................ ៥ $

៥- ឧ.សិ. តន់ ស៊ីត ព្រមទាំងកូនចៅ ....................................... ៥ $

៦- ឧ.សិ. មួយ ជា ព្រមទាំងកូនចៅ ...................................... ៥ $

៧- ឧ.សិ. ខឹង ធូ និង លោក ហ៊ី ថេង ព្រមទាំងបុត្រ ................... ៥ $

៨- ឧ.ស.កែប ទី ឧ.សិ. ឃួន សារីមព្រមទាំងកូនចៅ ................. ៥ $

៩- ឧ.ស.ជឹង ផេង ឧ.សិ. ឈួ បាក់លី ព្រមទាំងកូនចៅ ................ ៥ $

១០- ឧ.ស. ជា យាវ ឧ.សិ.កេត រឿនព្រមទាំងកូនចៅ .................... ៥ $

១១- ឧ.សិ. ជា យានារី ព្រមទាំងកូនចៅ ...................................... ៥ $

១២-ឧ.ស. សេង ហំ ព្រមទាំងកូនចៅ ........................................ ៥ $

១៣-ឧ.ស.ជឿង ថេង ឧ.សិ.នូ សុខុម ព្រមទាំងកូនចៅ ................... ៥ $

១៤-ឧ.សិ.ញ៉ែម សុគន្ធា និងស្វាមី ព្រមទាំងកូនចៅ ..................... ៥ $

១៥-ឧ.ស.ញ៉ែម ឌុក ឧ.សិ. អ៊ុំច រុន ព្រមទាំងកូនចៅ ............... ៥ $

១៦-ឧ.សិ. ញ៉ែម ឈុនលី ព្រមទាំងកូនចៅ .................................. ៥ $

១៧-ឧ.សិ. ឆាយ ស៊ា ព្រមទាំងកូនចៅ ......................................... ៥ $

១៨-លោក សេក សារឿន ឧ.សិ. ជៃ សុន្ទរី ព្រមទាំងបុត្រ ............... ៤ $

១៩-ឧ.សិ. ឱ ដាលី ព្រមទាំងកូនចៅ ............................ ៣២.៥០០៛

២០-ឧ.សិ. កើត ស្រ៊ុន ព្រមទាំងកូនចៅ ........................... ៣២.៥០០៛

២១-ឧ.ស. ឈាង លីមហួន ឧ.សិ.ឆៃ វ៉នព្រមទាំងកូនចៅ ....... ១៦.៥០០៛

២២-ឧ.ស. ប៊ិន ប៊ុនផេងព្រមទាំងកូនចៅ .......................... ១៦.៥០០៛

២៣- លោក ជឿង សុម៉េង អ្នកស្រី ឡាន ព្រមទាំងបុត្រ ......... ១៦.០០០៛

២៤- ឧ.សិ. ពៅ នាង ព្រមទាំងកូនចៅ ............................. ១៦.០០០៛

២៥- ឧ.សិ. វ៉ា គឹមសុខ ព្រមទាំងកូនចៅ ............................. ១៦.០០០៛

២៦- ឧ.សិ. ហេង ណាវ៉ាត ឧ.សិ.ហង្ស ប៊ុនផល .................. ១៦.០០០៛

២៧- ឧ.សិ. គ្រី ទូច ព្រមទាំងកូនចៅ .................................. ១០.០០០៛

២៨- ឧ.សិ. ណៃ សេង ព្រមទាំងកូនចៅ ........................... ១០.០០០៛

២៩- ឧ.សិ. ស្រ៊ុន សំអឿន ព្រមទាំងកូនចៅ ........................ ១០.០០០៛

៣០- ឧ.ស. ញ៉ែម វណ្ណា និង ភរិយា ............................. ៥.០០០៛

